មហាវិនាច

« ភាគទី២ »

ដោយអ្នកស្រី **អែលិន ជី ង៉ែត៍**

បកប្រែនិងបោះពុម្ព

ចែកចាយដោយ

បេសកកម្មអាត់ភេនទីស្តកម្ពុជា

២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
—***—

ក្រសួងធម្មការ និង សាសនា
លេខ...៩៧៤.....ស.ធ.ស
—***—

ភ្នំពេញ.ថ្ងៃទី ១៦ ខែ ៩ ឆ្នាំ ១៩៩៩

ជូនចំពោះ ក្រសួងធម្មការ និងសាសនា

ដំ ណ ឹ ង ក្រ

លោក លឹម ផេង តំណាងព្រះវិហារ "សេចក្តីអំណរនៃសេចក្តីសុខ" ស្ថាក់ការមានទីតាំងនៅផ្ទះលេខ: ៤៨ ផ្លូវលេខ ៥៤២ សង្កាត់ បឹងកក់ទី ២ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ ។

កម្មវត្ថុ: -ករណីសុំច្បាប់បោះពុម្ពសៀវភៅប្រភេទអប់រំផ្នែកសាសនារបស់ "អង្គការសេចក្តីអំណរនៃសេចក្តីសុខកម្ពុជា" ។

យោង: -សេចក្តីសំរេចរបស់ក្រសួងធម្មការ និងសាសនាលេខ:១៧៣_៩៥កធស, ចុះថ្ងៃ ទី២៤ ខែសីហា ឆ្នាំ ១៩៩៥ ស្តីពីការទទួលស្គាល់ "ក្រុមប្រឹក្សាចំពោះសេចក្តីសុខនៃគណៈនិកាយសេចក្តីអំណរនៃសេចក្តីសុខកម្ពុជា" ។

-លិខិតស្នើសុំបោះពុម្ពសៀវភៅរបស់ "អង្គការសេចក្តីអំណរនៃសេចក្តីសុខកម្ពុជា" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៩។

-ចំណារបញ្ជូនរបស់មន្ទីរធម្មការ និងសាសនារាជធានីភ្នំពេញលេខ: ៤២៦_៩៩ប.ជ, ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជំរាបលោកថា+ ករណីសុំច្បាប់បោះពុម្ពសៀវភៅចំនួនបីប្រភេទ ដូចមានរាយឈ្មោះខាងក្រោមនេះ+

១_ ទេសាភិបាល	ចំនួន	៥០០០ក្បាល
២_ ព្រះនៃសេចក្តីអស្ចារ្យ	ចំនួន	៥០០០ក្បាល
៣_ ការស្តោះទឹកដោយឱ្យប្រសើរឡើង	ចំនួន	១០០០០ក្បាល

ក្រសួងធម្មការ និងសាសនា បានពិនិត្យនិងសំរេចអនុញ្ញាតជូនលោកតាមសំណើសុំ ។ ចំពោះការបោះពុម្ពសៀវភៅនេះត្រូវរក្សាតាមលំនាំច្បាប់ដើមដែលមានសុំរក្សាទុកនៅក្រសួងធម្មការ និងសាសនា ។

អាស្រ័យហេតុនេះសូមលោកមេត្តាជ្រាប និងអនុវត្តន៍ឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃលិខិតនេះ។

ចំលងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងអប់រំ យុវជន និងកីឡា
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
"ដើម្បីគោរពជូនជ្រាប"
-គ្រប់សាលាខេត្ត_ក្រុង
-គ្រប់មន្ទីរធម្មការ និងសាសនា ខេត្ត_ក្រុង
"ដើម្បីមុខការ"
-ឯកសារ_កាលប្បវត្តិ

ស៊ាំ-សាងថ្លឹង

ហេតុដែលត្រូវអានសៀវភៅ

ចំពោះមនុស្សរាប់លាននាក់ ជីវិតហាក់បីដូចជាគ្មានន័យហើយមិនសមហេតុសមផលអ្វីសោះ។ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ហើយសូម្បីតែទស្សនវិទ្យា និងសាសនវិទ្យាផងដែរ បានសម្តែងពីមនុស្សជាតិថាគ្រាន់តែជាសត្វដែលកើតមកដោយចៃដន្យប៉ុណ្ណោះ។ ប៉ុន្តែទោះជាដឹងឬមិនដឹងខ្លួនក៏ដោយ បុរស និងស្ត្រីយើញថាពិបាកទទួលយកជីវិតដ៏ឥតន័យនេះណាស់។ អំពើហិង្សា បាតុកម្ម ការបះបោរ ការពិសោធជាមួយគ្រឿងញៀន ទាំងអស់នេះ ក្នុងករណីភាគច្រើន គឺជាទង្វើដ៏ឥតសមហេតុសមផលរបស់មនុស្ស ដែលតស៊ូនឹងភាពបាត់បង់ដ៏ហួសនិស្ស័យ។ គេស្រែកឡើងចេញពីភាពឯកោ និងភាពអស់សង្ឃឹម ដូចជាក្មេងកំព្រាថា៖ «តើខ្ញុំជានរណា? តើនរណាជាឪពុកម្តាយរបស់ខ្ញុំ? ហេតុអ្វីបានជាលោកបំបះបង់ខ្ញុំចោល? តើធ្វើដូចម្តេចទៅទើបរកលោកទាំងពីរឃើញ?»

មនុស្សភាគច្រើនងាកមកឯវិទ្យាសាស្ត្រដើម្បីរកចម្លើយ ដោយយកវិទ្យុតេលីស្កុបដ៏ធំ ឆ្លុះមើលហើយស្តាប់ដង្ហើមហ្វូងផ្កាយទាំងឡាយ ទាំងមានចិត្តប្រាថ្នាចង់ដឹងថា តើមាននរណានៅទីនោះដែលស្គាល់ខ្ញុំឬទេ? តើមាននរណាខ្វល់ខ្វាយចំពោះខ្ញុំឬទេ? ប៉ុន្តែវិទ្យាសាស្ត្រគ្មានចម្លើយសោះ។ វិទ្យាសាស្ត្រគឺបានរៀបចំឡើងដើម្បីសួរសំណួរដូចនេះ៖ តើអាតូមបានផ្សំផ្គុំឡើងដោយរបៀបណា? តើត្រូវញែកវាដោយរបៀបណា? តើខួរក្បាលរបស់យើងដើរបៀបណា? តើពិភពសកលបានផ្សំផ្គុំគ្នាដូចម្តេច?

វិទ្យាសាស្ត្រមិនអាចប្រាប់យើងថា ហេតុអ្វីបានជាមានអាតូម ហេតុអ្វីបានជាមានមនុស្សជាតិ និងហេតុអ្វីបានជាមានពិភពសកលទាល់តែសោះ។ ហើយក៏មិនអាចឆ្លើយនឹងសំណួរដ៏សំខាន់ៗ ដែលអ្នកត្រិះរិះចោទឡើងដែរថា៖

ប្រសិនជាមានន័យ និងយុត្តិធម៌ក្នុងពិភពសកល ហេតុអ្វីបានជាជនឥតទោសទទួលរងទុក្ខជាមួយនឹងជនមានទោសដូច្នោះ?

ក្រោយពីបានស្លាប់ទៅតើនៅមានជីវិតឬទេ?តើបុគ្គលិកលក្ខណៈរបស់

មនុស្ស នៅតែរស់តទៅទៀតឬយ៉ាងណា?

តើវិហារគ្រីស្ទានសព្វថ្ងៃនេះ ពិតជានិយាយអំពីព្រះមែនឬ? តើអ្វីទៅជាសេចក្តីពិត?

តើអ្វីទៅជាអនាគតនៃពិភពលោក? តើវានឹងបញ្ចប់ដោយតម្លៃរបស់ក្មេងដែលត្រដរដកដង្ហើមជាចុងក្រោយក្នុងអាកាសធាតុដ៏កខ្វក់ ឬដោយការផ្ទុះនៃគ្រាប់បរមាណូ? ឬមួយមនុស្សដែលមិនដែលបង្ហាញសមត្ថភាពទប់ទល់នឹងអាត្មានិយមរបស់ខ្លួន ក្នុងប្រវត្តិសាស្ត្រដែលបានកត់ត្រាទុកមក ស្រាប់តែមានជ័យជម្នះក្នុងការបំបាត់ភាពអាក្រក់ សង្គ្រាម ភាពទ័លក្រ ហើយនិងសេចក្តីស្លាប់?

សៀវភៅនេះ ផ្តល់ចម្លើយដល់សំណួរទាំងឡាយនោះ ហើយអស់លោកអ្នកនឹងពេញចិត្តចំពោះចម្លើយទាំងនោះជាមិនខាន។ ជីវិតគឺមានន័យ! យើងមិនមែននៅតែឯងទេក្នុងពិភពលោកនេះ។ មានគេដែលនៅទីនោះ ដែលខ្វល់ខ្វាយចំពោះលោកអ្នក! ប្រាកដណាស់ ជនម្នាក់ដែលបានប្រឡូកខ្លួនក្នុងប្រវត្តិសាស្ត្ររបស់មនុស្ស ដែលបានចូលរួមជាមួយពូជរបស់យើង ប្រយោជន៍ឱ្យយើងអាចចូលទៅឯទ្រង់ ហើយទ្រង់មកឯយើង ជនម្នាក់ដែលមានព្រះហស្តដ៏ខ្លាំងក្លា ធ្លាប់រស់នៅក្នុងពិភពនេះ ហើយដែលនឹងនាំលោកីយ៍មកឯសន្តិភាពវិញ ក្នុងពេលបន្តិចទៀត។

ប៉ុន្តែអស់រយៈពេលជាយូរឆ្នាំមកហើយ មានបុគ្គលមួយអង្គនៅស្ថានសូគ៌ដែលពូកែទាក់ទាញគេបានតាំងចិត្តរឹបអូសយកពិភពលោកយើង ហើយបង្ខូចផែនការរបស់ព្រះ សម្រាប់សុភមង្គលនៃក្រុមគ្រួសារនៅនាលោកីយ៍របស់ទ្រង់។ និយាយជាភាសាដៃ លតំណាងដោយរូបភាពវិញ មានមនុស្សរាប់សែននាក់បានហៅថាភាសាដែលបណ្តាលមកពីខាងលើ អ្នកនិពន្ធសៀវភៅនេះ បើកវាំងនន សម្តែងនូវភាពស្រពេចស្រពិលឱ្យឃើញច្បាស់ ហើយបង្ហាញដោយឥតញញើ តនូវឧបាយកលនៃបុគ្គលដ៏ខ្លាំងពូកែ ហើយដ៏មើលមិនឃើញនេះដែលបានឈោងដៃស្រវាចាប់អំណាចគ្រប់គ្រងនៃពិភពលោកយើង។ មើលទៅទ ស្ថានីយភាពនៃមនុស្សជាតិវិញ ពួកក្បត្រដែលកាន់សាសនាដទៃ និង

វិ ទ្យាស្ថានសាសនាទាំងឡាយ ត្រូវបានលេចឡើងថាជាអ្នកមានកំហុសក្នុង ការធ្វើគម្រោងការក្បត់។

មានតែក្នុងសម័យដែលមានសេរីភាពខាងសាសនាទេ ទើបសៀវភៅ នេះអាចបោះពុម្ព ហើយនិងផ្សព្វផ្សាយជាសកលបាន ពីព្រោះសៀវភៅនេះ មានការប៉ះទង្គិចយ៉ាងខ្លាំងដល់អ្នកកាន់អំណាចដ៏ខ្លាំងពូកែខ្លះៗ ក្នុងជំនាន់ យើងនេះ។វាបង្ហាញថាហេតុអ្វីបានជាត្រូវការកំណែទម្រង់ ហើយហេតុអ្វីបាន ជាកំណែទម្រង់ត្រូវបានឈប់ទៅមុខ បង្ហាញអំពីរឿងកម្សត់នៃក្រុមជំនុំដែល ងាកចេញពីជំនឿ អំពីសម្ព័ន្ធមិត្តដែលគេធ្វើទុក្ខទោស អំពីការរួបរួមរវាងព្រះ វិហារនិងរដ្ឋដែលកំពុងលេចឡើង ហើយនឹងសម្តែងឆាកដ៏អាប់រស្មី មុននឹង មហាវិវាទរវាងសេចក្តីអាក្រក់និងល្អត្រូវបញ្ចប់។ការប៉ះទង្គិចនេះនឹងប៉ះពាល់ ដល់មនុស្សគ្រប់រូប។

ទីនេះ អ្នកនិពន្ធសរសេរអំពីអ្វីដែលមិនទាន់កើតឡើងនៅជំនាន់គាត់។ លោកស្រីមានប្រសាសន៍ដោយភាពស្មោះត្រង់ ដែលនឹងធ្វើឱ្យចិត្តរំជើបរំជួល ហើយភ្ញាក់ផ្អើល។ រឿងរ៉ាវនៃការវិវាទគឺធំដុំហើយមានសារៈសំខាន់ណាស់ បានជាខាននឹងបញ្ចេញពាក្យពេចន៍ព្រមាន និងការបំភ្លឺទាំងនេះមិនបាន។

ឥតមានអ្នកអានណាដែលបើកសន្លឹកសៀវភៅទាំងឡាយនេះ ហើយ ដាក់ចុះវិញដោយពុំបានឆ្ងល់ថាជាការហួសពីចៃដន្យទៅទៀត ដែលនាំឱ្យគេ រកឃើញសៀវភៅនេះដើម្បីអានឡើយ។

អ្នកបោះពុម្ព

លំនាំដើម

មុនអំពើបាបកើតមានឡើង លោកអ័ដាមបានប្រស្រ័យទាក់ទងទៅវិញទៅមកជាមួយព្រះអាទិកររបស់លោកដោយរីករាយប៉ុន្តែចាប់តាំងពីមនុស្សញែកខ្លួនចេញពីព្រះដោយសារការប្រព្រឹត្តល្មើសមក ពូជមនុស្សក៏ត្រូវបានកាត់ផ្តាច់ពីឯកសិទ្ធដ៏ខ្ពង់ខ្ពស់នេះទៅ។តែដោយសារគម្រោងការប្រោសលោះក៏មានផ្លូវមួយបើកឡើង ប្រយោជន៍ឲ្យពូកមនុស្សរស់នៅផែនដី បានរក្សាការទាក់ទងជាមួយនឹងឋានសួគ៌។ ព្រះបានទាក់ទងជាមួយមនុស្សដោយព្រះវិញ្ញាណរបស់ទ្រង់ ហើយពន្លឺមកពីឋានសួគ៌ក៏ត្រូវបានចាំងជះមកដល់ផែនដីដោយការបើកសម្តែងដល់អ្នកបម្រើដែលទ្រង់ជ្រើសរើស។ «មនុស្សបរិសុទ្ធរបស់ព្រះ... បានទាយដោយសារព្រះវិញ្ញាណបរិសុទ្ធបណ្តាល។» ពេត្រុសទី២ ១:២១។

ក្នុងអំឡុង២៥០០ឆ្នាំនៃប្រវត្តិសាស្ត្រមនុស្ស គ្មានការបើកសម្តែងអ្វីដែលបានកត់ទុកជាលាយលក្ខណ៍អក្សរទេ។អ្នកដែលបានរៀនសូត្រអំពីព្រះបានចែកចាយចំណេះរបស់ខ្លួនដល់អ្នកដទៃហើយបន្តពីតំណមួយទៅតំណមួយទៀត គឺពីឪពុកទៅកូនជាលំដាប់តមក។ ការរៀបចំសរសេរជាលាយលក្ខណ៍អក្សរបានចាប់ផ្តើមនៅជំនាន់ហោរាម៉ូសេ។ការបើកសម្តែងដែលព្រះបានបណ្តាលឱ្យសរសេរក៏ត្រូវបានចងក្រងកើតជាព្រះគម្ពីរ។ កិច្ចការនេះបានបន្តក្នុងអំឡុងពេលដ៏យូរអស់រយៈពេល១៦០០ឆ្នាំ ចាប់ពីហោរាម៉ូសេដែលជាប្រវត្តិវិទូខាងការបង្កបង្កើតនិងក្រឹត្យវិន័យ ទៅដល់សាវ័កយ៉ូហានដែលជាអ្នកកត់ចុះសេចក្តីពិតនៃដំណឹងល្អដ៏ពោរពេញទៅដោយឧត្តមគតិខ្ពង់ខ្ពស់បំផុត។

ព្រះគម្ពីរចង្អុលទៅព្រះថាជាអ្នកនិពន្ធតែបានសរសេរដោយដៃមនុស្សវិញ ហើយការដែលកណ្ឌនីមួយៗនៃព្រះគម្ពីរ មានរបៀបសរសេរខុសប្លែកពីគ្នានោះ គឺជាការបង្ហាញចរិតលក្ខណៈនៃអ្នកសរសេរទាំងឡាយ។ សេចក្តីពិតដែលបានបើកសម្តែង «គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឱ្យតែង» (ធីម៉ូថេទី២ ៣:១៦) ប៉ុន្តែ មានសំនៀងជាពាក្យពេចន៍របស់មនុស្ស។ ដោយ

សារព្រះវិញ្ញាណព្រះដ៏មានព្រះជន្មគ្មានទីបំផុត បានជះពន្លឺដល់ចិត្តគំនិតនៃអ្នកបម្រើរបស់ទ្រង់។ ទ្រង់បានប្រទានឱ្យគេយល់សប្តិ ហើយនិងមានទស្សនិមិត្ត និមិត្តរូប រូបប្រៀបធៀប ហើយអ្នកដែលបានទទួលសេចក្តីពិតនោះ ក៏កត់ចុះនូវអ្វីដែលបានគិតជាភាសាមនុស្ស។

កណ្ឌទាំងឡាយនៃព្រះគម្ពីរ បានសរសេរក្នុងសម័យផ្សេងគ្នា ដោយមនុស្សដែលមានឋានៈនិងមុខរបរ ហើយនិងអំណោយទានខាងបញ្ញា និងវិញ្ញាណខុសៗគ្នា ម្ល៉ោះហើយបានជាមានបែបបទប្លែកស្រឡះពីគ្នា ព្រមទាំងមានភាពខុសគ្នាក្នុងនិស្ស័យនៃការបើកសម្តែងរឿងអ្វីមួយផងដែរ។ អ្នកនិពន្ធម្នាក់ៗប្រើទម្រង់នៃការសរសេរខុសគ្នា ជាញឹកញយ អ្នកនិពន្ធម្នាក់សម្តែងសេចក្តីពិតតែមួយនោះច្បាស់ជាងម្នាក់ទៀត។ ហើយដោយសារអ្នកនិពន្ធទាំងឡាយបើកបង្ហាញសេចក្តីអ្វីមួយ ក្រោមទិដ្ឋភាព និងទំនាក់ទំនងទីទៃពីគ្នានោះ អ្នកអានត្រូវៗ មិនប្រយ័ត្នប្រយែង ឬប្រកាន់ទៅខាងណាមួយ រមែងឃើញមានការមិនស្របគ្នាឬផ្ទុយគ្នាផង តែចំពោះសិស្សមានគំនិត មានចិត្តគោរពមានវិចារណញ្ញាណភ្លឺស្វាងវិញ រមែងយល់អំពីបុរសគល់ដែលធ្វើឱ្យមានការស្របគ្នា។

សេចក្តីពិតលេចឡើងក្នុងទិដ្ឋភាពផ្សេងៗពីគ្នាតាមតែអ្នកនិពន្ធម្នាក់ៗសរសេរ។ អ្នកសរសេរម្នាក់ ដែលមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើរឿងរ៉ាវអ្វីមួយជាងម្នាក់ទៀតនោះ រមែងគោងចំណុចទាំងនោះ ដែលសមស្របទៅតាមបទពិសោធន៍របស់ខ្លួន ឬទៅតាមការយល់ដឹងរបស់ខ្លួន ម្នាក់ទៀតចាប់អារម្មណ៍ទៅលើរឿងរ៉ាវផ្សេងៗវិញ ហើយម្នាក់ៗ ក្រោមការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ សម្តែងនូវអ្វីដែលដក់ក្នុងចិត្តរបស់គេរៀងៗខ្លួន ក្នុងសំណេរនីមួយៗ ទិដ្ឋភាពនៃសេចក្តីពិតឃើញប្លែកពីគ្នាមែន ប៉ុន្តែរួមសេចក្តីទាំងអស់ទៅ ឃើញថាមានការស្របគ្នាដ៏ឥតខ្ចោះ។ ហើយសេចក្តីពិតដែលបានបើកសម្តែងនោះ រួបរួមជាតួដ៏ឥតខ្ចោះមួយ តម្រូវសម្រាប់ចំណង់របស់មនុស្សគ្រប់កាល:ទេស: និងគ្រប់បទពិសោធន៍នៃជីវិត។

ព្រះទ្រង់សព្វព្រះទ័យនឹងប្រស្រ័យទាក់ទងសេចក្តីពិតរបស់ទ្រង់ដល់

ពិភពលោកដោយមានមនុស្ស និងប្រទានសមត្ថភាពដល់គេដើម្បីប្រកបកិច្ច
ការនេះ។ ទ្រង់ណែនាំចិត្តគេឱ្យរើសយកអ្វីដែលត្រូវសរសេរ ឬនិយាយ។ កំណប់
ដែលត្រូវបានប្រទានដល់មនុស្សជាតិ គឺមកពីហានសួគ៌។ ទីបន្ទាល់គឺចែង
ប្រាប់តាមរបៀបសរសេរនៃភាសាមនុស្សដ៏មិនគ្រប់លក្ខណ៍ តែជាទីបន្ទាល់
របស់ព្រះ ហើយអ្នកគោរពប្រតិបត្តិតាមដែលជឿដល់ព្រះ គេឃើញមានសិរី
ល្អនៃព្រះចេស្តាដែលពោរពេញទៅដោយព្រះគុណនិងសេចក្តីពិតក្នុងសំណេរ
នោះ។

ក្នុងព្រះបន្ទូលរបស់ព្រះ ទ្រង់បានបង្អុរឱ្យមនុស្សនូវតម្រិះប្រាជ្ញាដែល
អាចនាំឱ្យគេមានសេចក្តីសង្គ្រោះបាន។ ត្រូវទទួលស្គាល់ថាព្រះគម្ពីរបរិសុទ្ធ
មានអំណាច ហើយជាការបើកសម្តែងដ៏មិនចេះខុស អំពីព្រះហឫទ័យរបស់
ទ្រង់។ បទគម្ពីរទាំងឡាយជាខ្នាតនៃចរិតលក្ខណៈ ជាអ្នកបើកសម្តែងគោល
លទ្ធិ ជាការសាកល្បងនៃការពិសោធ។ «គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់
បានបញ្ចេញព្រះវិញ្ញាណបណ្តាលឱ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការ
បង្រៀន ការរំឭកឱ្យដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្តី
សុចរិត ដើម្បីឱ្យអ្នកសំណព្វរបស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំង
ចំណេះសម្រាប់នឹងធ្វើការល្អគ្រប់មុខ។» ធីម៉ូថេទី២ ៣:១៦,១៧។

ការដែលព្រះបានបើកសម្តែងព្រះហឫទ័យរបស់ទ្រង់ ដល់មនុស្ស
តាមរយៈព្រះបន្ទូលរបស់ទ្រង់គឺពុំមែនមានន័យថា យើងមិនត្រូវការវត្តមាន
របស់ទ្រង់ ឬការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់នោះទេ។ ផ្ទុយទៅវិញ
ព្រះអង្គសង្គ្រោះបានសន្យាថានឹងប្រទានឱ្យព្រះវិញ្ញាណ ដើម្បីចែកចាយព្រះ
បន្ទូលដល់អ្នកបម្រើរបស់ទ្រង់ ហើយដើម្បីបំភ្លឺនិងអនុវត្តសេចក្តីបង្រៀន
ទាំងឡាយនៃព្រះបន្ទូល។ ហើយដោយព្រោះតែព្រះវិញ្ញាណនោះជាអ្នកបណ្តាល
ឱ្យសរសេរព្រះគម្ពីរ សេចក្តីបង្រៀននៃព្រះវិញ្ញាណ គឺមិនអាចផ្ទុយនឹងព្រះ
បន្ទូលបានឡើយ។

ព្រះវិញ្ញាណពុំបានប្រទានមក ឬក៏នឹងត្រូវប្រទានមក ដើម្បីលប់លើ
ព្រះគម្ពីរឡើយ ពីព្រោះបទគម្ពីរទាំងឡាយចែងយ៉ាងច្បាស់ថា ព្រះបន្ទូលរបស់

ព្រះគឺជាខ្នាតដែលអស់ទាំងសេចក្តីបង្រៀន និងការពិសោធនឹងត្រូវបានសាកល្បង។ សាវ័កយ៉ូហានមានប្រសាសន៍ថា៖ «កុំឱ្យជឿគ្រប់ទាំងវិញ្ញាណឡើយ ចូរល្បងវិញ្ញាណទាំងអស់វិញ ដើម្បីឱ្យបានដឹងថាមកពីព្រះ ឬមិនមែន ដ្បិតមានហោរាក្លែងក្លាយជាច្រើនកើតមកក្នុងលោកីយ៍នេះហើយ។» យ៉ូហានទី១ ៤:១។ ហោរាអេសាយថ្លែងថា៖ «ចូរទៅបើកគម្ពីរបញ្ញត្តិ និងសេចក្តីបន្ទាល់មើល បើគេនិយាយមិនត្រូវនឹងព្រះបន្ទូលនោះ នោះគ្មានពន្លឺរះឡើងនៅក្នុងខ្លួនទេ។» អេសាយ ៨:២០។

កំហុសនៃក្រុមមួយដែលអះអាងថាខ្លួនមានការត្រាស់ដឹង ហើយលែងត្រូវការអ្វីទៀតពីការដឹកនាំនៃព្រះបន្ទូលរបស់ព្រះនោះ បានថ្កោលទោសយ៉ាងខ្លាំងដល់កិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ។ ពួកគេត្រូវបានដឹកនាំដោយអារម្មណ៍ដែលគេស្មានថាជាព្រះសូរសៀងរបស់ព្រះដែលបន្លឺឡើងក្នុងមនុស្ស។ ប៉ុន្តែវិញ្ញាណដែលគ្រប់គ្រងគេនោះមិនមែនជាព្រះវិញ្ញាណរបស់ព្រះទេ។ ការធ្វើតាមអារម្មណ៍ដើម្បីមិនអើពើនឹងបទគម្ពីរ បានគ្រាន់តែនាំឱ្យមានការភាន់ច្រឡំ ការបោកបញ្ឆោត និងការហិនវិនាសប៉ុណ្ណោះ ពោលគឺបានគ្រាន់តែជាជំនួយដល់គម្រោងការរបស់អារក្ស។ ដោយព្រោះកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ មានសារៈសំខាន់យ៉ាងខ្លាំងដល់ក្រុមជំនុំរបស់ព្រះគ្រីស្ទសាតាំងក៏បង្កើតឧបាយកលតាមរយៈកំហុសខុសឆ្គងនៃពួកប្រកាន់ទិដ្ឋិចុងបំផុត និងពួកជឿងប់ងុល ដើម្បីបញ្ចេញសេចក្តីស្អប់ខ្ពើមដល់កិច្ចការនៃព្រះវិញ្ញាណ ហើយបណ្តាលឱ្យរាស្ត្ររបស់ព្រះភ្លេចប្រភពកម្លាំងនេះ ដែលព្រះអម្ចាស់របស់យើងបានប្រទានមក។

ក្នុងការសម្របទៅតាមព្រះបន្ទូលរបស់ព្រះ ព្រះវិញ្ញាណរបស់ទ្រង់នឹងត្រូវបន្តកិច្ចការពេញអំឡុងពេលដែលទុកឱ្យផ្សាយដំណឹងល្អ។ ក្នុងសម័យដែលព្រះបណ្តាលហោរាឱ្យសរសេរបទគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ព្រះវិញ្ញាណបរិសុទ្ធពុំបានឈប់ប្រទានពន្លឺដល់ចិត្តគំនិតនៃបុគ្គលម្នាក់ៗទេ ក្រៅពីការបើកសម្តែងក្នុងព្រះគម្ពីរបរិសុទ្ធ។ ឯព្រះគម្ពីរវិញសោត ថ្លែងប្រាប់អំពីរបៀបមនុស្សឮការព្រមាន ទទួលការកែតម្រូវ ការឱ្យឱវាទ និងការណែនាំតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលគ្មានអ្វីទាក់ទងនឹងការប្រទានបទគម្ពីរសោះ

ឡើយ។ ហើយក៏មានឮពីហោរាជាច្រើនក្នុងសម័យនីមួយៗ តែពាក្យពេចន៍
របស់គេពុំបានកត់ទុកទេ។ ក៏ដូចគ្នាដែរ បន្ទាប់ពីការបិទលែងឱ្យកត់បញ្ចូល
បន្ថែមទៀតក្នុងព្រះគម្ពីរនោះ ព្រះវិញ្ញាណបរិសុទ្ធក៏នៅតែបន្តកិច្ចការរបស់
ទ្រង់ ដើម្បីបំភ្លឺ ព្រមាន និងកំសាន្តចិត្តកូនចៅរបស់ព្រះដដែល។

ព្រះយេស៊ូវបានសន្យាដល់សាវ័ករបស់ទ្រង់ថា៖ «ព្រះដ៏ជាជំនួយ គឺជា
ព្រះវិញ្ញាណបរិសុទ្ធដែលព្រះវរបិតានឹងចាត់មក ដោយនូវឈ្មោះខ្ញុំ ទ្រង់នឹង
បង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្តីទាំងអស់ ក៏នឹងរំលឹកពីគ្រប់ទាំងសេចក្តីដែល
ខ្ញុំបានប្រាប់អ្នករាល់គ្នាផងដែរ។» «កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណ
នៃសេចក្តីពិតបានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំង សេចក្តី
ពិត... ហើយនិងសម្តែងឱ្យអ្នករាល់គ្នាដឹងការដែលត្រូវមក។» យ៉ូហាន ១៤:២៦;
១៦:១៣។ បទគម្ពីរបង្រៀនយ៉ាងច្បាស់ថា សេចក្តីសន្យាទាំងនេះ គឺពុំមែន
សម្រាប់តែជំនាន់ពួកសាវ័កប៉ុណ្ណោះទេ តែសម្រាប់ក្រុមជំនុំរបស់ព្រះគ្រីស្ទ
ក្នុងគ្រប់សម័យផងដែរ។ ព្រះអង្គសង្គ្រោះធានាដល់អ្នកដើរតាមទ្រង់ថា «ខ្ញុំ
ក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។» ម៉ាថាយ
២៨:២០។ សាវ័កប៉ុលថ្លែងថា អំណោយទាន និងការសម្តែងទាំងឡាយនៃ
ព្រះវិញ្ញាណ គឺបានកកើតឡើងក្នុងក្រុមជំនុំ «ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធ
បានគ្រប់លក្ខណ៍ឡើង សម្រាប់ធ្វើការជំនួយ ហើយនិងស្អាងរូបកាយព្រះគ្រីស្ទ
ឡើង ទាល់តែយើងរាល់គ្នាបានរួបរួមខាងឯសេចក្តីជំនឿរួចស្រេច ហើយបាន
ស្គាល់ព្រះរាជបុត្រានៃព្រះ ដូចគ្នាទាំងអស់គឺដល់បានពេញជាមនុស្ស ហើយ
ដល់ខ្នាតកម្ពស់នៃសេចក្តីពោរពេញផងព្រះគ្រីស្ទ។» អេភេសូរ ៤:១២,១៣។

សាវ័កប៉ុល ក៏បានអធិស្ឋានសម្រាប់ពួកអ្នកជឿទាំងឡាយនៅស្រុក
អេភេសូរ «ដើម្បីនឹងសូមឱ្យព្រះនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង
គឺជាព្រះវរបិតាដ៏មានសិរីល្អ បានប្រទានឱ្អអ្នករាល់គ្នាបាន*ព្រះវិញ្ញាណ
ដែលប្រោសឱ្យមានប្រាជ្ញា ហើយក៏បើកសម្តែង* ឱ្យដឹងពីដំណើរស្គាល់ទ្រង់
ដើម្បីឱ្យភ្នែកចិត្តរបស់អ្នករាល់គ្នា បានភ្លឺឡើង ប្រយោជន៍ឱ្យបានដឹងថា
ដែលទ្រង់ហៅអ្នករាល់គ្នា នោះមានសេចក្តីសង្ឃឹមជាយ៉ាងណា ហើយថា...

ព្រះចេស្តាដ៏ខ្លាំងលើសលន់ របស់ទ្រង់ដល់យើងរាល់គ្នាដែលជឿជាយ៉ាងណាដែរ តាមដែលកម្លាំងទ្រង់ដ៏មានឫទ្ធិបានពូកែនឹងធ្វើ។» អេភេសូរ ១:១៧-១៩។ កិច្ចការនៃព្រះវិញ្ញាណពីហានសូគ៌ ក្នុងការធ្វើឱ្យការយល់ដឹងបានភ្លឺច្បាស់ឡើង និងក្នុងការបើកចិត្តគំនិតឱ្យឈ្វេងយល់ខ្លឹមសារដ៏ជ្រាលជ្រៅនៃព្រះបន្ទូលបរិសុទ្ធរបស់ព្រះនោះ គឺជាព្រះពរដែលសាវ័កប៉ុលបានស្វះស្វែងរកសម្រាប់ក្រុមជំនុំនៃស្រុកអេភេសូរ។

បន្ទាប់ពីការសម្តែងយ៉ាងអស្ចារ្យរបស់ព្រះវិញ្ញាណបរិសុទ្ធ នៅថ្ងៃបុណ្យទីហាសិបមក សាវ័កពេត្រុសបានសូមឱ្យប្រជាជនលន់តួបាបខ្លួន ហើយទទួលបុណ្យជ្រមុជទឹកក្នុងព្រះនាមព្រះគ្រីស្ទ ប្រយោជន៍ឱ្យគេបានលើកលែងពីបាបកម្មរបស់ខ្លួនរួចគាត់មានប្រសាសន៍ថា៖«អ្នករាល់គ្នានឹងទទួលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ។ដ្បិតសេចក្តីសន្យានោះគឺសន្យាដល់អ្នករាល់គ្នា និងកូនចៅអ្នករាល់គ្នា ព្រមទាំងអស់អ្នកដែលនៅឆ្ងាយដែរ គឺដល់អស់អ្នកណាដែលព្រះអម្ចាស់ជាព្រះនៃយើងរាល់គ្នា ទ្រង់នឹងហៅ។» កិច្ចការ ២:៣៨, ៣៩។

នៅថ្ងៃដ៏អស្ចារ្យរបស់ព្រះ ទ្រង់បានសន្យាតាមរយៈហោរាយ៉ូអែល ថានឹងសម្តែងព្រះវិញ្ញាណរបស់ទ្រង់ដ៏វិសេសវិសាលមួយ។ យ៉ូអែល ២:២៨។ ទំនាយនេះ បានសម្រេចខ្លះៗក្នុងការបង្អុរព្រះវិញ្ញាណនៅថ្ងៃបុណ្យទីហាសិប តែនឹងបានសម្រេចសព្វគ្រប់វិញ ក្នុងការសម្តែងព្រះគុណដ៏ពិសិដ្ឋដែលនឹងធ្វើឱ្យការផ្សាយដំណឹងល្អបានសម្រេចជាស្តាពរ។

មហាវិវាទរវាងសេចក្តីល្អនិងអាក្រក់ នឹងបានកាន់តែខ្លាំងឡើង លុះដល់គ្រាចុងបញ្ចប់។ ក្នុងគ្រប់សម័យ សាតាំងបញ្ចេញកំហឹងរបស់វាទាស់នឹងក្រុមជំនុំរបស់ព្រះគ្រីស្ទ ឯព្រះ ទ្រង់បានប្រទានព្រះគុណនិងព្រះវិញ្ញាណរបស់ទ្រង់ដល់មនុស្ស ដើម្បីពង្រឹងគេឱ្យបានឈរមាំមួនតទល់នឹងអំណាចរបស់អារក្ស។ នៅពេលពួកសាវ័ករបស់ព្រះគ្រីស្ទ ត្រូវយកដំណឹងល្អរបស់ទ្រង់ទៅផ្សាយដល់ពិភពលោក ហើយត្រូវកត់ទុកសម្រាប់គ្រប់ទាំងសម័យតទៅអនាគតនោះ គឺពួកគេបានទទួលការត្រាស់ដឹងមកពីព្រះវិញ្ញាណ។ ប៉ុន្តែនៅពេលដែលក្រុម

ជំនុំឈានទៅកាន់ការរំដោះជាចុងក្រោយសាតាំងនឹងខិតខំធ្វើការដោយអំណាចយ៉ាងខ្លាំងដែរ។ វាចុះមក «ទាំងមានសេចក្តីឃោរឃៅជាខ្លាំង ដោយវាដឹងថាពេលវេលាវាខ្លីណាស់ហើយ។»វិវរណៈ ១២:១២។ វានឹងធ្វើការ«ដោយនូវគ្រប់ទាំងឫទ្ធិ ទីសម្គាល់ និងការអស្ចារ្យដ៏កំភូត។» ថែស្សាឡូនីចទី២ ២:៩។ អស់រយៈ ៦០០០ឆ្នាំហើយ មេគំនិតដែលធ្លាប់ជាអ្នកកំពូលក្នុងចំណោមទេវតារបស់ព្រះបានតាំងចិត្តយ៉ាងមុឺងម៉ាត់ ដើម្បីធ្វើការបោកបញ្ឆោត និងបំផ្លិចបំផ្លាញ។ ហើយអស់ទាំងជំនាញការ និងការប៉ិនប្រសប់ខាងសេចក្តីហិនវិនាស ដែលវាបានរៀនយ៉ាងជ្រៅជ្រះ អស់ទាំងសេចក្តីឃោរឃៅដែលដុះដាលឡើង ក្នុងកាលដែលវាតស៊ូទាំងវេទនាក្នុងសម័យទាំងប៉ុន្មាននេះ នឹងត្រូវបានដាក់មកលើរាស្ត្ររបស់ព្រះក្នុងការប្រយុទ្ធចុងក្រោយ។ ហើយក្នុងពេលដ៏គ្រោះថ្នាក់នេះ អ្នកដើរតាមព្រះគ្រីស្ទ ត្រូវនាំយកសេចក្តីព្រមានអំពីការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ដល់ពិភពលោក ហើយមនុស្សម្នាក់ៗនឹងត្រូវរៀបចំខ្លួនដើម្បីឈរនៅចំពោះទ្រង់ ទាំង «ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន» នៅពេលទ្រង់យាងមក។ ពេត្រុសទី២ ៣:១៤។ នៅពេលនេះក្រុមជំនុំត្រូវការព្រះគុណនឹងព្រះចេស្តាពីហានសូគិដ៏វិសេសវិសាល ដូចនៅជំនាន់ពួកសាវ័កដែរ។

តាមការបំភ្លឺនៃព្រះវិញ្ញាណបរិសុទ្ធ ទស្សនីយភាពនៃការប៉ះទង្គិចដែលបន្តដ៏យូរយារ រវាងអំពើល្អ និងអាក្រក់ ត្រូវបានបើកសម្តែងដល់អ្នកសរសេរសន្លឹកសៀវភៅទាំងនេះ។ យូរៗម្តង ព្រះបានអនុញ្ញាតឱ្យខ្ញុំឃើញកិច្ចការក្នុងសម័យនីមួយៗ អំពីមហាវិវាទរវាងព្រះគ្រីស្ទ ដែលជាស្តេចនៃជីវិត ជាអ្នកផ្តល់សេចក្តីសង្គ្រោះដល់យើង ហើយនិងសាតាំងដែលជាស្តេចនៃសេចក្តីអាក្រក់ ជាអ្នកបង្កឱ្យមានបាបជាអ្នកប្រព្រឹត្តល្មើសទីមួយនៃក្រឹត្យវិន័យបរិសុទ្ធរបស់ព្រះ។ ភាពជាខ្មាំងរបស់សាតាំងទាស់នឹងព្រះគ្រីស្ទត្រូវបានសម្តែងទាស់នឹងអ្នកដើរតាមទ្រង់។ សេចក្តីស្អប់ខ្ពើមដល់គោលការនៃក្រឹត្យវិន័យរបស់ព្រះដដែលនេះ នយោបាយបោកបញ្ឆោតដដែល ដែលបំភ្លៃកំហុសឱ្យមើលទៅដូចជាសេចក្តីពិត ដែលច្បាប់របស់មនុស្សត្រូវបានប្តូរជំនួសក្រឹត្យវិន័យរបស់

ព្រះ ហើយដែលមនុស្សត្រូវបាននាំឱ្យថ្វាយបង្គំដល់សត្វ ជាជាងព្រះដ៏ជាអ្នក
បង្កបង្កើត គឺអាចរកដានឃើញក្នុងអស់ទាំងប្រវត្តិសាស្ត្រពីអតីតកាល។ ការ
ខិតខំរបស់សាតាំងដើម្បីបង្ខូចចរិតលក្ខណៈរបស់ព្រះ និងដើម្បីបណ្តាល
មនុស្សឱ្យឱបក្រសោបនូវការយល់ខុសអំពីព្រះអាទិករ ធ្វើឱ្យគេមើលទៅទ្រង់
ទាំងខ្លាចហើយស្អប់ ជាជាងដោយសេចក្តីស្រឡាញ់ ការព្យាយាមរបស់វា
ដើម្បីបំបាត់ក្រឹត្យវិន័យរបស់ព្រះ នាំឱ្យមនុស្សគិតថាខ្លួនរួចពីសេចក្តីដែលត្រូវ
ធ្វើ ហើយការធ្វើទុក្ខទោសដល់អ្នកដែលហ៊ានទទឹងនឹងការបញ្ឆោតរបស់វាគឺ
បានមានកើតឡើងក្នុងគ្រប់សម័យមកហើយ។ ការទាំងនេះអាចរកដានឃើញ
ក្នុងប្រវត្តិរបស់ពួកព្រឹទ្ធាចារ្យ ពួកហោរា និងពួកសាវ័ក ពួកអ្នកប្តូរខ្លួនស្លាប់
និងពួកកែទម្រង់សាសនាជាដើម។

ក្នុងមហាប៉ះទង្គិចចុងក្រោយ សាតាំងនឹងប្រើរបៀបដដែល សម្តែង
កិរិយាដដែល ហើយធ្វើការសម្រាប់ប្រយោជន៍ដដែល ដូចនៅក្នុងសម័យ
មុនៗដែរ។ អ្វីដែលធ្លាប់កើតមានឡើង នឹងកើតឡើងម្តងទៀត គ្រាន់តែការ
តស៊ូដែលកំពុងមកដល់នឹងមានភាពលំបាកវេទនាជាខ្លាំង ដូចដែលពិភពលោក
មិនដែលប្រទះឡើយ។ ការបោកបញ្ឆោតរបស់សាតាំងនឹងពិបាកសម្គាល់
ជាងមុន ហើយរំលោភកាន់តែលើសលប់ជាងមុនផងដែរ។ បើអាច វានឹងនាំ
ឱ្យអ្នករើសតាំងវង្វេងទៀតផង។ ម៉ាកុស ១៣:២២។

នៅពេលព្រះវិញ្ញាណរបស់ព្រះបើកចិត្តខ្ញុំឱ្យឃើញសេចក្តីពិតនៃព្រះ
បន្ទូលរបស់ទ្រង់ ព្រមទាំងឱ្យឃើញទស្សនីយភាពនៃអតីតកាល និងអនាគត
កាល ទ្រង់បានសូមឱ្យខ្ញុំចែកចាយដល់អ្នកដទៃអំពីអ្វីដែលបានបើកសម្តែង
គឺដើម្បីតាមដានប្រវត្តិនៃទំនាស់ដ៏ធំក្នុងសម័យមុនៗ មកដល់បច្ចុប្បន្នកាល
នេះ ដើម្បីបញ្ជាំងពន្លឺឱ្យឃើញអំពីការតស៊ូដ៏វេទនានៅនាអនាគតដែលកំពុង
មកដល់យ៉ាងឆាប់រហ័ស។ ក្នុងការបំពេញគោលបំណងនេះ ខ្ញុំបានព្យាយាម
ជ្រើសរើស និងប្រមូលផ្តុំព្រឹត្តិការណ៍ក្នុងប្រវត្តិសាស្ត្រព្រះវិហារ ដើម្បីតាម
ដានការបើកសម្តែងនៃសេចក្តីពិតដ៏ធំដែលល្បងល ដែលបានប្រទានដល់
ពិភពលោកក្នុងអំឡុងពេលខុសៗគ្នា ដែលបានរំជួលឱ្យសាតាំងឆេះឆួលឡើង

ព្រមទាំងរំជួលភាពជាខ្មាំងនៃវិហារដែលស្រឡាញ់លោកីយ៍ ហើយដែលបានរក្សាដោយទីបន្ទាល់នៃអ្នកដែល «មិនស្តាយជីវិតខ្លួនដរាបដល់ស្លាប់»។

ក្នុងកាលកំណត់រឿងទាំងនេះ យើងអាចឃើញប្រផ្នូលមួយនៃការប៉ះទង្គិចដែលនៅនឹងមុខយើង។ ដោយចាត់ទុកកំណត់រឿងទាំងនោះថាជាពន្លឺនៃព្រះបន្ទូលរបស់ព្រះ ហើយដោយការបំភ្លឺនៃព្រះវិញ្ញាណរបស់ទ្រង់ យើងនឹងអាចឃើញឧបាយកលទាំងឡាយរបស់មេទុច្ចរិត ហើយនិងគ្រោះទាំងឡាយដែលយើងត្រូវគេចឱ្យផុតនោះ បើយើងគ្មានកំហុសនៅចំពោះព្រះអម្ចាស់ នាពេលទ្រង់យាងមក។

ព្រឹត្តិការណ៍ធំៗ ដែលធ្វើឱ្យកត់សម្គាល់បានអំពីវឌ្ឍភាពនៃកំណែទម្រង់ក្នុងសម័យមុនៗនោះគឺវិស័យប្រវត្តិសាស្ត្រ ដែលល្បីល្បាញហើយដែលពិភពប្រៃតេស្តង់ទទួលស្គាល់ទូទាំងសកលលោក ដែលជារឿងពិតដែលគ្មាននរណាអាចបដិសេធបាន។ ប្រវត្តិសាស្ត្រដែលខ្ញុំបានសរសេរជូនដោយសង្ខេបនេះ គឺស្របទៅតាមន័យទាំងមូលនៃសៀវភៅប្រវត្តិសាស្ត្រ ហើយត្រូវបំព្រួញឱ្យខ្លីព្រោះជាការចាំបាច់ ខ្ញុំបានសង្ខេបសេចក្តីដែលបានចែងទាំងប៉ុន្មានលុះដល់ធ្វើទៀតលែងបាន បើពុំនោះគោងបាត់ន័យរបស់វា។ ក្នុងករណីខ្លះ ខ្ញុំដកស្រង់ពាក្យពេចន៍របស់អ្នកប្រវត្តិវិទូ នៅពេលលោកប្រមូលផ្តុំព្រឹត្តិការណ៍ចូលគ្នា ដើម្បីបរិយាយទស្សន:នៃរឿងអ្វីមួយឱ្យបានទូលំទូលាយក្នុងសេចក្តីសង្ខេបឬសង្ខេបរឿងដ៏ពិស្តារអ្វីមួយ ដើម្បីឱ្យមានបែបបទស្រួលបួល ប៉ុន្តែក្នុងករណីខ្លះទៀត ខ្ញុំពុំបានប្រាប់ថាការដកស្រង់នោះបានមកពីណាទេ ពីព្រោះការដកស្រង់ ពុំបានធ្វើឡើងដោយមានគោលបំណង ដើម្បីលើកអ្នកសរសេរនោះថាជាអ្នកមានឫទ្ធិអំណាចទេ តែដោយព្រោះពាក្យរបស់គេមានខ្លឹមសារចំពោះសេចក្តីដែលបានចែងវិញ។ ក្នុងការរ៉ាយរ៉ាប់បទពិសោធន៍ និងទស្សន:នៃអ្នកដែលធ្វើឱ្យកិច្ចកែទម្រង់ចម្រើនទៅមុខក្នុងសម័យយើងនេះ ខ្ញុំក៏ធ្វើដូចគ្នាដែរដោយប្រើសំណេររបស់គេ។

កម្មវត្ថុនៃសៀវភៅនេះ គឺពុំមែនសម្រាប់សម្តែងសេចក្តីពិតថ្មី ស្តីពីការតស៊ូនៅសម័យមុននោះប៉ុន្មានទេ តែសម្រាប់លើកយករឿងពិត និងគោលការ

ដែលទាក់ទងនឹងព្រឹត្តិការណ៍ដែលកំពុងតែមកដល់វិញ។ តែទោះបីមើលទៅជាផ្នែកនៃវិវាទរវាងកម្លាំងនៃពន្លឺ និងសេចក្តីងងឹតក៏ដោយ ក៏អស់ទាំងឯកសារកាលពីអតីតកាល មើលទៅដូចជាមានសារៈសំខាន់ថ្មីមួយដែរ ហើយតាមរយៈឯកសារនោះពន្លឺភ្លឺជះទៅអនាគតកាល បំភ្លឺផ្លូវរបស់អ្នកដែលនឹងត្រូវបានហៅ ដូចជាអ្នកកែទម្រង់កាលពីសម័យដើមដែរ ដើម្បីធ្វើទីបន្ទាល់ «តាមព្រះបន្ទូល និងសេចក្តីបន្ទាល់នៃព្រះយេស៊ូគ្រីស្ទ» ទោះមានគ្រោះបាត់បង់ទ្រព្យសម្បត្តិលោកីយ៍ក៏ដោយ។

កម្មវត្ថុនៃសៀវភៅនេះ គឺដើម្បីបើកសម្តែងទស្សនីយភាពនៃមហាវិវាទរវាងសេចក្តីពិត និងសេចក្តីមិនពិត ដើម្បីបើកសម្តែងកលល្បិចរបស់សាតាំង និងរបៀបទប់ទល់នឹងវាឱ្យបានជោគជ័យ ដើម្បីបង្ហាញដំណោះស្រាយដ៏សមគួរសម្រាប់បញ្ហានៃសេចក្តីអាក្រក់ និងដើម្បីបញ្ចាំងពន្លឺដល់ដើមកំណើត និងទីអវសាននៃអំពើបាប ប្រយោជន៍ឱ្យបានឃើញជាក់ច្បាស់នូវយុត្តិធម៌ និងសប្បុរធម៌របស់ព្រះក្នុងអស់ទាំងការប្រស្រ័យទាក់ទងជាមួយសត្វលោករបស់ទ្រង់ ហើយនិងដើម្បីបង្ហាញក្រឹត្យវិន័យដ៏បរិសុទ្ធរបស់ទ្រង់ ដែលមានប្រភេទផ្លាស់ប្តូរមិនបាន។ សេចក្តីអធិស្ឋានរបស់អ្នកនិពន្ធ គឺឱ្យឥទ្ធិពលនៃសៀវភៅនេះ នាំមនុស្សឱ្យរំដោះខ្លួនរួចពីអំណាចនៃសេចក្តីងងឹត ហើយក្លាយទៅជាអ្នក «ទទួលចំណែកកេរ្តិ៍អាករក្នុងពួកបរិសុទ្ធនៅទីភ្លឺ» ឱ្យបានដល់សិរីល្អនៃទ្រង់ដែលបានស្រឡាញ់យើង ព្រមទាំងលះបង់ព្រះអង្គទ្រង់សម្រាប់យើងរាល់គ្នា។

អែលិន ហ្គូល ហ្វៃត៍ (Ellen G. White)

មាតិការឿង

លេខរៀង	ចំណងជើង	លេខទំព័រ
	ហេតុដែលត្រូវអានសៀវភៅ	V
	លំនាំដើម	VIII
១៩.	ហេតុអ្វីបានជាមានការខកចិត្តដ៏សម្បើមម្ល៉េះ	៣០៥
២០.	ការស្រឡាញ់ដំណើរយាងមកវិញរបស់ព្រះគ្រីស្ទ	៣១៦
២១.	ការច្រូតកាត់ខ្យល់កួច	៣៣៤
២២.	បទទំនាយត្រូវបានសម្រេច	៣៤៨
២៣.	ការបើកសម្តែងអាថ៌កំបាំងនៃពាងឧបោសថ	៣៦១
២៤.	តើព្រះគ្រីស្ទកំពុងធ្វើអ្វីឥឡូវនេះ?	៣៧៤
២៥.	ក្រឹត្យវិន័យរបស់ព្រះដែលពុំអាចផ្លាស់ប្តូរបាន	៣៨៣
២៦.	អ្នកក្លាហានសម្រាប់សេចក្តីពិត	៤០០
២៧.	ការភ្ញាក់រលឹកឡើងវិញនាសម័យបច្ចុប្បន្ន	៤០៧
២៨.	នៅចំពោះបញ្ហីជីវិត	៤២៣
២៩.	ហេតុអ្វីបានអនុញ្ញាតឱ្យមានបាប ?	៤៣៦
៣០.	សាតាំង និងមនុស្ស	៤៤៦
៣១.	វិញ្ញាណអាក្រក់	៤៥២
៣២.	របៀបយកជ័យជម្នះលើសាតាំង	៤៥៩
៣៣.	ហួសពីផ្នូរនៅមានអ្វីទៀត?	៤៧១
៣៤.	តើមនុស្សស្លាប់អាចនិយាយមកយើងបានឬទេ?	៤៨៧
៣៥.	សេរីភាពនៃសម្បជញ្ញៈស្ថិតក្នុងភាពគ្រោះថ្នាក់	៤៩៧
៣៦.	ការប៉ះទង្គិចដែលជិតនឹងកើតឡើង	៥១៣
៣៧.	ប្រដាប់ការពារតែមួយគត់របស់យើង	៥២២
៣៨.	ព្រះរាជសារចុងក្រោយបង្អស់	៥៣០
៣៩.	គ្រាវេទនា	៥៣៩
៤០.	ដែនដីស្ថិតនៅក្នុងភាពអន្តរាយ	៥៥៨
៤១.	ការរំដោះរាស្ត្ររបស់ព្រះ	៥៧៣
៤២.	សន្តិភាពអស់កល្បជានិច្ច មហាវិវាទត្រូវបានបញ្ចប់	៥៨១

ហេតុអ្វីបានជាមានការខកចិត្តដ៏សម្បើមម្ល៉េះ

<u>ពុធ-១៤ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ៨

ខព្រះគម្ពីរប្រចាំថ្ងៃ:*ពេលវេលាបានសំរេចហើយ នគរព្រះជិតមកដល់ ដូច្នេះ ចូរប្រែចិត្ត ហើយជឿដំណឹងល្អចុះ។ ម៉ាកុស ១:១៥*

ពីយុគសម័យមួយទៅយុគសម័យមួយ ការងាររបស់ព្រះសម្តែងភាពស្រដៀងគ្នាដ៏គួរឱ្យចាប់អារម្មណ៍ នៅរាល់ពេលមានចលនាកែទម្រង់ និងចលនាសាសនាធំៗ។ គោលការរបស់ព្រះក្នុងការប្រស្រ័យទាក់ទងជាមួយមនុស្ស នៅតែដដែល។ ចលនាសំខាន់ៗនៅនាបច្ចុប្បន្ននេះ មានការស្របគ្នាទៅនឹងចលនាកាលពីអតីតកាល ហើយការពិសោធរបស់ព្រះវិហារកាលពីសម័យដើម មានមេរៀនជាច្រើនសម្រាប់យើងនៅគ្រាឥឡូវនេះ។

តាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះ ទ្រង់បានតម្រែតម្រង់ជាពិសេសដល់អ្នកបម្រើព្រះអង្គនៅផែនដី ឱ្យផ្សព្វផ្សាយការងារនៃសេចក្តីសង្គ្រោះ។ មនុស្សជាឧបករណ៍នៅក្នុងព្រះហស្តនៃព្រះ ម្នាក់ៗត្រូវបានផ្តល់ពន្លឺឱ្យមួយរង្វាល់គ្រប់ល្មមដើម្បីប្រកបការងារដែលត្រូវបានប្រគល់មក។ ប៉ុន្តែ គ្មាននរណាម្នាក់បានឈានដល់ការយល់ដឹងដ៏ពេញខ្នាតនូវព្រះរាជបំណងនៅក្នុងការងារសម្រាប់ពេលវេលារបស់ខ្លួនឡើយ។ មនុស្សមិនយល់នូវព្រះរាជសារដែលខ្លួនផ្សព្វផ្សាយក្នុងព្រះនាមទ្រង់ទាំងស្រុងទេ។ សូម្បីតែពួកហោរាក៏ពុំបានយល់ជ្រួតជ្រាបទាំងស្រុងដែរ អំពីការបើកសម្តែងមកចំពោះលោក។ អត្ថន័យនោះនឹងបានត្រូវបកស្រាយពីយុគមួយទៅយុគមួយវិញ។

សាវ័កពេត្រុសមានប្រសាសន៍អំពីសេចក្តីសង្គ្រោះនេះថា៖ «ពួកហោរាជាអ្នកបានទាយពីព្រះគុណ ដែលផ្តល់មកអ្នករាល់គ្នា គេបានស៊ើប

សូរហើយខំរកឱ្យដឹងពីសេចក្តីសង្គ្រោះនេះ ទាំងស្វែងរកឱ្យដឹង *ពេលវេលាណា ឬ គ្រាយ៉ាងណា* ដែលព្រះវិញ្ញាណនៃព្រះគ្រីស្ទដ៏សណ្ឋិតក្នុងគេ ទ្រង់ចង្អុលបង្ហាញក្នុងកាលដែលទ្រង់ធ្វើបន្ទាល់ជាមុន អំពីព្រះគ្រីស្ទត្រូវរងទុក្ខលំបាក ហើយពីសិរីល្អទាំងប៉ុន្មានដែលត្រូវមកតាមក្រោយ តែទ្រង់បានសម្តែងឱ្យគេដឹងថា សេចក្តីទាំងនោះមិនមែន *សម្រាប់គេទេ* គឺ *សម្រាប់យើងរាល់គ្នាវិញ*»។ ពេត្រុសទី១ ១:១០-១២។ នេះជាមេរៀនដ៏ល្អណាស់សម្រាប់បណ្តាជនរបស់ព្រះ នៅក្នុងយុគសម័យគ្រីស្ទាន! អស់អ្នកបរិសុទ្ធនៃព្រះ «បានស៊ើបសួរ ហើយខំរកឱ្យដឹង» អំពីការបើកសម្តែងដែលបានប្រគល់មកសម្រាប់កូនចៅតំណក្រោយដែលពុំទាន់កើតមក។ នេះបានចំជាការថ្កោលទោសដល់លោកីយ៍ដែលស្រឡាញ់សេចក្តីព្រងើយកន្តើយ ដែលពេញចិត្តតែនឹងប្រកាសថាបទទំនាយទាំងឡាយពុំអាចយល់បាន!

សូម្បីតែគំនិតនៃអ្នកបម្រើព្រះ ក៏បានទទួលការបាំងបិទជាញឹកញយដោយទំនៀមទម្លាប់ និងសេចក្តីបង្រៀនខុសឆ្គងដែរ បានជាពួកគេចាប់យកបានតែផ្នែកខ្លះៗនូវអ្វីដែលបានបើកសម្តែងនៅក្នុងព្រះបន្ទូលព្រះ។ ពួកសិស្សរបស់ព្រះគ្រីស្ទក៏ដូច្នោះដែរ សូម្បីតែកាលព្រះអង្គសង្គ្រោះបានគង់នៅជាមួយផង ក៏ពួកគេមានគំនិតគិតក្នុងចិត្តថា ព្រះមែស្ស៊ីគ្រាន់តែជាព្រះរាជបុត្រនៃលោកីយ៍ដែលនឹងត្រូវលើកស្ទួយអ៊ីស្រាអែលឱ្យទៅជាចក្រភពសាកលមួយប៉ុណ្ណោះ។ ពួកគេពុំបានយល់ព្រះបន្ទូលព្រះអង្គ ដែលទស្សន៍ទាយប្រាប់ជាមុនអំពីសេចក្តីរងទុក្ខ និងជីវិតរបស់ព្រះអង្គឡើយ។

«ពេលវេលាត្រូវបានសម្រេច»

ព្រះគ្រីស្ទទ្រង់បានបញ្ជូនព្រះរាជសារដល់គេជាមុនថា៖ «ពេលវេលាបានសម្រេចហើយ នគរព្រះជិតមកដល់ ដូច្នេះចូរប្រែចិត្ត ហើយជឿដំណឹងល្អចុះ»។ ម៉ាកុស ១:១៥។ ព្រះរាជសារនោះបានតាំងនៅក្នុងបទទំនាយនៃគម្ពីរដានីយ៉ែលជំពូក៩។ អំឡុងពេល «ហុកសិបប្រាំបួនអាទិត្យ» លាត

សន្ធឹងទៅដល់ «ព្រះមែស្ស៊ីដ៏ជាព្រះរាជបុត្រ» ហើយពួកសិស្សបានទន្ទឹងរង់ចាំ នូវការស្ថាបនានគររបស់ព្រះមែស្ស៊ី នៅយេរូសាឡិម ដើម្បីគ្រប់គ្រងលើ ផែនដីទាំងមូល។

ពួកគេបានផ្សព្វផ្សាយព្រះរាជសារដែលបានផ្ទុកផ្តាក់ដល់ខ្លួន ទោះ បីពួកគេពុំបានយល់សព្វគ្រប់ក៏ដោយ។ នៅពេលដែលសេចក្តីប្រកាសរបស់ ពួកគេត្រូវបានរកឃើញនៅដានីយ៉ែល ៩:២៥ ពួកគេពុំបានមើលនៅខបន្ទាប់ ដែលថា ព្រះមែស្ស៊ីនឹងត្រូវ «ផ្តាច់ចេញវិញ» នោះទេ។ ចិត្តពួកគេបានផ្តោត ទៅលើសិរីរុងរឿងនៃអាណាចក្រនៅផែនដីតែប៉ុណ្ណោះ ដែលជាហេតុធ្វើឱ្យ បាំងការយល់ដឹងរបស់ខ្លួន។ នៅចំពេលដែលពួកគេសង្ឃឹមថានឹងបានឃើញ ព្រះអម្ចាស់របស់ខ្លួនឡើងទៅកាន់បល្ល័ង្កហ្លួងដាវីឌ ស្រាប់តែមានគេចាប់ ទ្រង់ វាយដំ ចំអកឱ្យ ហើយផ្តន្ទាទ្រង់ នៅលើឈើឆ្កាង។ តើសេចក្តីអស់ សង្ឃឹម និងសេចក្តីទង្គឹះចិត្តបានរណ្តំចិត្តពួកសិស្សដល់ប៉ុនណាទៅ?

<u>ព្រហស្បតិ៍-១៥ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ៩

ខព្រះគម្ពីរប្រចាំថ្ងៃ: *អញនឹងនាំពួកមនុស្សខ្វាក់តាមផ្លូវ១ដែលគេមិនស្គាល់ អញនឹងដឹកគេតាមផ្លូវច្រកដែលគេមិនធ្លាប់ដើរ អញនឹងធ្វើឲ្យសេចក្តីងងឹត បានភ្លឺឡើងនៅមុខគេ ហើយផ្លូវភ្ញិចភ្ញក់ឲ្យទៅជាត្រង់វិញ គឺការទាំងនេះ ដែលអញនឹងធ្វើ ហើយមិនបោះបង់ចោលគេឡើយ។ អេសាយ ៤២:១៦*

ព្រះគ្រីស្ទបានយាងមកចំពេលដែលបានទាយទុកមក។ បទគម្ពីរត្រូវ បានសម្រេចគ្រប់សេចក្តី។ ព្រះបន្ទូល និងព្រះវិញ្ញាណនៃព្រះ បានបញ្ជាក់ យ៉ាងច្បាស់នូវបេសកកម្មដ៏ពិសិដ្ឋរបស់ព្រះរាជបុត្រាព្រះអង្គ។ ចិត្តគំនិតរបស់ ពួកសិស្សនៅតែពោរពេញទៅដោយការសង្ឃ័យ។ ប្រសិនបើព្រះយេស៊ូវជា ព្រះមែស្ស៊ីពិតមែននោះ តើពួកគេនឹងត្រូវធ្លាក់ទៅក្នុងសេចក្តីទុក្ខសោក និង សេចក្តីខកចិត្តយ៉ាងដូច្នេះឬ? នេះជាសំណួរដែលបានចោទសួរដុកដាន់ជា ខ្លាំងដល់ព្រលឹងរបស់ពួកគេ នៅក្នុងអំឡុងពេលអស់សង្ឃឹមនៃថ្ងៃសប្ប៉ាតហ៍

ចន្លោះពេលព្រះអង្គសុគត និងពេលព្រះអង្គមានព្រះជន្មរស់ឡើងវិញ។

តែព្រះអង្គមិនចោលពួកគេទេ។ «កាលខ្ញុំអង្គុយក្នុងទីងងឹត នោះព្រះយេហូវ៉ានឹងជាពន្លឺដល់ខ្ញុំ...។ ទ្រង់នឹងនាំខ្ញុំចេញមកឯពន្លឺ រួចខ្ញុំនឹងរំពឹងមើលសេចក្ដីសុចរិតរបស់ទ្រង់»។ «មានពន្លឺភ្លឺឡើងក្នុងទីងងឹត សម្រាប់មនុស្សទៀងត្រង់»។ «អញនឹងធ្វើឱ្យសេចក្ដីងងឹត បានភ្លឺឡើងនៅមុខគេ ហើយផ្លូវកិកកូក់ឱ្យទៅជាត្រង់វិញ គឺជាទាំងនេះដែលអញនឹងធ្វើ ហើយមិនបោះបង់ចោលគេឡើយ»។ មីកា ៧:៨,៩; ទំនុកតំកើង ១១២;៤; អេសាយ ៤២:១៦។

ការប្រកាសផ្សាយដោយពួកសិស្ស គឺត្រឹមត្រូវណាស់ «ពេលវេលាបានសម្រេច ហើយនគរព្រះជិតមកដល់»។ នៅពេលដែល «ពេលវេលា» បានកន្លងផុតទៅ ហុកសិបប្រាំបួនអាទិត្យនៃដានីយ៉ែល ៩ ត្រូវលាតសន្ធឹងមកដល់ព្រះមែស្ស៊ី ជា «អ្នកដែលចាក់ប្រេងតាំង» ព្រះគ្រីស្ទបានទទួលចាក់ប្រេងតាំងដោយព្រះវិញ្ញាណបរិសុទ្ធ បន្ទាប់ពីទទួលបុណ្យជ្រមុជដោយលោកយ៉ូហានមក។ «នគរព្រះ» ពុំមែនជាអាណាចក្រនៅផែនដី ដូចគេបានបង្ហាត់បង្រៀនពួកគេនោះទេ ក៏ពុំមែនជានគរដ៏នៅស្ថិតស្ថេរអស់កល្បជានិច្ចនៅអនាគតកាលដែល «គ្រប់ទាំងអំណាចគ្រប់គ្រងនឹងត្រូវគោរពដល់ទ្រង់ ហើយស្តាប់បង្គាប់ផង» នោះឡើយ។ ដានីយ៉ែល ៧:២៧។

ដែលហៅថា «នគរព្រះ» នោះមានន័យថាជានគរនៃព្រះគុណ និងនគរនៃសិរីល្អ។ សាវ័កប៉ុលមានប្រសាសន៍ថា៖ «ដូច្នេះត្រូវឱ្យយើងរាល់គ្នាមកដល់ *បល្ល័ង្កនៃព្រះគុណ* ដោយក្លាហានដើម្បីទទួលសេចក្ដីមេត្តា ហើយរកបានព្រះគុណចុះ»។ ហេព្រើរ ៤:១៦។ មានបល្ល័ង្ក បញ្ជាក់ថាមាននគរ។ ព្រះគ្រីស្ទទ្រង់ប្រើពាក្យថា «នគរនៃស្ថានសួគ៌» ដើម្បីសម្គាល់កិច្ចការនៃព្រះគុណនៅលើចិត្តមនុស្ស។ ដូច្នេះបល្ល័ង្កនៃសិរីល្អ តំណាងឱ្យនគរនៃសិរីល្អ។ ម៉ាថាយ ២៥:៣១,៣២។ នគរនេះនៅក្នុងអនាគតកាលនៅឡើយ ពុំទាន់តាំងឡើងទេ រហូតទាល់តែព្រះគ្រីស្ទយាងមកជាលើកទីពីរ។

នៅពេលដែលព្រះអង្គសង្គ្រោះបានប្រគល់ព្រះជន្មទ្រង់ដោយស្រែក

ឡើងថា «ការស្រេចហើយ» សេចក្តីសន្យានៃសេចក្តីសង្គ្រោះចំពោះគូស្វាមីភរិយាមានបាបនៅក្នុងសួនច្បារអេដែន ក៏បានសម្រេច។ នគរនៃព្រះគុណដែលមាននៅតាំងតែពីមុន ដោយសេចក្តីសន្យានៃព្រះនោះ គឺបានស្ថាបនាឡើងនៅពេលនោះឯង។

ដូច្នេះជីវិតនៃព្រះគ្រីស្ទ ជាព្រឹត្តិការណ៍ដែលពួកសិស្សចាត់ទុកថាជាការវិនាសបង់នូវទីសង្ឃឹមរបស់ខ្លួនជារៀងរហូត ជាសេចក្តីសុគតដែលសម្រេចយ៉ាងជាក់ស្តែងនូវសេចក្តីសន្យារបស់ទ្រង់។ ការដែលបាននាំមកនូវការខកចិត្តដ៏ឃោរឃៅ គឺជាភ័ស្តុតាងបង្ហាញឱ្យឃើញថា ពួកគេបានជឿដូច្នោះមែន។ ព្រឹត្តិការណ៍ដែលបានបំពេញពួកគេដោយការអស់សង្ឃឹម បានបើកទ្វារនៃសេចក្តីសង្ឃឹមដល់អស់អ្នកស្មោះត្រង់ចំពោះព្រះនៅគ្រប់ជំនាន់វិញ។

លាយជាមួយនឹងមាសសុទ្ធនៃសេចក្តីស្រឡាញ់របស់ពួកសិស្សដល់ព្រះយេស៊ូវ គឺជាគ្រឹះលង្ហិននៃមហិច្ឆតាផ្ទាល់ខ្លួន។ ទស្សនៈរបស់ពួកគេបានពោរពេញទៅដោយបល្ល័ង្ក មកុដ ហើយនិងសិរីរុងរឿង។ ការមានចិត្តធំ និងការស្រេកឃ្លានូវសិរីរុងរឿងនាលោកីយ៍ បាននាំឱ្យពួកគេរំលងហួសដោយមិនដឹងខ្លួននូវព្រះបន្ទូលព្រះអង្គសង្គ្រោះ ដែលសម្តែងប្រាប់អំពីភាពពិតនៃនគររបស់ព្រះអង្គ ហើយដែលសំដៅទៅរកជីវិតរបស់ទ្រង់ផង។ ការខុសឆ្គងនេះបណ្តាលឱ្យមានគ្រាទង្គឹះចិត្តប្រយោជន៍ឱ្យពួកគេមានឱកាសកែប្រែឡើង ព្រោះគេនឹងត្រូវទទួលបន្ទុកនូវដំណឹងល្អដ៏រុងរឿងនៃព្រះអម្ចាស់ របស់គេដែលបានមានព្រះជន្មរស់ឡើងវិញ។ ដើម្បីរៀបចំពួកគេសម្រាប់ការងារនេះ ពួកគេត្រូវបានបណ្តាលឱ្យជួបប្រទះនូវការពិសោធ ដែលហាក់ដូចជាជូរចត់ក្រៃលែង។

បន្ទាប់ពីព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបានលេចមកឯពួកសិស្សនៅតាមផ្លូវទៅអេម៉ូស ហើយក៏ «ស្រាយន័យសេចក្តីដែលតម្រូវដល់ទ្រង់ ពីក្នុងគម្ពីរទាំងឡាយឱ្យគេស្តាប់»។ បំណងព្រះទ័យទ្រង់ គឺដើម្បី

ឱ្យគេជឿដល់ «បទពាក្យទំនាយដ៏ពិត» (លូកា ២៤:២៧; ពេត្រុសទី២ ១:១៩) មិនគ្រាន់តែដោយសារទីបន្ទាល់ផ្ទាល់របស់ព្រះអង្គប៉ុណ្ណោះទេ គឺដោយបទទំនាយនៅក្នុងគម្ពីរសញ្ញាចាស់ផងដែរ។ នៅជំហានដំបូងបង្អស់ក្នុងការចែកចំណេះនេះ ព្រះយេស៊ូវបានតម្រង់ពួកសិស្សទៅឯ «គម្ពីរលោកម៉ូសេ និងគម្ពីរពួកហោរារៀងមក» ក្នុងគម្ពីរសញ្ញាចាស់។

<u>សុក្រ-១៦ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ១០

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដ្បិតសេចក្ដីខ្ញាល់របស់ទ្រង់នៅតែ១ភ្លែតទេ តែព្រះគុណនៃទ្រង់ នោះនៅអស់១ជីវិតវិញ ទឹកភ្នែកនឹងមាននៅជាប់អស់មួយយប់ក៏បានតែព្រឹកឡើង គង់នឹងមានសេចក្ដីអំណរឡើងដែរ។ ទំនុកតម្កើង ៣០:៥*

ពីការអស់សង្ឃឹម ដល់ការសង្ឃឹមទុកចិត្ត

អ្វីដែលពោរពេញទៅដោយសុភនិច្ឆ័យជាងពេលណាៗទាំងអស់នោះ គឺពួកសិស្សបាន «រកឃើញព្រះអង្គដែលលោកម៉ូសេបានចែងទុកពីទ្រង់នៅក្នុងក្រឹត្យវិន័យ ហើយពួកហោរាក៏បានទាយពីទ្រង់ផង» ដែរ។ ភាពមិនច្បាស់លាស់ ភាពអស់សង្ឃឹមបែរជាមានភាពសង្ឃឹមទុកចិត្ត និងមានជំនឿដែលឥតស្រពេចស្រពិលវិញ។ ពួកគេបានឆ្លងផុតគ្រាទុក្ខព្រួយដ៏ធំធេងដែលពួកគេបានពិសោធ ហើយបានឃើញពីរបៀបដែលព្រះបន្ទូលនៃព្រះបានសម្រេចជាស្ថាពរផង។ ពីនេះតទៅមុខ តើមានអ្វីអាចមកធ្វើឱ្យស្រអាប់ជំនឿពួកគេបានទៀត? ក្នុងគ្រាមានទុក្ខព្រួយខ្លាំង ពួកគេមាន «សេចក្ដីកម្លាចិត្តឡើងជាខ្លាំង» ដែរ ជាសេចក្ដីសង្ឃឹមដែល «ទុកដូចជាយុថ្កានៃព្រលឹងដ៏ជាប់លាប់មាំមួន»។ ហេព្រើរ ៦:១៨,១៩។

ព្រះអម្ចាស់មានបន្ទូលថា៖ «រាស្ត្រអញនឹងមិនត្រូវមានសេចក្ដីខ្មាសទៀតឡើយ» «ទឹកភ្នែកនឹងមាននៅជាប់អស់មួយយប់...តែព្រឹកឡើង គង់នឹងមានសេចក្ដីអំណរឡើង»។ យ៉ូអែល ២:២៦; ទំនុកតំកើង ៣០:៥។ នៅថ្ងៃព្រះអង្គមានព្រះជន្មរស់ឡើងវិញ ពួកសិស្សទាំងនេះបានជួបទ្រង់ ចិត្តពួកគេ

ក៏ឆេះឆូលឡើង ហើយបានស្តាប់ទ្រង់មានបន្ទូល។ នៅពេលមុនទ្រង់យាងឡើងទៅឋានសួគ៌វិញ ព្រះយេស៊ូវបានផ្តាំដល់ពួកសិស្សថា៖ «ចូរអ្នករាល់គ្នាទៅពេញសព្វក្នុងលោកីយ៍ទាំងមូល ហើយផ្សាយដំណឹងល្អទូទៅដល់គ្រប់មនុស្សទាំងអស់ចុះ» ទ្រង់បានបន្ថែមទៀតថា៖ «មើលខ្ញុំក៏នៅជាមួយអ្នករាល់គ្នាជាដរាបដែរ»។ ម៉ាកុស ១៦:១៥; ម៉ាថាយ ២៨:២០។ នៅថ្ងៃបុណ្យទីហាសិបព្រះអង្គដ៏ជាអ្នកកំសាន្តចិត្តដែលបានសន្យាថានឹងប្រទានមកនោះ បានយាងចុះមក ហើយពួកអ្នកជឿក៏បានរំភើបចិត្តឡើងដោយដឹងថាព្រះអម្ចាស់របស់ខ្លួនដែលបានយាងទៅលើហើយនោះ មានវត្តមាននៅជាមួយគេ។

ដំណឹងរបស់ពួកសិស្ស ប្រៀបធៀបទៅនឹងព្រះរាជសារឆ្នាំ១៨៤៤

បទពិសោធន៍របស់ពួកសិស្សនៅពេលព្រះគ្រីស្ទយាងមកជាលើកទីមួយ គឺស្រដៀងគ្នានឹងបទពិសោធន៍របស់ពួកអ្នកដែលប្រកាសផ្សាយអំពីដំណើរយាងមកជាលើកទីពីររបស់ព្រះអង្គដែរ។ ដូចដែលពួកសិស្សបានអធិប្បាយផ្សាយថា «ពេលវេលាបានសម្រេច...នគរព្រះជិតមកដល់» លោកមិល្លើរ និងគូកនគាត់ក៏ប្រកាសផ្សាយដែរថា រយៈកាលតាមបទទំនាយក្នុងគម្ពីរហៀបនឹងផុតកំណត់ហើយ ថាសេចក្តីជំនុំជម្រះក៏ជិតមកដល់ ហើយថានគរដ៏ស្ថិតស្ថេរនៅអស់កល្បជានិច្ច ក៏បានរៀបចំរួចស្រេចហើយដែរ។ សេចក្តីអធិប្បាយរបស់ពួកសិស្សដែលអាស្រ័យទៅនឹងពេលវេលា គឺត្រូវបានតាំងទៅលើ៧០អាទិត្យនៃគម្ពីរដានីយ៉ែល ៩។ ព្រះរាជសារដែលត្រូវផ្សាយដោយមិល្លើរ និងសហការី បានប្រកាសផ្សាយអំពីការបញ្ចប់នៃ២៣០០ថ្ងៃ នៅគម្ពីរដានីយ៉ែល ៨:១៤ ដែល៧០អាទិត្យនោះគ្រាន់តែជាផ្នែកមួយប៉ុណ្ណោះ។ សេចក្តីអធិប្បាយនីមួយៗបានអាស្រ័យទៅលើការសម្រេចនូវផ្នែកផ្សេងគ្នានៃរយៈកាលតាមបទទំនាយដដែលនោះឯង។

ដូចគ្នានឹងពួកសិស្សនៅគ្រាដំបូងដែរ លោកវិល្លៀម មិល្លើរ និងក្រុមគាត់ ពុំបានយល់សព្វគ្រប់នូវព្រះរាជសារដែលពួកគេបានទទួលនោះទេ។

ការខុសឆ្គងដែលបានស្ថាបនាឡើងនៅក្នុងវិហារជាយូរមកហើយនោះ បានបង្ការមិនឱ្យគេបកស្រាយត្រឹមត្រូវនូវចំណុចសំខាន់ៗក្នុងបទទំនាយ។ ម្ល៉ោះហើយ ទោះបីពួកគេបានប្រកាសផ្សាយព្រះរាជសារដែលព្រះបានផ្ទុកផ្ដាក់ដល់ខ្លួនក៏ដោយ ក៏ពួកគេនៅតែមានការខកចិត្តដ៏ឥតគណនាដែរ ដោយសារការយល់ខុសអត្ថន័យ។

<u>សៅរ៍-១៧ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ១១

ខព្រះគម្ពីរប្រចាំសប្ដាហ៍: *មើល យើងហៅពួកអ្នកដែលទ្រាំទ្រ ថាជាអ្នកមានពរ ចុះអ្នករាល់គ្នាបានឮនិយាយ ពីសេចក្ដីអត់ធន់របស់លោកយ៉ូបទៅហើយ ក៏បានឃើញថាដល់ចុងបំផុត នោះព្រះអម្ចាស់ទ្រង់មានព្រះហឫទ័យមេត្តាករុណា និងសេចក្ដីអាណិតអាសូរពោរពេញដែរ។ យ៉ាកុប ៥:១១*

មិល្លើរបានប្រកាន់យកទស្សន:ទូទៅថាផែនដីជា «ទីបរិសុទ្ធ» ហើយគាត់ជឿថា «ការសម្អាតទីបរិសុទ្ធ» ជានិមិត្តរូបនៃការសម្អាតផែនដីដោយភ្លើងនៅពេលព្រះអង្គយាងមក។ ម្ល៉ោះហើយគាត់បានសន្និដ្ឋានថា ទីបញ្ចប់នៃរយៈកាល២៣០០ថ្ងៃ ជាកំណត់ពេលវេលានៃដំណើរយាងមកជាលើកទីពីរ។

ការសម្អាតទីបរិសុទ្ធ គឺជាការងារចុងក្រោយបង្អស់ ធ្វើឡើងដោយសម្ដេចសង្ឃជាន់ខ្ពស់នៅក្នុងកិច្ចការប្រចាំឆ្នាំ ជាកិច្ចបញ្ចប់នៃការសណ្ដោសប្រោស ជាការយកចេញ ឬញែកចេញនូវអំពើបាបអំពីជនជាតិអ៊ីស្រាអែល។ ការសម្អាតនេះជាតំណាងដល់កិច្ចការបញ្ចប់របស់សម្ដេចសង្ឃជាន់ខ្ពស់របស់យើងនៅស្ថានសួគ៌ នៅក្នុងការយកចេញ ឬលុបចេញនូវអំពើបាបរបស់មនុស្សដែលមានចុះឈ្មោះនៅក្នុងកំណត់ហេតុនៅស្ថានសួគ៌។ ការងារនេះមានទាក់ទងជាមួយកិច្ចការពិនិត្យអង្កេត កិច្ចការជំនុំជម្រះ ហើយចាប់ផ្ដើមឡើងមុនដំណើរយាងមករបស់ព្រះគ្រីស្ទនៅក្នុងពពកនាឰដ៏ស្ថានសួគ៌ ដ្បិតនៅពេលទ្រង់យាងមក ករណីទាំងអស់ត្រូវបានសម្រេចអស់ហើយ។ ព្រះ

យេស៊ូវមានបន្ទូលថា៖ «មើលអញមកជាឆាប់ ទាំងនាំយករង្វាន់មកជាមួយ ដើម្បីនឹងចែកឱ្យគ្រប់គ្នាតាមការដែលខ្លួនបានធ្វើ»។ វិវរណៈ ២២:១២។ កិច្ចការជំនុំជម្រះនេះឯងដែលត្រូវបានប្រកាសនៅក្នុងព្រះរាជសារនៃទេវតាទីមួយ នៅវិវរណៈ:១៤:៧៖ «ចូរកោតខ្លាចដល់ព្រះ ហើយសរសើរសិរីល្អរបស់ទ្រង់ចុះ ដ្បិតពេលដែលទ្រង់ត្រូវជំនុំជម្រះ នោះបានមកដល់ហើយ»។

អស់អ្នកដែលបានប្រកាសផ្សាយសេចក្តីព្រមាននេះ គឺបានផ្តល់នូវព្រះរាជសារដ៏ត្រឹមត្រូវហើយចំពេលតែម្តង។ ដែលពួកសិស្សបានគិតខុសថា នគរនឹងត្រូវតាំងឡើងនៅទីបញ្ចប់នៃ «៧០អាទិត្យ» ជាយ៉ាងណា ពួកនិវត្តក:ក៏បានគិតខុសថា ព្រឹត្តិការណ៍នឹងកើតមាននៅពេលផុតកំណត់នៃរយៈកាល «២៣០០ថ្ងៃ» ជាយ៉ាងនោះដែរ។ នៅក្នុងករណីទីពីរ កំហុសខុសឆ្គងដែលគេនិយមខ្លាំងនេះ បានបិទបាំងគំនិតពីសេចក្តីពិត។ ទាំងពីរបានបំពេញបំណងព្រះទ័យនៃព្រះក្នុងការបញ្ជូនព្រះរាជសារដែលទ្រង់សព្វព្រះទ័យឱ្យផ្សាយ ហើយតាមរយៈការយល់ខុសចំពោះព្រះរាជសាររបស់ខ្លួន ពួកអ្នកទាំងពីរបានមានការខកចិត្តដ៏សែនជូរចត់។

ព្រះនៅតែសម្រេចបំណងព្រះទ័យព្រះអង្គ ក្នុងការអនុញ្ញាតឱ្យគេផ្សាយសេចក្តីព្រមាននៃសេចក្តីជំនុំជម្រះ ដូចបានធ្វើរួចមកហើយនោះ។ នៅក្នុងទិព្វញ្ញាណព្រះអង្គ ព្រះរាជសារនោះគឺសម្រាប់ល្បងល និងធ្វើឱ្យស្អាតដល់ក្រុមជំនុំ។ តើសេចក្តីស្រឡាញ់របស់ពួកគេ បានដាក់ទៅលើលោកីយ៍នេះ ឬក៏ទៅលើព្រះគ្រីស្ទ និងស្ថានសួគ៌? តើពួកគេសុខចិត្តលះបង់មហិច្ឆតានាលោកីយ៍ ហើយត្រៀមខ្លួនចាំទទួលដំណើរយាងមករបស់ព្រះអង្គសង្គ្រោះនៃខ្លួនដែរឬទេ?

ការខកចិត្តបានសាកល្បងដល់ចិត្តនៃអស់អ្នកដែលអះអាងថាបានទទួលការព្រមាននោះហើយដែរ។ តើពួកគេនឹងប្រញាប់ប្រញាល់បោះបង់ចោលបទពិសោធន៍ ហើយលែងទុកចិត្តដល់ព្រះបន្ទូលរបស់ព្រះ នៅពេលដែលត្រូវហៅឱ្យទ្រាំទ្រចំពោះសេចក្តីបន្ទោសនៃលោកីយ៍ និងការសាកល្បង

នៃការពន្យារពេល ហើយនិងការខកចិត្តនោះឬយ៉ាងណា? ដោយព្រោះពួក
គេពុំយល់ភ្លាមៗនូវសេចក្តីប្រព្រឹត្តរបស់ព្រះ តើពួកគេនឹងបោះបង់ចោលនូវ
សេចក្តីពិតទាំងឡាយដែលបានទ្រទ្រង់ដោយទីបន្ទាល់ច្បាស់លាស់នៃព្រះ
បន្ទូលទ្រង់ឬ?

ការសាកល្បងនេះ បង្រៀនពីការគ្រោះថ្នាក់នៃការទទួលនូវការបក
ស្រាយរបស់មនុស្សជាជាងឱ្យព្រះគម្ពីរធ្វើជាអ្នកបកស្រាយដោយខ្លួនឯង។
ពួកកូនចៅនៃជំនឿត្រូវបាននាំឱ្យរៀនព្រះបន្ទូលរឹតតែជិតដល់ ឱ្យពិនិត្យសង្កេត
បានប្រិតប្រៀនថែមទៀតនូវមូលដ្ឋាននៃជំនឿរបស់ខ្លួន ហើយឱ្យបដិសេធគ្រប់
ទាំងអ្វីៗដែលពុំមានឃើញនៅក្នុងបទគម្ពីរ ទោះជាបានទទួលជាទូទៅ
ដោយពិភពគ្រីស្ទានប៉ុនណាក៏ដោយ។

អ្វីដែលហាក់ដូចជាងងឹតពិបាកយល់នៅក្នុងគ្រាវេទនា នឹងបាន
យល់ច្បាស់វិញនៅពេលក្រោយ។ ថ្វីបើមានសេចក្តីទន្ទឹងចិត្ត ដែលជាលទ្ធផល
មកអំពីការខុសឆ្គងរបស់ខ្លួនក៏ដោយ ក៏ពួកគេបានរៀនសូត្រដោយការ
ពិសោធន៍ដ៏មានពរ ថាព្រះអម្ចាស់ទ្រង់ «មានព្រះទ័យមេត្តាករុណា និង
សេចក្តីអាណិតអាសូរពោរពេញដែរ» ថាអស់ទាំងផ្លូវរបស់ទ្រង់ «សុទ្ធតែ
ប្រកបដោយសេចក្តីសប្បុរស និងសេចក្តីពិត ចំពោះអស់អ្នកដែលកាន់តាម
សេចក្តីសញ្ញា និងសេចក្តីបន្ទាល់របស់ទ្រង់»។ យ៉ាកុប ៥:១១; ទំនុកតំកើង
២៥:១០។



«ដរាបដល់បានកន្លង២៣០០ព្រឹកនិងល្ងាចទៅ នោះទើបទីបរិសុទ្ធនឹងបានស្អាតឡើង»។

ការស្រឡាញ់ដំណើរយាងមកវិញរបស់ព្រះគ្រីស្ទ

<u>អាទិត្យ-១៨ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ១២

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែចំណែកអ្នក ឱដានីយ៉ែលអើយ ចូរបិទបាំងពាក្យទាំងនេះ ហើយបិទត្រាសៀវភៅនេះទុកដរាបដល់គ្រាចុងបំផុតចុះ មនុស្សជាច្រើននឹងខំរកយល់ ហើយចំណេះនឹងបានចំរើនឡើង។ ដានីយ៉ែល ១២:៤*

ដំណឹងរបស់ទេវតាទីមួយក្នុងគម្ពីរវិវរណៈជំពូក១៤ បានទាយពីការភ្ញាក់រឭកដ៏អស្ចារ្យមួយបែរទៅរកសាសនាវិញ។ មានឃើញទេវតាមួយអង្គហោះ «កាត់កណ្តាលមេឃ ទាំងមានដំណឹងល្អដ៏នៅអស់កល្បជានិច្ច សម្រាប់ នឹងថ្លែងប្រាប់មនុស្សនៅផែនដី គឺដល់គ្រប់អស់ទាំងសាសន៍ គ្រប់ពូជអំបូរ គ្រប់ភាសា ហើយគ្រប់ទាំងគ្រួសារដែរ»។ ទេវតាប្រកាសដោយ «សំឡេង ជាខ្លាំង» ថា៖ «ចូរកោតខ្លាចដល់ព្រះ ហើយសរសើរសិរីល្អរបស់ទ្រង់ចុះ ដ្បិតពេលដែលទ្រង់ត្រូវជំនុំជម្រះ នោះបានមកដល់ហើយ។ ចូរក្រាបថ្វាយ បង្គំព្រះដ៏ [ជាអ្នក] បង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងរន្ធទឹកទាំងប៉ុន្មានចុះ»។ វិវរណៈ ១៤:៦,៧។

ទេវតា គឺតំណាងពីចរិតលក្ខណៈដ៏ឧត្តុង្គឧត្តមនៃកិច្ចការដែលនឹងត្រូវបានសម្រេចដោយព្រះរាជសារ ហើយនិងដោយអំណាច និងសិរីល្អដែលត្រូវប្រទានមកតាមក្រោយ។ ការដែលទេវតាហោះ «កាត់កណ្តាលមេឃ» ក្នុង «សំឡេងជាខ្លាំង» និងការប្រកាស «ដល់គ្រប់អស់ទាំងសាសន៍ គ្រប់ពូជអំបូរ គ្រប់ភាសា ហើយគ្រប់ទាំងគ្រួសារ» បង្ហាញភ័ស្តុតាងនៃការធ្វើចលនាយ៉ាងឆាប់រហ័ស ហើយទូទាំងពិភពលោក។ នៅពេលដែលការប្រកាសផ្សាយនេះចាប់ផ្តើមឡើង ក៏មានឮការប្រកាសផ្សាយអំពីការចាប់

ផ្តើមជំនុំជម្រះផងដែរ។

ដំណឹងនេះគឺជាដំណឹងល្អមួយផ្នែក ដែលនឹងត្រូវប្រកាសក្នុងជំនាន់ចុងក្រោយប៉ុណ្ណោះ ព្រោះមានតែនៅពេលនោះទេ ដែលពេលជំនុំជម្រះបានមកដល់ មែននោះ។ ព្រះទ្រង់បង្គាប់ឱ្យដានីយ៉ែលបិទ ហើយបោះត្រានូវផ្នែកនៃទំនាយដែលទាក់ទងទៅនឹងជំនាន់ចុងក្រោយ «ទុកដរាបដល់គ្រាចុងក្រោយបំផុត»។ ដានីយ៉ែល ១២:៤។ លុះដល់ពេលនេះទើបដំណឹងស្តីពីការជំនុំជម្រះនឹងអាចប្រកាសបាន ព្រោះបទទំនាយបានសម្រេចស្រេចហើយ។

សាវ័កប៉ុលបានហាមក្រុមជំនុំ មិនឱ្យរង់ចាំនូវការយាងមកវិញនៃព្រះគ្រីស្តក្នុងជំនាន់គាត់។ លុះដល់មានការបែរចេញពីជំនឿជាខ្លាំង និងការសោយរាជ្យដ៏យូរលង់របស់ «មនុស្សដែលជាតួបាប» សិនទើបយើងអាចទន្ទឹងចាំការយាងមកនៃព្រះអម្ចាស់របស់យើងបាន។ សូមអាន ថែស្សាឡូនីចទី២ ២:៣។ «មនុស្សដែលជាតួបាប» ឬ «សេចក្តីអាថកំបាំងនៃការទទឹងច្បាប់» «មួយនាក់នោះដែលបានតម្រូវឱ្យត្រូវវិនាស» និង «អាទទឹងច្បាប់» គឺតំណាងប្រព័ន្ធកាតូលិកដែលនឹងត្រូវមានអំណាចគ្រប់គ្រងអស់ ១២៦០ឆ្នាំ។ អំឡុងពេលនេះបានចប់នៅឆ្នាំ១៧៩៨។ ការយាងមកវិញរបស់ព្រះគ្រីស្ត ពុំអាចកើតឡើងមុនពេលនោះទេ។ សាវ័កប៉ុលបានរៀបរាប់យ៉ាងប្រយ័ត្នប្រយែង ពីការបែកខ្ញែកនៃគ្រីស្ទានទាំងមូលរហូតដល់ឆ្នាំ១៧៩៨។ ដំណឹងនៃការយាងមកវិញជាលើកទីពីររបស់ព្រះគ្រីស្ត គឺនឹងត្រូវប្រកាសបន្ទាប់ពីឆ្នាំនេះឯង។

ឥតមានដំណឹងដូចនេះត្រូវបានប្រកាសឡើងក្នុងជំនាន់មុនទេ។ ដូចយើងបានឃើញហើយសាវ័កប៉ុលពុំបានផ្សព្វផ្សាយដំណឹងនេះទេ តែគាត់បានចង្អុលទៅអនាគតកាលនៅឯនាយឯនុះ ថាជាដំណើរយាងមកវិញរបស់ព្រះអម្ចាស់។ ពួកកែទម្រង់ក៏ពុំបានប្រកាសដែរ។ លោកម៉ាធីន លូធើរបានកំណត់ថា ការជំនុំជម្រះគឺ៣០០ឆ្នាំនៅឯអនាគតកាលឯនុះ ចាប់ពីជំនាន់

គាត់ទៅ។ ប៉ុន្តែ ចាប់តាំងពីឆ្នាំ១៧៩៨មក គម្ពីរដានីយ៉ែលត្រូវបានបកត្រាចេញ ហើយជនជាច្រើនបានប្រកាសផ្សាយដំណឹងនៃការវិនិច្ឆ័យទោសដែលនឹងមកដល់។

ចលនានិកត្តលេចឡើងព្រមៗគ្នាក្នុងប្រទេសជនៃ

ដូចជាកំណែទម្រង់នៃសតវត្សទី១៦ដែរ ចលនានិកត្តបានលេចឡើងព្រមៗគ្នាក្នុងប្រទេសដទៃទៀត។ អ្នកមានជំនឿត្រូវបានគេនាំឱ្យសិក្សាបទទំនាយ ហើយឃើញនូវភ័ស្តុតាងយ៉ាងច្បាស់ថាទីបញ្ចប់គឺជិតដល់ហើយ។ ដោយសារតែការសិក្សាបទគម្ពីរ ក្រុមគ្រីស្ទានដែលនៅដាច់ឡែកពីគេក៏បាន ជឿថាការយាងមករបស់ព្រះអង្គសង្គ្រោះគឺជិតដល់ហើយដែរ។

បីឆ្នាំបន្ទាប់ពីលោកមិល្លើរបានបកស្រាយបទទំនាយរបស់គាត់មក បណ្ឌិតយ៉ូសែប វុហ្វដែលជា «បេសកជននៃពិភពលោក» ក៏បានចាប់ផ្តើមប្រកាសពីការយាងមកនៅពេលបន្តិចទៀតរបស់ព្រះអម្ចាស់។ លោកបានកើតនៅក្នុងប្រទេសអាល្លឺម៉ង់ មានឪពុកម្តាយជាសាសន៍ហេព្រើរ កាលគាត់នៅពីតូចគាត់បានជឿច្បាស់នូវសេចក្តីពិតនៃសាសនាព្រះគ្រីស្ទ។ គាត់ចូលចិត្តស្តាប់ការសន្ទនាគ្នាក្នុងផ្ទះរបស់ឪពុកគាត់ នៅពេលពួកសាសន៍ហេព្រើរដែលជឿស៊ប់ជួបជុំគ្នា ដើម្បីដំណាលពីសេចក្តីសង្ឃឹមនៃប្រជាជនខ្លួន ពីសិរីល្អនៃព្រះមែស្ស៊ីដែលកំពុងយាងមក និងពីការកែលម្អឡើង ក៏សួរថាទ្រង់ជានរណា។ «ជាសាសន៍ជូវដ៏មានអំណោយទានយ៉ាងខ្លាំងអស្ចារ្យម្នាក់» ជាចម្លើយ «ប៉ុន្តែ នៅពេលទ្រង់ធ្វើពុតជាព្រះមែស្ស៊ី នោះសាលាកាត់ក្តីជូវក៏កាត់ទោសទ្រង់ដល់ស្លាប់»។

«ហេតុអ្វី» កុមារសួរបន្តែមទៀត «បានជាក្រុងយេរូសាឡិមត្រូវបានហិនហោច ហើយហេតុអ្វីបានជាយើងស្ថិតនៅក្នុងភាពជាឈ្លើយដូច្នេះ?»

«ឱកូនអើយ!» ឪពុកគាត់ឆ្លើយ «ពីព្រោះពួកជូវបានសម្លាប់ហោរាទាំងឡាយណាកូន»។ គំនិតមួយបានលេចឡើងភ្លាមដល់កុមារថា៖

«ប្រហែលព្រះយេស៊ូវជាហោរាដែរទេដឹង ហើយពួកជូវបានសម្លាប់ទ្រង់ដែលគ្មានទោសសោះ»។ ទោះជាគេហាមដាច់ខាតមិនឱ្យចូលព្រះវិហារគ្រីស្ទានក៏ដោយ កុមារតែងតែលួចស្តាប់ការអធិប្បាយពីខាងក្រៅ។ ពេលមានអាយុត្រឹមតែប្រាំពីរឆ្នាំប៉ុណ្ណោះ កុមារបានអួតអាងដល់អ្នកគ្រីស្ទានដែលជាអ្នកជិតខាងម្នាក់ពីជ័យជម្នះនាអនាគតកាលរបស់ប្រទេសអ៊ីស្រាអែលនៅពេលព្រះមែស្ស៊ីយ៉ាងមកវិញ។ព្រឹទ្ធាចារ្យក៏តបមកវិញដោយស្រទន់ថា៖ «ចៅអើយ តានឹងប្រាប់ឯងថានរណាជាព្រះមែស្ស៊ីពិតនោះ៖ ទ្រង់ជាព្រះយេស៊ូវនៃស្រុកណាសារ៉ែត...ដែលដូនតាឯង បានឆ្កាង ណាចៅ...ចូរ ទៅផ្ទះ ហើយអានគម្ពីរអេសាយជំពូក៥៣ទៅ នោះឯងនឹងជឿច្បាស់ថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រារបស់ព្រះហើយ»។[9]

<u>ចន្ទ-១៩ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ១៣

ខព្រះគម្ពីរប្រចាំថ្ងៃ:*ពីព្រោះ ឯព្រះបន្ទូលនៃព្រះរស់នៅ ហើយពូកែផង ក៏មុតជាងដាវណាមានមុខ២ ទាំងធ្លុះចូលទៅ ទាល់តែកាត់ព្រលឹង និងវិញ្ញាណ ហើយសន្លាក់ និងខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិត ដែលចិត្តគិត ហើយដែលសំរេចដែរ។ ហេព្រើរ ៤:១២*

កុមារក៏បានត្រឡប់ទៅផ្ទះហើយអានបទគម្ពីរ។ ឃើញថា ព្រះយេស៊ូវនៃស្រុកណាសារ៉ែតបានសម្រេចបទទំនាយយ៉ាងឥតខ្ចោះ។ តើពាក្យពេចន៍នៃពួកគ្រីស្ទានទាំងឡាយនោះពិតឬ? កុមារបានសួរឪពុកឱ្យពន្យល់ពីបទទំនាយ ប៉ុន្តែ បានជួបប្រទះនឹងសេចក្តីស្ងប់ស្ងាត់បែបមិនស្រួលទៅវិញ ប្រុសតូចក៏លែងហ៊ានលើកសំដៅទៅរឿងនោះទៀតតាំងពីពេលនោះមក។

នៅពេលអាយុបានដប់មួយឆ្នាំ កុមារបានចេញពីសំបុកទៅក្នុងលោកខាងក្រៅ ទៅរៀនសូត្រដើម្បីជ្រើសរើសសាសនា និងកិច្ចការប្រចាំជីវិតរបស់ខ្លួន។ មានតែខ្លួនមួយ ហើយឥតប្រាក់កាសមួយរៀលសោះ កុមារត្រូវតែពុះពារ។ គាត់បានសិក្សាដោយយកចិត្តទុកដាក់ ហើយចិញ្ចឹមជីវិត

ដោយបង្រៀនភាសាហេព្រើរ។ គាត់ក៏បានជឿជំនឿកាតូលិករ៉ូម ហើយក៏ទៅបន្តការសិក្សានៅមហាវិទ្យាល័យយោសនាការនាក្រុងរ៉ូម។ នៅទីនេះ គាត់ បានចោទប្រកាន់ដល់សេចក្តីរំលោភនៃព្រះវិហារ ហើយទទូចឱ្យមានការកែទម្រង់។ មិនយូរប៉ុន្មាន គេក៏ដកគាត់ចេញ។ ឃើញថាគាត់នឹងមិនចុះចូល ដល់ចំណងនៃលទ្ធិរ៉ូមនិយមជាដាច់ខាត។ គេបានប្រកាសថាគាត់ជាមនុស្សហួសពីកែច្នៃទៅហើយ ហើយឱ្យទៅណាស្រេចតែទំនើងចិត្តខ្លួនចុះ។ គាត់ក៏ចាកចេញទៅប្រទេសអង់គ្លេស ហើយចូលរួមជាមួយវិហារអង់គ្លេស។ បន្ទាប់ពីបានសិក្សាពីរឆ្នាំហើយ គាត់ក៏ចេញទៅធ្វើបេសកកម្មក្នុងឆ្នាំ ១៨២១។

លោកវុហ្វបានឃើញថា បទទំនាយទាំងឡាយបើកសម្តែងអំពីដំណើរ យាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ ដោយអំណាច និងសេចក្តីរុងរឿង។ កាលគាត់ស្វះស្វែងដឹកនាំប្រជាជនរបស់គាត់ឱ្យស្គាល់ព្រះយេស៊ូវនៃស្រុកណាសារ៉ែតថាជាព្រះតាមសេចក្តីសន្យាដើម្បីបង្ហាញពួកគេពីដំណើរយាងមកជាលើកទីមួយថាជាយញ្ញបូជាលោះបាបនោះ គាត់ក៏បង្ហាត់បង្រៀនពួកគេពីការយាងមកជាលើកទីពីរផងដែរ។

លោកវុហ្វជឿថា ការយាងមកនៃព្រះអម្ចាស់គឺជិតដល់ហើយ។ ការបកស្រាយពីអំឡុងពេលនៃបទទំនាយរបស់គាត់ គឺខុសគ្នាតែពីរបីឆ្នាំទៅនឹងពេលវេលាដែលលោកមិល្លើរបានទូទាត់ប៉ុណ្ណោះ។ «តើព្រះអម្ចាស់របស់យើង...មិនប្រទានទីសម្គាល់នៃពេលវេលា ប្រយោជន៍ឱ្យយើងដឹង យ៉ាងហោចណាស់ពីការដែលទ្រង់យាងមក ដូចជាការដែលយើងដឹងពីដំណើរចូលខែប្រាំង ឬពេលដើមល្ងាររុះស្លឹកទេឬអ្វី? ទីសម្គាល់នៃពេលវេលាអាចប្រាប់ឱ្យដឹងគ្រប់គ្រាន់ហើយ ដើម្បីទាក់ទាញយើងឱ្យរៀបចំសម្រាប់ការយាងមករបស់ទ្រង់ ដូចជាលោកណូអេរៀបចំទូកដូច្នោះដែរ»។[២]

ចំណាស់ឆឹងការបកស្រាយដែលគេនិយម

លោកវុហ្វបានសរសេរពីប្រព័ន្ធបកស្រាយបទគម្ពីរដែលគេនិយមនោះថា៖ «ព្រះវិហារភាគច្រើនបានងាកចេញពីភាពងាយស្រួលយល់នៃគម្ពីរហើយ...បើគេអានពាក្យថា សាសន៍ជូវ គេត្រូវយល់ថាជាសាសន៍ដទៃ ពេលគេអានពាក្យយេរូសាឡិម គេត្រូវយល់ថាជាព្រះវិហារ ហើយបើនិយាយសំដៅទៅផែនដី មានន័យថា មេឃទៅវិញ ចំណែកឯដំណើរយាងមករបស់ព្រះអម្ចាស់ គេត្រូវយល់ថាជាការចម្រើនលូតលាស់នៃសង្គមបេសកកម្ម ហើយការឡើងភ្នំដ៏ជាទីសំណាក់របស់ព្រះតំណាងការជួប ជុំនៃពួកមេថូឌីសត៍ក្នុងមួយក្រុមធំទៅវិញ»។[៣]

ចាប់ពីឆ្នាំ១៨២១ ដល់១៨៤៥ លោកវុហ្វបានធ្វើដំណើរក្នុងប្រទេសអេស៊ីព្ទ អាប៊ីសនា ប៉ាលេស្ទីន ស៊ីរ៉ា ពើស៊ី បុក្ខារ៉ា ឥណ្ឌា និងសហរដ្ឋអាមេរិក។

អំណាចក្នុងសៀវភៅ

បណ្ឌិតវុហ្វបានធ្វើដំណើរក្នុងប្រទេសភាគច្រើនដែលសំបូរគ្រោះថ្នាក់ ដោយគ្មានអ្វីការពារខ្លួនសោះ ដោយស៊ូទ្រាំនឹងភាពលំបាក និងគ្រោះថ្នាក់យ៉ាយីរាប់មិនអស់។ គាត់បានអត់ឃ្លាន ត្រូវគេយកទៅលក់ជាខ្ញុំកញ្ជះគេ គេកាត់ទោសដល់ស្លាប់បីដង បៀតបៀនដោយពួកចោរ ហើយជួនកាលស្ទើរតែនឹងស្លាប់ដោយសម្រេកទៀតផង។ មានម្តងនោះគេបានសម្រាតគាត់ឱ្យដើររាប់រយគីឡូម៉ែត្រដោយជើងទទេកាត់ព្រៃភ្នំ មានទឹកកកធ្លាក់ជះលើមុខគាត់ ហើយបាទជើងទទេក៏ស្ពឹកដោយដីដ៏ត្រជាក់ស្រឹប។

នៅពេលគេហាមមិនឱ្យចេញដំណើរក្នុងចំណោមពួកកុលសម្ព័ន្ធកាចសាហាវ ដោយឥតមានអ្វីការពារខ្លួន គាត់បានពោលថាគាត់ «បានប្រដាប់ អាវុធសព្វគ្រប់ក្នុងខ្លួនហើយ» គឺ «សេចក្តីអធិស្ឋានសេចក្តីមោះមុតសម្រាប់ ព្រះគ្រីស្ទ និងទំនុកចិត្តក្នុងជំនួយរបស់ទ្រង់»។ «ខ្ញុំក៏ប្រដាប់ដោយសេចក្តីស្រឡាញ់របស់ព្រះ និងរបស់អ្នកជិតខាងរបស់ខ្ញុំនៅក្នុងចិត្តខ្ញុំ

ហើយព្រះគម្ពីរ គឺនៅក្នុងដៃខ្ញុំ»។ «ខ្ញុំមានអារម្មណ៍ថាអំណាចរបស់ខ្ញុំគឺនៅក្នុងសៀវភៅ ហើយឥទ្ធិពលរបស់សៀវភៅនោះនឹងទ្រទ្រង់ខ្ញុំ»។[៤]

<u>អង្គារ-២០ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ១៤

ខព្រះគម្ពីរប្រចាំថ្ងៃ:*ឯហោណុក ជាដំណទី៧ពីលោកអ័ដាមមក គាត់បានទាយពីមនុស្សទាំងនោះថា មើល ព្រះអម្ចាស់ទ្រង់យាងមក នៅកណ្តាលពួកបរិសុទ្ធទ្រង់ទាំងសល់សែន ។ យូដាស ខ:១៤*

គាត់បានតស៊ូរហូតដល់ដំណឹងបាននាំទៅដល់ទឹកដីជាច្រើន។ គាត់បានចែកចាយព្រះបន្ទូលរបស់ព្រះជាភាសាដទៃ ក្នុងចំណោមពួកជូវ ពួកទួរគី ពួកជាស៊ី ពួកព្រហ្មញ្ញ និងជាតិសាសន៍ដទៃទៀត។ ហើយនៅគ្រប់ទីកន្លែង គាត់បានផ្សព្វផ្សាយពីការយាងមកវិញជាឆាប់របស់ព្រះមែស្ស៊ី។

នៅប្រទេសបុក្ខារ៉ា គាត់បានឃើញប្រជាជនដែលនៅដាច់ឡែកពីគេនេះ កាន់គោលលទ្ធិនៃការយាងមកដ៏ឆាប់ៗនៃព្រះអម្ចាស់។ គាត់មានប្រសាសន៍ ថាពួកអារ៉ាប់នៃប្រទេសយេម៉ែន «មានសៀវភៅមួយឈ្មោះ សៀរ៉ា ដែលប្រាប់ ពីការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ និងការសោយរាជ្យក្នុងភាពរុងរឿង ហើយគេសង្ឃឹមថានឹងមានព្រឹត្តិការណ៍ដ៏អស្ចារ្យកើតឡើងក្នុង ឆ្នាំ១៨៤០»។ «ខ្ញុំឃើញពួកកូនចៅអ៊ីស្រាអែល កូនចៅនៃកុលសម្ពន្ធរបស់ដែន...ដែលសង្ឃឹមរង់ចាំជាមួយនឹងកូនចៅរបស់រីឆាបនូវការយាងត្រឡប់មកវិញយ៉ាងឆាប់រហ័សនៃព្រះមែស្ស៊ីក្នុងពពកនៃស្ថានសួគ៌»។[៥]

បេសកជនម្នាក់បានរកឃើញអ្នកកាន់ជំនឿស្រដៀងគ្នានេះដែរ ក្នុងប្រទេសថាថារី (Tatary)។ សង្ឃជនជាតិថាថារ (Tatar) មួយអង្គបានសួរពីពេលវេលានៃព្រះគ្រីស្ទនឹងយាងមកជាលើកទីពីរ។ នៅពេលបេសកជនឆ្លើយថាគាត់ពុំដឹងពីពេលវេលានោះទេ សង្ឃក៏ភ្ញាក់ផ្អើលចំពោះអវិជ្ជានៃគ្រូគម្ពីរនេះ ហើយក៏ដំណាលជំនឿរបស់ខ្លួនដែលស្ថិតនៅលើបទទំនាយ ថាព្រះគ្រីស្ទនឹងយាងមកប្រហែលក្នុងឆ្នាំ១៨៤៤។

ដំណឹងនៃការនិវត្តនៅប្រទេសអង់គ្លេស

ដំណឹងនៃការយាងមកត្រូវបានចាប់ផ្តើមផ្សព្វផ្សាយនៅប្រទេសអង់គ្លេស តាំងតែពីដើមឆ្នាំ១៨២៥ម្ល៉េះ។ គេពុំបានបង្រៀនជាទូទៅអំពីពេលវេលាពិតប្រាកដនៃការយាងមកនោះទេ ប៉ុន្តែ ការពិតនៃការដែលព្រះគ្រីស្ទយាងមកជាឆាប់ដោយព្រះចេស្តា និងសេចក្តីរុងរឿងនោះ ត្រូវបានប្រកាសផ្សាយយ៉ាងឱឡារិក។ អ្នកនិពន្ធអង់គ្លេសម្នាក់បានថ្លែងថា គ្រូគង្វាលរបស់វិហារនៃអង់គ្លេសប្រហែល៧០០នាក់ បានខ្នះខ្នែងក្នុងការផ្សាយ «ដំណឹងល្អនេះ ដែលសម្តែងពីនគរ» ព្រះ។

ដំណឹងដែលចង្អុលទៅឆ្នាំ១៨៤៤ ថាជាពេលវេលានៃការយាងមករបស់ព្រះគ្រីស្ទ ក៏ត្រូវបានផ្សាយក្នុងចក្រភពអង់គ្លេសដែរ។ ការបោះពុម្ពផ្សាយចេញពីសហរដ្ឋអាមេរិកអំពីការនិវត្ត ក៏ត្រូវបានចែកចាយពាសពេញដែរ។ ក្នុងឆ្នាំ១៨៤២ លោករ៉ប់បិត វិនធើរ ដែលជាសាសន៍អង់គ្លេសម្នាក់ បានត្រឡប់ទៅមាតុប្រទេសខ្លួនវិញ ដើម្បីផ្សាយពីដំណើរយាងមកនៃព្រះអម្ចាស់ បន្ទាប់ពីគាត់បានទទួលជឿជំនឿនិវត្តន៍នៅប្រទេសអាមេរិកហើយ។ មនុស្សជាច្រើនបានរួបរួមជាមួយនឹងគាត់ក្នុងកិច្ចការនេះ នៅទីកន្លែងផ្សេងៗទៀតនៃប្រទេសអង់គ្លេស។

ក្នុងអាមេរិកខាងត្បូង នៅរដ្ឋឡាយ្ងនសា មានសាសន៍អេស្ប៉ាញ៉ុលម្នាក់ដែលជាសមាជិកនៃក្រុមជេស៊ូត បានជឿដល់សេចក្តីពិតនៃការយាងមកវិញដ៏ឆាប់រហ័សនៃព្រះគ្រីស្ទ។ ដោយមានចំណង់ចង់គេចពីការតិះដៀលរបស់រ៉ូម គាត់ក៏បោះពុម្ពសៀវភៅមួយ ដោយប្រើឈ្មោះក្លែងក្លាយថា រ៉ាប់ប៊ី បិនអេសរ៉ា តំណាងខ្លួនធ្វើជាជនជាតិជូវដែលប្រែចិត្តជឿដល់គ្រីស្ទសាសនា។ លុះប្រហែលឆ្នាំ១៨២៥ គេបានបកប្រែសៀវភៅគាត់ទៅជាភាសាអង់គ្លេស។ សៀវភៅនេះបានធ្វើឱ្យមនុស្សដែលបានភ្ញាក់រឭកនៅប្រទេសអង់គ្លេស មានការចាប់ចិត្តកាន់តែខ្លាំងឡើង។

គម្ពីរវិវរណៈបើកសម្តែងដល់លោកបិនដែល

នៅប្រទេសអាល្លឺម៉ង់ លោកបិនដែលដែលជាគ្រូគង្វាលនៃគណៈលូធើរិន និងជានិស្សិតខាងព្រះគម្ពីរ បានបង្ហាត់បង្រៀនអំពីគោលលទ្ធិ។ កាលកំពុងព្រោងសេចក្តីអធិប្បាយចេញពីគម្ពីរវិវរណៈជំពូក២១ ពន្លឺនៃដំណើរយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ ក៏ចាំងជះចូលក្នុងគំនិតគាត់។ បទទំនាយ នៃគម្ពីរវិវរណៈបានបើកសម្តែងឱ្យគាត់យល់។ ដោយអស្ចារ្យពន់ពេកចំពោះសារៈសំខាន់ និងភាពរុងរឿងនៃទស្សនីយភាពទាំងឡាយដែលហោរាបានបរិយាយ គាត់ក៏ត្រូវងាកចេញពីរឿងនេះមួយរយៈសិន។ កាលកំពុងអធិប្បាយស្រាប់តែទស្សនីយភាពនេះបានលេចឡើងយ៉ាងច្បាស់ក្រឡែតដល់គាត់ម្តងទៀត។ តាំងពីពេលនោះមក គាត់ក៏តាំងចិត្តសិក្សាបទទំនាយ ហើយក្រោយមកបានជឿថា ការយាងមករបស់ព្រះគ្រីស្ទគឺជិតដល់ហើយ។ ថ្ងៃទីដែលគាត់បានកំណត់ថាជាពេលវេលានៃការនិវត្តជាលើកទីពីរ គឺមិនហួសពីពីរឬបីឆ្នាំដែលលោកមិល្លើរកំណត់ទុកដែរនោះទេ។

សំណេររបស់លោកបិនដែលបានឮសុសសាយក្នុងរដ្ឋវើតថិមបឺករបស់គាត់ និងផ្នែកនានានៃប្រទេសអាល្លឺម៉ង់។ ដំណឹងនៃការនិវត្តត្រូវបានឮនៅប្រទេសអាល្លឺម៉ង់ ក្នុងពេលដំណាលគ្នាដែលគេកំពុងចាប់អារម្មណ៍នៅទឹកដីផ្សេងៗទៀត។

<u>ពុធ-២១ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ១៥

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដើម្បីនឹងកាត់ទោសដល់គ្រប់មនុស្សទាំងឡាយ ហើយនិងរំឭកពួកទមិលល្មើសទាំងអម្បាលម៉ាន ឲ្យដឹងខ្លួនពីគ្រប់ទាំងការទមិលល្មើស ដែលគេបានប្រព្រឹត្តធ្វើ ដោយចិត្តល្មើស ហើយពីអស់ទាំងសេចក្តីរឹងទទឹងទាំងប៉ុន្មាន ដែលអស់ពួកទមិលល្មើសដ៏មានបាបទាំងនោះ បានពោលទាស់នឹងទ្រង់។ យូដាស ខ:១៥*

នៅរដ្ឋហ្សឺណែវ លោកហ្គ័រសិនអធិប្បាយពីការនិវត្តជាលើកទីពីរ។ នៅពេលគាត់ចាប់ផ្តើមធ្វើជាគ្រូគង្វាល គាត់បានស្ថិតក្នុងភាពសង្ស័យ។ ក្នុងយុវវ័យ គាត់បានក្លាយជាចាប់ចិត្តនឹងបទទំនាយ។ បន្ទាប់ពីអានសៀវភៅប្រវត្តិសាស្ត្របុរាណ របស់លោកវ៉ូលិនចប់ហើយ គាត់ក៏បានផ្តោតអារម្មណ៍ទៅលើគម្ពីរដានីយ៉ែលជំពូក២ម្តង។ គាត់បានកោតស្ងប់ស្ងែងនឹងទំនាយដែលទស្សន៍ទាយត្រូវទាំងអស់។ នេះជាទីបន្ទាល់នៃបទគម្ពីរស្តីពីការសណ្ឋិតដោយព្រះវិញ្ញាណ។ ការនិយមវែកញែករកហេតុផល ពុំបានធ្វើឱ្យគាត់ស្កប់ចិត្តទេ ហើយដោយការសិក្សាព្រះគម្ពីរ គាត់ក៏បានឈានដល់ជំនឿដ៏ល្អប្រពៃមួយ។

ការសិក្សាបង្ហាញដល់គាត់ថា ការយាងមករបស់ព្រះអម្ចាស់គឺកៀកហើយ។ ដោយរំភើបចិត្តនឹងភាពសំខាន់នៃសេចក្តីពិតនេះ គាត់ក៏ចង់ចែកចាយដល់មនុស្សម្នាទាំងឡាយដែរ។ ប៉ុន្តែ ជំនឿដែលគេនិយមជឿថាទំនាយនៃដានីយ៉ែលមិនអាចយល់បាននោះ គឺជាឧបសគ្គដ៏ធំមួយ។ ដូចជាលោកហ្វាវ៉ែលដែលបានផ្សព្វផ្សាយមុនគាត់នៅឯរដ្ឋហ្សឺណែវនោះដែរ គាត់តាំងចិត្តថានឹងចាប់ផ្តើមជាមួយពួកកុមារ សង្ឃឹមថាពួកគេនឹងធ្វើឱ្យឪពុកម្តាយចាប់ចិត្ត។ គាត់មានប្រសាសន៍ថា «ខ្ញុំប្រមូលហ្វូងកុមារមួយក្រុម កាលបើក្រុមនោះរីកធំឡើង ឬបើមើលទៅឃើញថាពួកកុមារស្តាប់ រីករាយចិត្ត ឬចាប់ចិត្ត ឬយល់ហើយពន្យល់មកវិញនូវអ្វីដែលគេបានរៀន នោះខ្ញុំដឹងជាប្រាកដថានឹងកើតមានក្រុមមួយទៀតមិនយូរមិនឆាប់ ហើយជាលទ្ធផលមនុស្សពេញវ័យនឹងឃើញថាជាការចំណេញមួយដែរក្នុងការចំណាយពេលសិក្សា។ នៅពេលការនេះបានសម្រេចសព្វគ្រប់ហើយ នោះនឹងរាប់ថាជាគួរ»។[៦]

ពេលគាត់ដំណាលប្រាប់ពួកកុមារ មនុស្សចាស់ៗបានមកស្តាប់ផងដែរ។ ទីធ្លាខាងក្រោយវិហារ បានពេញដោយអ្នកស្តាប់ អ្នកមានបុណ្យស័ក្តិ និងតម្រិះវិជ្ជា ជនចម្លែក និងទេសចរបរទេសដែលមកលំហែកំសាន្តក្នុងរដ្ឋ

ហ្សឺណែវ។ ម្ល៉ោះហើយដំណឹងក៏ឮដល់ផ្នែកនានាទៀត។

មើលទៅឃើញថាល្អហើយ លោកហ្គ័រសិនក៏បោះពុម្ពមេរៀនរបស់គាត់ ដោយសង្ឃឹមថានឹងលើកទឹកចិត្តឱ្យមនុស្សសិក្សាសៀវភៅទំនាយទាំងឡាយ។ ក្រោយមកគាត់បានធ្វើជាគ្រូក្នុងសាលាសាសនាមួយ ហើយនៅថ្ងៃអាទិត្យគាត់បន្តការងារជាអ្នកបង្ហាត់បង្រៀនដល់កុមារាកុមារីពីបទគម្ពីរ។ ពីកៅអីសាស្ត្រាចារ្យ តាមរយៈសារព័ត៌មាន និងក្នុងនាមជាគ្រូបង្រៀនកុមារ គាត់បានធ្វើជាឧបករណ៍អស់រាប់ឆ្នាំ ក្នុងការអំពាវនាវហៅមនុស្សជាច្រើនមកឯបទទំនាយ ដែលបង្ហាញថា ការយាងមករបស់ព្រះអម្ចាស់គឺជិតដល់ហើយ។

កុមារផ្សាយដំណឹងនៃប្រទេសស្កែនឌីណេវី

នៅប្រទេសស្កែនឌីនេវី ដំណឹងនៃការនិវត្តក៏ត្រូវបានប្រកាសផ្សាយដែរ។ ជនជាច្រើនបានលន់តួបាបនិងលះបង់នូវអំពើបាបរបស់ខ្លួនចោល ហើយទូលអង្វរករសូមការលើកលែងទោសក្នុងព្រះនាមនៃព្រះគ្រីស្ទ។ ប៉ុន្តែក្រុមគ្រូគង្វាលនៃព្រះវិហារប្រចាំរដ្ឋបានជំទាស់នឹងចលនានេះ ហើយអ្នកដែលផ្សាយដំណឹងខ្លះនោះ ត្រូវគេចាប់ដាក់គុកទៀតផង។

នៅកន្លែងជាច្រើន ដែលអ្នកផ្សាយដំណឹងពីការយាងមករបស់ព្រះអម្ចាស់ដ៏ឆាប់ ត្រូវបានគេហាមឃាត់ ព្រះទ្រង់សព្វព្រះទ័យនឹងផ្សាយដំណឹងតាមរយៈក្មេងតូចៗវិញ។ រដ្ឋមិនអាចឃាត់ឃាំងពួកគេបានទេ ព្រោះគេមិនទាន់គ្រប់អាយុ ដូច្នេះគេអាចផ្សាយដោយគ្មាននរណាព្យាបាទឡើយ។

ក្នុងទីលំនៅដ៏ខ្សត់ក្រទាំងឡាយនៃពួកកម្មករ ប្រជាជនបានជុំគ្នាដើម្បីស្តាប់ការព្រមាន។ ក្មេងផ្សាយដំណឹងខ្លះមានអាយុមិនលើសពីប្រាំមួយទៅប្រាំបីឆ្នាំទេ ហើយក្នុងពេលដែលជីវិតរបស់គេធ្វើទីបន្ទាល់ថាគេស្រឡាញ់ព្រះអង្គសង្គ្រោះនោះ គេបង្ហាញបញ្ញា និងសមត្ថភាពដែលក្មេងចំណាស់នោះមានប៉ុណ្ណោះ។ ពេលឈរនៅចំពោះមនុស្សម្នាវិញ គេបានប្រកប ដោយឥទ្ធិពលហួសពីអំណោយទានធម្មជាតិរបស់ខ្លួន។ សូរស័ព្ទ

និងអាកប្បកិរិយាត្រូវបានកែប្រែ ហើយគេបានស្រែកព្រមានពីការជំនុំជម្រះដោយអំណាចដ៏ម៉ឺងម៉ាត់ថា៖ «ចូរកោតខ្លាចព្រះហើយសរសើរសិរីល្អរបស់ទ្រង់ចុះ ដ្បិតពេលដែលទ្រង់ត្រូវជំនុំជម្រះនោះ បានមកដល់ហើយ»។

មនុស្សទាំងឡាយបានឮទាំងញាប់ញ័រ។ ព្រះវិញ្ញាណរបស់ព្រះបានខ្សឹបដល់ចិត្តគេ។ មនុស្សជាច្រើនបានបែរទៅស្រាវជ្រាវបទគម្ពីរ ពួកអ្នកឥតប្រមាណខ្លួន និងមនុស្សឥតសីលធម៌បានកែខ្លួន ហើយកិច្ចការនេះបានសម្រេចយ៉ាងអស្ចារ្យបំផុត សូម្បីតែពួកគ្រូគង្វាលនៃវិហារប្រចាំរដ្ឋក៏ទប់ខ្លួនមិនបាន ត្រូវតែទទួលស្គាល់ថាព្រះបានដាក់ព្រះហស្តទ្រង់ក្នុងចលនានេះ។

ជាព្រះហឫទ័យរបស់ព្រះ ដែលដំណឹងនៃការយាងមករបស់ព្រះអង្គសង្គ្រោះត្រូវបានផ្សព្វផ្សាយក្នុងប្រទេសស្កែនឌីនេវីនោះ ហើយទ្រង់ប្រទានព្រះវិញ្ញាណរបស់ទ្រង់ក្នុងកុមារទាំងឡាយ ដើម្បីឱ្យការងារបានសម្រេច។ នាកាលដែលព្រះយេស៊ូវបានយាងមកជិតក្រុងយេរូសាឡិមហើយនោះ ពួកបណ្តាជនឈប់ស្រែកអបអរសាទរនៅពេលគេចូលទ្វារក្រុង ព្រោះខ្លាចពួកសង្ឃ និងពួកអ្នកគ្រប់គ្រង។ ប៉ុន្តែ កុមារាកុមារីទាំងឡាយដែលនៅក្នុងទីធ្លាព្រះវិហារនោះ នៅតែបន្ទរឡើងថា «ហូសាណាដល់ព្រះរាជ្យហ្លួងដាវីឌ»។ ម៉ាថាយ ២១:៨-១៦។ ដូចជាព្រះប្រកបការងារតាមរយៈកូនក្មេងនៅពេលព្រះគ្រីស្ទយាងមកជាលើកទីមួយនោះ ទ្រង់ក៏ប្រកបការងារតាមរយៈពួកគេក្នុងការផ្សាយដំណឹងនៃការនិវត្តជាលើកទីពីរដែរ។

<u>ព្រហស្បត៍-២២ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ១៦

ខព្រះគម្ពីរប្រចាំថ្ងៃ: *ទេវតានោះបន្លឺសំឡេងយ៉ាងខ្លាំងថា ចូរកោតខ្លាចដល់ព្រះ ហើយសរសើរសិរីល្អរបស់ទ្រង់ចុះ ដ្បិតពេលដែលទ្រង់ត្រូវជំនុំជំរះនោះបានមកដល់ហើយ ចូរក្រាបថ្វាយបង្គំដល់ព្រះដ៏បង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងរន្ធទឹកទាំងប៉ុន្មានចុះ។ វិវរណៈ ១៤:៧*

ដំណឹងឮសុសសាយ

ប្រទេសអាមេរិកបានក្លាយទៅជាមជ្ឈមណ្ឌលនៃមហាចលនានិវត្ត។ សំណេររបស់លោកមិលើ្លរ និងគូកនរបស់គាត់ត្រូវបាននាំទៅទឹកដីឆ្ងាយៗ ទៅគ្រប់ទីកន្លែងណាដែលពួកបេសកជនអាចលុកលុយចូលក្នុងអស់ទាំងពិភពលោកបាន។ ដំណឹងដ៏អស់កល្បបានឮសុសសាយគ្រប់ទិសទី៖ «ចូរកោតខ្លាចព្រះ ហើយសរសើរសិរីល្អរបស់ទ្រង់ចុះ ដ្បិតពេលដែលទ្រង់ត្រូវជំនុំជម្រះនោះបានមកដល់ហើយ»។

បទទំនាយដែលហាក់បីដូចជាចង្អុលទៅការយាងមករបស់ព្រះគ្រីស្ទនៅរដូវផ្ការីកក្នុងឆ្នាំ១៨៤៤ បានដក់ជាប់ក្នុងគំនិតនៃបណ្តាមនុស្ស។ មនុស្សភាគច្រើនជឿថាការរែកញែកចេញពីអំឡុងពេលនៃបទទំនាយ គឺត្រឹមត្រូវហើយ ហើយដោយលះបង់អំនួតនៃមតិរបស់គេរៀងៗខ្លួនចោល គេក៏បានទទួលសេចក្តីពិតដោយអំណរ។ គ្រូគង្វាលខ្លះ លាមុខតំណែង និងចេញពីវិហាររបស់ខ្លួន ហើយរួបរួមគ្នាប្រកាសពីការយាងមករបស់ព្រះយេស៊ូវ។ យ៉ាងណាមិញ មានគ្រូគង្វាលតិចតួចណាស់ដែលទទួលជឿដល់ដំណឹងនេះ ដូច្នេះអ្នកជឿគឺសម្បូរតែជនសុភាពរាបសាទៅវិញ។ អ្នកកសិករចេញពីស្រែចម្ការរបស់ខ្លួន ជាងរថយន្តចោលគ្រឿងជូសជុល អ្នកលក់ដូរចោលទំនិញ ហើយជនមានមុខវិជ្ជាចោលតំណែងរបស់ខ្លួន។ គេស្ម័គ្រចិត្តទ្រាំទ្រនឹងពលកម្ម ការខ្វះមុខខ្វះក្រោយ និងការរងទុក្ខ ប្រយោជន៍ឱ្យគេអាចហៅមនុស្សឱ្យលន់តួបាបខ្លួន ដើម្បីឱ្យបានសង្គ្រោះ។ មនុស្សរាប់ពាន់នាក់បានទទួលជឿដល់សេចក្តីពិតនៃការនិវត្ត។

ខ្ចាយយល់បានធ្វើឱ្យគេខឿ

ដូចជាយ៉ូហាន បាទីស្ទដែរ ពួកផ្សាយដំណឹងបានដាក់ពូថៅនៅនឹងឫសឈើ ហើយក៏ហៅឱ្យមនុស្សទាំងអស់ឱ្យ «បង្កើតផលដែលសំណំានឹងសេចក្តីប្រែចិត្ត»។ ផ្ទុយពីការធានានូវសន្តិភាព និងសន្តិសុខ ដែលបន្លឺចេញពីតុអធិប្បាយល្បីៗនោះ ទីបន្ទាល់នៃបទគម្ពីរដ៏ងាយយល់ បានធ្វើឱ្យ

គេជឿជាក់ក្នុងចិត្ត ហើយមានតែអ្នកខ្លះទេដែលមិនព្រមជឿ។ មនុស្សភាគច្រើនបានស្វែងរកព្រះដោយមានចិត្តកែប្រែ។ អ្វីៗនៅផែនដីដែលគេស្រឡាញ់ជាយូរមកហើយនោះ ឥឡូវនេះ គេផ្តោតទៅលើស្ថានសួគ៌វិញម្តង។ គេបានចូលរួមស្រែកប្រកាសដោយចិត្តធូរស្រាល និងស្រទន់ថា៖ «ចូរកោតខ្លាចព្រះ ហើយសរសើរសិរីល្អ របស់ទ្រង់ចុះ ដ្បិតពេលដែលទ្រង់ត្រូវជំនុំជម្រះនោះ បានមកដល់ហើយ»។

អ្នកមានបាបសួរទាំងទឹកភ្នែកថា៖ «តើត្រូវធ្វើដូចម្តេចដើម្បីឱ្យខ្ញុំបានសង្គ្រោះ?» គឺអ្នកដែលធ្លាប់រៀចវេរអន្ទះអន្ទែងចង់កែតម្រង់ខ្លួនវិញ។ អស់អ្នកដែលរកឃើញសន្តិភាពក្នុងព្រះគ្រីស្ទ ក៏មានចិត្តចង់ឃើញអ្នកដទៃទទួលព្រះពរដែរ។ ចិត្តរបស់មាតាបិតាបានងឹងភ្នកដល់កូនរបស់ខ្លួន ហើយកូនដល់ឪពុកម្តាយខ្លួនវិញ។ ម៉ាឡាគី ៤:៥,៦។ រនាំងនៃសេចក្តីមានឫកខ្ពស់ និងសេចក្តីគុំកួនត្រូវបានរសាត់បាត់ទៅ។ ការសារភាពដ៏អស់ពីចិត្តក៏បានកើតឡើង។ មនុស្សបានអង្វរករដល់ព្រះគ្រប់ទីកន្លែង។ ភាគច្រើនបានខិតខំអធិស្ឋានអស់មួយយប់ ទូលសូមនូវការលើកលែងបាបទាំងឡាយរបស់ខ្លួន ឬទូលសូមឱ្យញាតិសន្តាន ឬអ្នកជិតខាងខ្លួនកែប្រែចិត្ត។

មនុស្សគ្រប់រណ្តៅ: អ្នកមាន និងអ្នកក្រ ខ្ពស់ និងទាប មានចិត្តក្តុកក្តួលចង់ស្តាប់នូវគោលលទ្ធិនៃការនិវត្តជាលើកទីពីរ។ ព្រះវិញ្ញាណរបស់ព្រះបានប្រទានអំណាចព្រះចេស្តាដល់សេចក្តីពិតរបស់ទ្រង់។ គេបានពិសោធវត្តមាននៃពួកទេវតាបរិសុទ្ធក្នុងការប្រជុំទាំងនេះ ហើយមានអ្នកប្រែចិត្តជឿរាល់ថ្ងៃ។ មនុស្សដ៏សន្ធឹកសន្ធាប់បានស្តាប់ដោយស្ងៀមស្ងាត់ដល់ពាក្យពេចន៍ដ៏មានន័យ។ ស្ថានសួគ៌ និងផែនដីហាក់បីដូចជាតម្រង់រកគ្នា។ បណ្តាមនុស្សត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ ដោយច្រៀងសរសើរជាប់នៅនឹងមាត់ ធ្វើឱ្យរាត្រីដ៏ស្ងប់ស្ងាត់បានពោរពេញទៅដោយសូរសៀវភៅដ៏ពីរោះ។ គ្មាននរណាម្នាក់ដែលបានអញ្ជើញទៅប្រជុំហើយ អាចភ្លេចទស្សនីយភាពដ៏ចាប់ចិត្តពេកក្រៃនោះឡើយ។

ខព្រះគម្ពីរប្រចាំថ្ងៃ:*មើល មុនដែលថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចរបស់ព្រះយេហូវ៉ាបានមកដល់ នោះអញនឹងចាត់អេលីយ៉ា ឲ្យមកឯឯងរាល់គ្នា លោកនឹងបង្វែរចិត្តពួកឪពុកមកឯកូន និងចិត្តកូនមកឯឪពុកវិញ ក្រែងអញមកវាយផែនដីដោយសេចក្ដីបណ្ដាសា។។ ម៉ាឡាគី ៤:៥-៦*

គេដំទាស់ដំណឹង

ការប្រកាសពេលកំណត់សម្រាប់ដំណើរយាងមករបស់ព្រះគ្រីស្ទ បានធ្វើឱ្យមានសេចក្តីជំទាស់ជាខ្លាំង ពីមនុស្សភាគច្រើននៃវណ្ណៈទាំងអស់ ពីគ្រូគង្វាលទៅដល់អ្នកមានបាបដ៏ឥតញញើតនឹងព្រះ។ ភាគច្រើនបានថ្លែងថា គេឥតជំទាស់នឹងគោលលទ្ធិនៃការនិរ្វត្តជាលើកទីពីរទេ គេគ្រាន់តែជំទាស់នឹងពេលកំណត់ប៉ុណ្ណោះ។ ប៉ុន្តែ ព្រះនេត្រដ៏ទតឃើញគ្រប់ទីកន្លែង របស់ព្រះ អាចមើលឃើញចិត្តរបស់គេ។ ពួកគេមិនចង់ឮពីការយាងមករបស់ព្រះគ្រីស្ទ ដើម្បីជំនុំជម្រះពិភពលោកដោយភាពសុចរិតទេ ព្រោះកិច្ចការរបស់គេមិនបានជាគួរដល់ព្រះដែលញាណដឹងចិត្តមនុស្សសព្វអន្លើ ម្ល៉ោះហើយបានខ្លាចជួបព្រះអម្ចាស់របស់ខ្លួន។ ដូចជាពួកជូវនាពេលព្រះគ្រីស្ទវិរត្តមកជាលើកទីមួយនោះដែរ ពួកគេពុំចង់ស្វាគមន៍ព្រះយេស៊ូវទេ។ ពួកគេមិនគ្រាន់ តែបដិសេធមិនព្រមស្តាប់សេចក្តីពន្យល់ដ៏ងាយយល់អំពីព្រះគម្ពីរទេ តែបែរទៅជាចំអកឱ្យអ្នកដែលទន្ទឹងចាំព្រះអម្ចាស់ទៅវិញ។ សាតាំងបានចាក់រុក ដល់ព្រះគ្រីស្ទថារាស្ត្រដែលអះអាងថាដើរតាមទ្រង់ មិនសូវស្រឡាញ់ទ្រង់ទេ បានជាគេមិនចង់ឱ្យទ្រង់យាងមក។

គេតែងតែលើកឡើងថា «គ្មាននរណាដឹងពីថ្ងៃ ឬម៉ោងឡើយ» ដើម្បីយកមកបដិសេធជំនឿនិរ្វត្ត។ បទគម្ពីរចែងដូច្នេះ៖ «ដ្បិតត្រង់ថ្ងៃ និងពេលកំណត់ នោះគ្មានអ្នកណាដឹងទេ ទោះទាំងពួកទេវតាដែលនៅស្ថានសួគ៌ក៏មិនដឹងដែរ ជ្រាបតែព្រះវរបិតានៃខ្ញុំប៉ុណ្ណោះ»។ ម៉ាថាយ ២៤:៣៦។ អ្នកដែល រង់ចាំព្រះអម្ចាស់បានពន្យល់ខនេះច្បាស់ជាងនេះទៅទៀត ហើយ

ការប្រើខនេះខុសរបៀបដោយពួកប្រឆាំង ក៏ត្រូវបានបង្ហាញយ៉ាងច្បាស់ដែរ។

ព្រះបន្ទូលណាមួយរបស់ព្រះអង្គសង្គ្រោះ មិនត្រូវប្រើដើម្បីបំបាត់ព្រះបន្ទូលមួយទៀតឡើយ។ ទោះជាគ្មាននរណាដឹងពីថ្ងៃ ឬម៉ោងនៃការយាងមករបស់ទ្រង់ក៏ដោយ យើងត្រូវដឹងថា តើកៀកពេលហើយ ឬនៅ។ ការបដិសេធ ឬមិនអើពើនឹងចង់ដឹងថាការនិវត្តរបស់ទ្រង់គឺជិតដល់ហើយនោះ គឺនឹងកើតគ្រោះថ្នាក់ដល់យើងដូចជាដល់ពួកអ្នកដែលនៅជំនាន់លោកណូអេដែរ ដែលគេមិនចង់ដឹងថាទឹកជំនន់នឹងធ្លាក់មកនៅពេលណា។ ព្រះគ្រីស្ទមានបន្ទូលថា៖ «បើឯងមិនចាំយាមទេ នោះអញនឹងមកឯងឯងដូចជាចោរ ហើយនឹងមិនដឹងជាវេលាណា ដែលអញមកឯងឯងឡើយ»។ វិវរណៈ ៣:៣។

សាវ័កប៉ុលបានមានប្រសាសន៍អំពីអ្នកយកចិត្តទុកដាក់ពីសេចក្តីព្រមានថា៖ «បងប្អូនអើយអ្នករាល់គ្នាមិនមែននៅក្នុងសេចក្តីងងឹត ឱ្យថ្ងៃនោះបានមកដល់អ្នករាល់គ្នាដូចជាចោរនោះទេ។ អ្នករាល់គ្នាសុទ្ធតែជាពួកនៃពន្លឺ ហើយជាពួកនៃថ្ងៃ»។ ថែស្សាឡូនីចទី១ ៥:២-៥។

ប៉ុន្តែ អ្នកដែលប្រាថ្នារកលេស ដើម្បីបដិសេធសេចក្តីពិត បានបិទត្រចៀករបស់ខ្លួនមិនព្រមស្តាប់សេចក្តីពន្យល់នេះ ហើយពាក្យថា «គ្មាននរណា ដឹងពីថ្ងៃ ឬម៉ោងឡើយ» បានឮនៅតែនឹងមាត់នៃពួកចំអកឡកឡឺយ និងទាំងអ្នកដែលអះអាងថាជាគ្រូគង្វាលរបស់ព្រះគ្រីស្ទ។ នៅពេលបណ្តាជនស៊ើបសួរផ្លូវឱ្យបានសង្គ្រោះ ពួកគ្រូសាសនាបានជ្រៀតខ្លួនចូលរវាងគេ និងសេចក្តីពិត ដោយបកស្រាយព្រះបន្ទូលរបស់ព្រះមិនឱ្យត្រឹមត្រូវ។

អ្នកដែលស៊ប់ជាងគេក្នុងវិហារ ច្រើនតែទទួលដំណឹងនោះមុនគេ។ ទីណាដែលក្រុមគ្រូគង្វាលមិនបានក្តោបក្តាប់បណ្តាជន ទីណាដែលគេស្រាវជ្រាវព្រះបន្ទូលរបស់ព្រះដោយខ្លួនឯង ទីនោះគោលលទ្ធិនៃការនិវត្តនឹងបានរកឃើញដោយគ្រាន់តែផ្ទៀងនឹងបទគម្ពីរប៉ុណ្ណោះ ដើម្បីឱ្យដឹងថាជា

អំណាចមកពីស្ថានសួគ៌មែន។

មនុស្សជាច្រើនត្រូវបានរវែងរវាន់ដោយសារប្តីប្រពន្ធ ឪពុកម្តាយ ឬកូនចៅផង ហើយគេបានធ្វើឱ្យពួកគេជឿថា ការស្តាប់ «លទ្ធិខុសឆ្គងទាំងឡាយ» ដែលពួកនិវត្តក:បង្រៀន គឺជាអំពើបាបមួយ។ ព្រះបានដាក់ទេវតាឱ្យមើលថែរក្សាព្រលឹងទាំងនេះ ព្រោះនៅមានពន្លឺមួយទៀតដែលនឹងត្រូវចាំងជះមកលើគេពីបល្ល័ង្ករបស់ព្រះ។

អ្នកដែលបានទទួលដំណឹងហើយ បានរង់ចាំនូវការយាងមករបស់ព្រះអង្គសង្គ្រោះរបស់ខ្លួន។ ពេលវេលាដែលគេសង្ឃឹមថានឹងជួបទ្រង់គឺជិតដល់ហើយ។ គេបានទន្ទឹងចាំវេលានេះដោយចិត្តស្ងប់ស្ងាត់។ គ្មានអ្នកណាដែលបានពិសោធការនេះហើយ អាចភ្លេចវេលារង់ចាំដ៏មានតម្លៃនោះឡើយ។ ប៉ុន្មានសប្តាហ៍មុនពេលនោះ ជំនួញលោកីយ៍ភាគច្រើនត្រូវបានផ្អាកមួយរយៈ។ អ្នកជឿដែលមានចិត្តស្មោះត្រង់បានពិនិត្យចិត្តរបស់ខ្លួនយ៉ាងប្រយ័ត្នប្រយែង ហាក់បីដូចជាប៉ុន្មានម៉ោងទៀត គេនឹងលាចាកទស្សនីយភាពនៃផែនប្រថពីដូច្នោះ។ គ្មានការធ្វើ «សំលៀកបំពាក់ឡើងទៅស្ថានសួគ៌» ទេ ប៉ុន្តែ គេទាំងអស់គ្នាបានដឹងក្នុងខ្លួនថាមានភ័ស្តុតាងដើម្បីបញ្ជាក់ថា គេបានរៀបចំខ្លួនដើម្បីនឹងជួបព្រះអង្គសង្គ្រោះ។ សំលៀកបំពាក់សរបស់គេគឺជាព្រលឹងដ៏បរិសុទ្ធ ចរិយាសម្បត្តិដែលបានលាងស្អាតដោយព្រះលោហិតលោះបាបរបស់ព្រះគ្រីស្ទ។ តើជាការប្រសើរយ៉ាងណាទៅ បើរាស្ត្ររបស់ព្រះនឹងនៅតែមានចិត្តស្ទះស្ទែងចង់ដឹង និងនៅតែមានជំនឿដ៏អស់ពីចិត្តដដែលនោះ។

ព្រះបានគ្រោងនឹងបង្រៀនរាស្ត្រទ្រង់។ ព្រះហស្តរបស់ទ្រង់បានគ្របបាំងកំហុសក្នុងការទូទាត់អំឡុងពេលនៃបទទំនាយ។ ពេលដែលត្រូវយាងមក [ពោលគឺពេលដែលព្រះគ្រីស្ទនឹងយាងមកនៅរដូវផ្ការីកក្នុងឆ្នាំ១៨៤៤] បានកន្លងផុតទៅហើយ ប៉ុន្តែព្រះគ្រីស្ទពុំបានយាងមក។ អ្នកដែលទន្ទឹងចាំព្រះអង្គសង្គ្រោះរបស់ខ្លួន បានពិសោធការខកចិត្តដ៏ជូរចត់។ តែព្រះបាន

សាកល្បងចិត្តអ្នកដែលអះអាងថារង់ចាំទ្រង់យាងមក។ ភាគច្រើនបានប្រែចិត្តជឿដោយភ័យខ្លាច។ មនុស្សទាំងនេះបានថ្លែងថា គេមិនដែលជឿថាព្រះគ្រីស្ទនឹងយាងមកឡើយ។ គេជាមនុស្សក្នុងចំណោមអ្នកចំអកមុនគេដល់សេចក្តីសោកសង្រេងនៃអ្នកជឿពិតប្រាកដ។

ប៉ុន្តែព្រះយេស៊ូវ និងពួកពលបរិវារនៃស្ថានសួគ៌ បានទតមើលដោយសេចក្តីស្រឡាញ់ និងសេចក្តីអាណិតអាសូរ លើពួកអ្នកស្មោះត្រង់ដែលបានខកចិត្តនោះ។ ប្រសិនបើស្បៃដែលញែកពិភពមើលឃើញ និងពិភពមើលមិនឃើញត្រូវបានដកចេញ នោះនឹងឃើញទេវតាស្ថិតនៅជិតព្រលឹងដែលកាន់ជឿជាប់ ព្រមទាំងបំបាំងគេពីចង្កូមរបស់សាតាំងទៀតផង។

References:

1. Travel and Adventures of Rev. Joseph Wolff, vol. 1, pp. 67.
2. Joseph Wolff, Researches and Missionary Labors, pp. 404, 405.
3. Journal of the Rev. Joseph Wolff, p. 96.
4. W. H. D. Adams, In Perils Oft, pp. 192, 201.
5. Journal of the Rev. Joseph Wolff, pp. 377, 389.
6. L. Gaussen, Daniel the Prophet, vol. 2, preface.

ឯពូកធី
២១

ការប្រូតកាត់ខ្យល់ភួច

<u>សៅរ៍-២៤ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ១៨

ខព្រះគម្ពីរប្រចាំសប្តាហ៍: *វេទនាដល់ពួកអ្នក ដែលរាប់សេចក្តីអាក្រក់ថាជាល្អ ហើយសេចក្តីល្អថាជាអាក្រក់វិញ ជាពួកអ្នកដែលយកសេចក្តីងងឹតជាពន្លឺ ហើយយកពន្លឺជាងងឹត ក៏យកសេចក្តីជូរចត់ជាផ្អែម ហើយយកផ្អែមជាជូរចត់វិញ។ អេសាយ ៥:២០*

វិល្លៀម មិល្លើរ និងសហការីបាននាំគ្នាស្វែងរកវិធីដាស់ស្មារតីពួកសាស្ត្រាចារ្យសាសនាឱ្យបែរទៅរកសេចក្តីសង្ឃឹមដ៏ពិតនៃព្រះវិហារ និងសេចក្តីត្រូវការរបស់ខ្លួន ចំពោះការពិសោធដ៏ជ្រាលជ្រៅរបស់អ្នកគ្រីស្ទាន។ ពួកគេបានពញ្ញាក់ស្មារតីនៃពួកអ្នកមិនជឿ ឱ្យផ្លាស់ប្រែចិត្ត ហើយទទួលជឿ។ «ពួកគេពុំបានព្យាយាមប្រែមនុស្សឱ្យចូលគណៈណាទេ តែបានធ្វើការក្នុងចំណោមបក្ស និងគណៈវិញ»។ មិល្លើរថ្លែងថា «ខ្ញុំបានគិតរកផលប្រយោជន៍ឱ្យមនុស្សទាំងអស់គ្នា។ ប្រសិនបើជនគ្រីស្ទានទាំងអស់មានអំណរចំពោះដំណើរយាងមករបស់ព្រះគ្រីស្ទនៅខាងមុខ ហើយបើអស់អ្នកដែលពុំបានយល់ឃើញដូចខ្ញុំ រាប់អានដល់អ្នកដែលឱបក្រសោបគោលលទ្ធិនេះនោះខ្ញុំជឿថា ពុំគួរចាំបាច់នឹងបំបែកក្រុមជំនុំទេ...។ ចំនួនមនុស្សភាគច្រើននៃអស់អ្នកដែលបានប្រែចិត្តជឿដោយសារការងាររបស់ខ្ញុំបានរួបរួមជាមួយនឹងវិហារផ្សេងៗ»។[9]

ប៉ុន្តែ ពួកមេដឹកនាំសាសនា បានសម្រេចជំទាស់នឹងគោលលទ្ធិនិវត្តន៍វិញ ពួកគេបដិសេធមិនឱ្យសមាជិករបស់ខ្លួន មានសិទ្ធិរួមប្រជុំស្តាប់សេចក្តីអធិប្បាយអំពីដំណើរយាងមកជាលើកទីពីរ ឬក៏និយាយគ្នាអំពីសេចក្តី

ទំព័រ-៣៣៤- មហាវិវាទ

សង្ឃឹមរបស់ខ្លួននៅក្នុងវិហារឡើយ។ អ្នកជឿទាំងឡាយស្រឡាញ់វិហារ ណាស់។ ប៉ុន្តែ នៅពេលដែលពួកគេបានឃើញថា ខ្លួនមិនមានសិទ្ធិតាម ដានបទទំនាយនោះ ពួកគេមានអារម្មណ៍ថា ភក្តីភាពចំពោះព្រះ បានហាម មិនឱ្យចុះចូល ហើយគិតថាការបំបែកចេញក៏ជាការត្រឹមត្រូវដែរ។ នៅរដូវ ក្តៅនៃឆ្នាំ១៨៤៤ មានប្រហែលប្រាំម៉ឺននាក់ បានដកខ្លួនចេញពីវិហារ ទាំងឡាយ។

នៅក្នុងវិហារភាគច្រើន មានការកើនឡើងជាលំដាប់អស់រាប់ឆ្នាំមក ហើយ នូវការសម្របជាមួយនឹងការអនុវត្តនៃលោកីយ៍ ហើយជីវិតខាងព្រលឹង វិញ្ញាណក៏ត្រូវបានថយចុះដែរ។ ប៉ុន្តែ នៅក្នុងឆ្នាំនោះ មានភ័ស្តុតាងបញ្ជាក់ ថាមានការថយចុះយ៉ាងខ្លាំង នៅស្ទើរតែគ្រប់វិហារទាំងអស់ក្នុងប្រទេស។ ហេតុពិតប្រាកដត្រូវបានលើកឡើងជាទូទៅ ទាំងនៅតាមសារព័ត៌មាន និង លើគុអធិប្បាយ។

លោកបាណាស់ ដែលជាអ្នកនិពន្ធសៀវភៅវចនាធិប្បាយ និងជាគ្រូ គង្វាលនៃវិហារធំមួយនៅរដ្ឋភីឡាដិលភា «បានថ្លែងថា...*ឥឡូវនេះគ្មានការ ភ្ញាក់រឭក គ្មានការប្រែចិត្តជឿអ្វីទេ* ពុំសូវមានឃើញការលូតលាស់នៅក្នុង ព្រះគុណ នៅក្នុងពួកសាស្ត្រាចារ្យប៉ុន្មានដែរ ហើយក៏ពុំមាននរណាមកកាន់ បន្ទប់របស់គាត់ ដើម្បីនិយាយពីសេចក្តីសង្គ្រោះដល់ព្រលឹងខ្លួនសោះ...។ មានការខ្វល់ខ្វាយខាងលោកីយ៍កាន់តែច្រើនឡើង *ទាំងនៅក្នុងគណៈ ទាំងអស់ផង*»។[២]

នៅខែកុម្ភៈនៃឆ្នាំដដែលនោះ សាស្ត្រាចារ្យហ្វ្រីននី នៅមហាវិទ្យាល័យ អូបឺលីន បានមានប្រសាសន៍ថា៖ «ជាទូទៅវិហារប្រូតេស្តង់ទាំងឡាយនៃ ប្រទេសយើង ដូចជាគ្មានទឹកចិត្ត ហើយខ្សោះអង្គើយចំពោះទម្រង់សីលធម៌ នៃសម័យកាល ស្ទើរតែទាំងអស់...។ ការខ្សោះអង្គើយខាងព្រលឹងវិញ្ញាណ កំពុងរាលដាលស្ទើរសព្វអន្លើ ហើយជ្រាលជ្រៅគួរឱ្យខ្លាចផង សារព័ត៌មាន សាសនានៃប្រទេសទាំងមូល ថ្លែងទីបន្ទាល់ដូច្នេះវិញ...។ សមាជិកដ៏ច្រើន

របស់វិហារ បានក្លាយទៅជាអ្នកហ៊ីហារខាងម៉ូដសំលៀកបំពាក់ ចូលដៃជាមួយនឹងពួកគ្មានព្រះក្នុងពិធីជប់លៀង សប្បាយភ្លើតភ្លើនក្នុងការរាំច្រៀង និងក្នុងពិធីផ្សេងៗជាដើម...។ *វិហារទាំងឡាយជាទូទៅកំពុងធ្លាក់ចុះ ជាការគួរឱ្យសោកស្តាយ*។ គេបានឃ្លាតសែនឆ្ងាយពីព្រះ ហើយព្រះអង្គក៏បានដកអង្គទ្រង់ចេញអំពីគេដែរ»។

ការបដិសេធពន្លឺ

ភាពងងឹតខាងព្រលឹងវិញ្ញាណកើតមានឡើង ពុំមែនដោយព្រោះព្រះដកព្រះគុណចេញស្រេចតែព្រះទ័យព្រះអង្គទេ តែដោយសារមនុស្សបដិសេធពន្លឺវិញ។ ពួកអ៊ីស្រាអែល ដោយមានការជាប់ចិត្តចំពោះលោកីយ៍ ហើយភ្លេចព្រះ ពុំបានដឹងអំពីដំណើរយាងមករបស់ព្រះមែស្ស៊ីទេ។ គេបានបដិសេធព្រះអង្គសង្គ្រោះដោយសេចក្តីមិនជឿ។ ព្រះអង្គពុំបានកាត់ផ្តាច់សាសន៍អ៊ីស្រាអែលចេញអំពីព្រះពរនៃសេចក្តីសង្គ្រោះឡើយ។ អស់អ្នកដែលបានបដិសេធសេចក្តីពិត បាន «យកសេចក្តីងងឹតជាពន្លឺ ហើយយកពន្លឺជាងងឹត»។ អេសាយ ៥:២០។

បន្ទាប់ពីបានបដិសេធចោលដំណឹងល្អហើយ ពួកជូវនៅតែរក្សាទំនៀមទម្លាប់របស់ខ្លួនពីបុរាណដដែល នៅពេលដែលពួកគេទទួលសារភាពថា វត្តមានរបស់ព្រះពុំមាននៅក្នុងចំណោមពួកគេទៀតឡើយ។ បទទំនាយរបស់ហោរាដានីយ៉ែល បានចង្អុលបង្ហាញដោយឥតខុស ទៅឯពេលវេលានៃការយាងមករបស់ព្រះមែស្ស៊ី ហើយនិងទស្សន៍ទាយជាមុនយ៉ាងច្បាស់ អំពីជីវិតរបស់ព្រះអង្គទៀតផង។ ដូច្នេះ ពួកគេក៏បំបាក់ទឹកចិត្តជនទាំងឡាយ មិនឱ្យសិក្សាស្រាវជ្រាវបទទំនាយ ហើយនៅទីបំផុតពួកគ្រូអាចារ្យ បានដាក់បណ្តាសាទៅលើអស់អ្នកដែលព្យាយាមទូទាត់អំពីពេលវេលានោះ។ ក្នុងសេចក្តីកង្វាក់ និងសេចក្តីមិនលន់តួប្រែចិត្ត បណ្តាជនអ៊ីស្រាអែលមិនបានរីរាល់នឹងព្រះពរនៃដំណឹងល្អ អស់រាប់សតវត្សៗមក ដោយសារការព្រងើយ

កន្តើយចំពោះភាពសប្បុរសនៃការប្រទានសេចក្តីសង្គ្រោះ។ នេះជាសេចក្តីព្រមានដ៏ម៉ឺងម៉ាត់ ហើយដ៏គួរឱ្យខ្លាច ចំពោះភាពគ្រោះថ្នាក់នៃការបដិសេធពន្លឺពីស្ថានសួគ៌។

អ្នកណាដែលមិនប្រព្រឹត្តការកិច្ចដែលខ្លួនដឹងថាត្រូវធ្វើ ដោយព្រោះខ្លាចរំខានដល់ការលំអៀងរបស់ខ្លួន នៅទីបំផុតនឹងត្រូវបាត់បង់អំណាចក្នុងការបែងចែករវាងសេចក្តីពិត និងសេចក្តីខុសឆ្គង។ ព្រលឹងនោះនឹងបែកចេញអំពីព្រះ។ នៅទីណាដែលគេច្រានចោលសេចក្តីពិតដ៏ពិសិដ្ឋ ក្រុមជំនុំនឹងស្ថិតនៅក្នុងភាពងងឹត សេចក្តីជំនឿ និងសេចក្តីស្រឡាញ់ទៅជាខ្សោះអង្គើយ ហើយសេចក្តីទាស់ទែងគ្នាក៏ជ្រៀតចូលមក។ សមាជិកក្រុមជំនុំមានការចាប់អារម្មណ៍ក្នុងការដេញតាមសម្ភារៈលោកីយ៍ ហើយបាបជនមានចិត្តរឹងរូសក្នុងសេចក្តីមិនលន់តួប្រែចិត្តរបស់គេ។

<u>អាទិត្យ-២៥ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ១៩

ខព្រះគម្ពីរប្រចាំថ្ងៃ: *ពីព្រោះខ្ញុំប្រចណ្ឌ ចំពោះអ្នករាល់គ្នា ដោយសេចក្តីប្រចណ្ឌនៃព្រះ ដ្បិតខ្ញុំបានបំរុងអ្នករាល់គ្នាទុក ឲ្យមានប្តីតែ១ ទុកដូចជាក្រមុំបរិសុទ្ធ គឺដើម្បីនឹងថ្វាយទៅព្រះគ្រីស្ទតែមួយប៉ុណ្ណោះ។ កូរិនថូសទី២ ១១:២*

ព្រះរាជសារនៃទេវតាទីមួយ

ព្រះរាជសារនៃទេវតាទីមួយនៅវិវរណៈ:១៤ បានរៀបរៀងឡើង ដើម្បីញែកបណ្តាជនដែលតាំងខ្លួនជឿព្រះ ចេញអំពីឥទ្ធិពលពុករលួយ។ ក្នុងព្រះរាជសារនេះ ព្រះបានបញ្ជូនដល់ក្រុមជំនុំនូវសេចក្តីព្រមានដែលប្រសិនបើគេជឿនោះ នឹងបានកែប្រែនូវអំពើអាក្រក់ទាំងឡាយដែលបានបិទបាំងពួកគេចេញពីទ្រង់។ ប្រសិនបើពួកគេទទួលព្រះរាជសារ ហើយបន្ទាបចិត្តឱ្យបានរាបទាបទាំងស្វែងរកវិធីឈរឱ្យមាំនៅចំពោះវត្តមានព្រះអង្គ នោះព្រះវិញ្ញាណនៃព្រះនឹងបានបើកសម្តែងឱ្យគេឃើញទៅហើយ។ ក្រុមជំនុំនឹងបានឈានដល់ឯកភាពខាងជំនឿ និងសេចក្តីស្រឡាញ់ដូចក្នុងសម័យពួកសាវ័កម្តង

ទៀត នៅពេលពួកអ្នកជឿ «មានចិត្តគំនិតតែមួយ» និងនៅពេលដែល «ទ្រង់ ...បន្ថែមនូវអស់អ្នកដែលកំពុងតែបានសង្គ្រោះរាល់តែថ្ងៃ»។ កិច្ចការ ៤:៣២; ២:៤៧។

ប្រសិនបើបណ្តាជនព្រះ ព្រមទទួលពន្លឺពីព្រះបន្ទូលព្រះអង្គ គេនឹងបានឈានដល់ឯកភាពដែលសាវ័កពិពណ៌នាថាជា «សេចក្តីរួបរួមរបស់ព្រះវិញ្ញាណ ដោយសេចក្តីមេត្រីទុកជាចំណង» ជាមិនខាន «មានរូបកាយតែមួយ ហើយព្រះវិញ្ញាណ តែមួយ ដូចជាទ្រង់បានហៅអ្នករាល់គ្នាមកក្នុងសេចក្តីសង្ឃឹម តែមួយ មានព្រះអម្ចាស់តែមួយ សេចក្តីជំនឿតែមួយ បុណ្យជ្រមុជតែមួយ»។ អេភេសូរ ៤:៣-៦។

អស់អ្នកដែលទទួលព្រះរាជសារនៃការនិវត្តរបស់ព្រះ បានមកពីនិកាយផ្សេងៗ ហើយរបាំងរាំងរារាងនិកាយរបស់ពួកគេ ត្រូវបានគ្រវាត់ចោលទៅដី។ គោលជំនឿដែលខ្វែងគ្នាទាំងប៉ុន្មានត្រូវបានកម្ទេចល្អិត ទស្សនៈខុសអំពីដំណើរយាងមកជាលើកទីពីរ ត្រូវបានកែតម្រូវឡើងវិញ សេចក្តីខុសបានកែឱ្យត្រូវ ចិត្តគំនិតបានឯកភាពគ្នាយ៉ាងជិតស្និទ្ធ សេចក្តីស្រឡាញ់បានគ្រងរាជ្យដ៏ឧត្តម។ គោលលទ្ធិនេះនឹងធ្វើឱ្យគេទាំងអស់បានជាយ៉ាងដូច្នោះ ប្រសិនបើទាំងអស់គ្នាទទួល។

គ្រូគង្វាលទាំងឡាយដែលជាអ្នកចាំយាម គួរបានជាអ្នកយល់ដឹងមុនគេនូវសញ្ញានៃដំណើរយាងមករបស់ព្រះយេស៊ូវ តែពួកគេពុំបានរៀនអំពីសេចក្តីពិតពីពួកហោរា ឬអំពីទីសម្គាល់នៃពេលវេលាទេ។ សេចក្តីស្រឡាញ់ដល់ព្រះ និងសេចក្តីជំនឿចំពោះព្រះបន្ទូលព្រះអង្គ បានទៅជាខ្សោះអង្គើយ ហើយគោលលទ្ធិនៃការនិវត្ត គ្រាន់តែធ្វើឱ្យគេមិនជឿប៉ុណ្ណោះ។ ដូចកាលពីដើមដែរ ទីបន្ទាល់នៃព្រះបន្ទូលព្រះ បានជួបប្រទះនឹងពាក្យចោទសួរថា៖ «តើមានអ្នកណាក្នុងពួកនាម៉ឺន ឬក្នុងពួកផារិស៊ីដែលជឿដល់អ្នកនោះឬទេ?» យ៉ូហាន ៧:៤៨។ មនុស្សជាច្រើនធ្វើឱ្យគេធ្លាក់ទឹកចិត្តចំពោះការសិក្សាបទទំនាយ ហើយបង្រៀនថាសៀវភៅបទទំនាយទាំងឡាយ ត្រូវបានបោះត្រា

រួចហើយ ហើយក៏ពុំមែនសម្រាប់ឱ្យនរណាយល់បានដែរ។ ពួកបណ្តាជន បានជឿទុកចិត្តគ្រូគង្វាលរបស់ខ្លួន ក៏បដិសេធមិនព្រមស្តាប់ ចំណែកអ្នក ដទៃទៀត ទោះបីបានជឿចំពោះសេចក្តីពិតហើយក៏ដោយ ក៏ពុំហ៊ាន សារភាពថាខ្លួនជឿដែរ ក្រែងខ្លួនត្រូវ «កាត់ចេញពីក្រុមជំនុំ»។ យ៉ូហាន ៩:២២។ ព្រះរាជសារដែលព្រះបានបញ្ជូនមក ដើម្បីសាកល្បងក្រុមជំនុំ បាន បើកសម្តែងឱ្យឃើញថាមានមនុស្សសន្ធឹកសន្ធាប់ណាស់ ដែលផ្តោតចិត្ត របស់ខ្លួនទៅលើលោកីយ៍ ជាជាងព្រះគ្រីស្ទ។

ការបដិសេធសេចក្តីព្រមានរបស់ទេវតាទីមួយ គឺជាដើមហេតុនៃ លក្ខណៈដ៏គួរភ័យខ្លាចនៃសភាពលោកីយ៍ នៃការជំពប់ដួល និងនៃសេចក្តី ស្លាប់ខាងព្រលឹងវិញ្ញាណ ដែលកើតមាននៅក្នុងក្រុមជំនុំ នាឆ្នាំ១៨៤៤។

ព្រះរាជសារនៃទេវតាទីពីរ

នៅក្នុងគម្ពីរវិវរណៈជំពូក១៤ ទេវតាទីពីរប្រកាសតាមក្រោយទេវតា ទីមួយថា៖ «ក្រុងបាប៊ីឡូនដ៏ជាធំបានរលំហើយ បានរលំហើយ ដ្បិតវាបាន ឱ្យគ្រប់ទាំងសាសន៍ ផឹកស្រានៃសេចក្តីឃោរឃៅរបស់ការកំផិតខ្លួន»។ វិវរណៈ ១៤:៨។ ពាក្យថា «បាប៊ីឡូន» គឺមកអំពីពាក្យ «បាបិល» មានន័យថា ច្របូកច្របល់។ នៅក្នុងបទគម្ពីរ ពាក្យនេះតំណាងទម្រង់ផ្សេងៗនៃសាសនា ខុសឆ្គង និងសាសនាដែលប្រាសចាកជំនឿ។ ក្នុងវិវរណៈ១៧ ក្រុងបាប៊ីឡូន ជាតំណាងស្ត្រីមួយរូប រូបភាពប្រើនៅក្នុងគម្ពីរទុកជានិមិត្តរូបនៃក្រុមជំនុំ ស្ត្រី ប្រកបដោយគុណធម៌ ជាតំណាងវិហារបរិសុទ្ធ ស្ត្រីពោរពេញទៅដោយ បាបធម៌ ជាតំណាងក្រុមជំនុំដែលប្រាសចាកជំនឿ។

ទំនាក់ទំនងរវាងព្រះគ្រីស្ទ និងវិហាររបស់ទ្រង់នៅក្នុងគម្ពីរ គឺ តំណាងដោយពិធីអាពាហ៍ពិពាហ៍។ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «អញ នឹងដណ្តឹងនាងសម្រាប់អញ ទុកជាដរាបទៅ អើអញនឹងដណ្តឹងនាង សម្រាប់អញ ដោយសេចក្តីសុចរិត»។ ហូសេ ២:១៩។ «អញនឹងយកឯង

រាល់គ្នា»។ យេរេមា ៣:១៤។ សាវ័កប៉ុលសម្តែងថា «ខ្ញុំបានបម្រុងអ្នករាល់គ្នា ទុកឱ្យមានប្តីតែមួយ ទុកដូចជាក្រមុំបរិសុទ្ធ គឺដើម្បីនឹងថ្វាយទៅព្រះគ្រីស្ទ»។ កូរិនថូសទី២ ១១:២។

<u>ចន្ទ-២៦ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ២០

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែខ្ញុំខ្លាចក្រែងគំនិតអ្នករាល់គ្នា ត្រូវបង្ខូចចេញពីសេចក្តីទៀងត្រង់ខាងឯព្រះគ្រីស្ទ ដូចជាសត្វពស់បានបញ្ឆោតនាងអេវ៉ា ដោយឧបាយកលយ៉ាងនោះដែរ។ កូរិនថូសទី២ ១១:៣*

អំពើសហាយស្មន់ខាងព្រលឹងវិញ្ញាណ

ក្រុមជំនុំដែលមិនស្មោះត្រង់ចំពោះព្រះគ្រីស្ទ ដោយអនុញ្ញាតឱ្យរបស់លោកីយ៍ចូលគ្រប់គ្រងព្រលឹងខ្លួន គឺដូចគ្នានឹងការក្បត់ពាក្យសច្ចានៃពិធីអាពាហ៍ពិពាហ៍ដែរ។ អំពើបាបពួកអ៊ីស្រាអែលក្នុងការចាកចោលព្រះ ត្រូវបានស្តែងនៅក្រោមសេចក្តីប្រៀបធៀបនេះ៖ «ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឱពួជពង្សអ៊ីស្រាអែលអើយ ពិតប្រាកដជាឯងបានប្រព្រឹត្តអំពើក្បត់ចំពោះអញ ប្រៀបដូចជាប្រពន្ធប្រព្រឹត្តក្បត់ចាកចោលប្តីខ្លួន» «ជាស្ត្រីដែលប្រព្រឹត្តសេចក្តីកំផិត ជាស្រីដែលយកមនុស្សដទៃមកជំនួសប្តីហើយ»។
យេរេមា ៣:២០; អេសេគាល ១៦:៣២។

សាវ័កយ៉ាកុបសម្តែងថា៖ «ឱ ពួកកំផិតទាំងប្រុសទាំងស្រីអើយ តើមិនដឹងទេឬអីថា ដែលស្រឡាញ់ដល់លោកីយ៍ នោះគឺស្អប់ដល់ព្រះហើយ ដូច្នេះអ្នកណាដែលចូលចិត្តចង់ធ្វើជាមិត្រសម្លាញ់នឹងលោកីយ៍ នោះឈ្មោះថាបានតាំងខ្លួនជាខ្មាំងសត្រូវនឹងព្រះវិញ»។ យ៉ាកុប ៤:៤។

ស្ត្រី (បាប៊ីឡូន) ស្លៀកពាក់ «ពណ៌ស្វាយ ហើយក្រហម ក៏តែងដោយមាស ត្បូងមានតម្លៃហើយនិងកែវមុក្តា ព្រមទាំងកាន់ពែងមាស ដែលពេញដោយសេចក្តីស្មោកគ្រោករបស់ការកំផិតដ៏គួរខ្ពើមរបស់វាផង ហើយនៅលើថ្ងាសវាមានកត់ឈ្មោះថា ‘សេចក្តីអាថកំបាំង ក្រុងបាប៊ីឡូនដ៏ជាធំជា

ម្តាយនៃពួកស្រីសំផឹង'។ ហោរាសម្តែងថា៖ «ខ្ញុំក៏ឃើញស្ត្រីនោះស្រវឹងនឹងឈាមពួកបរិសុទ្ធ ហើយនិងឈាមពួកអ្នកធ្វើបន្ទាល់ពីព្រះយេស៊ូវ»។ បាប៊ីឡូន គឺជា «ទីក្រុងដ៏ធំដែលមានអំណាចលើស្តេចទាំងប៉ុន្មាននៅផែនដី»។ វិវរណៈ ១៧:៥-៦,១៨។

អំណាចដែលមានឥទ្ធិពលលើពួកមហាក្សត្រនៃពិភពគ្រីស្ទាន ជាច្រើនសតវត្សមកហើយនោះគឺជាអំណាចរ៉ូម។ ពណ៌ស្វាយ ក្រហម មាស ត្បូងមានតម្លៃ និងកែវមុក្តា ពិពណ៌នាអំពីភាពអធិកអធម និងមុខតំណែងដ៏ក្រអឺតរបស់រ៉ូម។ គ្មានអំណាចណាដែលសមនឹងសេចក្តី ដែលបានចែងថា «ស្រវឹងនឹងឈាមពួកបរិសុទ្ធ» ដូចជាវិហារដែលបានធ្វើទុក្ខទោសដ៏សែនឃោរឃៅដល់ពួកអ្នកជឿព្រះគ្រីស្ទឡើយ។

បាប៊ីឡូនត្រូវជាប់ចោទផងដែរ ដោយបានប្រស្រ័យទាក់ទងទាំងខុសច្បាប់ជាមួយនឹង «ពួកស្តេចនៅផែនដី»។ ដោយការឃ្លាតចេញពីព្រះអម្ចាស់ ហើយទៅចងសម្ព័ន្ធជាមួយពួកមិនជឿ ក្រុមជំនុំជួរក៏បានក្លាយទៅជាសំផឹងម្នាក់ ឯរ៉ូមវិញ ក៏នឹងទទួលការផ្តន្ទាទោសដូចគ្នាដែរ ដោយការស្វែងរកកម្លាំងគាំទ្រពីអំណាចលោកីយ៍។

បាប៊ីឡូនជា «*ម្តាយនៃពួកស្រីសំផឹង*» *កូនស្រី*របស់នាង គឺជាវិហារទាំងឡាយដែលតោងជាប់ទៅនឹងគោលលទ្ធិរបស់នាង ព្រមទាំងដើរតាមគំរូរបស់នាង ក្នុងការលះបង់សេចក្តីពិត ដើម្បីចងសម្ព័ន្ធមេត្រីជាមួយនឹងលោកីយ៍។ ព្រះរាជសារដែលប្រកាសថាបាប៊ីឡូន *រលំ* ហើយ ត្រូវតែសំដៅទៅលើតួអង្គសាសនាទាំងឡាយដែលពីដើមស្អាតស្អំ ហើយក៏ក្លាយទៅជាពុករលួយ។ ព្រះរាជសារនេះត្រូវផ្សាយនៅថ្ងៃចុងបំផុត ក្រោយការព្រមាននៃសេចក្តីជំនុំជម្រះ។ ម្ល៉ោះហើយព្រះរាជសារនោះ មិនអាចសំដៅទៅលើវិហារ៉ូមតែឯងទេ ព្រោះវិហារនោះបានស្ថិតនៅក្នុងលក្ខណៈរលំដួលរាប់សិបសតវត្សមកហើយ។

លើសពីនេះទៅទៀត បណ្តាជននៃព្រះត្រូវបានហៅឱ្យចេញពី

បាប៊ីឡូន។ យោងទៅតាមបទគម្ពីរត្រង់នេះ រាស្ត្ររបស់ព្រះជាច្រើន ច្បាស់ជានៅក្នុងបាប៊ីឡូននៅឡើយ។ តើនៅក្នុងតួអង្គនៃសាសនាណាខ្លះដែលមានអ្នកដើរតាមព្រះគ្រីស្ទច្រើនជាងគេ? គឺនៅក្នុងវិហារទាំងឡាយដែលកាន់ជំនឿប្រូតេស្តង់។ នៅគ្រាដែលវិហារទាំងនេះចេញមុខឡើង ពួកគេបានឈរការពារយ៉ាងមាំទាំសម្រាប់សេចក្តីពិត ហើយព្រះពរនៃព្រះក៏មាននៅជាមួយពួកគេដែរ។ ប៉ុន្តែ ពួកគេបានធ្លាក់ចុះដោយសេចក្តីប៉ងប្រាថ្នាដែលដូចគ្នានឹងការហិនវិនាសនៃពួកអ៊ីស្រាអែលដែរ ពោលគឺដោយការយកតម្រាប់តាមការអនុវត្ត និងការចែចង់ចងមិត្តភាពជាមួយពួកឥតមានព្រះនៅក្នុងខ្លួន។

ការរួមច្រាស្រ័យជាមួយលោកីយ៍

វិហារប្រូតេស្តង់ជាច្រើន បានដើរតាមគំរូរបស់រ៉ូម ក្នុងការចងមេត្រីជាមួយ «ពួកស្តេចនៅផែនដី» ពោលគឺវិហាររដ្ឋ ដោយមានទំនាក់ទំនងដល់រដ្ឋាភិបាលលោកីយ៍ និងជាមួយគណៈដទៃទៀតដោយស្វែងរកសន្តានចិត្តនៃលោកីយ៍។ ពាក្យថា «បាប៊ីឡូន» ច្របូកច្របល់ អាចបានដល់តួអង្គទាំងនេះ ដែលអះអាងថាបានដកយកគោលលទ្ធិរបស់ខ្លួនចេញពីព្រះគម្ពីរ តែបានបែងចែកគណៈដ៏រាប់មិនអស់ ទាំងមានគោលជំនឿខ្វែងគ្នាទៀតផង។

អ្នកធ្វើការកាតូលិករ៉ូមម្នាក់ បានជជែកថា «ប្រសិនបើវិហាររ៉ូម មានកំហុសដោយការថ្វាយបង្គំរូបក្នុងទំនាក់ទំនងទៅនឹងពួកសន្តបុគ្គល កូនស្រីរបស់វិហារនេះដែលជាវិហារអង់គ្លេស ក៏មានកំហុសដូចគ្នាដែរ ដែលមានវិហារដប់ថ្វាយចំពោះនាងម៉ារ ហើយមានមួយថ្វាយចំពោះព្រះគ្រីស្ទ»។[៣]

បណ្ឌិតហាប់ឃិនស៍បានថ្លែងថា៖ «កុំថាឡើយវិហាររ៉ូមមានឥរិយាប្រឆាំងគ្រីស្ទបរិស័ទ និងការអនុវត្តដែលប្រឆាំងគ្រីស្ទបរិស័ទ វិហារប្រូតេស្តង់ក៏មានការប្រឆាំងគ្រីស្ទបរិស័ទច្រើនណាស់ទៅទៀត ហើយក៏នៅឆ្ងាយអំពីការកែទម្រង់ពេញលេញ ចេញពីអំពើពុករលួយ និងអំពើអាក្រក់ទៀតផង»។[៤]

ស្តីអំពីការបែកចេញនៃវិហារប្រែសប៊ីធារៀន (Presbyterian Church) ពីរ៉ូមវិញ បណ្ឌិតហ្គូថរីសរសេរថា៖ «កាលពីបីរយឆ្នាំមុន វិហាររបស់យើងបានដើរក្បួនចេញពីខ្លោងទ្វាររបស់រ៉ូម ដោយមានគម្ពីរបើកនៅលើទង់សញ្ញា ទាំងមានពាក្យ 'ចូរស្វែងរកបទគម្ពីរ' នៅលើគ្រាំងទៀតផង»។ បន្ទាប់មកគាត់ក៏សួរសំណួរដ៏សំខាន់ថា «តើពួកគេបានចេញដោយជ្រះស្រឡះពីបាប៊ីឡូនឬទេ?»[៥]

<u>អង្គារ-២៧ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ២១

ខព្រះគម្ពីរប្រចាំថ្ងៃ:*ប៉ុន្តែ ឯអ្នករាល់គ្នា ជាពួកស្ងួនភ្ងាអើយ ចូររក្សាខ្លួនក្នុងសេចក្តីស្រឡាញ់របស់ព្រះចុះ ព្រមទាំងរង់ចាំសេចក្តីមេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ឲ្យបានជីវិតអស់កល្បជានិច្ចវិញ។ យូដាស ខ:២០*

ការចាកចេញពីដំណឹងល្អជាលើកដំបូង

តើវិហារបានចាកចេញពីភាពសាមញ្ញនៃដំណឹងល្អដោយរបៀបណា? គឺដោយសម្របទៅតាមពួកកាន់សាសនាដទៃ ដើម្បីឱ្យពួកមិនជឿទទួលជឿសាសនាព្រះគ្រីស្ទ។ «លុះដល់ចុងបញ្ចប់នៃសតវត្សទីពីរ មានវិហារជាច្រើនបានប្រកាន់យកទម្រង់ថ្មី...។ នៅពេលដែលពួកសិស្សចាស់ បានចូលនិវត្តទៅកាន់ផ្នូររបស់ខ្លួនអស់ទៅ ពួកកូនចៅរបស់គេរួមជាមួយនឹងពួកអ្នកជឿថ្មី...ក៏បានចេញមកកែច្នៃបុព្វហេតុឱ្យបានជាថ្មី»។ «ពួកកាន់សាសនាដទៃក៏បានចូលទៅក្នុងវិហារ ទាំងនាំមកជាមួយនូវទំនៀមទម្លាប់ ការអនុវត្ត និងការថ្វាយបង្គំរូបរបស់គេផង»។[៦] សាសនាព្រះគ្រីស្ទ ក៏ទៅពឹងពាក់ និងរកសេចក្តីគាំទ្រពីអ្នកកាន់អំណាចលោកីយ៍។ ពួកបណ្តាជនបានទទួលជឿតែសំបកក្រៅទេ ភាគច្រើននៅតែ «មានធាតុជាជនកាន់សាសនាដទៃដដែល មានដូចជាការលបលួចថ្វាយបង្គំរូបសំណាកបស់ខ្លួនជាដើម»។[៧]

តើដំណើរការដូចគ្នានេះ មិនបានធ្វើផ្ទួនៗគ្នានៅស្ទើរតែគ្រប់វិហារ

ដែលហៅខ្លួនថាប្រុតេស្តង់ទេឬ? នៅពេលដែលពួកបុព្វបុរសដែលប្រកប
ដោយវិញ្ញាណនៃលទ្ធិកែទម្រង់ពិតបានស្លាប់ទៅ កូនចៅតំណក្រោយរបស់
ពួកគេ ក៏ «កែច្នៃបុព្វហេតុឱ្យបានជាថ្មីឡើង»។ កូនចៅនៃពួកអ្នកកែទម្រង់
បានចាកចេញពីគំរូនៃការលះបង់ខ្លួន និងការលះបង់លោកីយ៍ ដោយ
បដិសេធទាំងងងឹតងងល់ មិនទទួលនូវសេចក្តីពិតណាមួយដែលពួកបិតា
របស់គេបានដឹង។

ចន វែស្លី បានថ្លែងថា តើវិហារដ៏មានប្រជាប្រិយ បានឃ្លាតចេញអំពី
ទម្រង់ព្រះគម្ពីរសែនឆ្ងាយអ្វីម្ល៉េះហ្ន៎! និយាយអំពីប្រាក់កាសវិញ៖ «ចូរកុំខ្ជះ
ខ្ជាយផ្នែកណាមួយនៃប្រាក់ដ៏វិសេសវិសាលឱ្យសោះ...ដោយមានសំលៀក
បំពាក់ច្រើនហួសពីសេចក្តីត្រូវការ ឬមានតម្លៃថ្លៃៗ និងប្រេងម្សៅមិន
ចាំបាច់។ កុំឱ្យចំណាយទៅលើរបស់តាក់តែងផ្ទះហួសខ្នាត ទៅលើគ្រឿង
សង្ហារិមច្រើនហួសពីត្រូវការ ឬថ្លៃៗ ទៅលើរូបភាព រូបគំនូរ គ្រឿងស្រោប
មាសដ៏ថ្លៃៗជាដើម...។ ដរាបណាអ្នក 'ស្លៀកពាក់សំពត់ពណ៌ស្វាយ និង
សំពត់ទ្បែនស្អាត' ហើយនិង 'គ្រឿងឆើតឆាយបំផុតឱ្យបានរាល់ថ្ងៃ' នោះ
មិនបាច់ឆ្ងល់ទេ ប្រាកដជាមានមនុស្សជាច្រើន សរសើររាប់អានដល់សភាព
ហ៊ឺហាសប្បុរសធម៌ និងកិច្ចរាក់ទាក់ចៅពៅរបស់អ្នកជាមិនខាន។ ប៉ុន្តែ គួរឱ្យ
ស្តប់ចិត្តជាមួយនឹងកិត្តិយសមកអំពីព្រះវិញ»។[៨]

ពួកគ្រប់គ្រង ពួកនយោបាយ ពួកអ្នកច្បាប់ ពួកបណ្ឌិត និងពួកអ្នក
ជំនួញ បានចូលរួមជាមួយវិហារ ដើម្បីរកផលប្រយោជន៍លោកីយ៍។ តួអង្គ
សាសនាទាំងឡាយដែលត្រូវបានពង្រឹងឡើងដោយភោគទ្រព្យនៃពួកលោកីយ៍
ដែលបានទទួលបុណ្យជ្រមុជហើយនោះ បានធ្វើឱ្យវិហារមានប្រជាប្រិយ
កាន់តែខ្លាំងឡើង។ ក្រុមជំនុំដែលប្រកបដោយសភាពសង្ហា ល្អប្រណីត
លើសលប់ ក៏ត្រូវបានស្តាបនាឡើង។ គេបានបង់ប្រាក់ខែខ្ពស់ឱ្យគ្រូគង្វាល
ដែលមានទេពកោសល្យ ចេះធ្វើឱ្យមនុស្សសប្បាយរីករាយ។ សេចក្តីអធិប្បាយ
របស់គាត់ត្រូវតែពីរោះដល់ត្រចៀកអ្នកសម័យនិយម។ ម្ល៉ោះហើយ អំពើ

បាបសម័យនិយម ត្រូវបានលាក់បាំងនៅក្រោមសេចក្តីពុតត្បុតថាមានព្រះក្នុងខ្លួន។

អ្នកនិពន្ធសារព័ត៌មានប្រចាំរដ្ឋញ្ញូយ៉ក *ឯកភាជ្ញ* បាននិយាយអំពីលទ្ធិមេថូឌីសត៌និយមដូច្នេះថា «បន្ទាត់នៃការបែងចែករវាងអ្នកជឿព្រះ និងអ្នកឥតសាសនា ត្រូវសាបរលាបទៅជាស្រមោលព្រឿងៗ ហើយអ្នកខ្ជាប់ខ្ជួនទាំងសងខាង ខំប្រឹងបំបាត់សេចក្តីខុសឆ្គងទាំងប៉ុន្មាន រវាងប្រភេទនៃការប្រព្រឹត្ត និងសេចក្តីកាត់ចិត្តរបស់ខ្លួន»។

នៅក្នុងជំនោរនៃការស្វែងរកសេចក្តីត្រេកត្រអាលនេះ ការធ្វើពលីកម្មខ្លួនដើម្បីព្រះគ្រីស្ទ ត្រូវបានបាត់បង់ស្ទើរទាំងស្រុង។ «បើចង់បានថវិកា ...ពុំបាច់សុំគេទេ។ ឱទេ! នាំគ្នាតាំងពិពណ៌លក់របស់របរ ផ្ទាំងគំនូរ របស់ច្នៃប្រឌិត របស់បុរាណ ធ្វើពិធីទទួលទានរបៀបបុរាណទៅ! ពោលគឺធ្វើអ្វីៗដែលធ្វើឱ្យមនុស្សសប្បាយរីករាយ»។

រ៉ប់បិត អាតយិនស៍ បានសម្តែងការជាក់ស្តែងនៃការរាថយខាងព្រលឹងវិញ្ញាណនៅប្រទេសអង់គ្លេសថា៖ «មានពាក្យ *ហ្ក្រាសចាកជំនឿ ហ្ក្រាសចាកជំនឿ ហ្ក្រាសចាកជំនឿ* ឆ្លាក់នៅគ្រប់មុខវិហារ តើពួកគេបានដឹងខ្លួនឬទេ ប្រហែលជាអាចមានសង្ឃឹមខ្លះ ប៉ុន្តែ ពួកគេបានស្រែកឡើងថា «អាឡាស់! យើងមានស្តុកស្តម្ភ មានសម្ភារៈកើនឡើងជាលំដាប់ គ្មានត្រូវការអ្វីទៀតទេ»។[៩]

អំពើបាបដ៏ធំដែលបានចោទចំពោះក្រុងបាប៊ីឡូន គឺត្រង់ថា «វាបានធ្វើឱ្យគ្រប់ទាំងសាសន៍ផឹកស្រានៃសេចក្តីឃោរឃៅរបស់ការកំផិតខ្លួន»។ ពែងនេះជាតំណាងគោលលទ្ធិខុសឆ្គង ដែលវាបានទទួលដោយព្រោះការចងមិត្តភាពជាមួយលោកីយ៍ ហើយបាប៊ីឡូនក៏បញ្ចេញឥទ្ធិពលពុករលួយមកលើពិភពលោក ដោយបង្ហាត់បង្រៀនគោលលទ្ធិដែលប្រឆាំងនឹងសេចក្តីចែងមកយ៉ាងច្បាស់ក្នុងព្រះគម្ពីរ។

បើលោកីយ៍មិនបានពុលស្រារបស់បាប៊ីឡូនវិញ បណ្តាជន

ទាំងឡាយប្រាកដជាជឿហើយប្រែចិត្ត ដោយសេចក្តីពិតដ៏ងាយយល់នៃព្រះបន្ទូលរបស់ព្រះទៅហើយ។ ប៉ុន្តែ ជំនឿសាសនាមើលទៅដូចជាច្រឡូកច្រឡំជាខ្លាំង ធ្វើឱ្យមនុស្សឡប់សតិ មិនដឹងជាត្រូវជឿអ្វីខ្លះ។ អំពើបាបដ៏មិនចេះកែប្រែរបស់លោកីយ៍ បានដេកនៅនឹងមាត់ទ្វារវិហារ។

ព្រះរាជសាររបស់ទេវតាទីពីរ ពុំបានមកដល់ទីសម្រេចពេញលេញនៅឆ្នាំ១៨៤៤ទេ។ នៅគ្រានោះ វិហារទាំងឡាយបានជួបប្រទះនឹងការអន់ថយផ្នែកសីលធម៌ដោយព្រោះការបដិសេធពន្លឺនៃព្រះរាជសារពីដំណើរយាងមក ប៉ុន្តែ ការធ្លាក់ចុះនោះពុំបានពេញលេញទេ។ ក្នុងពេលដែលគេនៅតែបដិសេធសេចក្តីពិតដ៏វិសេសសម្រាប់ពេលនេះ គេក៏បានធ្លាក់ចុះកាន់តែទាបទៅៗ ក៏ប៉ុន្តែ យើងពុំអាចនិយាយថា «បាប៊ីឡូនបានរលំហើយ...ពីព្រោះវាបានធ្វើឱ្យ *គ្រប់ទាំងសាសន៍* ផឹកស្រានៃសេចក្តីឃោរឃៅរបស់ការកំផិតខ្លួន» បានឡើយ។ វិហារប្រូតេស្តង់ទាំងឡាយត្រូវបានរួមបញ្ចូលនៅក្នុងការប្រកាសប្រឆាំងដ៏ឱឡារិករបស់ទេវតាទីពីរដែរ។ ប៉ុន្តែ កិច្ចការនៃការប្រាសចាកជំនឿពុំទាន់ឈានដល់កំពូលនៅឡើយទេ។

មុនដំណើរយាងមករបស់ព្រះជាម្ចាស់ សាតាំងនឹងធ្វើការ «ដោយនូវគ្រប់ទាំងឫទ្ធិ ទីសម្គាល់ និងការអស្ចារ្យដ៏កំភូត ហើយនិងដោយសេចក្តីឆបោកដ៏ទុច្ចរិត» ហើយពួក «ដែលមិនព្រមទទួលសេចក្តីស្រឡាញ់ដល់សេចក្តីពិត ដើម្បីឱ្យបានសេចក្តីសង្គ្រោះ» នឹងត្រូវទុកនៅឱ្យទទួល «សេចក្តីខុសឆ្គងបណ្តាលឱ្យជឿតាមសេចក្តីភូតភរវិញ»។ ថែស្សាឡូនីចទី២ ២:៩,១១។ បាប៊ីឡូនមិនទាន់រលំទាំងស្រុងនៅឡើយទេ រហូតទាល់តែសហភាពរបស់វិហារជាមួយនឹងលោកីយ៍ត្រូវបានសម្រេចពេញលេញជាមុនសិន។ ការផ្លាស់ប្តូរកំពុងជឿនលឿនទៅមុខ ហើយសេចក្តីសម្រេចដ៏គ្រប់លក្ខណៈនៃគម្ពីរវិវរណៈ ១៤:៨ គឺនៅក្នុងអនាគតកាលនៅឡើយ។

ថ្វីបើមានភាពងងឹតខាងព្រលឹងវិញ្ញាណ នៅក្នុងវិហារទាំងឡាយដែលរួមជាមួយបាប៊ីឡូនក៏ដោយក៏តួអង្គដ៏ធំនៃពួកគ្រីស្ទានបរិសុទ្ធពិតប្រាកដ

នៅតែមានឃើញនៅក្នុងជំនុំរបស់ពួកគេដែរ។ ជាច្រើនគ្នាពុំដែលឃើញសេចក្តីពិត ដ៏ពិសេសសម្រាប់ពេលនេះឡើយ។ ពួកគេទន្ទឹងចង់បានពន្លឺដ៏ច្បាស់ជាង។ គេខំប្រឹងរកជាអសារឥតការនូវរូបសំណាករបស់ព្រះគ្រីស្ទនៅក្នុងវិហារទាំង ឡាយដែលពួកគេមានទំនាក់ទំនងជាមួយ។

វិវរណៈ:១៨ ចង្អុលទៅពេលវេលាដែលព្រះនឹងហៅបណ្តាជនរបស់ព្រះអង្គ ដែលកំពុងស្ថិតនៅក្នុងបាប៊ីឡូននៅឡើយ ឱ្យបែរចេញពីជំនុំរបស់វា។ ព្រះរាជសារនេះ ដែលនឹងត្រូវផ្សាយជាចុងក្រោយបង្អស់ដល់លោកីយ៍ នឹងសម្រេចការងារជាស្តាពរ។ ពន្លឺនៃសេចក្តីពិតនឹងបំភ្លឺទៅលើអស់អ្នកណាដែលមានចិត្តបើកចំហ ហើយកូនរបស់ព្រះនៅក្នុងបាប៊ីឡូន នឹងឆ្លើយតបចំពោះព្រះបន្ទូលត្រាស់ហៅ ដែលថា៖ «រាស្ត្រអញអើយ ចូរចេញពីទីក្រុងនោះមក»។ វិវរណៈ ១៨:៤។

References:

1. Bliss, p. 328.
2. *Congregational Journal*, May 23, 1844.
3. Richard Challoner, *The Catholic Christian Instructed*, Preface, pp. 21, 22.
4. Samuel Hopkins, "A treatise on the Millennium," *Works*, vol. 2, p. 328.
5. Thomas Guthrie, *The Gospel in Ezekiel*, p. 237.
6. Robert Robinson, *Ecclesiastical Researches* (ed. 1792), ch. 6, par. 17, p. 51.
7. Gavazzi, *Lectures* (ed. 1854), p.. 278.
8. Wesley, *Works*, Sermon 50, "The Use of Money".
9. Second Advent Library, tract No. 39.

បទទំនាយត្រូវបានសម្រេច

<u>ពុធ-២៨ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ២២

ខព្រះគម្ពីរប្រចាំថ្ងៃ:*ដ្បិតការជាក់ស្តែងនេះ ទុកសំរាប់ដល់វេលាកំណត់ ក៏កំពុងស្រូតឲ្យដល់ពេលនោះហើយ នៅគ្រានោះ នឹងមិនកុហកទេ បើសិនជាបង្អង់យូរ ក៏ចូររង់ចាំចុះ ដ្បិតនឹងមកជាពិត ឥតរារង់ឡើយ។ហាបាគុក ២:៣*

នៅពេលរដូវផ្ការីកនាឆ្នាំ១៨៤៤ (ជាពេលដែលគេសង្ឃឹមជាលើកដំបូងថា ព្រះអម្ចាស់នឹងយាងមកវិញ) បានកន្លងផុតទៅ អ្នកដែលរង់ចាំការយាងមករបស់ទ្រង់ បានស្ថិតនៅក្នុងភាពសង្ស័យ និងភាពស្រពេចស្រពិល។ ពួកគេជាច្រើនបានបន្តការស្រាវជ្រាវបទគម្ពីរ ដើម្បីពិនិត្យរកឫសគល់នៃជំនឿរបស់ខ្លួនជាថ្មីឡើងវិញ។ បទទំនាយទាំងឡាយគឺច្បាស់ហើយប្រាកដ ព្រមទាំងបានចង្អុលប្រាប់ថា ការយាងមករបស់ព្រះគ្រីស្តគឺជិតដល់ហើយ។ ព្រះពររបស់ព្រះក្នុងការផ្លាស់ប្រែចិត្តគំនិត និងក្នុងការភ្ញាក់រលឹកឡើងវិញ នៅក្នុងចំណោមពួកគ្រីស្ទានទាំងឡាយបានធ្វើទីបន្ទាល់ថា ដំណឹងនោះគឺជាព្រះរាជសារមកពីស្ថានសួគ៌។ ការជំពាក់ជំពិនជាមួយនឹងបទទំនាយដែលគេស្មានថាសំដៅទៅឯពេលនៃការយាងមកជាលើកទីពីរនោះ គឺជាការបង្គាប់ដែលលើកទឹកចិត្តគេឱ្យរង់ចាំដោយអំណត់ក្នុងជំនឿ ព្រោះអ្វីដែលឥឡូវមើលទៅខ្មៅងងឹតហើយពិបាកយល់នោះ នឹងបានយល់ច្បាស់វិញ។ ក្នុងចំណោមបទទំនាយទាំងនេះ មានដូចជាទំនាយក្នុងគម្ពីរហាបាគុក ២:១-៤ ជាដើម។ យ៉ាងណាមិញ គ្មាននរណាម្នាក់បានកត់សម្គាល់ថា ការពន្យារពេលវេលា ពេលបង្អង់យូរ មានចែងក្នុងបទទំនាយសោះឡើយ។ ក្រោយពីការខកចិត្តនោះមក បទគម្ពីរបានលេចធ្លោឡើងថា៖ «ដ្បិតការជាក់ស្តែងនេះ

ទុកសម្រាប់ដល់វេលាកំណត់ ក៏កំពុងស្រូតឱ្យដល់ពេលនោះហើយ នៅគ្រានោះនឹងមិនកុហកទេ បើសិនជាបង្អង់យូរ ក៏ចូររង់ចាំចុះ ដ្បិតនឹងមកជាពិត ឥតរារង់ឡើយ...។ មនុស្សសុចរិតនឹងរស់នៅ ដោយសារសេចក្ដីជំនឿរបស់ខ្លួន»។

បទទំនាយរបស់ហោរាអេសេគាល ក៏ជាទីកំសាន្តចិត្តដល់អ្នកជឿទាំងឡាយដែរ៖ «ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ...វេលាកំណត់ជិតដល់ហើយ ព្រមទាំងពេលដែលនឹងសម្រេចតាមគ្រប់ទាំងការជាក់ស្តែងនោះផង...។ អញនឹងចេញបង្គាប់ ហើយពាក្យដែលអញប្រាប់នោះ នឹងបានសម្រេចជាពិត ឥតដែលបន្តយទៀតឡើយ»។ «ពាក្យដែលអញបញ្ចេញនោះនឹងបានសម្រេចជាពិត»។ អេសេគាល ១២:២៣-២៥,២៨។

អ្នកដែលរង់ចាំ បានអរសប្បាយ ព្រោះព្រះអង្គដែលជ្រាបពីទីបញ្ចប់តាំងតែពីដើមដំបូងមកបានប្រទានសេចក្ដីសង្ឃឹមដល់គេ។ បើពុំមានបទគម្ពីរជាផ្នែកៗដូច្នេះនោះ ជំនឿរបស់គេនឹងបានសាបសូន្យជាមិនខាន។

រឿងប្រៀបធៀបអំពីនាងព្រហ្មចារីដប់នាក់ក្នុងគម្ពីរម៉ាថាយជំពូក២៥ ក៏សម្តែងពីការពិសោធរបស់ពួកនិវត្តក:ដែរ។ រឿងប្រៀបធៀបនេះ បាននាំយើងឱ្យឃើញអំពីដំណើរនៃក្រុមជំនុំនាថ្ងៃចុងក្រោយ។ ការពិសោធរបស់គេគឺបានរ៉ាយរ៉ាប់ដោយអាពាហ៍ពិពាហ៍មួយនៅស្រុកខាងកើត៖

«គ្រានោះនគរស្ថានសួគ៌ នឹងបានដូចជាស្រីព្រហ្មចារីដប់នាក់ ដែលយកចង្កៀងរៀងខ្លួនចេញទៅទទួលប្តីថ្មោងថ្មី។ ក្នុងពួកនាងទាំងនោះ មានប្រាំនាក់មានគំនិត ហើយប្រាំនាក់លង់។ នាងលង់ទាំងនោះ គេយកតែចង្កៀងទៅ តែមិនបានយកប្រេងជាប់នឹងខ្លួនផងទេ។ ឯពួកនាងមានគំនិតវិញ គេបានយកទាំងចង្កៀង ហើយនិងប្រេងដាក់ក្នុងដបទៅជាមួយផង។ តែដោយប្តីក្រមកពេក បានជានាងទាំងនោះងោកងុយ ហើយដេកលក់ទៅ។ លុះដល់កណ្តាលអធ្រាត្រ ស្រាប់តែឮសូរសម្រែកថា៖ នែ ប្តីមកហើយ ចូរចេញទៅទទួលចុះ។» ម៉ាថាយ ២៥:១-៦។

គេបានយល់ថា ការយាងរបស់ព្រះគ្រីស្ទដែលបានប្រកាសដោយព្រះរាជសារនៃទេវតាទីមួយ គឺតំណាងដោយការមកដល់នៃកូនកម្លោះ។ ការកែទម្រង់ជាសកលដោយសារសេចក្តីប្រកាសថាព្រះគ្រីស្ទយាងមកជាឆាប់ៗនោះ គឺប្រៀបទៅនឹងស្រីព្រហ្មចារី ដែលធ្វើដំណើរចេញទៅជួបកូនកម្លោះ។ ក្នុងរឿងប្រៀបធៀបនេះ គេទាំងអស់គ្នាបានយកចង្កៀងរៀងៗខ្លួន ពោលគឺព្រះគម្ពីរ ហើយក៏ចេញទៅទទួលកូនកម្លោះ។ ប៉ុន្តែ កាលពួកនាងលង់ មិនបានយកប្រេងជាប់នឹងខ្លួន «នោះ ពួកនាងមានគំនិត...គេបានយកទាំងចង្កៀង ហើយនិងប្រេងដាក់ក្នុងដបទៅជាមួយផង»។ ពួកនាងមានគំនិតបានសិក្សាបទគម្ពីរដើម្បីរៀនពីសេចក្តីពិត ហើយបានមានបទពិសោធន៍ផ្ទាល់ខ្លួន ដែលជាការជឿដល់ព្រះ ដែលមិនអាចរំលំបានឡើយ ទោះជាមានការខកចិត្ត ឬការពន្យារពេលវេលាក៏ដោយ។ ខ្លះទៀត ប្រព្រឹត្តទៅដោយកម្សួលចិត្ត ព្រោះដំណឹងនោះធ្វើឱ្យគេភិតភ័យ។ គេបានសំអាងទៅលើជំនឿរបស់អ្នកដទៃ គេស្តប់ចិត្តនឹងមនោសញ្ចេតនាដែលឆេះលឹមៗ ដោយមិនបានយល់ច្បាស់អំពីសេចក្តីពិត ឬអំពីព្រះគុណដែលធ្វើការក្នុងចិត្តឡើយ។ ពួកគេទាំងនេះបានចេញ «ទៅទទួល» ព្រះអម្ចាស់ ដោយសង្ឃឹមថាបានរង្វាន់ភ្លាមៗ ប៉ុន្តែពុំចង់ប្រទះនឹងការពន្យារពេលវេលាឬការខកចិត្តណាឡើយ។ ជំនឿរបស់គេក៏ត្រូវសាបសូន្យទៅ។

«ដោយប្តីក្រមកពេក...នាងទាំងនោះងោកងុយ ហើយដេកលក់ទៅ»។ ការដែលកូនកម្លោះក្រមក គឺតំណាងពីពេលវេលាដែលកន្លងផុតទៅ ពោលគឺការខកចិត្ត ដែលជាការមើលទៅដូចជាពន្យារពេលវេលា។ អ្នកដែលតាំងគោលជំនឿទៅលើការចេះដឹងពីព្រះគម្ពីរ ប្រៀបដូចជាមានថ្មនៅក្រោមជើងរបស់គេ ដែលរលកនៃការខកចិត្តមិនអាចបក់បោកឱ្យរសាត់រសាយបានឡើយ។ «នាងទាំងនោះងោកងុយ ហើយដេកលក់ទៅ» មានន័យថា ក្រុមមួយបានបោះបង់ជំនឿរបស់ខ្លួនចោល មួយទៀតរង់ចាំទាំងអំណត់ លុះត្រាតែទទួលពន្លឺដែលភ្លឺជាង។ អ្នកមានជំនឿសើៗ មិនអាចពឹងផ្អែកទៅលើ

ជំនឿរបស់អ្នកដទៃបានទេ។ ម្នាក់ៗត្រូវឈរឬដួលដោយខ្លួនឯង។

<u>ព្រហស្បតិ៍-២៩ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ២៣

ខព្រះគម្ពីរប្រចាំថ្ងៃ:*រីឯព្រះ ដែលអាចនឹងថែរក្សា មិនឲ្យអ្នករាល់គ្នាជំពប់ដួល ហើយនិងដាក់អ្នករាល់គ្នា នៅចំពោះសិរីល្អទ្រង់ ដោយឥតមានកន្លែងបន្ទោសបាន ព្រមទាំងមានចិត្តត្រេកអរផង។ យូដាស ខ:២៤*

ជំនឿចង់ខុលលេចឡើង

មកទល់ពេលនេះ មានការជឿងប់ងុលចាប់ផ្តើមលេចចេញមក។ អ្នកខ្លះបង្ហាញការជឿងប់ដោយប្រកាន់ថាខ្លួនត្រូវទាំងអស់។ ក្រុមជំនុំដ៏ធំនៃពួកនិវត្តក: ពុំបានមូលមតិយល់ស្របដល់គំនិតដែលជឿងប់ងុលរបស់ពួកគេទេ ប៉ុណ្ណឹងហើយ ពួកងប់ងុលនៅតែថ្កោលទោសដល់ដំណើរការនៃសេចក្តីពិតទៀត។

សាតាំងបានដឹងថាខ្លួនកំពុងចាញ់ហើយ ក៏ខំស្វះស្វែងបញ្ឆោតអ្នកខ្លះដែលអះអាងថាមានជំនឿ ហើយធ្វើឱ្យគេប្រព្រឹត្តជ្រុលហួសហេតុ ដើម្បីផ្ទាញ់ផ្ទាលដល់កិច្ចការរបស់ព្រះ។ បន្ទាប់មក ភ្នាក់ងាររបស់វា នៅចាំចាប់គ្រប់ទាំងកំហុស គ្រប់ទាំងអំពើមិនសមរម្យ ហើយយកទៅនិយាយបន្លើសឱ្យគេដឹងឮគ្រប់គ្នា ដើម្បីឱ្យគេខ្ពើមរអើមដល់ពួកនិវត្តក:។ ចំនួនមនុស្សដែលវាប្រមូលឱ្យអះអាងថាជឿក្នុងការយាងមកជាលើកទីពីរបានកើនឡើងប៉ុនណាក្នុងពេលដែលអំណាចរបស់វាគ្រប់គ្រងចិត្តរបស់គេនោះ វាក៏បានប្រយោជន៍កាន់តែច្រើនឡើងប៉ុណ្ណោះដែរ។

សាតាំងគឺជាអ្នក «ដែលចោទប្រកាន់ពីពួកបងប្អូនយើង»។ វិវរណៈ ១២:១០។ វិញ្ញាណរបស់វាបណ្តាលចិត្តមនុស្សឱ្យសម្លឹងចាំចាប់កំហុសនៃរាស្ត្ររបស់ព្រះ ហើយលើកកំហុសទាំងនោះឡើងឱ្យគេឃើញ តែចំណែកឯអំពើល្អរបស់គេវិញ គ្មាននរណាលើកមកនិយាយស្តីសោះ។

ក្នុងគ្រប់ទាំងប្រវត្តិសាស្ត្រនៃព្រះវិហារ គ្មានការកែទម្រង់ណាដែល

ចម្រើនទៅមុខ ដោយឥតប្រទះនឹងឧបសគ្គដ៏ធ្ងន់ធ្ងរនោះឡើយ។ នៅទីណា ដែលសាវ័កប៉ុលបានបង្កើតក្រុមជំនុំឡើង អ្នកខ្លះដែលអះអាងថាទទួលជឿ ហើយនោះ រមែងនាំមកនូវលទ្ធិឈ្វេង។ លោកលូធើរក៏បានរងទុក្ខព្រួយ ដោយសារពួកជឿងប់ងុល អះអាងថាព្រះបានមានបន្ទូលតាមរយៈពួកគេ ផ្ទាល់ និងដោយសារពួកគេតាំងគំនិតរបស់គេលើបទគម្ពីរ។ ភាគច្រើនត្រូវ បានពួកគ្រូថ្មីៗបញ្ឆោត ហើយក៏ចូលរួមជាមួយនឹងសាតាំង ក្នុងការបំបាក់បំបែក នូវអ្វីដែលព្រះបានបណ្តាលឱ្យលោកលូធើរបានសង់ឡើងនោះ។ ពួកវែស្លីក៏ បានប្រទះនឹងឧបាយកលដ៏ប៉ិនប្រសប់របស់សាតាំងដែរ ក្នុងការដែលវា ជំរុញអ្នកដែលពុំមានលំនឹងរឹងមាំ និងមិនបរិសុទ្ធ ឱ្យមានជំនឿងប់ងុល។

លោកវិល្លៀម មិល្លើរ ពុំយល់ស្របនឹងជំនឿងប់ងុលនោះទេ។ គាត់ មានប្រសាសន៍ថា «អារក្សមានអំណាចខ្លាំងណាស់ លើចិត្តមនុស្សខ្លះនា បច្ចុប្បន្នកាលនេះ»។ «ខ្ញុំតែងតែឃើញជាញឹកញាប់នូវភ័ស្តុតាងនៃការគោរព ដែលសម្តែងមកពីក្នុងចិត្ត តាមរយៈភ្នែកក្រហម ថ្ពាល់ដែលសើមដោយទឹក ភ្នែក និងសំឡេងអូលដើមក ជាងអស់ទាំងសំឡេងក្នុងពិភពគ្រីស្ទានទៅ ទៀត»[9]។

ក្នុងកំណែទម្រង់ ពួកសត្រូវបានចោទអំពើអាក្រក់នៃជំនឿងប់ងុល ទៅលើអ្នកដែលខិតខំធ្វើការប្រឆាំងនឹងកិរិយារបៀបនោះវិញ។ អ្នកដែល ប្រឆាំងនឹងចលនានិរត្ត ក៏បានខិតខំប្រព្រឹត្តអំពើស្រដៀងគ្នាដែរ។ ដោយមិន ស្គប់ស្គល់នឹងការពន្លើសកំហុសនៃពួកជឿងប់ងុល គេថែមទាំងផ្សព្វផ្សាយ របាយការណ៍ដែលខុសស្រឡះអំពីរឿងពិត។ ការប្រកាសផ្សាយថាព្រះ គ្រីស្ទគឺនៅនឹងមាត់ទ្វារខ្លួន បានធ្វើឱ្យរំខានដល់សេចក្តីសុខរបស់គេ ព្រោះ គេខ្លាចក្រែងការនោះនឹងបានមកជាពិតតែគេខំសង្ឃឹមថានឹងមិនពិតវិញ។ នេះហើយជាអាថិកំបាំងរបស់ពួកគេ ដែលប្រឆាំងទាស់នឹងពួកនិរត្តក:នោះ។

ការផ្សាយព្រះរាជសាររបស់ទេវតាទីមួយ បានសំដៅទៅលើការគាប សង្កត់នឹងជំនឿងប់ងុលតែម្តង។ អ្នកដែលចូលរួមក្នុងចលនាដ៏ឱឡារិកនេះ

មានការចុះសម្រុងនឹងគ្នា ចិត្តគំនិតគេទាំងឡាយបានពោរពេញទៅដោយសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក និងចំពោះព្រះយេស៊ូវ ដែលគេសង្ឃឹមថានឹងឃើញក្នុងពេលបន្តិចទៀត។ ជំនឿតែមួយ សេចក្តីសង្ឃឹមតែមួយ ដែលប្រកបទៅដោយព្រះពរ បានបង្ហាញថាជាខែលរារាំងដល់ការវាយប្រហាររបស់សាតាំង។

<u>សុក្រ-៣០ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ២៤

ខព្រះគម្ពីរប្រចាំថ្ងៃ:*មនុស្សទាំងនោះជាពួកដែលចេះតែរទូរទាំ ហើយត្អូញត្អែរ ដែលដើរតាមតែសេចក្តីប៉ងប្រាថ្នារបស់ខ្លួន ហើយមាត់គេពោលសុទ្ធតែពាក្យអំនួតអួតយ៉ាងសំបើម គេរាប់អានមនុស្សឲ្យតែបានកំរៃទេ។ យូដាស ខ:១៦*

កំហុសត្រូវបានកែតម្រូវឡើងវិញ

«ដោយប្តីក្រមកពេក...នាងទាំងនោះងោកងុយ ហើយដេកលក់ទៅ។ លុះដល់កណ្តាលអធ្រាត្រ ស្រាប់តែឮសូរសម្រែកថា នែ ប្តីមកហើយ ចូរចេញទៅទទួលចុះ»។ នៅរដូវក្តៅនៃឆ្នាំ១៨៤៤ គេបានប្រកាសផ្សាយនូវអ្វីដែលបានចែងក្នុងបទគម្ពីរ។

អ្វីដែលធ្វើឱ្យគេឈានមកដល់ចលនានេះ គឺជាការរកឃើញថាបទបញ្ជារបស់ស្តេចអើថាសើកសេស ដែលបង្គាប់ឱ្យជួសជុលក្រុងយេរូសាឡិមឡើងវិញនោះ បង្កើតជាចំណុចដើមដំបូងនៃអំឡុងពេល២៣០០ថ្ងៃ បានចេញជាផ្លូវការនៅរដូវស្លឹកឈើរុះនៃឆ្នាំ៤៥៨មុនគ.ស. ពុំមែននៅដើមឆ្នាំដូចដែលគេបានគិតនោះទេ។ ដោយចាប់រាប់ពីរដូវស្លឹកឈើរុះនាឆ្នាំ៤៥៧មុនគ.ស. មក អំឡុងពេល២៣០០ឆ្នាំត្រូវចប់នៅរដូវស្លឹកឈើរុះក្នុងឆ្នាំ១៨៤៤។ និមិត្តរូបតំណាងដែលមានចែងក្នុងគម្ពីរសញ្ញាចាស់ ក៏ចង្អុលទៅរដូវស្លឹកឈើរុះថាជាពេលដែលត្រូវសម្អាតទីបរិសុទ្ធដែរ។

ការសម្លាប់កូនចៀមសម្រាប់បុណ្យរំលងនោះ គឺជាស្រមោលនៃ

ជីវង្គតរបស់ព្រះគ្រីស្ទ និមិត្តរូបតំណាងត្រូវបានសម្រេច ពុំមែនចំពោះតែព្រឹត្តិការណ៍ប៉ុណ្ណោះទេ តែចំពោះពេលវេលាផងដែរ។ នៅថ្ងៃទីដប់បួននៃខែទីមួយរបស់សាសន៍ជូវ ជាថ្ងៃនឹងខែដែលគេសម្លាប់កូនចៀមសម្រាប់បុណ្យរំលងអស់រាប់សតវត្សមកហើយនោះ ព្រះគ្រីស្ទបានតាំងបុណ្យនោះឱ្យគេរំលឹកសេចក្តីសុគតរបស់ទ្រង់ ក្នុងនាមជា «កូនចៀមរបស់ព្រះ»។ នៅចំយប់ដដែលនោះឯង គេបានយកទ្រង់ទៅឆ្កាងហើយធ្វើគុតទ្រង់។

ក្នុងរបៀបដូចគ្នាដែរ និមិត្តរូបតំណាងដែលទាក់ទងនឹងការនិវត្តជាលើកទីពីរ ត្រូវតែសម្រេចនៅចំពេលដែលបានប្រាប់មកក្នុងយញ្ញកិច្ចដែលជានិមិត្តរូបនោះ។ ការសម្អាតទីបរិសុទ្ធ ឬថ្ងៃបុណ្យធួននឹងបាប កើតឡើងនៅថ្ងៃទីដប់ខែទីប្រាំពីរនៃខែជូវ នៅពេលសម្តេចសង្ឃប្រារព្ធពិធីបុណ្យធួននឹងបាប សម្រាប់អស់ទាំងសាសន៍អ៊ីស្រាអែល ហើយដូច្នេះអំពើបាបរបស់គេទាំងឡាយក៏ត្រូវបានលាងពីទីបរិសុទ្ធ រួចហើយសង្ឃក៏ចេញមកប្រទានពរដល់បណ្តាជន។ ហេតុដូច្នេះហើយបានជាគេជឿថាព្រះគ្រីស្ទនឹងយាងមកដើម្បីសម្អាតផែនដីឱ្យបានបរិសុទ្ធ ដោយកម្ទេចអំពើបាប និងអ្នកមានបាបផង ហើយដើម្បីប្រទានព្រះពរជាអមតភាពដល់ប្រជារាស្ត្រដែលកំពុងរង់ចាំទ្រង់។ ថ្ងៃទីដប់ ក្នុងខែទីប្រាំពីរ ថ្ងៃបុណ្យធួននឹងបាបដ៏ឱឡារិក និងពេលលាងសម្អាតទីបរិសុទ្ធ ធ្លាក់ចំថ្ងៃទី២២ ខែតុលា ឆ្នាំ១៨៤៤ ដែលគេគិតថាជាថ្ងៃព្រះអម្ចាស់ត្រូវយាងមក។ អំឡុងពេល២៣០០ថ្ងៃនឹងចប់ក្នុងរដូវស្លឹកឈើរុះ ហើយការសម្រេចសេចក្តីនោះ ហាក់បីដូចជារកមិនជឿមិនបានឡើយ។

សម្រែកពាក់កណ្តាលយប់

ការវែកញែកបានធ្វើឱ្យគេជឿយ៉ាងខ្លាំង ហើយ «សម្រែកកណ្តាលអធ្រាត្រ» បានបន្លឺឡើងដោយអ្នកជឿរាប់ពាន់នាក់។ ចលនានេះបានផ្សាយចេញពីទីក្រុងមួយទៅទីក្រុងមួយ ពីភូមិមួយទៅភូមិមួយ ដូចរលកសមុទ្រដ៏

ធំមួយដូច្នោះ។ ជំនឿងប់ងុលក៏បានរលាយបាត់ទៅ ដូចទឹកកករលាយនៅពេលថ្ងៃរះ។ កិច្ចការនោះ គឺស្រដៀងនឹងពេលដែលពួកកូនចៅអ៊ីស្រាអែលកាលពីជំនាន់បុរាណងាកមកឯព្រះយេហូវ៉ាវិញ បន្ទាប់ពីបានទទួលព្រះរាជសារនៃការបន្ទោស មកពីអ្នកបម្រើទាំងឡាយរបស់ទ្រង់។ អំណរដ៏ស្រើបស្រាលនោះ មានតែបន្តិចបន្តួចទេ តែមានការត្រិះរិះយ៉ាងជ្រាលជ្រៅក្នុងចិត្តមានការសារភាពអំពើបាប ហើយនិងការលះបង់លោកីយ៍ទៀតផង។ ឃើញថាមានការឧទ្ទិសទៅរកព្រះយ៉ាងខ្លាំង។

ក្នុងគ្រប់ទាំងចលនាសាសនាដ៏ធំៗទាំងប៉ុន្មានតាំងពីជំនាន់ពួកសាវ័កមក មិនដែលមានចលនាណាដែលវៀរចាកផុតពីសេចក្តីមិនគ្រប់លក្ខណ៍របស់មនុស្ស និងឧបាយកលដ៏ប៉ិនប្រសប់របស់សាតាំងដូចជាចលនានៅរដូវស្លឹកឈើរុះនាឆ្នាំ១៨៤៤នោះឡើយ។

នៅពេលមានសម្រែកថា «ប្តីមកហើយ» នោះអ្នកដែលរង់ចាំ «ក៏ភ្ញាក់ឡើង រៀបចំចង្កៀងរៀងខ្លួន» គឺគេទាំងឡាយបានសិក្សាព្រះបន្ទូលរបស់ព្រះទាំងចូលចិត្តយ៉ាងខ្លាំងចំពោះអ្វីដែលគេពុំបានដឹងពីមុនៗមក។ អ្នកទីមួយដែលគោរពតាមសម្រែកហៅនោះ គឺមិនមែនអ្នកមានអំណោយទានខ្លាំងក្លានោះទេ ប៉ុន្តែ គឺជាអ្នកដែលបន្ទាបខ្លួនជាងគេ និងជឿស៊ប់ជាងគេវិញ។ អ្នកធ្វើស្រែចម្ការបានចោលធញ្ញជាតិរបស់ខ្លួននៅឯវាល ជាងជួសជុលរថយន្តដាក់ប្រដាប់ប្រដារបស់ខ្លួនចុះ ហើយចេញទៅព្រមានប្រាប់ដល់អ្នកដទៃដោយរីករាយ។ ព្រះវិហារទូទៅ បានបិទទ្វាររបស់គេជំទាស់នឹងដំណឹងនេះ ហើយក្រុមជំនុំមួយចំនួនធំដែលជឿដល់ដំណឹងនោះ ក៏បានដកខ្លួនចេញពីព្រះវិហារ។ អ្នកមិនជឿទាំងឡាយដែលមក ចូលរួមក្នុងការប្រជុំជាមួយពួកនិវត្តក: មានអារម្មណ៍ថា ដំណឹង «នៃ ប្តីមកហើយ» នេះ មានអំណាចគួរឱ្យជឿមែន។ ជំនឿបានធ្វើឱ្យមានការឆ្លើយតបដល់សេចក្តីអធិស្ឋាន។ ព្រះវិញ្ញាណនៃព្រះគុណបានបង្អុរចុះមកលើអ្នកដែលខំស្វែងរកយ៉ាងអស់ពីចិត្ត ដូចជាភ្លៀងធ្លាក់លើដីដែលហួតហែងដែរ។ អ្នកដែលសង្ឃឹម

ថានឹងបានឈរនៅចំពោះព្រះភ័ក្ត្រព្រះអង្គប្រោសលោះ ក្នុងពេលបន្តិចទៀត នោះ មានអំណរពេកក្រៃ ព្រោះព្រះវិញ្ញាណបរិសុទ្ធបានរំលាយចិត្តរបស់គេ។

<u>សៅរ៍-៣១ កក្កដា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ២៥

ខព្រះគម្ពីរប្រចាំសប្តាហ៍: *ពួកស្ងួនភ្ងាអើយ ចូរនឹកចាំពីព្រះបន្ទូល ដែលពួកសាវ័ករបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង បានផ្សាយប្រាប់ពីដើមរៀងមកចុះ។ យូដាស ខ:១៧*

អ្នកដែលបានឮដំណឹងនោះ បានមកដល់ពេលដែលគេសង្ឃឹមថានឹងជួបព្រះអម្ចាស់របស់ខ្លួនហើយ។ ពួកគេបានអធិស្ឋានជាញឹកញយជាមួយគ្នា។ គេតែងតែជួបជុំគ្នានៅទីស្ងាត់ដាច់ពីគេ ដើម្បីប្រកបជាមួយនឹងព្រះ ហើយសំឡេងនៃការអង្វរករចេញពីទីវាល និងព្រៃឈើ អណ្តែតឡើងទៅឋានសួគ៌។ ការមានទំនុកចិត្តក្នុងខ្លួនថាព្រះសព្វព្រះទ័យចំពោះខ្លួនហើយនោះ គឺប្រសើរជាងម្ហូបអាហារប្រចាំថ្ងៃទៅទៀត ហើយប្រសិនបើពពកមកគ្របដណ្តប់ចិត្តគេឱ្យខ្មៅងងឹតវិញ ក៏គេពុំនៅស្ងៀមដែរទាល់តែ បានពិសោធព្រះគុណដែលអត់ទោសឱ្យសិន។

ខកចិត្តម្តងទៀត

ប៉ុន្តែ ម្តងទៀតហើយ ពេលវេលាដែលគេសង្ឃឹមថាព្រះអង្គសង្គ្រោះនឹងយាងមកនោះក៏បានកន្លងផុតទៅ ហើយព្រះអង្គពុំបានយាងមក។ ឥឡូវនេះ គេមានអារម្មណ៍ដូចនាងម៉ារាដែរ នៅពេលនាងចេញទៅផ្នូររបស់ព្រះអង្គសង្គ្រោះ ហើយឃើញនៅទទេនោះ នាងក៏យំហើយឧទានឡើងថា៖ «គេបានយកព្រះអម្ចាស់ខ្ញុំទៅបាត់ហើយ ខ្ញុំមិនដឹងជាគេទុកទ្រង់នៅឯណាទេ»។ យ៉ូហាន ២០:១៣។

ការខ្លាចក្រែងដំណឹងនោះអាចមកជាការពិត បានធ្វើជារនាំងមួយសម្រាប់ពិភពនៃអ្នកមិនជឿ។ ប៉ុន្តែ នៅពេលពុំឃើញសញ្ញានៃសេចក្តីក្រោធ

របស់ព្រះ គេក៏លែងខ្លាច ហើយបន្តការផ្ចាញ់ផ្ចាល និងការចំអកឡកឡឺយ តទៅទៀត។ ក្រុមមួយដ៏ធំដែលអះអាងថាជឿ បានលះបង់ជំនឿរបស់ខ្លួនវិញ។ ពួកអ្នកចំអកទាំងនេះ បានទាក់ទាញមនុស្សខ្សោយ និងមនុស្សកំសាកមកខាងខ្លួន ហើយរួបរួមគ្នាប្រកាសថា ពិភពលោកប្រហែលជានៅដដែលអស់រាប់ពាន់ឆ្នាំទៅទៀត។

ពួកអ្នកជឿអស់ពីចិត្ត ហើយមានចិត្តស្មោះត្រង់ បានលះបង់គ្រប់ទាំងអ្វីៗទាំងអស់ ដើម្បីព្រះគ្រីស្ទ ហើយដូចដែលគេបានជឿនោះ គេបានផ្តល់នូវការព្រមានចុងក្រោយរបស់គេដល់លោកីយ៍ហើយ។ គេបានអធិស្ឋានដោយមានចិត្តប៉ងប្រាថ្នាយ៉ាងខ្លាំងថា «ព្រះអម្ចាស់យេស៊ូវអើយ សូមយាងមក»។ ប៉ុន្តែ ឥឡូវនេះ ការដែលត្រូវទទួលបន្ទុកស្មុគស្មាញនៃជីវិតម្តងទៀត ហើយត្រូវទ្រាំទ្រនឹងពិភពចំអកឡកឡឺយនោះ គឺជាគ្រាលំបាកដ៏អាក្រក់អាក្រីណាស់។

នៅពេលព្រះយេស៊ូវគង់លើសត្វលា យាងចូលទៅក្នុងក្រុងយេរូសាឡិមដោយជោគជ័យនោះ អស់អ្នកដែលដើរតាមទ្រង់បានជឿថា ទ្រង់នឹងឡើងសោយរាជ្យលើបល្ល័ង្ករបស់ស្តេចដាវីឌ ហើយរំដោះអ៊ីស្រាអែលឱ្យរួចពីពួកអ្នកជិះជាន់លើខ្លួន។ មនុស្សជាច្រើនបានដោះអាវធំលាតត្រដាងក្រាលធ្វើជាព្រំ ឬរាយធាងចាកតាមផ្លូវដែលទ្រង់យាង ដោយក្តីសង្ឃឹមយ៉ាងខ្លាំង។ ពួកសាវ័កកំពុងតែសម្រេចគោលបំណងរបស់ព្រះ ប៉ុន្តែគេកំពុងតែឆ្ពោះទៅកាន់សេចក្តីខកចិត្តដ៏ល្វីងជូរចត់ដែរទេ។ ពីរបីថ្ងៃក្រោយមក គេបានរកឃើញជីវិតដ៏ឈឺចុកចាប់របស់ព្រះអង្គសង្គ្រោះ ហើយបានផ្តេកទ្រង់ទៅក្នុងផ្នូរទៀតផង។ សេចក្តីសង្ឃឹមរបស់គេក៏បានស្លាប់ជាមួយនឹងព្រះយេស៊ូវដែរ។ លុះដល់ព្រះអម្ចាស់របស់គេបានចេញពីផ្នូរវិញ ទើបពួកគេបានយល់ថា អ្វីៗទាំងអស់សុទ្ធតែបានទាយទុកក្នុងបទទំនាយរួចមកហើយ។

ការផ្សាយដំណឹងចំពេលវេលា

ក្នុងរបៀបដូចគ្នាដូច្នោះដែរ លោកមិល្លើរ និងគូកនរបស់គាត់ បានសម្រេចបទទំនាយ ហើយផ្សាយដំណឹងដែលព្រះគម្ពីរចែងឱ្យប្រាប់ដល់ពិភពលោក។ ប្រសិនបើគេបានយល់ពេញលេញនូវបទទំនាយដែលចង្អុលប្រាប់ពីការខកចិត្តរបស់គេនោះ គេមិនអាចផ្សាយដំណឹងនោះបានទេ ហើយក៏មិនអាចថ្លែងប្រាប់ពីដំណឹងផ្សេងៗទៀត ដែលនឹងត្រូវផ្សព្វផ្សាយដល់គ្រប់ជាតិសាសន៍ មុនពេលព្រះយេស៊ូវយាងមកបានដែរ។ ព្រះរាជសាររបស់ទេវតាទីមួយ និងទីពីរ ត្រូវបានផ្សាយចំពេលវេលា ហើយបានសម្រេចកិច្ចការដែលព្រះគ្រោងទុកឱ្យទេវតាទាំងពីរនោះសម្រេច។

<u>អាទិត្យ-១ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ២៦

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែពួកមនុស្សសុចរិតនឹងរស់នៅ ដោយអាងសេចក្តីជំនឿ បើអ្នកណាថយទៅវិញ នោះចិត្តអញគ្មានសេចក្តីអំណរចំពោះអ្នកនោះទេ»។ ហេព្រើរ ១០:៣៨*

លោកីយ៍បានគិតថា បើព្រះគ្រីស្ទពុំបានយាងមកទេ នោះលទ្ធិនិរត្តនិយមនឹងត្រូវរលាយសាបសូន្យហើយ ប៉ុន្តែនៅពេលដែលមនុស្សជាច្រើនលះបង់ជំនឿរបស់ខ្លួននោះ មានអ្នកខ្លះទៀតកាន់ជឿយ៉ាងខ្ជាប់ខ្ជួន។ ផលផ្លែនៃចលនានិរត្ត វិញ្ញាណនៃការត្រិះរិះ ការលះបង់លោកីយ៍ និងការកែទម្រង់ជីវិត ធ្វើទីបន្ទាល់ថា ដំណឹងនោះគឺមកពីព្រះ។ គេមិនហ៊ានប្រកែកថាព្រះវិញ្ញាណបរិសុទ្ធពុំបានធ្វើជាស្មរបន្ទាល់ ដល់ការផ្សព្វផ្សាយអំពីការនិរត្តជាលើកទីពីរឡើយ។ គេរកកំហុសក្នុងអំឡុងបទទំនាយមិនឃើញសោះ។ បក្ខប្រឆាំងរបស់គេ មិនបានជោគជ័យក្នុងការរំលំនូវការបកស្រាយបទទំនាយទេ។ គេមិនសុខចិត្តលះបង់ដំណាក់ការដែលខ្លួនស្រូតដល់ហើយនោះឡើយ ដោយព្រោះខ្លួនបានខិតខំសិក្សាបទគម្ពីរដោយអធិស្ឋាន និងការយកចិត្តទុកដាក់យ៉ាងអស់ពីចិត្ត ដោយគំនិតបានភ្លឺស្វាងដោយព្រះ

វិញ្ញាណរបស់ព្រះ ហើយចិត្តឆេះឆូលដោយអំណាចដ៏រស់នៃព្រះវិញ្ញាណ
នោះ ព្រមទាំងបានឈររឹងមាំ ប្រឆាំងនឹងអ្នកមានចំណេះវិជ្ជាខ្ពង់ខ្ពស់ និង
អ្នកបុិនប្រសប់ខាងវោហារផង។

ពួកនិវត្តក:បានជឿថា ព្រះបានដឹកនាំគេឱ្យព្រមានអំពីការវិនិច្ឆ័យ
ទោស។ គេបានថ្លែងថា «ដំណឹងនោះបានសាកល្បងចិត្តរបស់អស់អ្នក
ដែលឲ...ប្រយោជន៍ឱ្យអ្នកដែលនឹងពិនិត្យចិត្តរបស់ខ្លួនអាចដឹងថា តើព្រះ
នឹងយើញគេនៅខាងណា បើទ្រង់យាងមកមែននោះ តើគេនឹងឧទានឡើង
ថា 'នេះគឺជាព្រះនៃយើងរាល់គ្នា យើងបានរង់ចាំទ្រង់ ហើយទ្រង់នឹងជួយ
សង្គ្រោះយើង' ឬគេស្រែកហៅថ្ម និងភ្នំឱ្យធ្លាក់លើគេ ដើម្បីលាក់បាំងខ្លួនពីព្រះ
ភ័ក្ត្ររបស់ព្រះដែលប្រថាប់នៅលើបល្ល័ង្ក»[២]។

អារម្មណ៍របស់អ្នកដែលនៅតែជឿថាព្រះបានដឹកនាំពួកគេនោះ គឺត្រូវ
បានបញ្ជាក់ឱ្យយើញនៅក្នុងពាក្យពេចន៍របស់លោកវិល្លៀម មិល្លើរថា៖
«សេចក្តីសង្ឃឹមរបស់ខ្ញុំក្នុងការយាងត្រឡប់មកវិញនៃព្រះគ្រីស្ទ គឺនៅតែរឹងមាំ
ដដែល។ ក្រោយពីបានពិចារណាយ៉ាងហ្មត់ចត់អស់រាប់ឆ្នាំហើយនោះ ខ្ញុំគ្រាន់
តែធ្វើអ្វីដែលជាភារកិច្ចដែលខ្ញុំត្រូវធ្វើប៉ុណ្ណោះ»។ «មនុស្សរាប់ពាន់នាក់ មិន
ថាពណ៌សម្បុរអ្វីឡើយ បានសិក្សាបទគម្ពីរ ដោយព្រោះតែការផ្សព្វផ្សាយ
នៅពេលនោះ ហើយមធ្យោបាយទាំងនោះតាមរយ:ជំនឿ និងការប្រោះ
លោហិតរបស់ព្រះគ្រីស្ទ បានធ្វើឱ្យគេស្រុះស្រួលជាមួយនឹងព្រះវិញ»[៣]។

គេនៅតែមានជំនឿ

ព្រះវិញ្ញាណរបស់ព្រះនៅតែគង់ជាមួយនឹងអស់អ្នកដែលមិនរហ័ស
នឹងបដិសេធនូវពន្លឺ ដែលគេបានទទួល និងមិនរហ័សជំទាស់នឹងចលនា
និវត្ត។ «ដូច្នេះ ចូរកុំឱ្យបោះបង់ចោលសេចក្តីក្លាហានរបស់អ្នករាល់គ្នា ដែល
មានរង្វាន់ជាធំនោះឡើយ។ ដ្បិតអ្នករាល់គ្នាត្រូវការនឹងសេចក្តីអត់ធ្មត់ ដើម្បី
ឱ្យបានទទួលសេចក្តីដែលបានសន្យា ដោយធ្វើតាមព្រះហឬទ័យព្រះ។

ពីព្រោះនៅតែបន្តិចទៀត "នោះព្រះអង្គដែលត្រូវមក ទ្រង់នឹងយាងមកមែន ឥតបង្អង់ឡើយ។ តែពួកសុចរិតនឹងរស់នៅដោយអាងសេចក្តីជំនឿ បើអ្នកណាថយទៅវិញ នោះចិត្តអញគ្មានសេចក្តីអំណរចំពោះអ្នកនោះទេ"។ តែយើងរាល់គ្នាមិនមែនជាពួកអ្នកដែលថយទៅវិញឱ្យត្រូវវិនាសនោះឡើយ គឺជាពួកអ្នកដែលមានសេចក្តីជំនឿសម្រាប់ឱ្យព្រលឹងបានសង្គ្រោះវិញ»។ ហេព្រើរ ១០:៣៥-៣៩។

ការដាស់តឿននេះ គឺសម្រាប់ក្រុមជំនុំនៅថ្ងៃចុងក្រោយ ព្រោះបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះអង្គហាក់បីដូចជានៅបង្អង់។ មនុស្សដែលត្រូវបានបរិយាយខាងលើនេះ បានធ្វើតាមព្រះហឫទ័យរបស់ព្រះ ក្នុងការដើរតាមការដឹកនាំរបស់ព្រះវិញ្ញាណរបស់ទ្រង់ និងព្រះបន្ទូលរបស់ទ្រង់ តែគេពុំបានយល់នូវគោលបំណងរបស់ទ្រង់ក្នុងបទពិសោធន៍របស់គេទេ។ ជួនកាលគេមានចិត្តសង្ស័យថា តើព្រះបានដឹកនាំគេមែន ឬមិនមែន។ មកដល់ពេលនេះ ពាក្យទាំងនេះគឺសមស្របនឹងកាល:ទេស: «មនុស្សសុចរិតនឹងរស់នៅដោយអាងសេចក្តីជំនឿ»។ បើទោះជាធ្លាក់ទឹកចិត្តដោយសេចក្តីសង្ឃឹមដែលធ្វើឱ្យខកចិត្តក៏ដោយ ក៏គេនៅតែអាចឈរបានដោយសារតែជំនឿទៅលើព្រះ និងព្រះបន្ទូលទ្រង់ប៉ុណ្ណោះ។ ការដែលលះបង់ចោលជំនឿរបស់ខ្លួន ហើយបដិសេធអំណាចនៃព្រះវិញ្ញាណបរិសុទ្ធដែលបានជួយរត់ការក្នុងការផ្សាយដំណឹងនោះ គឺជាការដកខ្លួនងាកទៅឯនរកហើយ។ ផ្លូវដ៏សុខសាន្តតែមួយគត់នោះ គឺការឱបក្រសោបពន្លឺដែលគេបានទទួលពន្លឺដែលគេបានទទួលពីព្រះរួចហើយ ហើយបន្តការស្រាវជ្រាវបទគម្ពីរ ព្រមទាំងរង់ចាំមើលដោយអំណត់ ដើម្បីទទួលពន្លឺបន្ថែមទៀត។

References:

1. Bliss, pp. 236, 282.

2. *The Advent Herald and Signs of the Times Reporter*, vol. 8, no. 14, Nov. 13, 1844.

ការបើកសម្តែងអាថ៌កំបាំងនៃរោងឧបោសថ

<u>ចន្ទ-២ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ២៧

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដូច្នេះ កុំឲ្យបោះបង់ចោលសេចក្តីក្លាហានរបស់អ្នករាល់គ្នា ដែលមានរង្វាន់ជាធំនោះឡើយ។ ហេព្រើរ ១០:៣៥*

បទគម្ពីរដែលសំខាន់ជាងអ្វីៗទាំងអស់ ដែលជាគ្រឹះ និងជាសសរកន្លោងនៃជំនឿនៃដំណើរនិវត្ត គឺជាបទទំនាយដែលចែងថា «ដរាបដល់បានកន្លង២៣០០ព្រឹកនិងល្ងាចទៅ នោះទើបទីបរិសុទ្ធនឹងបានស្អាតឡើង»។ ដានីយ៉ែល ៨:១៤។ ពាក្យទាំងនេះជាពាក្យធ្លាប់ដឹងឮច្បាស់ដល់អស់អ្នកដែលជឿក្នុងការយាងមកជាឆាប់របស់ព្រះអម្ចាស់ ប៉ុន្តែ ព្រះអម្ចាស់ពុំបានយាងមកឡើយ។ អ្នកជឿទាំងឡាយបានដឹងថា ព្រះបន្ទូលរបស់ព្រះមិនអាចខុសបានទេ ការបកស្រាយបទទំនាយរបស់គេត្រូវតែខុសវិញ។ ប៉ុន្តែ តើវាខុសកន្លែងណាខ្លះ?

ព្រះបានដឹកនាំរាស្ត្រទ្រង់ ក្នុងចលនានិវត្តដ៏ធំនេះ។ ទ្រង់ពុំអនុញ្ញាតឱ្យកិច្ចការនេះចប់ក្នុងភាពងងឹត និងក្នុងការខកចិត្ត នាំឱ្យតែគេថ្កោលទោសថាខុស ឬវង្វេងស៊ប់ហួសហេតុនោះទេ។ ទោះជាមានភាគច្រើន បានបោះបង់ចោលលេខអត្តក្នុងអំឡុងពេលវេលានៃបទទំនាយ ហើយបដិសេធចលនាដែលស្ថិតនៅលើអំឡុងពេលវេលានោះក៏ដោយ មានខ្លះទៀតមិនព្រមលះបង់ជំនឿ និងការពិសោធដែលបានទ្រទ្រង់ដោយបទគម្ពីរ និងព្រះវិញ្ញាណរបស់ព្រះឡើយ។ ភារកិច្ចរបស់គេ គឺដើម្បីកាន់ខ្ជាប់នូវសេចក្តីពិតដែលមានមកហើយ។ គេបានសិក្សាបទគម្ពីរ ដើម្បីរកកំហុសរបស់ខ្លួន ដោយការអធិស្ឋានដ៏អស់ពីចិត្ត។ ពេលគេរកកំហុសក្នុងការគិតលេខក្នុងអំឡុងពេល

វេលានៃបទទំនាយមិនឃើញគេក៏បែរមកពិនិត្យកម្មវត្ថុនៃរោងឧបោសថឱ្យ
បានជិតជិតថែមទៀត។

គេបានរកឃើញថា គ្មានភ័ស្តុតាងណាក្នុងបទគម្ពីរ ដែលគាំទ្រទស្សន:
ដែលគេនិយមថាផែនដីជារោងឧបោសថទេ ប៉ុន្តែ គេបានរកឃើញការ
ពន្យល់ពីរោងឧបោសថយ៉ាងពេញលេញ ស្តីពីប្រភេទទីកន្លែង និងយញ្ញកិច្ច
នៃរោងឧបោសថនោះ៖

«ចំណែកសេចក្តីសញ្ញាមុននោះ គឺមានរបៀបថ្វាយបង្គំព្រះ ក៏មានទី
បរិសុទ្ធ ជាកន្លែងមានជើងចង្កៀង និងតុ ហើយនំប៉័ងតាំងទុក។ ខាងក្រោយ
វាំងននទីពីរមានកន្លែងហៅថា ទីបរិសុទ្ធបំផុត។ ទីនោះមានជើងពានមាស
សម្រាប់ដុតគ្រឿងក្រអូប និងហឹបនៃសេចក្តីសញ្ញា ដែលស្រោបដោយមាស
ជុំវិញទាំងអស់។ នៅក្នុងហឹបនោះមានចានមាសដាក់នំម៉ាន៉ា ក៏មានដំបង
របស់លោកអើរ៉ុនដែលប៉ិចឡើង និងបន្ទះថ្មនៃសេចក្តីសញ្ញាផង។ ឯខាងលើ
ហឹបនោះ មានរូបចេរូប៊ីនដ៏មានសិរីល្អ ដែលបាំងទីសន្តោសប្រោស»។
ហេព្រើរ ៩:១-៥។

រោងឧបោសថ ជាអាគារដែលបានសង់ដោយលោកម៉ូសេក្រោម
បញ្ជាពីព្រោះ ជាព្រះទីនាំងនៅលោកីយ៍នៃព្រះដ៏ខ្ពស់បំផុត។ «ឱ្យគេស្អាងទី
បរិសុទ្ធ ដើម្បីឱ្យអញបាននៅកណ្តាលគេ» (និក្ខមនំ ២៥:៨) នេះគឺជាការ
បង្គាប់ពីព្រះដល់លោកម៉ូសេ។ រោងឧបោសថជាទម្រង់ដ៏រុងរឿងសម្បើម
មួយ។ ក្រៅពីទីធ្លាខាងក្រៅ រោងឧបោសថមានពីរបន្ទប់ ហៅថាទីបរិសុទ្ធ និង
ទីបរិសុទ្ធបំផុតបែងចែក ដាច់ពីគ្នាដោយវាំងនន ឬស្បៃដ៏ស្អាតមួយ។
វាំងននស្រដៀងគ្នាមួយទៀត បិទផ្លូវចូលទៅកាន់បន្ទប់ទីមួយ។

ទីបរិសុទ្ធ និងទីបរិសុទ្ធបំផុត

នៅក្នុងទីបរិសុទ្ធ ជើងចង្កៀង និងទៀនទាំងប្រាំពីរ ស្ថិតនៅខាងត្បូង
ហើយបញ្ចេញពន្លឺទាំងយប់ទាំងថ្ងៃ។ នៅខាងជើង មានតុ និងនំប៉័ងតាំងទុក។

នៅពីមុខវាំងននដែលខណ្ឌទីបរិសុទ្ធ និងទីបរិសុទ្ធបំផុតនោះ មានជើងពាន មាសនៃគ្រឿងក្រអូប ដែលផ្សែងក្រអូបព្រមទាំងពាក្យអធិស្ឋាននៃសាសន៍ អ៊ីស្រាអែល បានហុយភាយនៅចំពោះព្រះរៀងរាល់ថ្ងៃ។

ក្នុងទីបរិសុទ្ធបំផុត មានហឹប ជាប្រអប់មួយដែលស្រោបដោយមាស ហើយជាប្រដាប់ដាក់ក្រឹត្យវិន័យដប់ប្រការ។ នៅលើហឹប ជាទីសន្តោស ប្រោស ដែលមានរូបចេរូប៊ីនពីរធ្វើពីមាសសុទ្ធ។ នៅក្នុងបន្ទប់នេះ មានវត្តមាន របស់ព្រះសម្តែងក្នុងពពកនៃសិរីល្អ នៅចន្លោះចេរូប៊ីន។

<u>អង្គារ-៣ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ២៨

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដ្បិតអ្នករាល់គ្នាត្រូវការនឹងសេចក្តីអត់ធ្មត់ ដើម្បីឲ្យបានទទួលសេចក្តីដែលបានសន្យា ដោយធ្វើតាមព្រះហឫទ័យព្រះ។*
ហេព្រើរ ១០:៣៦

បន្ទាប់ពីពួកហេព្រើរបានតាំងទីលំនៅក្នុងស្រុកកាណានមក រោងឧបោសថត្រូវបានជំនួសដោយព្រះវិហារនៃស្តេចសាឡូម៉ូនវិញ ជាអាគារដែលមិនអាចយកពីកន្លែងមួយទៅកន្លែងមួយបាន ហើយធំជាងមុន មានទំហំសមាមាត្រដូចគ្នា ហើយមានរៀបតុបតែងស្រដៀងនឹងគ្នាដែរ។ រោងឧបោសថបានស្ថិតស្ថេរក្នុងទម្រង់របៀបនេះ រៀរលែងតែនៅជំនាន់ដានីយ៉ែល កាលព្រះវិហារនោះស្ថិតក្នុងភាពហិនហោច រហូតដល់ឆ្នាំ៧០គ.ស. ក្នុងពេលដែលរ៉ូមធ្វើវិនាសកម្មដល់ព្រះវិហារ។ នេះជារោងឧបោសថនៅផែនដីតែមួយគត់ដែលព្រះគម្ពីរប្រាប់មក ដែលជារោងឧបោសថនៃសេចក្តីសញ្ញាទីមួយ។ ប៉ុន្តែ តើសេចក្តីសញ្ញាថ្មីពុំមានរោងឧបោសថទេឬ?

ត្រឡប់ទៅគម្ពីរហេព្រើរវិញ អ្នកស្វែងរកសេចក្តីពិតបានរកឃើញរោងឧបោសថទីពីរ ឬរោងឧបោសថនៃសេចក្តីសញ្ញាថ្មី មានចែងក្នុងពាក្យដែលបានដកស្រង់ទាំងនេះថា៖ «ចំណែកសេចក្តីសញ្ញា *មុននោះ* គឺមានរបៀបថ្វាយបង្គំព្រះ ក៏មានទីបរិសុទ្ធដែលនៅលោកីយ៍នេះដែរ» ត្រឡប់ទៅ

ជំពូកមុនវិញ មានចែងដូចតទៅថា៖ «បង្រួមសេចក្ដីអធិប្បាយទាំងប៉ុន្មាន អម្បាញ់មិញនេះ នោះគឺថា យើងរាល់គ្នាមានសម្ដេចសង្ឃមួយអង្គយ៉ាង នោះ ដែលទ្រង់បានគង់ខាងស្ដាំបល្ល័ង្កនៃឫទ្ធានុភាពនៅឋានសួគ៌ ជាអ្នក មានការងារក្នុងទីបរិសុទ្ធ និងក្នុងរោងឧបោសថដ៏ពិត ដែលព្រះអម្ចាស់បាន ដំឡើងមិនមែនមនុស្សទេ»។ ហេព្រើរ ៨:១,២។

នេះគឺជាការលើកសម្ដែងពីរោងឧបោសថនៃសេចក្ដីសញ្ញាថ្មី។ រោងឧបោសថនៃសេចក្ដីសញ្ញាទីមួយ គឺបានដំឡើងឡើងដោយម៉ូសេ តែមួយនេះបានដំឡើងដោយព្រះអម្ចាស់។ នៅក្នុងរោងឧបោសថនោះ សង្ឃនៅផែនដីបានប្រព្រឹត្តកិច្ចការរបស់ខ្លួន។ តែក្នុងរោងឧបោសថនេះ ព្រះគ្រីស្ទដ៏ជាសម្ដេចសង្ឃដ៏ធំរបស់យើង ទ្រង់ប្រកបការងារនៅព្រះហស្តខាងស្ដាំនៃព្រះវរបិតា។ រោងឧបោសថមួយនៅផែនដី មួយទៀតនៅឯស្ថានសួគ៌។

រោងឧបោសថដែលបានសង់ដោយម៉ូសេ ត្រូវបានធ្វើឡើងតាមគំរូ។ ព្រះអម្ចាស់បានបង្គាប់ថា៖ «ត្រូវឱ្យឯងធ្វើរោងឧបោសថ និងគ្រឿងប្រដាប់ទាំងប៉ុន្មាន តាមគំរូដែលអញនឹងបង្ហាញឯង»។ «ហើយត្រូវប្រយ័ត្ននឹងធ្វើឱ្យត្រឹមត្រូវតាមគំរូ ដូចដែលបានបង្ហាញឱ្យឯងឃើញនៅលើភ្នំស្រាប់»។ រោងឧបោសថទីមួយ គឺ «ជាសេចក្ដីប្រៀបពន្យល់ដល់ជាន់ឥឡូវនេះ ជាគ្រាដែលគេនៅតែថ្វាយតង្វាយ និងយញ្ញបូជានៅឡើយ»។ បន្ទប់បរិសុទ្ធទាំងពីរនៃរោងឧបោសថទីមួយនេះគឺជា «គំរូពីរបស់ស្ថានសួគ៌»។ សង្ឃទាំងឡាយបានប្រកបកិច្ចការក្នុងនាម «ជាគំរូ និងជាស្រមោលពីរបស់នៅស្ថានសួគ៌»។ ព្រះគ្រីស្ទមិនបានយាងចូលទៅក្នុងទីបរិសុទ្ធធ្វើដោយដៃ ដែលជាគំរូពីទីបរិសុទ្ធពិតនោះទេ គឺបានចូលទៅក្នុងស្ថានសួគ៌នោះឯង ដើម្បីនឹងលេចមកក្នុងពេលឥឡូវនេះ នៅចំពោះព្រះភក្ត្រនៃព្រះ តំណាងយើងរាល់គ្នា។ និក្ខមនំ ២៥:៩,៤០; ហេព្រើរ ៩:៨,២៣; ៨:៥; ៩:២៤។

រោងឧបោសថនៅស្ថានសួគ៌ គឺជាគំរូដើមដ៏ធំ ឯរោងឧបោសថដែលបានសង់ដោយម៉ូសេ គឺជាការចម្លងពីគំរូដើមនោះឯង។ សោភណភាពនៃ

រោងឧបោសថនៅផែនដី បញ្ចាំងសិរីល្អនៃព្រះវិហារនៅស្ថានសួគ៌ ដែលជាកន្លែងដែលព្រះគ្រីស្ទទ្រង់ធ្វើកិច្ចការសម្រាប់យើងរាល់គ្នា នៅចំពោះបល្ល័ង្ករបស់ព្រះ។ សេចក្តីពិតដ៏សំខាន់ៗ ស្តីពីរោងឧបោសថនៅស្ថានសួគ៌ និងការប្រោសលោះរបស់មនុស្ស គឺត្រូវបានបង្រៀនដោយរោងឧបោសថនៅផែនដី និងយញ្ញកិច្ចនៃរោងឧបោសថនេះ។

បន្ទប់ទាំងពីរ

បន្ទប់បរិសុទ្ធទាំងពីរនៃរោងឧបោសថនៅស្ថានសួគ៌ គឺបានតំណាងដោយបន្ទប់ទាំងពីរក្នុងរោងឧបោសថនៅផែនដី។ ព្រះបានអនុញ្ញាតឱ្យយ៉ូហានឃើញព្រះវិហាររបស់ទ្រង់នៅឯស្ថានសួគ៌។ គាត់បានឃើញ «ចង្កៀងប្រាំពីរឆេះនៅពីខាងមុខបល្ល័ង្ក»។ គាត់បានឃើញទេវតាមួយ «កាន់ពានមាស ហើយមានគ្រឿងក្រអូបជាច្រើនបានប្រគល់ឱ្យទេវតានោះ ដើម្បីនឹងថ្វាយជាមួយនឹងសេចក្តីអធិស្ឋានរបស់ពួកបរិសុទ្ធ នៅលើអាសនាមាសដែលនៅមុខបល្ល័ង្ក»។ វិវរណៈ ៤:៥; ៨:៣។ ទីនេះ ហោរាបានឃើញបន្ទប់ទីមួយនៃរោងឧបោសថដែលនៅឯស្ថានសួគ៌ ព្រមទាំងបានឃើញ «ចង្កៀងប្រាំពីរឆេះ» និង «អាសនាមាស» ដែលតំណាងដោយជើងពានមាស និងអាសនានៃគ្រឿងក្រអូបក្នុងរោងឧបោសថនៅផែនដី។

«មានគេបើកព្រះវិហារនៃព្រះ» ម្តងទៀត ហើយគាត់បានមើលទៅក្នុងទីបរិសុទ្ធបំផុត ដែលនៅខាងក្រោយវាំងននទីពីរ។ នៅទីនេះ គាត់បានឃើញ «ហឹបសេចក្តីសញ្ញារបស់ទ្រង់» ដែលតំណាងដោយហឹបដែលលោកម៉ូសេបានធ្វើដើម្បីដាក់ក្រឹត្យវិន័យរបស់ព្រះ។ វិវរណៈ ១១:១៩។

ដូច្នេះអ្នកដែលសិក្សាកម្មវត្ថុនេះ បានរកឃើញភ័ស្តុតាងថាមានរោងឧបោសថនៅស្ថានសួគ៌មែន។ ហោរាម៉ូសេបានសង់រោងឧបោសថនៅផែនដី ដោយចម្លងតាមគំរូដែលព្រះប្រទានឱ្យគាត់។ សាវកប៉ុលបានបង្រៀនថា គំរូនោះគឺជារោងឧបោសថពិត ដែលនៅឯស្ថានសួគ៌នោះឯង។

ហើយលោកយ៉ូហានបានធ្វើទីបន្ទាល់ថា គាត់បានឃើញអោងនោះនៅស្ថានសួគ៌។

<u>ពុធ-៤ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ២៩

ខព្រះគម្ពីរប្រចាំថ្ងៃ:*ពីព្រោះនៅតែបន្តិចទៀត «នោះព្រះអង្គដែលត្រូវមក ទ្រង់នឹងយាងមកមែនឥតបង្អង់ឡើយ។ ហេព្រើរ ១០:៣៧*

នៅក្នុងព្រះវិហារនៅឯស្ថានសួគ៌ ក្នុងទីបរិសុទ្ធបំផុត មានក្រឹត្យវិន័យរបស់ព្រះ។ ហឹបដែលតម្កល់ក្រឹត្យវិន័យគឺបានគ្របដោយទីសន្តោសប្រោសជាកន្លែងដែលទ្រង់អង្វរករដោយសម្អាងព្រះលោហិតរបស់ទ្រង់ជូនសម្រាប់មានបាប។ នេះគឺតំណាងពីសហភាពនៃយុត្តិធម៌ និងមេត្តាធម៌ ក្នុងគម្រោងការនៃការប្រោសលោះ ជាសហភាពមួយដែលធ្វើឱ្យអស់ទាំងស្ថានសួគ៌ពោរពេញទៅដោយសេចក្តីងឿងឆ្ងល់។ នេះគឺជាអាថ៌កំបាំងនៃសេចក្តីមេត្តាករុណា ដែលពួកទេវតាចង់ដឹងចង់ឃើញថាព្រះអាចនៅតែត្រឹមត្រូវឬយ៉ាងណា នៅពេលទ្រង់រកយុត្តិធម៌ឱ្យអ្នកមានបាបដែលបានកែប្រែចិត្ត។

កិច្ចការរបស់ព្រះគ្រីស្ទជាអ្នកអង្វរករ គឺបានសម្តែងដោយហោរាសាការីថា៖ ទ្រង់ «នឹងសង់ព្រះវិហារនៃព្រះយេហូវ៉ាឡើង...ហើយនឹងតាំងសិរីល្អនៃទីនោះឡើង ក៏នឹងអង្គុយគ្រប់គ្រងនៅលើបល្ល័ង្ករបស់ [ព្រះវរបិតា] ទ្រង់ ហើយទ្រង់នឹងបានជាសង្ឃលើបល្ល័ង្កទ្រង់ ហើយស្មារតីនៃសេចក្តីសុខសាន្តនឹងនៅរវាងព្រះទាំងពីរអង្គ»។ សាការី ៦:១២,១៣។

«ទ្រង់នឹងសង់ព្រះវិហារនៃព្រះយេហូវ៉ាឡើង»។ ដោយការសម្រុះសម្រួល និងយញ្ញបូជារបស់ទ្រង់ព្រះគ្រីស្ទគឺជាគ្រឹះស្ថាន និងជាអ្នកស្ថាបនានៃព្រះវិហាររបស់ព្រះ «ទ្រង់ជាថ្មជ្រុងយ៉ាងឯក ដែលដោយសារទ្រង់ ដំណាក់ទាំងមូលនោះបានផ្គុំជាប់គ្នា ទាំងចម្រើនឡើងជាវិហារបរិសុទ្ធក្នុងព្រះអម្ចាស់»។ អេភេសូរ ២:២០,២១។ «ទ្រង់នឹងតាំងសិរីល្អនៃទីនោះឡើង»។ ចម្រៀងនៃអ្នកដែលបានប្រោសលោះនឹងថ្លែងដូច្នេះវិញថា៖ «រីឯព្រះអង្គ

ដែលទ្រង់ស្រឡាញ់យើងរាល់គ្នា ហើយបានលាងយើងដោយព្រះលោហិត
ទ្រង់ឱ្យរួចពីបាប...នោះសូមឱ្យទ្រង់បានសិរីល្អ និងព្រះចេស្តានៅអស់កល្ប
ជានិច្ចរៀងរាបតទៅ»។ វិវរណៈ ១:៥,៦។ ទ្រង់ «នឹងគង់គ្រប់គ្រងនៅលើ
បល្ល័ង្ករបស់ទ្រង់ ហើយទ្រង់នឹងបានជាសង្ឃលើបល្ល័ង្កទ្រង់»។ ព្រះវរបិតាពុំ
ទាន់បានហៅទ្រង់នូវនគរមួយដែលទ្រង់នឹងសោយរាជ្យតរៀងទៅ។ លូកា
១:៣៣។ ក្នុងនាមជាសង្ឃ ឥឡូវនេះព្រះគ្រីស្ទកំពុងតែពិចារណាជាមួយ
ព្រះវរបិតានៅលើបល្ល័ង្កទ្រង់។ នៅលើបល្ល័ង្ក គឺទ្រង់ដែល «ទ្រាំទ្រងអស់
ទាំងសេចក្តីឈឺចាប់របស់យើង ហើយទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយ
របស់យើង» «ទ្រង់បានត្រូវសេចក្តីល្បួងគ្រប់យ៉ាង ដូចជាយើងរាល់គ្នាដែរ
តែឥត ធ្វើបាប» ឡើយ ដើម្បីឱ្យទ្រង់អាច «នឹងជួយដល់អស់អ្នកដែលត្រូវ
សេចក្តី ល្បួងដែរ»។ អេសាយ ៥៣:៤; ហេព្រើរ ៤:១៥; ២:១៨។
ព្រះហស្តដែលមាន ស្នាមរបួស ចំហៀងទ្រង់ដែលគេបានចាក់ ព្រះបាទ
ដែលបានខូចអង្ងរសម្រាប់មនុស្សដែលវិនាស ព្រោះការប្រោសលោះរបស់
គេត្រូវបានទិញ ដោយតម្លៃនេះ។

«ហើយស្មាក្តីនៃសេចក្តីសុខសាន្តនឹងនៅរវាងព្រះទាំងពីរអង្គ»។
សេចក្តីស្រឡាញ់របស់ព្រះវរបិតា គឺជាគ្រឹះស្ថាននៃការសង្គ្រោះសម្រាប់ពូជ
សាសន៍ដែលបានបាត់បង់។ ព្រះយេស៊ូវមានបន្ទូលទៅពួកសាវកទ្រង់ថា៖
«ដ្បិតព្រះវរបិតា ទ្រង់ក៏ស្រឡាញ់អ្នករាល់គ្នាដែរ»។ ព្រះគឺ «នៅក្នុងព្រះគ្រីស្ទ
កំពុងផ្សះផ្សាលោកីយ៍នឹងព្រះអង្គទ្រង់»។ «ព្រះទ្រង់ស្រឡាញ់មនុស្សលោក
ដល់ម្ល៉េះបានជាទ្រង់កំពុងផ្សះផ្សាលោកីយ៍នឹងព្រះអង្គទ្រង់»។ «ព្រះទ្រង់
ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ
មួយ»។ យ៉ូហាន ១៦:២៧; កូរិនថូសទី២ ៥:១៩; យ៉ូហាន ៣:១៦។

ព្រហស្បត៍-៥ សីហា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ៣០

ខព្រះគម្ពីរប្រចាំថ្ងៃ: *ឯអស់ទាំងសង្ឃក៏ឈរធ្វើការងាររាល់តែថ្ងៃ ទាំងថ្វាយយញ្ញបូជាដដែលជាញឹកញាប់ ដែលពុំអាចនឹងដោះបាបបានឡើយ។ ហេព្រើរ ១០:១១*

អាថ៌កំបាំងនៃរោងឧបោសថត្រូវបានបកស្រាយ

«រោងឧបោសថពិត» នៅស្ថានសួគ៌ គឺជារោងឧបោសថនៃសេចក្តីសញ្ញាថ្មី។ នៅពេលព្រះគ្រីស្ទបានសុគត យញ្ញកិច្ចត្រូវបានចប់។ នៅពេលបទទំនាយក្នុងគម្ពីរដានីយ៉ែល ៨:១៤ បានសម្រេចក្នុងលំដាប់ពេលវេលានេះ ទីបរិសុទ្ធដែលសំដៅទៅនោះ គឺប្រាកដជាទីបរិសុទ្ធនៃសេចក្តីសញ្ញាថ្មី។ ដូច្នេះបទទំនាយ «ដរាបបានកន្លង២៣០០ព្រឹកនិងល្ងាចទៅ នោះទើបទី បរិសុទ្ធនឹងបានស្អាតឡើង» គឺចង្អុលទៅទីបរិសុទ្ធ នៅឯស្ថានសួគ៌ទេ។

ប៉ុន្តែ តើការសម្អាតទីបរិសុទ្ធនោះគឺជាអ្វីទៅ? តើមានអ្វីនៅស្ថានសួគ៌ដែលត្រូវលាងសម្អាតនោះ? នៅក្នុងគម្ពីរហេព្រើរជំពូក៩ ការសម្អាតរោងឧបោសថទាំងផែនដី និងស្ថានសួគ៌ គឺបានបង្រៀនយ៉ាងច្បាស់ថា៖ «ហើយតាមក្រឹត្យវិន័យ សឹងតែគ្រប់របស់ទាំងអស់បានស្អាតដោយសារឈាម បើគ្មានខ្ចាយឈាមទេ នោះគ្មានផ្លូវណាឱ្យបានរួចពីបាបឡើយ។ ដូច្នេះ អស់ទាំងគំរូពីរបស់នៅស្ថានសួគ៌បានត្រូវសម្អាត ដោយសាររបស់ទាំងនោះ [ឈាមសត្វ] តែរបស់នៅស្ថានសួគ៌វិញ នោះត្រូវសម្អាតដោយយញ្ញបូជាប្រសើរជាងទៅទៀត» (ហេព្រើរ ៩:២២,២៣) ពោលគឺព្រះលោហិតដ៏ថ្លៃវិសេសរបស់ព្រះគ្រីស្ទ។

ការសម្អាតទីបរិសុទ្ធ

ការសម្អាតក្នុងយញ្ញកិច្ចពិតប្រាកដ ត្រូវតែបានសម្រេចជាមួយនឹងព្រះលោហិតនៃព្រះគ្រីស្ទ។ «បើគ្មានខ្ចាយឈាមទេ នោះគ្មានផ្លូវណាឱ្យបានរួចពីបាបឡើយ»។ ការលើកលែងទោស គឺជាការងារដែលនឹងត្រូវសម្រេច។

ប៉ុន្តែ ធ្វើម្តេចបានជាបាប មានការទាក់ទងជាមួយរោងឧបោសថ

នៅស្ថានសួគ៌កើត? ការនេះអាចយល់បាន ដោយយោងទៅលើនិមិត្តរូបនៃយញ្ញកិច្ច ព្រោះពួកសង្ឃនៅផែនដីបានប្រារព្ធ «ជាគំរូ ហើយជាស្រមោលពីរបស់នៅស្ថានសួគ៌»។ ហេព្រើរ ៨:៥។

កិច្ចការនៃរោងឧបោសថនៅផែនដីមានពីរផ្នែក។ ពួកសង្ឃប្រកបការងាររាល់ថ្ងៃនៅក្នុងទីបរិសុទ្ធ ហើយក្នុងមួយឆ្នាំម្តង សង្ឃជាន់ខ្ពស់ធ្វើការថ្វាយយញ្ញបូជាធួននឹងបាបដ៏ពិសេសមួយ នៅក្នុងទីបរិសុទ្ធបំផុត ដើម្បីលាងសម្អាតទីបរិសុទ្ធ។ រៀងរាល់ថ្ងៃអ្នកមានបាបដែលបានលន់តួប្រែចិត្តនាំតង្វាយរបស់ខ្លួន ហើយដាក់ដៃលើក្បាលសត្វដែលត្រូវសម្លាប់ រួចសារភាពអំពើបាបទាំងឡាយរបស់ខ្លួន។ ជានិមិត្តរូប គឺគេផ្ទេរបាបទាំងនោះពីខ្លួន ទៅយញ្ញបូជាដែលឥតទោសសោះ។ សត្វនោះ បន្ទាប់មកត្រូវសម្លាប់។ «ដ្បិតជីវិតនៃរូបសាច់ នោះនៅក្នុងឈាម»។ លេវីវិន័យ ១៧:១១។ ក្រឹត្យវិន័យរបស់ព្រះដែលត្រូវបានបំពាន ទាមទារជីវិតនៃអ្នកប្រព្រឹត្ត។ សង្ឃក៏យកឈាមសត្វដែលតំណាងជីវិតនៃអ្នកមានបាប ចូលទៅក្នុងទីបរិសុទ្ធ ហើយប្រោះនៅមុខស្បៃ ដែលនៅខាងក្រោយនោះគឺជាក្រឹត្យវិន័យដែលអ្នកមានបាបបានប្រព្រឹត្តរំលង។ តាមពិធីនេះ បាបត្រូវបានចម្លងទៅក្នុងទីបរិសុទ្ធបំផុតជានិមិត្តរូប។ ក្នុងករណីខ្លះ គេពុំបានយកឈាមចូលទៅក្នុងទីបរិសុទ្ធទេ ប៉ុន្តែ សង្ឃត្រូវបរិភោគសាច់វាជាអាហារវិញ។ ពិធីទាំងពីរ ជានិមិត្តរូបអំពី ការចម្លងបាបពីអ្នកលន់តួខ្លួនទៅក្នុងទីបរិសុទ្ធ។

កិច្ចការរបៀបនេះ បានបន្តទៅពេញមួយឆ្នាំជានិរន្តរ។ អំពើបាបនៃពួកអ៊ីស្រាអែល ក៏ត្រូវបានចម្លងទៅក្នុងទីបរិសុទ្ធ ហើយឃើញថា ត្រូវការប្រារព្ធពិធីពិសេសដ៏ចាំបាច់មួយសម្រាប់យកបាបទាំងនោះចេញ។

ថ្ងៃបុណ្យធួននឹងបាបដ៏ធំ

មួយឆ្នាំម្តង នៅថ្ងៃបុណ្យធួននឹងបានដ៏ធំ សង្ឃបានចូលទៅទីបរិសុទ្ធបំផុត ដើម្បីសម្អាតទីបរិសុទ្ធ។ កូនពពែពីរត្រូវបាននាំមក ហើយគេក៏ចាប់ឆ្នោត «មួយសម្រាប់ព្រះយេហូវ៉ា មួយទៀតសម្រាប់បំបរបង់ទៅ»។

លេវីវិន័យ ១៦:៨។ ពពែសម្រាប់ព្រះអម្ចាស់ គឺបានសម្លាប់ធ្វើជាតង្វាយបាប កម្មសម្រាប់ប្រជាជន ហើយសង្ឃត្រូវយកឈាមពពែទៅខាងក្នុងវាំងនន ហើយប្រោះទៅលើទីសន្តោសប្រោស និងលើអាសនានៃគ្រឿងក្រអូបនៅមុខវាំងនន។

<u>ស្បក្រ-៦ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សុភាសិត ជំពូក ៣១

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែទ្រង់វិញ ក្រោយដែលទ្រង់បានថ្វាយយញ្ញបូជាតែ១ ដោយព្រោះបាប នោះទ្រង់បានគង់ខាងស្តាំព្រះ នៅជារៀងរាប ដរាបទៅ ។ ហេព្រើរ ១០:១២*

«រួចអើរ៉ុនដាក់ដៃទាំងពីរនៅលើក្បាលពពែនោះ លន់តួពីអស់ទាំងសេចក្តីទុច្ចរិត និងអស់ទាំងសេចក្តីរំលងរបស់ពួកកូនចៅអ៊ីស្រាអែល ពីលើពពែនោះ គឺអំពើបាបរបស់គេទាំងអស់ ត្រូវដាក់ទាំងអស់លើក្បាលពពែនោះ រួចប្រគល់ដល់មនុស្សម្នាក់ ដែលប្រុងជាស្រេចដើម្បីដឹកវាទៅឯទីរហោស្ថាន។ ឯពពែនោះត្រូវផ្ទុកអស់ទាំងសេចក្តីទុច្ចរិតរបស់គេលើខ្លួន ចេញទៅឯទីតំបន់សូន្យស្ងាត់»។ លេវីវិន័យ ១៦:២១,២២។ ពពែនោះលែងមកជំរំនៃកូនចៅអ៊ីស្រាអែលទៀតឡើយ។

យញ្ញពិធីនេះត្រូវបានធ្វើឡើង ដើម្បីឱ្យសាសន៍អ៊ីស្រាអែលឃើញភាពបរិសុទ្ធរបស់ព្រះ និងការដែលទ្រង់ស្អប់ខ្ពើមអំពើបាប។ ជនរាល់រូបត្រូវបញ្ឈឺចិត្ត ក្នុងពេលដែលកិច្ចថ្វាយយញ្ញបូជាធូននឹងបាបនេះវិវឌ្ឍទៅមុខ។ អស់ទាំងជំនួញត្រូវផ្អាក ហើយពួកអ៊ីស្រាអែលត្រូវចំណាយពេលមួយថ្ងៃក្នុងការអធិស្ឋាន តមអាហារ និងឆ្លុះមើលចិត្តរបស់ខ្លួន។

សត្វដែលបានថ្វាយ ត្រូវបានទទួលជាយញ្ញបូជាជូសម្ពុកមានបាប ប៉ុន្តែអំពើបាបពុំបានសាបសូន្យដោយឈាមនៃសត្វនោះឡើយ ពីព្រោះអំពើបាបនោះគឺគ្រាន់តែបានចម្លងទៅក្នុងទីបរិសុទ្ធប៉ុណ្ណោះ។ ដោយការថ្វាយ

តង្វាយឈាម អ្នកមានបាបបានទទួលស្គាល់អំណាចនៃក្រឹត្យវិន័យ ហើយសារភាពអំពើល្មើសរបស់ខ្លួន និងសម្តែងជំនឿរបស់ខ្លួនក្នុងព្រះដ៏ជាអ្នកប្រោសលោះដែលនឹងមក ប៉ុន្តែ គេមិនទាន់បានរួចផុតពីការកាត់ទោសនៃក្រឹត្យវិន័យនៅឡើយទេ។ នៅថ្ងៃបុណ្យធួននឹងបាប សម្តេចសង្ឃក៏ចូលទៅក្នុងទីបរិសុទ្ធបំផុត បន្ទាប់ពីបានយកតង្វាយពីក្រុមជំនុំហើយ។ លោកប្រោះតង្វាយជាឈាមនេះ ទៅលើទីសន្តោសប្រោស ចំពីលើក្រឹត្យវិន័យតែម្តង ដើម្បីឆ្លើយតបចំពោះការទាមទារនៃក្រឹត្យវិន័យ។ បន្ទាប់មក ក្នុងនាមជាអ្នកសម្រុះសម្រួល សម្តេចសង្ឃត្រូវទទួលយកអំពើបាបទាំងឡាយជូនអ្នកមានបាប ហើយនាំអំពើបាបនោះចេញពីវាងឧបោសថ។ ដោយដាក់ដៃទាំងពីរលើក្បាលពពែ ក្នុងនិមិត្តរូបសម្តេចសង្ឃផ្ទេរអស់ទាំងបាបកម្មទាំងនេះពីខ្លួនទៅពពែ។ ពពែក៏ត្រូវទទួលយកបាបទាំងនោះទៅឯទីឆ្ងាយ ហើយបាបទាំងនោះត្រូវបានចាត់ទុកថានឹងឃ្លាតចេញពីប្រជាជនរហូតតរៀងទៅ។

តាពពិតនៃស្ថានសួគ៌

អ្វីដែលបានធ្វើជានិមិត្តរូបក្នុងយញ្ញកិច្ចនៃវាងឧបោសថនៅផែនដី គឺបានធ្វើពិតមែននៅក្នុងវាងឧបោសថនៅឯស្ថានសួគ៌។ បន្ទាប់ពីការយាងទៅលើ ព្រះអង្គសង្គ្រោះរបស់យើងបានចាប់ផ្តើមកិច្ចការរបស់ទ្រង់ជាសង្ឃជាន់ខ្ពស់៖ «ព្រះគ្រីស្ទមិនបានយាងចូលទៅក្នុងទីបរិសុទ្ធធ្វើដោយដៃ ដែលជាគំរូពីទីបរិសុទ្ធពិតនោះទេ គឺបានចូលទៅក្នុងស្ថានសួគ៌នោះឯង ដើម្បីនឹងលេចមកក្នុងពេលឥឡូវនេះ នៅចំពោះព្រះភ័ក្ត្រនៃព្រះ តំណាងយើងរាល់គ្នា»។ ហេព្រើរ ៩:២៤។

ការងាររបស់សង្ឃក្នុងបន្ទប់ទីមួយ (ដែលនៅខាងក្រោយវាំងននដែលញែកទីបរិសុទ្ធពីទីធ្លាខាងក្រៅ) គឺតំណាងការងារដែលព្រះគ្រីស្ទបានធ្វើ នៅពេលទ្រង់យាងទៅលើ។ កិច្ចការប្រចាំថ្ងៃរបស់សង្ឃ ត្រូវថ្វាយឈាមនៃតង្វាយបាបកម្មដល់ព្រះ ព្រមទាំងថ្វាយផ្សែងក្រអូបដែលអណ្តែតទៅលើ ជា

មួយនឹងសេចក្តីអធិស្ឋាននៃសាសន៍អ៊ីស្រាអែល។ ក៏ដូចគ្នានឹងព្រះគ្រីស្ទដែរ ទ្រង់យកលោហិតទ្រង់មកអង្វរនឹងព្រះវរបិតាជួសអ្នកមានបាប ហើយថ្វាយដល់ព្រះអង្គនូវក្លិនក្រអូបនៃសេចក្តីសុចរិតរបស់ទ្រង់ ជាមួយនឹងសេចក្តីអធិស្ឋាននៃអ្នកលន់តួប្រែចិត្ត។ នេះហើយជាសង្ឃកិច្ចក្នុងបន្ទប់ទីមួយនៃរោងឧបោសថនៅស្ថានសួគ៌។

ពួកសាវករបស់ព្រះយេស៊ូវបានតម្រង់ជំនឿរបស់គេទៅទីនោះ នៅពេលទ្រង់យាងឡើងទៅលើ។ សេចក្តីសង្ឃឹមរបស់គេបានតាំងនៅលើចំណុចនេះឯង «សេចក្តីសង្ឃឹមនោះទុកដូចជាយុថ្កានៃព្រលឹងដ៏ជាប់លាប់មាំមួន ដែលចូលទៅខាងក្នុងវាំងនន ជាកន្លែងដែលព្រះយេស៊ូវយាងចូលទៅជំនួសយើងរាល់គ្នា ទុកដូចជាអ្នកនាំមុខ ដោយទ្រង់បានត្រឡប់ជាសម្តេចសង្ឃ នៅអស់កល្បជានិច្ច»។ «ទ្រង់បានយាងចូលទៅក្នុងទីបរិសុទ្ធបំផុត មួយដងជាសម្រេច ទាំងមានសេចក្តីប្រោសលោះនៅអស់កល្បជានិច្ច ...ដោយយកព្រះលោហិតនៃអង្គទ្រង់វិញ»។ ហេព្រើរ ៦:១៩,២០; ៩:១២។

កិច្ចការនេះបានបន្តអស់រយៈ១៨សតវត្ស ក្នុងបន្ទប់ទីមួយនៃរោងឧបោសថនៅស្ថានសួគ៌។ ព្រះលោហិតនៃព្រះគ្រីស្ទ បានធានានូវការលើកទោស និងការព្រមទទួលជាមេត្រីនឹងព្រះវរបិតា ជួសអ្នកមានជំនឿដែលបានសោយសោកហើយកែប្រែខ្លួន តែអំពើបាបរបស់គេ គឺនៅរក្សាក្នុងសៀវភៅកំណត់ហេតុនៅឡើយទេ។ ក៏ដូចគ្នានឹងយញ្ញកិច្ចដែលជានិមិត្តរូបតំណាង ដែលមានកិច្ចថ្វាយយញ្ញបូជាធូននឹងបាបនៅចុងឆ្នាំដែរ មុននឹងកិច្ចការរបស់ព្រះគ្រីស្ទដែលធ្វើសម្រាប់មនុស្ស ត្រូវបានចប់សព្វគ្រប់ទៅ ក៏នឹងមានកិច្ចថ្វាយយញ្ញបូជាធូននឹងបាប សម្រាប់លុបអំពើបាបចេញពីទីបរិសុទ្ធដែរ។ ការនេះបានចាប់ផ្តើមនៅពេល២៣០០ថ្ងៃបានកន្លងផុតទៅ។ នៅ ពេលនោះ ព្រះដ៏ជាសម្តេចសង្ឃរបស់យើង ទ្រង់យាងចូលទៅទីបរិសុទ្ធបំផុត ដើម្បីសម្អាតទីបរិសុទ្ធ។

កិច្ចវិនិច្ឆ័យ

នៅក្នុងសេចក្តីសញ្ញាថ្មី អំពើបាបនៃអ្នកលន់តួខ្លួន ត្រូវដាក់ទៅលើព្រះគ្រីស្ទដោយជំនឿ ហើយក៏ផ្ទេរទៅឯរោងឧបោសថនៅស្ថានសួគ៌។ ហើយដូចជានិមិត្តរូបនៃការសម្អាតទីបរិសុទ្ធនៅផែនដីដែលត្រូវបានបង្គ្រប់កិច្ចដោយការយកចេញនូវបាបដែលធ្វើឱ្យកខ្វក់នោះ ការសម្អាតដ៏ពិតនៃទីបរិសុទ្ធនៅស្ថានសួគ៌ ក៏បានបង្គ្រប់កិច្ចដោយការយកចេញ ឬការលុបចេញនៃបាបដែលបានកត់ទុកដូច្នោះដែរ។ ប៉ុន្តែ មុននឹងការនេះអាចសម្រេចបាន ត្រូវមានការពិនិត្យសៀវភៅកំណត់ហេតុ ដើម្បីរកឱ្យឃើញថា តើនរណាដែលធ្វើតាមការលន់តួ និងជំនឿក្នុងព្រះគ្រីស្ទ សមនឹងទទួលប្រយោជន៍នៃការថ្វាយយញ្ញបូជាធួននឹងបាបរបស់ទ្រង់។ ដូច្នេះ ការសម្អាតទីបរិសុទ្ធមានទាក់ទង នឹងការស៊ើបអង្កេត ការជំនុំជម្រះមុននឹងព្រះគ្រីស្ទយាងមក ដ្បិតនៅពេល ទ្រង់យាងមក ទ្រង់យករង្វាន់មកជាមួយ ដើម្បីប្រទានដល់មនុស្សគ្រប់រូប តាមការដែលគេបានធ្វើ។ វិវរណៈ ២២:១២។

ដូច្នេះអ្នកដែលដើរតាមពន្លឺនៃបទទំនាយ គេបានឃើញថា ជាជាងទ្រង់យាងមកផែនដីនៅទីបញ្ចប់នៃ២៣០០ថ្ងៃក្នុងឆ្នាំ១៨៤៤ ព្រះគ្រីស្ទបានយាងចូលទៅក្នុងទីបរិសុទ្ធបំផុតនៃរោងឧបោសថនៅស្ថានសួគ៌ ដើម្បីចាប់ផ្តើមធ្វើការថ្វាយយញ្ញបូជាធួននឹងបាបឱ្យបានចប់សព្វគ្រប់ រៀបចំសម្រាប់ការយាងមករបស់ទ្រង់។

នៅពេលព្រះគ្រីស្ទយកបាបរបស់រាស្ត្រទ្រង់ ចេញពីទីបរិសុទ្ធនៅឯស្ថានសួគ៌ ក្នុងពេលទ្រង់បញ្ចប់កិច្ចការរបស់ព្រះអង្គដោយសម្អាងព្រះលោហិតរបស់ទ្រង់នោះ ទ្រង់នឹងដាក់បាបទាំងឡាយទៅលើសាតាំង ដែលត្រូវទទួលពិន័យចុងក្រោយ។ ពពែត្រូវបានបញ្ជូនទៅទីរហោស្ថាន ហើយនិងលែងមកក្រុមជំនុំនៃអ៊ីស្រាអែលទៀតឡើយ។ ក៏ដូចគ្នានឹងសាតាំងដែរ វានឹងត្រូវបានបំបរបង់ចោលពីវត្តមានរបស់ព្រះ និងរាស្ត្រទ្រង់ ហើយវានឹងត្រូវបានបាត់សូន្យក្នុងវិនាសកម្មចុងក្រោយនៃអំពើបាបរបស់អ្នកមានបាប។

តើព្រះគ្រីស្ទកំពុងធ្វើអ្វីឥឡូវនេះ?

<u>សៅរ៍-៧ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ១

ខព្រះគម្ពីរប្រចាំសប្តាហ៍: *ដ្បិតទ្រង់ធ្វើឲ្យពួកអ្នក ដែលបានញែកជាបរិសុទ្ធ ហើយ បានគ្រប់លក្ខណ៍អស់កល្បជានិច្ច ដោយសារដង្វាយតែ១នោះ។ ហេព្រើរ ១០:១៤*

កម្មវត្ថុនៃរោងឧបោសថ បានបើកឱ្យឃើញអាថ៌កំបាំងនៃការខកចិត្ត និងប្រព័ន្ធនៃសេចក្តីពិតដ៏ពេញលេញមួយ ដែលប្រស្រ័យទាក់ទងគ្នាហើយស្របតាមគន្លងគ្នា បង្ហាញឱ្យឃើញថា ព្រះហស្តរបស់ព្រះបានដឹកនាំមហាចលនានិវត្ត។ អ្នកដែលបានទន្ទឹងចាំក្នុងជំនឿចំពោះការយាងមករបស់ទ្រង់ បានរំពឹងថាទ្រង់នឹងយាងមកក្នុងសិរីល្អ ប៉ុន្តែ នៅពេលក្តីសង្ឃឹមរបស់គេត្រូវបានក្លាយទៅជាការខកចិត្ត គេពុំបានដឹងថាព្រះយេស៊ូវស្ថិតនៅឯណាទេ។ ឥឡូវនេះ នៅក្នុងទីបរិសុទ្ធបំផុត គេបានទន្ទឹងចាំសម្តេចសង្ឃរបស់ខ្លួនម្តងទៀត ដែលនឹងលេចមកជាស្តេច និងជាអ្នករំដោះ ក្នុងពេលបន្តិចទៀត។ ពន្លឺពីរោងឧបោសថបានបំភ្លឺអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។ ទោះបីជាគេពុំបានយល់ដំណឹងដែលគេផ្សាយក៏ដោយ ដំណឹងនោះគឺត្រឹមត្រូវទេ។

កំហុសគឺពុំមែននៅក្នុងការទូទាត់លេខអត្តនៃពេលវេលានោះទេ គឺក្នុងព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅចុងបញ្ចប់នៃ២៣០០ថ្ងៃវិញ។ តែអ្វីៗដែលបានទាយដោយទំនាយនោះ គឺបានសម្រេចទាំងអស់។

ព្រះគ្រីស្ទបានយាងមកមែន តែពុំមែនមកផែនដីទេ គឺមកឯទីបរិសុទ្ធ

បំផុតក្នុងព្រះវិហារនៅស្ថានសួគ៌ឯនុះ៖ «ខ្ញុំក៏ឃើញក្នុងការជាក់ស្តែង ពេលយប់នោះ មានមួយអង្គដូចជាមនុស្សជាតិ ទ្រង់យាងមកក្នុងពពកឲ្ជ៏អាកាស» មិនមែនមកផែនដីទេ តែ «ទ្រង់យាងមកឯព្រះដ៏មានព្រះជន្មពីបុរាណនោះ ហើយមានគេនាំចូលទៅចំពោះព្រះអង្គ»។ ដានីយ៉ែល ៧:១៣។

ការយាងមកនេះក៏ត្រូវបានទាយដោយហោរាម៉ាឡាគីដែរថា៖ «ព្រះអម្ចាស់ដែលឯងរាល់គ្នាស្វែងរកនោះ ទ្រង់នឹងលោតែមកដល់ព្រះវិហាររបស់ទ្រង់ភ្លាម ឯទូតដែលនាំសេចក្តីសញ្ញាមក ជាសេចក្តីសញ្ញាដែលឯងរាល់គ្នាចង់បានទាំងម្លេ៉ះនោះ មើលន៍ ទ្រង់យាងមក នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ»។ ម៉ាឡាគី ៣:១។ ការដែលព្រះអម្ចាស់យាងមកឯព្រះវិហាររបស់ទ្រង់ គឺយាងទៅ «មួយព្រឹប» តែម្តង ដោយរាស្ត្រព្រះអង្គមិនបានដឹងខ្លួនផង។ គេពុំបានស្វែងរកព្រះអង្គនៅទីនោះទេ។

ពួកបណ្តាជន ពុំបានរៀបចំខ្លួន ដើម្បីនឹងជួបព្រះអម្ចាស់របស់គេនៅឡើយទេ ពីព្រោះនៅមានការរៀបចំមួយដែលត្រូវសម្រេចសម្រាប់ពួកគេ។ នៅពេលគេដើរតាមសម្តេចសង្ឃក្នុងកិច្ចការរបស់ទ្រង់ដោយជំនឿនោះ ករណីយកិច្ចថ្មីៗនឹងត្រូវបានសម្តែងឱ្យឃើញ។ ដំណឹងមួយទៀតគឺនឹងត្រូវផ្សាយដល់ក្រុមជំនុំ។

តើអ្នកណានឹងឈរនៅបាន?

ហោរាបានមានប្រសាសន៍ថា៖ «តើមានអ្នកណាធន់នៅបាន ក្នុងកាលដែលទ្រង់យាងមកនោះ តើអ្នកណានឹងឈរនៅ ក្នុងកាលដែលទ្រង់លេចមក?...ទ្រង់នឹងគង់ចុះដូចជាជាងសំរងហើយនឹងដេញអាចម៍ប្រាក់ ទ្រង់នឹងសម្អាតពួកកូនចៅពួកលេវី ហើយសម្រងគេដូចជាមាស ហើយនិងប្រាក់ នោះគេនឹងថ្វាយតង្វាយដល់ព្រះយេហូវ៉ាដោយសេចក្តីសុចរិត»។ ម៉ាឡាគី ៣:២,៣។ នៅពេលការអង្វរការរបស់ព្រះគ្រីស្ទនឹងត្រូវឈប់លែង

មានតទៅទៀត អ្នកដែលរស់នៅលើផែនដីនឹងត្រូវឈរនៅចំពោះព្រះភ័ក្ត្រ
របស់ព្រះ ដោយគ្មានអ្នកសម្រុះសម្រួល។ សំលៀកបំពាក់របស់គេត្រូវតែ
ឥតខ្ចោះ ចរិតរបស់គេត្រូវតែបានជ្រះស្អាតពីអំពើបាប ដោយព្រះលោហិត
នៃការប្រោះ។ តាមរយៈព្រះគុណរបស់ព្រះនិងការខិតខំយ៉ាងអស់ពីចិត្ត
របស់គេ ពួកគេត្រូវតែធ្វើជាអ្នកមានជ័យជម្នះក្នុងការប្រយុទ្ធជាមួយសេចក្តី
អាក្រក់។ ក្នុងពេលដែលការជំនុំជម្រះដោយស៊ើបអង្កេតកំពុងតែប្រព្រឹត្តទៅ
នៅស្ថានសួគ៌ ក្នុងពេលដែលបាបកម្មនៃអ្នកជឿដែលបានសោយសោក
កំពុងតែបានលុបចេញពីរោងឧបោសថ នោះក៏នឹងមានការងារពិសេសមួយ
ដើម្បីបំបាត់អំពើបាបក្នុងចំណោមរាស្ត្ររបស់ព្រះដែលនៅលើផែនដីដែរ។
កិច្ចការនេះគឺត្រូវបានសម្តែងនៅក្នុងព្រះរាជសារនៃគម្ពីរវិវរណៈជំពូក១៤។
នៅពេលកិច្ចការនេះត្រូវបានសម្រេចសព្វគ្រប់ហើយ ពួកគ្រីស្ទបរិស័ទ
នឹងបានត្រៀមខ្លួនជាស្រេច សម្រាប់ដំណើរយាងមករបស់ទ្រង់។ បន្ទាប់មក
ក្រុមជំនុំដែលព្រះអម្ចាស់របស់យើងនឹងទទួលយកនាពេលទ្រង់យាងមក
នោះ នឹងបានទៅ «ជាពួកជំនុំដ៏ឧត្តម ឥតប្រឡាក់ ឥតជ្រួញ ឬមានអ្វី
ឱ្យខូចឡើយ»។ អេភេសូរ ៥:២៧។

<u>អាទិត្យ-៨ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ២

ខព្រះគម្ពីរប្រចាំថ្ងៃ:*«ឯសេចក្តីសញ្ញា ដែលអញនឹងតាំងដល់គេក្រោយគ្រានោះ គឺថា អញនឹងដាក់ក្រឹត្យវិន័យអញនៅក្នុងចិត្តគេ ហើយនិងកត់ទុកនៅក្នុងគំនិតគេផង»។ ហេព្រើរ ១០:១៦*

ព្រះគ្រីស្ទឧទ្ទិលព្រះរាជនគរ

ការដែលព្រះគ្រីស្ទយាងទៅសម្អាតរោងឧបោសថក្នុងទីបរិសុទ្ធបំផុត
ក្នុងព្រះនាមជាសម្តេចសង្ឃ (ដានីយ៉ែល ៨:១៤) ការដែលកូនមនុស្សយាង
ទៅឯព្រះដ៏មានព្រះជន្មពីបុរាណ (ដានីយ៉ែល ៧:១៣) និងការដែលព្រះ

អម្ចាស់យាងទៅឯព្រះវិហាររបស់ទ្រង់ (ម៉ាឡាគី ៣:១) គឺជាព្រឹត្តិការណ៍តែមួយទេ។ ការនេះក៏បានតំណាងដោយការដែលកូនកំឡោះអញ្ជើញទៅរៀបមង្គលការ ក្នុងរឿងប្រៀបធៀបនៃស្ត្រីព្រហ្មចារីដប់នាក់ ក្នុងគម្ពីរម៉ាថាយ ជំពូក២៥ដែរ។

ក្នុងរឿងប្រៀបធៀបនោះ នៅពេលកូនកំឡោះមកដល់ «ពួកនាងដែលបម្រុងជាស្រេច ក៏ចូលទៅក្នុងពោងការជាមួយគ្នា»។ ការអញ្ជើញមកដល់នៃកូនកំឡោះ គឺកើតមានឡើងមុនមង្គលការ។ មង្គលការគឺតំណាងព្រះគ្រីស្ទទទួលព្រះរាជនគររបស់ទ្រង់។ ទីក្រុងបរិសុទ្ធ ក្រុងយេរូសាឡិមថ្មី រដ្ឋធានីនៃនគរ និងអ្នកតំណាងនគរ គឺត្រូវបានហៅថា «ប្រពន្ធថ្មោងថ្មី ជាភរិយារបស់កូនចៀម»។ ទេវតាបានមានបន្ទូលទៅយ៉ូហានថា៖ «ចូរមកឯណេះ ខ្ញុំនឹងបង្ហាញអ្នកឱ្យឃើញប្រពន្ធថ្មោងថ្មី ជាភរិយារបស់កូនចៀម»។ «នោះក៏ទេវតានាំវិញ្ញាណខ្ញុំ» ហោរាមានប្រសាសន៍ «បង្ហាញខ្ញុំឱ្យឃើញទីក្រុងបរិសុទ្ធគឺជាក្រុងយេរូសាឡិមដែលកំពុងតែចុះពីស្ថានសួគ៌មកអំពីព្រះ»។ វិវរណៈ ២១:៩,១០។

ប្រពន្ធថ្មោងថ្មី គឺតំណាងទីក្រុងបរិសុទ្ធ ហើយស្ត្រីព្រហ្មចារីដែលចេញទៅជួបប្តី គឺជានិមិត្តរូបនៃក្រុមជំនុំ។ នៅក្នុងសេចក្តីបើកសម្តែង រាស្ត្ររបស់ព្រះដែលនៅឯពោងការ គឺត្រូវបានហៅថាជាភ្ញៀវ។ ប្រសិនបើគេជា *ភ្ញៀវ* គេពុំអាចជា *ប្រពន្ធ* បានទេ។ នៅស្ថានសួគ៌ ព្រះគ្រីស្ទនឹងទទួលពីព្រះដ៏មានព្រះជន្មពីបុរាណ នូវ «អំណាចគ្រប់គ្រង និងសិរីល្អ ព្រមទាំងរាជ្យ» ដែលជាក្រុងយេរូសាឡិមថ្មី ជារដ្ឋធានីនៃនគរទ្រង់ «គាក់តែងដូចជាប្រពន្ធថ្មោងថ្មីតែងខ្លួនទទួលប្តី»។ ដានីយ៉ែល ៧:១៤; វិវរណៈ ២១:២។ បន្ទាប់ពីបានទទួលនគរហើយ ទ្រង់នឹងយាងមកក្នុងនាមជាស្តេចលើអស់ទាំងស្តេច ព្រះអម្ចាស់លើព្រះអម្ចាស់ សម្រាប់រំដោះរាស្ត្រទ្រង់ឱ្យមកចូលរួមក្នុងការបរិភោគការនៃកូនចៀម។

ការរង់ចាំព្រះអម្ចាស់របស់ខ្លួន

សេចក្តីប្រកាស «នៃ ប្តីមកហើយ» បានធ្វើឱ្យមនុស្សរាប់ពាន់នាក់ រំពឹងចាំការយាងមកយ៉ាងភ្លាមៗនៃព្រះអម្ចាស់។ នៅពេលកំណត់ កូនកំឡោះក៏មកដល់ ពុំមែនមកផែនដីទេ តែមកឯព្រះដ៏មានព្រះជន្មពីបុរាណនៅស្ថានសួគ៌ឯនោះវិញ គឺមកឯអាពាហ៍ពិពាហ៍ដែលជាការទទួលនគររបស់ទ្រង់។ «ពួកនាងដែលបម្រុងជាស្រេច ក៏ចូលទៅក្នុងរោងការជាមួយគ្នា»។ គេមិនត្រូវអញ្ជើញទៅក្នុងភាពជារូបសាច់ទេ ព្រោះគេនៅផែនដី។ គ្រីស្ទបរិស័ទត្រូវរង់ចាំចៅហ្វាយខ្លួន *ត្រឡប់* ពីបរិភោគការវិញ។ លូកា ១២:៣៦។ ប៉ុន្តែ គេត្រូវយល់កិច្ចការរបស់ទ្រង់ ហើយដើរតាមទ្រង់ដោយជំនឿ។ ក្នុងន័យនេះហើយដែលហៅថាចូលទៅរៀបមង្គលការនោះ។

នៅក្នុងរឿងប្រៀបធៀប អ្នកដែលមានប្រេងក្នុងចង្កៀងបានចេញទៅរៀបមង្គលការ។ អ្នកដែលនៅក្នុងរាត្រីនៃការសោកល្បងដ៏ជូរចត់ ដែលបានរង់ចាំដោយអត់ធ្មត់ ហើយសិក្សាព្រះគម្ពីរ ដើម្បីឱ្យភ្លឺច្បាស់ថែមទៀតនោះ បានឃើញសេចក្តីពិតស្តីពីរោងឧបោសថនៅឯស្ថានសួគ៌ និងការផ្លាស់ប្តូរកិច្ចការរបស់ព្រះអង្គសង្គ្រោះ។ ដោយជំនឿ គេបានដើរតាមទ្រង់ក្នុងកិច្ចការរបស់ទ្រង់ ក្នុងរោងឧបោសថដែលនៅឯលើ។ ហើយអស់អ្នកដែលបានទទួលសេចក្តីពិតដូចគ្នានេះ ចូលទៅក្នុងរោងការ ដោយដើរតាមព្រះគ្រីស្ទដោយជំនឿ នៅពេលទ្រង់ប្រព្រឹត្តការងារចុងក្រោយនៃការសម្រុះសម្រួល។

<u>ចន្ទ-៩ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ៣

ខព្រះគម្ពីរប្រចាំថ្ងៃ:*ដូច្នេះ បងប្អូនអើយ ដែលយើងមានសេចក្តីក្លៀវក្លានឹងចូលទៅក្នុងទីបរិសុទ្ធ ដោយសារព្រះលោហិតនៃព្រះយេស៊ូវ ។*
ហេព្រើរ ១០:១៩

កិច្ចការបញ្ចប់ក្នុងពេលឧបោសថ

ក្នុងរឿងប្រៀបធៀបនៃម៉ាថាយជំពូក២២ ការជំនុំជម្រះបានកើតឡើងមុនពិធីរៀបការ។ មុននឹងប្រារព្ធពិធីរៀបមង្គលការ ព្រះមហាក្សត្រយាងមកទតមើលថាតើភ្ញៀវទាំងអស់ស្លៀកពាក់សំលៀកបំពាក់ការហើយឬនៅ ដែលជាសំលៀកបំពាក់ដ៏ឥតប្រទ្បាក់នៃចរិត លាងដោយព្រះលោហិតរបស់កូនចៀម។ វិវរណៈ ៧:១៤។ អស់អ្នកណាដែលត្រូវបានពិនិត្យទៅឃើញថាបានពាក់សំលៀកបំពាក់ការហើយ គឺត្រូវបានអនុញ្ញាតឱ្យចូល ហើយរាប់ថាសមនឹងទទួលចំណែកមួយក្នុងនគររបស់ព្រះ ព្រមទាំងមានកន្លែងអង្គុយមួយលើបល្ល័ង្កទ្រង់ទៀតផង។ កិច្ចការនៃការពិនិត្យចរិតលក្ខណៈនេះគឺជាការវិនិច្ឆ័យទោសដោយស៊ើបអង្កេត ដែលជាកិច្ចការបញ្ចប់ក្នុងរោងឧបោសថនៅឯលើ។

នៅពេលក្តីទាំងឡាយនៃអ្នកដែលបានជឿស្មោះត្រង់ដល់ព្រះគ្រីស្ទក្នុងគ្រប់សម័យមកហើយ ត្រូវបានពិនិត្យ និងសម្រេចសេចក្តីហើយនោះ ពេលទុកឱ្យប្រែចិត្តនឹងត្រូវបិទ ហើយទ្វារនៃសេចក្តីមេត្តាករុណាក៏នឹងត្រូវបិទដែរ។ ដូច្នេះ ក្នុងប្រយោគដ៏ខ្លីមួយនេះ «ពួកនាងដែលបានបម្រុងរួចជាស្រេចក៏ចូលទៅក្នុងរោងការជាមួយគ្នា រួចគេបិទទ្វារ» គឺជាការនាំយើងឱ្យឃើញពេលសម្រេចកិច្ចការដ៏ធំអស្ចារ្យឱ្យបានចប់សព្វគ្រប់ សម្រាប់សេចក្តីសង្គ្រោះរបស់មនុស្ស។

នៅក្នុងរោងឧបោសថនៅផែនដី នាពេលសម្តេចសង្ឃចូលទៅក្នុងទីបរិសុទ្ធបំផុតនៅថ្ងៃលោះបាបនោះ ការងារក្នុងបន្ទប់ទីមួយត្រូវផ្អាក។

ដូច្នេះ នៅពេលព្រះគ្រីស្ទបានយាងចូលទៅក្នុងទីបរិសុទ្ធបំផុត ដើម្បីបញ្ចប់កិច្ចការនៃការលោះបាបនោះ ទ្រង់បានបញ្ឈប់កិច្ចរបស់ទ្រង់ក្នុងបន្ទប់ទីមួយហើយ។ បន្ទាប់មក កិច្ចការក្នុងបន្ទប់ទីពីរក៏បានចាប់ផ្តើម។ ព្រះគ្រីស្ទបានសម្រេចកិច្ចការរបស់ទ្រង់តែមួយផ្នែកគត់ ក្នុងនាមជាអ្នកអង្វរករ ហើយឥឡូវនឹងចាប់ផ្តើមកិច្ចការមួយផ្នែកទៀត។ ទ្រង់នៅតែអង្វរដោយអាងព្រះលោហិតទ្រង់នៅចំពោះព្រះវរបិតា ជួសអ្នកមានបាបទាំងឡាយដដែល។

ជាការពិតមួយ គឺថា នៅពេលទ្វារនៃសេចក្តីសង្ឃឹម និងធម៌មេត្តា ដែលមនុស្សបានចេញចូលទៅឯព្រះអស់រយៈ១៨០០ឆ្នាំ បានបិទទៅ ទ្វារមួយទៀតបានបើកឡើង។ ការអត់ទោសនៃអំពើបាបគឺត្រូវបានថ្វាយតាមរយៈនៃការអង្វរកររបស់ព្រះគ្រីស្ទក្នុងទីបរិសុទ្ធបំផុត។ នៅកន្លែងដែលព្រះគ្រីស្ទប្រកបកិច្ចជាសង្ឃជួសអ្នកមានបាបមាន «ទ្វារបើក» ចូលទៅរោងឧបោសថដែលនៅឯស្ថានសួគ៌ដដែល។

ឥឡូវនេះ អត្ថន័យនៃព្រះបន្ទូលទាំងនោះរបស់ព្រះគ្រីស្ទ ក្នុងការបើកសម្តែង ដែលសំដៅមកពេលបច្ចុប្បន្ននេះ ត្រូវបានលាតឱ្យឃើញហើយ ៖ «ព្រះអង្គដ៏បរិសុទ្ធ ហើយពិតប្រាកដ ដែលទ្រង់កាន់កូនសោរបស់ហ្លួងដាវីឌ ដែលទ្រង់បើក ហើយគ្មានអ្នកណាបិទ ហើយគ្មានអ្នកណាបើកបាន...មើល អញបានបើកទ្វារចំហនៅមុខឯង គ្មានអ្នកណាអាចនឹងបិទបានទេ»។ វិវរណៈ ៣:៧,៨។

អ្នកដែលដើរតាមព្រះយេស៊ូវដោយជំនឿ ក្នុងកិច្ចការដ៏ធំនៃការលោះបាប បានទទួលលទ្ធផលនៃការសម្រុះសម្រួលរបស់ទ្រង់ ហើយអ្នកដែលបដិសេធពន្លឺ គឺពុំបានផលប្រយោជន៍អ្វីពីការនោះឡើយ។ ពួកជូវដែលមិនព្រមជឿដល់ព្រះគ្រីស្ទថាជាព្រះអង្គសង្គ្រោះ នឹងពុំអាចទទួលការលើកលែងទោសពីទ្រង់បានឡើយ។ នៅពេលព្រះយេស៊ូវបានយាងទៅលើ ហើយចូលទៅក្នុងរោងឧបោសថនៅស្ថានសួគ៌ ដើម្បីចែកចាយព្រះពរនៃការសម្រុះសម្រួលរបស់ទ្រង់ដល់ពួកសាវក ពួកជូវត្រូវបានទុកនៅក្នុងភាពងងឹតសូន្យ

ឈឹង ឱ្យនៅប្រារព្ធពិធីធ្វើយញ្ញបូជា និងថ្វាយតង្វាយឥតប្រយោជន៍របស់ខ្លួន។ ទ្វារដែលមនុស្សបានចេញចូលទៅឯព្រះកាលពីមុននោះ លែងបើកទៀតហើយ។ ពួកជូវ បានបដិសេធ មិនព្រមរកទ្រង់តាមផ្លូវតែមួយដែលអាចរកទ្រង់ឃើញ ពោលគឺតាមរយៈរោងឧបោសថនៅស្ថានសួគ៌។

ពួកជូវដែលមិនជឿ បង្ហាញពីការខ្ជីខ្ជា និងការមិនជឿក្នុងចំណោមពួកអះអាងថាជាអ្នកគ្រីស្ទានដែលជម្ទះធ្វើមិនដឹងអំពីកិច្ចការនៃសម្តេចសង្ឃរបស់យើង។ ក្នុងយញ្ញកិច្ចដែលជានិមិត្តរូប នៅពេលសម្តេចសង្ឃចូលទៅទីបរិសុទ្ធបំផុតនោះ អស់ទាំងសាសន៍អ៊ីស្រាអែលត្រូវមកជួបជុំគ្នានៅជុំវិញរោងឧបោសថ ហើយបន្ទាបខ្លួននៅចំពោះព្រះ ដើម្បីឱ្យគេបានទទួលការលើកលែងបាប និងដើម្បីកុំឱ្យគេបាន «កាត់ចេញ» ពីក្រុមជំនុំ។ តើសំខាន់ប៉ុនណាទៅ ក្នុងថ្ងៃលោះបាបពិតៗនេះ បើយើងយល់កិច្ចការនៃសម្តេចសង្ឃរបស់យើង និងដឹងពីភារកិច្ចដែលយើងត្រូវធ្វើនោះ?

ដំណឹងមួយត្រូវបានផ្ញើពីស្ថានសួគ៌ ទៅពិភពលោកក្នុងជំនាន់លោកណូអេ ហើយសេចក្តីសង្គ្រោះរបស់គេ បានអាស្រ័យទៅលើរបៀបដែលគេតបទៅនឹងដំណឹងនោះ។ លោកុប្បត្តិ ៦:៦-៩; ហេព្រើរ ១១:៧។ ក្នុងជំនាន់ក្រុងសូដុំម គ្រប់គ្នាត្រូវបានស្លាប់ដោយភ្លើងធ្លាក់មកពីស្ថានសួគ៌លើកលែងតែលោកឡុត ប្រពន្ធគាត់ និងកូនស្រីពីរនាក់របស់គាត់ប៉ុណ្ណោះ (លោកុប្បត្តិ ១៩)។ នៅជំនាន់ព្រះគ្រីស្ទក៏ដូច្នោះដែរ។ ព្រះរាជបុត្រារបស់ព្រះ បានមានព្រះបន្ទូលដល់សាសន៍ជូវដែលមិនជឿថា៖ «ផ្ទះឯងនឹងត្រូវចោលស្ងាត់ទុកឱ្យឯង»។ ម៉ាថាយ ២៣:៣៨។ មើលទៅជំនាន់ចុងក្រោយវិញ ស្តីពីអ្នកដែល «មិនព្រមស្រឡាញ់ដល់សេចក្តីពិត ដើម្បីឱ្យគេបានសង្គ្រោះនោះ» ព្រះដ៏មានឥទ្ធិឫទ្ធិគ្មានទីបំផុតដដែលនោះថ្លែងថា៖ «ហេតុនោះបានជាព្រះទ្រង់នឹងឱ្យសេចក្តីខុសឆ្គងមកបណ្តាលឱ្យគេជឿតាមសេចក្តីភូតភរវិញ»។ ថែស្សាឡូនីចទី២ ២:១០,១១។ នៅពេលគេបដិសេធសេចក្តីបង្រៀននៃព្រះបន្ទូលទ្រង់ ព្រះនឹងដកព្រះវិញ្ញាណរបស់ទ្រង់ចេញ ហើយទុកឱ្យគេស្ថិតនៅ

ក្នុងក្តីបោកបញ្ឆោតដែលគេស្រឡាញ់នោះទៅ។ ប៉ុន្តែ ព្រះគ្រីស្ទនៅតែអង្វរជួសមនុស្សលោកដដែល ហើយពន្លឺនឹងត្រូវបានប្រទានឱ្យអ្នកណាដែលស្វែងរក។

ក្នុងការឆ្លងកាត់ពេលវេលាក្នុងឆ្នាំ១៨៤៤ ឃើញមានកើតទុក្ខលំបាកជាខ្លាំង ដល់អ្នកដែលកាន់ជំនឿនិវត្តន៍។ ការសម្រាលចិត្តតែមួយគត់របស់គេ គឺពន្លឺដែលតម្រង់គំនិតរបស់គេទៅឯពេងឧបោសថនៅឯលើ។ នៅពេលគេរង់ចាំហើយអធិស្ឋាន គេបានឃើញថាសម្តេចសង្ឃរបស់ខ្លួន បានយាងចូលធ្វើកិច្ចការមួយទៀត។ ដោយដើរតាមទ្រង់ដោយជំនឿ គេបានឃើញកិច្ច ការបញ្ចប់នៃក្រុមជំនុំផងដែរ។ គេបានយល់ច្បាស់ជាងមុននូវដំណឹងនៃទេវតាទីមួយ និងទីពីរ ហើយចាំតែទទួលហើយផ្សាយដល់ពិភពលោកអំពីការព្រមានដ៏ម៉ឺងម៉ាត់នៃទេវតាទីបីនៃវិវរណៈជំពូក១៤។

ក្រឹត្យវិន័យរបស់ព្រះដែលពុំអាចផ្លាស់ប្តូរបាន

<u>អង្គារ-១០ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ៤

ខព្រះគម្ពីរប្រចាំថ្ងៃ: *តាមផ្លូវដែលទ្រង់ បានតាំងសំរាប់យើងរាល់គ្នា ជាផ្លូវថ្មី ហើយរស់ ដែលចូលកាត់វាំងនន គឺជារូបសាច់របស់ទ្រង់ ហើយដែលមានសំដេចសង្ឃដ៏ធំ១អង្គត្រួតលើដំណាក់ព្រះ ។ ហេព្រើរ ១០:២០-២១*

«នោះមានបើកព្រះវិហារនៃព្រះនៅស្ថានសួគ៌ ហើយឃើញមានហឹបនៃសេចក្តីសញ្ញារបស់ទ្រង់នៅក្នុងព្រះវិហារនោះ»។ វិវរណៈ ១១:១៩។ ហឹបនៃសេចក្តីសញ្ញារបស់ព្រះគឺស្ថិតនៅក្នុងទីបរិសុទ្ធបំផុត ដែលជាបន្ទប់ទីពីរនៃរោងឧបោសថ។ ក្នុងការប្រកបយញ្ញកិច្ចក្នុងរោងឧបោសថនៅផែនដី ដែល «គ្រាន់តែជាគំរូ និងស្រមោលនៃរបស់នៅស្ថានសួគ៌» នោះ បន្ទប់នេះត្រូវបានបើកឡើងនៅថ្ងៃបុណ្យធួននឹងបាបដ៏ធំប៉ុណ្ណោះ សម្រាប់លាងសម្អាតទីបរិសុទ្ធ។ ដូច្នេះ ការប្រកាសថា គេបើកព្រះវិហារនៅស្ថានសួគ៌ ហើយមានឃើញហឹបនៃសេចក្តីសញ្ញានោះ ចង្អុលទៅការបើកទីបរិសុទ្ធបំផុតនៃរោងឧបោសថនៅស្ថានសួគ៌ក្នុងឆ្នាំ១៨៤៤ នៅពេលព្រះគ្រីស្ទបានយាងចូលក្នុងបន្ទប់នោះ ដើម្បីប្រារព្ធកិច្ចការលោះបាប។ អ្នកដែលដើរតាមសម្តេចសង្ឃរបស់ខ្លួនដោយជំនឿ នៅពេលទ្រង់ផ្តើមការងាររបស់ទ្រង់ក្នុងទីបរិសុទ្ធបំផុតនោះ បានឃើញហឹបនៃសេចក្តីសញ្ញារបស់ព្រះអង្គ។ នៅពេលគេបានសិក្សាកម្មវត្ថុនៃរោងឧបោសថ គេបានយល់ពីការផ្លាស់ប្តូរកិច្ចការរបស់ព្រះអង្គសង្គ្រោះ ហើយគេបានឃើញថា ឥឡូវនេះទ្រង់កំពុងប្រកបករណីយកិច្ចនៅចំពោះហឹបរបស់ព្រះ។

ហឹបក្នុងអោងឧបោសថនៅផែនដី មានបន្ទះថ្មពីរបាំង ដែលចារឹកនៃក្រឹត្យវិន័យរបស់ព្រះ។ នៅពេលព្រះវិហាររបស់ព្រះបានបើកឡើងនៅស្ថានសួគ៌ ហឹបនៃសេចក្តីសញ្ញាក៏ត្រូវបានឃើញ។ ក្នុងក្រអៅនៃទីបរិសុទ្ធបំផុតនៅស្ថានសួគ៌ មានក្រឹត្យវិន័យដ៏ពិសិដ្ឋតម្កល់នៅទីនោះ គឺជាក្រឹត្យវិន័យដែលបានមានព្រះបន្ទូលដោយព្រះ ហើយបានសរសេរដោយព្រះអង្គុលីរបស់ទ្រង់នៅលើបន្ទះថ្ម។

អ្នកដែលបានយល់មកដល់ចំណុចនេះ បានឃើញដូចពុំដែលឃើញពីមុននូវអត្ថន័យដ៏ជ្រាលជ្រៅនៃព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ដែលថា៖ «នឹងគ្មានបាំងឈើមួយ ឬក្បៀសមួយនៅក្នុងក្រឹត្យវិន័យត្រូវបាត់ឡើយ ដរាបដល់មេឃ និងផែនដីបានកន្លងបាត់ទៅ»។ ម៉ាថាយ ៥:១៨។ ក្រឹត្យវិន័យរបស់ព្រះ ដែលជាការបើកសម្តែងព្រះហឫទ័យរបស់ទ្រង់ ហើយជាចំណារចារឹកនៃចរិតលក្ខណៈរបស់ទ្រង់ ត្រូវតែស្ថិតស្ថេរជាដរាប។

ក្នុងក្រអៅនៃទសបញ្ញត្តិ† មានបញ្ញត្តិនៃថ្ងៃឈប់សម្រាក។ ព្រះវិញ្ញាណរបស់ព្រះបានធ្វើការក្នុងចិត្តនៃសិស្សដែលសិក្សាព្រះបន្ទូលទ្រង់ ថាគេបានប្រព្រឹត្តរំលងសិក្ខាបទនេះដោយមិនដឹងខ្លួន ដោយពុំគោរពថ្ងៃឈប់សម្រាករបស់ព្រះអាទិករ។ គេបានចាប់ផ្តើមវែកញែករកមូលហេតុ ដើម្បីគោរពថ្ងៃទីមួយនៃសប្តាហ៍វិញ។ គេរកភ័ស្តុតាងពុំឃើញសោះថា បញ្ញត្តិទីបួនត្រូវបានលុបចោល ឬថ្ងៃឈប់សម្រាកត្រូវបានប្តូរហើយនោះឡើយ។ គេបានសង្វាតចង់ដឹង និងចង់ធ្វើតាមព្រះហឫទ័យរបស់ព្រះដោយអស់អំពីចិត្ត ហើយឥឡូវនេះគេសម្តែងភាពស្មោះត្រង់ដល់ព្រះ ដោយរក្សាថ្ងៃឈប់សម្រាករបស់ព្រះឱ្យបានបរិសុទ្ធវិញ។

មានមនុស្សជាច្រើនបានខិតខំ ដើម្បីរំសាយជំនឿនៃពួកនិវត្តក:ទាំងឡាយ។ គ្មាននរណាម្នាក់ដែលពុំយល់ថា ការទទួលជឿសេចក្តីពិតស្តីពីអោងឧបោសថនៅស្ថានសួគ៌នោះ ទាក់ទងនឹងការទាមទារនៃក្រឹត្យវិន័យរបស់ព្រះ និងថ្ងៃឈប់សម្រាកនៃបញ្ញត្តិទីបួនសោះឡើយ។ នេះជាអាថកំបាំងនៃអ្នក

តស៊ូជំទាស់នឹងការពិពណ៌នាដ៏ជាក់លាក់នៃបទគម្ពីរ ដែលសម្តែងអំពីកិច្ចការរបស់ព្រះគ្រីស្ទ ក្នុងរោងឧបោសថនៅស្ថានសួគ៌។ មនុស្សបានស្វះស្វែងរកបិទទ្វារដែលព្រះបានបើក ហើយបើកទ្វារដែលទ្រង់បានបិទ។ ប៉ុន្តែ ព្រះគ្រីស្ទបានបើកទ្វារ ដើម្បីប្រកបការងារក្នុងទីបរិសុទ្ធបំផុតហើយ។ បញ្ញត្តិទីបួនក៏មាននៅក្នុងក្រឹត្យវិន័យដែលតម្កល់នៅទីនោះដែរ។

<u>ពុធ-១១ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ៥

ខព្រះគម្ពីរប្រចាំថ្ងៃ: *នោះត្រូវឲ្យយើងចូលទៅជិតទាំងមានចិត្តស្មោះត្រង់ និងចិត្តដឹងពិតប្រាកដ ហើយសេចក្តីជំនឿ ព្រមទាំងមានចិត្តប្រោះញែកជាស្អាតរួចពីបញ្ជាចិត្តដែលសៅហ្មងផង ហើយបានលាងរូបកាយនឹងទឹកដ៏ស្អាតដែរ។ ហេព្រើរ ១០:២២*

អ្នកដែលទទួលពន្លឺស្តីពីការសម្រុះសម្រួលនៃព្រះគ្រីស្ទ និងក្រឹត្យវិន័យរបស់ព្រះ បានដឹងថាប្រការទាំងនេះជាសេចក្តីពិតនៃវិវរណៈជំពូក១៤ ដែលជាការព្រមានបីលើក ដើម្បីរៀបចំអ្នកដែលរស់នៅផែនដី សម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់។ ការប្រកាស «ពេលដែលទ្រង់ត្រូវជំនុំជម្រះនោះបានមកដល់ហើយ» ប្រាប់ឱ្យដឹងសេចក្តីពិតមួយ ដែលត្រូវតែប្រកាសលុះដល់ការអង្វរកររបស់ព្រះអង្គសង្គ្រោះនឹងត្រូវឈប់ ហើយទ្រង់នឹងត្រឡប់មកយករាស្ត្រទ្រង់មកឯទ្រង់វិញ។ ការជំនុំជម្រះដែលបានចាប់ផ្តើមនៅឆ្នាំ១៨៤៤ ត្រូវតែបន្តទៅមុខរហូតដល់ក្តីទាំងអស់ត្រូវបានសម្រេចទាំងអ្នកនៅរស់ និងអ្នកស្លាប់ ដូច្នេះការជំនុំជម្រះនេះនឹងពន្យារដល់ទីបញ្ចប់នៃពេលវេលាទុកឱ្យមនុស្សប្រែចិត្ត។

ដើម្បីឱ្យមនុស្សទាំងពួងអាចរៀបចំខ្លួន ដើម្បីឈរក្នុងទីជំនុំជម្រះបាន ព្រះរាជសារបានបង្គាប់ឱ្យគេ «កោតខ្លាចព្រះ ហើយសរសើរសិរីល្អរបស់ទ្រង់» «ហើយចូរក្រាបថ្វាយបង្គំព្រះដ៏ [ជាអ្នក] បង្កើតផ្ទៃមេឃ ផែនដី

សមុទ្រ និងរន្ធទឹកទាំងប៉ុន្មាន» ផង។ លទ្ធផលនៃការទទួលព្រះរាជសារទាំង
នេះគឺបានចែងមកហើយថា៖ «នេះហើយជាសេចក្តីអត់ធ្មត់របស់ពួកបរិសុទ្ធ
ដែលកាន់តាមបញ្ញត្តិរបស់ព្រះ ហើយមានសេចក្តីជំនឿដល់ព្រះយេស៊ូវ»។
វិវរណៈ ១៤:៧,១២។

ដើម្បីរៀបចំខ្លួនសម្រាប់ការជំនុំជម្រះ មនុស្សត្រូវរក្សាក្រឹត្យវិន័យ
របស់ព្រះ ដែលជាខ្នាតនៃចរិតក្នុងការវិនិច្ឆ័យ។ សាវកប៉ុលបានមាន
ប្រសាសន៍ថា៖ «អស់អ្នកណាដែលធ្វើបាបក្នុងបន្ទុកក្រឹត្យវិន័យនោះនឹងត្រូវ
ក្រឹត្យវិន័យជំនុំជម្រះវិញ...ក្នុងថ្ងៃដែលទ្រង់នឹងជំនុំជម្រះអស់ទាំងការលាក់
បាំងរបស់មនុស្ស...ដោយសារព្រះយេស៊ូវគ្រីស្ទ»។ «គឺបានរាប់ជាសុចរិតតែ
ពួកអ្នកដែលប្រព្រឹត្តតាមក្រឹត្យវិន័យតែប៉ុណ្ណោះទេ»។ សេចក្តីជំនឿគឺមាន
សារៈសំខាន់ណាស់ ក្នុងការរក្សាក្រឹត្យវិន័យរបស់ព្រះព្រោះ «បើឥតមាន
សេចក្តីជំនឿទេ នោះមិនអាចនឹងគាប់ព្រះហឫទ័យព្រះបានឡើយ»។
«ដ្បិតការទាំងប៉ុន្មានដែលធ្វើដោយឥតមានសេចក្តីជំនឿនោះសុទ្ធតែជាបាប
ទាំងអស់»។ រ៉ូម ២:១២-១៦; ហេព្រើរ ១១:៦; រ៉ូម ១៤:២៣។

ទេវតាទីមួយបានហៅមនុស្សឱ្យ «កោតខ្លាចព្រះ ហើយសរសើរសិរី
ល្អរបស់ទ្រង់» ព្រមទាំងឱ្យថ្វាយបង្គំទ្រង់ ដែលជាអ្នកបង្កបង្កើតផ្ទៃមេឃ និង
ផែនដី។ ដើម្បីធ្វើការនេះទៅបាន គេត្រូវគោរពក្រឹត្យវិន័យរបស់ទ្រង់។
ដោយគ្មានការប្រតិបត្តិតាម នោះគ្មានការគោរពណាដែលអាចគាប់ព្រះទ័យ
ដល់ព្រះឡើយ។ «ដ្បិតនេះហើយជាសេចក្តីស្រឡាញ់ដល់ព្រះ គឺឱ្យយើង
កាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់»។ យ៉ូហានទី១ ៥:៣; សូមអាន
សុភាសិត ២៨:៩។

ការហៅឱ្យគោរពព្រះអង្គការ

ភារកិច្ចដែលយើងត្រូវថ្វាយបង្គំព្រះ គឺស្ថិតនៅលើសេចក្តីដែលថា
ទ្រង់ជាព្រះដ៏ជាអ្នកបង្កបង្កើត។ «ចូរយើងឱនកាយថ្វាយបង្គំទាំងអស់គ្នា ចូរ
យើងលុតជង្គង់នៅចំពោះព្រះយេហូវ៉ា ជាព្រះដ៏ [ជាអ្នក] បង្កើតយើងខ្ញុំ»។

ទំនុកតំកើង ៩៥:៦; ទំនុកតំកើង ១០០:៣; អេសាយ ៤០:២៥,២៦; ៤៥:១៨។

នៅក្នុងវិវរណៈជំពូក១៤ មនុស្សត្រូវបានហៅឱ្យគោរពព្រះអាទិករ ហើយរក្សាបទបញ្ញត្តិរបស់ព្រះ។ មានបញ្ញត្តិមួយក្នុងបញ្ញត្តិទាំងនេះដែលចង្អុលទៅព្រះថាជាអ្នកបង្កបង្កើតៈ «រីឯថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សម្រាកថ្វាយព្រះយេហូវ៉ានៃឯងៈ...ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាទ្រង់បានធ្វើផ្ទៃមេឃ ផែនដី ហើយនិងសមុទ្រ ព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី៧ ទ្រង់ឈប់សម្រាក ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សម្រាក ហើយក៏ញែកចេញជាបរិសុទ្ធ»។ និក្ខមនំ ២០:១០,១១។ ចំពោះថ្ងៃឈប់សម្រាក ព្រះយេហូវ៉ាមានបន្ទូលថាជា «ទីសម្គាល់...ដើម្បីឱ្យឯងដឹងថា អញនេះគឺជាយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា»។ អេសេគាល ២០:២០។ ប្រសិនបើមនុស្សបានរក្សាថ្ងៃឈប់សម្រាកទូទាំងសកលលោក នោះគេប្រាកដជាបានបែរទៅឯព្រះអាទិករ ដើម្បីថ្វាយបង្គំ ហើយ ក៏នឹងលែងមានអ្នកថ្វាយបង្គំរូបចម្លាក់ លែងមានទមិឡ ឬអ្នកមិនជឿដែរ។ ការរក្សាថ្ងៃឈប់សម្រាក គឺជាសញ្ញានៃសេចក្តីស្មោះត្រង់ដល់ «ព្រះដ៏[ជាអ្នក] បង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងរន្ធទឹកទាំងប៉ុន្មាន»។ ព្រះរាជសារដែលអំពាវនាវមនុស្សឱ្យថ្វាយបង្គំព្រះ និងឱ្យរក្សាក្រឹត្យវិន័យរបស់ទ្រង់នោះ នឹងហៅគេឱ្យរក្សាបញ្ញត្តិទីបួន។

<u>ព្រហស្បតិ៍-១២ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃៈ សាស្តា ជំពូក ៦

ខព្រះគម្ពីរប្រចាំថ្ងៃ: *ត្រូវឲ្យយើងរាល់គ្នាកាន់ខ្ជាប់ តាមសេចក្តីបន្ទាល់របស់សេចក្តីសង្ឃឹមនោះ ឥតរវើរវាយ ដ្បិតព្រះដែលបានសន្យានោះ ទ្រង់ស្មោះត្រង់។ ហេព្រើរ ១០:២៣*

ផ្ទុយនឹងអ្នកដែលរក្សាបញ្ញត្តិរបស់ព្រះ ហើយមានជំនឿដល់ព្រះ

យេស៊ូវនោះ ទេវតាចង្អុលទៅក្រុមមួយទៀតថា៖ «បើអ្នកណាក្រាបថ្វាយបង្គំសត្វនោះ និងរូបវា ហើយទទួលទីសម្គាល់វានៅលើថ្ងាស អ្នកនោះនឹងផឹកស្រាផងសេចក្ដីឃោរឃៅរបស់ព្រះ»។ វិវរណៈ ១៤:១០,១១។ តើអ្វីទៅដែលតំណាងដោយសត្វ រូបវា និងទីសម្គាល់វានោះ?

អត្តសញ្ញាណនៃសត្វនាគ

និមិត្តរូបទាំងឡាយនៃបទទំនាយ គឺបានរកឃើញក្នុងវិវរណៈជំពូក ១២។ នាគដែលរកបំផ្លាញព្រះគ្រីស្ទនៅពេលទ្រង់ចាប់បដិសន្ធិនោះ គឺជាសាតាំង (វិវរណៈ ១២:៩) ព្រោះវាបានបណ្ដាលស្តេចហេរ៉ូដឱ្យធ្វើគុតដល់ព្រះអង្គសង្គ្រោះ។ ប៉ុន្តែ ភ្នាក់ងាររបស់សាតាំងដែលធ្វើសង្គ្រាមជាមួយព្រះគ្រីស្ទ និងរាស្ត្រទ្រង់ក្នុងសតវត្សទីមួយ គឺជាចក្រភពរ៉ូម ដែលនៅកាលនោះសាសនាដទៃជាសាសនាដែលគេកាន់ច្រើន។ ដូច្នេះនាគ ក្នុងន័យទីពីរ គឺជារ៉ូមដែលកាន់សាសនាដទៃ។

នៅក្នុងវិវរណៈជំពូក១៣ មានសត្វមួយទៀត «មើលទៅដូចជាខ្លារខិន» ដែលនាគឱ្យ «ឫទ្ធិ និងបល្ល័ង្ក...ព្រមទាំងអំណាចយ៉ាងធំ» ដល់សត្វនោះ។ ក្រុមប្រូតេស្តង់ភាគច្រើនបានជឿថា និមិត្តរូបនេះ តំណាងប្រព័ន្ធកាតូលិករ៉ូមដែលបានទទួលឫទ្ធិ បល្ល័ង្ក និងអំណាចពីចក្រភពរ៉ូម។ ស្តីពីសត្វដែលដូចជាខ្លារខិនវិញ មានចែងថា៖ «នាគក៏ឱ្យវាមានមាត់ចេះនិយាយពាក្យសម្តីដ៏ធំ និងពាក្យប្រមាថ...វាបើកមាត់ប្រមាថដល់...ព្រះ...ព្រះនាម និងព្រះវិហារនៃទ្រង់ដែរ ព្រមទាំងដល់ពួកអ្នកដែលនៅស្ថានសួគ៌ផង។ ក៏មានអំណាចបានប្រគល់ដល់វា ឱ្យច្បាំងឈ្នះពួកបរិសុទ្ធបាន ហើយនិងអំណាចលើគ្រប់ទាំងពូជមនុស្ស គឺអស់ទាំងគ្រួសារភាសា ហើយនិងអស់ទាំងសាសន៍ផង»។ វិវរណៈ ១៣:២,៥-៧។ ទំនាយនេះ គឺស្ទើរតែដូចគ្នានឹងការពិពណ៌នាអំពីស្នែងតូច ក្នុងគម្ពីរដានីយ៉ែលជំពូក៧ដែរ ដែលចង្អុលទៅប្រព័ន្ធកាតូលិករ៉ូម ដោយពុំបាច់ឆ្ងល់។

«ក៏ឱ្យមានអំណាចនឹងធ្វើការ [របស់] វា រវាង៤២ខែ» ជាអំឡុងពេល

បីឆ្នាំកន្លះ ឬ១២៦០ថ្ងៃ ក្នុងដានីយ៉ែលជំពូក៧ ក្នុងពេលដែលអំណាចកាតូលិក រ៉ូមបានជិះជាន់ដល់រាស្ត្ររបស់ព្រះ។ អំឡុងពេលនេះ ដូចបានចែងពីជំពូកពី មុនហើយ គឺចាប់ផ្តើមឡើងដោយឧត្តមភាពនៃប្រព័ន្ធកាតូលិករ៉ូមពីឆ្នាំ៥៣៨ គ.ស. ហើយចប់នៅឆ្នាំ១៧៩៨។ នៅពេលនោះអំណាចកាតូលិករ៉ូម បាន ទទួល «របួសដល់ស្លាប់» ហើយទំនាយត្រូវបានសម្រេចដូចបានទាយ៖ «អ្នកណាដែលដឹកគេឱ្យទៅជាឈ្លើយ អ្នកនោះឯងនឹងត្រូវគេដឹកនាំខ្លួនទៅ ជាឈ្លើយដែរ»។

ការលេចឡើងនៃអំណាចថ្មី

មកដល់ចំណុចនេះ និមិត្តរូបមួយទៀតបានមានលេចឡើង៖ «ខ្ញុំក៏ យើញសត្វសាហាវមួយទៀតឡើងចេញពីដីមក វាមានស្នែងពីរដូចជាកូន ចៀម តែពោលពាក្យដូចជានាគវិញ»។ វិវរណៈ ១៣:១១។ ប្រទេសជាតិនេះ គឺពុំដូចជាប្រទេសទាំងនោះដែលបានសម្តែងក្រោមនិមិត្តរូបពីមុនទេ។ នគរ ដ៏ធំៗដែលបានគ្រប់គ្រងពិភពលោក គឺបានសម្តែងដល់ហោរាដានីយ៉ែល ថាជាសត្វដែលបានលេចឡើងនៅពេល «ខ្យល់ទាំងបួននៅលើអាកាសធ្លាក់ ចុះមកលើមហាសមុទ្រ»។ ដានីយ៉ែល ៧:២។ នៅក្នុងវិវរណៈ ១៧:១៥ ទេវតាបានពន្យល់ថា ទឹកគឺតំណាង «ប្រជាជន មនុស្សផងទាំងឡាយ គ្រប់ សាសន៍ គ្រប់ភាសា។ ខ្យល់គឺតំណាងពីចលាចល។ ខ្យល់ទាំងបួនដែលបក់ បោកមកលើមហាសមុទ្រ តំណាងទស្សនីយភាពនៃការប្រយុទ្ធ និងបដិវត្តន៍ ដ៏អាក្រក់ ដែលនគរទាំងប៉ុន្មានបានបង្កើតឡើង ដើម្បីកាន់អំណាច»។

ប៉ុន្តែ សត្វដែលមានស្នែងដូចជាកូនចៀម ត្រូវបានឃើញ «ឡើង ចេញពីដី»។ ជាជាងទម្លាក់អំណាចនៃប្រទេសដទៃទៀត ដើម្បីដំឡើងខ្លួន ឯង ប្រទេសនេះត្រូវតែលេចឡើងក្នុងតំបន់ដែលគ្មាននរណាគ្រប់គ្រងពីមុន ហើយបានលូតលាស់ឡើងដោយសន្តិភាព។ ប្រទេសនេះត្រូវរកឃើញនៅ ទ្វីបខាងលិច។

<u>សុក្រ-១៣ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ៧

ខព្រះគម្ពីរប្រចាំថ្ងៃ: *ហើយត្រូវឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្តាលឲ្យមានសេចក្តីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង ។ ហេព្រើរ ១០:២៤*

តើប្រទេសនៃដែនដីថ្មីណាដែលក្នុងឆ្នាំ១៧៩៨ បានលេចមានអំណាចឡើង ហើយអះអាងនូវកម្លាំងខ្លាំងក្លា ហើយទាក់ស្មារតីពិភពលោកនោះ? មានតែប្រទេសមួយគត់ ដែលត្រូវនឹងទំនាយនេះគឺសហរដ្ឋអាមេរិក។ ក្នុងការពិពណ៌នាដំណើរលូតឡើងនៃប្រទេសនេះ អ្នកប្រវត្តិសាស្ត្របានប្រើពាក្យដោយមិនដឹងខ្លួនថា អ្វីដែលខ្លួនបានសរសើរគឺស្ទើរតែដូចគ្នានឹងសំណេររបស់ហោរា។ អ្នកនិពន្ធដ៏ល្បីល្បាញម្នាក់បានថ្លែងពី *«អាថ៌កំបាំងនៃការលេចឡើងពីកន្លែងទទេ»* ហើយមានប្រសាសន៍ថា «ដូចជាគ្រាប់ពូជមួយយើងបានលូតលាស់ឡើងទៅជាចក្រភព»[1]។ ទស្សនាវដ្តីអ៊ឺរ៉ុបក្នុងឆ្នាំ១៨៥០ បានថ្លែងពីសហរដ្ឋអាមេរិកថា «លេចធ្លោឡើង» ហើយ «ក្នុងភាពសូប់ស្ងាត់នៃដែនដី វាបានមានអំណាច និងឫកក្អែងក្អាងរាល់ថ្ងៃ»[2]។

«វាមានស្នែងពីរ ដូចជាកូនចៀម»។ ស្នែងដូចជាកូនចៀម បង្ហាញពីយុវភាព ភាពស្លូតបូត និងភាពទន់ភ្លន់។ ក្នុងចំណោមជននិរទេសគ្រីស្ទានដែលបានគេចខ្លួនទៅអាមេរិក ពីអំណាចជិះជាន់របស់ស្តេច និងពីការបៀតបៀនរបស់ពួកសង្ឃ ភាគច្រើនជាអ្នកតាំងចិត្តតស៊ូ ដើម្បីកសាងសេរីភាពស៊ីវិល និងសេរីភាពសាសនា។ សេចក្តីប្រកាសឯករាជ្យបានពន្លេចចេញការពិតថា «មនុស្សគ្រប់រូបត្រូវបានបង្កើតមកទាំងមានភាពស្មើគ្នា» ហើយបានប្រកបដោយសិទ្ធិនឹងទទួល «ជីវិត សេរីភាព និងការស្វែងរកសុភមង្គល» ដែលពុំអាចដកចេញបាន។ រដ្ឋធម្មនុញ្ញ ធានាឱ្យប្រជាជននូវសិទ្ធិគ្រប់គ្រងដោយខ្លួនឯង ឱ្យតែអ្នកតំណាងរាស្ត្រដែលត្រូវបានជ្រើសរើសដោយសន្លឹកឆ្នោតច្រើននោះ អនុម័ត ហើយចាត់ចែងច្បាប់។ សេរីភាពនៃជំនឿសាសនា

ក៏បានអនុញ្ញាតឱ្យមានដែរ។ សាធារណរដ្ឋនិយម និងប្រូតេស្តង់និយម បានក្លាយជាគោលការដ៏សំខាន់របស់ជាតិ ហើយនេះជាភាពសម្ងាត់នៃអំណាច និងការរីកចម្រើនរបស់វា។ មនុស្សរាប់លានបានឆ្លងមកតាំងទីលំនៅ ហើយសហរដ្ឋអាមេរិកបានលូតឡើងចូលក្នុងចំណោមប្រទេសមានអំណាចបំផុតនៃផែនដី។

ការផ្ទុយគ្នាដ៏ច្បាស់ក្រឡែត

ប៉ុន្តែ សត្វដែលមានស្នែងដូចកូនចៀម «ពោលពាក្យដូចជានាគវិញ ក៏ប្រព្រឹត្តដោយនូវគ្រប់ទាំងអំណាចរបស់សត្វទីមួយ នៅមុខនាគនោះ ទាំងបណ្តាលឱ្យផែនដី និងអស់អ្នកដែលនៅផែនដីបានក្រាបថ្វាយបង្គំដល់សត្វទីមួយ ដែលមានរបួសដល់ស្លាប់នោះ តែបានសះជាវិញ...ក៏ប្រាប់ដល់ពួកអ្នកនៅផែនដី ឱ្យធ្វើរូបសត្វនោះ ដែលត្រូវរបួសនឹងដាវតែបានរស់វិញ»។ វិវរណៈ ១៣:១១-១៤។

ស្នែងដូចជាកូនចៀម និងនាគ ចង្អុលប្រាប់ថាមានសេចក្តីផ្ទុយគ្នា។ ការទាយថាវានឹងពោល «ដូចជានាគ» ហើយ «ប្រព្រឹត្តដោយនូវគ្រប់ទាំងអំណាចរបស់សត្វទីមួយ» គឺសំដៅទៅលើកិរិយាមិនអត់ធ្មត់ និងការធ្វើទុក្ខបុកម្នេញ ដែលអនុវត្តដោយនាគ និងសត្វដែលដូចជាខ្លារខិន ហើយប្រយោគដែលថាសត្វមានស្នែងពីរដែល «បណ្តាលឱ្យផែនដី និងអស់អ្នកដែលនៅផែនដីបានក្រាបថ្វាយបង្គំដល់សត្វទីមួយ» នោះ បង្ហាញថាប្រទេសនេះនឹងប្រើអំណាចបង្ខំឱ្យគេគោរពដល់ប្រព័ន្ធកាតូលិក។

អំពើរបៀបនេះ នឹងផ្ទុយទៅនឹងសេចក្តីក្លៀវក្លានៃច្បាប់សេរី ផ្ទុយនឹងសច្ចាប្រណិធាននៃសេចក្តីប្រកាសឯករាជ្យ និងរដ្ឋធម្មនុញ្ញហើយ។ រដ្ឋធម្មនុញ្ញបានចែងមកថា «សភានឹងមិនត្រូវធ្វើច្បាប់ចំពោះការស្ថាបនានៃសាសនាណាមួយ ឬហាមប្រាមការអនុវត្តដោយសេរីនូវសាសនានោះឡើយ» ហើយ «នឹងមិនត្រូវការការសាកល្បងខាងសាសនា ដើម្បីឱ្យបានចូលទៅក្នុងក្រសួងសាធារណៈណាមួយក្នុងសហរដ្ឋអាមេរិកឡើយ»។ ការរំលោភ

ដ៏ជាក់ស្តែងដែលមិនឱ្យមានសេរីភាពចំពោះសេចក្តីអះអាងទាំងនេះ គឺ តំណាងដោយនិមិត្តរូបវិញ។ តាមសេចក្តីអះអាងនោះ សត្វដែលមានស្នែង ដូចជាកូនចៀមគឺបរិសុទ្ធ សុភាព និងស្លូតបូត តែពោលដូចជាសត្វនាគវិញ។

«ក៏ប្រាប់ដល់ពួកអ្នកនៅផែនដី ឱ្យធ្វើរូបសត្វនោះ»។ នេះជាការសម្តែងទម្រង់រដ្ឋាភិបាលដែលអំណាចបង្កើតច្បាប់ គឺស្រេចនៅលើប្រជាជន ហើយជាភ័ស្តុតាងយ៉ាងជាក់លាក់បំផុតថា ប្រទេសដែលសំដៅទៅនោះ គឺ សហរដ្ឋអាមេរិក។

ប៉ុន្តែ តើអ្វីទៅជា «រូបសត្វ»? តើវានឹងមានរូបរាងយ៉ាងណាទៅ?

នៅពេលវិហារជំនាន់ដើមបានពុករលួយទៅ គេក៏បានរកការគាំទ្រពីអំណាចលោកីយ៍។ លទ្ធផលគឺ៖ ប្រព័ន្ធកាតូលិករ៉ូម ដែលជាវិហារគ្រប់គ្រងរដ្ឋ ជាពិសេសខាងការដាក់ទណ្ឌកម្មចំពោះ «លទ្ធិខុសឆ្គង»។ ដើម្បីឱ្យសហរដ្ឋអាមេរិកធ្វើ «រូបសត្វ» នោះបាន អំណាចសាសនាត្រូវតែគ្រប់គ្រងរដ្ឋាភិបាលស៊ីវិល ហើយរដ្ឋត្រូវធ្វើការក្រោមការត្រួតត្រារបស់វិហារ ដើម្បីឱ្យបានសម្រេចគោលបំណងរបស់ខ្លួន។

<u>សៅរ៍-១៤ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ៨

ខព្រះគម្ពីរប្រចាំសប្តាហ៍: *ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំឡាចិត្តគ្នាវិញ ឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ។ ហេព្រើរ ១០:២៥*

វិហារប្រូតេស្តង់ដែលបានតាមជំហានរបស់រ៉ូម បានសម្តែងចំណង់ប្រហាក់ប្រហែលគ្នាដើម្បីបន្តឹងសេរីភាពខាងសតិសម្បជញ្ញៈ។ ឧទាហរណ៍ពីការនេះ មានដូចជាការធ្វើទុក្ខទោសដ៏យូរអង្វែងដល់ពួកអ្នកខ្វែងយោបល់ដោយព្រះវិហារអង់គ្លេស។ ក្នុងអំឡុងសតវត្សទី១៦ និង១៧ ពួកគ្រូគង្វាលដែលមិនចុះចូលនឹងគេ និងពួកបណ្តាជនទាំងឡាយ ត្រូវបានទទួលពិន័យ

ការជាប់គុក ទារុណកម្ម និងការប្តូរជីវិតដល់ស្លាប់ទៀតផង។

ការងាកចេញពីជំនឿ បាននាំឱ្យវិហារជាន់ដើមរកជំនួយពីរដ្ឋាភិបាលស៊ីវិល ហើយការនេះបានរៀបចំផ្លូវសម្រាប់ប្រព័ន្ធកាតូលិក ដែលជាសត្វ។ សាវ័កប៉ុលមានប្រសាសន៍ថា៖ «ទាល់តែមានការក្បត់សាសនាមក ជាមុនហើយមនុស្សដែលជាតួបាបនោះបានលេចមក»។ ថែស្សាឡូនីចទី២ ២:៣។

ព្រះគម្ពីរបានចែងថា៖ «ចូរឱ្យដឹងថា នៅជាន់ក្រោយបង្អស់ នឹងមានគ្រាលំបាកណាស់ ដ្បិតនៅគ្រានោះ មនុស្សនឹង *ស្រឡាញ់តែខ្លួនឯង* ទាំងស្រឡាញ់ប្រាក់ អួតអាងគយរ មានឫកខ្ពស់ ប្រមាថមើលងាយ មិនស្តាប់បង្គាប់ឪពុកម្តាយ រមិលគុណ មានចិត្តមិនបរិសុទ្ធ មិនស្រឡាញ់តាមធម្មតាមនុស្ស គ្មានសេចក្តីអធ្យោគ និយាយបង្កាច់គេ មិនចេះទប់ចិត្ត មានចិត្តសាហាវ *មិនចូលចិត្តនឹងការល្អ* ក្បត់គេឥតបើគិត មានចិត្តធំ ហើយ *ចូលចិត្តនឹងល្បែងលេងជាជាងព្រះ គេមានឫកពាជាអ្នកគោរពប្រតិបត្តិដល់ព្រះ* ប៉ុន្តែមិនព្រមទទួលស្គាល់ព្រះចេស្តាដែលមកដោយ [ការ] គោរពប្រតិបត្តិនោះទេ»។ ធីម៉ូថេទី២ ៣:១-៥។ «តែព្រះវិញ្ញាណទ្រង់មានបន្ទូលយ៉ាងជាក់ច្បាស់ថា នៅគ្រាជាន់ក្រោយបង្អស់ អ្នកខ្លះនឹងលាចាកចេញពីសេចក្តីជំនឿដោយស្តាប់តាមវិញ្ញាណបញ្ឆោតនឹងសេចក្តីបង្រៀនរបស់ពួកអារក្ស»។ ធីម៉ូថេទី១ ៤:១។

អស់អ្នកដែល «មិនព្រមស្រឡាញ់ដល់សេចក្តីពិត ដើម្បីឱ្យបានសង្គ្រោះនោះ» នឹងទទួល «សេចក្តីខុសឆ្គង បណ្តាលឱ្យគេជឿតាមសេចក្តីភូតភរវិញ»។ ថែស្សាឡូនីចទី២ ២:១០-១១។ នៅពេលបានដល់ស្ថានភាពនេះ នឹងមានលទ្ធផលដូចនៅក្នុងសតវត្សទីមួយដែរ។

ការមានជំនឿប្លែកគ្នាជាច្រើនក្នុងព្រះវិហារប្រូតេស្តង់ ធ្វើឱ្យជនជាច្រើនចាត់ទុកជាសក្ខីភាពថាមិនអាចបង្ខំឱ្យមានឯកភាពបានឡើយ។ ប៉ុន្តែ វិហារប្រូតេស្តង់ចង់ធ្វើឱ្យមានសហភាពនឹងគ្នា អស់រាប់ឆ្នាំមកហើយ។ ដើម្បីឱ្យបានសហភាពនេះ គោលលទ្ធិណាមួយដែលគេទាំងអស់គ្នាពុំយល់ស្រប

តាមនោះ នឹងត្រូវទុកដោយឡែក។ ក្នុងការព្យាយាមទាញយកឯកភាពទាំងស្រុងនោះ គឺខ្វះតែមួយជំហានទៀត ដល់ការបង្ខំហើយ។

នៅពេលព្រះវិហារល្បីៗនៃសហរដ្ឋអាមេរិក រួបរួមគោលជំនឿដែលគេមានដូចគ្នា បង្ខំរដ្ឋឱ្យចេញក្រឹត្យក្រមរបស់ខ្លួន ហើយលើកស្ទួយច្បាប់ដែលបានតាំងឡើងនោះ នោះប្រូតេស្តង់អាមេរិកនឹងបានធ្វើជារូបនៃហានន្តរបស់រ៉ូម ហើយនឹងមានការដាក់ពិន័យដល់អ្នកខ្វែងយោបល់ជាពុំខាន។

សត្វ និងរូបខា

សត្វដែលមានស្នែងពីរ វាបង្ខំឱ្យមនុស្សទាំងអស់ ទាំងធំទាំងតូច ទាំងមានទាំងក្រ ហើយទាំងអ្នកជានិងបាវគេ ឱ្យទទួលទីសម្គាល់នៅដៃស្តាំ ឬនៅថ្ងាសគេរៀងខ្លួន ហើយមិនបើកឱ្យអ្នកណាមានច្បាប់នឹងទិញ ឬលក់អ្វីបានឡើយ លើកតែអ្នកដែលមានទីសម្គាល់នោះចេញគឺជាឈ្មោះរបស់សត្វនោះ ឬជាលេខឈ្មោះរបស់វា។ វិវរណៈ ១៣:១៦-១៧។ ទេវតាទីបីព្រមានថា៖ «បើអ្នកណាក្រាបថ្វាយបង្គំដល់សត្វនោះនិងរូបវា ហើយទទួលទីសម្គាល់វានៅលើថ្ងាស ឬនៅដៃ អ្នកនោះនឹងត្រូវផឹកស្រាផងសេចក្តីឃោរឃៅរបស់ព្រះ»។

«សត្វ» ដែលគេបង្ខំឱ្យគោរពនោះ គឺជាសត្វដូចជាខ្លារខិន ឬសត្វទីមួយនៃវិវរណៈជំពូក១៣ដែលជាប្រព័ន្ធកាតូលិករ៉ូម។ «រូបសត្វ» គឺតំណាងរូបរាងនៃប្រូតេស្តង់និយមដែលងាកចេញពីជំនឿដែលនឹងកកើតឡើងនៅពេលវិហារប្រូតេស្តង់រកជំនួយពីអំណាចស៊ីវិល ដើម្បីបង្ខំឱ្យគេទទួលគោលជំនឿរបស់ខ្លួន។ រីង «ទីសម្គាល់របស់សត្វ» យើងនឹងឱ្យអត្ថន័យ នៅពេលបន្តិចទៀត។

អ្នកដែលរក្សាបញ្ញត្តិរបស់ព្រះ គឺផ្ទុយទៅនឹងអ្នកដែលគោរពសត្វនិងរូបសត្វ ហើយទទួលទីសម្គាល់របស់វា។ ការរក្សា និងការបំពានក្រឹត្យវិន័យរបស់ព្រះ នឹងបានជាទីសម្គាល់រវាងអ្នកគោរពថ្វាយបង្គំព្រះ និងអ្នកគោរពថ្វាយបង្គំសត្វ។

<u>អាទិត្យ-១៥ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ៩

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដ្បិតក្រោយដែលយើងបានទទួលស្គាល់សេចក្តីពិតហើយ បើយើងធ្វើបាប ស្ម័គ្រពីចិត្តទៀត នោះគ្មានយញ្ញបូជាណា សំរាប់នឹងលោះបាបទៀតទេ។ ហេព្រើរ ១០:២៦*

លក្ខណៈសម្បត្តិពិសេសនៃសត្វ និងរូបរបស់វា គឺការបំពានបញ្ញត្តិរបស់ព្រះ។ ដានីយ៉ែលមានប្រសាសន៍អំពីស្នែងតូច ដែលជាប្រព័ន្ធកាតូលិករ៉ូមថា៖ «ស្តេចនោះ...គិតបំផ្លាស់ពេលកំណត់ និងច្បាប់»។ ដានីយ៉ែល ៧:២៥។ សាវ័កប៉ុលបានហៅអំណាចដូចគ្នានេះ ថាជា «មនុស្សដែលជាតួបាប» (ថែស្សាឡូនីចទី២ ២:៣) ដែលនឹងត្រូវតម្កើងខ្លួនលើព្រះបាន។ អ្នកណាដែលរក្សាក្រឹត្យវិន័យរបស់ព្រះដែលបានដឹងថាគេបានបំផ្លាស់បំប្រែ នោះនឹងផ្តល់កិត្តិយសដ៏ឧត្តមដល់ក្រឹត្យវិន័យរបស់លទ្ធិកាតូលិករ៉ូមហើយជាទីសម្គាល់នៃសេចក្តីស្មោះត្រង់ដល់ប៉ាប ជាជាងដល់ព្រះ។

ប្រព័ន្ធកាតូលិករ៉ូម បានរកបំផ្លាស់បំប្រែក្រឹត្យវិន័យរបស់ព្រះ។ បញ្ញត្តិទីបួនត្រូវបាន «ប្តូរ» ដើម្បីឱ្យគេគោរពថ្ងៃទីមួយ ជាជាងថ្ងៃទីប្រាំពីរជា ថ្ងៃឈប់សម្រាក។ ការផ្លាស់ប្តូរដោយប៉ិង និងដោយចេតនានោះ គឺបានសម្តែងថា៖ «ស្តេចនោះ...*គិត*បំផ្លាស់ពេលកំណត់ និងច្បាប់»។ ការបំផ្លាស់បំប្រែដល់បញ្ញត្តិទីបួន គឺបានសម្រេចបទទំនាយយ៉ាងជាក់ច្បាស់។ ទីនេះអំណាចស្តេចសង្ឃលើកតម្កើងខ្លួនលើព្រះដោយមិនលាក់មុខ។

អ្នកគោរពថ្វាយបង្គំព្រះ នឹងបានឃើញខុសប្លែកពីគេដោយការគោរពបញ្ញត្តិទីបួន ដែលជាសញ្ញានៃឥទ្ធិឫទ្ធិបង្កបង្កើតរបស់ទ្រង់។ អ្នកគោរពថ្វាយបង្គំសត្វ នឹងបានឃើញខុសប្លែកពីគេ ដោយការខិតខំបំផ្លិចបំផ្លាញសាធារណៈវត្ថុរបស់ព្រះអាទិករ ដើម្បីតម្កើងបទបញ្ជារបស់រ៉ូម។ គឺដោយការយកថ្ងៃអាទិត្យមកធ្វើជា «ថ្ងៃរបស់ព្រះអម្ចាស់» នេះឯង បានជាលទ្ធិកាតូលិករ៉ូមពោលពាក្យអះអាងដ៏ក្រអឺតនោះ។ ប៉ុន្តែ ព្រះគម្ពីរបានចង្អុលទៅថ្ងៃទីប្រាំពីរ

ថាជាថ្ងៃរបស់ព្រះអម្ចាស់។ ព្រះគ្រីស្ទបានមានបន្ទូលថា៖ «កូនមនុស្សជាម្ចាស់នៃថ្ងៃឈប់សម្រាក»។ ម៉ាកុស ២:២៨។ សូមអានអេសាយ ៥៨:១៣; ម៉ាថាយ ៥:១៧-១៩។ ការពោលអះអាងដែលច្រើនតែលើកមកថា ព្រះគ្រីស្ទបានផ្លាស់ថ្ងៃឈប់សម្រាកហើយនោះ គឺបានបង្ហាញឱ្យឃើញថាខុស ដោយព្រះបន្ទូលទ្រង់ផ្ទាល់។

ឥតមានចែងក្នុងសញ្ញាថ្មី

ក្រុមប្រូតេស្តង់ទទួលស្គាល់ថា «ព្រះគម្ពីរសញ្ញាថ្មីឥតមានចែងទាល់តែសោះ អំពីបទបញ្ជាដ៏ច្បាស់ណាមួយចំពោះថ្ងៃឈប់សម្រាក [ថ្ងៃអាទិត្យជាថ្ងៃទីមួយក្នុងសប្តាហ៍] ឬអំពីវិន័យច្បាស់លាស់ណាមួយ សម្រាប់ការរក្សាថ្ងៃឈប់សម្រាកឡើយ»[៣]។

«មកដល់វេលានៃការសុគតរបស់ព្រះគ្រីស្ទ គ្មានការផ្លាស់ប្តូរថ្ងៃទេ» ហើយ «បើតាមឯកសារវិញ វាបង្ហាញថាពួកគេ [ពួកសាវ័ក]...ពុំបានចេញសេចក្តីបញ្ជាជាក់លាក់ បង្គាប់ឱ្យលះបង់ចោលថ្ងៃទីប្រាំពីរដែលជាថ្ងៃឈប់សម្រាក ហើយគោរពនៅថ្ងៃទីមួយនៃសប្តាហ៍ទេ»[៤]។

ពួកកាតូលិករ៉ូមបានទទួលស្គាល់ថា ការផ្លាស់ប្តូរថ្ងៃឈប់សម្រាកត្រូវបានធ្វើដោយព្រះវិហាររបស់គេ ហើយពោលថា ដោយគោរពថ្ងៃអាទិត្យ ពួកប្រូតេស្តង់ គឺទទួលស្គាល់អំណាចរបស់វិហារគេហើយ។ គេបានថ្លែងថា៖ «នៅក្នុងក្រឹត្យវិន័យចាស់ ថ្ងៃសៅរ៍គឺជាថ្ងៃដែលបានញែកជាបរិសុទ្ធ ប៉ុន្តែ *ព្រះវិហារ* ដែលបានបង្គាប់ដោយព្រះយេស៊ូវគ្រីស្ទ និងដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ បានប្តូរថ្ងៃសៅរ៍ទៅថ្ងៃអាទិត្យវិញ ដូច្នេះឥឡូវនេះយើងគោរពថ្ងៃទីមួយជាថ្ងៃបរិសុទ្ធ ពុំមែនថ្ងៃទីប្រាំពីរទេ។ ថ្ងៃអាទិត្យឥឡូវនេះមានន័យថាជាថ្ងៃរបស់ព្រះអម្ចាស់»[៥]។

ពួកអ្នកនិពន្ធកាតូលិកបានលើកពី «ការប្តូរថ្ងៃឈប់សម្រាកទៅថ្ងៃអាទិត្យ ដែលពួកប្រូតេស្តង់មិនដែលជំទាស់នោះ» ថាជាទីសម្គាល់នៃ

អំណាចរបស់វិហារកាតូលិក «...ពីព្រោះដោយរក្សាថ្ងៃអាទិត្យគេទទួលស្គាល់អំណាចរបស់ព្រះវិហារ ឱ្យប្រសិទ្ធីពិធីជប់លៀង និងបញ្ជាគេឱ្យធ្វើបាបទៀតផង»[៦]។

<u>ចន្ទ-១៦ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ១០

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែយើងរាល់គ្នាមិនមែនជាពួកអ្នក ដែលថយទៅវិញឲ្យត្រូវវិនាសនោះឡើយ គឺជាពួកអ្នកដែលមានសេចក្តីជំនឿសំរាប់ឲ្យព្រលឹងបានសង្គ្រោះវិញ។ ហេព្រើរ ១០:៣៩*

បើដូច្នោះ តើការផ្លាស់ប្តូរថ្ងៃឈប់សម្រាកគឺជាអ្វីទៅ ក្រៅពីគ្រាន់តែជាសញ្ញា ឬជាទីសម្គាល់នៃអំណាចរបស់វិហារ៉ូមនោះ? ជា «ទីសម្គាល់របស់សត្វ» ទេដឹង?

វិហារ៉ូម ពុំដែលលះបង់ចោលសេចក្តីអះអាងចង់បាននូវអំណាចគ្រប់គ្រងឡើយ។ នៅពេលពិភពលោក និងវិហារប្រូតេស្តង់ ទទួលថ្ងៃឈប់សម្រាកដែលវិហារ៉ូមបង្កើតនោះ ក្នុងពេលដែលគេបដិសេធថ្ងៃឈប់សម្រាកនៃព្រះគម្ពីរ ពួកគេប្រៀបដូចជាទទួលស្គាល់នូវអំណាចគ្រប់គ្រងរបស់វិហារ៉ូមដូច្នោះឯង។ ក្នុងការប្រព្រឹត្តដូចនេះ គឺគេបំភ្លេចគោលការដែលញែកពួកគេចេញពីរ៉ូមហើយ ថា «ព្រះគម្ពីរហើយមានតែព្រះគម្ពីរតែមួយគត់ គឺជាសាសនានៃពួកប្រូតេស្តង់»។ នៅពេលចលនានៃការចេញច្បាប់ឱ្យគោរពថ្ងៃអាទិត្យ ទាក់ចិត្តមនុស្សកាន់តែខ្លាំងឡើង នោះពិភពប្រូតេស្តង់ទាំងមូលនឹងស្ថិតនៅក្រោមនឹមរបស់រ៉ូមក្នុងទីបំផុតជាប្រាកដ។

ពួកកាន់សាសនារ៉ូមថ្លែងថា «ការដែលពួកប្រូតេស្តង់គោរពថ្ងៃអាទិត្យ ក៏ដូចជាគេគោរពដល់អំណាចនៃវិហារ [កាតូលិក] ដូច្នោះ ទោះជាគេមានជំនឿខុសគ្នាក៏ដោយ»[៧]។ ការបង្ខិតបង្ខំឱ្យមានភារកិច្ចគោរពសាសនាដោយអំណាចលោកីយ៍ នឹងបង្កើតរូបសត្វ ម្ល៉ោះហើយការចេញច្បាប់

ឱ្យរក្សាថ្ងៃអាទិត្យក្នុងសហរដ្ឋអាមេរិក នឹងបានជាការចេញច្បាប់ឱ្យគោរពសត្វនិងរូបសត្វវិញ។

ពួកគ្រីស្ទានៅជំនាន់ដើម គោរពថ្ងៃអាទិត្យដោយគិតថាគេរក្សាថ្ងៃឈប់សម្រាកក្នុងព្រះគម្ពីរ ហើយឥឡូវនេះ មានពួកគ្រីស្ទានពិតប្រាកដក្នុងគ្រប់ព្រះវិហារ ដែលជឿស្មោះអស់ពីចិត្តថាថ្ងៃអាទិត្យជាថ្ងៃដែលព្រះបានដាក់មកឱ្យគោរព។ ព្រះទ្រង់ទទួលស្គាល់សេចក្តីស្មោះត្រង់ និងសេចក្តីសុចរិតរបស់គេ។ ប៉ុន្តែ នៅពេលគេចេញច្បាប់ឱ្យគោរពថ្ងៃអាទិត្យ ហើយពិភពលោកនឹងបានយល់ច្បាស់ពីថ្ងៃឈប់សម្រាកពិតប្រាកដនោះ នោះអស់អ្នកណាដែលបំពានសេចក្តីបង្គាប់របស់ព្រះ ដើម្បីស្តាប់តាមសិក្ខាបទរបស់រ៉ូមនឹងគោរពលទ្ធិកាតូលិករ៉ូមលើព្រះហើយ។ គឺគេគោរពវិហាររ៉ូមតែម្តង។ គេគោរពសត្វ និងរូបសត្វ។ មនុស្សនឹងទទួលស្គាល់សញ្ញានៃសេចក្តីស្មោះស្ម័គ្រដល់រ៉ូម ដែលជា «ទីសម្គាល់របស់សត្វ»។ លុះដល់រឿងនេះបានលាតត្រដាងនៅចំពោះមនុស្សទាំងឡាយ ហើយគេត្រូវជ្រើសរើសរវាងបញ្ញត្តិរបស់ព្រះ និងបញ្ញត្តិរបស់មនុស្ស នោះទើបអ្នកដែលនៅតែប្រព្រឹត្តរំលងនឹងទទួល «ទីសម្គាល់របស់សត្វ»។

ការព្រមានៃទេវតាទីបី

សេចក្តីបំភិតបំភ័យដ៏ខ្លាំងក្លាបំផុតដែលបានធ្វើដល់មនុស្សជាតិ គឺមាននៅក្នុងព្រះរាជសាររបស់ទេវតាទីបី។ មនុស្សនឹងមិនត្រូវស្ថិតនៅក្នុងសេចក្តីងងឹត ស្តីពីរឿងដ៏សំខាន់នេះទេ ព្រោះសេចក្តីព្រមាននឹងត្រូវប្រទានដល់ពិភពលោកសិន មុននឹងការជំនុំជម្រះរបស់ព្រះមកដល់ ប្រយោជន៍ឱ្យមនុស្សទាំងអស់ មានឱកាសដើម្បីគេចខ្លួនបាន។ ទេវតាទីមួយ ប្រកាសដល់គ្រប់ «ទាំងសាសន៍ គ្រប់ពូជអំបូរ គ្រប់ភាសា ហើយគ្រប់ទាំងគ្រួសារដែរ»។ សេចក្តីព្រមាននៃទេវតាទីបី នឹងមិនត្រូវសុសសាយតិចជាងមុនទេ។ សេចក្តីព្រមាននោះនឹងត្រូវប្រកាសដោយសំឡេងយ៉ាងខ្លាំង ហើយនឹងទាក់

ស្មារតីនៃពិភពលោក។

ទាំងអស់គ្នានឹងត្រូវបានចែកជាពីរក្រុម៖ អ្នកដែលរក្សាបញ្ញត្តិរបស់ព្រះ ហើយមានជំនឿលើព្រះគ្រីស្ទ និងអ្នកដែលគោរពដល់សត្វ និងរូបសត្វ ហើយទទួលទីសម្គាល់របស់វា។ វិហារ និងរដ្ឋនឹងរួបរួមគ្នា ដើម្បីបង្ខំអស់ទាំងមនុស្សឱ្យទទួល «ទីសម្គាល់របស់សត្វ» តែរាស្ត្ររបស់ព្រះនឹងមិនបានទទួលទេ។ ហោរាសម្លឹងមើលទៅពួកអ្នកដែលបានឈ្នះសត្វនោះ និងរូបវា និងលេខឈ្មោះវាផង ឃើញគេឈរលើសមុទ្រកែវ ទាំងកាន់ស៊ុងរបស់ព្រះគ្រប់គ្នា។ វិវរណៈ ១៥:២។

References:

1. G. A. Townsend, *The New World Compared With the Old*, p. 462.
2. *Dublin Nation*.
3. George Elliot, *The Abiding Sabbath*, p. 184.
4. A. E. Waffle, *The Lord's Day*, pp, 186-188.
5. *Catholic Catechism of Christian Religion*.
6. Henry Tuberville, *An Abridgment of the Christian Doctrine*, p. 58.
7. Mgr. Segur, *Plain Talk About the Protestantism of Today*, p. 213.

† ក្រឹត្យវិន័យដប់ប្រការ។

អ្នកភ្លាហានសម្រាប់សេចក្តីពិត

<u>អង្គារ-១៧ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ១១

ខព្រះគម្ពីរប្រចាំថ្ងៃ: *ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះថា ចូររក្សាសេចក្តីយុត្តិធម៌ ហើយប្រព្រឹត្តតាមសេចក្តីសុចរិតចុះ ពីព្រោះសេចក្តីសង្គ្រោះរបស់អញបានមកជិតដល់ហើយ ឯសេចក្តីសុចរិតរបស់អញ ក៏រៀបនឹងសំដែងឲ្យឃើញដែរ។ អេសាយ ៥៦:១*

ការកែទម្រង់ដល់ថ្ងៃឈប់សម្រាកនៅថ្ងៃចុងក្រោយ ត្រូវបានទាយទុកនៅក្នុងគម្ពីរអេសាយថា៖ «ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចូររក្សាសេចក្តីយុត្តិធម៌ ហើយប្រព្រឹត្តតាមសេចក្តីសុចរិតចុះ ពីព្រោះសេចក្តីសង្គ្រោះរបស់អញបានមកជិតដល់ហើយ ឯសេចក្តីសុចរិតរបស់អញ ក៏រៀបនឹងសម្តែងឱ្យឃើញដែរ។ មានពរហើយមនុស្សណាដែលប្រព្រឹត្តយ៉ាងនោះ ព្រមទាំងកូនមនុស្សណាដែលកាន់សេចក្តីនេះឱ្យខ្ជាប់ខ្ជួន គឺជាអ្នកថែរក្សាថ្ងៃឈប់សម្រាកឥតបង្អាប់ ហើយរក្សាដៃមិនឱ្យធ្វើការអាក្រក់ណាឡើយ...។ ឯពួកសាសន៍ដទៃដែលភ្ជាប់ខ្លួននឹងព្រះយេហូវ៉ា ដើម្បីធ្វើការងារទ្រង់ ហើយនិងស្រឡាញ់ព្រះនាមនៃព្រះយេហូវ៉ា ព្រមទាំងធ្វើជាអ្នកបម្រើទ្រង់ គឺគ្រប់អស់អ្នកណាដែលរក្សាថ្ងៃឈប់សម្រាកឥតបង្អាប់ឡើយ ហើយកាន់ខ្ជាប់តាមសេចក្តីសញ្ញារបស់អញ នោះអញនឹងនាំគេមកឯភ្នំបរិសុទ្ធរបស់អញ ហើយឱ្យគេបានអរសប្បាយ នៅក្នុងដំណាក់របស់អញ ដែលសម្រាប់ជាទីអធិស្ឋាន»។ អេសាយ ៥៦:១,២,៦,៧។

ព្រះបន្ទូលទាំងនេះ គឺសំដៅមកជំនាន់គ្រីស្ទាន ដូចបានឃើញក្នុង

ន័យទាំងមូលនៃខនោះហើយ៖ «ព្រះអម្ចាស់យេហូវ៉ា ជាព្រះដែលប្រមូលអស់អ្នកដែលត្រូវបំបរបង់ក្នុងសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលថា អញនឹងប្រមូលមនុស្សដទៃមកជាមួយដែរ គឺជាពួកអ្នកក្រៅពីពួកអ៊ីស្រាអែលដែលបានប្រមូលមកហើយ» (ខ៨)។ ទីនេះ គឺទាយពីការប្រមូលពួកសាសន៍ដទៃដោយដំណឹងល្អ នៅពេលអ្នកបម្រើរបស់ទ្រង់ផ្សាយដល់អស់ទាំងសាសន៍អំពីដំណឹងដ៏រីករាយ។

ព្រះអម្ចាស់បង្គាប់ថា៖ «បិទត្រាបញ្ញត្តិច្បាប់នៅក្នុងពួកសិស្សរបស់អញចុះ»។ អេសាយ ៨:១៦។ ត្រាបញ្ញត្តិច្បាប់របស់ព្រះនោះ គឺត្រូវបានចែងនៅក្នុងបញ្ជីទីបួន។ បញ្ញត្តិនេះ ក្នុងអស់ទាំងបញ្ញត្តិដប់ប្រការ គឺនាំឱ្យឃើញទាំងព្រះនាម និងងារនៃព្រះដែលជាអ្នកបង្កើតច្បាប់។ នៅពេលថ្ងៃឈប់សម្រាកត្រូវបានផ្លាស់ប្តូរដោយអំណាចស្តេចសង្ឃ ត្រាក៏ត្រូវបានបកចេញពីក្រឹត្យវិន័យ។ ពួកសាវ័ករបស់ព្រះយេស៊ូវត្រូវបានហៅមក ដើម្បីឱ្យកែតម្រូវឡើងវិញ ដោយលើកតម្កើងថ្ងៃឈប់សម្រាក ទុកជាការរំលឹកដល់ព្រះអាទិករ និងទុកជាទីសម្គាល់នៃអំណាចរបស់ទ្រង់។

មានចេញបទបញ្ជាឡើងថា៖ «ចូរស្រែកឱ្យពេញបំពង់ក កុំសំចៃឡើយ ចូរបន្លឺសម្លេងឡើងដូចជាត្រែ ហើយប្រកាសប្រាប់ដល់រាស្ត្រអញពីអំពើរំលងរបស់គេ»។ អ្នកដែលទ្រង់ហៅថា «រាស្ត្រអញ» នឹងត្រូវបានកែតម្រង់ឡើងវិញចំពោះការប្រព្រឹត្តល្មើសរបស់គេ ព្រោះគេជាក្រុមដែលគិតថាខ្លួនសុចរិតក្នុងការបម្រើព្រះ។ ប៉ុន្តែការបន្ទោសដ៏ម៉ឺងម៉ាត់នៃព្រះដ៏ជាអ្នកស្វែងរកចិត្តមនុស្ស បញ្ជាក់ថាគេកំពុងជាន់ឈ្លីសិក្ខាបទរបស់ព្រះ។ អេសាយ ៥៨:១,២។

ដូច្នេះហោរាបង្ហាញបញ្ញត្តិដែលគេបានបំភ្លេចចោលថា៖ «ពួកអ្នកដែលនឹងកើតមកពីឯង គេនឹងសង់ទីចាស់ដែលខូចបង់ឡើងជាថ្មី ឯងនឹងសង់ឡើងលើជើងជញ្ជាំង ដែលមានតាំងពីច្រើនតំណមកហើយ ក៏នឹងមានឈ្មោះថាជាអ្នកជួសជុលទីបាក់បែក គឺជាអ្នករៀបចំផ្លូវទៅឯទីលំនៅឡើង

វិញ។ បើឯងឃាត់ជើងឯង មិនឱ្យបែរចេញពីថ្ងៃឈប់សម្រាក គឺមិនឱ្យធ្វើតាមអំពើចិត្តនៅថ្ងៃបរិសុទ្ធរបស់អញ បើឯងរាប់ថ្ងៃឈប់សម្រាកទុកជាទីរីករាយចិត្ត ហើយលើកថ្ងៃបរិសុទ្ធរបស់ព្រះយេហូវ៉ាទុកជាថ្ងៃគួរគោរព ព្រមទាំងប្រតិបត្តិតាមផង ឥតធ្វើតាមអំពើចិត្តរបស់ខ្លួន ឬពោលតែពាក្យរបស់ផងខ្លួនគ្រានោះឯងនឹងបានចិត្តរីករាយក្នុងព្រះយេហូវ៉ា»។ អេសាយ ៥៨:១២-១៤។

«ទីចាស់ដែលខូចបង់» គឺបានកើតឡើងដល់ក្រឹត្យវិន័យរបស់ព្រះនៅពេលថ្ងៃឈប់សម្រាកត្រូវបានប្តូរដោយអំណាចរ៉ូម។ ប៉ុន្តែ ពេលវេលាបានមកដល់សម្រាប់ជួសជុលទីខូចបង់នោះហើយ។

<u>ពុធ-១៨ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ សាស្តា ជំពូក ១២

ខព្រះគម្ពីរប្រចាំថ្ងៃ: *មានពរហើយ មនុស្សណាដែលប្រព្រឹត្តយ៉ាងនោះ ព្រមទាំងកូនមនុស្សណាដែលកាន់សេចក្តីនេះឲ្យខ្ជាប់ខ្ជួនផង គឺជាអ្នកដែលថែរក្សាថ្ងៃឈប់សំរាកឥតបង្អាប់ ហើយរក្សាដៃមិនឲ្យធ្វើការអាក្រក់ណាឡើយ ។ អេសាយ ៥៦:២*

ថ្ងៃឈប់សម្រាកពិតប្រាកដត្រូវបានកាន់តាំងតែពីដើមមក

ថ្ងៃឈប់សម្រាក ត្រូវបានរក្សាដោយលោកអ័ដាមក្នុងសួនអេដែនតាំងតែពីកាលដែលលោកមិនទាន់បាបម្ល៉េះ។ លោកបានភ្លាត់មានបាប តែបានលន់តួវិញ ហើយទោះជាត្រូវបានបណ្តេញចេញពីគេហដ្ឋានរបស់លោកក៏ដោយ ក៏លោកនៅតែរក្សាថ្ងៃនោះដែរ។ ថ្ងៃឈប់សម្រាកនេះត្រូវបានរក្សាដោយអស់ទាំងពូកអយ្យកោ ចាប់តាំងពីអេបិលដល់លោកណូអេ ដល់អាប្រាហាំ ដល់យ៉ាកុប។ នៅពេលព្រះយេហូវ៉ារំដោះអ៊ីស្រាអែល ទ្រង់បានប្រកាសក្រឹត្យវិន័យរបស់ទ្រង់ ទៅដល់ពូកមនុស្ស។

តាំងតែពីថ្ងៃនោះមកដល់បច្ចុប្បន្នកាលនេះ គេបានកាន់ថ្ងៃឈប់

សម្រាកជាប់។ ទោះបីជា «មនុស្សដែលជាតួបាប» មានជ័យជម្នះក្នុងការជាន់ឈ្លីដោយជើង ដល់ថ្ងៃបរិសុទ្ធរបស់ព្រះក៏ដោយ ក៏នៅតែមានអ្នកគោរពដ៏ស្មោះត្រង់នៅទីស្ងាត់ដែរ។ តាំងតែពីគ្រាកែទម្រង់មក មានមនុស្សខ្លះក្នុងគ្រប់តំណនៅតែគោរពដល់ថ្ងៃបរិសុទ្ធនេះ។

សេចក្តីពិតទាំងនេះ រួមទាំង «ដំណឹងល្អដ៏នៅអស់កល្បជានិច្ច» នឹងញែកឱ្យឃើញនូវក្រុមជំនុំរបស់ព្រះគ្រីស្ទ នៅពេលទ្រង់យាងមក។ «នេះហើយជា...ពួកបរិសុទ្ធដែលកាន់តាមបញ្ញត្តិរបស់ព្រះ ហើយមានសេចក្តីជំនឿដល់ព្រះយេស៊ូវ»។ វិវរណៈ ១៤:១២។

អ្នកដែលបានទទួលពន្លឺស្តីពីរោងឧបោសថ និងក្រឹត្យវិន័យរបស់ព្រះបានពេញទៅដោយអំណរ នៅពេលគេឃើញមានការស្របគ្នាក្នុងសេចក្តីពិត។ គេចង់ឱ្យពន្លឺបានចាំងជះដល់អស់ពួកគ្រីស្ទានទាំងឡាយ ប៉ុន្តែ សេចក្តីពិតដែលខុសប្លែកពីលោកីយ៍ ត្រូវបានបដិសេធដោយជនជាច្រើនដែលអះអាងថាដើរតាមព្រះគ្រីស្ទ។

នៅពេលសេចក្តីទាំងប៉ុន្មាននៃថ្ងៃឈប់សម្រាក ត្រូវបានសម្តែងឱ្យគេឃើញ មនុស្សជាច្រើននិយាយថា៖ «យើងតែងតែកាន់ថ្ងៃអាទិត្យ ជីដូនជីតាយើងបានកាន់ថ្ងៃនោះដែរ ហើយមនុស្សល្អជាច្រើនដែលកាន់ថ្ងៃនេះបានស្លាប់ទៅដោយសុខដុមរមនា។ តើក្រុមដ៏តូចមួយដែលកាន់ថ្ងៃទីប្រាំពីរអាចទទួលលទ្ធផលអ្វីខ្លះ ក្នុងពេលអស់ទាំងពិភពលោករក្សាថ្ងៃអាទិត្យនោះ?» ពួកជូវបានប្រើការវែកញែកដូចគ្នា ដើម្បីបដិសេធព្រះគ្រីស្ទ។ ដូចនឹងជំនាន់លោកលូធើរដែរ អ្នកកាន់សាសនាកាតូលិកបានវែកញែកថា អ្នកគ្រីស្ទានពិតប្រាកដបានស្លាប់ក្នុងជំនឿកាតូលិក ដូច្នេះសាសនានោះ គឺគ្រប់គ្រាន់ហើយ។ ការវែកញែករបៀបនេះ នឹងបានជារនាំងចាំងការជឿនលឿនក្នុងជំនឿជាប្រាកដ។

ជនជាច្រើនបានលើកឡើងថា ការរក្សាថ្ងៃអាទិត្យត្រូវបានជាទំនៀមទម្លាប់ទូទៅនៃព្រះវិហាររាប់សតវត្សមកហើយ។ ផ្ទុយនឹងសេចក្តីដែលបាន

ថ្លែងនេះ ថ្ងៃឈប់សម្រាក និងការរក្សាថ្ងៃនេះ គឺបុរាណជាង ថែមទាំងមានអាយុចាស់ដូចជាផែនដីដែរ ហើយត្រូវបានតាំងឡើងដោយព្រះដ៏មានព្រះជន្មពីបុរាណទៀតផង។

ក្នុងពេលដែលឥតមានទីបន្ទាល់ពីព្រះគម្ពីរនោះ មនុស្សជាច្រើនបានពោលថា៖ «ហេតុអ្វីបានជាវីរបុរសរបស់យើងពុំបានយល់ពីថ្ងៃឈប់សម្រាកនេះ? មានតិចតួចណាស់ដែលជឿដូចជាអ្នក។ អ្នកមិនអាចត្រូវ ហើយអស់ទាំងមនុស្សនៃចំណេះវិជ្ជាខ្ពង់ខ្ពស់នោះខុសទេ»។

ដើម្បីបង្ហាញថាការវែកញែកនេះខុស គឺគ្រាន់តែមើលបទគម្ពីរ និងការប្រស្រ័យទាក់ទងរបស់ព្រះយេហូវ៉ា ជាមួយរាស្ត្រទ្រង់ក្នុងគ្រប់ទាំងសម័យចុះ នោះគ្រប់គ្រាន់ហើយ។ មូលហេតុដែលព្រះពុំសូវជ្រើសរើសអ្នកមានចំណេះវិជ្ជា និងតំណែងខ្ពង់ខ្ពស់ ដើម្បីដឹកនាំក្នុងការកែទម្រង់ គឺព្រោះគេពឹងពាក់ទៅនឹងគោលជំនឿ និងប្រព័ន្ធសាសនវិទ្យារបស់គេ ហើយមិនត្រូវការចង់រៀនពីព្រះ។ ជនដែលមានចំណេះវិជ្ជាស្ទួចស្តើងពីសាលាជួនកាល ត្រូវបានហៅមកដើម្បីប្រកាសសេចក្តីពិត គឺពុំមែនដោយគេគ្មានតម្រិះនោះទេ ប៉ុន្តែដោយគេមិនពឹងលើខ្លួន តែដាក់ខ្លួនឱ្យព្រះបង្រៀនវិញ។ ការឱនលំទោន និងការស្តាប់បង្គាប់តាម ធ្វើឱ្យគេក្លាយទៅជាវីរជន។

<u>ព្រហស្បតិ៍-១៩ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ចម្រៀងសាឡូម៉ូន ជំពូក ១
ខព្រះគម្ពីរប្រចាំថ្ងៃ: *រីឯសេចក្តីជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថានឹងបានដូចសង្ឃឹម ជាសំគាល់ពីការដែលមើលមិនឃើញ។ ហេព្រើរ ១១:១*

ប្រវត្តិសាស្ត្រនៃអ៊ីស្រាអែលបុរាណ គឺជាគំរូដ៏ល្អបំផុតអំពីពិសោធន៍ពីអតីតកាលនៃក្រុមជំនុំនិរន្តរ:។ ព្រះបាននាំរាស្ត្រទ្រង់ក្នុងចលនានិរន្តរ ដូចទ្រង់បាននាំកូនចៅអ៊ីស្រាអែលចេញពីប្រទេសអេស៊ីព្ទដែរ។ ប្រសិនបើអស់អ្នកដែលបានធ្វើការដោយសាមគ្គីគ្នាក្នុងឆ្នាំ១៨៥៥ បានទទួលព្រះរាជសារ

របស់ទេវតាទីបី ហើយប្រកាសក្នុងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ នោះផែនដីនឹងត្រូវបានព្រមានរាប់ឆ្នាំមុនម្ល៉េះ ហើយព្រះគ្រីស្ទនឹងបានយាងមករំដោះយករាស្ត្រទ្រង់ទៅហើយ។

ពុំមែនជាព្រះហឫទ័យរបស់ព្រះ

ពុំមែនជាព្រះហឫទ័យរបស់ព្រះទេ ដែលជនជាតិអ៊ីស្រាអែលបាននៅវិលវល់ក្នុងទីរហោស្ថានអស់សែសិបឆ្នាំនោះ ព្រោះទ្រង់មានព្រះទ័យចង់នាំគេចេញទៅស្រុកកាណាន ហើយតាំងគេនៅទីនោះ ធ្វើជារាស្ត្របរិសុទ្ធ និងជារាស្ត្រដ៏សប្បាយរីករាយ ប៉ុន្តែ «អ្នកទាំងនោះពុំអាចនឹងចូលបានទេ ព្រោះគេមិនជឿ»។ ហេព្រើរ ៣:១៩។ ក៏ដូចគ្នាដែរ ពុំមែនជាព្រះហឫទ័យរបស់ព្រះទេ ដែលការយាងមករបស់ព្រះគ្រីស្ទត្រូវពន្យារដ៏យូរយា ហើយរាស្ត្រទ្រង់ត្រូវស្ថិតនៅក្នុងពិភពនៃបាបកម្ម និងសេចក្តីទុក្ខសោកអស់រាប់ឆ្នាំដូច្នេះ។ ការមិនជឿបានញែកគេចេញពីព្រះ។ ព្រះយេស៊ូវបានពន្យារការយាងមករបស់ទ្រង់ ដោយសារសេចក្តីមេត្តាករុណាដល់លោកីយ៍ ដើម្បីឱ្យអ្នកមានបាបបានឮសេចក្តីព្រមាន ហើយរកជម្រកជ្រកកោន មុននឹងសេចក្តីក្រោធរបស់ព្រះត្រូវបានបង្អុរចុះមក។

ឥឡូវនេះ ដូចនៅជំនាន់ពីអតីតកាលដែរ ការបង្ហាញសេចក្តីពិតនឹងបង្កសេចក្តីប្រឆាំង។ មនុស្សជាច្រើនប្រើសេចក្តីព្យាបាទ ដើម្បីជិះជាន់ចរិតលក្ខណៈ និងគោលបំណងរបស់អ្នកដែលឈរការពារជំនឿដែលគេមិននិយមជឿ។ គេបានហៅហោរាអេលីយ៉ាថាជាអ្នកបង្កវើងក្នុងអ៊ីស្រាអែល ហោរាយេរេមាថាជាអ្នកក្បត់ សាវ័កប៉ុលថាជាអ្នកធ្វើឱ្យព្រះវិហារកខ្វក់។ ចាប់ពីពេលនោះមកដល់ពេលនេះ អ្នកដែលស្មោះត្រង់ដល់សេចក្តីពិត ត្រូវបានគេថ្កោលថាជាមនុស្សបះបោរ បែកឆ្វេង ឬបែកគណៈ។

ការថ្លែងជំនឿដែលបានពោលដោយពួកបរិសុទ្ធ និងអ្នកប្តូរជីវិត និងឧទាហរណ៍នៃភាពបរិសុទ្ធ និងភាពសុចរិតដ៏មាំមួន បណ្តាលឱ្យមានទឹកចិត្តដល់អ្នកដែលឥឡូវនេះបានហៅមកធ្វើជាស្មរបន្ទាល់សម្រាប់ព្រះ។ បទ

បញ្ជាដល់អ្នកបម្រើរបស់ព្រះក្នុងពេលនេះគឺ៖ «ចូរបន្លឺសំឡេងឡើង ដូចជាត្រែ ហើយប្រកាសប្រាប់ដល់រាស្ត្រអញពីអំពើរំលងរបស់គេ និងដល់ពូជពង្សនៃយ៉ាកុប ពីអំពើបាបរបស់គេ»។ «អញបានតាំងឯងឡើងធ្វើជាអ្នកចាំយាម ដល់ពូជវង្សអ៊ីស្រាអែល ដូច្នេះចូរស្តាប់ពាក្យពីមាត់អញ ហើយប្រកាសប្រាប់គេឱ្យអញ»។ អេសាយ ៥៨:១; អេសេគាល ៣៣:៧។

ឧបសគ្គដ៏ធំក្នុងការទទួលជឿសេចក្តីពិត គឺដោយព្រោះមានការរំខាន និងការកែប្រែ។ នេះជាសេចក្តីអះអាងតែមួយគត់ទាស់នឹងសេចក្តីពិតដែលអ្នកគាំទ្រសេចក្តីពិតមិនអាចកាត់ស្រាយបាន។ ប៉ុន្តែ អ្នកដើរតាមព្រះគ្រីស្ទពិតប្រាកដ ពុំចាំឱ្យសេចក្តីពិតបានល្បីល្បាញទេ។ គេទទួលស្គាល់ឈើឆ្កាងជាមួយសាវ័កប៉ុលដោយជឿថា «សេចក្តីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឱ្យយើងខ្ញុំមានសិរីល្អដ៏នៅអស់កល្បជានិច្ចវិញ» ឯលោកម៉ូសេ «បានរាប់សេចក្តីដំនៀល ដែលគេតិះដៀលដល់ព្រះគ្រីស្ទទុកជាទ្រព្យសម្បត្តិ ប្រសើរជាងអស់ទាំងរបស់ថ្លៃវិសេសនៅស្រុកអេស៊ីព្ទ» ទៅទៀត។ កូរិនថូសទី២ ៤:១៧; ហេព្រើរ ១១:២៦។

យើងត្រូវជ្រើសរើសយកសេចក្តីត្រូវពីព្រោះវាត្រូវ ហើយទុកលទ្ធផលនៃការជ្រើសរើសនេះឱ្យព្រះចុះ។ ពិភពលោកត្រូវការជនដែលប្រកបដោយគន្លងធម៌ ជំនឿ និងសេចក្តីក្លាហាន ដើម្បីធ្វើការកែទម្រង់ដ៏ចម្បង។ តាមរយៈជនទាំងនេះ កិច្ចកែទម្រង់សម្រាប់ពេលនេះ ត្រូវតែឆ្ពោះទៅមុខ។

ជំពូកទី
២៧

ការភ្ញាក់រលឹកឡើងវិញនាសម័យបច្ចុប្បន្ន

<u>សុក្រ-២០ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ចម្រៀងសាឡូម៉ូន ជំពូក ២

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដែលព្រះបានតាំងទ្រង់ទុកជាទីសន្តោសប្រោស ដោយសារសេចក្តីជំនឿដល់ព្រះលោហិតទ្រង់ សំរាប់នឹងសំដែងឲ្យឃើញ សេចក្តីសុចរិតរបស់ព្រះ ចំពោះការដែលទ្រង់មិនប្រកាន់អំពើបាប ដែលគេប្រព្រឹត្តពីដើម ដោយទ្រង់មានព្រះហឫទ័យអត់ធ្មត់។ រ៉ូម ៣:២៥*

នៅទីណាដែលគេផ្សាយព្រះបន្ទូលរបស់ព្រះដោយស្មោះ ឃើញថាបានទទួលលទ្ធផលជាលំដាប់ បង្ហាញឱ្យឃើញពីដើមកំណើតដ៏ពិសិដ្ឋអំពីការផ្សាយនេះ។ អ្នកមានបាបបានគិតថាសតិសម្បជញ្ញៈរបស់ខ្លួនបានភ្លឺជ្រះថ្លា។ ការយល់ដឹងដ៏ច្បាស់ បានជិតជាប់នៅក្នុងចិត្តគំនិតរបស់គេ។ ពួកគេដូចជាមានភាពសុចរិតរបស់ព្រះ ហើយស្រែកឡើងថា៖ «តើអ្នកណានឹងជួយឱ្យខ្ញុំរួចពីតួសេចក្តីស្លាប់នេះបាន?» រ៉ូម ៧:២៤។ នៅពេលគេឃើញឈើឆ្កាង គេបានយល់ថា មានតែគុណសម្បត្តិរបស់ព្រះគ្រីស្ទទេ ដែលនឹងអាចលោះអំពើល្មើសរបស់គេបាន។ គេបានទទួលការលើកលែងទោសដែលបានប្រព្រឹត្តកន្លងមកហើយ ដោយសារព្រះលោហិតរបស់ព្រះគ្រីស្ទ។ រ៉ូម ៣:២៥។

ជនទាំងនេះបានជឿហើយបានទទួលបុណ្យជ្រមុជទឹក ព្រមទាំងបានងើបឡើងដើរក្នុងជីវិតថ្មី ដោយជំនឿរបស់ព្រះរាជបុត្រានៃព្រះ គេដើរតាមជំហានទ្រង់ យកចរិតលក្ខណៈរបស់ទ្រង់មកធ្វើជាគំរូរបស់ខ្លួន ព្រមទាំងធ្វើឱ្យខ្លួនបានបរិសុទ្ធដូចជាទ្រង់ដែរ។ អ្វីៗដែលគេធ្លាប់ស្អប់ ឥឡូវគេ

ស្រឡាញ់ ហើយអ្វីដែលគេធ្លាប់ស្រឡាញ់ គេស្អប់វិញ។ អ្នកមានឫកខ្ពស់ទៅជាសុភាព មនុស្សឥតប្រយោជន៍ និងកោងក្រអឺត ទៅជានឹងនហើយលែងក្អេងក្អាងវិញ។ អ្នកប្រមឹកបានក្លាយទៅជាបាត់ស្រវឹង អ្នកឥតសីលធម៌បានក្លាយជាបរិសុទ្ធ។ អ្នកគ្រីស្ទាន គេពុំរវល់នឹងការតាក់តែងខ្លួនដោយបែបខាងក្រៅ «ដូចជាក្រងសក់ ពាក់មាស ឬសំលៀកបំពាក់ផ្សេងៗឡើយ» តែ«ដោយគ្រឿងដ៏មិនចេះពុករលួយរបស់ព្រះវិញ្ញាណសម្លូត ហើយរម្យទមនោះឯងជាសេចក្តីមានតម្លៃវិសេសនៅចំពោះព្រះ»។ ពេត្រុសទី១ ៣:៣,៤។

ការភ្ញាក់រលឹកឡើងវិញ គឺបានសម្គាល់ដោយការអង្វរករយ៉ាងអស់ពីចិត្តទៅដល់អ្នកមានបាប។ លទ្ធផលគឺបានឃើញក្នុងអ្នកដែលមិនរួញរាចំពោះការលះបង់ខ្លួន ហើយបានអរសប្បាយ ព្រោះគេបានរាប់ជាសមប្រសើរ ដើម្បីរងទុក្ខសម្រាប់ព្រះគ្រីស្ទ។ មនុស្សបានឃើញការផ្លាស់ប្តូរក្នុងអ្នកដែលកាន់ជឿដល់ព្រះនាមព្រះយេស៊ូវ។ នេះជាផលក្នុងឆ្នាំមុនៗ បន្ទាប់ពីរដូវនៃការភ្ញាក់រលឹកខាងសាសនាមក។

ប៉ុន្តែការភ្ញាក់រលឹកឡើងវិញនៅសម័យបច្ចុប្បន្ននេះ បង្ហាញពីការផ្ទុយគ្នាស្រឡះ។ ជាការពិតណាស់ ដែលមានភាគច្រើនបានផ្លាស់ប្រែគំនិតហើយមានកំណើនយ៉ាងច្រើនក្នុងព្រះវិហារ។ តែទោះជាយ៉ាងណាក៏ដោយលទ្ធផលនេះមិនមែនបង្ហាញឱ្យឃើញថាមានការរីកចម្រើនខាងព្រលឹងវិញ្ញាណនោះទេ។ ពន្លឺដែលឆេះឆួលក្នុងមួយរយៈ បន្តិចទៀតនឹងរលត់ទៅវិញ។

ការភ្ញាក់រលឹកឡើងវិញដ៏ល្បី។ តែងតែរំជួលមនោសញ្ចេតនា ហើយបំប៉នសេចក្តីត្រេកត្រអាលចំពោះអ្វីដែលថ្មីហើយអស្ចារ្យ។ ដូច្នេះ អ្នកដែលទើបនឹងជឿ មានចំណង់ស្លូចស្តើងណាស់ ក្នុងការចង់ស្គាប់សេចក្តីពិតក្នុងព្រះគម្ពីរ។ បើសាសនកិច្ចនោះគ្មានអ្វី ដើម្បីបណ្តែតអារម្មណ៍ទេ នោះគេមិនរវីរវល់ឡើយ។

ចំពោះអ្នកដែលបានប្រែចិត្តគំនិតច្បាស់លាស់វិញ ការប្រស្រ័យ

ជាមួយព្រះ និងរឿងរ៉ាវស្តីពីអនន្តភាព នឹងបានជាមេរៀនដ៏ធំដល់ជីវិត។ ចុះតើការឧទ្ទិសពិតប្រាកដដល់ព្រះនៅក្នុងវិហារល្បីៗនាសព្វថ្ងៃនេះ នៅឯណាទៅ? អ្នកប្រែចិត្តទាំងឡាយ ពុំបានលះបង់ឫកឆ្មើងឆ្មៃ និងសេចក្តីត្រេកត្រអាលនៃលោកីយ៍ទេ។ គេពុំមានចិត្តចង់លះបង់ខ្លួន ដើម្បីដើរតាមព្រះយេស៊ូវដ៏ស្លូតស្រទន់ ដូចកាលដែលគេមិនប្រែចិត្តនោះដែរ។ កិរិយាថ្លៃថ្នូររបស់ព្រះ ស្ទើរតែឃ្លាតចេញពីវិហារភាគច្រើនទៅហើយ។

<u>សៅរ៍-២១ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ចម្រៀងសាឡូម៉ូន ជំពូក ៣
ខព្រះគម្ពីរប្រចាំសប្តាហ៍: *តែដោយពឹងដល់ព្រះគុណទ្រង់ នោះបានរាប់ជាសុចរិតទទេ ដោយសារសេចក្តីប្រោសលោះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ។ រ៉ូម ៣:២៤*

ទោះបីការរាថយនៃជំនឿវារាលដាលឡើងក៏ដោយ ក៏នៅមានគ្រីស្ទបរិស័ទពិតប្រាកដនៅក្នុងវិហារទាំងនេះដែរ។ មុននឹងសេចក្តីជំនុំជម្រះរបស់ព្រះមកដល់ នឹងមានការភ្ញាក់រលឹកឡើងវិញនូវភាពមានព្រះនៅក្នុងខ្លួន ដែលទើបតែកកើតឡើងក្នុងចំណោមរាស្ត្ររបស់ព្រះអម្ចាស់ ដូចពុំដែលមានឃើញតាំងតែពីជំនាន់ពួកសាវ័កមក។ ព្រះវិញ្ញាណរបស់ព្រះ នឹងត្រូវបានបង្អុរមក។ ភាគច្រើននឹងញែកខ្លួនចេញពីព្រះវិហារដែលស្រឡាញ់លោកីយ៍ជាងព្រះ និងព្រះបន្ទូលរបស់ទ្រង់។ គ្រូគង្វាល និងប្រជាជនជាច្រើន រីករាយនឹងទទួលសេចក្តីពិតដ៏អស្ចារ្យនោះ ដែលនឹងរៀបចំមនុស្ស សម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់។

សត្រូវនៃមនុស្សជាតិ ខិតខំរំខានកិច្ចការនេះខ្លាំងណាស់ ហើយមុនពេលដែលចលនានេះមកដល់ វានឹងព្យាយាមបង្ការមិនឱ្យកើតឡើងបានដោយប្រើការក្លែងបន្លំគ្រប់វិធី។ ក្នុងព្រះវិហារទាំងនោះដែលវាក្តោបក្តាប់ វានឹងធ្វើឱ្យមើលទៅដូចជាមានព្រះពររបស់ព្រះ បានចាក់បង្អុរមកដូច្នោះ។

ពួកមនុស្សនឹងសរសើរតម្កើង «ព្រះដែលកំពុងតែធ្វើការអស្ចារ្យ» តែការនោះ គឺមកពីវិញ្ញាណមួយទៀត។ ក្រោមការបន្លំនៃសាសនា សាតាំងនឹងខិតខំពង្រីកឥទ្ធិពលរបស់វាលើពិភពគ្រីស្ទាន។ មានការរំជើបរំជួលខាងផ្លូវមនោសញ្ចេតនា ហើយនិងការលាយឡំសេចក្តីពិត និងសេចក្តីមិនពិត រៀបចំជាស្រេចដើម្បីបង្វែរទៅរកផ្លូវខុស។

តែក្នុងរស្មីនៃព្រះបន្ទូលរបស់ព្រះ គឺមិនពិបាករកឬសគល់នៃចលនាទាំងនេះទេ។ ទៅទីណាដែលមានមនុស្សព្រងើយកន្តើយនឹងទីបន្ទាល់នៃព្រះគម្ពីរងាកចេញពីសេចក្តីពិតដ៏ងាយយល់ ដែលជាការសាកល្បងដល់ព្រលឹង ហើយដែលត្រូវការឱ្យមនុស្សលះបង់នូវសេចក្តីប្រាថ្នារបស់ខ្លួន និងលោកីយ៍នោះ នៅទីនោះយើងនឹងអាចដឹងជាប្រាកដថា ព្រះពររបស់ព្រះពុំបានប្រទានដល់គេឡើយ។ មានសេចក្តីចែងមកថា៖ «អ្នករាល់គ្នានឹងស្គាល់គេបាន ដោយសារផលគេបង្កើត» (ម៉ាថាយ ៧:១៦) ព្រោះជាភ័ស្តុតាងជាក់ច្បាស់ណាស់ថា ចលនាទាំងនេះមិនមែនជាកិច្ចការនៃព្រះវិញ្ញាណរបស់ព្រះទេ។

សេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះ គឺជាខែលបាំងសេចក្តីបញ្ឆោតរបស់សាតាំង។ ការមិនរវល់នឹងសេចក្តីពិតទាំងនេះ បានបើកទ្វារឱ្យសេចក្តីអាក្រក់ ដែលឥឡូវនេះមានសព្វកន្លែងក្នុងពិភពលោក។ សារៈសំខាន់នៃក្រឹត្យវិន័យរបស់ព្រះ ត្រូវបានបាត់ពីក្រសែចក្ខុស្ទើរតែទាំងស្រុងទៅហើយ។ ការយល់ខុសចំពោះក្រឹត្យវិន័យរបស់ព្រះ បាននាំឱ្យមានកំហុសក្នុងការកែប្រែចិត្ត និងការញែកចេញជាបរិសុទ្ធ ធ្វើឱ្យការគោរពព្រះទៅជាថោកទាបទៅវិញ។ នេះហើយជាសេចក្តីអាថកំបាំងនៃការខ្វះខាតព្រះវិញ្ញាណរបស់ព្រះ ក្នុងការភ្ញាក់រលឹកឡើងវិញក្នុងជំនាន់យើងនេះ។

ក្រឹត្យវិន័យខាងសេរីភាព

គ្រូសាសនាជាច្រើន ពោលថាព្រះគ្រីស្ទបានលុបក្រឹត្យវិន័យ ដោយ

ការសុគតរបស់ទ្រង់។ ខ្លះទៀត ប្រដូចក្រឹត្យវិន័យនេះទៅនឹងនឹមដ៏ធ្ងន់ធ្ងរ ហើយផ្ទុយពី «ចំណង» នៃក្រឹត្យវិន័យ គេសម្តែងថាដំណឹងល្អបានរំដោះគេពីក្រឹត្យវិន័យ ឱ្យមាន «សេរីភាព» វិញ។

ប៉ុន្តែហោរា និងសាវ័កទាំងឡាយ ពុំបានគិតពីក្រឹត្យវិន័យដ៏បរិសុទ្ធរបស់ព្រះក្នុងរបៀបដូច្នោះទេ។ ស្តេចដាវីឌបានមានបន្ទូលថា៖ «ទូលបង្គំនឹងដើរទៅដោយសេរីភាព ដ្បិតទូលបង្គំបានស្វែងរកអស់ទាំងបញ្ញត្តិទ្រង់»។ ទំនុកតំកើង ១១៩:៤៥។ សាវ័កយ៉ាកុប សំដៅទៅទសបញ្ញត្តិថាជា «ក្រឹត្យវិន័យដ៏គ្រប់លក្ខណ៍ គឺជាក្រឹត្យវិន័យខាងឯសេរីភាព» យ៉ាកុប ១:២៥។ ព្រះដ៏ជាអ្នកបើកសម្តែង បានប្រទានព្រះពរដល់អ្នកដែល «កាន់តាមក្រឹត្យវិន័យរបស់ទ្រង់ ដើម្បីឱ្យបានច្បាប់ដល់ដើមជីវិត ហើយឱ្យបានចូលទៅក្នុងក្រុងតាមទ្វារ»។ វិវរណៈ ២២:១៤។

<u>អាទិត្យ-២២ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ចម្រៀងសាឡូម៉ូន ជំពូក ៤

ខព្រះគម្ពីរប្រចាំថ្ងៃ: *គឺថា ឱព្រះនៃទូលបង្គំអើយ ទូលបង្គំមានសេចក្តីអំណរនឹងធ្វើតាមព្រះហឫទ័យទ្រង់ អើ ក្រឹត្យវិន័យរបស់ទ្រង់ក៏នៅក្នុងចិត្តទូលបង្គំ។ ទំនុកតម្កើង ៤០:៨*

ប្រសិនបើអាចផ្លាស់ប្តូរ ឬទុកក្រឹត្យវិន័យដោយឡែកបាន ព្រះគ្រីស្ទពុំបាច់សុគតដើម្បីសង្គ្រោះមនុស្សពីទោសនៃអំពើបាបទេ។ ព្រះរាជបុត្រារបស់ព្រះបានយាងមកដើម្បី «លើកតំកើងក្រឹត្យវិន័យ ហើយឱ្យមានកិត្តិសព្ទ»។ អេសាយ ៤២:២១។ ទ្រង់បានមានបន្ទូលថា៖ «កុំនឹងស្មានថាខ្ញុំមកដើម្បីនឹងលើកក្រឹត្យវិន័យ...ចោលឡើយ» «នឹងគ្មានបាំងឈើមួយ ឬក្បៀសមួយនៅក្នុងក្រឹត្យវិន័យត្រូវបាត់ឡើយ»។ ស្តីពីទ្រង់ផ្ទាល់ ទ្រង់បានថ្លែងថា៖ «ឱព្រះនៃទូលបង្គំអើយ ទូលបង្គំមានសេចក្តីអំណរនឹងធ្វើតាមព្រះហឫទ័យទ្រង់ អើ ក្រឹត្យវិន័យរបស់ទ្រង់ក៏នៅក្នុងចិត្តទូលបង្គំ»។ ម៉ាថាយ ៥:១៧,១៨;

ទំនុកតំកើង ៤០:៨។

ក្រឹត្យវិន័យរបស់ព្រះ គឺផ្លាស់ប្តូរពុំបាន ព្រោះជាការសម្តែងអំពីចរិតលក្ខណៈនៃព្រះដ៏ជាអ្នកនិពន្ធ។ ព្រះគឺជាសេចក្តីស្រឡាញ់ ហើយក្រឹត្យវិន័យរបស់ទ្រង់ ក៏ជាសេចក្តីស្រឡាញ់ដែរ។ «សេចក្តីស្រឡាញ់ ជាកិច្ចសម្រេចតាមក្រឹត្យវិន័យ»។ អ្នកសរសើរព្រះមានវាចាថា៖ «ក្រឹត្យវិន័យទ្រង់ជាសេចក្តីពិត» «ពីព្រោះសេចក្តីបង្គាប់របស់ទ្រង់ សុទ្ធតែសេចក្តីសុចរិតទាំងអស់»។ សាវ័កប៉ុលថ្លែងថា៖ «ក្រឹត្យវិន័យជាបរិសុទ្ធទេ ហើយសេចក្តីបញ្ញត្តិក៏បរិសុទ្ធ សុចរិត ល្អដែរ»។ រ៉ូម ១៣:១០; ទំនុកតំកើង ១១៩:១៤២, ១៧២; រ៉ូម ៧:១២។ ក្រឹត្យវិន័យដូចនេះ គួរតែស្ថិតស្ថេរនៅដូចជាព្រះដ៏ជាអ្នកនិពន្ធដែរ។

កិច្ចការនៃការកែប្រែ និងការធ្វើឱ្យបរិសុទ្ធ គឺដើម្បីសម្របសម្រួលមនុស្សនឹងព្រះ ដោយនាំគេឱ្យមានការស្របនឹងគន្លងធម៌នៃក្រឹត្យវិន័យរបស់ទ្រង់។ កាលពីដើម មនុស្សបានប្រកបគ្នាយ៉ាងជិតស្និទ្ធរវាងក្រឹត្យវិន័យរបស់ព្រះ។ ប៉ុន្តែ បាបកម្មបានបង្វែរគេ ពីអ្នកបង្កើតរបស់ខ្លួនទៅ។ ចិត្តរបស់គេបានធ្វើសង្គ្រាមជាមួយនឹងក្រឹត្យវិន័យរបស់ព្រះ។ «ព្រោះគំនិតខាងសាច់ឈាមនោះ រមែងទាស់ទទឹងនឹងព្រះ ដ្បិតមិនចុះចូលនឹងក្រឹត្យវិន័យរបស់ព្រះទេ ក៏ពុំអាចនឹងចុះចូលបានផង»។ រ៉ូម ៨:៧។ ប៉ុន្តែ «ព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ» ដើម្បីនឹងអាចឱ្យមនុស្សស្រុះស្រួលនឹងព្រះ ហើយបានប្រកបគ្នាឡើងវិញជាមួយអ្នកបង្កើតរបស់ខ្លួន។ ការផ្លាស់ប្តូរនេះ គឺជាកំណើតថ្មីដែលបើពុំដូច្នោះទេ «នោះមិនអាចនឹងឃើញនគរព្រះបាន» ឡើយ។ យ៉ូហាន ៣:១៦,៣។

ការដឹងថាខ្លួនមានបាប

ជំហានទីមួយក្នុងការស្រុះស្រួលនឹងព្រះ គឺការដឹងខ្លួនមានបាប។ «អំពើបាបជាការរំលងក្រឹត្យវិន័យ»។ «ក្រឹត្យវិន័យគ្រាន់តែសម្តែងឱ្យស្គាល់

អំពើបាប»។ យ៉ូហានទី១ ៣:៤; រ៉ូម ៣:២០។ ដើម្បីឱ្យឃើញកំហុសរបស់ខ្លួន អ្នកមានបាបត្រូវឆ្លុះចរិតខ្លួន ដោយកញ្ចក់របស់ព្រះ ដែលបង្ហាញភាពគ្រប់លក្ខណ៍នៃចរិតលក្ខណៈដ៏សុចរិត ហើយដែលធ្វើឱ្យគេយល់អំពីសេចក្តីខូចវៀចវេរក្នុងខ្លួនគេផង។

ក្រឹត្យវិន័យ បើកសម្តែងអំពើបាបទាំងឡាយរបស់មនុស្ស ប៉ុន្តែ ពុំបានផ្តល់ថ្នាំព្យាបាលទេ។ ក្រឹត្យវិន័យចែងមកថា សេចក្តីស្លាប់គឺជាចំណែកនៃអ្នកបំពាន។ មានតែដំណឹងល្អរបស់ព្រះគ្រីស្ទមួយប៉ុណ្ណោះ ដែលអាចដោះមនុស្សឱ្យរួចពីទោស ឬសេចក្តីកខ្វក់នៃបាបកម្មបាន។ គេត្រូវលន់តួខ្លួនដល់ព្រះ ដោយគេបានបំពានក្រឹត្យវិន័យរបស់ទ្រង់ ហើយត្រូវមានជំនឿក្នុងព្រះគ្រីស្ទ ក្នុងយញ្ញបូជាសម្រាប់លោះបាបដល់ខ្លួន។ ដូច្នេះ គេទទួល «ការដែលទ្រង់មិនប្រកាន់អំពើបាបដែលគេប្រព្រឹត្តពីដើម» (រ៉ូម ៣:២៥) ហើយក្លាយទៅជាកូនរបស់ព្រះវិញ។

តើគេឥឡូវនេះមានសេរីភាពនឹងបំពានក្រឹត្យវិន័យរបស់ព្រះឬទេ? សាវ័កប៉ុលមានប្រសាសន៍ថា៖ «តើយើងឈ្មោះថាធ្វើឱ្យក្រឹត្យវិន័យទៅជាឥតប្រយោជន៍ ដោយសេចក្តីជំនឿឬអី? ទេ មិនមែនឡើយ គឺឈ្មោះថា យើងតាំងក្រឹត្យវិន័យឱ្យកាន់តែមាំមួនឡើងវិញទេតើ។» «ធ្វើម្តេចឱ្យយើងដែលស្លាប់ខាងឯអំពើបាបហើយ បាននៅរស់ក្នុងអំពើបាបទៀតបាន?» យ៉ូហានថ្លែងថា៖ «ដ្បិតនេះហើយជាសេចក្តីស្រឡាញ់ដល់ព្រះ គឺឱ្យយើងកាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់ ឯបញ្ញត្តិរបស់ទ្រង់ នោះមិនមែនជាបន្ទុកដ៏ធ្ងន់ទេ»។ ក្នុងកំណើតថ្មី ចិត្តគំនិតគឺបាននាំមកក្នុងការស្របគ្នាជាមួយព្រះ និងមកក្នុងសេចក្តីលំអាននៃក្រឹត្យវិន័យរបស់ទ្រង់។ នៅពេលការផ្លាស់ប្តូរនេះបានកើតឡើងដល់អ្នកមានបាប នោះគេបានឆ្លងផុតពីសេចក្តីស្លាប់មកងជីវិត ផុតពីការប្រព្រឹត្តល្មើស និងការទទឹងរឹងរូស មកងការស្តាប់ឱវាទ និងសេចក្តីស្មោះត្រង់វិញ។ ជីវិតចាស់បានផុតហើយ ជីវិតថ្មីនៃការសម្រុះសម្រួលនៃជំនឿ និងសេចក្តីស្រឡាញ់ក៏បានចាប់ផ្តើម។ នៅពេលនោះ «សេ

ចក្ដីដែលក្រឹត្យវិន័យបង្គាប់មក» នឹង «បានសម្រេចក្នុងខ្លួនយើងរាល់គ្នា ដែលមិនដើរតាមសាច់ឈាម គឺដើរតាមព្រះវិញ្ញាណវិញ»។ ភាសារបស់មនុស្សនឹងបានជាដូច្នេះវិញ៖ «ឱទូលបង្គំស្រឡាញ់ក្រឹត្យវិន័យរបស់ទ្រង់ណាស់ហ្ន៎ ទូលបង្គំរំពឹងគិតពីក្រឹត្យវិន័យនោះជាដរាបរាល់ថ្ងៃ»។ រ៉ូម ៣:៣១; ៦:២; យ៉ូហានទី១ ៥:៣; រ៉ូម ៨:៤; ទំនុកតំកើង ១១៩:៩៧។

<u>ចន្ទ-២៣ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ចម្រៀងសាឡូម៉ូន ជំពូក ៥

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដ្បិតយើងខ្ញុំអាងថា មនុស្សបានរាប់ជាសុចរិតដោយសារសេចក្ដីជំនឿ គឺមិនមែនដោយការប្រព្រឹត្តតាមក្រឹត្យវិន័យទេ។ រ៉ូម ៣:២៨*

បើគ្មានក្រឹត្យវិន័យ មនុស្សពុំមានការដឹងពិតប្រាកដថាខ្លួនមានបាបទេ ហើយរមែងឥតត្រូវការការលន់តួបាបទៀតផង។ គេមិនបានដឹងថាខ្លួនត្រូវការព្រះលោហិតលោះបាបនៃព្រះគ្រីស្ទឡើយ។ គេសង្ឃឹមថាខ្លួនបានសង្គ្រោះដោយពុំបាច់ផ្លាស់ប្រែចិត្តគំនិត ឬកែទម្រង់ជីវិតឡើយ។ ដូច្នេះ ការប្រែចិត្តគំនិតសើៗឃើញថាច្រើនលើសលប់ ហើយបណ្ដាជនជាច្រើន ចូលព្រះវិហារដែលមិនដែលរួបរួមនឹងព្រះគ្រីស្ទសោះ។

អ្វីទៅជាសន្ទូបនីយកម្ម?

ទ្រឹស្ដីខុសឆ្គងនៃការញែកចេញជាបរិសុទ្ធ គឺកកើតមកពីការបដិសេធ ឬការមិនអើពើនឹងក្រឹត្យវិន័យរបស់ព្រះផងដែរ។ គេកំពុងតែនិយមជាទូទៅចំពោះទ្រឹស្ដីទាំងនេះ ដែលមានលទ្ធិមិនត្រឹមត្រូវ និងមានគ្រោះថ្នាក់ក្នុងការអនុវត្ត។

សាវ័កប៉ុលថ្លែងថា៖ «ព្រះទ្រង់សព្វព្រះហឫទ័យ ឱ្យអ្នករាល់គ្នាញែកជាបរិសុទ្ធ»។ ព្រះគម្ពីរបង្រៀនយ៉ាងច្បាស់អំពីការញែកចេញជាបរិសុទ្ធ និង

របៀបធ្វើឱ្យបានបរិសុទ្ធទៀតផង។ ព្រះអង្គសង្គ្រោះបានអធិស្ឋានឱ្យពួកសាវ័ករបស់ទ្រង់ថា៖ «សូមញែកគេចេញជាបរិសុទ្ធ ដោយសារសេចក្តីពិតរបស់ទ្រង់ ឯសេចក្តីពិតគឺព្រះបន្ទូលរបស់ទ្រង់»។ ហើយសាវ័កប៉ុលបង្រៀនថា អ្នកជឿគឺនឹងត្រូវបាន «ញែកចេញជាបរិសុទ្ធ ដោយព្រះវិញ្ញាណបរិសុទ្ធ»។ ថែស្សាឡូនីចទី១ ៤:៣; យ៉ូហាន ១៧:១៧; រ៉ូម ១៥:១៦។

តើអ្វីទៅជាកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ? ព្រះយេស៊ូវបានប្រាប់ពួកសាវ័ករបស់ទ្រង់ថា៖ «កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្តីពិតបានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលគ្រប់ទាំងសេចក្តីពិត»។ យ៉ូហាន ១៦:១៣។ ហើយអ្នកសរសើរតម្កើងព្រះពោលថា៖ «ក្រឹត្យវិន័យទ្រង់ជាសេចក្តីពិត»។ ហើយដោយព្រោះក្រឹត្យវិន័យរបស់ព្រះ «បរិសុទ្ធ សុចរិត ល្អដែរ» នោះ ចរិតលក្ខណៈដែលមានរូបរាងឡើងដោយការស្តាប់បង្គាប់តាមក្រឹត្យវិន័យ នឹងបានជាបរិសុទ្ធ។ ព្រះគ្រីស្ទគឺជាគំរូដ៏ល្អឥតខ្ចោះនៃចរិតលក្ខណៈនោះ។ ទ្រង់មានបន្ទូលថា៖ «ខ្ញុំបានកាន់តាមបញ្ញត្តិនៃព្រះវរបិតាខ្ញុំ»។ «ខ្ញុំចេះតែធ្វើការដែលគាប់ដល់ព្រះហឫទ័យទ្រង់ជាដរាប»។ យ៉ូហាន ១៥:១០; ៨:២៩។ អ្នកដើរតាមព្រះគ្រីស្ទ ត្រូវតែបានដូចជាទ្រង់ដែរ ដោយព្រះគុណរបស់ព្រះ គេត្រូវបង្កើតចរិតលក្ខណៈឱ្យស្របគ្នាជាមួយ គន្លងធម៌នៃក្រឹត្យវិន័យដ៏បរិសុទ្ធរបស់ទ្រង់។ នេះហើយជាសន្ធបនីយកម្មក្នុងព្រះគម្ពីរ។

មានតែតាមជំនឿតែប៉ុណ្ណោះ

ការនេះនឹងអាចសម្រេចបានតាមជំនឿតែមួយគត់ក្នុងព្រះគ្រីស្ទ ដោយអំណាចនៃព្រះវិញ្ញាណរបស់ព្រះដែលសណ្ឋិតនៅក្នុងខ្លួន។ អ្នកគ្រីស្ទានឹងមានស្មារតីដឹងពីអំពើបាបក្នុងខ្លួន ប៉ុន្តែ គេនឹងនៅតែជម្នះចិត្តគេជានិច្ច។ នេះជាពេលដែលត្រូវការជំនួយពីព្រះគ្រីស្ទ។ ភាពកម្សោយរបស់មនុស្សរួបរួមកម្លាំងពីស្ថានសួគ៌ ធ្វើឱ្យជំនឿឧទានឡើងថា៖ «អរព្រះគុណដល់ព្រះអង្គ ពីព្រោះទ្រង់ប្រទានឱ្យយើងរាល់គ្នាមានជ័យជម្នះ ដោយសារព្រះយេស៊ូវគ្រីស្ទ

ជាព្រះអម្ចាស់នៃយើង»។ កូរិនថូសទី១ ១៥:៥៧។

កិច្ចការនៃសន្តបនីយកម្ម គឺជាការដែលចម្រើនទៅមុខបន្តិចម្តងៗ។ នៅក្នុងស្ថានភាពនៃការកែប្រែចិត្តគំនិត ជីវិតជាគ្រីស្ទបរិស័ទទើបតែបានចាប់ផ្តើមឡើង នៅពេលអ្នកមានបាបទទួលសេចក្តីក្សេមក្សាន្តជាមួយនឹងព្រះ។ ឥឡូវនេះ គេ «ខំឱ្យបានជឿទៅមុខ ដរាបដល់ពេញខ្នាត» គេត្រូវលូតលាស់ «ដល់ខ្នាតកម្ពស់នៃសេចក្តីពោរពេញផងព្រះគ្រីស្ទ» «ទាំងរត់តម្រង់ទៅឯទី ដើម្បីឱ្យបានរង្វាន់នៃការងារដ៏ខ្ពស់របស់ព្រះ ក្នុងព្រះគ្រីស្ទយេស៊ូវ»។ ហេព្រើរ ៦:១; អេភេសូរ ៤:១៣; ភីលីព ៣:១៤។

អ្នកដែលបានពិសោធសន្តបនីយកម្មក្នុងព្រះគម្ពីរ នឹងបង្ហាញនូវភាពដាក់ខ្លួន។ គេឃើញភាពមិនសមគួររបស់ខ្លួន ដែលផ្ទុយនឹងសេចក្តីគ្រប់លក្ខណ៍នៃព្រះអនន្ត។ ហោរដានីយ៉ែល គឺជាគំរូនៃសន្តបនីយកម្មដ៏ពិត។ ជាជាងទាមទារឱ្យបានឥតខ្ចោះ និងបរិសុទ្ធ ហោរដែលមានកិត្តិយសនេះបានដាក់ខ្លួនលោកជាមួយនឹងអំពើបាបដ៏ធ្ងន់ធ្ងរនៃអ៊ីស្រាអែល នៅពេលលោកអង្វរដល់ព្រះជំនួសប្រជាជនរបស់លោក។ ដានីយ៉ែល ១០:១១; ៩:១៥,១៨,២០; ១០:៨,១១។

<u>អង្គារ-២៤ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ចម្រៀងសាឡូម៉ូន ជំពូក ៦

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដូច្នេះ តើយើងឈ្មោះថាធ្វើឲ្យក្រឹត្យវិន័យទៅជាឥតប្រយោជន៍ ដោយសេចក្តីជំនឿឬអី ទេ មិនមែនឡើយ គឺឈ្មោះថា យើងតាំងក្រឹត្យវិន័យឲ្យកាន់តែមាំមួនឡើងវិញទេតើ។ រ៉ូម ៣:៣១*

ចំពោះអ្នកដែលដើរក្នុងស្រមោលឈើឆ្កាងនៃកាល់វ៉ារី គេមិនមានការលើកតម្កើងខ្លួនឯង ក៏មិនមានអំនួតអះអាងថាខ្លួនបានរួចពីអំពើបាបដែរ។ គេមានអារម្មណ៍ក្នុងចិត្តថា គឺអំពើបាបរបស់ខ្លួនទេ ដែលបណ្តាលឱ្យមានការឈឺចាប់យ៉ាងក្រៃលែង ហើយបំបែកព្រះឱរានៃព្រះរាជបុត្រារបស់

ព្រះនោះ ហើយគំនិតនេះនឹងនាំបុគ្គលនោះឱ្យបន្ទាបខ្លួន។ អ្នកដែលរស់នៅជិតព្រះយេស៊ូវយល់យ៉ាងច្បាស់បំផុតអំពីភាពទន់ខ្សោយ និងភាពមានបាបនៃមនុស្សជាតិ ហើយសេចក្តីសង្ឃឹមរបស់គេ គឺនៅក្នុងគុណសម្បត្តិនៃព្រះអង្គសង្គ្រោះដែលបានជាប់ឆ្កាងហើយមានព្រះជន្មរស់ឡើងវិញ។

ការញែកចេញជាបរិសុទ្ធ ដែលឥឡូវនេះកំពុងតែល្បីខ្លាំងឡើងក្នុងពិភពសាសនា គឺប្រកបដោយវិញ្ញាណនៃការលើកតម្កើងខ្លួនឯង និងការមិនគោរពក្រឹត្យវិន័យរបស់ព្រះ ដែលបង្ហាញថាប្លែកស្រឡះពីព្រះគម្ពីរ។ អ្នកគាំទ្រព្រះគម្ពីរបង្រៀនថា សន្តបនីយកម្មគឺជាការងារដែលធ្វើទៅជាប់ជានិច្ច ដែលមានតែតាមរយៈ «សេចក្តីជំនឿមួយគត់» ទើបអាចទទួលភាពបរិសុទ្ធដ៏គ្រប់ខ្នាតបាន។ «គ្រាន់តែជឿទៅ» គេពោល «ហើយព្រះពរគឺជារបស់អ្នកហើយ»។ ធ្វើមើលតែអ្នកទទួល ឥតមានត្រូវការការខិតខំអ្វីសោះ។ ក្នុងពេលជាមួយគ្នា គេបដិសេធអំណាចនៃក្រឹត្យវិន័យរបស់ព្រះ ដោយពោលថាខ្លួនមិនបាច់មានកាតព្វកិច្ច ដើម្បីរក្សាបញ្ញត្តិទាំងឡាយឡើយ។ តើនឹងអាចបរិសុទ្ធដោយពុំបាច់សម្របនឹងគន្លងធម៌ ដែលបង្ហាញពីនិស្ស័យ និងព្រះហឫទ័យរបស់ព្រះបានឬទេ?

ទីបន្ទាល់នៃព្រះបន្ទូលរបស់ព្រះ គឺប្រឆាំងនឹងគោលលទ្ធិដ៏គ្រោះថ្នាក់នៃជំនឿដែលគ្មានការប្រព្រឹត្តនេះ។ ការដែលទាមទារសេចក្តីសព្វព្រះទ័យពីស្ថានសួគ៌ ដោយមិនបាច់សម្របទៅតាមលក្ខខណ្ឌនៃសេចក្តីមេត្តាករុណានោះ គឺមិនមែនជាសេចក្តីជំនឿទេ តែជាសេចក្តីឥតកោតក្រែងវិញ។ សូមអាន យ៉ាកុប ២:១៤-២៤។

កុំឱ្យអ្នកណាម្នាក់បញ្ឆោតខ្លួនឯងថា ខ្លួនអាចបរិសុទ្ធបាន ដោយរំលោភសេចក្តីតម្រូវណាមួយរបស់ព្រះ ដោយទំនើងចិត្តនោះឡើយ។ ការធ្វើបាបដែលខ្លួនដឹងថាជាអំពើបាប បណ្តាលឱ្យសំឡេងធ្វើទីបន្ទាល់របស់ព្រះវិញ្ញាណស្ងប់ស្ងាត់ទៅ ហើយញែកព្រលឹងចេញពីព្រះទៀតផង។ ទោះបើលោកយ៉ូហានសង្កត់យ៉ាងធ្ងន់ទៅលើសេចក្តីស្រឡាញ់ក្តី លោកឥតអល់

អែកនឹងបើកសម្តែងចរិតលក្ខណៈពិតប្រាកដនៃមនុស្សមួយចំនួន ដែលអះអាងថាខ្លួនបានញែកចេញជាបរិសុទ្ធ ក្នុងពេលដែលគេរស់នៅក្នុងការបំពានក្រឹត្យវិន័យរបស់ព្រះឡើយ។ «អ្នកណាដែលថាបានស្គាល់ទ្រង់ តែមិនកាន់តាមបញ្ញត្តិព្រះបន្ទូលទ្រង់ទេ អ្នកនោះឈ្មោះថាជាអ្នកកុហក ហើយសេចក្តីពិតមិននៅក្នុងអ្នកនោះឡើយ។ តែអ្នកណាដែលកាន់តាមព្រះបន្ទូលទ្រង់វិញ នោះប្រាកដជាសេចក្តីស្រឡាញ់នៃព្រះបានពេញខ្នាត»។ យ៉ូហានទី១ ២:៤,៥។ នេះគឺជាការសាកល្បងនៃការអះអាងរបស់មនុស្ស។ ប្រសិនបើមនុស្សចាត់ទុកថាសិក្ខាបទរបស់ព្រះ មានសារៈសំខាន់តិចតួច ហើយនិងធូរស្រាលនោះ ប្រសិនបើគេ «រំលងបទណាមួយ សូម្បីយ៉ាងតូចបំផុតក្នុងបញ្ញត្តិទាំងនេះ ហើយបង្រៀនមនុស្សឱ្យធ្វើដូច្នោះដែរ» (ម៉ាថាយ ៥:១៨) នោះយើងអាចដឹងថាសេចក្តីអះអាងរបស់គេ គឺគ្មានគ្រឹះតាងទេ។

ការអះអាងថាគ្មានបាបសោះ គឺជាភ័ស្តុតាងថា អ្នកដែលអះអាងនោះ គឺនៅឆ្ងាយពីភាពបរិសុទ្ធណាស់។ គេឥតបានយល់ច្បាស់លាស់ អំពីភាពឥតខ្ចោះ និងភាពបរិសុទ្ធដ៏គ្មានទីបំផុតរបស់ព្រះ និងភាពអសោច និងសេចក្តីអាក្រក់នៃអំពើបាបទេ។ ចម្ងាយឃ្លាតគ្នារវាងគេហើយនិងព្រះធំប៉ុណ្ណា គេក៏ឃើញខ្លួនគេមានសេចក្តីសុចរិតប៉ុណ្ណោះដែរ។

សន្ទុបនីយកម្មនៃព្រះគម្ពីរ

ការញែកចេញជាបរិសុទ្ធ ឱ្យក្រសោបរូបអង្គទាំងមូល វិញ្ញាណ ព្រលឹង និងរាងកាយ។ សូមអានថែស្សាឡូនីចទី១ ៥:២៣។ ព្រះទ្រង់បានហៅគ្រីស្ទានទាំងឡាយឱ្យបង្ហាញខ្លួនគេ «ជាយញ្ញបូជារស់ ហើយបរិសុទ្ធដែលគាប់ព្រះហឫទ័យដល់ព្រះ» អង្គ។ រ៉ូម ១២:១។ គ្រប់ទាំងការអនុវត្តណាដែលធ្វើឱ្យខ្សោយកម្លាំងខាងសាច់ឈាម ឬខាងចិត្តគំនិត គឺធ្វើឱ្យមនុស្សខ្វះសមត្ថភាពនឹងប្រកបកិច្ចការសម្រាប់ព្រះអាទិករបស់ខ្លួនហើយ។ អ្នកដែលស្រឡាញ់ព្រះដ៏អស់ពីចិត្ត នឹងខំស្វះស្វែងនាំគ្រប់ទាំងអំណាចនៃរូបអង្គ

របស់ខ្លួន ឱ្យស្របគ្នាជាមួយនឹងក្រឹត្យវិន័យដែលលើកស្ទួយគេឱ្យមាន សមត្ថភាព ដើម្បីធ្វើតាមព្រះហឫទ័យរបស់ទ្រង់។ គេនឹងមិនធ្វើឱ្យខ្លួនខ្សោយ ឬធ្វើឱ្យខូចតង្វាយដែលថ្វាយដល់ព្រះវរបិតានៃស្ថានសួគ៌ ដោយការមិនប្រមាណអាហារ ឬការត្រេកត្រអាលឡើយ។

គ្រប់ទាំងសេចក្តីបំប៉ងដែលមានបាប រមែងធ្វើឱ្យការឈ្វេងយល់ខាងចិត្តគំនិត និងវិញ្ញាណស្ពឹកហើយស្លាប់ផង។ ព្រះបន្ទូល ឬព្រះវិញ្ញាណរបស់ព្រះ អាចបណ្តាលចិត្តគេបានតិចតួចណាស់។ «ដូច្នេះ ពួកស្ងួនភ្ងាអើយ ...ត្រូវឱ្យយើងរាល់គ្នាសម្អាតខ្លួនយើង ពីគ្រប់ទាំងសេចក្តីដែលប្រឡាក់ខាងសាច់ឈាមចេញ ហើយខាងព្រលឹងវិញ្ញាណផង ព្រមទាំងបង្ហើយសេចក្តីបរិសុទ្ធ ដោយនូវសេចក្តីកោតខ្លាចដល់ព្រះ»។ កូរិនថូសទី២ ៧:១។

<u>ពុធ-២៥ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ចម្រៀងសាឡូម៉ូន ជំពូក ៧

ខព្រះគម្ពីរប្រចាំថ្ងៃ: *តើគម្ពីរថាដូចម្តេច គម្ពីរថា «អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្តីជំនឿនោះ បានរាប់ជាសេចក្តីសុចរិតដល់លោក»។*
រ៉ូម ៤:៣

តើមានអ្នកចាត់ខ្លួនថាជាជនគ្រីស្ទានប៉ុន្មាននាក់ ដែលកំពុងតែបន្ទាបភាពជាមនុស្សដែលមានលក្ខណៈរបស់ព្រះ ដោយការល្មោភអាហារ ដោយធឹកគ្រឿងស្រវឹង ដោយការសប្បាយភ្លើតភ្លើនដ៏ពុំគួរគប្បីនោះ។ ព្រះវិហារលើកទ្រសេចក្តីអាក្រក់ទាំងនេះជាញឹកញយណាស់ ដើម្បីឱ្យឃ្លាំងទ្រព្យសម្បត្តិដែលខ្វះខាតរបស់ខ្លួនបានពោរពេញឡើង ព្រោះគេខ្វះសេចក្តីស្រឡាញ់ដល់ព្រះយេស៊ូវ។ ប្រសិនបើព្រះយេស៊ូវនឹងយាងចូលក្នុងព្រះវិហារទាំងឡាយនៅសព្វថ្ងៃនេះ ហើយឃើញការទទួលទានអាហារដែលប្រព្រឹត្តឡើងក្នុងឈ្មោះនៃសាសនា តើទ្រង់មិនដេញអ្នកប្រមាថទាំងនោះចេញ ដូចជាទ្រង់បានដេញអ្នកលក់ដូរក្នុងព្រះវិហារទេឬ?

«តើមិនដឹងទេឬអីថា រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ។ ដ្បិតព្រះទ្រង់បានចេញថ្លៃលោះអ្នករាល់គ្នាហើយ ដូច្នេះចូរតម្កើងព្រះនៅក្នុងរូបកាយ ហើយក្នុងវិញ្ញាណនៃអ្នករាល់គ្នា ដែលជារបស់ផងទ្រង់ចុះ»។ កូរិនថូសទី១ ៦:១៩,២០។ អ្នកដែលមានរូបកាយជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធនឹងមិនត្រូវធ្វើជាខ្ញុំបម្រើនៃទម្លាប់ដ៏អាក្រក់ហិនហោចឡើយ។ អំណាចរបស់គេទាំងប៉ុន្មានគឺជារបស់ព្រះគ្រីស្ទ។ ទ្រព្យសម្បត្តិរបស់គេគឺជារបស់ព្រះអម្ចាស់។ តើអាចចាយវាយខ្ជះខ្ជាយនូវទ្រព្យដែលជាបញ្ញើម្តេចបាន?

អ្នកដែលចាត់ខ្លួនថាជាជនគ្រីស្ទាន ក្នុងមួយឆ្នាំៗ ចំណាយទៅលើការបំប៉នសេចក្តីត្រេកត្រអាលអស់មួយចំនួនដ៏ច្រើនក្រៃលែង។ គេបានប្លន់តង្វាយភាគដប់ និងតង្វាយផ្សេងៗពីព្រះ នៅពេលដែលគេចំណាយទៅលើសេចក្តីប្រាថ្នារបស់ខ្លួន ជាជាងបរិច្ចាគឱ្យអ្នកក្រីក្រ ដើម្បីបន្ធូរសម្រាលគេ ឬជាជាងគាំទ្រដំណឹងល្អ។ ប្រសិនបើអស់អ្នកដែលចាត់ខ្លួនថាជឿព្រះគ្រីស្ទបានញែកចេញជាបរិសុទ្ធពិតប្រាកដនោះ ធនធានរបស់គេនឹងបានត្រឡប់ទៅជាទ្រព្យសម្បត្តិរបស់ព្រះ ជាជាងចាយវាយទៅ លើការបំប៉នសេចក្តីត្រេកត្រអាលដែលឥតប្រយោជន៍ ហើយគ្រោះថ្នាក់ផង។ អ្នកគ្រីស្ទានត្រូវធ្វើជា គំរូនៃការប្រមាណ និងការលះបង់ខ្លួន នោះគេនឹងបានជាពន្លឺនៃលោកីយ៍។

«សេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម នឹងសេចក្តីប៉ងប្រាថ្នារបស់ភ្នែក ហើយសេចក្តីអំនួតរបស់ជីវិត» (យ៉ូហានទី១ ២:១៦) គ្រប់គ្រងមនុស្សទាំងពួង។ ប៉ុន្តែ គ្រីស្ទបរិស័ទ ត្រូវបានហៅមកឱ្យបានបរិសុទ្ធជាង។ «ព្រះអម្ចាស់ទ្រង់មានបន្ទូលថា៖ ចូរចេញពីកណ្តាលពួកគេទៅ ហើយញែកខ្លួនទៅដោយឡែក កុំឱ្យពាល់របស់ស្មោកគ្រោកឡើយ»។ ចំពោះអ្នកណាដែលសម្របទៅនឹងលក្ខខណ្ឌសេចក្តីសន្យារបស់ព្រះគឺ៖ «អញនឹងធ្វើជាឪពុកដល់ឯងរាល់

គ្នា ហើយឯងរាល់គ្នានឹងធ្វើជាកូនប្រុសស្រីដល់អញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏មានព្រះចេស្តាបំផុត»។ កូរិនថូសទី២ ៦:១៧,១៨។

គ្រប់ទាំងជំហាននៃជំនឿ និងការស្តាប់បង្គាប់ នាំព្រលឹងឱ្យចូលទៅជិតព្រះដ៏ជាពន្លឺនៃលោកីយ៍។ កាំរស្មីដ៏ភ្លឺព្រោងព្រាតនៃព្រះដ៏ជាព្រះសុរិយានៃសេចក្តីសុចរិត ចាំងមកលើអ្នកបម្រើព្រះ ហើយគេត្រូវជះរស្មីមកវិញ។ ផ្កាយទាំងឡាយប្រាប់យើងថា មានពន្លឺមួយនៅស្ថានសួគ៌ ដែលបំភ្លឺវាដោយសិរីល្អ ដូច្នេះអ្នកគ្រីស្ទានត្រូវធ្វើឱ្យគេឃើញថា មានព្រះមួយអង្គគង់លើបល្ល័ង្ក ដែលមានចរិតលក្ខណៈគួរសរសើរ និងគួរគ្រាប់តាម។ ភាពបរិសុទ្ធនៃចរិតលក្ខណៈរបស់ទ្រង់ នឹងត្រូវបានឃើញក្នុងអ្នកធ្វើទីបន្ទាល់របស់ទ្រង់។

តាមរយៈគុណសម្បត្តិនៃព្រះគ្រីស្ទ យើងមានផ្លូវចូលទៅឯបល្ល័ង្កនៃឫទ្ធិអំណាចដ៏គ្មានទីបំផុត។ «ឯព្រះអង្គដែលមិនសំចៃទុកនូវព្រះរាជបុត្រាទ្រង់ គឺបានបញ្ជូនទ្រង់ទៅជំនួសយើងរាល់គ្នា នោះតើមានទំនងអ្វីឱ្យទ្រង់មិនប្រទានគ្រប់ទាំងអស់មកយើង ជាមួយនឹងព្រះរាជបុត្រាទ្រង់នោះផង?» ព្រះយេស៊ូវមានបន្ទូលថា៖ «បើអ្នករាល់គ្នាដែលជាមនុស្សអាក្រក់ អ្នកចេះឱ្យរបស់ល្អទៅកូនយ៉ាងដូច្នេះ នោះចំណង់បើព្រះវរបិតាដែលគង់នៅស្ថានសួគ៌ តើទ្រង់នឹងប្រទានព្រះវិញ្ញាណបរិសុទ្ធមកអស់អ្នកដែលសូម ជាជាងអម្បាលម៉ានទៅទៀត?» «បើអ្នករាល់គ្នានឹងសូមអ្វីដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនឹងសម្រេចឱ្យ»។ «ចូរសូមចុះ នោះអ្នករាល់គ្នានឹងបាន ដើម្បីឱ្យសម្រេចអំណររបស់អ្នករាល់គ្នាបានពោរពេញពិត»។ រ៉ូម ៨:៣២; លូកា ១១:១៣; យ៉ូហាន ១៤:១៤; ១៦:២៤។

មនុស្សគ្រប់រូបមានបុព្វសិទ្ធដើម្បីរស់នៅ ប្រយោជន៍ឱ្យព្រះសព្វព្រះទ័យ ហើយប្រទានព្រះពរដល់ខ្លួន។ ព្រះហឫទ័យនៃព្រះវរបិតានៃស្ថានសួគ៌របស់យើង ពុំចង់ឱ្យយើងស្ថិតនៅក្រោមទោសពៀរ និងភាពងងឹតឡើយ។ គឺគ្មានភ័ស្តុតាងនៃការដាក់ខ្លួនពិតប្រាកដទេ ក្នុងការប្រព្រឹត្តទៅដោយឱនក្បាលចុះ តែចិត្តគិតតែពីខ្លួនឯងនោះ។ យើងអាចទៅឯព្រះយេស៊ូវ ហើយ

បានជ្រះស្អាត និងឈរនៅចំពោះក្រឹត្យវិន័យដោយគ្មានការអាម៉ាស់មុខ និងការស្តាយក្រោយឡើយ។

តាមរយៈព្រះយេស៊ូវ កូនចៅទាំងឡាយរបស់លោកអ័ដាមដែលមានបាប បានក្លាយទៅជា «កូនព្រះ»។ «ទ្រង់មិនខ្មាស់នឹងហៅគេជាបងប្អូនទេ»។ ជីវិតអ្នកគ្រីស្ទាន គួរតែប្រកបដោយជំនឿ សេចក្តីជោគជ័យ និងអំណរក្នុងព្រះ។ «ពីព្រោះ *សេចក្តីអំណរ* នៃព្រះយេហូវ៉ា ជាកម្លាំងនៃអ្នករាល់គ្នា»។ «ចូរអរសប្បាយជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណក្នុងគ្រប់ការទាំងអស់ ពីព្រោះព្រះទ្រង់សព្វព្រះទ័យឱ្យអ្នករាល់គ្នាធ្វើយ៉ាងដូច្នោះ ដោយនូវព្រះគ្រីស្ទយេស៊ូវ»។ ហេព្រើរ ២:១១; នេហេមា ៨:១០; ថែស្សាឡូនីចទី១ ៥:១៦-១៨។

នេះហើយជាផលផ្លែនៃការកែប្រែចិត្ត និងសន្លប់នីយកម្មក្នុងព្រះគម្ពីរ ហើយដោយព្រោះគន្លងធម៌ដ៏ធំធេងនៃសេចក្តីសុចរិតដែលមានចែងក្នុងក្រឹត្យវិន័យ ត្រូវបានគេគោរពដោយសើៗដូច្នោះ បានជាកម្រឃើញផលផ្លែទាំងនេះ។ ដូច្នេះហើយ បានជាមានការបើកសម្តែងយ៉ាងតិចតួចណាស់ អំពីកិច្ចការដ៏មានខ្លឹមសាររបស់ព្រះវិញ្ញាណ ខុសពីការរលឹកឡើងវិញនៅអតីតកាល។

យើងអាចផ្លាស់ប្តូរបាន ដោយការសម្លឹងមើល។ នៅពេលសិក្ខាបទបរិសុទ្ធទាំងនោះ ដែលព្រះទ្រង់បានបើកសម្តែងដល់មនុស្ស អំពីភាពគ្រប់ខ្នាត និងភាពបរិសុទ្ធនៃចរិតលក្ខណៈរបស់ព្រះអង្គត្រូវបានគេលែងអើពើទៅ ហើយគំនិតរបស់ពួកបណ្តាជន ត្រូវបានទាក់ទាញទៅរកសេចក្តីបង្រៀន និងទ្រឹស្តីរបស់មនុស្ស នោះក៏មានការអន់ថយក្នុងការគោរពព្រះក្នុងព្រះវិហារដែរ។ ទាល់តែកែតម្រូវក្រឹត្យវិន័យរបស់ព្រះឱ្យបានត្រឹមត្រូវវិញ ទើបអាចមានជំនឿដូចកាលពីដើម ហើយនិងភាពមានព្រះក្នុងខ្លួនឡើងវិញក្នុងចំណោមរាស្ត្រដែលដើរតាមទ្រង់។

នៅចំពោះបញ្ជីជីវិត

ព្រហស្បតិ៍-២៦ សីហា អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ ចម្រៀងសាឡូម៉ូន ជំពូក ៨

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដូចជាហ្លួងដាវីឌបានសំដែងពីសណ្ដានដ៏មានពរនៃមនុស្ស ដែលព្រះទ្រង់រាប់ជាសុចរិតក្រៅពីការប្រព្រឹត្តថា «មានពរហើយ អ្នកណាដែលការទទឹងច្បាប់របស់ខ្លួនបានអត់ទោសឲ្យ និងបាបខ្លួនបានគ្របបាំង មានពរហើយ មនុស្សណាដែលព្រះអម្ចាស់មិនរាប់ជាមានបាបឡើយ»។ រ៉ូម ៤:៦-៨*

«ខ្ញុំក៏គន់មើល រហូតទាល់តែមានគេយកបល្ល័ង្កមកតាំង ហើយព្រះដ៏មានព្រះជន្មពីចាស់បុរាណទ្រង់ក៏គង់លើ ព្រះពស្ត្រទ្រង់សស្គុសដូចហិម: ហើយព្រះកេសនៅព្រះសិរទ្រង់ក៏សដូចរោមចៀមយ៉ាងស្អាត ឯបល្ល័ង្កទ្រង់នោះសុទ្ធតែជាអណ្តាតភ្លើង ហើយកង់នៃបល្ល័ង្កនោះក៏ជាភ្លើងដែរ។ មានដូចជាភ្លើងហូរចេញពីចំពោះទ្រង់មក មានទាំងពាន់ៗដែលគោរពដល់ទ្រង់ ហើយទាំងម៉ឺនទាំងសែនក៏ឈរនៅចំពោះទ្រង់ នោះការវិនិច្ឆ័យបានរៀបចំជាស្រេច ឯបញ្ជីទាំងប៉ុន្មានបានបើកឡើងហើយ»។ ដានីយ៉ែល ៧:៩,១០។

ការទាំងនេះបានប្រទានមកឱ្យដានីយ៉ែលបានឃើញ នូវថ្ងៃដ៏ធំដែលជីវិតទាំងឡាយរបស់មនុស្សកំពុងស្ថិតនៅចំពោះមុខចៅក្រមនៃផែនដីទាំងមូល។ ព្រះដ៏មានព្រះជន្មពីចាស់បុរាណ គឺជាព្រះវរបិតា។ ទ្រង់ជាប្រភពនៃសត្វមានជីវិតទាំងអស់ ជាប្រភពនៃច្បាប់ទាំងអស់ ជាអ្នកគ្រប់គ្រងក្នុងទីជំនុំជម្រះ ដោយមានពួកទេវតាបរិសុទ្ធជាមន្ត្រី និងជាស្មរបន្ទាល់ចូលរួមផង។

«ក៏ឃើញមានមួយអង្គដូចជាកូនមនុស្ស ទ្រង់យាងមកក្នុងពពកឰដ៏

អាកាស ទ្រង់យាងមកឯព្រះដ៏មានព្រះជន្មពីចាស់បុរាណនោះ ហើយមាន
គេនាំចូលទៅចំពោះព្រះអង្គ។ នោះបានប្រគល់ឱ្យទ្រង់មានអំណាច
គ្រប់គ្រង និងសិរីល្អ ព្រមទាំងឱ្យមានរាជ្យផង ដើម្បីឱ្យបណ្តាជនទាំងឡាយ
សាសន៍ដទៃ និងមនុស្សគ្រប់ភាសា បានគោរពដល់ទ្រង់៖ ឯអំណាចគ្រប់
គ្រងរបស់ទ្រង់ នោះក៏ស្ថិតស្ថេរនៅអស់កល្ប ឥតដែលកន្លងបាត់ឡើយ»។
ដានីយ៉ែល ៧:១៣,១៤។

ការពិពណ៌នាអំពីដំណើរយាងមករបស់ព្រះគ្រីស្ទនៅត្រង់នេះ ពុំមែន
ជាការយាងមកជាលើកទីពីររបស់ទ្រង់មកកាន់ផែនដីទេ។ គឺទ្រង់យាងទៅ
កាន់ព្រះដ៏មានព្រះជន្មពីចាស់បុរាណ នៅស្ថានសួគ៌ ដើម្បីគ្រងរាជ្យដែល
នឹងត្រូវប្រគល់ថ្វាយទ្រង់ នៅទីបញ្ចប់នៃការងារជាស្ថានមេត្រី។ ការយាង
មកនេះ ពុំមែនជាការយាងមកនៅលើកទីពីរមកកាន់ផែនដីឡើយ គឺជាការ
យាងនៅទីបញ្ចប់នៃកំណត់២៣០០ថ្ងៃនាឆ្នាំ១៨៤៤។ សម្តេចសង្ឃជាន់ខ្ពស់
របស់យើង បានយាងចូលទីបរិសុទ្ធបំផុតនៃរោងឧបោសថ ដើម្បីទទួល
ការងារជាសង្ឃ ជាលើកចុងក្រោយបង្អស់ជំនួសមនុស្ស។

នៅក្នុងយញ្ញកិច្ចដែលជានិមិត្តរូបនោះ មានតែអ្នកដែលអំពើបាបរបស់
ខ្លួនត្រូវបានផ្ទេរទៅកាន់រោងឧបោសថទេ ទើបមានចំណែកនៅក្នុងថ្ងៃបុណ្យ
ធួននឹងបាប។ ដូច្នេះ នៅក្នុងការប្រោសលោះបាបដ៏ធំ ហើយនិងនៅគ្រាជំនុំ
ជម្រះដ៏ឱឡារិកដោយពិនិត្យអង្កេតជាចុងក្រោយបង្អស់នោះករណីដែលត្រូវ
ពិចារណាមានតែករណីរបស់អស់អ្នកដែលចាត់ទុកខ្លួនថាជាបណ្តាជនរបស់
ព្រះតែប៉ុណ្ណោះ។ ការជំនុំជម្រះមនុស្សអាក្រក់ គឺជាកិច្ចការផ្សេងគ្នាដែលធ្វើ
នៅពេលក្រោយមកទៀត។ «ដ្បិតសេចក្តីជំនុំជម្រះត្រូវចាប់ផ្តើមពីដំណាក់
នៃព្រះ»។ ពេត្រុសទី១ ៤:១៧។

បញ្ជីកំណត់ហេតុនៅស្ថានសួគ៌ ត្រូវអនុម័តសេចក្តីសម្រេចនៃការ
ជំនុំជម្រះ។ បញ្ជីជីវិតមានឈ្មោះរបស់អ្នកទាំងអស់ដែលធ្លាប់បានចូលទៅ
ក្នុងពិធីថ្វាយបង្គំព្រះ។ ព្រះយេស៊ូវមានបន្ទូលទៅពួកសិស្សថា៖ «ត្រូវឱ្យ

រីករាយ ដោយព្រោះឈ្មោះអ្នករាល់គ្នាបានកត់ទុកនៅស្ថានសួគ៌»។ សាវ័ក ប៉ុលមានប្រសាសន៍អំពីអ្នកធ្វើការជាមួយគាត់ «ដែលមានឈ្មោះកត់ទុកក្នុង បញ្ជីជីវិតដែរ»។ ភីលីព ៤:៣។ ដានីយ៉ែលបញ្ជាក់ថារាស្ត្ររបស់ព្រះ នឹងត្រូវ បានប្រោសឱ្យរួច «គឺអស់អ្នកណាដែលមានកត់ទុកនៅក្នុងបញ្ជី»។ អ្នកបើក សម្តែងក៏បានចែងថា អ្នកដែលអាចចូលទីក្រុងនោះ គឺបានតែអ្នកណា «ដែល មានឈ្មោះកត់ទុកក្នុងបញ្ជីជីវិតរបស់កូនចៀមតែប៉ុណ្ណោះ»។ លូកា ១០:២០; ភីលីព ៤:៣; ដានីយ៉ែល ១២:១; វិវរណៈ ២១:២៧។

នៅក្នុង «សៀវភៅរំឭក» មានកត់ត្រានូវអំពើល្អរបស់ «ពួកអ្នកដែល កោតខ្លាចដល់ទ្រង់ និងពួកអ្នកដែលនឹកដល់ព្រះនាមព្រះអង្គ»។ គ្រប់ទាំង សេចក្តីល្បួងដែលបានទប់ទល់ គ្រប់ទាំងអំពើអាក្រក់ដែលបានឈ្នះ គ្រប់ ទាំងពាក្យអាណិតអាសូរដែលបានបន្លឺឡើង គ្រប់ទាំងកិច្ចពលីកម្ម និងគ្រប់ ទាំងទុក្ខព្រួយដែលបានទ្រាំទ្រដើម្បីព្រះគ្រីស្ទ សុទ្ធតែបានកត់ទុកទាំងអស់។ «ទ្រង់រាប់អស់ទាំងការរសាត់អណ្តែតរបស់ទូលបង្គំ៖ សូមទ្រង់ដាក់អស់ទាំង ទឹកភ្នែករបស់ទូលបង្គំ ទុកនៅក្នុងដបនៃទ្រង់៖ តើមិនកត់ទុកក្នុងបញ្ជីទ្រង់ទេ ឬអី?» ម៉ាឡាគី ៣:១៦; ទំនុកតំកើង ៥៦:៨។

<u>សុក្រ-២៧ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដ្បិតសេចក្តីសន្យា ដល់លោកអ័ប្រាហាំ និងពូជលោក ឲ្យបានលោកីយ៍ជាមរដក នោះមិនមែនដោយសារក្រឹត្យវិន័យទេ គឺ ដោយសារសេចក្តីសុចរិតដែលមកដោយសេចក្តីជំនឿវិញ។ រ៉ូម ៤:១៣*

អំពើលាក់កំបាំង

មានការកត់ត្រាផងដែរ ចំពោះអំពើបាបរបស់មនុស្ស។ «ពីព្រោះព្រះ ទ្រង់នឹងនាំគ្រប់ការទាំងអស់មកដើម្បីជំនុំជម្រះ ព្រមទាំងអ្វីៗដែលលាក់ កំបាំងផង ទោះល្អ ឬអាក្រក់ក្តី»។ «អស់ទាំងហេតុនៃពាក្យឥតប្រយោជន៍

ដែលមនុស្សបាននិយាយ នោះនឹងត្រូវរៀបរាប់ប្រាប់នៅថ្ងៃជំនុំជម្រះ»។ «ដ្បិតអ្នកនឹងបានរាប់ជាសុចរិត ដោយសារពាក្យសម្តីរបស់ខ្លួន ឬនឹងត្រូវទោសក៏ដោយសារពាក្យសម្តីនោះដែរ»។ អំពើអាថិកំបាំងនឹងលេចឡើងនៅលើបញ្ជី ដ្បិតព្រះ «ទ្រង់នឹងយកអស់ទាំងអំពើលាក់កំបាំងដែលធ្វើនៅទីងងឹត មកដាក់នៅឯទីភ្លឺវិញ ហើយនិងបើកសម្តែងឱ្យឃើញអស់ទាំងគំនិតក្នុងចិត្តរបស់មនុស្សផង»។ សាស្តា ១២:១៤; ម៉ាថាយ ១២:៣៦,៣៧; កូរិនថូសទី១ ៤:៥។ នៅពីមុខឈ្មោះនីមួយៗក្នុងសៀវភៅនៃស្ថានសួគ៌ មានចុះអស់ទាំងពាក្យខុសឆ្គង អស់ទាំងអំពើអាត្មានិយមអស់ទាំងភារកិច្ចដែលពុំបានបំពេញ ហើយនិងអស់ទាំងអំពើបាបដែលបានលាក់កំបាំងផង។ ការព្រមានដែលបានបញ្ជូនមកពីស្ថានសួគ៌ និងការមិនរវល់នឹងសេចក្តីបន្ទោស ការចំណាយពេលឥតប្រយោជន៍ ការបញ្ចេញឥទ្ធិពលដ៏ជ្រាលជ្រៅចំពោះអំពើល្អ ឬអាក្រក់ ទាំងអស់សុទ្ធតែត្រូវបានកត់ត្រាទុកដោយទេវតាដ៏ជាស្មៀន។

ខ្លាតនៃការជំនុំជម្រះ

ក្រឹត្យវិន័យរបស់ព្រះគឺជាខ្លាតនៅក្នុងការជំនុំជម្រះ។ «ដូច្នេះចូរកោតខ្លាចដល់ព្រះហើយកាន់តាមបញ្ញត្តិទ្រង់ចុះ ដ្បិតប៉ុណ្ណោះឯងជាកិច្ចទាំងមូលដែលមនុស្សត្រូវធ្វើ។ ពីព្រោះព្រះទ្រង់នឹងនាំគ្រប់ការទាំងអស់មកដើម្បីជំនុំជម្រះ»។ «ចូរឱ្យអ្នករាល់គ្នានិយាយ ព្រមទាំងប្រព្រឹត្តបែបដូចជាក្រឹត្យវិន័យនៃសេចក្តីសេរីភាព រៀបនឹងជំនុំជម្រះអ្នកហើយចុះ»។ សាស្តា ១២:១៣,១៤; យ៉ាកុប ២:១២។

អស់អ្នកដែល «បានរាប់ជាគួរ» នឹងមានចំណែកក្នុងការរស់ឡើងវិញនៃពួកសុចរិត។ ព្រះយេស៊ូវមានបន្ទូលថា៖ «អស់អ្នកដែលបានរាប់ជាគួរឱ្យបានទៅឯបរលោកនាយ ហើយឱ្យបានរស់ពីស្លាប់ឡើងវិញ ហើយជាពួកកូនរបស់ព្រះផង ដោយបានរស់ពីស្លាប់ឡើងវិញ» «គឺពួកដែលបានប្រព្រឹត្តល្អ គេនឹងរស់ឡើងវិញឱ្យបានជីវិត»។ លូកា ២០:៣៥,៣៦; យ៉ូហាន

៥:២៩។ ពួកសុចរិតដែលស្លាប់ទៅ នឹងមិនទាន់រស់ឡើងវិញទេ រហូតទាល់តែបន្ទាប់ពីការជំនុំជម្រះបានរាប់ថាពួកគេគួរ «រស់ឡើងវិញឱ្យបានជីវិត»។ ដូច្នេះ យើញថាពួកគេពុំមានវត្តមានផ្ទាល់ទេ នៅពេលដែលកំណត់ហេតុរបស់ខ្លួនត្រូវបានពិនិត្យ ហើយករណីរបស់ខ្លួនត្រូវបានសម្រេច។

ព្រះយេស៊ូវនឹងលេចមកធ្វើជាស្មាក្តីរបស់គេ ដើម្បីជួយអង្វរសុំព្រះជំនួសគេ។ «ប្រសិនបើអ្នកណាភ្លាត់ធ្វើបាបវិញ នោះយើងមានព្រះដ៏ជាជំនួយមួយអង្គហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏សុចរិត»។ «ដ្បិតព្រះគ្រីស្ទទ្រង់មិនបានយាងចូលទៅក្នុងទីបរិសុទ្ធធ្វើដោយដៃ ដែលជាគំរូពីទីបរិសុទ្ធពិតនោះទេ គឺបានចូលទៅក្នុងស្ថានសួគ៌នោះឯង ដើម្បីនឹងលេចមកក្នុងពេលឥឡូវនេះ នៅចំពោះព្រះភ័ក្ត្រនៃព្រះ តំណាងយើងរាល់គ្នា»។ «ដោយហេតុនោះបានជាទ្រង់អាចនឹងជួយសង្គ្រោះសព្វគ្រប់បាន ដល់មនុស្សទាំងអស់ដែលចូលទៅឯព្រះ ដោយសារទ្រង់ ដ្បិតទ្រង់មានព្រះជន្មរស់នៅជានិច្ច ដើម្បីនឹងជួយអង្វរជំនួសយើង»។ យ៉ូហាន ២:១; ហេព្រើរ ៧:២៥; ៩:២៤។

នៅពេលដែលសៀវភៅកំណត់ហេតុបានបើកឡើងនៅក្នុងទីជំនុំជម្រះ ព្រះទ្រង់នឹងពិនិត្យសើរើជីវិតទាំងអស់ដែលបានជឿព្រះយេស៊ូវ។ ចាប់ផ្តើមជាមួយនឹងអស់អ្នកដែលបានរស់នៅលើផែនដីតាំងពីដើមដំបូងមក ព្រះដ៏ជាជំនួយរបស់យើង បញ្ចេញនូវករណីរបស់យើងម្នាក់ៗ តាំងពីដើមរៀងមក។ គេបានហៅឈ្មោះទាំងអស់ ព្រមទាំងពិនិត្យអង្កេតផង។ មានឈ្មោះដែលបានទទួល និងឈ្មោះដែលមិនបានទទួល។ បើនរណាម្នាក់មានអំពើបាបនៅលើសៀវភៅកំណត់ហេតុ ព្រោះមិនបានប្រែចិត្ត ហើយនិងមិនបានអត់ទោសឱ្យ នោះឈ្មោះរបស់ផងអ្នកនោះនឹងត្រូវលុបចេញអំពីបញ្ជីជីវិត។ ព្រះអង្គបានមានបន្ទូលដល់ហោរាម៉ូសេថា៖ «ឯអ្នកណាដែលបានធ្វើបាបនឹងអញ នោះអញនឹងលុបឈ្មោះអ្នកនោះឯងចេញពីបញ្ជីអញ»។ និក្ខមនំ ៣២:៣៣។

អ្នកទាំងអស់ដែលបានប្រែចិត្តពិតប្រាកដ ហើយបានអះអាងព្រះលោហិតព្រះគ្រីស្ទទុកជាយញ្ញបូជាប្រោសលោះរបស់ខ្លួន នោះនឹងបានទទួលសេចក្តីអត់ទោស កត់ចូលទៅក្នុងសៀវភៅស្ថានសួគ៌។ នៅពេលដែលគេមានចំណែកក្នុងសេចក្តីសុចរិតរបស់ព្រះគ្រីស្ទហើយ នោះចរិតលក្ខណៈរបស់គេ នឹងបានស្របទៅតាមក្រឹត្យវិន័យរបស់ព្រះ អំពើបាបរបស់គេត្រូវបានលុបចេញ ហើយគេនឹងបានរាប់ជាគួរទទួលជីវិតអស់កល្ប។ ព្រះទ្រង់មានបន្ទូលថា៖ «គឺអញ អញនេះហើយជាអ្នកដែលលុបអំពើរំលងរបស់ឯងចេញ ដោយយល់ដល់ខ្លួនអញ ហើយអញមិននឹកចាំពីអំពើបាបរបស់ឯងទៀតឡើយ»។ «អ្នកណាដែលឈ្នះ នោះនឹងបានស្លៀកពាក់ស ហើយអញនឹង...ថ្លែងប្រាប់ឈ្មោះអ្នកនោះ នៅចំពោះព្រះវរបិតាអញ និងចំពោះពួកទេវតាទ្រង់ដែរ»។ «ដូច្នេះអស់អ្នកណាដែលទទួលថ្លែងប្រាប់ពីខ្ញុំ នៅមុខមនុស្សលោក នោះខ្ញុំនឹងទទួលថ្លែងប្រាប់ពីអ្នកនោះនៅចំពោះព្រះវរបិតាខ្ញុំដែលគង់នៅស្ថានសួគ៌ដែរ។ តែអ្នកណាដែលមិនព្រមទទួលស្គាល់ខ្ញុំនៅមុខមនុស្សលោកទេ នោះខ្ញុំក៏មិនព្រមទទួលស្គាល់អ្នកនោះនៅចំពោះព្រះវរបិតាខ្ញុំដែលគង់នៅស្ថានសួគ៌ដែរ»។ អេសាយ ៥៣:២៥; វិវរណៈ ៣:៥; ម៉ាថាយ ១០:៣២,៣៣។

<u>សៅរ៍-២៨ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ២

ខព្រះគម្ពីរប្រចាំសប្តាហ៍: *ដ្បិតកាលលោកអស់ទីសង្ឃឹមហើយ នោះក៏ចេះតែជឿដោយសង្ឃឹមវិញ ដើម្បីឲ្យបានត្រឡប់ជាឪពុកដល់សាសន៍ជាច្រើន ដូចសេចក្តីដែលមានព្រះបន្ទូលទុកមកថា «ពូជឯងនឹងបានដូច្នោះ»។ រ៉ូម ៤:១៨*

ព្រះដ៏ជាជំនួយបានដាក់សេចក្តីទូលអង្វរថា អស់អ្នកដែលបានឈ្នះដោយជឿដល់ព្រះលោហិតព្រះអង្គ គួរបានសង្គ្រោះទៅកាន់លំនៅឯសួន

អេដែនរបស់ខ្លួនវិញ ព្រមទាំងពាក់មកុដគ្រងមរតកជាមួយទ្រង់ ក្នុង «អំណាចគ្រប់គ្រងដូចដើម»។ មីកា ៤:៨។ ឥឡូវនេះ ព្រះគ្រីស្ទបានសូមឱ្យផែនការបង្កបង្កើតមនុស្ស បានប្រព្រឹត្តទៅប្រៀបដូចជាមនុស្សពុំដែលមានបាបសោះ។ ទ្រង់ពុំគ្រាន់តែសូមឱ្យរាស្ត្ររបស់ផងទ្រង់ បានអត់ទោស និងគ្មានបាបសោះប៉ុណ្ណោះទេ គឺថែមទាំងសូមឱ្យមានចំណែកក្នុងសិរីល្អរបស់ផងទ្រង់ ព្រមទាំងឱ្យបានគ្រងរាជ្យបល្ល័ង្កជាមួយព្រះអង្គទៀតផង។

នៅពេលព្រះយេស៊ូវកំពុងអង្វរសុំនូវព្រះគុណសម្រាប់រាស្ត្ររបស់ផងទ្រង់ សាតាំងបានចោទប្រកាន់ពួកគេនៅចំពោះព្រះ។ វាចង្អុលទៅងកំណត់ហេតុនៃជីវិតរបស់ពួកគេ ទៅងចរិតវៀចវេរ ភាពមិនដូចព្រះគ្រីស្ទ និងអស់ទាំងអំពើបាបដែលវាបានល្បួងពួកគេឱ្យប្រព្រឹត្ត។ ដោយព្រោះតែការទាំងនេះ វាបានអះអាងថា ពួកគេជារណបរបស់វា។

ព្រះយេស៊ូវពុំចោទប្រកាន់ចំពោះអំពើបាបរបស់ពួកគេទេ តែទ្រង់បង្ហាញនូវភាពលន់តួបាប និងជំនឿរបស់ពួកគេវិញ។ ដើម្បីអះអាងឱ្យពួកគេនូវការអត់ទោស ទ្រង់លើកព្រះហស្តមានរបួសរបស់ព្រះអង្គនៅចំពោះព្រះភ័ក្តព្រះវរបិតា ដោយមានបន្ទូលថា៖ ទូលបង្គំបានចារឹកពួកគេនៅលើបាតដៃទូលបង្គំ។ «ឯតង្វាយដែលគួរថ្វាយដល់ព្រះ នោះគឺជាវិញ្ញាណខ្ទេចខ្ទាំ ឱព្រះអង្គអើយ ទ្រង់មិនមើលងាយចំពោះចិត្តខ្ទេចខ្ទាំ ហើយទន់ទាបឡើយ»។ ទំនុកតំកើង ៥១:១៧។

ព្រះអម្ចាស់បន្ទោសសាតាំង

ចំពោះមេចោទប្រកាន់ ទ្រង់មានបន្ទូលថា៖ «ម្នាលសាតាំង ព្រះយេហូវ៉ាទ្រង់បន្ទោសឯងអើ ព្រះយេហូវ៉ាដែលបានរើសក្រុងយេរូសាឡិម ទ្រង់ស្តីបន្ទោសដល់ឯង៖ នេះតើមិនមែនជាកន្ទុយឧសដែលបានកញ្ឆក់យកចេញពីភ្លើងទេឬ?» សាការី ៣:២។ ព្រះគ្រីស្ទនឹងបំពាក់ដល់អ្នកស្មោះត្រង់របស់ទ្រង់ នូវសេចក្តីសុចរិតរបស់ទ្រង់ផ្ទាល់ ដើម្បីឱ្យទ្រង់អាចបង្ហាញពួកគេដល់ព្រះវរបិតាព្រះអង្គ «ទុកជាពួកជំនុំដ៏ឧត្តម ឥតប្រឡាក់ ឥតជ្រួញ ឬមាន

អ្វីដូច្នោះឡើយ»។ អេភេសូរ ៥:២៧។

យ៉ាងនោះនឹងបានឃើញសេចក្តីសម្រេចដ៏ពោរពេញនៃសេចក្តីសន្យាពីសេចក្តីសញ្ញាថ្មី៖ «អញនឹងអត់ទោសចំពោះអំពើទុច្ចរិតរបស់គេ ហើយនឹងលែងនឹកចាំពីអំពើបាបគេទៀតជាដរាបទៅ»។ «ព្រះយេហូវ៉ាមានបន្ទូលថា នៅគ្រានោះ គឺនៅវេលានោះឯង គេនឹងរកសេចក្តីទុច្ចរិតរបស់ពួកអ៊ីស្រាអែល តែនឹងមិនប្រទះទេ ហើយរកអំពើបាបពួកយូដា តែនឹងមិនឃើញឡើយ» «អ្នកណាដែលសល់នៅក្នុងក្រុងស៊ីយ៉ូន ជាអ្នកដែលនៅសល់ក្នុងយេរូសាឡិមនៅឡើយ នោះនឹងបានហៅជាអ្នកបរិសុទ្ធ គឺគ្រប់ទាំងមនុស្សក្នុងយេរូសាឡិម ដែលមានឈ្មោះកត់ទុកក្នុងពួកមនុស្សរស់»។ យេរេមា ៣១:៣៤; ៥០:២០; អេសាយ ៤:៣។

ការលុបចេញនៃអំពើបាប

កិច្ចការជំនុំជម្រះដោយពិនិត្យអង្កេត ហើយនិងការលុបចេញនូវអំពើបាប ត្រូវតែបញ្ចប់នៅមុនដំណើរឃាងមកជាលើកទីពីររបស់ព្រះអម្ចាស់។ នៅក្នុងយញ្ញកិច្ចដែលជានិមិត្តរូប សង្ឃជាន់ខ្ពស់បាននិមន្តចេញមកជូនពរដល់ក្រុមជំនុំ។ ដូច្នេះព្រះគ្រីស្ទ ក៏បែបយ៉ាងនោះដែរ នៅពេលចប់ការងារជាស្ពានមេត្រីហើយ ទ្រង់នឹងលេចមក «ក្រៅពីរឿងអំពើបាប គឺដើម្បីនឹងជួយសង្គ្រោះដល់អ្នកដែលរង់ចាំទ្រង់»។ ហេព្រើរ ៩:២៨។

ចំណែកសង្ឃវិញ នៅក្នុងការយកបាបចេញពីទីបរិសុទ្ធនៃរោងឧបោសថ ក៏បានលន់តួបាបទាំងអស់នោះ ទៅលើក្បាលពពែ។ ព្រះគ្រីស្ទនឹងដាក់អស់ទាំងអំពើបាបនេះទៅលើសាតាំង ដែលជាដើមចមនៃអំពើបាប។ ពពែក៏ត្រូវបានបញ្ជូនចេញ «ទៅឯទីតំបន់សូន្យស្ងាត់»។ លេវីវិន័យ ១៦:២២។ សាតាំងដែលជាអ្នកទទួលកំហុសនៃអំពើបាប ដែលវាបណ្តាលឱ្យរាស្ត្ររបស់ព្រះប្រព្រឹត្ត នឹងត្រូវជាប់ឃុំមួយពាន់ឆ្នាំនៅលើផែនដីល្ហល្ហែរួចហើយនៅទីបំផុត នឹងទទួលរងទុក្ខទោសដោយភ្លើងដែលនឹងបញ្ឆេះពួកអាក្រក់។ យ៉ាងនោះផែនការនៃសេចក្តីសង្គ្រោះនឹងបានសម្រេច នៅពេល

ដែលបាបត្រូវបានបំផ្លាញចោលឱ្យសូន្យសុងទៅ។

<u>អាទិត្យ-២៩ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៣

ខព្រះគម្ពីរប្រចាំថ្ងៃ: *ហើយដោយព្រោះលោកមិនខ្សោយខាងសេចក្តីជំនឿ បានជាលោកមិនគិតពីរូបកាយលោក ដែលរាប់ដូចជាស្លាប់ ដោយមានអាយុប្រហែលជា១០០ឆ្នាំហើយ ឬពីផ្ទៃសារ៉ា ដែលរាប់ដូចជាស្លាប់ដែរនោះទេ។ រ៉ូម ៤:១៩*

នៅពេលកំណត់

នៅពេលកំណត់ ទីបញ្ចប់នៃ២៣០០ថ្ងៃនៅគ.ស.១៨៤៤ ការពិនិត្យអង្កេត ហើយនិងការលុបចោលអំពើបាប បានចាប់ផ្តើមឡើង។ អំពើបាបដែលពុំបានប្រែចិត្ត និងពុំបានលះបង់ចោល នឹងពុំបានលុបចេញពីបញ្ជីកត់ហេតុទេ។ ពពួកទេវតារបស់ព្រះជាអ្នកបានឃើញនូវអំពើបាបនីមួយៗ ហើយក៏កត់ទុកក្នុងបញ្ជី។ មនុស្សអាចបដិសេធអំពើបាប ឬលាក់បាំងអំពើបាបពីឪពុកម្តាយ ប្រពន្ធកូន និងមិត្តភក្តិបាន ប៉ុន្តែអំពើទាំងនោះនឹងលាតត្រដាងនៅចំពោះស្ថានសួគ៌វិញ។ ពុំអាចបញ្ឆោតព្រះដោយអាការៈខាងក្រៅបានទេ។ ទ្រង់ជ្រាបទាំងអស់។ មនុស្សអាចត្រូវគេបញ្ឆោតបានដោយអស់អ្នកដែលមានចិត្តពុករលួយ តែព្រះទ្រង់ជ្រាបជីវិតខាងក្នុងវិញ។

ឱ តើអាចបាបដូច្នេះកើតឬទេហ្ន៎! ព្រះដ៏ជាមេទ័ពដ៏ខ្លាំងពូកែបំផុតនៅលើផែនដី ពុំអាចបកទៅមើលកំណត់ហេតុសូម្បីតែមួយថ្ងៃនោះ។ អំពើបាបរបស់យើង ពាក្យសម្តីរបស់យើង សូម្បីតែបំណងអាថិកំបាំងរបស់យើង ទោះបីយើងបាបភ្លេចទៅហើយក្តី ក៏នឹងមានសាក្សីចាំបញ្ជាក់ឱ្យរួចខ្លួន ឬឱ្យត្រូវទទួលទោស។

នៅគ្រាជំនុំជម្រះ ការប្រើអស់ទាំងអំណោយទាន នឹងត្រូវបានពិនិត្យពិច័យយ៉ាងហ្មត់ចត់។ តើយើងបានប្រើពេលវេលារបស់យើង ស្លាបប៉ាការបស់យើង សំឡេងរបស់យើង ប្រាក់កាសរបស់យើង និងឥទ្ធិពលរបស់យើង ដោយរបៀបណាខ្លះ? តើយើងមានបានធ្វើអ្វីខ្លះសម្រាប់ព្រះគ្រីស្ទ

សម្រាប់ជនក្រីក្រ ជនរងទុក្ខឈឺចាប់ កូនកំព្រា និងស្ត្រីមេម៉ាយ? តើយើង បានធ្វើអ្វីខ្លះជាមួយពន្លឺ និងសេចក្តីពិតដែលបានប្រគល់មកយើងនោះ? មានតែសេចក្តីស្រឡាញ់ដែលបង្ហាញដោយការប្រព្រឹត្តទេ ទើបរាប់ថាពិតបាន។ មានតែសេចក្តីស្រឡាញ់ដែលព្រះទតឃើញប៉ុណ្ណោះ ដែលធ្វើឱ្យឥរិយាប្រព្រឹត្តមានតម្លៃថ្លៃថ្នូរ។

គំនិតអាត្មានិយម ត្រូវបានលាតត្រដាង

គំនិតលាក់កំបាំងប្រកបដោយអាត្មានិយម នឹងលាតត្រដាងនៅក្នុងសៀវភៅនៃស្ថានសួគ៌។ តើបានប្រគល់ពេលវេលា គំនិត ហើយនិងកម្លាំងដែលជារបស់ផងព្រះគ្រីស្ទ ទៅឱ្យសាតាំងជាញឹកញយប៉ុន្មានដែរ? ពួកអ្នកអះអាងថាដើរតាមព្រះគ្រីស្ទ បានស្ថិតនៅក្នុងការខំប្រឹងប្រមូលទ្រព្យសម្បត្តិលោកីយ៍ ឬក៏ក្នុងការអរសប្បាយចំពោះការត្រេកត្រអាលរបស់លោកីយ៍។ ប្រាក់កាស ពេលវេលា និងកម្លាំងកាយ បានបូជាសម្រាប់សំញែង ហើយនិងសម្រាប់ការបណ្តោយតាមចំណង់ខ្លួន មានពេលបន្តិចបន្តួចទេ សម្រាប់សេចក្តីអធិស្ឋាន សម្រាប់ស្វែងរកបទគម្ពីរ និងសម្រាប់លន់តួបាប។

សាតាំងប្រឌិតគម្រោងការដ៏រាប់មិនអស់ ដើម្បីគ្រប់គ្រងគំនិតរបស់យើង។ មេឆបោកវាស្អប់ដល់សេចក្តីពិតដ៏ឧត្តមដែលនាំឱ្យឃើញយញ្ញបូជាសម្រាប់ប្រោសលោះ ហើយនិងព្រះដ៏ជាស្ថានមេត្រីមានគ្រប់ព្រះចេស្តា។ ជាមួយវាអ្វីៗទាំងអស់សុទ្ធតែ ដើម្បីបង្វែរគំនិតចេញអំពីព្រះយេស៊ូវ។

ចំពោះអស់អ្នកដែលចែករំលែកផលប្រយោជន៍នៃស្ថានមេត្រីរបស់ព្រះអង្គសង្គ្រោះ គេមិនគួរអនុញ្ញាតឱ្យមានអ្វីមកជ្រៀតជ្រែកជាមួយករណីយកិច្ចបង្គ្រប់លក្ខណ៍ដល់ភាពបរិសុទ្ធ ក្នុងការកោតខ្លាចដល់ព្រះឡើយ។ ផ្ទុយអំពីការចំណាយពេលដ៏វិសេសវិសាល ក្នុងការស្វែងរកភាពត្រេកត្រអាល ឬរកប្រយោជន៍ផ្ទាល់ខ្លួន គួរតែខ្ជាប់ខ្ជួនចំពោះការរៀនសូត្រទាំងអធិស្ឋាននូវព្រះបន្ទូលនៃសេចក្តីពិតវិញ។ គួរតែបានយល់ច្បាស់អំពីរោងឧបោសថ ហើយនិងការជំនុំជម្រះដោយពិនិត្យអង្កេត។ ទាំងអស់គ្នាត្រូវការចំណេះចេះដឹង

អំពីតំណែងការងារ និងកិច្ចការនៃសម្តេចសង្ឃជាន់ខ្ពស់របស់ខ្លួន។ បើមិនដូច្នោះទេ នឹងពុំមានសមត្ថភាពអនុវត្តនូវសេចក្តីជំនឿ ជាពិសេសនៅពេលនេះបានឡើយ។

រោងឧបោសថនៅស្ថានសួគ៌គឺជាមជ្ឈមណ្ឌលសម្រាប់ការងាររបស់ព្រះគ្រីស្ទជំនួសមនុស្ស។ រោងឧបោសថ មានទំនាក់ទំនងដល់ព្រលឹងទាំងអស់រស់នៅផែនដី ហើយនិងបើកឱ្យឃើញផែនការសង្គ្រោះ ទាំងនាំយើងទៅរកទីបញ្ចប់នៃការប្រជែងគ្នារវាងភាពសុចរិត និងបាបកម្មផង។

<u>ចន្ទ-៣០ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៤

ខព្រះគម្ពីរប្រចាំថ្ងៃ: *លោកក៏មិនបានសង្ស័យ ចំពោះសេចក្តីសន្យារបស់ព្រះដោយចិត្តមិនជឿឡើយ គឺរឹតតែមានសេចក្តីជំនឿខ្លាំងឡើង ទាំងសរសើរដំកើងដល់ព្រះវិញ ហើយក៏ជឿជាក់អស់ពីចិត្តថា សេចក្តីអ្វីដែលទ្រង់សន្យា នោះអាចនឹងធ្វើឲ្យសំរេចបាន។ រ៉ូម ៤:២០-២១*

ការអង្វរករបស់ព្រះគ្រីស្ទ

ការទូលអង្វររបស់ព្រះគ្រីស្ទជំនួសមនុស្សនៅក្នុងរោងឧបោសថខាងលើ គឺមានសារៈសំខាន់ដល់ផែនការសង្គ្រោះ ដូចជាជីវិតព្រះអង្គនៅលើឈើឆ្កាងដែរ។ ដោយជីវិតរបស់ព្រះអង្គទ្រង់បានចាប់ផ្តើមកិច្ចការដែលទ្រង់បានយាងឡើងទៅបំពេញនៅស្ថានសួគ៌។ យើងត្រូវតែចូលទៅខាងក្នុងវាំងននដោយជំនឿ «ទ្រង់បានយាងចូលទៅជំនួសយើងរាល់គ្នាទុកដូចជាអ្នកនាំមុខ»។ ហេព្រើរ ៦:២០។ នៅទីនោះមានពន្លឺឆ្លុះចេញអំពីឈើឆ្កាង។ នៅទីនោះនឹងបានឃើញច្បាស់ជាងនូវអាថិកំបាំងនៃសេចក្តីសង្គ្រោះ។

«អ្នកណាដែលគ្របបាំងការរំលងរបស់ខ្លួន នោះនឹងមិនចម្រើនឡើងទេ តែអ្នកណាដែលលន់តួ ហើយលះបង់អំពើនោះ នឹងប្រទះបានសេចក្តីមេត្តាករុណាវិញ»។ សុភាសិន ២៨:១៣។ ប្រសិនបើអស់អ្នកដែលដោះសាកំហុសខ្លួន អាចឃើញនូវការដែលសាតាំងបានលួកលាន់ព្រះគ្រីស្ទ ដើម្បី

ពួកគេ នោះពួកគេនឹងលន់តួអំពើបាបខ្លួន ហើយវាក៏ដឹងថា បើយើងបណ្តោយខ្លួនតាមភាពកម្សោយរបស់យើងនោះ វានឹងបានឈ្នះហើយ។ ម្ល៉ោះហើយ សាតាំងនៅតែស្វះស្វែងដោយឥតឈប់ឈរ ដើម្បីបញ្ឆោតពួកអ្នកដើរតាមព្រះគ្រីស្ទ ដោយប្រើទស្សនៈឧបាយកលដ៏សែនគ្រោះថ្នាក់ ថាពួកគេពុំអាចមានសមត្ថភាពនឹងទប់ទល់បានឡើយ។ ប៉ុន្តែ ព្រះយេស៊ូវបានបញ្ជាក់ដល់ទាំងអស់គ្នាដែលដើរតាមទ្រង់ថា៖ «គុណរបស់ខ្ញុំល្មមដល់ឯងហើយ»។ «នឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាលដែរ»។ កូរិនថូសទី២ ១២:៩; ម៉ាថាយ ១១:៣០។ សូមកុំឱ្យនរណាម្នាក់គិតថា មិនអាចកែភាពកម្សោយរបស់ខ្លួនបាននោះឡើយ។ ព្រះទ្រង់នឹងប្រទានជំនឿ និងព្រះគុណ ឱ្យអាចឈ្នះបាន។

យើងឥឡូវនេះកំពុងរស់នៅក្នុងថ្ងៃដ៏ធំនៃសេចក្តីប្រោសលោះ។ នៅពេលដែលសម្តេចសង្ឃកំពុងធ្វើការសណ្តោសប្រោសសម្រាប់ជនជាតិអ៊ីស្រាអែល ទាំងអស់គ្នាត្រូវបានតម្រូវឱ្យមានការឈឺចិត្តផ្លាស់ប្រែពីអំពើបាប។ ក៏បែបដូច្នោះដែរ ទាំងអស់គ្នាដែលមានឈ្មោះរក្សាទុកនៅក្នុងបញ្ជីជីវិត ឥឡូវនេះគួរតែមានការឈឺចិត្ត នៅចំពោះព្រះដោយការប្រែចិត្តពិតប្រាកដ។ ត្រូវតែមានចិត្តស្វែងរកដោយស្មោះត្រង់ ហើយជ្រាលជ្រៅ។ វិញ្ញាណឡើករឡក់ដែលមនុស្សជាច្រើនមាននោះ ត្រូវតែលះបង់ចោល។ មានចម្បាំងដ៏ខ្លាំងក្លានៅចំពោះមុខអស់អ្នកដែលបង្ក្រាបនូវចំណង់អាក្រក់ដែលខ្ទុះខ្ទែង រកអំណាចគ្រប់គ្រង។ ទាំងអស់គ្នាត្រូវតែឃើញថា «ឥតប្រឡាក់ឥតជ្រួញ ឬមានអ្វីដូច្នោះឡើយ»។ អេភេសូរ ៥:២៧។

នៅពេលនេះដែលសំខាន់ជាងគេទាំងអស់គឺ ព្រលឹងរាល់រូបគួរតែខំស្វែងរកការព្រមានដាស់តឿនរបស់ព្រះអង្គសង្គ្រោះ៖ «ចូរប្រុងប្រយ័ត្ន ឱ្យចាំយាមហើយអធិស្ឋានផង ដ្បិតអ្នករាល់គ្នាមិនដឹងពេលកំណត់នោះទេ»។ ម៉ាកុស ១៣:៣៣។

ខាសនារបស់មនុស្សទាំងអស់ត្រូវបានសម្រេច

ពេលវេលាទុកឱ្យប្រែចិត្ត នឹងត្រូវបញ្ចប់ក្នុងរយៈពេលខ្លីមួយ មុនការ

លេចមកពីរបស់ព្រះអម្ចាស់នៅក្នុងពពកនៃឰដ៏ស្ថានសួគ៌។ ក្នុងការទន្ទឹងចាំពេលកំណត់នោះ ព្រះគ្រីស្ទបានមានបន្ទូលថា៖ «អ្នកណាដែលទុច្ចរិត ឱ្យអ្នកនោះនៅតែទុច្ចរិត អ្នកណាដែលស្មោកគ្រោក ឱ្យអ្នកនោះនៅតែស្មោកគ្រោកចុះ តែអ្នកណាដែលសុចរិតវិញ ត្រូវឱ្យអ្នកនោះចេះតែប្រព្រឹត្តផ្លូវសុចរិតទៅ ហើយអ្នកណាដែលបរិសុទ្ធ ឱ្យអ្នកនោះនៅតែបរិសុទ្ធដដែល មើលអញមកជាឆាប់ ទាំងនាំយករង្វាន់មកជាមួយ ដើម្បីនឹងចែកឱ្យគ្រប់គ្នាតាមការដែលខ្លួនបានធ្វើ»។ វិវរណៈ ២២:១១,១២។

មនុស្សនឹងនាំគ្នាដាំដំណាំ ហើយសង់ផ្ទះ ស៊ីនិងផឹក ទាំងអស់គ្នាពុំបានដឹងខ្លួនថាសេចក្តីសម្រេចចុងក្រោយ ត្រូវបានប្រកាសនៅក្នុងរោងឧបោសថខាងលើនោះទេ។ នៅមុនទឹកជំនន់ បន្ទាប់ពីលោកណូអេបានចូលទៅក្នុងទូកធំ ព្រះទ្រង់បានបិទទុកគាត់នៅខាងក្នុង ហើយបិទឱ្យពួកគ្មានព្រះនៅខាងក្រៅ ប៉ុន្តែអស់រយៈកាល៧ថ្ងៃ មនុស្សម្នានៅតែបន្តជីវិតត្រេកត្រអាលរបស់ខ្លួន ព្រមទាំងចំអកឡកឡឺយដល់សេចក្តីព្រមាននៃការជំនុំជម្រះទៀតផង។ «ក៏នឹងមានដូច្នោះដែរ» ព្រះអង្គសង្គ្រោះមានបន្ទូល «កាលណាកូនមនុស្សមក»។ វេលាកំណត់នៃវាសនាមនុស្សគ្រប់រូបនឹងមកដល់យ៉ាងស្ងាត់ជ្រៀបដោយគ្មានចាប់ភ្លឹក ដូចចោរនៅកណ្តាលអធ្រាត្រដូច្នោះ។ «ដូច្នេះចូរ ចាំយាមចុះក្រែងលោលោកមកដល់ភ្លាម ឃើញអ្នករាល់គ្នាកំពុងតែដេកលក់»។ ម៉ាថាយ ២៤:៣៩; ម៉ាកុស ១៣:៣៥,៣៦។

វរហើយអស់អ្នកដែលខ្សោះល្វើយក្នុងការចាំយាម រួចបែរទៅចាប់អារម្មណ៍ចំពោះលោកីយ៍វិញនោះ។ នៅពេលដែលពួកជំនួញកំពុងជក់ចិត្តស្វែងរកចំណេញ ពួកស្រឡាញ់តម្រេកកំពុងស្វែងរកបំពេញចំណង់ចិត្តខ្លួន ពួកស្រីៗដែលដេញតាមម៉ូដកំពុងរៀបចំពាក់គ្រឿងតុបតែងកាយ គឺអាចជាពេលនោះហើយ ដែលចៅក្រមនៃលោកីយ៍ទាំងមូលប្រកាសឡើងនូវសេចក្តីកាត់ទោសដែលថា «ត្រូវបានថ្លឹងនៅជញ្ជីង ឃើញថាខ្វះខាត»។ ដានីយ៉ែល ៥:២៧។

ហេតុអ្វីបានអនុញ្ញាតឱ្យមានបាប?

<u>អង្គារ-៣១ សីហា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដូច្នេះ ដែលយើងរាល់គ្នាបានរាប់ជាសុចរិត ដោយការជឿ នោះឈ្មោះថាយើងបានមេត្រីនឹងព្រះ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ។ រ៉ូម ៥:១*

មនុស្សជាច្រើនឃើញការប្រព្រឹត្តនៃអំពើអាក្រក់ ដែលមានសេចក្តីទុក្ខសោក និងសេចក្តីហិនវិនាស ហើយឆ្ងល់ថាតើការនេះអាចកើតមានដូចម្តេចបាន ក្រោមការគ្រប់គ្រងរបស់ព្រះដែលប្រកបដោយប្រាជ្ញា និងសេចក្តីស្រឡាញ់គ្មានទីបំផុតនោះ។ អ្នកដែលរមែងងឿងឆ្ងល់ តោងយកសេចក្តីនេះមកធ្វើជាលេស ដើម្បីបដិសេធពាក្យពេចន៍នៃសំណេរបរិសុទ្ធ។ ទំនៀមទម្លាប់ និងការយល់ខុស បានធ្វើឱ្យសេចក្តីបង្រៀននៃព្រះគម្ពីរដែលស្តីអំពីចរិតលក្ខណៈរបស់ព្រះ ពីរបៀបគ្រប់គ្រងរបស់ទ្រង់ និងពីគោលការណ៍នៃការដោះស្រាយអំពើបាប ក្លាយទៅជាស្រពេចស្រពិលទៅវិញ។

យើងមិនអាចពន្យល់អំពីដើមចមនៃបាប ដើម្បីនឹងផ្តល់មូលហេតុឱ្យវាបានទាល់តែសោះ។ មានការយល់ដឹងតិចតួចណាស់ ស្តីពីដើមកំណើត និងការលៃលកចុងក្រោយបង្អស់នៃអំពើបាប ដើម្បីឱ្យឃើញច្បាស់នៃសេចក្តីយុត្តិធម៌ និងមេត្តាធម៌របស់ព្រះ។ ព្រះពុំមែនជាអ្នករ៉ាប់រងចំពោះអំពើបាបទេ ព្រោះគ្មានការដកព្រះគុណដ៏ពិសិដ្ឋតាមតែព្រះហឫទ័យទ្រង់ ក៏គ្មានភាពទន់ខ្សោយក្នុងការគ្រប់គ្រងដ៏ពិសិដ្ឋ ដែលបណ្តាលឱ្យមានការប្រឆាំងនោះដែរ។ បាបគឺជាការជ្រៀតចូលមួយដែលពុំអាចរកមូលហេតុឱ្យវត្តមានរបស់វាបានឡើយ។ បើដោះសា គឺការពារវាហើយ។ ប្រសិនបើរកការដោះសានោះឃើញ វានឹងលៃងជាបាបទៀតហើយ។ អំពើបាបគឺជាគោលការមួយដែល

ទទឹងនឹងច្បាប់នៃសេចក្តីស្រឡាញ់ដែលជាគ្រឹះនៃការគ្រប់គ្រងដ៏ពិសិដ្ឋ។

មុននឹងមានសេចក្តីអាក្រក់ មានសន្តិសុខ និងអំណរទូទាំងពិភពសកល។ សេចក្តីស្រឡាញ់ដល់ព្រះគឺឧត្តុង្គឧត្តម ហើយសេចក្តីស្រឡាញ់រវាងគ្នា និងគ្នា គឺមិនលំអៀងទៅខាងណាមួយឡើយ។ ព្រះគ្រីស្ទដែលជាព្រះរាជបុត្រតែមួយគត់របស់ព្រះ បានមានភាពតែមួយក្នុងនិស្ស័យ ក្នុងចរិតលក្ខណៈ និងក្នុងគោលបំណងជាមួយព្រះវរបិតាដ៏នៅអស់កល្ប ព្រោះទ្រង់ជាតួអង្គតែមួយដែលអាចចូលទៅក្នុងអស់ទាំងទីប្រឹក្សា និងគម្រោងការរបស់ព្រះ។ «ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌...ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ»។ កូល៉ុស ១:១៦។

ច្បាប់នៃសេចក្តីស្រឡាញ់ គឺជាគ្រឹះនៃការគ្រប់គ្រងរបស់ព្រះ សុភមង្គលនៃអស់ទាំងទេវបុត្រដែលបានបង្កើតមក គឺអាស្រ័យទៅលើការស្របទៅតាមគន្លងធម៌នៃសេចក្តីសុចរិត។ ព្រះទ្រង់ពុំមានព្រះទ័យសោមនស្សក្នុងការបង្ខំឱ្យគេមានចិត្តស្មោះត្រង់មកកាន់ទ្រង់ទេ ហើយទ្រង់ប្រទានដល់គេទាំងអស់នូវសេរីភាពនៃទំនើងចិត្ត ប្រយោជន៍ឱ្យគេធ្វើតបមកទ្រង់វិញដោយការបម្រើស្ម័គ្រពីចិត្ត។

ប៉ុន្តែ មានម្នាក់បានសម្រេចចិត្តនឹងបង្វែរសេរីភាពនេះ។ បាបគឺបានកកើតឡើងដោយសារម្នាក់នោះឯង ដែលបន្ទាប់ពីព្រះគ្រីស្ទ ព្រះប្រទានកិត្តិយសដល់វាខ្លាំងណាស់។ មុននឹងមានបាប លូស៊ីហ្វ័រជាចេរូប៊ីនគ្របបាំងទីមួយ បរិសុទ្ធហើយឥតខ្ចោះ។ «ព្រះអម្ចាស់យេហូវ៉ាមានបន្ទូលដូច្នេះ ឯងជាអ្នកបំពេញខ្នាត ដោយមានប្រាជ្ញាពោរពេញ ហើយលម្អគ្រប់លក្ខណ៍។ ពីដើមឯងបាននៅក្នុងច្បារអេដែនជាសួនរបស់ព្រះ ឯងបានប្រដាប់កាយដោយត្បូងដ៏មានតម្លៃគ្រប់មុខ...។ ឯងជាចេរូប៊ីនដែលបានចាក់ប្រេងតាំងឡើងជាអ្នកគ្របបាំង គឺអញបានតាំងឯងឡើងឱ្យឯងបាននៅលើភ្នំបរិសុទ្ធរបស់ព្រះឯងក៏បានដើរទៅមកនៅកណ្តាលថ្មភ្លឺចាំង។ ចាប់តាំងពីថ្ងៃដែលឯងកើតមក នោះឯងបានគ្រប់លក្ខណ៍ ក្នុងគ្រប់ទាំងផ្លូវរបស់ឯង ដរាបដល់

វេលាដែលឃើញមានសេចក្តីទុច្ចរិតនៅក្នុងខ្លួនឯង...។ ចិត្តឯងបានស្វួយ ឡើង ដោយព្រោះសេចក្តីលម្អរបស់ឯង ឯងបានបង្ខូច ប្រាជ្ញាឯងដោយ ពន្លឺរស្មីរបស់ឯង។» «ឯងបានតាំងចិត្តឱ្យបានដូចជាព្រះ ហឫទ័យនៃព្រះ»។ «ឯងបានគិតក្នុងចិត្តថា អញនឹងឡើងទៅឯស្ថានសួគ៌ អញនឹងតម្កើងបល្ល័ង្ក អញឱ្យខ្ពស់ជាងផ្កាយរបស់ព្រះ ហើយអញនឹងអង្គុយលើភ្នំជាទីប្រជុំជំនុំ...។ អញនឹងឡើងផុតទីខ្ពស់នៃពពក អញនឹងលើកខ្លួនឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត»។ អេសេគាល ២៨:១២-១៧; ២៨:៦; អេសាយ ១៤:១៣,១៤។

<u>ពុធ-១ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៦

ខព្រះគម្ពីរប្រចាំថ្ងៃ:*ក៏ដោយសារទ្រង់ យើងមានផ្លូវចូលក្នុងព្រះគុណនេះ ជាទីដែលយើងកំពុងឈរនៅដោយសេចក្តីជំនឿ ហើយយើងអួតពីសេចក្តីសង្ឃឹមដល់សិរីល្អនៃព្រះផង។ រ៉ូម ៥:២*

ដោយច្រណែនកិត្តិយសដែលព្រះវរបិតាបានប្រទានដល់ព្រះរាជបុត្រារបស់ទ្រង់ មេពួកទេវតានេះបានប្រាថ្នាចង់កាន់អំណាច ដែលមានតែព្រះគ្រីស្ទមួយគត់មានសិទ្ធិកាន់កាប់។ សូរសៀវភៅនៃសំឡេងខុសចង្វាក់មួយ បានបង្ខូចការប្រគុំដ៏រងំនៃស្ថានសួគ៌។ ការលើកតម្កើងខ្លួនបានពញ្ញាក់ស្មារតីនៃពពួកទេវបុត្រដែលពោរពេញដោយសិរីល្អដ៏ឧត្តុង្គឧត្តមរបស់ព្រះ ឱ្យដឹងពីប្រផ្នូលនៃសេចក្តីអាក្រក់។ ក្រុមប្រឹក្សានៃស្ថានសួគ៌បានអង្វរលូស៊ីហ្វើរ។ ព្រះរាជបុត្រារបស់ព្រះបានបង្ហាញលូស៊ីហ្វើរនូវសេចក្តីល្អ និងសេចក្តីយុត្តិធម៌នៃព្រះអាទិករ និងនិស្ស័យបរិសុទ្ធនៃក្រឹត្យវិន័យរបស់ទ្រង់។ បើងាកចេញវិញ លូស៊ីហ្វើរនឹងបង្អាប់កិត្តិយសនៃអ្នកបង្កើតខ្លួន ហើយនឹងនាំឱ្យមានក្តីអន្តរាយដល់ខ្លួនទៀតផង។ ប៉ុន្តែ ការព្រមានបានគ្រាន់តែបណ្តាលឱ្យមានសេចក្តីរឹងទទឹងឡើងថែមទៀត។ លូស៊ីហ្វើរបានអនុញ្ញាតឱ្យសេចក្តីច្រណែននឹងព្រះគ្រីស្ទរាលដាលឡើងរហូតដល់ទប់លែងបាន។

ចិត្តធំរបស់វាបានបំប៉នឱ្យមានសេចក្តីប្រាថ្នាចង់បានឧត្តមភាព។ កិត្តិយសខ្ពង់ខ្ពស់ដែលត្រូវបានប្រទានឱ្យលូស៊ីហ្វើរ ពុំបានទទួលមកវិញនូវ

ការសងគុណដល់ព្រះអាទិករទេ។ លូស៊ីហ្វ័រចង់បានស្មើនឹងព្រះខ្លាំងណាស់។ តែគេទទួលស្គាល់គ្រប់គ្នាថា ព្រះរាជបុត្រានៃព្រះគឺជាព្រះមហាក្សត្រនៃស្ថានសួគ៌ ដែលទ្រង់មានភាពតែមួយក្នុងឫទ្ធិអំណាចជាមួយនឹងព្រះវរបិតា។ ក្នុងអស់ទាំងទីប្រឹក្សារបស់ព្រះ ព្រះគ្រីស្ទជាអ្នកចូលរួមមួយដែរ ប៉ុន្តែ លូស៊ីហ្វ័រពុំបានអនុញ្ញាតឱ្យចូលក្នុងរឿងរ៉ាវនៃគម្រោងការរបស់ព្រះទេ។ «ហេតុអ្វី» ទេវតាដ៏ខ្លាំងពូកែបានសួរ «បានជាព្រះគ្រីស្ទត្រូវមានឧត្តមភាព? ហេតុអ្វីបានជាទ្រង់មានកិត្តិយសលើលូស៊ីហ្វ័រ?»

ភាពមិនស្កប់ចិត្តក្នុងចំណោមពពួកទេវតា

ចេញពីវត្តមានរបស់ព្រះ លូស៊ីហ្វ័របានទៅបន្សុសបន្សាយភាពមិនស្កប់ចិត្ត ក្នុងចំណោមពពួកទេវតា។ ដោយសេចក្តីសម្ងាត់យ៉ាងខ្លាំង និងដោយការលាក់គោលបំណងពិតប្រាកដរបស់ខ្លួន ដើម្បីធ្វើឱ្យមើលទៅដូចជាទេវបុត្រនៃស្ថានសួគ៌ ដោយប្រាប់គេថា ក្រឹត្យវិន័យធ្វើឱ្យមានការទើសទាល់ដែលមិនចាំបាច់។ ដោយនិស្ស័យរបស់គេជាបរិសុទ្ធ លូស៊ីហ្វ័របានថ្លែងថាពួកទេវតាគួរស្តាប់តាមសេចក្តីបញ្ជានៃទំនើងចិត្តរបស់ខ្លួនវិញ។ ព្រះបានប្រព្រឹត្តដល់លូស៊ីហ្វ័រដោយអយុត្តិធម៌ ក្នុងការប្រទានកិត្តិយសដ៏ឧត្តមឱ្យព្រះគ្រីស្ទ។ លូស៊ីហ្វ័របានអះអាងថា ខ្លួនមិនមែនតម្រង់ទៅរកការតម្កើងខ្លួនឯងទេ ប៉ុន្តែចង់បានសេរីភាពសម្រាប់អស់ទាំងអ្នកដែលរស់នៅក្នុងស្ថានសួគ៌ឱ្យបានជាស្តាពរ ប្រយោជន៍ឱ្យគេអាចទទួលភាពខ្ពង់ខ្ពស់ជាងនេះទៅទៀត។

ព្រះទ្រង់បានស៊ូទ្រាំជាមួយនឹងលូស៊ីហ្វ័រ។ លូស៊ីហ្វ័រពុំបានធ្លាក់ពីតំណែងខ្ពស់ទេ សូម្បីតែនៅពេលមានការចាប់ផ្តើមសម្តែងការអះអាងមិនពិតដល់ពួកទេវតាក៏ដោយ។ ម្តងហើយម្តងទៀត ព្រះបានផ្តល់ឱកាសឱ្យលូស៊ីហ្វ័របានរួចពីទោស ប្រសិនបើលន់តួហើយចុះចូល។ មានតែការខិតខំស្រឡាញ់ដ៏គ្មានទីបំផុតទេ ទើបអាចធ្វើគម្រោងការដើម្បីបញ្ជាក់ថាលូស៊ីហ្វ័រខុសបាន។ ភាពមិនស្កប់ពុំដែលមាននៅស្ថានសួគ៌ពីមុនឡើយ។ លូស៊ីហ្វ័រផ្ទាល់ក៏ពុំបានយល់ប្រភេទពិតប្រាកដនៃអារម្មណ៍របស់ខ្លួនដែរ។ នៅពេលការមិនពេញចិត្តត្រូវបានបញ្ជាក់ថាគ្មានដើមហេតុនោះ លូស៊ីហ្វ័របានដឹង

ច្បាស់ណាស់ថា សេចក្តីអះអាងរបស់ព្រះ គឺយុត្តិធម៌ហើយគួរតែប្រាប់ដល់អស់ទាំងស្ថានសួគ៌។ បើបានធ្វើដូច្នេះ នោះប្រហែលជាជួយសង្គ្រោះខ្លួនឯង និងទេវតាជាច្រើនទៀតផង។ ប្រសិនបើ លូស៊ីហ្វ័រសុខចិត្តត្រឡប់មកព្រះវិញ នោះនឹងត្រូវបានតំណែងវិញ។ ប៉ុន្តែ ការប្រកាន់ឫកធំបានឃាំងមិនឱ្យវាចុះចូល។ លូស៊ីហ្វ័រនៅតែអះអាងថាខ្លួនឥតត្រូវការលន់តួ ហើយក៏ដាក់ខ្លួនទាំងស្រុងទៅក្នុងមហាវិវាទទាស់នឹងព្រះដែលជាអ្នកបង្កើតខ្លួន។

អស់ទាំងអំណាចនៃគំនិតវាងវៃរបស់វា ឥឡូវត្រូវបានបត់បែនទៅរកសេចក្តីបញ្ឆោត ដើម្បីទាញអារម្មណ៍នៃពួកទេវតា។ សាតាំងបានលើកឡើងថា គេបានគិតស្មានខុសពីខ្លួន ហើយគេបានផ្តាច់សេរីភាពរបស់ខ្លួនផង។ បន្ទាប់ពីបានបំផ្លើសព្រះបន្ទូលរបស់ព្រះគ្រីស្ទហើយ វាមួលបង្កាច់ថែមទៀតដោយចោទព្រះរាជបុត្រារបស់ព្រះ ថាបានបង្កើតវាមកឱ្យអាម៉ាស់មុខ នៅចំពោះមុខទេវបុត្រនៃស្ថានសួគ៌។

អស់អ្នកដែលវាមិនអាចទាញមកខាងវាបាន វាចោទពួកគេថាមិនរវល់នឹងរឿងរ៉ាវរបស់ពួកទេវបុត្រ។ វានិយាយបំផ្លើសព្រះអាទិករតែម្តង។ ក្បួនរបស់វាគឺដើម្បីធ្វើឱ្យពួកទេវតាមានចិត្តស្មុគស្មាញ ដោយប្រើការវែកញែកដ៏ប៉ិនប្រសប់ ស្តីពីគោលបំណងរបស់ព្រះ។ អ្វីៗដែលងាយស្រួល វាបានគ្របបាំងដោយអាថិកំបាំង វាបានពិចារណាឆ្ងល់ពាក្យដ៏ស្រួលយល់របស់ព្រះដោយការបង្វែរបង្វិលយ៉ាងប៉ិនប្រសប់។ តំណែងខ្ពង់ខ្ពស់របស់វា បានធ្វើឱ្យវាកាន់តែមានអំណាចខ្លាំងឡើង។ មានភាគច្រើនត្រូវបានវាលោមបញ្ឆោតឱ្យរួមសហការជាមួយវាក្នុងការប្រឆាំង។

<u>ព្រហស្បតិ៍-២ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៧

ខព្រះគម្ពីរប្រចាំថ្ងៃ: *មិនតែប៉ុណ្ណោះសោត យើងនៅតែអួតក្នុងកាលដែលមានទុក្ខលំបាកដែរ ដោយដឹងថា សេចក្តីទុក្ខលំបាកបង្កើតឲ្យមានសេចក្តីទ្រាំទ្រ សេចក្តីទ្រាំទ្របង្កើតឲ្យមានសេចក្តីសាំញ៊ីក សេចក្តីសាំញ៊ីកបង្កើតឲ្យមានសេចក្តីសង្ឃឹម ឯសេចក្តីសង្ឃឹមក៏មិនដែលនាំឲ្យយើងមានសេចក្តី*

ខ្មាសឡើយ ពីព្រោះសេចក្តីស្រឡាញ់របស់ព្រះ បានផ្សាយមកសព្វក្នុងចិត្ត យើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានមកយើង ហើយ។ រ៉ូម ៥:៣-៥

សេចក្តីមិនស្កប់ចិត្តភ្លាយទៅជាអំពើបះបោរយ៉ាងសកម្ម

ក្នុងព្រះតម្រិះប្រាជ្ញារបស់ព្រះ ទ្រង់បានអនុញ្ញាតឱ្យសាតាំងបន្តកិច្ចការរបស់វា រហូតដល់សេចក្តីមិនស្កប់ចិត្តបានធំលូតលាស់ដល់មានការបះបោរ។ នេះជាការចាំបាច់មួយ ដើម្បីទុកឱ្យគម្រោងការរបស់វាបានពេញរូបរាងឡើង ប្រយោជន៍ឱ្យទាំងអស់គ្នាបានឃើញនិស្ស័យពិតប្រាកដរបស់វា។ ពពួកទេវបុត្រនៃស្ថានសួគ៌ស្រឡាញ់លូស៊ីហ្វ័រខ្លាំងណាស់ ហើយវាក៏មានអនុភាពលើគេណាស់ដែរ។ ព្រះពុំគ្រាន់តែគ្រប់គ្រងលើពួកអ្នករស់នៅស្ថានសួគ៌ប៉ុណ្ណោះទេ តែលើអស់ទាំងពិភពដែលទ្រង់បានបង្កើតមកផង ហើយសាតាំងបានគិតថា ប្រសិនបើអាចនាំពួកទេវតាជាមួយវាក្នុងការប្រឆាំងនោះ វាក៏នឹងអាចកាន់ពិភពដទៃទៀតបានដែរ។ ដោយប្រើកលល្បិចនិងការបន្លំអំណាចបោកបញ្ឆោតរបស់វាគឺខ្លាំងណាស់។ សូម្បីតែពួកទេវតាដែលស្មោះត្រង់នោះ ក៏ពុំអាចយល់ពីចរិតរបស់វាបានពេញលក្ខណៈ ឬដឹងថាកិច្ចការរបស់វានោះនឹងកើតទៅជាអ្វីដែរ។

គេបានគោរពសាតាំងខ្លាំងណាស់ ហើយអស់ទាំងការប្រព្រឹត្តរបស់វាត្រូវបានបិទបាំងដោយអាថ៌កំបាំង ធ្វើឱ្យពិបាកនឹងបើកឱ្យពួកទេវតាឃើញនូវនិស្ស័យពិតប្រាកដ។ បើមិនបានពេញរូបរាងពិតប្រាកដទេ បាបមិនមែនមើលទៅឃើញអាក្រក់ដូច្នោះឡើយ។ ពួកទេវតាពុំបានយល់នូវផលវិបត្តិនៃការជាត់ចោលក្រឹត្យវិន័យដ៏ពិសិដ្ឋទេ។ មុនដំបូងសាតាំងបានអះអាងថា វាស្វះស្វែងចង់លើកតម្កើងកិត្តិយសរបស់ព្រះ និងរកប្រយោជន៍សម្រាប់អស់អ្នករស់នៅស្ថានសួគ៌។

ក្នុងការដោះស្រាយអំពើបាប ព្រះអាចប្រើបានតែសេចក្តីសុចរិត និងសេចក្តីពិតទេ។ សាតាំងអាចប្រើនូវអ្វីដែលព្រះប្រើពុំបាន ពោលគឺសេចក្តីបញ្ឆោរ និងសេចក្តីបញ្ឆោត។ ចរិតពិតប្រាកដនៃមេដៅល្មើសអំណាចនេះ ត្រូវ

តែបានយល់ដោយសត្វលោកទាំងអស់។ ត្រូវឱ្យពេលវេលាដល់វា ដើម្បីឱ្យវាសម្តែងខ្លួនដោយអំពើទុច្ចរិតរបស់វា។

រីឯសេចក្តីមិនស្របគ្នាដែលវាបានបង្កើតឡើងនៅស្ថានសួគ៌នោះ វាបានចោទទៅលើព្រះវិញ។ អស់ទាំងអំពើអាក្រក់ទាំងប៉ុន្មាន វាបានប្រកាសថាជាលទ្ធផលនៃការចាត់ចែងរបស់ព្រះ។ ដូច្នេះ ជាការចាំបាច់ណាស់ ដែលត្រូវឱ្យវាសម្តែងផលផ្លែនៃការផ្លាស់ប្តូរក្រឹត្យវិន័យរបស់ព្រះដែលវាបានលើកមក។ កិច្ចការរបស់វាត្រូវផ្ទាញ់ផ្ទាលវា។ ពិភពលោកទាំងមូលត្រូវឃើញមេបញ្ឆោត។

សូម្បីតែនៅពេលបានសម្រេចថា វាមិនគួរនៅស្ថានសួគ៌ទៀតក៏ដោយ ព្រះដ៏មានតម្រិះប្រាជ្ញាគ្មានទីបំផុត ពុំបានបំផ្លាញសាតាំងទេ។ សេចក្តីស្មោះត្រង់នៃរាស្ត្ររបស់ព្រះ ត្រូវតែស្ថិតនៅលើការយល់ដឹងជាក់ច្បាស់នូវសេចក្តីយុត្តិធម៌របស់ទ្រង់។ បើប្រហារជីវិតសាតាំងនៅពេលនោះ អស់អ្នករស់នៅក្នុងស្ថានសួគ៌ និងស្ថានដទៃទៀត នឹងពុំអាចឃើញយុត្តិធម៌ និងមេត្តាធម៌របស់ព្រះបានឡើយ ដោយពួកគេពុំមានការឈ្វេងយល់អំពីផលវិបត្តិនៃបាបកម្ម ព្រោះពុំដែលបានប្រទះពីមុនមក។ បើបំបាត់វាមិនឱ្យមានតទៅទៀត នោះពួកគេនឹងបម្រើព្រះដោយសេចក្តីភ័យខ្លាច ជាជាងដោយសេចក្តីស្រឡាញ់។ ឥទ្ធិពលនៃមេបញ្ឆោតនឹងមិនបានវិនាសទាំងស្រុងទេ ហើយកិរិយានៃសេចក្តីប្រឆាំងក៏មិនបានបាត់សូន្យឈឹងដែរ។ ដើម្បីជាប្រយោជន៍ដល់ពិភពសកលតាមសម័យដ៏អស់កល្បនោះសាតាំងត្រូវគ្រោងការរបស់វាឱ្យបានពេញលេញថែមទៀត ដើម្បីឱ្យអស់ទាំងរូបអង្គដែលត្រូវបានបង្កើតមក ឃើញក្នុងពន្លឺដ៏ពិតនូវសេចក្តីចោទប្រកាន់នឹងការគ្រប់គ្រងរបស់ព្រះ។

<u>សុក្រ-៣ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៨

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែឯព្រះ ទ្រង់សំដែងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា*

នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង។ រ៉ូម ៥:៨

ការប្រឆាំងរបស់សាតាំង គឺនឹងត្រូវជាទីបន្ទាល់នៃលទ្ធផលដ៏អាក្រក់នៃអំពើបាប ដល់ពិភពសកល។ ការកាន់ក្តាប់របស់វា នឹងបង្ហាញផលផ្លែនៃការផាត់ចោលឫទ្ធិអំណាចដ៏ពិសិដ្ឋ។ ប្រវត្តិសាស្ត្រនៃការពិសោធនៃសេចក្តីប្រឆាំងនេះ គឺនឹងត្រូវបានជាសេចក្តីការពារជាដរាប ដល់អស់ទាំងប្រាជ្ញាបរិសុទ្ធទាំងឡាយ ដើម្បីសង្គ្រោះពួកគេពីអំពើបាបនិងទណ្ឌកម្ម។

នៅពេលដែលបានប្រកាសដល់អស់អ្នកយល់ស្របនឹងសាតាំងថា មេដណ្តើមអំណាចដ៏ធំត្រូវតែបណ្តេញចេញពីស្ថានបរមសុខ មេប្រឆាំងបានបញ្ចេញសេចក្តីស្អប់ខ្ពើមយ៉ាងខ្លាំង ដល់ក្រឹត្យវិន័យរបស់ព្រះអាទិករ។ វាបានចាត់ទុកលក្ខន្តិក:ដ៏ពិសិដ្ឋថា ជាការឃាត់ឃាំងមិនឱ្យមានសេរីភាព ហើយប្រកាសប្រាប់យ៉ាងម៉ឺងម៉ាត់ ពីគោលបំណងដើម្បីលុបបំបាត់ក្រឹត្យវិន័យ ពោលគឺបើរួចពីការឃាត់ឃាំងនេះ ពួកពលបរិវារនៃស្ថានសួគ៌នឹងប្រហែលចម្រើនដល់សភាវ:ដ៏ខ្ពង់ខ្ពស់ជាងនេះទៅទៀត។

ការបណ្តេញចេញពីស្ថានសួគ៌

សាតាំងនិងពួកពលរបស់វា បានយកការប្រឆាំងរបស់គេមកបន្ទោសព្រះគ្រីស្ទ។ បើមិនបានកែតម្រូវពួកគេ នោះគេនឹងមិនដែលប្រឆាំងទេ។ រឹងហើយចចេស ហើយនៅតែអះអាងទាមទារទាំងប្រមាថថាជាជនរងគ្រោះនៃអំណាចជិះជាន់ដែលឥតទោសសោះនោះ មេប្រឆាំង និងអ្នកកាន់ខាងវា ក៏ត្រូវបានបំបរបង់ពីស្ថានសួគ៌។ សូមអាន វិវរណៈ ១២:៧-៩។

អាកប្បកិរិយារបស់សាតាំង នៅតែបណ្តុះបណ្តាលសេចក្តីប្រឆាំងនៅផែនដី ទៅលើកូនចៅដែលមិនស្តាប់ឱវាទ។ ដូចជារូបវាដូច្នោះដែរ ពួកគេបានសន្យានឹងមនុស្សនូវសេរីភាពតាមការបំពានវិន័យរបស់ព្រះ។ ការកែតម្រូវអំពើបាបនៅតែរំជួលឱ្យមានសម្អប់។ សាតាំងបាននាំមនុស្សឱ្យដោះសាខ្លួនគេ ហើយឱ្យអ្នកដទៃរួបរួមគំនិតជាមួយអំពើបាបរបស់វា។ ជាជាងកែតម្រង់កំហុសរបស់ខ្លួន ពួកគេបានធ្វើឱ្យគេតូចចិត្តនឹងអ្នកណែនាំវិញ ធ្វើហាក់ដូចជាអ្នកនោះជាអ្នកបណ្តាលនូវភាពលំបាកដូច្នោះ។

សាតាំងបានលោមមនុស្សឱ្យធ្វើបាប ដោយប្រើការបង្ហាញចរិតលក្ខណៈមិនពិតរបស់ព្រះដូចវាបានអនុវត្តនៅស្ថានសួគ៌ ដែលធ្វើឱ្យគេចាត់ទ្រង់ថាជាអ្នកតឹងរ៉ឹង និងអ្នកប្រើអំណាចផ្តាច់ការ។ វាបានថ្លែងថា លក្ខខណ្ឌដ៏អយុត្តិធម៌របស់ព្រះបាននាំឱ្យមនុស្សជំពប់ដួល ដូចជាបាននាំឱ្យខ្លួនវាប្រឆាំងដែរ។

ក្នុងការបំបរបង់សាតាំងចេញពីស្ថានសួគ៌ ព្រះបានសម្តែងយុត្តិធម៌ និងកិត្តិយសរបស់ទ្រង់។ ប៉ុន្តែ នៅពេលមនុស្សបានធ្វើបាប ព្រះបានប្រទានភ័ស្តុតាងនៃសេចក្តីស្រឡាញ់ ដោយប្រទានព្រះរាជបុត្រារបស់ទ្រង់ ឱ្យសុគតជួសពូជសាសន៍ដែលបានធ្លាក់ទៅក្នុងអំពើបាប។ ក្នុងការលោះបាបនេះ យើងនឹងឃើញចរិតលក្ខណៈរបស់ព្រះ។ សេចក្តីវែកញែកដ៏ធំធេងនៃឈើឆ្កាង បង្ហាញថាបាបកម្មគឺមិនអាចចោទទៅលើការគ្រប់គ្រងរបស់ព្រះបានឡើយ។ ក្នុងការដែលព្រះអង្គសង្គ្រោះប្រកបការងារនៅផែនដី មេបញ្ឆោតដ៏ធំត្រូវបានបើកមុខឡើង។ ការប្រមាថដ៏ឥតញញើតដែលទាមទារឱ្យព្រះគ្រីស្ទឱនគោរពដល់វា សេចក្តីព្យាបាទដ៏មិនចេះឆោកឆុយ ដែលតាមយាយីព្រះអង្គពីកន្លែងមួយទៅកន្លែងមួយ បណ្តាលឱ្យចិត្តសង្ឃ និងប្រជាជនបដិសេធសេចក្តីស្រឡាញ់របស់ទ្រង់ និងឱ្យគេស្រែកថា «ឆ្កាងវាទៅ!។» ទាំងអស់នេះ បានធ្វើឱ្យពិភពសកលកោតស៊ើច និងមានចិត្តឈឺចាប់។ ស្តេចនៃសេចក្តីអាក្រក់ បានបញ្ចេញអស់ទាំងអំណាច និងការប៉ិនប្រសប់របស់វា ដើម្បីបំផ្លាញព្រះយេស៊ូវ។ សាតាំងបានយកមនុស្សធ្វើជាភ្នាក់ងាររបស់វា ដើម្បីធ្វើឱ្យព្រះជន្មនៃព្រះអង្គសង្គ្រោះបានពេញដោយសេចក្តីវេទនា និងសេចក្តីសោកសង្រេង។ ដុំភ្លើងនៃសេចក្តីច្រណែន និងសេចក្តីព្យាបាទ សេចក្តីស្អប់ខ្ពើម និងការសងសឹក បានផ្ទុះឡើងនៅកាល់វ៉ារី ទាស់នឹងព្រះរាជបុត្រារបស់ព្រះ។

<u>សៅរ៍-៤ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៩

ខព្រះគម្ពីរប្រចាំសប្តាហ៍: *ដូច្នេះ ដែលបាបបានចូលមកក្នុងលោកីយ៍ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្តីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្តីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ ។ រ៉ូម ៥:១២*

ឥឡូវនេះ កំហុសរបស់សាតាំង បានលេចចេញមកដោយគ្មានការដោះសា។ វាបានបើកសម្តែងចរិតលក្ខណៈពិតប្រាកដរបស់វា។ ការកុហករបស់សាតាំង ដែលចោទទាស់នឹងចរិតលក្ខណៈពិសិដ្ឋ បានលេចភ្លឺឡើងក្នុងពន្លឺដ៏ពិត។ វាបានចោទព្រះថាទ្រង់បានរកសេចក្តីលើកតម្កើងសម្រាប់តែព្រះអង្គទ្រង់ ដើម្បីឱ្យរាស្ត្ររបស់ព្រះអង្គស្តាប់បង្គាប់តាមទ្រង់ ហើយក៏បានថ្លែងទៀតថា ក្នុងពេលដែលព្រះអាទិករ បានបញ្ជាក់យ៉ាងម៉ឺងម៉ាត់នូវការលះបង់អ្វីៗទាំងអស់នោះ ព្រះអង្គផ្ទាល់ពុំបានអនុវត្តការលះបង់ខ្លួននោះទេ ហើយពុំបានធ្វើពលីកម្មអ្វីសោះ។ ឥឡូវនេះគេបានឃើញថា អ្នកកាន់កាប់ពិភពសកលបានធ្វើការលះបង់ដ៏លើសលប់ តាមតែសេចក្តីស្រឡាញ់អាចធ្វើទៅបាន ពីព្រោះ «ព្រះទ្រង់គង់ក្នុងព្រះគ្រីស្ទ កំពុងផ្សះផ្សាលោកីយ៍នឹងព្រះអង្គទ្រង់»។ កូរិនថូសទី២ ៥:១៩។ ដើម្បីកម្ទេចបាប ព្រះគ្រីស្ទបានដាក់ព្រះអង្គទ្រង់ ហើយបង្អោនចុះចូលរហូតដល់សោយជីវង្គតទៀតផង។

ការជជែកដួសមនុស្ស

អស់ទាំងស្ថានសួគ៌បានឃើញនូវការសម្តែងនៃសេចក្តីយុត្តិធម៌របស់ព្រះ។ លូស៊ីហ្វើរបានអះអាងថា ពូជសាសន៍មានបាបនេះគឺហួសពីការប្រោសលោះហើយ។ ប៉ុន្តែ ពិន័យនៃក្រឹត្យវិន័យបានធ្លាក់មកដល់ព្រះទ្រង់ដែលស្មើនឹងព្រះ បានជាមនុស្សមានសេរីភាពនឹងទទួលសេចក្តីសុចរិតរបស់ព្រះគ្រីស្ទ ហើយដោយការស្តាយក្រោយចំពោះការប្រព្រឹត្តអំពើបាប និងការបន្ទាបខ្លួន គេនឹងឈ្នះលើអំណាចរបស់សាតាំង។

ប៉ុន្តែ ព្រះគ្រីស្ទយាងមកសុគតនៅផែនដីនេះ គឺមិនមែនគ្រាន់តែសម្រាប់ប្រោសលោះមនុស្សលោកប៉ុណ្ណោះទេ ទ្រង់បានយាងមកដើម្បីសម្តែងឱ្យ

អស់ពិភពនានាឃើញថា ក្រឹត្យវិន័យរបស់ព្រះគឺផ្លាស់ប្តូរពុំបានឡើយ។ សេចក្តីសុគតរបស់ព្រះគ្រីស្ទបានបញ្ជាក់ថា កែប្រែមិនបាន ហើយសម្តែងថាសេចក្តីយុត្តិធម៌ និងមេត្តាធម៌ គឺជាគ្រឹះនៃការគ្រប់គ្រងរបស់ព្រះ។ ក្នុងការជំនុំជម្រះចុងក្រោយ គេនឹងបានឃើញថា ដើមហេតុនៃបាបនឹងលែងមានទៀតឡើយ។ នៅពេលព្រះដ៏ជាចៅក្រមនៃអស់ទាំងផែនដីទាមទារចម្លើយពីសាតាំង «ហេតុអ្វីបានជាឯងប្រឆាំងទាស់នឹងអញ?» នោះអ្នកដែលជាដើមចមនៃសេចក្តីអាក្រក់ មិនអាចឆ្លើយដោះសាបានឡើយ។

ក្នុងសម្រែកបង្ហើយរបស់ព្រះអង្គសង្គ្រោះ «ការស្រេចហើយ» សំឡេងភ្លេងបញ្ចុះសពរបស់សាតាំងបានបន្លឺឡើង។ មហាវិវាទ ត្រូវបានបញ្ចប់សេចក្តី នៅពេលនោះ បញ្ជាក់ថាជាការបំបាត់ឱ្យសូន្យជាចុងក្រោយដល់សេចក្តី អាក្រក់។ នៅពេលថ្ងៃនោះមកដល់ ដែល «ឆេះឆ្លាដូចជាគុកភ្លើង នោះអស់ ពួកអ្នកឆ្មើងឆ្មៃ ហើយនិងអស់អ្នកដែលប្រព្រឹត្តអំពើអាក្រក់ គេនឹងដូចជាជញ្ជាំង ហើយថ្ងៃដែលត្រូវមកដល់នោះនឹងឆេះបន្សុសគេទាំងអស់ទៅឥតទុកឱ្យគេមានឫស ឬមែកនៅសល់ឡើយនេះហើយជាព្រះបន្ទូលនៃព្រះ យេហូវ៉ានៃពួកពលបរិវារ»។ ម៉ាឡាគី ៤:១។

នឹងលែងមានសេចក្តីអាក្រក់ទៀតឡើយ។ វិន័យរបស់ព្រះ នឹងត្រូវបានគេគោរពជាក្រឹត្យវិន័យខាងឯសេរីភាព។ សត្វលោកដែលបានល្បួង និងបញ្ជាក់រួចហើយនោះ នឹងមិនងាកចេញម្តងទៀតពីសេចក្តីស្មោះត្រង់ដល់ទ្រង់ ដែលបានបង្ហាញចរិតលក្ខណៈថាជាសេចក្តីស្រឡាញ់ដែលរកជម្រៅគ្មាន និងជាតម្រិះប្រាជ្ញាដែលរកទីបំផុតគ្មានឡើយ។

សាតាំង និងមនុស្ស

<u>អាទិត្យ-៥ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១០

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែបើឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា មានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ ដល់អស់អ្នកដែលស្វែងរកទ្រង់។ ហេព្រើរ ១១:៦*

«អញនឹងធ្វើឱ្យពូជឯងហើយនិងស្ត្រី គឺទាំងពូជឯង និងពូជនាងមានសេចក្ដីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ»។ លោកុប្បត្តិ ៣:១៥។ សេចក្ដីខ្មាំងនឹងគ្នានេះ គឺមិនមែនមកពីធម្មជាតិទេ។ នៅពេលមនុស្សប្រព្រឹត្តរំលងក្រឹត្យវិន័យរបស់ព្រះ និស្ស័យរបស់គេក្លាយទៅជាអាក្រក់ ត្រូវគ្នានឹងសាតាំង។ ពួកទេវតាដែលព្រះបានទម្លាក់ពីស្ថានសួគ៌ និងពួកមនុស្សនឹងចងសម្ព័ន្ធនឹងគ្នាទាស់នឹងស្ថានសួគ៌ ហើយក្រុមគ្រួសារនៃមនុស្សទាំងមូល នឹងត្រូវបានរួបរួមគ្នាក្នុងការប្រឆាំងនឹងព្រះ។

នៅពេលសាតាំងបានឮថា សេចក្ដីខ្មាំងនឹងគ្នាត្រូវតែមានរវាងខ្លួនវា និងស្ត្រី ហើយនិងរវាងពូជវា និងពូជស្ត្រី វាដឹងថា មនុស្សនឹងអាចទប់ទល់នឹងអំណាចរបស់វា ដោយមធ្យោបាយណាមួយមិនខាន។

ព្រះគ្រីស្ទបានបណ្ដុះក្នុងមនុស្សនូវភាពជាខ្មាំងប្រឆាំងនឹងសាតាំង។ បើគ្មានព្រះគុណដែលជួយកែប្រែចរិតលក្ខណៈ និងគ្មានអំណាចថ្មីនេះទេ មនុស្សនឹងនៅតែជាខ្ញុំបម្រើ ធ្វើតាមសេចក្ដីបញ្ជារបស់សាតាំងជាដរាប។ ប៉ុន្តែ គន្លងធម៌ថ្មីក្នុងមនុស្ស បង្កើតឱ្យមានការប៉ះទង្គិច ព្រោះអំណាចដែល

ព្រះប្រទានឱ្យនោះ ធ្វើឱ្យមនុស្សអាចតទល់នឹងមេប្រើអំណាចផ្តាច់ការ។ ការស្អប់ខ្ពើមអំពើបាបជាជាងស្រឡាញ់អំពើបាប គឺជាការបង្ហាញគន្លងធម៌មកពីស្ថានលើទាំងស្រុង។

ការប្រឆាំងគ្នារវាងព្រះគ្រីស្ទ និងសាតាំង បានបង្ហាញយ៉ាងច្បាស់អស្ចារ្យក្នុងការដែលពិភពលោកទទួលព្រះយេស៊ូវ។ ភាពឥតខ្ចោះ និងភាពបរិសុទ្ធនៃព្រះគ្រីស្ទ បានធ្វើឱ្យអ្នកឥតព្រះក្នុងខ្លួនស្អប់ទ្រង់។ សេចក្តីលះបង់របស់ទ្រង់បានជាសេចក្តីបន្ទោសជានិរន្តដល់មនុស្សអួតអាង និងមនុស្សប្រកបដោយតម្រេក។ សាតាំង និងទេវតាអាក្រក់ បានសាមគ្គីជាមួយមនុស្សទុច្ចរិត ទាស់នឹងព្រះដែលជាអ្នកមានជ័យជម្នះខាងសេចក្តីពិត។ ភាពជាខ្មាំងដូចគ្នានេះ ក៏បានសម្តែងដល់ពួកគ្រីស្ទបរិស័ទដែរ។ អ្នកណាដែលទប់ទល់នឹងសេចក្តីល្បួង នឹងរំជួលកំហឹងរបស់សាតាំងហើយ។ ព្រះគ្រីស្ទ និងសាតាំងមិនអាចត្រូវគ្នាបានឡើយ។ «អស់អ្នកណាដែលចង់រស់ដោយប្រតិបត្តតាមព្រះយេស៊ូវ នោះនឹងត្រូវមានសេចក្តីបៀតបៀនដែរ»។ ធីម៉ូថេទី២ ៣:១២។

ភ្នាក់ងាររបស់សាតាំង ស្វែងរកមធ្យោបាយដើម្បីបញ្ឆោតអ្នកដើរតាមព្រះគ្រីស្ទ និងទាក់ទាញចិត្តគេចេញពីសេចក្តីស្មោះស្ម័គ្រ។ គេបានបង្វែរន័យបទគម្ពីរ ដើម្បីសម្រេចគោលបំណងរបស់ខ្លួន។ វិញ្ញាណដែលធ្វើគុតព្រះគ្រីស្ទ ទាញមនុស្សទុច្ចរិតឱ្យបំផ្លាញអ្នកដើរតាមទ្រង់។ ការអស់ទាំងនេះ គឺបានទស្សន៍ទាយក្នុងបទទំនាយផ្នែកខាងដើម «អញនឹងធ្វើឱ្យពូជឯងហើយ និងស្ត្រី គឺទាំងពូជឯង និងពូជនាង មានសេចក្តីខ្មាំងនឹងគ្នា»។

ហេតុអ្វីបានជាសាតាំងមិនពិសោធការដែលគេជម្នះនឹងវាដ៏ខ្លាំងជាងនេះទៅទៀតនោះ? ពីព្រោះកងទាហានរបស់ព្រះគ្រីស្ទ មានការទាក់ទងពិតប្រាកដតិចតួចណាស់ជាមួយព្រះគ្រីស្ទ។ គេមិនបានស្អប់ខ្ពើមអំពើបាប ដូចព្រះបរមគ្រូរបស់ខ្លួនទេ។ គេពុំបានខិតខំប្រឹងជម្នះអំពើបាបនោះឡើយ។ ម្ល៉ោះហើយគេមើលមិនឃើញទាល់តែសោះ នូវចរិតលក្ខណៈរបស់ស្តេចនៃ

សេចក្តីងងឹត។ មនុស្សទាំងឡាយឥតបានដឹងទេថា សត្រូវរបស់ខ្លួនគឺជាមេទ័ពដ៏ខ្លាំងពូកែដែលកំពុងធ្វើសង្គ្រាមជាមួយព្រះគ្រីស្ទ។ សូម្បីតែគ្រូផ្សាយដំណឹងល្អ ក៏មើលរំលងភ័ស្តុតាងនៃសកម្មភាពរបស់វាដែរ។ គេហាក់បីដូចជាមិនអើពើនឹងវត្តមានរបស់វាតែម្តង។

<u>ចន្ទ-៦ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១១

ខព្រះគម្ពីរប្រចាំថ្ងៃ:*ដោយសារសេចក្តីជំនឿ នោះហេណុកបានឡើងទៅលើ មិនបានឃើញសេចក្តីស្លាប់ឡើយ ហើយគេរកគាត់មិនឃើញទៀត ពីព្រោះព្រះបានយកគាត់ទៅ ដ្បិតកាលមុនដែលលើកយកគាត់ទៅ នោះមានសេចក្តីបន្ទាល់ពីគាត់ថា ព្រះទ្រង់សព្វព្រះហឫទ័យនឹងគាត់ណាស់ ។ ហេព្រើរ ១១:៥*

សត្រូវដែលចាំឃ្លាំមើល

សត្រូដែលឃ្លាំមើលនេះ ជ្រៀតជ្រែកចូលក្នុងគ្រប់ទាំងផ្ទះសម្បែង គ្រប់ទាំងផ្លូវ ក្នុងក្រុមជំនុំ ក្នុងក្រុមប្រឹក្សាជាតិ និងក្នុងតុលាការ។ វាធ្វើឱ្យគេស្មុគស្មាញ វាបញ្ឆោត និងលួងលោមបំផ្លាញព្រលឹង និងរូបកាយរបស់មនុស្ស ក្មេងចាស់ប្រុសស្រីគ្រប់ទីកន្លែង។ វាបំបាក់បំបែកក្រុមគ្រួសារសាបព្រោះសេចក្តីសម្អប់ ទំនាស់ទាស់ទែង ចិត្តមិនស្កប់ និងឃាតកម្ម។ ហើយពិភពលោកហាក់បីដូចជាចាត់ទុកការទាំងនេះថាព្រះបានដាក់មកដូច្នោះ ហើយនិងគិតថាការនេះត្រូវតែមាន។ អស់អ្នកណាដែលពុំបានសម្រេចចិត្តដើរតាមព្រះគ្រីស្ទ គឺជាខ្ញុំបម្រើរបស់សាតាំងហើយ។ នៅពេលពួកគ្រីស្ទានជ្រើសរើសសង្គមនៃមនុស្សគ្មានព្រះ គេបើកចំហខ្លួនគេឱ្យមានសេចក្តីល្បួងហើយ។ សាតាំងលាក់ខ្លួនវាមិនឱ្យគេមើលឃើញ ហើយយកការបញ្ឆោតរបស់វាមកគ្របលើភ្នែករបស់គេ។

ការចុះសម្រុងនឹងទំនៀមទម្លាប់លោកីយ៍ គឺបំផ្លាស់បំប្រែព្រះវិហារ

ទៅឯផ្លូវលោកីយ៍ មិនដែលលោកីយ៍ទៅឯផ្លូវព្រះគ្រីស្ទទេ។ ភាពស៊ាំនឹងអំពើបាប នឹងធ្វើឱ្យអំពើបាបនោះ មើលទៅមិនសូវអាក្រក់ណាស់ណាទេ។ នៅពេលដែលយើងប្រកបការងារ ហើយត្រូវកើតទុក្ខលំបាក យើងអាចដឹងច្បាស់ថាព្រះនឹងការពារយើង ប៉ុន្តែបើយើងដាក់ខ្លួនក្រោមសេចក្តីល្បួងវិញ មិនយូរមិនឆាប់យើងនឹងដួលជាមិនខាន។

មេល្បួងតែងតែធ្វើការបានជោគជ័យល្អ តាមរយៈអ្នកដែលមើលទៅមិនសូវសង្ស័យថាស្ថិតនៅក្រោមកណ្តាប់ដៃវា។ ទេពកោសល្យ និងការលូតលាស់ក្នុងការអប់រំ គឺជាអំណោយទានរបស់ព្រះ ប៉ុន្តែនៅពេលប្រការទាំងនេះឃ្លាតចេញពីទ្រង់ វានឹងក្លាយទៅជាអន្ទាក់ទៅវិញ។ មនុស្សជាច្រើនដែលមានបញ្ញាវាងវៃដែលចម្រើនមកពីការអប់រំ ហើយដែលមានអាកប្បកិរិយារួសរាយ គឺជាឧបករណ៍ដ៏ល្អប្រណីតមួយក្នុងកណ្តាប់ដៃរបស់សាតាំង។

ចូរកុំភ្លេចសេចក្តីព្រមានរបស់ព្រះ ដែលបានបន្លឺប្រាប់រាប់សតវត្សរហូតមកដល់ជំនាន់យើងឥឡូវនេះថា៖ «ចូរឱ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសឹង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន»។ ចូរពាក់«គ្រឿងសឹករបស់ព្រះ ដើម្បីឱ្យបាននឹងឈរមាំមួន ទាស់នឹងឧបាយកលទាំងអម្បាលម៉ានរបស់អារក្ស»។ ពេត្រុសទី១ ៥:៨; អេភេសូរ ៦:១១។ សត្រូវដ៏ធំរបស់យើងកំពុងតែគ្រោងយុទ្ធនាការចុងក្រោយរបស់វា។ អស់អ្នកណាដែលដើរតាមព្រះយេស៊ូវ នឹងប៉ះទង្គិចនឹងសត្រូវនេះជាមិនខាន។ កាលណា ពួកគ្រីស្ទានត្រាប់តាមគំរូដ៏ពិសិដ្ឋបានកាន់តែជិតដូចទ្រង់ប៉ុណ្ណា ខ្លួនគេនឹងច្បាស់ជាបានជាទីសម្គាល់ សម្រាប់ឱ្យសាតាំងធ្វើទុក្ខប៉ុណ្ណោះដែរ។

សាតាំងបានវាយប្រហារព្រះគ្រីស្ទ ដោយសេចក្តីល្បួងដ៏សាហាវ និងដ៏ប៉ិនប្រសប់ជាក្រៃលែង ប៉ុន្តែទ្រង់បានច្រានវាចេញទៅវិញ ក្នុងគ្រប់ទាំងការប៉ះទង្គិចគ្នានេះ។ ជ័យជម្នះទាំងនោះធ្វើឱ្យយើងឈ្នះបានដែរ។

ព្រះគ្រីស្ទនឹងប្រទាននូវកម្លាំងដល់អ្នកណាដែលសូម។ គ្មានមនុស្សណាអាច
ចាញ់សាតាំងបានទេ បើខ្លួនមិនអនុញ្ញាតឱ្យនោះ។ មេឈ្លួងគ្មានអំណាចនឹង
គ្រប់គ្រងទំនើងចិត្ត ឬបង្ខំមនុស្សឱ្យធ្វើបាបឡើយ។ វាអាចបណ្តាលឱ្យមាន
ចិត្តខ្វល់ខ្វាយ តែមិនអាចធ្វើឱ្យមិនស្អាតបានឡើយ។ រឿងហេតុដែលព្រះ
គ្រីស្ទបានឈ្នះនោះ គួរតែបណ្តាលចិត្តនៃអ្នកដើរតាមទ្រង់ ឱ្យមានចិត្ត
ក្លាហាន ដើម្បីប្រយុទ្ធនឹងអំពើបាបហើយនិងសាតាំង។

វិញ្ញាណអាក្រក់

<u>អង្គារ-៧ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១២

ខព្រះគម្ពីរប្រចាំថ្ងៃ:*ដោយសារសេចក្តីជំនឿ នោះព្រះបានមានព្រះបន្ទូលពន្យល់លោកណូអេ ពីការដែលមើលមិនទាន់ឃើញនៅឡើយ ហើយដោយលោកមានសេចក្តីកោតខ្លាច បានជាលោកធ្វើទូក១យ៉ាងធំសំរាប់នឹងជួយសង្គ្រោះដល់ពួកគ្រួសាររបស់លោក ហើយលោកបានកាត់ទោសលោកីយ៍ដោយការនោះ ក៏ត្រឡប់ជាអ្នកគ្រងសេចក្តីសុចរិត ដែលត្រូវខាងសេចក្តីជំនឿ ទុកជាមរដកដែរ។ ហេព្រើរ ១១:៧*

បទគម្ពីរបានបើកសម្តែងយ៉ាងច្បាស់ អំពីពួកទេវតារបស់ព្រះ និងវិញ្ញាណអាក្រក់ទាំងឡាយ ដែលប្រស្រ័យទាក់ទងជាមួយប្រវត្តិសាស្ត្រមនុស្ស។ ពួកទេវតាបរិសុទ្ធដែលជួយបម្រើ «ដល់ពួកដែលត្រូវទទួលសេចក្តីសង្គ្រោះជាមរដក» (ហេព្រើរ ១:១៤) ត្រូវបានមនុស្សជាច្រើនចាត់ទុកថាជាវិញ្ញាណនៃអ្នកស្លាប់។ ប៉ុន្តែ បទគម្ពីរបង្ហាញវត្ថុតាងថា វិញ្ញាណទាំងនេះមិនមែនជាព្រលឹងនៃអ្នកស្លាប់ទេ។

មុនការបង្កើតមនុស្ស មានពួកទេវតារួចស្រេចទៅហើយ ពីព្រោះនៅពេលគ្រឹះផែនដីបានធ្វើឡើង «ផ្កាយព្រឹកបានច្រៀងជាមួយគ្នា ហើយអស់ទាំងកូនព្រះបានស្រែកអរសាទរ»។ យ៉ូប ៣៨:៧។ បន្ទាប់ពីមនុស្សបានធ្លាក់ទៅក្នុងអំពើបាបមក ព្រះក៏បានបញ្ជូនពួកទេវតាឱ្យទៅយាមដើមជីវិតមុននឹងមនុស្សម្នាក់ស្លាប់ទាន់។ ពួកទេវតាមានអំណាចលើមនុស្ស ព្រោះមនុស្សដែលបង្កើតមក «ទាបជាងពួកទេវតាតែបន្តិចទេ»។ ទំនុកតំកើង ៨:៥។

ហោរាមានប្រសាសន៍ថា៖ ខ្ញុំ «ក៏ឮសំឡេងទេវតាជាច្រើននៅជុំវិញបល្ល័ង្ក»។ គេជា «ពួកទេវតាដ៏សល់សែន» រង់ចាំបម្រើស្តេចលើអស់ទាំងស្តេច ព្រោះជា «អ្នកបម្រើទ្រង់ដែលធ្វើតាមព្រះហឫទ័យ» និង «ស្តាប់តាមព្រះសូរសៀងនៃព្រះបន្ទូលទ្រង់»។ វិវរណៈ ៥:១១; ទំនុកតំកើង ១០៣:២០,២១; ហេព្រើរ ១:២។ ដោយព្រោះពួកគេជាអ្នកនាំសាររបស់ព្រះ គេនាំគ្នាចេញទៅ «ដូចជាផ្លេកបន្ទោរ» ការហោះហើររបស់គេនោះលឿនណាស់។ ទេវតាដែលបានលេចមកនៅឯផ្នូររបស់ព្រះអង្គសង្គ្រោះមានសណ្ឋាន «ដូចជាផ្លេកបន្ទោរ» ធ្វើឱ្យអាមាត្យភ័យញាប់ញ័រ «ហើយត្រឡប់ដូចជាមនុស្សស្លាប់»។ នៅពេលសានហេរីបបានប្រមាថព្រះ និងគំរាមអ៊ីស្រាអែល «ទេវតានៃព្រះយេហូវ៉ាក៏ចេញទៅប្រហារទីបោះទ័ពនៃពួកអាសស៊ើ សម្លាប់មនុស្សអស់មួយសែនប្រាំបីម៉ឺនប្រាំពាន់នាក់»។ អេសេគាល ១:១៤; ម៉ាថាយ ២៨:៣,៤; ពង្សាវតាក្សត្រទី២ ១៩:៣៥។

ពួកទេវតាត្រូវបានបញ្ជូនទៅដល់កូនចៅរបស់ព្រះ ក្នុងបេសកកម្មនៃសេចក្តីមេត្តាករុណា ដល់លោកអ័ប្រាហាំនូវសេចក្តីសន្យានៃការប្រទានពរ ដល់ក្រុងសូដុម ដើម្បីសង្គ្រោះលោកឡុតពីសេចក្តីអន្តរាយ ដល់អេលីយ៉ាដែលស្ទើរតែបាត់បង់ក្នុងវាលរហោស្ថាន ដល់អេលីសេនូវរាជរថ និងសេះភ្លើង ពេលគាត់បានទ័លច្រកដោយសត្រូវ ដល់ដានីយ៉ែលនៅពេលគេបោះឱ្យទៅជាចំណីសិង្ហ ដល់ពេត្រុសដែលហៀបនឹងស្លាប់ក្នុងគុករបស់ស្តេចហេរ៉ូឌ ដល់អ្នកជាប់គុកនៅក្រុងភីលីព ដល់ប៉ុលក្នុងយប់នៃព្យុះសង្ឃរានៅលើសមុទ្រ និងទៅបើកចិត្តកូនីលៀសឱ្យទទួលដំណឹងល្អ ទៅដល់ពេត្រុសដើម្បីបញ្ជូនគាត់ឱ្យយកដំណឹងនៃសេចក្តីសង្គ្រោះ ដល់ជនចម្លែកដែលជាសាសន៍ដទៃ។ គឺរបៀបនេះហើយដែលពួកទេវតាបានបម្រើដល់រាស្ត្ររបស់ព្រះ។

ទេវតាការពារ

ទេវតាការពារមួយអង្គ ត្រូវបានចាត់មកឯអ្នកដើរតាមព្រះគ្រីស្ទ

ម្នាក់ៗ។ «ទេវតានៃព្រះយេហូវ៉ាចោមរោមនៅជុំវិញនៃអស់អ្នកដែលកោត
ខ្លាចដល់ទ្រង់ ហើយក៏ជួយគេឱ្យរួច»។ ព្រះអង្គសង្គ្រោះបានមានបន្ទូលអំពី
អ្នកដែលជឿដល់ទ្រង់ថា ទេវតារបស់គេ «ដែលនៅស្ថានសួគ៌ តែងតែឃើញ
ព្រះភ័ក្ត្រព្រះវរបិតានៃខ្ញុំជានិច្ច»។ ទំនុកតំកើង ៣៤:៧; ម៉ាថាយ ១៨:១០។ រាស្ត្រ
របស់ព្រះដែលប្រឈមមុខនឹងសេចក្តីព្យាបាទដ៏រោលរាលរបស់ស្តេចនៃ
ភាពងងឹតនោះ គឺត្រូវមានពួកទេវតាជាអ្នកការពារជានិច្ច។ ការធានានេះត្រូវ
បានប្រទានឱ្យមក ពីព្រោះមនុស្សនឹងត្រូវជួបប្រទះភ្នាក់ងារនៃសេចក្តី
អាក្រក់ដ៏ខ្លាំងពូកែ។ ពួកវានេះមានច្រើនអនេក វាខំតស៊ូ ហើយមិនចេះ
នឿយហត់សោះ។

<u>ពុធ-៨ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១៣

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដោយសារសេចក្តីជំនឿ កាលព្រះបានហៅលោក
អ័ប្រាហាំ នោះលោកក៏បានស្តាប់បង្គាប់ លោកចេញទៅឯកន្លែងដែលត្រូវ
ទទួលជាមរដក គឺចេញទៅឥតមានដឹងជាទៅឯណាទេ។ ហេព្រើរ ១១:៨*

ពួកវិញ្ញាណអាក្រក់ ដែលកាលពីដើមបានបង្កើតមកដោយគ្មានបាប
មាននិស្ស័យ អំណាច និងសិរីល្អស្មើពួកទេវតាបរិសុទ្ធដែរ ដែលឥឡូវនេះ
ជាអ្នកនាំសាររបស់ព្រះ។ តែដោយបានធ្លាយធ្លាក់ព្រោះអំពើបាប គេបានព្រួត
ដៃគ្នាបំបាក់កិត្តិយសរបស់ព្រះ និងបំផ្លិចបំផ្លាញមនុស្ស។ ពួកគេរួបរួម
ជាមួយសាតាំងក្នុងការប្រឆាំង ហើយធ្វើសហការច្បាំងនឹងឫទ្ធិអំណាច
ស្ថានសួគ៌។

ប្រវត្តិសាស្ត្រក្នុងគម្ពីរសញ្ញាចាស់ បានចែងពីវត្តមានរបស់ពួកគេ
ប៉ុន្តែ ក្នុងអំឡុងពេលដែលព្រះគ្រីស្ទបាននៅផែនដីនោះ វិញ្ញាណអាក្រក់
ទាំងនេះបានសម្តែងអំណាចរបស់វា ក្នុងភាពដ៏សាហាវបំផុត។ ព្រះគ្រីស្ទ
បានយាងមកដើម្បីប្រោសលោះមនុស្សលោក ចំណែកឯសាតាំងបានតស៊ូ

ចង់គ្រប់គ្រងពិភពលោក។ វាបានជោគជ័យក្នុងការបង្កើតឱ្យមានការគោរព
រូបចម្លាក់ ក្នុងគ្រប់ផ្នែកនៃផែនដី លើកលែងតែប្រទេសប៉ាលេស្ទីនប៉ុណ្ណោះ។
ព្រះគ្រីស្ទបានយាងមកប្រទេសនេះ ជាប្រទេសតែមួយគត់ ដែលពុំទាន់បាន
ទោរទន់ទៅតាមមេល្បួងទាំងស្រុង ទាំងលាតព្រះហស្តនៃសេចក្តីស្រឡាញ់
អញ្ជើញគេទាំងអស់គ្នា ឱ្យរកសេចក្តីលើកលែងទោស និងសន្តិភាពក្នុង
ទ្រង់។ ពួកពលបរិវារនៃសេចក្តីងងឹតបានដឹងថា បើបេសកកម្មរបស់ព្រះ
គ្រីស្ទបានជោគជ័យនោះ ការកាន់ក្តាប់របស់គេនឹងត្រូវចប់នៅពេលខាងមុខ
ជាមិនខាន។

ការដែលអារក្សចូលមនុស្ស គឺបានចែងក្នុងព្រះគម្ពីរសញ្ញាថ្មីយ៉ាង
ច្បាស់។ ជនដែលបានរងទុក្ខនោះ មិនគ្រាន់តែឈឺចាប់ពីជំងឺដែលកើតមកពី
ធម្មជាតិទេ តែព្រះគ្រីស្ទទ្រង់ឈ្វេងយល់ពីវត្តមាននៃពួកវិញ្ញាណអាក្រក់ និង
ភ្នាក់ងាររបស់ពួកវា។ អ្នកដែលខ្មោចចូលទៅស្រុកកាដារ ដែលឆ្កួតប្រកាច់
បែកពពុះមាត់ និងកម្រោលចូលនោះ គឺកំពុងធ្វើបាបខ្លួនឯង ហើយអាចធ្វើ
ឱ្យអ្នកមកជិតគ្រោះថ្នាក់ទៀតផង។ ឈាមដែលហូរ រាងកាយដែលខូចទ្រង់
ទ្រាយ និងគំនិតដែលវង្វេងនោះ បានបង្ហាញនូវទស្សនីយភាពមួយ ដែល
គាប់ចិត្តដល់ស្តេចនៃសេចក្តីងងឹត។ អារក្សម្នាក់ក្នុងចំណោមអារក្ស
ទាំងឡាយដែលចូលគេ បាននិយាយថា «ទូលបង្គំឈ្មោះកងទ័ព ពីព្រោះ
យើងខ្ញុំមានគ្នាច្រើន»។ ម៉ាកុស ៥:៩។ ក្នុងកងទាហានរ៉ូម៉ាំង កងទ័ពមួយ
ពលមានទាហានចំនួនពីបីទៅប្រាំពាន់នាក់។ គ្រាន់តែឮបទបញ្ជាពីព្រះ
យេស៊ូវភ្លាម ពួកវិញ្ញាណអាក្រក់ក៏ចេញពីជនរងគ្រោះ ទុកឱ្យគេធូរស្រាល
មានបញ្ញាវាងវៃឡើងវិញ ហើយទន់ភ្លន់ផង។ ប៉ុន្តែ ពួកអារក្សបាននាំហ្វូង
ជ្រូកមួយហ្វូងចូលក្នុងទឹកសមុទ្រ ឯអ្នកស្រុកកាដារា បានឃើញការខូចខាត
នោះវាច្រើនជាងការទទួលព្រះពររបស់ព្រះគ្រីស្ទ ដូច្នេះគេបានសូមឱ្យលោក
គ្រូព្យាបាលដ៏ពិសិដ្ឋចេញពីទីនោះទៅ។ សូមអានម៉ាថាយ ៨:២៨-៣៤។ ដោយ
ចោទព្រះយេស៊ូវចំពោះការខាតបង់របស់ខ្លួន សាតាំងបានធ្វើឱ្យប្រជាជន

ភ័យខ្លាចដោយគិតដល់ប្រយោជន៍ផ្ទាល់ខ្លួន ហើយបានបង្ការគេមិនឱ្យស្តាប់ដល់ព្រះបន្ទូលរបស់ទ្រង់។

ព្រះគ្រីស្ទបានអនុញ្ញាតឱ្យពួកវិញ្ញាណអាក្រក់បំផ្លាញជ្រូក ដើម្បីជាសេចក្តីបន្ទោសដល់ពួកជូវ ដែលចិញ្ចឹមសត្វមិនស្អាតសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួន។ បើព្រះគ្រីស្ទពុំបានទប់ពួកអារក្សទេនោះ ហ្វូងជ្រូក អ្នកឃ្វាល និងម្ចាស់ជ្រូក នឹងត្រូវធ្លាក់ទៅក្នុងសមុទ្រទាំងអស់គ្នាទៅហើយ។

មួយសោតទៀត ព្រឹត្តិការណ៍ត្រូវបានអនុញ្ញាតឱ្យកើតឡើង ដើម្បីឱ្យពួកសាវ័កឃើញអំណាចឃោរឃៅរបស់សាតាំងលើមនុស្ស និងសត្វ ប្រយោជន៍កុំឱ្យគេចាញ់កលល្បិចរបស់វា ហើយក៏ជាព្រះហឫទ័យទ្រង់ដែរ ដើម្បីឱ្យប្រជាជនឃើញព្រះមហិទ្ធិឫទ្ធិរបស់ទ្រង់ ក្នុងការបណ្តាច់ចំណងរបស់សាតាំង ហើយដោះលែងអ្នកជាប់ឈ្លើយនោះ។ ទោះជាព្រះយេស៊ូវបានយាងចេញទៅហើយក្តី មនុស្សម្នាដែលបានរួចខ្លួនដោយការអស្ចារ្យនោះ បានរស់នៅដើម្បីថ្លែងប្រាប់សេចក្តីមេត្តាករុណានៃព្រះដ៏ជាមគ្គុរបស់គេ។

<u>ព្រហស្បតិ៍-៩ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១៤

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដោយសារសេចក្តីជំនឿ នោះនាងសារ៉ាក៏ទទួលអំណាចឲ្យមានគភ៌បង្កើតកូនបាន ហើយនាងបង្កើតកូនមក ក្នុងកាលដែលហួសអាយុហើយ ពីព្រោះនាងបានរាប់ព្រះដែលសន្យានោះ ទុកជាស្មោះត្រង់។ ហេព្រើរ ១១:១១*

មានព្រឹត្តិការណ៍ខ្លះទៀតដែលបានកត់ទុក៖ កូនស្រីនៃសាសន៍ស៊ីរ៉ូនេភីស ត្រូវបានរងទុក្ខជាខ្លាំងដោយអារក្សបិសាចមួយ ដែលព្រះយេស៊ូវបានបណ្តេញចេញដោយព្រះបន្ទូលទ្រង់ (ម៉ាកុស ៧:២៦-៣០) មានយុវជនម្នាក់ដែលខ្មោចចូល ហើយជូនបោះគាត់ទៅក្នុងភ្លើងក្នុងទឹកជាញយៗ ដើម្បី

នឹងបំផ្លាញគាត់ (ម៉ាកុស ៩:១៧-២៧) មនុស្សឆ្កួតម្នាក់ដែលបានរងទុក្ខ
វេទនាដោយវិញ្ញាណអារក្សអសោចមួយ ដែលរំខានដល់ភាពស្ងប់ក្សេមក្សាន្ត
នៃថ្ងៃសប្ប៉ាតហ៍នៅក្រុងកាពើណិម (លូកា ៤:៣៣-៣៦)។ គេទាំងអស់គ្នាត្រូវ
បានជាសះស្បើយដោយព្រះអង្គសង្គ្រោះ។ នៅស្ទើរតែគ្រប់ករណីទាំងអស់
ព្រះគ្រីស្ទបានមានបន្ទូលទៅពួកអារក្ស ក្នុងនាមដែលវាជារូបអង្គដ៏មាន
បញ្ញាមួយ ដោយបញ្ជាឱ្យឈប់ធ្វើទុក្ខទោសដល់ជនរងគ្រោះតទៅទៀត។
អ្នកថ្វាយបង្គំព្រះនៅកាពើណិម «ក៏នឹកស្ងើចក្នុងចិត្ត ទាំងសួរគ្នាថា តើពាក្យ
បែបយ៉ាងណានេះ ដែលលោកបង្គាប់ដល់វិញ្ញាណអសោច ដោយអំណាច
និងឫទ្ធិបាន ហើយវាក៏ចេញទៅដូច្នេះ?» (លូកា ៤:៣៦)។

ដោយព្រោះតែចង់បានអំណាចហួសពីធម្មជាតិនោះហើយ បានជា
អ្នកខ្លះទទួលយកឥទ្ធិពលរបស់សាតាំង។ ឥទ្ធិពលទាំងនេះ មិនមានការប៉ះ
ទង្គិចជាមួយពួកអារក្សអសោចទេ។ ក្នុងក្រុមនេះមានអ្នកដែលចេះទស្សន៍
ទាយ ដូចជាស៊ីម៉ូន មេគីស គ្រូគាថា អេលីម៉ាស និងស្ត្រីក្រមុំដែលបានតាម
សាវ័កប៉ុល និងស៊ីឡាស នៅឯក្រុងភីលីពជាដើម។ សូមអានកិច្ចការ
៨:៩,១៨; ១៣:៨; ១៦:១៦-១៨។

អ្នកដែលស្ថិតនៅក្នុងភាពគ្រោះថ្នាក់ជាងគេ គឺអស់អ្នកដែល
បដិសេធថាគ្មានអារក្ស និងពួកទេវតារបស់វា។ ពួកគេជាច្រើនបានស្តាប់
តាមយោបល់របស់ពួកវា ដោយស្មានថាគេស្តាប់តាមប្រាជ្ញាឈ្លាសវៃរបស់
ខ្លួន។ នៅពេលយើងខិតចូលទៅជិតគ្រាចុងបំផុត នាពេលដែលសាតាំងនឹង
ធ្វើការដោយអំណាចដ៏ខ្លាំងក្លាដើម្បីបោកបញ្ឆោតនោះ វានឹងធ្វើឱ្យគេជឿ
គ្រប់ទីកន្លែងថាគ្មានរូបវាទេ។ នយោបាយរបស់វាគឺដើម្បីលាក់ខ្លួនវា និង
របៀបវាធ្វើការ។

មេបញ្ឆោតដ៏ធំ ខ្លាចយើងស្គាល់ឧបាយកលរបស់វា។ ដើម្បីលាក់
ចរិតពិតប្រាកដរបស់វា វាបានធ្វើខ្លួនវា ឱ្យគេមើលទៅថាជាការលេងសើច
និងការសម្អប់។ វាសប្បាយចិត្តណាស់ នៅពេលគេគូររូបវាធ្វើជារូបកំប្លែង

រូបខ្ញុចរាងវៅ និងរូបសត្វពាក់កណ្តាល និងមនុស្សពាក់កណ្តាល។ វាសប្បាយចិត្តនឹងឮឈ្មោះវាប្រើក្នុងកីឡា និងការចំអកឡកឡឺយណាស់។ ដោយព្រោះវាបានគ្របមុខវាដោយជំនាញដ៏កំពូលដូចនេះ គេតែងតែសួរសំណួរនេះគ្រប់ទីកន្លែងថា៖ «តើមានតួអង្គនោះមែនឬទេ?» ពីព្រោះសាតាំងអាចគ្រប់គ្រងគំនិតនៃអ្នកដែលមិនដឹងពីឥទ្ធិពលរបស់វា បានជាព្រះបន្ទូលរបស់ព្រះបើកសម្តែងនៅមុខយើងឱ្យឃើញនូវកម្លាំងសម្ងាត់របស់វា ដើម្បីឱ្យយើងការពារខ្លួនបាន។

យើងអាចរកជម្រក និងការរំដោះបាន ក្នុងព្រះចេស្តាដ៏ឧត្តុង្គឧត្តមនៃព្រះដែលជាអ្នកប្រោសលោះ។ យើងចាក់ខ្នាស់ផ្ទះរបស់យើងដោយខ្លៅ និងសោ ដើម្បីការពារកម្មសិទ្ធិ និងជីវិតរបស់យើងពីមនុស្សអាក្រក់ ប៉ុន្តែកម្រគិតពីពួកទេវតាអាក្រក់ដែលបៀតបៀនយើង ដែលក្នុងកម្លាំងយើងៗមិនអាចការពារបានសោះឡើយ។ បើអនុញ្ញាត ពួកវាអាចរំខានគំនិតយើង វាយដំខ្លួនប្រាណយើង និងបំផ្លាញទ្រព្យសម្បត្តិ និងជីវិតរបស់យើងទៀតផង។ ប៉ុន្តែ អ្នកដែលដើរតាមព្រះគ្រីស្ទ គឺផុតពីទុក្ខភ័យហើយក្រោមការគាំពាររបស់ទ្រង់។ ពួកទេវតាដ៏មានមហិទ្ធិឫទ្ធិ ត្រូវបានបញ្ជូនឱ្យមកការពារគេ។ មនុស្សទុច្ចរិតមិនអាចឆ្លងកាត់អ្នកយាម ដែលព្រះបានដាក់នៅជុំវិញរាស្ត្ររបស់ទ្រង់ឡើយ។

របៀបយកជ័យជម្នះលើសាតាំង

<u>សុក្រ-១០ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១៥

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដូច្នេះ ក៏មានមនុស្ស១ហ្វូង ដូចផ្កាយនៅលើមេឃ ហើយដូចខ្សាច់នៅមាត់សមុទ្រ ដែលរាប់មិនចេះអស់ បានកើតមកអំពីមនុស្សតែម្នាក់ ដែលអ្នកនោះក៏ទុកដូចជាស្លាប់ហើយដែរ។*
ហេព្រើរ ១១:១២

មហាវិវាទរវាងព្រះគ្រីស្ទ និងសាតាំង នឹងត្រូវចប់ក្នុងពេលបន្តិចទៀត ហើយអាមេទុច្ឆរិតខំប្រឹងប្រើកម្លាំងមួយជាពីរ ដើម្បីជម្នះកិច្ចការដែលព្រះគ្រីស្ទធ្វើសម្រាប់មនុស្ស។ កម្មវត្ថុដែលវាចង់បានសម្រេចនោះ គឺដើម្បីក្តៅបក្តាប់ប្រជាជនក្នុងភាពងងឹត និងភាពរឹងរូស រហូតដល់ការសម្រុះសម្រួលរបស់ព្រះអង្គសង្គ្រោះត្រូវបានបញ្ចប់។ កាលណាមានសេចក្តីមិនអើពើក្នុងព្រះវិហារ សាតាំងវាមិនខ្វល់អ្វីឡើយ។ ប៉ុន្តែ នៅពេលមនុស្សសួរថា «តើឱ្យខ្ញុំធ្វើដូចម្តេចដើម្បីឱ្យបានសង្គ្រោះ?» នោះវាចាំក្នុងសៃវៀនហើយជាស្រេចដើម្បីប្រើអំណាចរបស់វាមកប្រកួតនឹងព្រះគ្រីស្ទ ហើយទប់ទល់នឹងឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ។

មានពេលមួយ នៅពេលពួកទេវតាបានយាងមកគាល់ព្រះវរបិតា សាតាំងក៏បានមកជាមួយពួកគេផងដែរ តែមិនមែនមកឱនគោរពព្រះមហាក្សត្រដ៏មាននៅអស់កល្បជានិច្ចទេ គឺមកដើម្បីគ្រោងគម្រោងការនៃសេចក្តីក្បាចទរបស់វា ទាស់នឹងអ្នកសុចរិតថែមទៀត។ សូមអានយ៉ូប ១:៦។ នៅពេលមនុស្សប្រជុំគ្នាថ្វាយបង្គំព្រះ វាក៏នៅទីនោះដែរ ខិតខំធ្វើការយ៉ាង

ស្វាហាប់ ដើម្បីគ្រប់គ្រងចិត្តគំនិតអ្នកក្រាបថ្វាយបង្គំទាំងឡាយ។ នៅពេល វាឃើញអ្នកនាំសាររបស់ព្រះបើករកបទគម្ពីរ វាកត់សម្គាល់មេរៀនដែលនឹង ត្រូវអធិប្បាយ។ បន្ទាប់មកវាប្រើល្បិច និងប្រាជ្ញាដ៏ប៉ិនប្រសប់របស់វា ដើម្បី ធ្វើកុំឱ្យដំណឹងនោះបានឮទៅដល់អ្នកដែលវាកំពុងបំភាន់។ អ្នកដែល ត្រូវការសេចក្តីព្រមានជាងគេនោះ នឹងត្រូវបានជំរុញឱ្យនឹកឃើញពីជំនួញ ឬនឹងត្រូវបានវាបង្ការមិនឱ្យឮព្រះបន្ទូល ដោយមធ្យោបាយផ្សេងទៀត។

សាតាំងឃើញអ្នកបម្រើរបស់ព្រះអម្ចាស់មានបន្ទុក ដោយព្រោះតែ ភាពងងឹតដែលគ្របបាំងប្រជាជន។ វាឮសេចក្តីបួងសួងរបស់គេ ទូលសូម នូវព្រះគុណ និងអំណាចពិសិដ្ឋ ដើម្បីរំលាយស្នេហ៍នៃភាពព្រងើយកន្តើយ និងភាពខ្ជិលច្រអូស។ បន្ទាប់មកដោយសេចក្តីស្វាហាប់ថ្មី វាល្បួងមនុស្សឱ្យ បណ្តោយខ្លួនទៅលើចំណីអាហារ ឬឱ្យបំប៉នខ្លួន ម្ល៉ោះហើយស្មារតីដឹងខ្លួន ត្រូវបានស្តឹក ធ្វើឱ្យគេពុំអាចឮនូវអ្វីដែលគេត្រូវការរៀនជាងគេ។

សាតាំងដឹងថា អស់អ្នកណាដែលមិនអើពើនឹងការអធិស្ឋាន និងការ អានបទគម្ពីរ នឹងចាញ់ការវាយសង្គ្រប់របស់វាហើយ។ ដូច្នេះវាបង្កើត ឧបាយកលគ្រប់យ៉ាង ដើម្បីធ្វើឱ្យគេស្លុងផុងគំនិត។ សេនាដៃស្តាំរបស់វា គឺមមាញឹកជាប់ នៅពេលព្រះប្រកបកិច្ចការ។ ពួកវានឹងធ្វើឱ្យគេឃើញថា អ្នក បម្រើរបស់ព្រះគ្រីស្ទដែលឧស្សាហ៍ ហើយស្ងួលៈបង់ខ្លួន ត្រូវបានគេបញ្ឆោត ឬជាពួកបោកបញ្ឆោតគេវិញ។ កិច្ចការរបស់ពួកវា គឺដើម្បីមូលបង្កាច់បំណាង ល្អក្នុងអស់ទាំងអំពើល្អ និងផ្សព្វផ្សាយពាក្យដៀមដាម ធ្វើឱ្យមានសេចក្តី សង្ស័យក្នុងគំនិតអ្នកដែលខ្វះការពិសោធ។ ប៉ុន្តែ យើងគង់តែដឹងថាគេជា កូនចៅអ្នកណា ដើរតាមគំរូអ្នកណា ហើយប្រកបកិច្ចការរបស់អ្នកណា ហើយ។ «អ្នករាល់គ្នានឹងស្គាល់គេបាន ដោយសារផលគេបង្កើត»។ សូម អានម៉ាថាយ ៧:១៦ និងវិវរណៈ ១២:១០។

សេចក្តីពិតញែកឱ្យបរិសុទ្ធ

មេបញ្ឆោតដ៏ធំមានគោលលទ្ធិបែកឆ្វេងច្រើនណាស់ រៀបចំទុកឱ្យ

អ្នកដែលវានឹងបំផ្លាញដែលមានចំណូលចិត្តប្លែកៗពីគ្នា។ គម្រោងការរបស់វា គឺដើម្បីនាំមកក្នុងក្រុមជំនុំនូវសេចក្តីមិនស្មោះត្រង់ ធាតុដែលមិនចម្រើនលូតលាស់ ដែលធ្វើឱ្យមានការសង្ស័យ និងការមិនជឿ។ ជនភាគច្រើនដែលឥតមានជំនឿពិតប្រាកដទៅលើព្រះ ដែលធ្វើឱ្យមានការសង្ស័យ និងការមិនជឿ។ ជនភាគច្រើនដែលឥតមានជំនឿពិតប្រាកដទៅលើព្រះ បានតោងទៅនឹងគោលការនៃសេចក្តីពិតខ្លះ ហើយរាប់ខ្លួនថាជាអ្នកគ្រីស្ទាន ដូច្នេះហើយក៏អាចបង្កើតសេចក្តីខុសឆ្គង ហើយយកសេចក្តីខុសឆ្គងនោះមកធ្វើជាគោលលទ្ធិនៃបទគម្ពីរ។ សាតាំងដឹងថា សេចក្តីពិត កាលបើបានទទួលក្នុងសេចក្តីមេត្រី នោះនឹងញែកព្រលឹងឱ្យទៅជាបរិសុទ្ធ។ ម្ល៉ោះហើយ វាសង្វាតរកទ្រឹស្តីមិនពិត រឿងប្រឌិត និងដំណឹងដទៃយកមកប្តូរ។ តាំងតែពីដើមមក អ្នកបម្រើទាំងឡាយរបស់ព្រះបានប្រជែងជាមួយនឹងគ្រូក្លែងក្លាយដែលមិនមែនគ្រាន់តែជាមនុស្សកាចសាហាវទេ តែជាអ្នកបង្រៀនអប់រំសេចក្តីមិនពិតដែលគ្រោះថ្នាក់ដល់ជីវិតមនុស្ស។ ហោរាអេលីយ៉ា យេរេមា និងសាវ័កប៉ុល បានជំទាស់យ៉ាងខ្លាំងនឹងអ្នកដែលបង្វែរមនុស្សពីព្រះបន្ទូលរបស់ព្រះ។ ភាពសេរីនិយមដែលចាត់ទុកថាជំនឿដ៏ត្រឹមត្រូវគ្មានសារៈសំខាន់នោះ ឃើញថាផ្ទុយស្រឡះពីអ្នកការពារនៃសេចក្តីពិតដ៏បរិសុទ្ធទាំងនេះ។

<u>សៅរ៍-១១ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១៦

ខព្រះគម្ពីរប្រចាំសប្តាហ៍: *ពួកអ្នកទាំងនោះបានស្លាប់ក្នុងសេចក្តីជំនឿ ឥតទទួលសេចក្តីដែលបានសន្យាទាំងប៉ុន្មានទេ តែគេបានឃើញពីចំងាយ ហើយក៏ទទួលគំនាប់ដែរ ទាំងយល់ព្រមថា ខ្លួនគេជាអ្នកដទៃ ដែលគ្រាន់តែសំណាក់នៅផែនដីប៉ុណ្ណោះ។ ហេព្រើរ ១១:១៣*

ការបកស្រាយបទគម្ពីរដ៏ស្រពេចស្រពិលហើយក្បាច់ក្បួរ និងទ្រឹស្តី

ដែលផ្ទុយគ្នាក្នុងពិភពគ្រីស្ទាន គឺជាកិច្ចការនៃមហាសត្រូវរបស់យើង ដើម្បីបំភាន់គំនិត។ ការមិនចុះសម្រុងនឹងគ្នា និងការបែកជាបក្ខពួកក្នុងព្រះវិហារទាំងឡាយ គឺភាគច្រើនកើតឡើងដោយសារតែការមូលបង្កាច់បទគម្ពីរ ដើម្បីគាំទ្រទ្រឹស្តីណាមួយដែលគេចូលចិត្ត។

ដើម្បីលើកស្ទួយគោលលទ្ធិមិនត្រឹមត្រូវនោះ ខ្លះយកខគម្ពីរខុសពីអត្ថន័យទាំងមូល ដោយលើកយកតែកន្លះខមកបញ្ជាក់ចំណុចរបស់ខ្លួន តែកន្លះខទៀត បង្ហាញន័យផ្ទុយស្រឡះពីនោះទៅវិញ។ គេតាំងគោលជំហររបស់គេដោយប្រើខតែពាក់កណ្តាល ដើម្បីពន្យល់ឱ្យសមនឹងសេចក្តីប្រាថ្នារបស់មនុស្សជាតិ ដោយភាពបិនប្រសប់នៃសត្វពស់។ ខ្លះទៀត គោងយករូបភាព និងអត្ថាបដិរូប ហើយបកស្រាយតាមតែគេនឹកឃើញ ដោយឱ្យតម្លៃតិចតួចណាស់ដល់ទីបន្ទាល់នៃបទគម្ពីរជាអ្នកបកស្រាយ ហើយក្រោយមកគេបញ្ចេញយោបល់របស់គេថាជាសេចក្តីបង្រៀននៃព្រះគម្ពីរ។

គម្ពីរចាំងមូលជាមគ្គុទ្ទេសក៍

នៅពេលណាគេសិក្សាបទគម្ពីរដោយឥតអធិស្ឋាន ហើយគ្មានចិត្តជាសិស្សនោះ ឃ្លាដ៏ស្រួលយល់បំផុតនឹងត្រូវបានបង្កាច់ពីន័យពិតប្រាកដ។ ព្រះគម្ពីរទាំងមូល គួរតែបានយល់ដល់មនុស្សតាមតែពាក្យដែលចែងមក។

ព្រះបានប្រទានបទទំនាយដ៏ច្បាស់ ពួកទេវតា និងព្រះគ្រីស្ទផងដែរបានយាងមកបើកសម្តែងឱ្យដានីយ៉ែល និងយ៉ូហានដឹងនូវអ្វីដែល «បន្តិចទៀតត្រូវកើតមានមក»។ វិវរណៈ ១:១។ រឿងរ៉ាវសំខាន់ៗស្តីពីសេចក្តីសង្គ្រោះរបស់យើង ពុំមែនបានសម្តែងឱ្យឃើញ ក្នុងរបៀបឱ្យវង្វេងស្មុគស្មាញដល់អ្នកស្វែងរកសេចក្តីពិតនោះទេ។ ព្រះបន្ទូលរបស់ព្រះគឺងាយយល់ចំពោះអស់អ្នកដែលសិក្សាដោយមានចិត្តអធិស្ឋាន។

ដោយស្រែកចង់បានភាពសេរីនិយម មនុស្សទៅជាងងឹតមើលមិនឃើញឧបាយកលទាំងឡាយនៃសត្រូវរបស់ខ្លួន។ វាបានជោគជ័យដោយយកការស្មានរបស់មនុស្ស មកជំនួសគម្ពីរ។ គេបានបំភ្លេចក្រឹត្យវិន័យរបស់

ព្រះ ហើយវិហារត្រូវស្ថិតនៅក្រោមចំណងនៃបាបកម្ម ក្នុងពេលដែលគេអះអាងថាមានសេរីភាពហើយ។

ព្រះបានអនុញ្ញាតឱ្យមានចំណេះដ៏បរិបូរ ធ្លាក់មកលើផែនដី ក្នុងការស្រាវជ្រាវខាងវិទ្យាសាស្ត្រ។ ប៉ុន្តែ ទោះជាគំនិតនោះឧត្តុង្គឧត្តមក៏ដោយ បើមិនបានដឹកនាំដោយព្រះបន្ទូលរបស់ព្រះទេ ប្រាកដជាភាន់ច្រឡំក្នុងការព្យាយាមរកទំនាក់ទំនងរវាងវិទ្យាសាស្ត្រ និងការបើកសម្តែងរបស់ព្រះជាមិនខាន។

តម្រិះវិជ្ជារបស់មនុស្ស គឺតិចតួចហើយមិនគ្រប់លក្ខណៈ ម្ល៉ោះហើយបានជាភាគច្រើន មិនអាចសម្របទស្សនៈនៃវិទ្យាសាស្ត្ររបស់ខ្លួន ជាមួយនឹងបទគម្ពីរបាន។ ភាគច្រើនបានទទួលយកទ្រឹស្តីថាជាសេចក្តីពិតនៃវិទ្យាសាស្ត្រ ហើយគេគិតថាព្រះបន្ទូលរបស់ព្រះ គឺនឹងត្រូវសាកល្បងដោយ «សេចក្តីក្លែង ហៅថាចំណេះវិជ្ជា»។ ធីម៉ូថេទី១ ៦:២០។ ដោយព្រោះគេមិនអាចពន្យល់ព្រះអាទិករ និងកិច្ចការរបស់ទ្រង់ដោយច្បាប់ធម្មជាតិបាន ប្រវត្តិសាស្ត្រគម្ពីរត្រូវបានគេចាត់ទុកថាជាឥតប្រយោជន៍ទៅវិញ។ អ្នកដែលសង្ស័យទៅលើគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ច្រើនតែហួសទៅមួយជំហានទៀត ហើយសង្ស័យពីវត្តមានរបស់ព្រះ។ បន្ទាប់ពីទម្លាក់យុថ្កាគេចុះ គេអណ្តែតតែលតោល បោកទង្គិចថ្មនៃសេចក្តីខ្វះជំនឿ។

ស្នាដៃនៃសេចក្តីបញ្ឆោតរបស់សាតាំង គឺដើម្បីឱ្យមនុស្សបញ្ចេញយោបល់ឥតភ័ស្តុតាង ក្នុងសេចក្តីដែលព្រះពុំបានបើកឱ្យយល់។ លូស៊ីហ្វើរបានក្លាយទៅជាមិនស្កប់ចិត្ត ពីព្រោះអស់ទាំងសេចក្តីសម្ងាត់នៃគម្រោងការរបស់ព្រះ ពុំបានចែករំលែកដល់វា ហើយវាមិនបានគោរពនូវអ្វីដែលបានបើកសម្តែងឱ្យយល់ឡើយ។ ឥឡូវនេះ វាប្រឹងបណ្តុះបណ្តាលចិត្តមនុស្ស ដោយកិរិយាដូចគ្នា ហើយនាំគេឱ្យបដិសេធសេចក្តីបញ្ជាផ្ទាល់របស់ព្រះ។

<u>អាទិត្យ-១២ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១៧

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដោយសារសេចក្តីជំនឿ នោះយ៉ូសែបបានប្រាប់ពីដំណើរពួកជនជាតិអ៊ីស្រាអែល ដើរចេញពីស្រុកអេស៊ីព្ទ ក៏ផ្តាំពីដំណើរសពរបស់ខ្លួន ក្នុងកាលដែលហៀបនឹងផុតដង្ហើមទៅផង។ ហេព្រើរ ១១:២២*

សេចក្តីពិតត្រូវបានបដិសេធ ព្រោះទាក់ទងនឹងឈើឆ្កាង

ការដែលគេសម្តែងគោលលទ្ធិដោយខ្វះព្រះវិញ្ញាណ និងសេចក្តីលះបង់ខ្លួនប៉ុណ្ណានោះ មនុស្សម្នាក៏រីករាយនឹងទទួលប៉ុណ្ណោះដែរ។ សាតាំងវាតែងចាំឧបត្ថម្ភនូវអ្វីដែលចិត្តប៉ងប្រាថ្នា ហើយនិងដាក់សេចក្តីបញ្ឆោតជួសសេចក្តីពិតវិញ។ វិធីនេះហើយដែលលទ្ធិកាតូលិករ៉ូមបានកេងអំណាចលើគំនិតមនុស្ស។ ហើយដោយបដិសេធសេចក្តីពិត ព្រោះមានការទាក់ទងនឹងឈើឆ្កាង ពួកប្រូតេស្តង់គឺកំពុងតែដើរតាមគន្លងផ្លូវដូចគ្នាហើយ។ អស់អ្នកណាដែលសិក្សាផ្លូវស្រណុកស្រួល និងមធ្យោបាយ ដើម្បីឱ្យគេបានស្របជាមួយនឹងលោកីយ៍ នឹងត្រូវទុកឱ្យទទួល «សេចក្តីវិនាសដ៏ឆាប់រហ័ស» មកធ្វើជាសេចក្តីពិតវិញ។ ពេត្រុសទី២ ២:១។ អ្នកដែលមើលទៅសេចក្តីបញ្ឆោតណាមួយដោយសេចក្តីភ័យរន្ធត់ នឹងត្រូវបានទទួលសេចក្តីបញ្ឆោតមួយទៀត។ «ហេតុនោះបានជាព្រះទ្រង់នឹងឱ្យសេចក្តីខុសឆ្គងមក បណ្តាលឱ្យគេជឿតាមសេចក្តីភូតភរវិញ ដើម្បីឱ្យមនុស្សណាដែលមិនជឿតាមសេចក្តីពិត គឺពេញចិត្តនឹងសេចក្តីទុច្ចរិត នោះបានជាប់មានទោសវិញ»។ ថែស្សាឡូនីចទី២ ២:១១,១២។

កំហុសដ៏គ្រោះថ្នាក់

ក្នុងចំណោមភ្នាក់ងារដ៏ពូកែបំផុតរបស់មេបញ្ឆោត គឺមានការអស្ចារ្យដ៏កំភូតនៃវិញ្ញាណខន្ធនិយម។ នៅពេលមនុស្សបដិសេធសេចក្តីពិត គេនឹងក្លាយទៅជាចំណីនៃការបញ្ឆោតវិញ។

កំហុសមួយទៀត គឺគោលលទ្ធិដែលបដិសេធព្រះគ្រីស្ទថាមិនមែន

ជាព្រះ ដោយអះអាងថាទ្រង់ឥតមានព្រះជន្មរស់នៅ កាលទ្រង់ពុំទាន់យាងមកផែនដីនេះ។ ទ្រឹស្តីនេះគឺផ្ទុយនឹងព្រះបន្ទូលនៃព្រះអង្គសង្គ្រោះរបស់យើង ស្តីពីទំនាក់ទំនងរវាងព្រះវរបិតា និងការដែលទ្រង់មានព្រះជន្មរស់នៅតាំងតែពីមុនមក។ វាធ្វើឱ្យខ្សត់ខ្សោយខាងឯជំនឿក្នុងព្រះគម្ពីរដែលជាការបើកសម្តែងមកពីព្រះ។ បើមនុស្សបដិសេធទីបន្ទាល់នៃបទគម្ពីរស្តីពីព្រះគ្រីស្ទជាព្រះ ការជជែកជាមួយគេ នោះគឺឥតប្រយោជន៍ទេ ព្រោះគ្មានសេចក្តីវែកញែកណា នឹងអាចពន្យល់គេឱ្យបានយល់ដាច់ស្រេចឡើយ ទោះបីជាច្បាស់យ៉ាងណាក៏ដោយ។ គ្មានអ្នកណាម្នាក់ដែលកាន់សេចក្តីខុសនេះ អាចយល់ដឹងពីព្រះគ្រីស្ទពិតប្រាកដ ឬពីគម្រោងការរបស់ព្រះសម្រាប់ការប្រោសលោះរបស់មនុស្សបានឡើយ។

កំហុសមួយទៀត គឺជំនឿដែលថាសាតាំងពុំមែនជាតួអង្គមានជីវិត ហើយថាឈ្មោះដែលប្រើក្នុងបទគម្ពីរនោះ គ្រាន់តែសម្រាប់តំណាងគំនិតអាក្រក់ និងសេចក្តីប៉ងប្រាថ្នារបស់មនុស្សប៉ុណ្ណោះ។

សេចក្តីបង្រៀនដែលថា ការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ គឺជាការយាងមកដល់បុគ្គលម្នាក់ៗនៅពេលស្លាប់ទៅនោះ គឺជាមធ្យោបាយមួយដើម្បីបង្វែរគំនិតពីការយាងមកផ្ទាល់របស់ទ្រង់ក្នុងពពកនៅលើអាកាសទេ។ ដូច្នេះសាតាំងបាននិយាយថា «មើល ទ្រង់គង់នៅក្នុងបន្ទប់» (សូមអានម៉ាថាយ ២៤:២៣-៣៦) ហើយមនុស្សជាច្រើនត្រូវបានបាត់បង់ ដោយជឿដល់ការបោកបញ្ឆោតនេះ។

អ្នកវិទ្យាសាស្ត្រអះអាងថា មិនអាចមានចម្លើយពិតប្រាកដសម្រាប់ការអធិស្ឋានសោះឡើយថាបាដិហារ្យជាអំពើរំលងច្បាប់ ហើយបាដិហារ្យគឺគ្មានទេ។ គេពោលថា ពិភពសកលគឺត្រូវបានគ្រប់គ្រងដោយច្បាប់ឥតផ្លាស់ប្តូរ ហើយព្រះមិនប្រព្រឹត្តអ្វីដែលផ្ទុយនឹងច្បាប់ទាំងនេះទេ។ ដូច្នេះគេចាត់ទុកថា ព្រះស្ថិតនៅក្រោមច្បាប់របស់ព្រះអង្គផ្ទាល់ ធ្វើដូចជាច្បាប់របស់ព្រះអាចរារាំងសេរីភាពរបស់ទ្រង់បានដូច្នោះ។

តើព្រះគ្រីស្ទ និងពួកសាវ័កទ្រង់ពុំបានធ្វើបដិហារ្យទាំងឡាយទេឬ
អី? ព្រះអង្គសង្គ្រោះដដែលនៅតែសព្វព្រះទ័យចង់ស្តាប់ការអធិស្ឋាននៃ
សេចក្តីជំនឿ ដូចកាលដែលទ្រង់បានយាងក្នុងចំណោមមនុស្សដែរ។ ធម្មជាតិ
ធ្វើសហការជាមួយអធិធម្មជាតិ។ គម្រោងការមួយផ្នែករបស់ព្រះ គឺទ្រង់
ឆ្លើយតបដល់ការអធិស្ឋានដោយជំនឿ ដើម្បីប្រទានឱ្យយើងនូវអ្វីដែលយើង
សូម។

<u>ចន្ទ-១៣ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១៨

ខព្រះគម្ពីរប្រចាំថ្ងៃ: *អើហ្ន៎ប្រាជ្ញា និងចំណេះដ៏បរិបូររបស់ព្រះជ្រៅណាស់តើ
ឯព្រះជំរិះរបស់ទ្រង់ តើមានអ្នកណានឹងស្ទង់បាន ហើយផ្លូវទ្រង់ តើមានអ្នក
ណានឹងរកតាមបាន ។ រ៉ូម ១១:៣៣*

គោលនៃព្រះបន្ទូល

គោលលទ្ធិមិនពិតក្នុងចំណោមវិហារទាំងឡាយ រំលើងចេញនូវគោល
ដែលដោតភ្ជាប់ដោយព្រះបន្ទូលរបស់ព្រះ។ បន្ទាប់ពីបដិសេធសេចក្តីពិត
មួយហើយ មានតិចតួចណាស់ដែលបដិសេធតទៅទៀត។ ភាគច្រើនជាត់
គោលការនៃសេចក្តីពិតចោលម្តងមួយៗ រហូតដល់ក្លាយទៅជាអ្នកមិនជឿ។

កំហុសទាំងប៉ុន្មាននៃសាសនវិទ្យាល្បីៗ បានធ្វើឱ្យជនជាច្រើនមាន
ចិត្តសង្ស័យ។ គេមិនអាចទទួលគោលលទ្ធិ ដែលទ្រគោះដុកដាន់ដល់
សេចក្តីយល់ដឹងអំពីយុត្តិធម៌ មេត្តាធម៌ និងសប្បុរសធម៌របស់ខ្លួនបានឡើយ។
ដោយគុណធម៌ទាំងនេះត្រូវបានតំណាងសេចក្តីបង្រៀននៃព្រះគម្ពីរ គេមិន
ព្រមទទួលស្គាល់ថាជាព្រះបន្ទូលរបស់ព្រះឡើយ។

គេមើលព្រះបន្ទូលរបស់ព្រះដោយមិនទុកចិត្ត ពីព្រោះព្រះបន្ទូល
នោះស្តីប្រដៅ និងថ្កោលទោសអំពើបាប។ អ្នកដែលទទឹងមិនស្តាប់តាម
ខំព្យាយាមបង្ហាប់បង្អោនឫទ្ធិអំណាចនៃព្រះបន្ទូលទាំងនោះ។ អ្នកដែលបាន

ក្លាយទៅជាមិនជឿ ដើម្បីដោះសាសេចក្តីខ្ជីខ្ជាំនៃកិច្ចដែលត្រូវធ្វើនោះគឺមិនមែនមានតិចតួចទេ។ ខ្លះទៀត ដោយស្រឡាញ់សេចក្តីស្រណុកពេក មិនចង់សម្រេចការងារអ្វីៗ ដែលត្រូវការការលះបង់ខ្លួននោះឡើយ ហើយចាត់ទុកថាខ្លួនមានប្រាជ្ញាខ្ពង់ខ្ពស់ដោយពូកែទិតៀនព្រះគម្ពីរ។ ភាគច្រើននឹកគិតក្នុងចិត្តថា ជាគុណធម៌មួយដែលគេមានចិត្តមិនជឿ ចិត្តសង្ស័យ និងចិត្តមិនស្មោះត្រង់។ អាការៈខាងក្រៅរបស់គេ មើលទៅដូចជាប្រកបទៅដោយសេចក្តីស្មោះត្រង់ ប៉ុន្តែ នៅក្នុងចិត្តគេវិញ គេគិតថាខ្លួនគ្រាន់បើហើយមានឫកខ្ពស់ទៀតផង។ ភាគច្រើនសប្បាយនឹងរកចំណុចអ្វីមួយក្នុងបទគម្ពីរដើម្បីបំភាន់គំនិតអ្នកដទៃ។ អ្នកខ្លះចាប់ផ្តើមវែកញែកទៅផ្លូវខុសសិន ដោយព្រោះតែ ចូលចិត្តនឹងសេចក្តីវិវាទ។ ប៉ុន្តែ ដោយសម្តែងចិត្តមិនជឿឱ្យគេដឹងឮ នោះឈ្មោះថាគេរួបរួមជាមួយនឹងអ្នកឥតមានព្រះនៅក្នុងខ្លួនហើយ។

ភ័ស្តុតាងគ្រប់គ្រាន់

ព្រះបានប្រទានភ័ស្តុតាងគ្រប់គ្រាន់ហើយអំពីចរិតលក្ខណៈដ៏ពិសិដ្ឋក្នុងព្រះបន្ទូលទ្រង់។ តែគំនិតខ្លីរបស់មនុស្ស ពុំអាចយល់ពេញលេញនូវគោលបំណងនៃព្រះអនន្តឡើយ។ «ឯតម្រិះរបស់ទ្រង់តើអ្នកណានឹងស្ទង់បាន ហើយផ្លូវទ្រង់តើអ្នកណានឹងរកតាមបាន»។ រ៉ូម ១១:៣៣។ យើងអាចយល់សេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណាដ៏គ្មានព្រំដែន ដែលបានរួបរួមទៅនឹងឥទ្ធិឫទ្ធិដ៏គ្មានទីបំផុតបាន។ ព្រះវរបិតានៃស្ថានសួគ៌នឹងសម្តែងឱ្យយើងឃើញ តាមតែទ្រង់សព្វព្រះទ័យថាល្អសម្រាប់យើង អ្វីៗហួសពីនោះយើងត្រូវទុកចិត្តលើព្រះដ៏ប្រកបដោយសព្វានុភាព និងដោយព្រះទ័យពោរពេញដោយសេចក្តីស្រឡាញ់ចុះ។

ព្រះនឹងមិនបំបាត់អស់ទាំងសេចក្តីដោះសា ដែលបណ្តាលឱ្យមានចិត្តមិនជឿនោះឡើយ។ អស់អ្នកណាដែលសម្លឹងរកទំពក់សម្រាប់ព្យួរសេចក្តីសង្ស័យ នឹងរកបានជាប្រាកដ។ ហើយអ្នកណាដែលមិនព្រមគោរពតាម ហើយចាំដល់សេចក្តីជំទាស់ទាំងប៉ុន្មានត្រូវបានរំលើងចេញអស់ទៅ

នោះ នឹងមិនដែលខិតមកឯពន្លឺឡើយ។ ចិត្តដែលមិនបានផ្លាស់ប្រែជាថ្មី គឺស្ថិតក្នុងភាពជាខ្មាំងនឹងព្រះ។ ប៉ុន្តែ សេចក្តីជំនឿត្រូវបានបណ្តុះបណ្តាលដោយព្រះវិញ្ញាណបរិសុទ្ធ ហើយនឹងលូតលាស់ឡើងនៅពេលមានការថ្នាក់ថ្នមថែរក្សា។ គ្មានបុគ្គលណាអាចទៅជារឹងមាំក្នុងសេចក្តីជំនឿដោយគ្មានការខិតខំតស៊ូនោះទេ។ ប្រសិនបើមនុស្សអនុញ្ញាតខ្លួនឱ្យរកឃើញរកហេតុដែលមិនសមរម្យនោះគេនឹងឃើញថា គេកាន់តែមានការសង្ស័យច្រើនថែមទៀត។

<u>អង្គារ-១៤ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ១៩

ខព្រះគម្ពីរប្រចាំថ្ងៃ: *នោះទេវតាប្រាប់មកខ្ញុំថា នេះជាព្រះបន្ទូលដែលព្រះយេហូវ៉ាមានព្រះបន្ទូលដល់សូរ៉ូបាបិល គឺព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានព្រះបន្ទូលថា មិនមែនដោយឥទ្ធិឫទ្ធិ ឬដោយអំណាចទេ គឺដោយសារវិញ្ញាណរបស់អញវិញ។ សាការី ៤:៦*

ប៉ុន្តែ អ្នកដែលសង្ស័យ និងមិនទុកចិត្តចំពោះសេចក្តីធានាអះអាងនៃព្រះគុណរបស់ទ្រង់ គឺបង្អាប់កិត្តិយសព្រះគ្រីស្ទហើយ។ គេជាដើមឈើដែលឥតបង្កើតផលផ្លែ ដែលបាំងពន្លឺថ្ងៃពីដើមរុក្ខជាតិនានា ធ្វើឱ្យស្រពោនងាប់ក្រោមម្លប់។ កិច្ចការប្រចាំជីវិតរបស់ជនទាំងនេះ នឹងមើលទៅដូចជាទីបន្ទាល់ដ៏ឥតឈប់ឈរទាស់នឹងខ្លួនគេ។

មានតែផ្លូវមួយគត់ ចំពោះអ្នកដែលចង់សង្ឃាតទៅមុខយ៉ាងអស់ពីចិត្តឱ្យបានរួចពីសេចក្តីសង្ស័យ គឺជាជាងសូរចង់ដឹងនូវអ្វីដែលគេមិនយល់ ចូរឱ្យគេចាប់អារម្មណ៍ដល់ពន្លឺដែលចាំងជះមកលើគេរួចហើយនោះវិញ នោះគេនឹងទទួលពន្លឺខ្លាំងជាងមុនទៅទៀត។

សាតាំងអាចបង្ហាញការក្លែងបន្លំដែលស្រដៀងនឹងសេចក្តីពិត ហើយបញ្ឆោតអ្នកដែលចង់ឱ្យគេបញ្ឆោត ជាអ្នកដែលប្រាថ្នាចង់ជៀសពី

សេចក្តីលះបង់ ដែលសេចក្តីពិតទាមទារ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ វាមិនអាចប្រើអំណាចរបស់វា ដើម្បីក្តោបក្តាប់បុគ្គលណាម្នាក់ ដែលប្រាថ្នាចង់ដឹងសេចក្តីពិតដ៏អស់ពីចិត្តបានឡើយ។ ព្រះគ្រីស្ទគឺជាសេចក្តីពិត «ជាពន្លឺដែលបំភ្លឺដល់មនុស្សទាំងអស់ដែលកើតមកក្នុងលោកីយ៍»។ «បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងថាសេចក្តីបង្រៀននេះមកពីព្រះ»។ យ៉ូហាន ១:៩; ៧:១៧។

ព្រះអម្ចាស់អនុញ្ញាតឱ្យរាស្ត្រទ្រង់ស្ថិតនៅក្នុងការពិសោធនៃសេចក្តីល្បួងដ៏យ៉ាប់យឺន ពុំមែនព្រោះទ្រង់សព្វព្រះទ័យនឹងឃើញការរងទុក្ខរបស់គេនោះទេ តែព្រោះជាការចាំបាច់សម្រាប់ជ័យជម្នះចុងក្រោយរបស់គេ។ ទ្រង់ពុំអាចការពារគេពីសេចក្តីល្បួងដោយប្រើសិរីល្អរបស់ទ្រង់គ្រប់ពេលវេលានោះទេ ព្រោះកម្មវត្ថុនៃគ្រាលំបាកនោះ គឺដើម្បីរៀបចំគេឱ្យទប់ទល់នឹងអស់ទាំងគ្រឿងបញ្ឆោតនៃសេចក្តីអាក្រក់។ គ្មានមនុស្សទុច្ចរិត ឬអារក្សសាតាំងណាអាចបិទវត្តមានរបស់ព្រះពីរាស្ត្ររបស់ទ្រង់បានឡើយ បើគេសារភាពហើយបោះចោលអំពើបាបរបស់គេ ហើយអះអាងសូមសេចក្តីសន្យារបស់ទ្រង់។ គ្រប់ទាំងសេចក្តីល្បួង ទោះនៅខាងក្រៅឬសម្ងាត់ខាងក្នុងក្តី គឺនឹងអាចទប់ទល់បាន «មិនមែនដោយឥទ្ធិឫទ្ធិ ឬដោយអំណាចទេ គឺដោយវិញ្ញាណរបស់អញវិញ»។ សាការី ៤:៦។

«បើអ្នករាល់គ្នាប្រព្រឹត្តការល្អ នោះតើមានអ្នកណានឹងធ្វើបាបដល់អ្នករាល់គ្នា?» ពេត្រុសទី១ ៣:១៣។ សាតាំងដឹងច្បាស់ណាស់ថា មនុស្សកម្សោយបំផុតដែលនៅជាប់ក្នុងព្រះគ្រីស្ទ គឺខ្លាំងហួសពីគូប្រយុទ្ធនឹងពួកពលបរិវារនៃសេចក្តីងងឹតទៅទៀត។ ដូច្នេះ វាសង្វាតទាក់ទាញកងទាហាននៃឈើឆ្កាងពីបន្ទាយដ៏រឹងមាំរបស់គេ ហើយពូនស្នាក់ចាំវាយបំផ្លាញអស់អ្នកណាដែលដើរក្នុងទីរបស់វា។ មានតែការពឹងពាក់ទៅលើព្រះ និងការស្តាប់បង្គាប់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់ទេ ទើបយើងអាចគេចផុតពីទុក្ខភ័យបាន។

គ្មានមនុស្សណាផុតពីគ្រោះថ្នាក់ ក្នុងពេញមួយថ្ងៃ ឬមួយម៉ោង ដោយគ្មានការអធិស្ឋានឡើយ។ ចូរអង្វរករដល់ព្រះវរបិតា សូមប្រាជ្ញាដើម្បីឱ្យបានយល់អំពីព្រះបន្ទូលរបស់ទ្រង់ចុះ។ សាតាំងគឺជាជើងឯកខាងលើកបទគម្ពីរ ហើយដាក់យោបល់របស់វាក្នុងឃ្លាទាំងឡាយ ដោយសង្ឃឹមថានឹងធ្វើឱ្យយើងជំពប់ដួល។ យើងត្រូវសិក្សាដោយមានចិត្តសុភាព។ ក្នុងពេលដែលយើងត្រូវការពារខ្លួនជានិច្ចពីឧបាយកលទាំងឡាយរបស់សាតាំង យើងត្រូវអធិស្ឋានក្នុងសេចក្តីជំនឿដោយឥតឈប់ឈរថា៖ «សូមកុំនាំយើងខ្ញុំទៅក្នុងសេចក្តីល្បួងឡើយ»។ ម៉ាថាយ ៦:១៣។

ហួសពីផ្នូរនៅមានអ្វីទៀត?

<u>ពុធ-១៥ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ២០

ខព្រះគម្ពីរប្រចាំថ្ងៃ:*ដោយសារសេចក្តីជំនឿ នោះគេបានដើរកាត់សមុទ្រក្រហម ដូចជាដើរលើដីគោក តែកាលពួកសាសន៍អេស៊ីព្ទបានល្បងល នោះគេក៏ត្រូវលេបបាត់ទៅ។ ហេព្រើរ ១១:២៩*

សាតាំងដែលបានបំផុសបំផុលឱ្យមានការបះបោរនៅស្ថានសួគ៌ ប្រាថ្នាចង់អូសទាញអ្នករស់នៅលើផែនដី ឱ្យរួបរួមនៅក្នុងសង្គ្រាមជាមួយវាប្រឆាំងនឹងព្រះ។ លោកអ័ដាម និងនាងអេវ៉ា តែងរីករាយក្នុងការស្តាប់បង្គាប់ចំពោះក្រឹត្យវិន័យរបស់ព្រះ ជាទីបន្ទាល់ប្រឆាំងនឹងការអះអាងដែលសាតាំងបានលើកឡើងនៅស្ថានសួគ៌ថា ក្រឹត្យវិន័យរបស់ព្រះប្រកបដោយការសង្កត់សង្កិន។ សាតាំងបានប្តេជ្ញាធ្វើឱ្យពួកគេធ្លាក់ចុះ នោះវានឹងអាចគ្រប់គ្រងផែនដី ព្រមទាំងកសាងអាណាចក្ររបស់វានៅទីនេះ ដើម្បីប្រឆាំងនឹងព្រះដ៏ខ្ពស់បំផុត។

លោកអ័ដាម និងនាងអេវ៉ា បានទទួលការព្រមានដាស់តឿន ឱ្យប្រុងប្រយ័ត្នចំពោះមេកំណាចដ៏ប្រកបដោយគ្រោះថ្នាក់នេះ ប៉ុន្តែវាបានធ្វើការក្នុងទីងងឹត ដោយលាក់កំបាំងនូវគោលបំណងរបស់វា។ វាបានប្រើសត្វពស់ជាសត្វមានទ្រង់ទ្រាយដ៏គួរឱ្យពេចពិលរមិលមើលនៅគ្រានោះ រួចក៏និយាយមកកាន់នាងអេវ៉ាថា «តើព្រះមានបន្ទូលហាមមិនឱ្យអ្នកបរិភោគផ្លែឈើណានៅក្នុងសួនច្បារមែនឬ?» នាងអេវ៉ាបានផ្សងព្រេងសាសងជាមួយវា ហើយក៏ធ្លាក់ទៅក្នុងបាបធម៌របស់វា៖ «ស្ត្រីឆ្លើយតបថា យើងបរិភោគអស់ទាំង

ផ្លែឈើនៅក្នុងសួនច្បារបាន តែត្រង់ដើមឈើមួយនៅកណ្តាលសួនច្បារ
នោះ ព្រះទ្រង់មានបន្ទូលថា កុំឱ្យបរិភោគផ្លែនោះឡើយ ថែមទាំងកុំឱ្យប៉ះ
ពាល់ផងក្រែងលោស្លាប់ រួចពស់និយាយទៅស្ត្រីថា អ្នកមិនស្លាប់ជាពិតទេ
ដ្បិតព្រះទ្រង់ជ្រាបថា នៅថ្ងៃណាដែលអ្នកបរិភោគ នោះភ្នែកអ្នកនឹងបានភ្លឺ
ឡើង ហើយអ្នកនឹងបានដូចជាព្រះដែរ ព្រមទាំងដឹងការខុសត្រូវផង»។
លោកុប្បត្តិ ៣:១៥។

នាងអេវ៉ាក៏យល់ព្រម ហើយតាមរយៈឥទ្ធិពលរបស់នាង លោកអ័ដាម
ត្រូវបាននាំចូលទៅក្នុងអំពើបាបដែរ។ គេទាំងពីរនាក់បានជឿពាក្យសម្តី
របស់សត្វពស់ ពួកគេបានលែងទុកចិត្តចំពោះព្រះអាទិកររបស់ខ្លួន ព្រម
ទាំងពិចារណាឃើញថា ទ្រង់បានឃាត់ឃាំងសេរីភាពរបស់ខ្លួនទៀតផង។

ប៉ុន្តែតើលោកអ័ដាមបានរកឃើញអត្ថន័យរបស់ពាក្យនោះដូចម្តេច
ខ្លះ «ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន»។
លោកុប្បត្តិ ២:១៧។ តើគាត់នឹងត្រូវបានគេណែនាំទៅរកសេចក្តីថ្កុំថ្កើងជាង
នេះទៅទៀតឬ? លោកអ័ដាមពុំបានយល់ឃើញថា ការនេះជាអត្ថន័យនៃ
ការកាត់ទោសរបស់ព្រះទេ។ ព្រះទ្រង់បានបញ្ជាក់ថា ចំពោះពិន័យសម្រាប់
អំពើបាបរបស់គាត់ មនុស្សត្រូវតែត្រឡប់ទៅជាធូលីដីវិញ៖ «ដ្បិតឯងជា
ធូលីដី ក៏ត្រូវតែត្រឡប់ទៅជាធូលីដីវិញ»។ លោកុប្បត្តិ ៣:១៩។ សម្តី
សាតាំងដែលថា «ភ្នែកអ្នកនឹងបានភ្លឺឡើង» ឃើញថា ត្រូវចំពោះសេចក្តីនេះ
មែន៖ ភ្នែកគេបានភ្លឺឡើងយល់ដឹងនូវបាបធម៌របស់ខ្លួន។ ពួកគេបានស្គាល់
អំពើអាក្រក់ ហើយនិងបានភ្លក្សផលផ្លែដ៏ល្វីងជូរចត់នៃការបំពាន។

ដើមឈើជីវិតមានអំណាចបន្តជីវិតរស់នៅដ៏អស់កល្ប។ បើលោក
អ័ដាមពុំបានធ្វើបាបទេ លោកអាចចេញចូលទៅឯដើមឈើនោះនៅពេល
ណាក៏បាន ហើយចេះតែមានជីវិតរស់នៅជារហូត ប៉ុន្តែនៅពេលដែលគាត់
បានធ្វើបាប គាត់ក៏ត្រូវបានកាត់ចេញអំពីដើមឈើជីវិត ហើយត្រូវស្ថិតនៅ
ក្រោមសេចក្តីស្លាប់។ ភាពអមតៈត្រូវបានបាត់បង់ដោយសារការប្រព្រឹត្ត

រំលង។ បើព្រះទ្រង់ពុំបាននាំភាពអមត:មកដល់ដៃគេ ដោយសារយញ្ញបូជា
នៃព្រះរាជបុត្រារបស់ព្រះអង្គទេ នោះប្រាកដជានឹងគ្មានសង្ឃឹមសម្រាប់ជាតិ
សាសន៍ដែលរំលំដួលនេះឡើយ។ «សេចក្តីស្លាប់បានឆ្លងរាលដាលដល់
មនុស្សគ្រប់គ្នា ដ្បិតគ្រប់គ្នាបានធ្វើបាប» ព្រះគ្រីស្ទបាន «យកជីវិត និង
សេចក្តីមិនចេះស្លាប់ មកដាក់នៅពន្លឺដោយសារដំណឹងល្អវិញ»។ មានតែ
តាមរយៈព្រះគ្រីស្ទប៉ុណ្ណោះ ទើបអាចមានសេចក្តីមិនចេះស្លាប់បាន។ «អ្នក
ណាដែលជឿដល់ព្រះរាជបុត្រា នោះមានជីវិតដ៏នៅអស់កល្បជានិច្ចហើយ
តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះនឹងមិនឃើញជីវិត
សោះឡើយ»។ រ៉ូម ៥:១២; ធីម៉ូថេទី២ ១:១០; យ៉ូហាន ៣:៣៦។

<u>ព្រហស្បតិ៍-១៦ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ២១

ខព្រះគម្ពីរប្រចាំថ្ងៃ: *ឯព្រលឹងណាដែលធ្វើបាប គឺព្រលឹងនោះឯងនឹងត្រូវ
ស្លាប់ កូនមិនត្រូវរងសេចក្តីទុច្ចរិតរបស់ឪពុកទេ ហើយឪពុកក៏មិនត្រូវរង
សេចក្តីទុច្ចរិតរបស់កូនដែរ សេចក្តីទុច្ចរិតរបស់មនុស្សសុចរិតនឹងនៅលើអ្នក
នោះឯង ហើយសេចក្តីទុច្ចរិតរបស់មនុស្សទុច្ចរិតនឹងនៅលើខ្លួនអ្នកទុច្ចរិត
នោះឯងដែរ។ អេសេគាល ១៨:២០*

មហាកំតូត

អ្នកដែលបានសន្យាថាឱ្យជីវិត ដោយការមិនស្តាប់បង្គាប់ គឺជាមេ
បោកប្រាស។ នោះហើយជាសេចក្តីបញ្ជាក់របស់សត្វពស់ នៅក្នុងសួនច្បារ
អេដែន «អ្នកនឹងមិនស្លាប់ជាប្រាកដទេ» គឺជាបទអធិប្បាយដំបូងបង្អស់
ស្តីអំពីអមតភាពនៃព្រលឹង។ សេចក្តីបញ្ជាក់នេះ ដែលស្ថិតនៅលើអំណាច
របស់សាតាំង ត្រូវបានបន្ទរចេញអំពីតុអធិប្បាយ ហើយក៏បានទទួលជឿ
ដោយមនុស្សជាតិភាគច្រើនដោយងាយ ដូចឪពុកម្តាយដំបូងរបស់យើង
ដូច្នោះដែរ។ ព្រះរាជឱង្ការកាត់ទោសដែលថា «ព្រលឹងណាដែលបានធ្វើ

បាប គឺព្រលឹងនោះឯងនឹងត្រូវស្លាប់» (អេសេគាល ១៨:២០) ត្រូវបានធ្វើឱ្យមានន័យថា ព្រលឹងណាដែលបានធ្វើបាប ព្រលឹងនោះឯងនឹង *មិន* ស្លាប់ទេ គឺរស់នៅជារហូតវិញ។ បើព្រះអនុញ្ញាតឱ្យមនុស្សមានសិទ្ធិដល់ដើមជីវិត បន្ទាប់ពីបានធ្វើបាបហើយនោះ បាបនឹងស្ថិតស្ថេរនៅអស់កល្បជាមិនខាន។ ប៉ុន្តែ ពុំមាននរណាម្នាក់នៅក្នុងគ្រួសារលោកអ័ដាម ត្រូវបានអនុញ្ញាតឱ្យមានចំណែកដល់ផ្លែជីវិតនោះឡើយ។ ម្ល៉ោះហើយបានជាពុំមានបាបជនដ៏នៅអស់កល្បជានិច្ច។

បន្ទាប់ពីសាតាំងបានធ្វើបាប វាបានបញ្ឆោពួកទេវតារបស់វាឱ្យបង្ហាត់បង្រៀននូវជំនឿនៃភាពអមតៈជាធម្មជាតិរបស់មនុស្ស។ បន្ទាប់ពីបានអន្ទងមនុស្សឱ្យទទួលសេចក្តីខុសឆ្គងនេះហើយ ពួកគេបានណែនាំអ្នកមានបាបឱ្យសម្រេចសេចក្តីថា ពួកគេនឹងរស់នៅក្នុងសេចក្តីវេទនាដ៏អស់កល្បជានិច្ច។ ឥឡូវនេះ ស្តេចនៃសេចក្តីងងឹតបានប្រដូចព្រះទៅនឹងអ្នកសងសឹកផ្តាច់ការ ដោយថ្លែងថា ទ្រង់នឹងបោះអ្នកណាដែលមិនធ្វើតាមព្រះទ័យទ្រង់ចូលទៅក្នុងនរក ហើយថាព្រះអាទិករបស់ពួកគេសព្វព្រះទ័យណាស់ នៅពេលទ្រង់ទតចុះមកឃើញពួកគេកំពុងស្ថិតនៅក្នុងអណ្តាតភ្លើងដែលកំពុងឆេះជានិច្ចនោះ។ គឺរបៀបនេះហើយដែលមហាបិសាចបំពាក់គុណសម្បត្តិរបស់វាទៅលើព្រះអង្គដែលប្រទានមត៌កឱ្យមនុស្សជាតិ។ សេចក្តីឃោរឃៅគឺជាគុណជាតិរបស់សាតាំង ចំណែកឯព្រះទ្រង់ជាសេចក្តីស្រឡាញ់។ សាតាំងជាសត្រូវដែលល្បួងមនុស្សឱ្យធ្វើបាប ហើយនិងបំផ្លាញគេចោលតែម្តងបើអាចធ្វើបាន។ គោលលទ្ធិដែលថាពួកអាក្រក់ដែលបានស្លាប់ នឹងត្រូវរងទុក្ខនៅក្នុងភ្លើងនរកដែលឆេះអស់កល្បជានិច្ច ហើយដែលថា អំពើបាបនៃជីវិតដ៏ខ្លីនៅផែនដី ត្រូវរងទារុណកម្មជារៀងរហូតឱ្យតែព្រះនៅតែមានព្រះជន្មរស់នៅនោះ អីក៏ទទឹងនឹងសេចក្តីស្រឡាញ់ សេចក្តីមេត្តាករុណា និងសេចក្តីយុត្តិធម៌អ្វីម្ល៉ោះ»

តើក្នុងព្រះគម្ពីរមានសេចក្តីបង្រៀនបែបនេះនៅត្រង់ណា? តើអារម្មណ៍

របស់មនុស្សជាតិសាមញ្ញនឹងត្រូវប្តូរយកភាពយោរយៅនៃមនុស្សសាហាវយង់ឃ្នងឬ? ទេ នេះពុំមែនជាសេចក្តីបង្រៀននៃព្រះគម្ពីររបស់ព្រះទេ។ «ព្រះអម្ចាស់យេហូវ៉ាទ្រង់ស្បថថា ដូចជាអញរស់នៅ នោះប្រាកដជាអញមិនរីករាយចំពោះសេចក្តីស្លាប់របស់មនុស្សអាក្រក់ឡើយ គឺចូលចិត្តឱ្យគេលះចោលផ្លូវរបស់ខ្លួន ហើយមានជីវិតរស់នៅវិញទេតើ ចូរឱ្យឯងរាល់គ្នាបែរមក ចូរបែរមកពីផ្លូវអាក្រក់របស់ខ្លួនចុះ ហេតុអ្វីបានជាចង់ស្លាប់?» អេសេគាល ៣៣:១១។

តើព្រះអង្គសព្វព្រះទ័យនឹងឃើញទារុណកម្មដ៏មិនចេះឈប់ឈរនោះឬ? តើទ្រង់សព្វព្រះទ័យនឹងស្តាប់សំឡេងយំសោកសៅ និងការស្រែកថ្ងូររបស់សត្វលោកដែលកំពុងរងទុក្ខឈឺចាប់ដោយទ្រង់បញ្ជោះទុកនៅក្នុងអណ្តាតភ្លើងឬ? តើសំឡេងដ៏រន្ធត់ទាំងនេះ អាចបានជាតូរ្យតន្ត្រីដ៏ពីរោះដល់ព្រះការណ៍នៃព្រះដ៏ពោរពេញទៅដោយសេចក្តីស្រឡាញ់បានដែរឬទេ? ឱ នេះចំជាការប្រមាថដ៏អាក្រក់មែន! សិរីល្អរបស់ព្រះពុំមែនរុងរឿងឡើងដោយអំពើបាបដែលចេះតែបន្តពីយុគសម័យគ្មានទីបញ្ចប់នោះឡើយ។

សេចក្តីបង្រៀនខុសឆ្គងនៃទារុណកម្មអស់កល្បជានិច្ច

អំពើអាក្រក់បានកើតមានឡើងដោយការបង្រៀនខុសឆ្គងនៃទារុណកម្មដ៏អស់កល្ប។ សាសនានៃព្រះគម្ពីរ ដែលពោរពេញទៅដោយសេចក្តីស្រឡាញ់ និងសេចក្តីល្អ ត្រូវបានគ្របបាំងដោយជំនឿអកុសល ហើយបានគ្របដណ្តប់ដោយសេចក្តីបំភិតបំភ័យ។ សាតាំងបានលាបសម្បុរក្លែងក្លាយដល់ចរិតលក្ខណៈរបស់ព្រះ។ ម្ល៉ោះហើយ គេបានភ័យខ្លាច ញ័ររន្ធត់ថែមទាំងស្អប់ដល់ព្រះអាទិករដែលប្រកបដោយសេចក្តីមេត្តាករុណាទៀតផង។ ទស្សនៈដ៏ហួសខ្នាតស្តីអំពីព្រះដែលបានផ្សព្វផ្សាយពេញពិភពលោកដោយសេចក្តីបង្រៀនចេញពីគុអធិប្បាយ បានធ្វើឱ្យមនុស្សរាប់លាននាក់សង្ស័យហើយលែងជឿតែម្តង។

ការរងទុក្ខដ៏អស់កល្ប គឺជាគោលលទ្ធិដ៏ខុសឆ្គងមួយ ដែលជាស្រោនៃសេចក្តីកំផិត (វិវរណៈ ១៤:៨; ១៧:២) ដែលបាប៊ីឡូនឱ្យគ្រប់សាសន៍ផឹក។ ពួកគ្រូគង្វាលនៃព្រះគ្រីស្ទ បានទទួលសេចក្តីបង្រៀនខុសឆ្គងនេះមកពីរ៉ូម បន្ទាប់ពីបានទទួលថ្ងៃសាបាថក្លែងក្លាយមក។ ប្រសិនបើយើងបែរចេញអំពីព្រះបន្ទូលព្រះ ហើយទទួលគោលលទ្ធិខុសឆ្គងដោយព្រោះដូនតាទាំងឡាយរបស់យើងបានបង្រៀន នោះយើងនឹងត្រូវទទួលការកាត់ទោសដូចបាប៊ីឡូនដែរ គឺយើងកំពុងផឹកស្រានៃសេចក្តីកំផិតរបស់បាប៊ីឡូននោះហើយ។

<u>សុក្រ-១៧ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ២២
ខព្រះគម្ពីរប្រចាំថ្ងៃ: *ដោយសារសេចក្តីជំនឿ លុះគេដើរព័ទ្ធជុំវិញក្រុងយេរីខូរអស់៧ថ្ងៃហើយ នោះកំផែងទីក្រុងក៏រលំទៅ។ ហេព្រើរ ១១:៣០*

មានក្រុមដ៏ធំមួយបានងាកទៅរកជំនឿខុសឆ្គងហួសល្បត់មួយទៀត។ គេបានយល់ឃើញថា បទគម្ពីរតំណាងព្រះនៃសេចក្តីស្រឡាញ់ និងសេចក្តីអាណិតមេត្តា ហើយមិនអាចជឿថា ទ្រង់នឹងដាក់សត្វលោករបស់ព្រះអង្គ ទៅក្នុងភ្លើងនរកដែលឆេះអស់កល្បជានិច្ចនោះបានឡើយ។ ដោយប្រកាន់ជឿថា មនុស្សមានបាបអាចរស់នៅក្នុងសេចក្តីត្រេកត្រអាល ទោះបីមិនអើពើចំពោះសេចក្តីតម្រូវរបស់ព្រះ ក៏ទ្រង់នៅតែសព្វព្រះទ័យទទួលដែរ។ គោលលទ្ធិបែបនេះពឹងផ្អែកទៅលើសេចក្តីមេត្តាករុណារបស់ព្រះ តែមើលរំលងសេចក្តីយុត្តិធម៌របស់ទ្រង់វិញ គឺជាលទ្ធិដែលបំពេញចិត្តស្រើបស្រាលទេ។

សេចក្តីសង្គ្រោះជាសាកល ដែលពុំមានចែងក្នុងបទគម្ពីរ

ពួកអ្នកជឿចំពោះសេចក្តីសង្គ្រោះជាសាកល បានមូលបង្កាច់បទគម្ពីរ។ អ្នកដែលបានតាំងខ្លួនថាជាគ្រូគង្វាលរបស់ព្រះគ្រីស្ទ បានបន្លឺផ្ទួន។

នូវពាក្យកុហកភូតភរ ចេញពីមាត់ពស់នៅក្នុងសួនច្បារអេដែនដែលថា «អ្នកមិនស្លាប់ជាពិតមែនទេ»។ «នៅថ្ងៃណាដែលអ្នកបរិភោគ ភ្នែកអ្នកនឹងបានភ្លឺឡើង ហើយអ្នកនឹងបានដូចជាព្រះដែរ»។ វាបញ្ជាក់ថា អំពើអាក្រក់បំផុតរបស់អ្នកមានបាបទាំងឡាយ អ្នកកាប់សម្លាប់ ចោរលួចប្លន់ អ្នកកំផិត នឹងបានចូលទៅកាន់ស្ថានបរមសុខ បន្ទាប់ពីបានស្លាប់ទៅ។ នេះជារឿងល្បីកដ៏គួរឱ្យគាប់ចិត្តមែន សម្រាប់បំប៉នដល់ចិត្តត្រេកត្រអាល!

ប្រសិនបើពិតថា មនុស្សទាំងអស់នឹងចូលនគរស្ថានសួគ៌តែម្តង នៅក្នុងខណៈដែលខ្លួនស្លាប់ទៅ នោះយើងរាល់គ្នាគួរលោភចង់បានសេចក្តីស្លាប់វិញ ជាជាងជីវិត។ មានមនុស្សជាច្រើនត្រូវបានណែនាំឱ្យផ្តាច់ជីវិតរបស់ខ្លួនដោយជំនឿបែបនេះ។ បន្ទាប់ពីបានលង់ខ្លួនក្នុងឧបសគ្គ និងការខកចិត្តហើយ វាជាការងាយស្រួលណាស់ ដើម្បីនឹងផ្តាច់ខ្សែជីវិត ហើយឡើងទៅកាន់ភពដែលរស់អស់កល្បជានិច្ច។

ព្រះទ្រង់បានប្រទានភ័ស្តុតាងយ៉ាងច្បាស់នៅក្នុងព្រះបន្ទូលទ្រង់ថា ទ្រង់នឹងដាក់ទណ្ឌកម្មដល់អស់អ្នកដែលរំលងបញ្ញត្តិរបស់ផងព្រះអង្គ។ តើព្រះអង្គមានសេចក្តីមេត្តាករុណាហួសពេក រហូតទាល់តែពុំអាចរកយុត្តិធម៌ឱ្យបាបជនមិនបានឬ? ចូរមើលទៅឯឈើឆ្កាងនៃកាល់វ៉ារីចុះ។ ជីវង្គតនៃព្រះរាជបុត្រារបស់ព្រះបានបញ្ជាក់ជាភ័ស្តុតាងថា «ឈ្នួលនៃអំពើបាបនោះជាសេចក្តីស្លាប់» (រ៉ូម ៦:២៣) គឺថារាល់ទាំងការបំពានដល់បញ្ញត្តិព្រះ ត្រូវតែទទួលទារុណកម្ម។ ព្រះគ្រីស្ទដែលពុំមានបាបសោះបានក្លាយជាបាបសម្រាប់មនុស្ស។ ទ្រង់បានទទួលរងកំហុសនៃសេចក្តីរំលង ហើយបានបាំងព្រះភ័ក្ត្រនៃព្រះវរបិតារបស់ព្រះអង្គ រហូតទាល់តែព្រះទ័យបានប្រេះឆា ហើយព្រះជន្មទ្រង់បានបាត់បង់ ទាំងអស់នេះគឺដើម្បីឱ្យបាបជនអាចបានសង្គ្រោះ។ គ្រប់ទាំងព្រលឹងណាដែលបដិសេធមិនព្រមរួមចំណែកក្នុងតង្វាយប្រោសលោះដ៏មានតម្លៃលើសលប់នេះ ត្រូវតែទទួលរងកំហុស និងទណ្ឌកម្មនៃសេចក្តីរំលងដោយខ្លួនឯង។

លក្ខខណ្ឌដែលបានសញ្ញាក់ច្បាស់លាស់

«អញនឹងឱ្យអ្នកនោះផឹកពីរន្ធទឹកនៃជីវិត [ដោយ] ឥតយកថ្លៃ» សេចក្តីសន្យានេះបានដល់អ្នកណាដែលស្រេកប៉ុណ្ណោះ។ «អ្នកណាដែលឈ្នះនោះនឹងបានគ្រងសេចក្តីទាំងនេះជាមត៌ក អញនឹងធ្វើជាព្រះដល់អ្នកទាំងនោះ ហើយអ្នកទាំងនោះនឹងធ្វើជាកូនរបស់អញ»។ វិវរណៈ ២១:៦,៧។ លក្ខខណ្ឌទាំងឡាយត្រូវបានចែងមកឱ្យឃើញស្រាប់ហើយ។ ដើម្បីគ្រងទុករបស់ទាំងអស់ជាមត៌កយើងត្រូវតែឈ្នះអំពើបាប។

«មិនមានសេចក្តីសុខស្រួលដល់មនុស្សអាក្រក់ទេ»។ សាស្តា ៨:១៣។ បាបជនកំពុងប្រមូល «សេចក្តីក្រោធ ទុកសម្រាប់ដល់ថ្ងៃនៃសេចក្តីក្រោធវិញ ជាថ្ងៃដែលសេចក្តីជំនុំជម្រះដ៏សុចរិតរបស់ព្រះនឹងសម្តែងមក ដែលទ្រង់នឹងសងដល់គ្រប់គ្នា តាមអំពើដែលខ្លួនបានប្រព្រឹត្ត» ពោលគឺសងសេចក្តីវេទនា និងសេចក្តីលំបាក ដល់គ្រប់ទាំងព្រលឹងមនុស្សណាដែលប្រព្រឹត្តអាក្រក់។ រ៉ូម ២:៥,៦,៩។

<u>សៅរ៍-១៨ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ២៣

ខព្រះគម្ពីរប្រចាំសប្តាហ៍: *ដ្បិតព្រះបានផ្គត់ផ្គង់សេចក្តីប្រសើរជាងសំរាប់យើងរាល់គ្នា ដើម្បីមិនឲ្យអ្នកទាំងនោះបានគ្រប់លក្ខណ៍ ក្រៅពីយើងឡើយ។ ហេព្រើរ ១១:៤០*

«គ្មានមនុស្សកំផិត ឬស្មោកគ្រោក ឬលោភ គឺជាមនុស្សថ្វាយបង្គំរូបព្រះ ដែលនឹងគ្រងមត៌កនៅក្នុងនគរនៃព្រះគ្រីស្ទ ហើយនៃព្រះផងបានឡើយ»។ «មានពរហើយអស់អ្នកដែលលាងអាវខ្លួន [កាន់តាមបញ្ញត្តិព្រះ] ដើម្បីឱ្យបានច្បាប់ដល់ដើមជីវិត ហើយឱ្យបានចូលទៅក្នុងក្រុងតាមទ្វារ។ ខាងក្រៅមានសុទ្ធតែពួកឆ្កែ ពួកមន្តអាគម ពួកកំផិត ពួកកាប់សម្លាប់គេ ពួកថ្វាយបង្គំរូបព្រះ ហើយគ្រប់អ្នកណាដែលស្រឡាញ់ ហើយប្រព្រឹត្តសេចក្តី

កំភូត»។ អេភេសូរ ៥:៥; វិវរណៈ ២២:១៤,១៥។

ព្រះបានប្រទានដល់មនុស្ស នូវសេចក្តីបញ្ជាក់នៃវិធីរបស់ព្រះអង្គ សម្រាប់ទប់ទល់ជាមួយអំពើបាប។ «ព្រះយេហូវ៉ា...នឹងបំផ្លាញពួកមនុស្សអាក្រក់»។ «ឯពួកមនុស្សរំលងច្បាប់នឹងត្រូវវិនាសទៅជាមួយគ្នា ឯចុងបំផុតនៃមនុស្សអាក្រក់ នោះនឹងត្រូវកាត់ចេញវិញ»។ ទំនុកតំកើង ១៤៥:២០; ៣៧:៣៨។ អាជ្ញាច្បាប់នៃការគ្រប់គ្រងរបស់ព្រះនឹងបង្ក្រាបការបះបោរ ប៉ុន្តែក្នុងការសងកម្មពៀរ ដើម្បីរកយុត្តិធម៌ ព្រះទ្រង់នៅតែមានចរិតលក្ខណៈដែលប្រកបដោយសេចក្តីមេត្តាករុណា និងសេចក្តីប្រណីសណ្តោសដដែល។

ព្រះទ្រង់ពុំប្រើការបង្ខិតបង្ខំទេ ព្រះអង្គគ្មានអំណាចចំពោះការស្តាប់បង្គាប់ដោយការបង្ខំចិត្តឡើយ។ ព្រះអង្គប្រាថ្នាឱ្យសត្វលោកដែលជាស្នាព្រះហស្តព្រះអង្គ ស្រឡាញ់ទ្រង់ដោយព្រោះទ្រង់គួរជាទីស្រឡាញ់។ ព្រះអង្គសព្វព្រះទ័យឱ្យគេស្តាប់បង្គាប់ទ្រង់ ដោយព្រោះគេមានការដឹងគុណចំពោះតម្រិះប្រាជ្ញា យុត្តិធម៌ និងសេចក្តីប្រោសប្រណីរបស់ផងព្រះអង្គ។

គោលការនៃការគ្រប់គ្រងរបស់ព្រះ គឺស្របគ្នាជាមួយសិក្ខាបទរបស់ព្រះអង្គសង្គ្រោះ ពោលគឺ «ត្រូវស្រឡាញ់ពួកខ្មាំងសត្រូវ»។ ម៉ាថាយ ៥:៤៤។ ព្រះទ្រង់ប្រតិបត្តសេចក្តីយុត្តិធម៌ដល់មនុស្សអាក្រក់ ដើម្បីជាសេចក្តីល្អសម្រាប់ពិភពលោក ហើយថែមទាំងដើម្បីជាសេចក្តីល្អសម្រាប់អស់អ្នកដែលត្រូវទទួលសេចក្តីជំនុំជម្រះរបស់ព្រះអង្គផង។ ទ្រង់បានក្រសោបគេដោយសញ្ញានៃសេចក្តីស្រឡាញ់ ព្រមទាំងតាមផ្តល់ឱ្យគេនូវសេចក្តីមេត្តាករុណាទៀតផង ប៉ុន្តែគេបានមើលងាយដល់សេចក្តីស្រឡាញ់របស់ទ្រង់ ធ្វើឱ្យបញ្ញត្តិរបស់ព្រះអង្គទៅជាឥតន័យ ហើយបដិសេធសេចក្តីមេត្តាករុណាទៀត។ គេនៅតែទទួលអំណោយទាន តែប្រមាថដល់ម្ចាស់អំណោយ។ ព្រះទ្រង់បានទ្រាំទ្រចំពោះអំពើមិនគួរគប្បីរបស់គេ ប៉ុន្តែតើឱ្យទ្រង់ចាក់ច្រវាក់ពួកបះបោរនេះទុកនៅក្បែរទ្រង់ ហើយបង្ខំគេឱ្យធ្វើទៅតាមបំណងរបស់ព្រះអង្គឬ?

មិនបានរៀបចំខ្លួនចូលនគរស្ថានសួគ៌

អស់អ្នកដែលបានរើសយកសាតាំងជាមេដឹកនាំរបស់ខ្លួន គឺពុំបានរៀបចំខ្លួនចូលគាល់ព្រះអង្គទេ។ ការមានឫកខ្ពស់ អំពើឆបោក អំពើអសីលធម៌ និងអំពើឃោរឃៅ បានផ្សារជាប់ក្នុងចរិតលក្ខណៈរបស់គេ។ តើគេអាចចូលទៅស្ថានសួគ៌រស់នៅជារៀងរហូត ជាមួយអស់អ្នកដែលខ្លួនស្អប់ខ្ពើមកាលនៅផែនដីបានដែរឬទេ? សេចក្តីពិតនឹងមិនដែលយល់ស្របជាមួយនឹងអ្នកភូតភរណាមួយឡើយ សភាពទន់ភ្លន់និងមិនស្តប់ចិត្តជាមួយការតម្កើងខ្លួនទេ ភាពស្អាតស្អំ ក៏មិនសមសូនដល់ជនពុករលួយដែរ សេចក្តីស្រឡាញ់ពិតប្រាកដ ពុំមានការចាប់អារម្មណ៍ចំពោះបុគ្គលដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួននោះទេ។ តើមានសេចក្តីអរសប្បាយអ្វីខ្លះ ដែលនគរស្ថានសួគ៌អាចផ្តល់ឱ្យពួកជនដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួននោះ?

តើអស់អ្នកដែលមានចិត្តពោរពេញទៅដោយសម្អប់ដល់ព្រះ ដល់សេចក្តីពិត និងភាពបរិសុទ្ធអាចលាយឡំជាមួយបណ្តាមនុស្សនៃស្ថានសួគ៌ ហើយចូលរួមក្នុងចម្រៀងសរសើរបានដែរឬ? ពេលវេលាទុកឱ្យប្រែចិត្តរាប់ឆ្នាំ បានផ្តល់មកឱ្យពួកគេ ប៉ុន្តែគេពុំដែលហ្វឹកហ្វឺនចិត្តគំនិតឱ្យស្រឡាញ់ភាពស្អាតស្អំឡើយ។ ពួកគេពុំដែលរៀនភាសានៃស្ថានសួគ៌ទេ ឥឡូវនេះហួសពេលហើយ។

ជីវិតបះបោរប្រឆាំងនឹងព្រះ ជាការធ្វើឱ្យខ្លួនគេមិនសមនឹងចូលនគរស្ថានសួគ៌បាន។ សន្តិភាព និងភាពស្អាតស្អំ នឹងក្លាយទៅជាទារុណកម្មចំពោះគេ សិរីល្អរបស់ព្រះនឹងបានជាភ្លើងឆាបឆេះវិញ។ គេប្រាថ្នារត់ចេញពីទីបរិសុទ្ធនោះ ហើយទូលសូមនូវសេចក្តីវិនាស ប្រយោជន៍ឱ្យគេអាចពួនបំបាំងពីព្រះភ័ក្ត្រព្រះដែលទទួលសុគតដើម្បីសង្គ្រោះគេ។ វាសនារបស់មនុស្សអាក្រក់ គឺសម្រេចទៅលើការជ្រើសរើសរបស់ខ្លួនផ្ទាល់។ ការជាត់ខ្លួនចេញអំពីស្ថានសួគ៌ គឺជាការស្ម័គ្រចិត្តរបស់ខ្លួន ហើយសេចក្តីយុត្តិធម៌និងមេត្តាធម៌ជាផ្នែករបស់ព្រះ។ ក៏ដូចគ្នានឹងទឹកជំនន់ដែរ ភ្លើងនៃថ្ងៃដ៏ធំ

ប្រកាសពី ការវិនិច្ឆ័យរបស់ព្រះថា ពួកអាក្រក់លែងកែបានហើយ។ គេបានប្រើទំនើងចិត្តរបស់គេក្នុងការបះបោរ។ នៅពេលដែលជីវិតបានផុតទៅហើយ នោះហួសពេលនឹងបង្វែរគំនិតគេចេញពីអំពើរំលង មកឯការស្តាប់បង្គាប់ ពីសម្ពប់ មកឯសេចក្តីស្រឡាញ់ហើយ។

<u>អាទិត្យ-១៩ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ: អេសាយ ជំពូក ២៤

ខព្រះគម្ពីរប្រចាំថ្ងៃ: *ចូរឲ្យកិរិយាដែលអ្នករាល់គ្នាប្រព្រឹត្ត បានឥតលោភឡើយ ឲ្យស្កប់ចិត្តនឹងរបស់ដែលមានហើយប៉ុណ្ណោះចុះ ដ្បិតទ្រង់មានព្រះបន្ទូលថា «អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ» ។ ហេព្រើរ ១៣:៥*

ឈ្នួលនៃអំពើបាប

«ដ្បិតឈ្នួលនៃអំពើបានជាសេចក្តីស្លាប់ តែអំណោយទានរបស់ព្រះជាជីវិតរស់នៅដ៏អស់កល្ប តាមរយៈព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា»។ នៅពេលដែលជីវិតនឹងបានជាមតិករបស់ពួកសុចរិត សេចក្តីស្លាប់នឹងបានជាចំណែករបស់មនុស្សអាក្រក់។ «សេចក្តីស្លាប់ទីពីរ» ត្រូវស្ថិតក្នុងទីកន្លែងផ្តុយគ្នានឹងជីវិតអស់កល្ប។ រ៉ូម ៦:២៣; វិវរណៈ ២០:១៤។

បន្ទាប់ពីលោកអ័ដាមបានធ្វើបាបមក សេចក្តីស្លាប់បានរាលដាលលើមនុស្សទាំងអស់។ ទាំងអស់ចូលទៅក្នុងផ្នូរដូចគ្នា។ តាមរយៈផែនការនៃសេចក្តីសង្គ្រោះ ទាំងអស់គ្នានឹងត្រូវបាននាំចេញពីផ្នូរមកវិញ៖ «ទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិត នឹងបានសេចក្តីរស់ឡើងវិញទាំងអស់គ្នា»។ «ព្រោះដូចជាមនុស្សទាំងអស់បានត្រូវស្លាប់ ក្នុងលោកអ័ដាមជាយ៉ាងណានោះ គ្រប់គ្នានឹងបានប្រោសឱ្យរស់ក្នុងព្រះគ្រីស្ទជាយ៉ាងនោះដែរ»។ ប៉ុន្តែ មានភាពខុសគ្នារវាងក្រុមទាំងពីរដែលបានចែងមកនេះ៖ «អស់ទាំងខ្មោចនៅក្នុងផ្នូរ នឹងឮសំឡេងហើយនឹងចេញមក គឺពួកអ្នកដែលបានប្រព្រឹត្តល្អ គេនឹងរស់ឡើង

វិញឱ្យបានជីវិត ឯពួកអ្នកដែលបានប្រព្រឹត្តអាក្រក់វិញ គេនឹងរស់ឡើងឱ្យជាប់មានទោស»។ កិច្ចការ ២៤:១៥; កូរិនថូសទី១ ១៥:២២; យ៉ូហាន ៥:២៨,២៩។

ការរស់ឡើងវិញជាលើកទីមួយ

អស់អ្នកដែល «បានរាប់ជាគួរ» ឱ្យបានរស់ពីស្លាប់ឡើងវិញ គឺ «មានពរហើយក៏បរិសុទ្ធផង» «សេចក្តីស្លាប់ទីពីរ គ្មានអំណាចលើអ្នកទាំងនោះឡើយ»។ លូកា ២០:៣៥; វិវរណៈ ២០:៦។ ប៉ុន្តែ អស់អ្នកដែលពុំបានទទួលការអត់ទោស តាមរយៈការប្រែចិត្ត និងការជឿ ត្រូវទទួល «ឈ្នួលនៃអំពើបាប»។ គេនឹងទទួលទណ្ឌកម្ម «តាមការប្រព្រឹត្តរបស់ខ្លួន» ហើយបញ្ចប់នៅក្នុង «សេចក្តីស្លាប់ទីពីរ»។

ដោយព្រោះព្រះពុំអាចជួយសង្គ្រោះបាបជន ដែលស្ថិតនៅក្នុងបាបកម្មរបស់ខ្លួនបានទាល់តែសោះនោះ ទ្រង់បានហូតយកជីវិតរស់នៅពីគេ ព្រោះអំពើរំលងរបស់គេបានធ្វើឱ្យខ្លួនបាត់បង់ និងដោយព្រោះគេបានបង្ហាញថាខ្លួនគេពុំគួរនឹងទទួលអ្វីសោះឡើយ។ «ដល់បន្តិចទៀត មនុស្សអាក្រក់នឹងមិនមានទៀតទេ អើអ្នកនឹងខំមើលកន្លែងគេ តែគេមិននៅទេ»។ គេ «នឹងត្រឡប់ដូចជាមិនដែលកើតមក»។ ទំនុកតំកើង ៣៧:១០; អូបាឌា ១៦។ គេលិចទៅក្នុងសេចក្តីបាត់បង់សូន្យឈឹងដែលគ្មានទីសង្ឃឹមអស់កល្បជានិច្ច។

នោះហើយជាទីបញ្ចប់នៃអំពើបាប។ «ទ្រង់បានបំផ្លាញពួកអាក្រក់ចេញ ទ្រង់បានលុបឈ្មោះគេឱ្យបាត់ជាដរាបរៀងទៅ។ ឱខ្មាំងសត្រូវអើយ ការហិនវិនាសបានផុតទៅជានិច្ច»។ ទំនុកតំកើង ៩:៥,៦។ ហោរាយ៉ូហាន នៅក្នុងគម្ពីរវិវរណៈ បានឮភ្លេងជាតិសកល ច្រៀងសរសើរតម្កើងដោយឥតច្រឡំចង្វាក់ដល់បន្តិចឡើយ។ គ្មានព្រលឹងបាត់បង់ណាមួយជេរប្រមាថដល់ព្រះនាមព្រះ ក្នុងពេលដែលគេកំពុងរមួលខ្លួនទៅក្នុងទារុណកម្មដ៏មិនចេះចប់នោះឡើយ។ គ្មានអ្នកខូចបង់ណាដែលនៅក្នុងនរក នឹងស្រែកថ្ងូរលាយឡំជាមួយចម្រៀងនៃពួកអ្នកបានសង្គ្រោះសោះឡើយ។

ក្នុងលទ្ធិខុសឆ្គងនៃភាពអមត:ជាធម្មជាតិ គឺគោលលទ្ធិនៃការយល់ដឹងក្នុងសេចក្តីស្លាប់។ ក៍ដូចគ្នានឹងទារុណកម្មអស់កល្បជានិច្ចដែរ គឺឃើញថាទាស់ទទឹងនឹងបទគម្ពីរ ហេតុផល និងអារម្មណ៍មនុស្សជាតិរបស់យើងផងដែរ។

យោងទៅតាមជំនឿដែលគេនិយមជឿវិញ ពួកអ្នកប្រាសលោះនៅស្ថានសួគ៌ បានស៊ាំជាមួយនឹងអ្វីៗដែលកើតឡើងនៅផែនដីហើយ។ ប៉ុន្តែធ្វើដូចម្តេចឱ្យពួកស្លាប់មានសេចក្តីសប្បាយរីករាយទៅបាន កាលបើគេដឹងនូវបញ្ហាស្មុគស្មាញរបស់មនុស្សរស់ ឃើញគេកំពុងទ្រាំទ្រចំពោះទុក្ខ វេទនា ការខកចិត្ត និងការឈឺចាប់នៃជីវិតនោះ? តើគួរឱ្យខ្ពើមរអើមយ៉ាង ណាទៅចំពោះជំនឿដែលថា ដរាបណាដង្ហើមចាកចេញពីរូបកាយហើយ ព្រលឹងដែលពុំបានប្រែចិត្ត ត្រូវបញ្ជូនទៅកាន់ភ្លើងនរកភ្លាមនោះ?

តើបទគម្ពីរចែងដូចម្តេច? មនុស្សពុំដឹងអ្វីទេនៅពេលស្លាប់៖ «គេផុតដង្ហើមទៅ ហើយត្រឡប់ទៅជាធូលីដីវិញ នៅថ្ងៃនោះឯងអស់ទាំងគំនិតរបស់គេ ក៍សូន្យបាត់ទៅ»។ «ដ្បិតមនុស្សដែលរស់ គេដឹងថាខ្លួននឹងស្លាប់ជាមិនខាន តែមនុស្សស្លាប់ឥតដឹងអ្វីឡើយ...។ សេចក្តីស្រឡាញ់ សេចក្តីសម្អប់ និងសេចក្តីឈ្នានីសរបស់គេ ក៍វិនាសសូន្យបាត់ជាយូរមកហើយ គេក៍ឥតមានចំណែកណាក្នុងការអ្វីដែលធ្វើនៅក្រោមថ្ងៃ ជាដរាបទៅមុខដែរ»។ «ស្ថានឃុំព្រលឹងមនុស្សស្លាប់ នឹងឈោងដៃរកទ្រង់មិនបាន ហើយសេចក្តីស្លាប់ក៍នឹងអួតសរសើរទ្រង់មិនបានដែរ ពួកអ្នកដែលចុះទៅក្នុងរណ្តៅ នឹងសង្ឃឹមដល់សេចក្តីពិតរបស់ទ្រង់មិនបានឡើយ។ ឯមនុស្សរស់ គឺមនុស្សរស់ហើយដែលនឹងសរសើរដល់ទ្រង់ដូចជាទូលបង្គំនៅថ្ងៃនេះដែរ»។ «ដ្បិតក្នុងមរណភាព គ្មានសេចក្តីនឹកចាំពីទ្រង់ទៀតឡើយ នៅស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះតើអ្នកណានឹងសរសើរដល់ទ្រង់?» ទំនុកតំកើង ១៤៦:៤; សាស្តា ៩:៥,៦; អេសាយ ៣៨:១៨,១៩; ទំនុកតំកើង ៦:៥។

នៅថ្ងៃបុណ្យទី៥០ ពេត្រុសបានបញ្ជាក់ថាស្តេចដាវីឌ «បានទាំង

សុគត ហើយគេបានបញ្ចុះសពលោកដែរ ផ្នូរលោកក៏បាននៅជាមួយយើង រាល់គ្នា ដរាបដល់សព្វថ្ងៃនេះ»។ «ដ្បិតហ្លួងដាវីឌមិនបានឡើងទៅស្ថានសួគ៌ទេ»។ កិច្ចការ ២:២៩,៣៤។ ការពិតដែលស្តេចដាវីឌស្ថិតនៅក្នុងផ្នូរហួតដល់គ្រារស់ឡើងវិញ ជាភ័ស្តុតាងថា ពួកសុចរិតមិនទៅស្ថានសួគ៌នៅពេលស្លាប់ទេ។

<u>ចន្ទ-២០ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ២៥

ខព្រះគម្ពីរប្រចាំថ្ងៃ: *បានជាយើងរាល់គ្នាអាចនឹងនិយាយ ដោយក្លាហានថា «ខ្ញុំមិនព្រមខ្លាចឡើយ ព្រោះព្រះអម្ចាស់ទ្រង់ជាជំនួយខ្ញុំ តើមនុស្សនឹងធ្វើដល់ខ្ញុំជាយ៉ាងណាបាន»។ ហេព្រើរ ១៣:៦*

សាវ័កប៉ុលមានប្រសាសន៍ថា៖ «ដ្បិតបើសិនជាពួកស្លាប់មិនរស់ឡើងវិញទេ នោះព្រះគ្រីស្ទក៏មិនបានរស់ឡើងវិញដែរ ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញមែន នោះសេចក្តីជំនឿរបស់អ្នករាល់គ្នា ក៏ជាការឥតអំពើ អ្នករាល់គ្នានៅក្នុងអំពើបាបនៅឡើយ ហើយអ្នកដែលបានដេកលក់ទៅក្នុងព្រះគ្រីស្ទ គេបានត្រូវវិនាសហើយ»។ កូរិនថូសទី១ ១៥:១៦-១៨។ ប្រសិនបើ៤០០០ឆ្នាំ មកហើយ ពួកសុចរិតបានឡើងទៅស្ថានសួគ៌នៅពេលស្លាប់ទៅ ធ្វើដូចម្តេចឱ្យសាវ័កប៉ុលនិយាយថា ប្រសិនបើគ្មានសេចក្តីរស់ឡើងវិញទេ «អស់អ្នកដែលបានដេកលក់ទៅក្នុងព្រះគ្រីស្ទ គេបានត្រូវវិនាសហើយ» បាន?

នៅពេលរៀបចាកចេញអំពីពួកសិស្ស ព្រះយេស៊ូវពុំបានប្រាប់ពួកគេថា ពួកគេនឹងមកឯទ្រង់ក្នុងពេលឆាប់ៗនោះទេ៖ «ខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា» ទ្រង់មានបន្ទូល។ «បើខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ»។ យ៉ូហាន ១៤:២,៣។ សាវ័កប៉ុលប្រាប់យើងរាល់គ្នាទៀតថា «ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថាន

សូគិមក ដោយស្រែកបង្គាប់មួយព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកអ្នកស្លាប់ក្នុងព្រះគ្រីស្ទ នឹងរស់ឡើងវិញជាមុន បង្អស់ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើង ទៅក្នុង ពពកជាមួយគ្នាទាំងអស់ ដើម្បីឱ្យបានជួបជុំនឹងព្រះអម្ចាស់ នៅនាអាកាស យ៉ាងនោះយើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ»។ លោកបន្ថែម ទៀតថា «ចូរកំសាន្តចិត្តគ្នាទៅវិញទៅមក ដោយដំណើរនេះចុះ»។ ថែស្សាឡូនីចទី១ ៤:១៦-១៨។ នៅពេលព្រះអង្គយាងមក គម្របផ្នូរនឹង របើកឡើង ហើយ «ពួកស្លាប់ក្នុងព្រះគ្រីស្ទ» នឹងបានរស់ឡើងឱ្យមានជីវិត អស់កល្បជានិច្ច។

ទាំងអស់គ្នានឹងត្រូវជំនុំជម្រះទៅតាមការដែលកត់ទុកនៅក្នុងបញ្ជី ហើយនិងបានទទួលរង្វាន់ទៅតាមការដែលខ្លួនបានធ្វើ។ ការជំនុំជម្រះនេះ ពុំបានអនុវត្តនៅពេលស្លាប់ទេ។ «ទ្រង់បានដាក់កំណត់ថ្ងៃ ដែលទ្រង់នឹងជំនុំ ជម្រះលោកីយ៍ដោយយុត្តិធម៌»។ «មើលព្រះអម្ចាស់ទ្រង់យាងមកនៅ កណ្តាលពួកបរិសុទ្ធទាំងសល់សែន ដើម្បីនឹងកាត់ទោសដល់មនុស្ស ទាំងអស់»។ កិច្ចការ ១៧:៣១; យូដាស ១៤,១៥។

ប៉ុន្តែ ប្រសិនបើពួកស្លាប់កំពុងអរសប្បាយនៅស្ថានសូគិ ឬក៏កំពុង រមូលខ្លួននៅក្នុងភ្លើងនរកទៅហើយនោះ មានត្រូវការសេចក្តីជំនុំជម្រះនៅ ក្នុងអនាគតកាលធ្វើអ្វីទៀត? ព្រះបន្ទូលព្រះអាចយល់បានដោយគំនិត មនុស្សសាមញ្ញ។ តែចំណែកគំនិតត្រង់ៗវិញ តើគេអាចមើលឃើញតម្រិះ ប្រាជ្ញា ឬក៏សេចក្តីយុត្តិធម៌នៅក្នុងទ្រឹស្តីបច្ចុប្បន្ននេះឬទេ? តើពួកសុចរិតនឹង ទទួលការសរសើរថា «ប្រពៃហើយបាវល្អស្មោះត្រង់អើយ...ចូរឱ្យឯងប្រកប ដោយសេចក្តីអំណររបស់ចៅហ្វាយឯងចុះ» ក្នុងពេលដែលគេបានស្គាក់នៅ ចំពោះព្រះភ័ក្ត្រទ្រង់ដ៏យូរលង់ហើយនោះឬ? តើពួកអាក្រក់នឹងត្រូវកោះហៅ ចេញអំពីទារុណកម្ម ដើម្បីទទួលការកាត់ទោសពីព្រះដ៏ជាអ្នកកាត់ក្តីដែល ថា «អ្នករាល់គ្នាដែលត្រូវបណ្តាសាអើយ ចូរថយពីអញចេញទៅក្នុងភ្លើង

ដែលឆេះអស់កល្បជានិច្ច» ដូច្នោះឬ? ម៉ាថាយ ២៥:២១,៤១។

ទ្រឹស្តីនៃអមតភាពរបស់ព្រលឹង គឺជាគោលលទ្ធិមួយក្នុងអស់ទាំងគោលលទ្ធិខុសឆ្គងទាំងឡាយដែលរ៉ូមបានចម្លងមកពីសាសនាដទៃ។ លោកលូធើរបានរាប់គោលលទ្ធិនេះថាជា «រឿងល្បិចដ៏មហាកំភូត ដែលបង្កើតជាផ្នែកនៃបទបញ្ជាគម្រក់របស់រ៉ូម»។[1] ព្រះគម្ពីរបង្រៀនថា ពួកស្លាប់នឹងដេកលក់រហូតដល់មានសេចក្តីរស់ឡើងវិញ។

អ្នកសុចរិតដែលហាត់នឿយ សម្រាន្តដោយសុខសាន្ត! ទោះយូរឬឆាប់ក្តី ចំពោះគេដូចជាមួយភ្លែតប៉ុណ្ណោះ។ គេបានដេកលក់ រួចហើយនឹងត្រូវបានដាស់ឡើងដោយសំឡេងត្រែរបស់ព្រះទៅកាន់អមតភាពដ៏រុងរឿង។ «ដ្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់នឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ...។ កាលណារូបកាយពុករលួយនេះ បានប្រដាប់ដោយសេចក្តីមិនពុករលួយ ហើយរូបកាយដែលតែងតែស្លាប់នេះ បានប្រកបដោយសេចក្តីមិនចេះស្លាប់វិញ នោះទើបនឹងបានសម្រេចតាមពាក្យថា ‹សេចក្តីជ័យជម្នះបានលេបសេចក្តីស្លាប់បាត់ហើយ›»។ កូរិនថូសទី១ ១៥:៥២-៥៤។

គេត្រូវបានហៅចេញពីដំណេកដ៏លង់លក់របស់ខ្លួន ហើយក៏ចាប់ផ្តើមគិតដូចនៅពេលដែលទើបតែស្លាប់ទៅ។ ការចាប់អារម្មណ៍ចុងក្រោយបង្អស់ គឺជាការឈឺចាប់នៃសេចក្តីស្លាប់ ការគិតចុងក្រោយ គឺនៅពេលដែលគេធ្លាក់ទៅក្នុងអំណាចរបស់ផ្នូរខ្មោច។ នៅពេលក្រោកឡើងពីផ្នូរវិញ គំនិតដ៏រីករាយជាដំបូងបង្អស់ គឺជាសំឡេងបំពងនៅក្នុងសម្រែកជ័យជម្នះថា៖ «ឱសេចក្តីស្លាប់អើយ ទ្រនិចឯងនៅឯណា? ឱផ្នូរអើយ សេចក្តីជ័យជម្នះឯងនៅឯណា?» កូរិនថូសទី១ ១៥:៤៥។

1. E. Petavel, *The Problem with Immortality*, p. 255.

តើមនុស្សស្លាប់អាចនិយាយមកយើងបានឬទេ?

<u>អង្គារ-២១ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ២៦

ខព្រះគម្ពីរប្រចាំថ្ងៃ: *ចូរនឹកចាំពីពួកអ្នកនាំមុខ ដែលបានផ្សាយព្រះបន្ទូលមកអ្នករាល់គ្នា ត្រូវតែគ្រាប់តាមសេចក្តីជំនឿរបស់អ្នកទាំងនោះ ទាំងពិចារណាមើលចុងបំផុតនៃកិរិយាគេផង។ ហេព្រើរ ១៣:៧*

គោលលទ្ធិនៃអមតភាពធម្មជាតិ គឺបានចម្លងមកពីទស្សនវិទ្យានៃសាសនាដទៃ ហើយក្នុងភាពងងឹតនៃការងាកចេញពីជំនឿយ៉ាងខ្លាំងនោះ គេក៏បានបញ្ចូលលទ្ធិនេះទៅក្នុងជំនឿគ្រីស្ទសាសនា ហើយក៏លុបលើសេចក្តីពិតដែលចែងថា «មនុស្សស្លាប់ឥតដឹងអ្វីឡើយ»។ សាស្តា ៩:៥។ មនុស្សជាច្រើនជឿថា វិញ្ញាណនៃអ្នកស្លាប់ គឺជាវិញ្ញាណបម្រើដែលទ្រង់ចាត់មកសម្រាប់ជួយដល់ពួកដែលត្រូវទទួលសេចក្តីសង្គ្រោះជាមតិក។ ហេព្រើរ ១:១៤។

ជំនឿដែលថា វិញ្ញាណនៃអ្នកស្លាប់ទាំងឡាយ ត្រឡប់មកបម្រើដល់អ្នកនៅរស់នោះបានរៀបចំផ្លូវសម្រាប់វិញ្ញាណខន្ធនិយម។ បើអ្នកស្លាប់បានមានបុព្វសិទ្ធិនឹងទទួលតម្រិះប្រាជ្ញាលើសកាលដែលគេមានពីមុនទៅទៀតនោះ ហេតុអ្វីបានជាមិនត្រឡប់មកផែនដី ហើយបង្គាប់អ្នកនៅរស់ទៅ? បើវិញ្ញាណនៃអ្នកស្លាប់សំកាំងលើមិត្តភក្តិនៅលើផែនដីនេះ ហេតុអ្វីបានជាមិននិយាយឆ្លងឆ្លើយនឹងគេទៅ? តើឱ្យអ្នកដែលជឿថាមនុស្សស្លាប់នៅមានស្មារតីដឹងខ្លួនក្នុងសេចក្តីស្លាប់ បដិសេធអ្វីដែលគេហៅថាពន្លឺស័ក្តិសិទ្ធិ ដែលពួកវិញ្ញាណខ្ពង់ខ្ពស់ធ្វើការទាក់ទងជាមួយនឹងគេម្តេចបាន? នេះគឺជាខ្សែរយៈ

មួយដែលគេចាត់ទុកថាជាបរិសុទ្ធ ហើយសាតាំងប្រើខ្សែរយៈនេះឯង។ ទេវតាដែលបានទម្លាក់ចុះពីស្ថានសួគ៌ លេចមកដូចជាអ្នកនាំសារពីពិភពវិញ្ញាណ។

ស្តេចនៃសេចក្តីអាក្រក់មានអំណាចនឹងនាំមកនៅចំពោះមនុស្ស នូវរូបរាងនៃមិត្រដែលបានលាចាកលោកីយ៍ទៅហើយ។ ការក្លែងបន្លំនេះ គឺដូចឥតខ្ចោះ ប្រឌិតឡើងវិញដោយភាពយ៉ាងច្បាស់អស្ចារ្យ។ ភាគច្រើនត្រូវបានធ្វូចិត្ត ដោយដឹងថាអ្នកដែលគេស្រឡាញ់កំពុងតែសប្បាយរីករាយនៅស្ថានសួគ៌។ គេយកត្រចៀក «ស្តាប់តាមវិញ្ញាណបញ្ឆោត និងសេចក្តីបង្រៀនរបស់ពួកអារក្ស» ដោយគ្មានសង្ស័យពីសេចក្តីគ្រោះថ្នាក់សោះ។ ធីម៉ូថេទី១ ៤:១។

អ្នកដែលស្លាប់ទៅដោយមិនបានប្រុងប្រៀប អះអាងថាបានសុខសប្បាយ ហើយទទួលតំណែងខ្ពង់ខ្ពស់នៅស្ថានសួគ៌ទៀតផង។ បន្ទាប់មក នៅពេលគេទុកចិត្តពួកវាហើយ វាបង្ហាញគោលលទ្ធិដែលរំលើងបទគម្ពីរវិញ។ ការដែលពួកវាថ្លែងសេចក្តីពិតខ្លះៗ ហើយជួនកាលទាយព្រឹត្តិការណ៍នៅអនាគតកាលនោះ ធ្វើឱ្យគេមើលទៅទំនងទុកចិត្តបាន ហើយក៏ទទួលសេចក្តីបង្រៀនក្លែងក្លាយរបស់វា។ គេបំភ្លេចក្រឹត្យវិន័យរបស់ព្រះ ទាំងស្អប់ព្រះវិញ្ញាណនៃព្រះគុណផង។ វិញ្ញាណទាំងនោះបដិសេធថាព្រះគ្រីស្ទពុំមែនជាព្រះ ហើយដាក់ព្រះអាទិករស្មើនឹងពួកវាដែរ។

ជាការពិតមួយ ដែលជាញយៗ ផលនៃល្បិចបញ្ឆោតត្រូវបានបន្លំថាជាការសម្តែងពិតប្រាកដ ហើយពួកទេវតាអាក្រក់ក៏បង្ហាញអំណាចអធិឋានជាតិដ៏អស្ចារ្យរបស់វាក្នុងពេលជាមួយគ្នាផងដែរ។ មនុស្សភាគច្រើនជឿថាវិញ្ញាណខន្ធនិយម គឺគ្រាន់តែជាការក្លែងបន្លំរបស់មនុស្សប៉ុណ្ណោះ។ តែនៅពេលគេឃើញការសម្តែងផ្ទាល់ភ្នែក គេនឹងជឿថាជាការហួសវិស័យធម្មជាតិ ហើយគេនឹងត្រូវចាញ់បញ្ឆោត ព្រមទាំងជឿការទាំងនោះថាជាមហិទ្ធិឫទ្ធិរបស់ព្រះវិញ។

ពួកគ្រូមន្តអាគមនៃស្តេចផារ៉ោន បានបន្លំកិច្ចការរបស់ព្រះ ដោយ

ជំនួយរបស់សាតាំង។ សូមអាននិក្ខមនំ ៧:១០-១២។ សាវ័កប៉ុលបានធ្វើទីបន្ទាល់ថា ព្រះអម្ចាស់នឹងយាងមកបន្ទាប់ពីការ «ធ្វើការដូចជាអារក្សសាតាំងដោយនូវគ្រប់ទាំងឫទ្ធិ ទីសម្គាល់ និងការអស្ចារ្យដ៏កំភូត ហើយដោយគ្រប់ទាំងសេចក្តីឆបោករបស់សេចក្តីទុច្ចរិត»។ ថែស្សាឡូនីចទី២ ២:៩,១០។ ឯសាវ័កយ៉ូហានបានថ្លែងថា៖ «វានឹងធ្វើទីបន្ទាល់យ៉ាងធំ ដល់ម៉្លេះបានជាធ្វើឱ្យធ្លាក់ទាំងភ្លើងពីលើមេឃមកលើផែនដី នៅមុខមនុស្សលោកផង។ វាបញ្ឆោតពួកមនុស្សនៅផែនដី ដោយសារទីសម្គាល់ដែលវាមានអំណាចនឹងធ្វើ»។ វិវរណៈ ១៣:១៣,១៤។ គ្មានអ្នកក្លែងបន្លំណាបានទាយទុកក្នុងសេចក្តីខាងលើនេះទេ។ ពួកមនុស្សត្រូវភាន់ច្រឡំដោយការអស្ចារ្យដែលភ្នាក់ងាររបស់សាតាំងធ្វើ ពុំមែនដោយអ្វីដែលពួកគេធ្វើដោយពុតត្បុតនោះទេ។

<u>ពុធ-២២ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ២៧

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដ្បិតព្រះយេស៊ូវគ្រីស្ទទ្រង់នៅតែដដែល គឺពីថ្ងៃម្សិល ថ្ងៃនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ ។ ហេព្រើរ ១៣:៨*

សំណូមពររបស់សាតាំងដល់អ្នកមានប្រាជ្ញា

ចំពោះមនុស្សដែលមានវប្បធម៌ និងអាកប្បកិរិយានឹងធឹងវិញ ស្តេចនៃសេចក្តីងងឹត សម្តែងវិញ្ញាណខន្ធនិយម ក្នុងទិដ្ឋភាពដ៏កាន់តែប្រសើរឡើង និងដ៏ប្រកបដោយប្រាជ្ញាថែមទៀត។ វាប្រើទស្សនីយភាពដ៏គួរឱ្យចាប់ចិត្ត និងការពិពណ៌នាហូរហែអំពីស្នេហា និងសប្បុរសធម៌ ដើម្បីធ្វើឱ្យចិត្តនឹករិលរល់នឹងរបស់ទាំងនោះ។ វានាំមនុស្សឱ្យមានអំនួតយ៉ាងខ្លាំងចំពោះប្រាជ្ញារបស់ខ្លួន រហូតដល់ចិត្តគេស្អប់ព្រះដែលមានព្រះជន្មអស់កល្បជានិច្ច។

សាតាំងបញ្ឆោតមនុស្សក្នុងពេលឥឡូវ ដូចជាវាបញ្ឆោតនាងអេវ៉ាក្នុងសួនអេដែនដូច្នោះដែរ ដោយធ្វើឱ្យចិត្តរំជួលចង់តម្កើងខ្លួនឯង។ «អ្នកនឹង

បានដូចជាព្រះដែរ» វាពោលឡើង «ព្រមទាំងដឹងការខុសត្រូវផង»។ លោកុប្បត្តិ ៣:៥។ វិញ្ញាណខន្ធនិយមបង្រៀនថា «មនុស្សគឺជាសត្វនៃការវិវឌ្ឍ...ទៅជាព្រះ»។ ហើយមួយសោតទៀតថា៖ «ការជំនុំជម្រះនឹងបានត្រឹមត្រូវ ពីព្រោះជាការជំនុំជម្រះដល់ខ្លួនឯង...។ បល្ល័ង្កគឺនៅក្នុងខ្លួនអ្នក»។ ហើយម្នាក់ទៀតថ្លែងថា៖ «មនុស្សណាដែលយុត្តិធម៌ ហើយគ្រប់ខ្នាត គឺជាព្រះគ្រីស្ទហើយ»។

ដូច្នេះ សាតាំងបានប្តូរយកនិស្ស័យមានបាបរបស់មនុស្ស មកធ្វើជាច្បាប់វិនិច្ឆ័យតែមួយគត់វិញ។ នេះគឺជាការវិវឌ្ឍហើយ មិនមែនទៅលើទេ តែទៅក្រោមវិញ។ មនុស្សនឹងមិនចម្រើនខ្ពស់ជាងខ្នាតនៃសេចក្តីបរិសុទ្ធ និងសេចក្តីល្អរបស់គេបានឡើយ។ ប្រសិនបើគេគិតថាខ្លួនគេជាកំពូលខ្ពង់ខ្ពស់បំផុតនោះ គេនឹងមិនទទួលអ្វីខ្ពស់ជាងនោះទៅទៀតសោះឡើយ។ មានតែព្រះគុណរបស់ព្រះតែមួយគត់ប៉ុណ្ណោះ ដែលមានអំណាចលើកតម្កើងមនុស្សបាន។ បើទុកឱ្យនៅតែឯង ដំណើររបស់គេគឺត្រូវតែចុះក្រោម។

ការខាក់ចិត្តដល់អ្នកស្រឡាញ់អំពើភ្លើតភ្លើន

ចំពោះអ្នកបណ្តោយខ្លួន អ្នកស្រឡាញ់អំពើភ្លើតភ្លើង និងអ្នកត្រេកត្រអាលកាមតណ្ហា វិញ្ញាណខន្ធនិយមពុំសូវសម្តែងការបន្លំដ៏ប៉ិនប្រសប់ទេ។ នៅក្នុងទម្រង់ទាំងមូលវិញ គេរកអ្វីដែលសមស្របទៅតាមការលំអៀងរបស់ខ្លួន។ សាតាំងសម្គាល់គ្រប់ទាំងបាបកម្ម ដែលបុគ្គលម្នាក់ៗរមែងប្រព្រឹត្ត ហើយវាធ្វើយ៉ាងម៉េច ដើម្បីឱ្យឱកាសនោះមកដល់ ដើម្បីបំប៉នចិត្តដែលលំអៀងនោះ។ វាបានល្បួងមនុស្សតាមសេចក្តីឥតប្រមាណ ដើម្បីធ្វើឱ្យខ្សោយអានុភាពខាងផ្លូវកាយ ផ្លូវចិត្ត និងសីលធម៌។ វាបំផ្លាញមនុស្សរាប់ពាន់នាក់ តាមការបណ្តោយតាមតណ្ហា ធ្វើឱ្យខូចនិស្ស័យទាំងមូលអស់ទៅ។ ហើយដើម្បីបញ្ចប់កិច្ចការរបស់វា វិញ្ញាណទាំងឡាយថ្លែងថា៖ «តម្រិះប្រាជ្ញាពិតប្រាកដ ដាក់មនុស្សខ្ពស់ជាងអស់ទាំងច្បាប់» ហើយ «អ្វីៗគឺត្រូវទាំងអស់»

ហើយថា «ព្រះទ្រង់មិនប្រកាន់ទោសអ្វីទេ» ព្រមទាំងថា «អស់ទាំងអំពើបាប ...គឺឥតមានកំហុសអ្វីសោះ»។ នៅពេលមនុស្សជឿថា សេចក្តីប្រាថ្នាគឺជាច្បាប់ខ្ពស់បំផុត ហើយសេរីភាពគឺជាការធ្វើតាមអំពើចិត្ត ហើយថាមនុស្សមានការទទួលខុសត្រូវសម្រាប់តែខ្លួនឯងនោះ តើមាននរណាអាចឆ្ងល់ថាអំពើពុករលួយមាននៅគ្រប់គ្នាបាន? មនុស្សជាច្រើន បណ្តែតអារម្មណ៍តាមកាមតណ្ហាដោយមិនអល់អែកឡើយ។ សាតាំងក៏ប្រមូលមនុស្សរាប់ពាន់នាក់ ដែលអះអាងថាដើរតាមព្រះគ្រីស្ទ មកក្នុងសំណាញ់របស់វា។

ប៉ុន្តែ ព្រះបានប្រទានពន្លឺគ្រប់គ្រាន់ហើយ ដើម្បីឱ្យរកឃើញអន្ទាក់នោះ។ គ្រឹះនៃវិញ្ញាណខន្ធនិយម គឺធ្វើសង្គ្រាមទាស់នឹងបទគម្ពីរតែម្តង។ ព្រះគម្ពីរចែងថាមនុស្សស្លាប់ឥតដឹងអ្វីសោះឡើយ គំនិតរបស់គេបានសាបសូន្យទៅ ហើយគេគ្មានចំណែកអ្វីក្នុងសេចក្តីសប្បាយ ឬសេចក្តីទុក្ខសោករបស់អ្នកនៅផែនដីឡើយ។

មួយទៀតសោត ព្រះបានហាមមិនឱ្យនិយាយឆ្លងឆ្លើយដោយធ្វើពុតជាមួយវិញ្ញាណដែលបានឃ្លាតចាកទៅហើយនោះឡើយ។ «វិញ្ញាណចម្លែកទាំងឡាយ» ដែលគេច្រើនតែហៅថាជាពួកអ្នកមកពីពិភពដទៃនោះ គឺមានចែងនៅក្នុងព្រះគម្ពីរថាជា «វិញ្ញាណនៃពួកអារក្ស»។ សូមអានជនគណនា ២៥:១៣; ទំនុកតំកើង ១០៦:២៨; កូរិនថូសទី១ ១០:២០; វិវរណៈ ១៦:១៤។ ការប្រស្រ័យទាក់ទងជាមួយវា ត្រូវបានហាមប្រាមក្រោមពិន័យដល់ស្លាប់។ លេវីវិន័យ ១៩:៣១; ២០:២៧។ ប៉ុន្តែ វិញ្ញាណខន្ធនិយម បានជ្រាបចូលដល់មជ្ឈដ្ឋានវិទ្យាសាស្ត្រ លុកលុយព្រះវិហារហើយបានចូលដល់នីតិបញ្ញត្តិទាំងដល់ក្រុមប្រឹក្សាស្តេចផង។ សេចក្តីបញ្ឆោតដ៏មហិមានេះ គឺជាការរស់ឡើងវិញក្នុងសេចក្តីបន្លំថ្មីនៃអំពើអាបធ្មប់ ដែលគេបានកាត់ទោសវាយប្រហារកាលពីដើម។

<u>ព្រហស្បត៍-២៣ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ២៨

ខព្រះគម្ពីរប្រចាំថ្ងៃ: *កុំឲ្យភ្លេចនឹងធ្វើគុណ ហើយចែកចាយឡើយ ដ្បិតព្រះទ្រង់សព្វព្រះហឫទ័យនឹងគ្រឿងបូជាយ៉ាងនោះ។ ហេព្រើរ ១៣:១៦*

ដោយតំណាងសេចក្តីថោកទាបបំផុតរបស់មនុស្ស ដូចការដែលវាបានធ្វើនៅស្ថានសួគ៌ សាតាំងនិយាយទៅកាន់លោកីយ៍ថា៖ «ទោះបើអ្នកជឿឬមិនជឿព្រះ ឬព្រះគម្ពីរក៏ដោយ ចូររស់នៅតាមតែអំពើចិត្តចុះ ព្រោះស្ថានសួគ៌គឺជាផ្ទះរបស់អ្នកហើយ»។ ព្រះបន្ទូលរបស់ព្រះបានចែងមកថា៖ «វេទនាដល់ពួកអ្នកដែលរាប់សេចក្តីអាក្រក់ថាល្អ ហើយសេចក្តីល្អថាជាអាក្រក់វិញ ជាពួកអ្នកដែលយកសេចក្តីងងឹតជាពន្លឺ ហើយយកពន្លឺជាងងឹត»។ អេសាយ ៥:២០។

ព្រះគម្ពីរត្រូវបានតំណាងថាជារឿងប្រឌិត

ពួកវិញ្ញាណកុហកបានមូលបង្កាច់នូវអ្វីដែលពួកសាវ័កបានសរសេរកាលគេរស់នៅលើផែនដីនេះ។ សាតាំងកំពុងធ្វើឱ្យពិភពលោកជឿថា ព្រះគម្ពីរគឺជារឿងប្រឌិត ដែលជាសៀវភៅសម្រាប់ទារកនៃពូជសាសន៍ ប៉ុន្តែឥឡូវវាជុតសម័យហើយ។ សៀវភៅដែលនឹងកាត់ទោសវា និងពួកអ្នកតាមវា វាបានដាក់នៅក្នុងទីងងឹត រីឯព្រះអង្គសង្គ្រោះនៃពិភពលោកវិញ វាបានធ្វើឱ្យគេមើលមកទ្រង់ថា គ្មានអ្វីលើសមនុស្សសាមញ្ញឡើយ។ ហើយអ្នកជឿខាងការសម្តែងព្រលឹងវិញ្ញាណ ខំធ្វើឱ្យមើលទៅឃើញថា ក្នុងព្រះជន្មនៃព្រះអង្គសង្គ្រោះ គឺគ្មានអ្វីអស្ចារ្យទាល់តែសោះ។ គេថ្លែងថា ការអស្ចារ្យរបស់គេគឺខ្លាំងលើសកិច្ចដែលព្រះគ្រីស្ទបានប្រព្រឹត្តទៅទៀត។

ឥឡូវនេះ វិញ្ញាណខន្ធនិយមកំពុងបន្លំក្នុងវិស័យគ្រីស្ទាន។ ប៉ុន្តែសេចក្តីបង្រៀនរបស់វា គឺមិនអាចបដិសេធ ឬលាក់បានឡើយ។ ទម្រង់របស់វានាបច្ចុប្បន្ននេះ គឺជាការបញ្ឆោតដ៏គ្រោះថ្នាក់ ហើយប៉ិនប្រសប់ជាងមុនទៅទៀត។ ឥឡូវវាអះអាងថាជឿព្រះគ្រីស្ទ និងព្រះគម្ពីរផង។ ប៉ុន្តែ គេ

បានបកស្រាយព្រះគម្ពីរក្នុងរបៀបដែលធ្វើឱ្យគាប់ចិត្តដល់អ្នកពុំទាន់ផ្លាស់ប្រែចិត្ត។ សេចក្តីស្រឡាញ់ត្រូវបានចាត់ទុកថាជាសម្បត្តិដ៏សំខាន់បំផុតរបស់ព្រះ ប៉ុន្តែត្រូវបានបន្ទាបបន្ថោកទៅជាមនោសញ្ចេតនានិយមដ៏ខ្សោយទៅវិញ។ សេចក្តីប្រកាសរបស់ព្រះ ដើម្បីកាត់ទោសអំពើបាប និងសេចក្តីតម្រូវនៃក្រឹត្យវិន័យបរិសុទ្ធរបស់ទ្រង់ គឺត្រូវបានទុកផុតពីភ្នែក។ រឿងព្រេងទាំងឡាយបាននាំមនុស្សឱ្យបដិសេធថាព្រះគម្ពីរគឺពុំមែនជាគ្រឹះនៃជំនឿរបស់គេទេ។ គេបានបដិសេធព្រះគ្រីស្ទដូចកាលពីមុនដូច្នោះដែរ តែពុំបានយល់ដឹងពីសេចក្តីបោកបញ្ឆោតឡើយ។

មានមនុស្សតិចណាស់ដែលយល់ច្រើនអំពីអំណាចបញ្ឆោតនៃវិញ្ញាណខន្ធនិយមនេះ។ ភាគច្រើនបានលូកលវា គ្រាន់តែដើម្បីបំបាត់សេចក្តីសង្ស័យប៉ុណ្ណោះ។ គេនឹងបានពេញទៅដោយសេចក្តីតក់ស្លុតជាខ្លាំង កាលបើដឹងថាកំពុងហុចខ្លួនឱ្យវិញ្ញាណទាំងនោះគ្រប់គ្រង។ ប៉ុន្តែ គេបានឆ្លងកាត់ទីហាមឃាត់ ហើយមេបំផ្លាញក៏ប្រើអំណាចរបស់វាទាស់នឹងទំនើងចិត្តរបស់គេ។ ឱ្យតែវាល្បួងចិត្តគំនិតរបស់គេឱ្យចុះចូលតាមសេចក្តីបញ្ជារបស់វាម្តងបានចុះ នោះវានឹងចាប់ពួកគេធ្វើជាឈ្លើយជាប្រាកដ។ ក្នុងការឆ្លើយតបដល់ការអធិស្ឋានដ៏អស់ពីចិត្តនោះ គឺគ្មានអំណាចអ្វីក្រៅពីអំណាចរបស់ព្រះទេ ទើបអាចរំដោះពួកគេទាំងនេះបាន។

អស់អ្នកដែលប្រព្រឹត្តអំពើបាបដោយចេតនានោះ គឺកំពុងអញ្ជើញសេចក្តីល្បួងរបស់សាតាំងហើយ។ គេញែកខ្លួនគេពីព្រះ និងពីការគាំពារនៃពួកទេវតារបស់ទ្រង់ផង ម្ល៉ោះហើយគេគ្មានអ្វីការពារខ្លួនសោះ។ «កាលបើអ្នកណាពោលដល់ឯងថា ចូររកពួកគ្រូខាប និងគ្រូគាថា ដែលចេញសំឡេងអ៊ុអ៊ុ ហើយងុមៗ នោះត្រូវឆ្លើយថា គួរគប្បីឱ្យបណ្តាជនស្វែងរកព្រះរបស់ខ្លួនវិញ តើនឹងរកចំពោះរូបខ្មោចជាប្រយោជន៍ដល់មនុស្សរស់ធ្វើអ្វី? ចូរទៅបើកគម្ពីរបញ្ញត្តិ និងសេចក្តីបន្ទាល់មើល បើគេនិយាយមិនត្រូវនឹងព្រះបន្ទូលនោះ នោះគ្មានពន្លឺរះឡើងនៅក្នុងខ្លួនទេ»។ អេសាយ ៨:១៩,២០។

ប្រសិនបើមនុស្សបានមានចិត្តចង់ដឹងសេចក្តីពិតស្តីអំពីនិស្ស័យមនុស្ស និងស្ថានភាពនៃមនុស្សស្លាប់នោះ គេនឹងឃើញក្នុងវិញ្ញាណខន្ធនិយមនូវអំណាចរបស់សាតាំង និងការអស្ចារ្យក្លែងក្លាយទាំងអម្បាលម៉ាណាជាមិនខាន។ ប៉ុន្តែ មនុស្សទាំងឡាយបិទភ្នែកមិនមើលពន្លឺឡើយ ហើយសាតាំងក៏ចាក់សំណាញ់វាជុំវិញពួកគេ។ «ដោយព្រោះគេមិនព្រមស្រឡាញ់ដល់សេចក្តីពិត ដើម្បីឱ្យគេបានសង្គ្រោះនោះ...ហេតុនោះបានជាព្រះទ្រង់នឹងឱ្យសេចក្តីខុសឆ្គងមក បណ្តាលឱ្យគេជឿតាមសេចក្តីភូតភររិញ»។
ថែស្សាឡូនីចទី២ ២:១០,១១។

<u>សុក្រ-២៤ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ២៩

ខព្រះគម្ពីរប្រចាំថ្ងៃ: *សូមជួយអធិស្ឋានឲ្យយើងខ្ញុំផង ដ្បិតយើងខ្ញុំជឿជាក់ថាយើងខ្ញុំមានបញ្ញាចិត្តជ្រះថ្លា ហើយក៏ប្រាថ្នាចង់ប្រព្រឹត្តល្អ ក្នុងគ្រប់ការទាំងអស់។ ហេព្រើរ ១៣:១៨*

អ្នកដែលប្រឆាំងនឹងវិញ្ញាណខន្ធនិយម គេមានកម្លាំងឈ្នះលើសាតាំងនិងពួកទេវតារបស់វា។ សាតាំងនឹងមិនថយខ្លួនមួយចំអាមឡើយ លើកលែងតែនៅពេលពួកអ្នកនាំសារនៃស្ថានសួគ៌ដេញវាចេញ។ វាអាចដកស្រង់បទគម្ពីរ ហើយនិងបង្កាច់សេចក្តីបង្រៀននៅក្នុងបទគម្ពីរនោះទៀតផង។ អ្នកដែលស្ថិតនៅក្នុងជំនាន់គ្រោះថ្នាក់នេះ ត្រូវយល់ក្នុងខ្លួនអំពីទីបន្ទាល់នៃបទគម្ពីរ។

វិញ្ញាណអារក្សដែលក្លែងធ្វើជាញាតិសន្តាន ឬមិត្តភក្តិ នឹងលេចមកសូមឱ្យគេអាណិត ហើយនឹងសម្តែងការអស្ចារ្យ។ យើងត្រូវទប់ទល់ពួកវាដោយសេចក្តីពិតក្នុងព្រះគម្ពីរ ដែលចែងថាមនុស្សស្លាប់ឥតដឹងអ្វីសោះ ហើយអ្នកដែលលេចមកនោះគឺជាវិញ្ញាណអារក្សទេ។

អស់អ្នកដែលមិនបានស្ថាបនាជំនឿលើព្រះបន្ទូលរបស់ព្រះ នឹងត្រូវ

បានគេបញ្ឆោត ហើយបរាជ័យទៅ។ សាតាំងវាប្រព្រឹត្តគ្រប់ទាំងអំពើឆបោក ដោយសេចក្តីទុច្ចរិត ហើយអំពើបោកបញ្ឆោតរបស់វានឹងកើនឡើង។ ប៉ុន្តែ អ្នកដែលស្វែងរកតម្រិះប្រាជ្ញានៃសេចក្តីពិត ហើយធ្វើឱ្យព្រលឹងបានបរិសុទ្ធ ដោយការស្តាប់បង្គាប់នោះ នឹងរកឃើញសេចក្តីការពារខ្លួនដ៏ជាក់លាក់ក្នុង ព្រះនៃសេចក្តីពិត។ ព្រះអង្គសង្គ្រោះនឹងបញ្ជូនគ្រប់ទាំងទេវតាពីស្ថានសួគ៌ មកការពាររាស្ត្រទ្រង់ ជាជាងទុកឱ្យព្រលឹងមួយដែលទុកចិត្តទ្រង់ត្រូវចាញ់ សាតាំង។ អ្នកដែលកំសាន្តខ្លួនដោយជឿជាក់ថាគ្មានទណ្ឌកម្មសម្រាប់អ្នក មានបាប ដែលលះបង់សេចក្តីពិតដែលព្រះនៃនគរស្ថានសួគ៌បានប្រទាន មកជាទីពំនាក់សម្រាប់ការពារថ្ងៃនៃសេចក្តីវឹកវរនោះ នឹងទទួលជឿសេចក្តី កុហករបស់សាតាំង ដែលជាអំពើពុតត្បុតនៃវិញ្ញាណខន្ធនិយមវិញ។

អ្នកសើចចំអកទាំងឡាយ គេចំអកដល់សេចក្តីចែងក្នុងបទគម្ពីរ ស្តីពីគម្រោងការនៃការសង្គ្រោះ ហើយនិងពៀរវេរដែលធ្លាក់ដល់ពួកអ្នក បដិសេធសេចក្តីពិត។ គេបង្ហាញសេចក្តីអាណិតអាសូរយ៉ាងខ្លាំងដល់អ្នក មានគំនិតរៀវ ទន់ខ្សោយ និងដល់ការចេះតែជឿតាម ដើម្បីគោរពតាមសេចក្តី តម្រូវនៃក្រឹត្យវិន័យរបស់ព្រះ។ មនុស្សចំអកទាំងនោះបានហុចខ្លួនគេឱ្យ មេល្បួងទាំងស្រុងគេបានរួបរួមជាមួយវា ហើយផ្សំខ្លួនជាមួយវិញ្ញាណរបស់ វាយ៉ាងជិតជិត រហូតដល់គ្មានការលំអៀងចង់បម្រះចេញពីអន្ទាក់របស់វា សោះឡើយ។

គ្រឹះនៃកិច្ចការរបស់សាតាំង គឺជាសេចក្តីធានាដែលបានបន្លឺដល់នាង អេវ៉ាក្នុងសួនអេដែនថា៖ «អ្នកមិនស្លាប់ជាពិត...»។ «នៅថ្ងៃណាដែលអ្នក បរិភោគ នោះភ្នែកអ្នកនឹងបានភ្លឺឡើង ហើយអ្នកនឹងបានដូចជាព្រះដែរ ព្រម ទាំងដឹងការខុសត្រូវផង»។ លោកុប្បត្តិ ៣:៤,៥។ ស្នាដៃនៃការបញ្ឆោតរបស់ វានឹងបានប្រើក្នុងជំនាន់ចុងក្រោយទៀត។ ហោរាមានប្រសាសន៍ថា៖ «ខ្ញុំ ឃើញវិញ្ញាណអសោចបីដូចជាកង្កែប...ដ្បិតវិញ្ញាណទាំងនោះ ជាវិញ្ញាណ នៃពួកអារក្ស ដែលចេញទៅឯអស់ទាំងស្តេចនៅផែនដីទាំងមូល ទាំងធ្វើ

ទីសម្គាល់ ដើម្បីនឹងប្រមូលស្តេចទាំងនោះមកក្នុងចម្បាំងនៅថ្ងៃដ៏ធំរបស់ព្រះដ៏មានព្រះចេស្តាបំផុត»។ វិវរណៈ ១៦:១៣,១៤។

លោកីយ៍ទាំងមូលនឹងធ្លាក់ចូលក្នុងក្រុមនៃសេចក្តីបំភាន់នេះ លើកលែងតែអស់អ្នកដែលបានថែរក្សាដោយមហិទ្ធិឫទ្ធិរបស់ព្រះ តាមជំនឿក្នុងព្រះបន្ទូលទ្រង់ប៉ុណ្ណោះ។ ពួកមនុស្សត្រូវបានគេនាំឱ្យជឿដោយងាយ ដល់សន្តិសុខដ៏ប្រកបដោយគ្រោះថ្នាក់ ហើយមានតែការបង្អុរសេចក្តីក្រោធរបស់ព្រះប៉ុណ្ណោះទេ ទើបគេភ្ញាក់ដឹងខ្លួនឡើងវិញ។

សេរីភាពនៃសម្បជញ្ញៈស្ថិតក្នុងភាពគ្រោះថ្នាក់

<u>សៅរ៍-២៥ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៣០

ខព្រះគម្ពីរប្រចាំសប្តាហ៍:*បងប្អូនអើយ កាលណាអ្នករាល់គ្នាមានសេចក្តីល្បួងផ្សេងៗ នោះត្រូវរាប់ជាសេចក្តីអំណរសព្វគ្រប់វិញ ដោយដឹងថា ការល្បងលមើលសេចក្តីជំនឿនៃអ្នករាល់គ្នា នោះនាំបង្កើតឲ្យមានសេចក្តីខ្ជាប់ខ្ជួន ។ យ៉ាកុប ១:២-៣*

ឥឡូវនេះក្រុមប្រូតេស្តង់ ពេញចិត្តលទ្ធិរ៉ូមនិយមជាខ្លាំង លើសជាងឆ្នាំមុនៗទៅទៀត។ នៅក្នុងប្រទេសដែលលទ្ធិកាតូលិកនិយមយកផ្លូវសម្របសម្រួលមកបង្កើនឥទ្ធិពលនោះ កំណើនមតិភាគច្រើនយល់ថា ចំណុចសំខាន់ៗរបស់យើងមិនខុសស្រឡះពីគ្នា ដូចដែលបានស្មាននោះទេ ហើយថាបើម្នាក់ៗចុះចូលបន្តិចបន្តួចទៅ នោះនឹងនាំឱ្យយើងត្រូវគ្នានឹងរ៉ូមកាន់តែខ្លាំងឡើងថែមទៀត។ មានពេលមួយនោះ ពួកប្រូតេស្តង់បានបង្រៀនកូនចៅរបស់គេថា ការចុះសម្រុងនឹងរ៉ូម គឺជាការមិនស្មោះនឹងព្រះ។ ប៉ុន្តែ ឥឡូវនេះឃើញថា គេសម្តែងចិត្តគំនិតខុសពីមុនយ៉ាងស្រឡះ។

អ្នកការពារប្រព័ន្ធកាតូលិករ៉ូមពោលថា គេបាននិយាយបង្ខូចឈ្មោះព្រះវិហារ ហើយថាវាមិនយុត្តិធម៌ទេ ក្នុងការវាយតម្លៃវិហារក្នុងសម័យសព្វថ្ងៃនេះ ដោយលើកសំដៅទៅនឹងការកាន់អំណាចក្នុងអំឡុងសតវត្សនៃអវិជ្ជា និងភាពខ្មៅងងឹតនោះ។ គេបានដោះសាសេចក្តីឃោរឃៅដ៏សាហាវរបស់វិហារ ថាជាអំពើល្ងង់ខ្លៅក្នុងសម័យនោះទៅវិញ។

តើមនុស្សទាំងនេះ បានភ្លេចសេចក្តីអះអាងនៃភាពមិនចេះខុស

ដែលអំណាចនេះបន្លឺឡើងហើយឬអ្វី? រ៉ូមបានថ្លែងថា៖ «យោងទៅតាមបទគម្ពីរ វិហារ *មិនដែលខុសឡើយ* ឬក៏ *នឹងខុសដែរ*»។[9]

វិហារកាតូលិកនឹងមិនដែលលះបង់នូវសេចក្តីអះអាងថាខ្លួនមិនចេះខុសនោះឡើយ។ ឱ្យតែសេចក្តីតឹងរ៉ឹងបានដកចេញឥឡូវដោយរដ្ឋាភិបាលលោកីយ៍ចុះ រ៉ូមនឹងយកអំណាចពីអតីតកាលមកកាន់ក្តាប់ជាមិនខាន ហើយក៏នឹងមានការងើបឡើងវិញយ៉ាងឆាប់រហ័ស នូវអំណាចផ្តាច់ការ និងការធ្វើទុក្ខបុកម្នេញទៀតផង។

ជាការពិតណាស់ ដែលមានពួកគ្រីស្ទានពិតប្រាកដ ស្ថិតនៅក្នុងក្រុមជំនុំនៃវិហារកាតូលិករ៉ូម។ មានជនរាប់ពាន់នាក់ក្នុងវិហារនោះ ដែលបម្រើព្រះតាមតែអំពើដែលគេមាន។ ព្រះទ្រង់ទតមើលដល់ព្រលឹងទាំងនេះដោយសេចក្តីអាណិតមេត្តា ព្រោះគេបានទទួលការអប់រំក្នុងជំនឿដែលបំភាន់ និងមិនស្តប់ស្តល់។ ទ្រង់នឹងបណ្តាលឱ្យកាំរស្មីចាំងជះចូលមកក្នុងភពងងឹត ហើយភាគច្រើននឹងមកចូលរួមជាមួយនឹងរាស្ត្រទ្រង់។

ប៉ុន្តែក្នុងនាមជាប្រព័ន្ធមួយ លទ្ធិរ៉ូមនិយម ឥតចុះសម្រុងជាមួយនឹងដំណឹងល្អនៃព្រះគ្រីស្ទក្នុងពេលឥឡូវជាងពេលពីមុនឡើយ។ វិហាររ៉ូមកំពុងប្រើឧបាយកលគ្រប់យ៉ាង ដើម្បីកាន់ក្តាប់ពិភពលោកឡើងវិញ និងដើម្បីបង្កើតការធ្វើទុក្ខទោសសាជាថ្មី ហើយនិងដើម្បីស្រាយនូវអ្វីដែលប្រូតេស្តង់និយមបានចង។ លទ្ធិកាតូលិកនិយមកំពុងបញ្ចេញសំឡេងខ្លាំងខ្លាគ្រប់ទីកន្លែង។ ចូរមើលទៅឯមហាវិទ្យាល័យ និងសិក្ខាសាលាទាំងឡាយរបស់គេដែលល្បី។ ដែលពួកប្រូតេស្តង់បានជួយឧបត្ថម្ភគ្រប់ទិសទីចុះ។ ចូរមើលទៅឯវឌ្ឍនភាពនៃសក្ការពិធីនិយម ក្នុងប្រទេសអង់គ្លេស និងកំណើនខាងជាន់ថ្នាក់នៃពួកកាតូលិកចុះ។

ការសម្រប និងការចុះចូល

ពួកប្រូតេស្តង់បានគាំទ្រលទ្ធិកាតូលិករ៉ូម។ គេបានធ្វើការសម្របសម្រួល និងការចុះចូល ដែលធ្វើឱ្យពួកកាតូលិកផ្ទាល់មានការភ្ញាក់ផ្អើល។

មនុស្សម្នាទាំងឡាយកំពុងតែបិទភ្នែករបស់ខ្លួន មិនមើលចរិតពិតប្រាកដនៃលទ្ធិរ៉ូមនិយមទេ។ ប្រជារាស្ត្រត្រូវតែនាំគ្នាជម្នះនឹងការជឿនទៅមុខនៃសត្រូវនេះ ដែលគ្រោះថ្នាក់ដល់សេរីភាពខាងស៊ីវិល និងខាងសាសនាទៀតផង។

<u>អាទិត្យ-២៦ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ: អេសាយ ជំពូក ៣១

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ។ យ៉ាកុប ១:៥*

ថ្វីដ្បិតតែលទ្ធិរ៉ូមនិយមស្ថិតនៅលើសេចក្តីបោកបញ្ឆោតក៏ដោយ វាមិនជាច្រឡោះបោះ ឬឆ្គាំឆ្គងទេ។ សាសនកិច្ចនៃវិហាររ៉ូម គឺជាពិធីដ៏ឱឡារិកសម្បើមបំផុតមួយ។ ការតែងតាំងដ៏ល្អប្រណីត និងសាសនពិធីដ៏ធ្ងៃតផ្ងង់ទាំងប៉ុន្មាន បានរំជើបរំជួលចិត្តរបស់ពួកបណ្តាជនក្រៃលែង ហើយធ្វើឱ្យគេគិតពិចារណាលែងបាន ព្រមទាំងធ្វើឱ្យសម្បជញ្ញៈស្ពឹកទៀតផង។ ភ្នែកត្រូវជាប់ស្នេហ៍។ វិហារដ៏រុងរឿងត្រចះត្រចង់ ការតម្រៀបជាជួរយ៉ាងគួរពេចពិលរមិលមើល អាសនាមាស ទីសក្ការបូជាដែលធ្វើពីគ្រឿងមាសពេជ្រគំនូរដ៏ល្អប្រណីត និងរូបចម្លាក់ដ៏ល្អឆើត ទាក់ភ្នែកអ្នកស្រឡាញ់សម្រស់ណាស់។ ចំណែកឯភ្លេងតូរ្យតន្ត្រីវិញ គឺគ្មាននរណាអាចលើសបានឡើយ។ សំឡេងដ៏ពីរោះនៃគ្រឿងព្យាណូខ្យល់ លាយឡំជាមួយទំនុកចម្រៀងជាច្រើនទៀត ពេលបំពងចេញពីកំពូលដ៏ខ្ពស់ និងកាត់តាមសសរច្រកផ្លូវដើរនៃមហាវិហារដ៏រុងរឿងនោះមក ធ្វើឱ្យគេកោតក្នុងចិត្ត និងមានចិត្តគោរពយ៉ាងក្រៃលែង។

ភាពត្រចះត្រចង់ និងពិធីអឺកធឹកតែសំបកខាងក្រៅនេះ គឺជាការចំអកដល់សេចក្តីទន្ទឹងចាំនៃព្រលឹង ដែលទ្រុឌទ្រោមដោយបាបកម្មទៅវិញ។

សាសនាព្រះគ្រីស្ទ មិនត្រូវការការទាក់ចិត្តដូចនេះទេ។ រស្មីចាំងចេញពីឈើឆ្កាង រំលេចពន្លឺភ្លឺបរិសុទ្ធហើយគួរឱ្យស្រឡាញ់ ដែលគ្មានការតុបតែងខាងក្រៅណា អាចធ្វើឱ្យលើសតម្លៃពិតប្រាកដនេះបានឡើយ។

ការឱ្យតម្លៃខ្ពស់ដល់វិចិត្រកម្ម ការចូលចិត្តនឹងអ្វីដែលល្អប្រណីត គឺច្រើនតែជាប្រការដែលសាតាំងប្រើ ដើម្បីនាំមនុស្សឱ្យភ្លេចនូវការចាំបាច់របស់ព្រលឹង ហើយនិងនាំឱ្យមនុស្សរស់នៅសម្រាប់តែលោកនេះប៉ុណ្ណោះ។

អធិកភាព និងពិធីអឺកធឹកនៃការគោរពថ្វាយបង្គំរបស់ពួកកាតូលិក មានឥទ្ធិពលទាក់ទាញ ហើយនិងមានមន្តស្នេហ៍ ដែលបញ្ឆោតមនុស្សជាច្រើន។ គេមកមើលវិហារ៉ូម ហើយចាត់ទុកថាជាទ្វារស្ថានសួគ៌។ គ្មានអ្នកណាមួយអាចច្រានចេញនូវឥទ្ធិពលរបស់វិហារនេះបានទេ លើកលែងតែអ្នកដែលតាំងជំហររឹងមាំលើគ្រឹះនៃសេចក្តីពិត ដែលមានចិត្តផ្លាស់ប្រែជាថ្មីដោយព្រះវិញ្ញាណរបស់ព្រះប៉ុណ្ណោះ។ អ្វីដែលពួកមនុស្សប្រាថ្នាចង់បាននោះ គឺទម្រង់សាសនាដែលគ្មានអំណាចនោះឯង។

ការដែលវិហារអះអាងថាមានសិទ្ធិលើកលែងទោស គឺនាំឱ្យពួកកាតូលិករ៉ូម មានអារម្មណ៍ធូរធានឹងអំពើបាប ហើយសក្ការពិធីនៃការសារភាព រមែងអនុញ្ញាតឱ្យប្រព្រឹត្តអំពើអាក្រក់។ អ្នកដែលលុតជង្គង់នៅចំពោះមនុស្សមានបាបដូចគ្នា ហើយបើកសារភាពនូវការនឹងគិតដ៏សម្ងាត់ដែលនៅក្នុងចិត្តរបស់ខ្លួន គឺបង្អាប់ដល់ព្រលឹងខ្លួនហើយ។ ក្នុងការរ៉ាយរ៉ាប់ប្រាប់អំពីបាបទាំងឡាយនៃជីវិតរបស់ខ្លួនដល់សង្ឃ ដែលជាមនុស្សមានបាបដែរនោះ ចរិតលក្ខណៈរបស់គេត្រូវបានបន្ទាបចុះ ហើយត្រូវទទួលសេចក្តីស្មោកគ្រោកជាផលវិបត្តិវិញ។ គំនិតគិតពីព្រះរបស់គេត្រូវបានអាប់អួ លុះដូចជាមនុស្សជាតិដែលធ្លាក់ខ្លួនដុនដាប ដោយព្រោះសង្ឃឈរជាអ្នកតំណាងព្រះ។ ការសារភាពដ៏អាប់ឱន ពីមនុស្សដល់មនុស្សនេះ គឺជាប្រភពទឹកសម្ងាត់ដែលច្រើនតែបង្ហូរសេចក្តីអាក្រក់ដែលកំពុងធ្វើឱ្យពិភពលោកស្មោកគ្រោក។ តែចំពោះអ្នកដែលស្រឡាញ់នឹងការបណ្តោយខ្លួនវិញ

ការសារភាពដល់មនុស្សសាមញ្ញ នោះវាគាប់ចិត្តជាងការចែករំលែកបញ្ហាខ្លួនទៅព្រះទៅទៀត។ ការធ្វើទុក្ករកិរិយាជាជាងលះបង់អំពើបាប ជាការងាយស្រួលដល់ធម្មជាតិមនុស្ស ហើយក៏ជាការងាយស្រួលមួយទៀតផងដែរ ដើម្បីបំបាក់សាច់ឈាមដោយសម្តែងអាការៈតែពីខាងក្រៅ បែបដូចជាសំពត់ធ្មៃជាជាងឆ្កាងសេចក្តីត្រេកត្រអាលខាងសាច់ឈាមវិញ។

<u>ចន្ទ-២៧ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៣២

ខព្រះគម្ពីរប្រចាំថ្ងៃ: *មានពរហើយ មនុស្សណាដែលស៊ូទ្រាំនឹងសេចក្តីល្បួង ដ្បិតកាលណាត្រូវល្បងល ឃើញថាខ្ជាប់ខ្ជួនហើយ នោះនឹងទទួលបានមកុដនៃជីវិត ដែលព្រះអម្ចាស់ទ្រង់សន្យានឹងប្រទានឲ្យដល់អស់អ្នកណាដែលស្រឡាញ់ទ្រង់។ យ៉ាកុប ១:១២*

តាពដូចគ្នាយ៉ាងខ្លាំង

ក្នុងពេលដែលពួកជូវជាន់ឈ្លីក្រឹត្យវិន័យរបស់ព្រះដោយសម្ងាត់ នៅពេលព្រះគ្រីស្ទយាងមកជាលើកទីមួយនោះ គេមានចិត្តមោះមុតតែខាងក្រៅក្នុងការគោរពសិក្ខាបទទាំងប៉ុន្មាន ដោយធ្វើតាមគ្រប់តួអក្សរយ៉ាងខ្ជាប់ខ្ជួនរហូតដល់ធ្វើឱ្យមានអំពល់ទុក្ខជាខ្លាំង ក្នុងការគោរពប្រតិបត្តតាម។ ពួកជូវប្រកាន់ថាខ្លួនខំគោរពក្រឹត្យវិន័យយ៉ាងណានោះ ពួកកាតូលិករ៉ូមក៏ប្រកាន់ថាគោរពឈើឆ្កាងយ៉ាងនោះដែរ។

គេដាក់ឈើឆ្កាងលើវិហារ អាសនា និងលើសំលៀកបំពាក់របស់គេ។ គ្រប់ទីកន្លែង គេបានសម្តែងការគោរព និងការលើកតម្កើងផ្លាកឈើឆ្កាង។ ប៉ុន្តែ សេចក្តីបង្រៀនរបស់ព្រះគ្រីស្ទ ត្រូវបានកប់ក្រោមទំនៀមទម្លាប់ដែលគ្មានប្រយោជន៍ និងក្រោមការខំប្រឹងប្រព្រឹត្តតាមគ្រប់តួអក្សរទៅវិញ។ ពួកអ្នកដែលមានជំនឿខ្ជាប់ខ្ជួន ត្រូវបានរក្សាទុកឱ្យភ័យខ្លាចដល់សេចក្តីក្រោធរបស់ព្រះ ក្នុងពេលដែលពួកគ្រូគង្វាលជាន់ខ្ពស់នៃវិហារ រស់នៅក្នុងជីវិត

សម្បូរហូរហៀរ និងក្នុងសេចក្តីសប្បាយតាមតម្រេក។

ការខិតខំតស៊ូរបស់សាតាំង គឺដើម្បីបង្ខូចចរិតលក្ខណៈរបស់ព្រះ និស្ស័យអំពើបាប ព្រមទាំងរឿងរ៉ាវពិតប្រាកដដែលទាក់ទងក្នុងមហាវិវាទ។ កលល្បិចដ៏ប៊ិនប្រសប់របស់វាបណ្តាលឱ្យមនុស្សធ្វើបាប។ ក្នុងពេលជាមួយគ្នា វាបណ្តាលឱ្យគេយល់ខុសពីព្រះ ដើម្បីឱ្យគេគោរពព្រះអង្គដោយសេចក្តីភ័យខ្លាច និងសេចក្តីស្អប់ ជាជាងដោយសេចក្តីស្រឡាញ់។ ដោយការយល់ខុសអំពីគុណធម៌របស់ព្រះ គេបាននាំឱ្យប្រទេសឥតសាសនាជាក់លាក់ជឿថា ការធ្វើយញ្ញបូជាមនុស្ស គឺជាការចាំបាច់ ដើម្បីឱ្យព្រះសព្វព្រះទ័យ។ សេចក្តីយោរយៅដ៏សាហាវយង់ឃ្នង ត្រូវបានប្រព្រឹត្តឡើងតាមទម្រង់ផ្សេងៗទៀត ក្រោមការគោរពរូបចម្លាក់។

សហភាពនៃសាសនាជទៃ និងគ្រីស្ទសាសនា

វិហារកាតូលិករ៉ូម កំពុងតែបង្រូបបង្រួមសាសនាដទៃ និងគ្រីស្ទសាសនា ហើយដូចជាសាសនាដទៃដែរ វិហារនេះកំពុងតែបង្ខូចចរិតលក្ខណៈរបស់ព្រះ ហើយក៏បានអនុវត្តនូវអំពើយោរយៅមិនតិចជាងមុនឡើយ។ ពួកសង្ឃជាន់ខ្ពស់បានស្វែងរកមធ្យោបាយ ដើម្បីដាក់ទារុណកម្មយ៉ាងតឹងរ៉ឹងបំផុត ដោយមិនចាំបាច់ផ្តាច់ជីវិតនៃអ្នកដែលមិនព្រមចុះចូលទៅនឹងសេចក្តីអះអាងរបស់ខ្លួន។ ក្នុងករណីភាគច្រើនអ្នករងទុក្ខបានប៉ងរកសេចក្តីស្លាប់ ព្រោះជាការបន្ធូរសម្រាលដ៏ផ្អែមមួយ។

ដើម្បីឱ្យបានជឿខ្ជាប់ខ្ជួននឹងរ៉ូម គេបានប្រើការវាយដំ ការបង្អត់អាហារ និងការបន្តឹងយ៉ាងខ្លាំងក្លាដល់សព៌ាង្គកាយ ជាវិន័យ។ ដើម្បីឱ្យបានគាប់ព្រះហប្ចទ័យពីស្ថានសួគ៌ គេបានបង្រៀនអ្នកលន់តូទោស ឱ្យផ្តាច់ចំណងដែលព្រះបានបង្កឡើងដើម្បីប្រទានប្រសិទ្ធិពរ និងដើម្បីធ្វើឱ្យមនុស្សរីករាយ ក្នុងការស្នាក់នៅផែនដីបណ្តោះអាសន្ននេះ។ ក្នុងទីធ្លាវិហារ មានជនរងគ្រោះរាប់ពាន់នាក់ ដែលចំណាយជីវិតគេជាអសារបង់ ដើម្បីព្យាយាមទប់គ្រប់ទាំងគំនិត និងអារម្មណ៍នៃសេចក្តីអាណិតអាសូរ មិនឱ្យមានសម្រាប់

គ្នាទៅវិញទៅមក ព្រោះខ្លាចព្រះប្រកាន់ទោស។

ព្រះពុំបានដាក់បន្ទុកដ៏ធ្ងន់យ៉ាងនេះដល់មនុស្សទេ។ ព្រះគ្រីស្ទពុំបានធ្វើគំរូដល់ជនស្រីប្រុសឱ្យនៅតែក្នុងវត្តអារាម ដើម្បីឱ្យសមនឹងបានចូលទៅស្ថានសួគ៌ទេ។ ព្រះអង្គពុំដែលបង្រៀនឱ្យទប់សេចក្តីស្រឡាញ់ឡើយ។

ស្តេចប៉ាបបានអះអាងខ្លួនថាជាអ្នកតំណាងព្រះគ្រីស្ទ។ ប៉ុន្តែ តើមានដែលឮព្រះគ្រីស្ទបញ្ជូនមនុស្សឱ្យចូលគុក ដោយព្រោះតែគេមិនបានឱនគោរពដល់ទ្រង់ជាស្តេចនៃស្ថានសួគ៌ឬទេ? តើមានព្រះសូរសៀងទ្រង់ កាត់ទោសដល់ស្លាប់ចំពោះជនណាដែលមិនបានទទួលទ្រង់ឬទេ?

ឥឡូវវិហារ៉ូម បង្ហាញមុខដល់ពិភពលោក ដោយប្រើវិធីខមាទោស ដើម្បីគ្របបាំងប្រវត្តិនៃអំពើសាហាវយង់ឃ្នងរបស់ខ្លួន។ គេបានបំពាក់ខ្លួនគេដោយសំលៀកបំពាក់ដូចជាព្រះគ្រីស្ទ ប៉ុន្តែគេនៅតែមិនផ្លាស់ប្តូរដដែល។ គ្រប់ទាំងគោលការណ៍នៃប្រព័ន្ធកាតូលិកក្នុងអតីតកាល នៅតែមានដល់សព្វថ្ងៃ។ គោលលទ្ធិដែលគេច្នៃក្នុងសម័យងងឹត នៅតែមានគេកាន់តាម។ ប្រព័ន្ធកាតូលិកដែលពួកប្រូតេស្តង់កំពុងគោរពឥឡូវនេះ គឺជាប្រព័ន្ធដដែលដែលបានកាន់ក្តាប់ក្នុងជំនាន់នៃកំណែទម្រង់ នៅពេលដែលជនរបស់ព្រះបានឈរឡើងប្តូរជីវិតដើម្បីបើកសម្តែងសេចក្តីទុច្ចរិតរបស់វិហារ។

<u>អង្គារ-២៨ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៣៣

ខព្រះគម្ពីរប្រចាំថ្ងៃ:*កាលណាមានសេចក្តីល្បួង នោះកុំឲ្យអ្នកណានិយាយថា ព្រះទ្រង់ល្បួងខ្លួនឡើយ ដ្បិតសេចក្តីអាក្រក់ពុំអាចនឹងល្បួងនាំព្រះហឫទ័យព្រះបានឡើយ ហើយព្រះក៏មិនដែលល្បួងអ្នកណាដែរ ។ យ៉ាកុប ១:១៣*

ប្រព័ន្ធកាតូលិក គឺជាអ្វីដែលបទទំនាយថាជាយ៉ាងណានោះឯង ពេលគឺជាការងាកចេញពីជំនឿក្នុងជំនាន់ក្រោយ។ សូមអាន ថែស្សាឡូនីចទី២

២:៣,៤។ នៅខាងក្រោមការប្តូរសម្បុរនៃសត្វបង្កួយ មានលាក់ពឹសដែលមិនផ្លាស់ប្តូររបស់សត្វពស់។ តើអំណាចដែលមានកំណត់កត់ទុកដោយឈាមនៃពួកបរិសុទ្ធអស់មួយពាន់ឆ្នាំ ឥឡូវត្រូវទទួលស្គាល់ថាជាផ្នែកមួយនៃវិហារនៃព្រះគ្រីស្ទបានឬ?

ការផ្លាស់ប្តូរក្នុងលទ្ធិប្រូតេស្តង់និយម

គេបានលើកថ្លែងសេចក្តីអះអាង ក្នុងប្រទេសដែលកាន់លទ្ធិប្រូតេស្តង់ថា លទ្ធិកាតូលិកនិយម ខុសគ្នាពីលទ្ធិប្រូតេស្តង់និយមជាងជំនាន់មុនៗ តែបន្តិចបន្តួចប៉ុណ្ណោះ។ មានការផ្លាស់ប្តូរ តែការផ្លាស់ប្តូរ គឺពុំមែននៅក្នុងប្រព័ន្ធកាតូលិកទេ។ លទ្ធិកាតូលិកនិយមមានសណ្ឋានស្រដៀងនឹងលទ្ធិប្រូតេស្តង់និយមដែលមាននៅសព្វថ្ងៃនេះ ពីព្រោះប្រូតេស្តង់និយម បានអន់ថយយ៉ាងខ្លាំងចាប់ពីជំនាន់នៃពួកកែទម្រង់មក។

វិហារប្រូតេស្តង់ ដែលកំពុងចង់បានឱ្យពិភពលោកលំអៀងមកខាងខ្លួន ជឿថាក្នុងសេចក្តីអាក្រក់ មានសេចក្តីល្អ ម្ល៉ោះហើយក្នុងទីបំផុតគេនឹងជឿថា ក្នុងសេចក្តីល្អ មានសេចក្តីអាក្រក់។ ឥឡូវនេះគេកំពុងតែសុំទោសរ៉ូម ដោយមិនចំមុខ ចំពោះសេចក្តីសៅហ្មងនឹងរ៉ូម ហើយអង្វរឱ្យគេអភ័យទោស ដោយព្រោះគេបាន «ប្រកាន់ថាខ្លួនត្រូវ»។ ពួកគេជាច្រើនលើកឡើងថា ភាពងងឹតនៃបញ្ញានិងសីលធម៌ដែលមានក្នុងមជ្ឈិមសម័យ បានជួយឱ្យមានការរាលដាលនៃជំនឿអកុសល និងការជិះជាន់របស់រ៉ូម ហើយថាបញ្ញាឈ្លាសវៃយ៉ាងខ្លាំងក្នុងសម័យទំនើប និងការមានសេរីភាពកាន់តែច្រើនឡើងក្នុងវិស័យនៃសាសនា គឺជាបម្រាមហាមមិនឱ្យមានការរស់ឡើងវិញនៃសេចក្តីទ្រាំមិនបាន។ ការគិតថាទិដ្ឋភាពរបៀបនេះនឹងមានក្នុងសម័យរុងរឿងនេះ គឺត្រូវបានចំអកឱ្យទៅវិញ។ ប៉ុន្តែ គួរចងចាំថា ឱ្យតែមានពន្លឺច្រើនប៉ុណ្ណា សេចក្តីងងឹតនៃអ្នកដែលបង្វែរ និងបដិសេធពន្លឺនោះក៏ច្រើនប៉ុណ្ណោះដែរ។

ជោគជ័យនៃប្រព័ន្ធកាតូលិក គឺបានពឹងផ្អែកទៅលើជំនាន់នៃសេចក្តីងងឹតយ៉ាងខ្លាំងខាងបញ្ញា។ ជំនាន់នៃរស្មីភ្លឺត្រចះត្រចង់ខាងបញ្ញា ក៏កាន់តែ

ល្អដូចគ្នាដែរ។ កាលពីអតីតកាល នៅពេលមនុស្សគ្មានតម្រិះប្រាជ្ញាអំពី
សេចក្តីពិត ពួកគេរាប់ពាន់នាក់ត្រូវបានជាប់អន្ទាក់ ដោយពុំបានឃើញសំណាញ់
ដែលលាតត្រដាងសម្រាប់ទាក់ជើងខ្លួន។ ក្នុងតំណាននេះ ភាគច្រើនពុំបានដឹង
ពីអន្ទាក់នោះទេ ហើយក៏ដើរចូលទៅដោយស្រួលដូចងងឹតភ្នែកដូច្នោះ។
នៅពេលមនុស្សលើកតម្កើងទ្រឹស្តីរបស់ខ្លួនលើព្រះបន្ទូលរបស់ព្រះ បញ្ហាវាង
វៃអាចនាំមកនូវគ្រោះថ្នាក់ជាងសេចក្តីលួងខ្លៅទៅទៀត។ ដូច្នេះ វិទ្យាសាស្ត្រ
ក្លែងក្លាយក្នុងសម័យបច្ចុប្បន្ននេះ នឹងបង្ហាញថាមានការជោគជ័យក្នុងការ
រៀបចំផ្លូវឱ្យមនុស្សទទួលប្រព័ន្ធកាតូលិក ដូចគ្នានឹងការឃុំឃាំងចំណេះវិជ្ជា
ក្នុងសម័យងងឹតដូច្នោះដែរ។

ការគោរពថ្ងៃអាទិត្យ

ការគោរពថ្ងៃអាទិត្យគឺជាទំនៀមទម្លាប់ ដែលបានចាប់ផ្តើមដោយ
វិហារ៉ូម ដែលអះអាងថាជាសញ្ញានៃអាជ្ញាធររបស់គេ។ គោលគំនិតនៃប្រព័ន្ធ
កាតូលិកស្តីពីការចុះសម្រុងនឹងទំនៀមទម្លាប់លោកីយ៍ និងការគោរពប្រពៃ
ណីរបស់មនុស្សលើក្រឹត្យបញ្ញត្តិរបស់ព្រះ គឺកំពុងតែជ្រាបចូលទៅក្នុងវិហារ
ប្រូតេស្តង់ ហើយនាំគេឱ្យលើកតម្កើងថ្ងៃអាទិត្យ ដូចដែលប្រព័ន្ធកាតូលិក
បានលើកតម្កើងកាលពីមុនមកដែរ។

ព្រះរាជក្រឹត្យ ក្រុមប្រឹក្សាទូទៅ និងបញ្ញត្តិច្បាប់ព្រះវិហារ ដែលបាន
គាំទ្រដោយអំណាចលោកីយ៍ គឺជាជំហានដែលពិធីបុណ្យនៃសាសនាដទៃ
បានទទួលស័ក្តិយសក្នុងពិភពគ្រីស្ទាន។ វិធានការសាធារណៈទីមួយ ដែល
បង្ខំឱ្យគោរពថ្ងៃអាទិត្យ គឺជាច្បាប់ដែលព្រះចៅអធិរាជកុងស្តង់ទីនបានដាក់
មក។ ទោះជាពីខាងក្រៅមើលទៅដូចជាលក្ខន្តិក:នៃសាសនាដទៃក៏ដោយ
ក៏ព្រះចៅអធិរាជនៅតែចេញច្បាប់នេះឱ្យគេប្រតិបត្តតាម បន្ទាប់ពីទ្រង់បាន
ទទួលជឿគ្រីស្ទសាសនាតែឈ្មោះមក។

យូស៊ីបៀស ជាសង្ឃជាន់ខ្ពស់ម្នាក់ ដែលបានសូមជំនួយពីពួកព្រះ
អម្ចាស់ និងជាមិត្រសម្លាញ់ពិសេសរបស់កុងស្តង់ទីន បានថ្លែងអះអាងថា ព្រះ

គ្រីស្ទបានប្តូរថ្ងៃឈប់សម្រាកទៅថ្ងៃអាទិត្យវិញ។ គ្មានទីបន្ទាល់ពីបទគម្ពីរ ធ្វើជាភ័ស្តុតាងសោះឡើយ។ យូស៊ីបៀសផ្ទាល់បានទទួលស្គាល់កំហុសនេះ ដោយមិនដឹងខ្លួន។ «គ្រប់ទាំងអ្វីៗ» គាត់មានប្រសាសន៍ «ដែលជាភារកិច្ច សម្រាប់ធ្វើនៅថ្ងៃឈប់សម្រាក ទាំងអស់នេះយើងបានប្តូរមកឯថ្ងៃនៃព្រះអម្ចាស់ហើយ»[២]។

<u>ពុធ-២៩ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៣៤
ខព្រះគម្ពីរប្រចាំថ្ងៃ: *តែដែលគ្រប់គ្នាកើតមានសេចក្តីល្បួង នោះគឺដោយសារតែសេចក្តីប៉ងប្រាថ្នារបស់ខ្លួននាំប្រទាញ ហើយលួងលោមទេ។ យ៉ាកុប ១:១៤*

នៅពេលប្រព័ន្ធកាតូលិកត្រូវបានស្ថាបនាឡើង ការលើកតម្កើងថ្ងៃអាទិត្យក៏បានបន្តទៅមុខ។ ថ្ងៃទីប្រាំពីរត្រូវបានចាត់ទុកថាជាថ្ងៃឈប់សម្រាកអស់មួយរយៈ ប៉ុន្តែ ការផ្លាស់ប្តូរនៅតែចាប់ផ្តើមជាលំដាប់។ បន្ទាប់មកប៉ាបបានបញ្ជាសង្ឃប្រចាំតំបន់ ឱ្យណែនាំអ្នកដែលបំពានថ្ងៃអាទិត្យ ក្រែងលោគេនឹងនាំមកនូវគ្រោះកាចដ៏ធំមកលើខ្លួនគេ និងអ្នកជិតខាងខ្លួន។

ក្រឹត្យក្រមនៃក្រុមប្រឹក្សា ឃើញថាឥតគ្រប់គ្រាន់ឡើយ អាជ្ញាធរលោកីយ៍ក៏បានអង្វរឱ្យចេញបញ្ញត្តិ ដែលនឹងបំភិតបំភ័យដល់មនុស្សទាំងពួង ហើយនិងបង្ខំគេឱ្យឈប់ធ្វើការនៅថ្ងៃអាទិត្យ។ នៅក្នុងអង្គប្រជុំនៃគណៈប្រតិភូប្រចាំវិហារដែលបានប្រព្រឹត្តឡើងក្នុងក្រុងរ៉ូម អស់ទាំងការសម្រេចពីមុនទាំងប៉ុន្មាន ត្រូវបានបញ្ជាក់សាជាថ្មី ហើយបានបញ្ចូលក្នុងច្បាប់សាស្ត្រាចារ្យ ទាំងបានចេញឱ្យប្រតិបត្តដោយអាជ្ញាធរស៊ីវិលផងដែរ។[៣]

ការដែលឥតមានអំណាចពីបទគម្ពីរឱ្យគាំទ្រនូវការគោរពថ្ងៃអាទិត្យ បានធ្វើឱ្យមានសេចក្តីអាម៉ាស់។ ប្រជាជនបានសួរសិទ្ធិរបស់គ្រូខ្លួន ក្នុងការផាត់ចោលសិក្ខាបទនេះ គឺ «ថ្ងៃទីប្រាំពីរជាថ្ងៃឈប់សម្រាកថ្វាយព្រះ

យេហូវ៉ាជាព្រះនៃឯង» ហើយបែរមកគោរពថ្ងៃនៃព្រះអាទិត្យទៅវិញ។ ដើម្បីបំពេញការខ្វះខាតនៃទីបន្ទាល់នៃព្រះគម្ពីរ មធ្យោបាយផ្សេងទៀតគឺជាការចាំបាច់។

អ្នកគាំទ្រថ្ងៃអាទិត្យដ៏ខ្ជាប់ខ្ជួនម្នាក់ ដែលបន្ទាប់ពីបានអញ្ជើញទៅទស្សនាវិហារអង់គ្លេសនៅចុងសតវត្សទីដប់ពីរ ត្រូវបានពួកស្មរបន្ទាល់ស្មោះត្រង់សម្រាប់សេចក្តីពិតជំទាស់នឹងគាត់ ម្ល៉ោះហើយ ការខិតខំចាកចេញពីស្រុកទេសដោយមានមូលហេតុមួយនោះ ក្លាយជាឥតផលប្រយោជន៍ទៅវិញ។ នៅពេលគាត់ត្រឡប់មកវិញ គាត់បានយកសំណុំរឿងមួយ ទាំងអះអាងថាបានមកពីព្រះផ្ទាល់ ហើយនៅក្នុងនោះមានសេចក្តីបញ្ជាឱ្យគោរពថ្ងៃអាទិត្យ ហើយគាត់ថែមទាំងមានសេចក្តីគំរាមកំហែងដ៏អាក្រក់ ដើម្បីបំភិតបំភ័យដល់អ្នកដែលមិនស្តាប់ឱវាទគាត់។ គាត់បានថ្លែងថាឯកសារដ៏មានតម្លៃនេះ ធ្លាក់មកពីស្ថានសួគ៌ ហើយថាបានរកឃើញនៅក្នុងក្រុងយេរូសាឡិមលើអាសនារបស់សន្តបុគ្គលស៊ីម៉ៀន នៅភូមិគាល់កូថា។ តែតាមពិត បល្ល័ង្កនៃសង្ឃរាជនៅឯរ៉ូមនេះទេ ដែលជាប្រភពនៃឯកសារនោះ។ ការបន្លំក្លែងក្លាយត្រូវបានពួកអ្នកមានតំណែងខ្ពស់នៃវិហារកាតូលិករ៉ូម ចាត់ទុកថាជាការត្រឹមត្រូវតាមច្បាប់ជាយូរមកហើយ។

ប៉ុន្តែ ទោះបីជាបានខំប្រឹងតាំងភាពបរិសុទ្ធនៃថ្ងៃអាទិត្យប៉ុណ្ណឹងហើយក៏ដោយ ក៏ពួកប៉ាបផ្ទាល់បានថ្លែងសារភាពជាសាធារណៈថា ថ្ងៃសប្ប៉ាតហ៍មានអំណាចមកពីព្រះដែរ។ នៅក្នុងសតវត្សទី១៦ ក្រុមប្រឹក្សាកាតូលិករ៉ូមបានថ្លែងថា៖ «ចូរឱ្យអស់ទាំងពួកគ្រីស្ទានចងចាំថា ថ្ងៃទីប្រាំពីរគឺត្រូវបានឧទ្ទិសដល់ព្រះ ហើយត្រូវបានទទួលស្គាល់នឹងគោរពផង មិនមែនត្រឹមតែដោយពួកជូវទេ តែដោយអស់ទាំងអ្នកដទៃទៀត ដែលមានពុតថាគោរពព្រះផងដែរ តែយើងជាពួកគ្រីស្ទាន បានប្តូរថ្ងៃឈប់សម្រាករបស់គេមកជាថ្ងៃនៃព្រះអម្ចាស់ហើយ»។[៤] អ្នកដែលជាន់ឈ្លីក្រឹត្យវិន័យពីស្ថានសួគ៌គឺមិនមែនថាមិនដឹងពីចរិយានៃការប្រព្រឹត្តរបស់ខ្លួនគេនោះទេ។

ពិន័យដ៏ធ្ងន់

ឧទាហរណ៍ដ៏ច្បាស់លាស់នៃនយោបាយរបស់រ៉ូម គឺបានឃើញក្នុងការធ្វើទុក្ខបុកម្នេញដ៏យូរដល់ពួកវ៉ាលដូ ដោយកម្ចាយឈាមអ្នកដែលគោរពថ្ងៃឈប់សម្រាក។ ប្រវត្តិសាស្ត្រនៃវិហារនៅប្រទេសអេធីយ៉ូពី (Ethiopia) និងប្រទេសអាប៊ីសនា (Abyssnia) មានសារៈសំខាន់ណាស់។ ក្នុងក្រអៅនៃសម័យងងឹត ពួកគ្រីស្ទានៃអាហ្វ្រិកកណ្តាល បាននៅឯកោតែឯង ហើយត្រូវពិភពលោកបំភ្លេចចោលហើយជាច្រើនសតវត្ស គេបានអរសប្បាយដោយមានសេរីភាពក្នុងជំនឿរបស់ខ្លួន។ ទីបំផុតវិហារ៉ូមបានដឹងឮពីប្រទេសនេះ ហើយគេបានបញ្ជោតព្រះចៅអធិរាជនៃប្រទេសអាប៊ីសនា ឱ្យទទួលស្គាល់សម្តេចប៉ាបថាជាតួតំណាងព្រះគ្រីស្ទ។ បញ្ញត្តិមួយក៏ត្រូវបានបញ្ចេញ ហាមមិនឱ្យកាន់ថ្ងៃឈប់សម្រាក ក្រោមការពិន័យដ៏ធ្ងន់ធ្ងរ។[៥] ប៉ុន្តែការប្រើអំណាចផ្តាច់ការនៃវិហារកាតូលិករ៉ូម បានក្លាយទៅជាបន្ទុកដ៏ធ្ងន់ រហូតដល់ពួកអាប៊ីសនាខំប្រឹងទម្លាក់ចេញវិញ។ គេបានបណ្តេញពួកកាតូលិករ៉ូមចេញពីតំបន់ត្រួតត្រារបស់ខ្លួន ហើយជំនឿបុរាណក៏បានមានឡើងវិញ។

<u>ព្រហស្បតិ៍-៣០ កញ្ញា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៣៥

ខព្រះគម្ពីរប្រចាំថ្ងៃ: *រួចកាលណាសេចក្តីប៉ងប្រាថ្នាជាប់មានជាផ្ទៃ នោះសំរាលចេញមកជាអំពើបាប ហើយកាលណាបាបបានពោរពេញឡើង នោះក៏បង្កើតជាសេចក្តីស្លាប់។ យ៉ាកុប ១:១៥*

នៅពេលដែលវិហារនៃប្រទេសអាហ្វ្រិកបានរក្សាថ្ងៃទីប្រាំពីរ ក្នុងការស្តាប់ឱវាទដល់បញ្ញត្តិរបស់ព្រះ គេបានរក្សាខ្លួនគេពីការប្រកបការងារនៅថ្ងៃអាទិត្យ ដើម្បីឱ្យស្របទៅនឹងទំនៀមទម្លាប់នៃវិហារ។ រ៉ូមបានជាន់ឈ្លីថ្ងៃឈប់សម្រាករបស់ព្រះ ដើម្បីលើកតម្កើងថ្ងៃឈប់សម្រាករបស់ខ្លួន ប៉ុន្តែវិហារនៃប្រទេសអាហ្វ្រិក ដែលបានលាក់ពួននៅតែឯងជិតមួយពាន់ឆ្នាំនោះ

ពុំបានចូលរួមក្នុងការងាកចេញនេះទេ។ នៅពេលដែលគេបានស្ថិតនៅក្រោមរ៉ូម គេបានបង្ខំពួកគេឱ្យបំភ្លេចថ្ងៃឈប់សម្រាកពិតប្រាកដ ហើយឱ្យលើកតម្កើងថ្ងៃក្លែងក្លាយវិញ។ ប៉ុន្តែ នៅពេលគេបានឯករាជ្យកាលណា គេបានត្រឡប់មកគោរពស្តាប់បង្គាប់ដល់ក្រឹត្យវិន័យទីបួនភ្លាម។

កំណត់ទាំងនេះ បង្ហាញយ៉ាងច្បាស់នៃភាពជាខ្មាំងនៃរ៉ូម ដល់ថ្ងៃឈប់សម្រាកពិតប្រាកដ និងដល់អ្នកគាំទ្រនៃថ្ងៃនោះផង។ ព្រះបន្ទូលរបស់ព្រះបង្រៀនថា ទស្សនីយភាពទាំងនេះនឹងកើតមានឡើងម្តងទៀត នៅពេលពួកកាតូលិក និងពួកប្រូតេស្តង់ រួបរួមគ្នាលើកតម្កើងថ្ងៃអាទិត្យ។

សត្វមានស្នែងដូចកូនចៀម

ទំនាយនៃវិវរណៈជំពូក១៣ ថ្លែងថាសត្វដែលមានស្នែងដូចកូនចៀមនឹងបណ្តាលឱ្យ «ផែនដី និងអស់អ្នកដែលនៅផែនដី» គោរពប្រព័ន្ធកាតូលិករ៉ូម ដែលមានសត្វ «ដូចជាខ្លារខិន» ជានិមិត្តរូប។ សត្វដែលមានស្នែងពីរនឹងនិយាយដល់ «ពួកអ្នកនៅផែនដី ឱ្យធ្វើរូបដល់សត្វនោះ»។ មិនត្រឹមតែប៉ុណ្ណោះ វានឹងបញ្ជាអស់ទាំងអ្នកធំ អ្នកតូច អ្នកមាន អ្នកក្រ អ្នកជា និងទាំងបាវគេផងឱ្យទទួលទីសម្គាល់របស់សត្វនោះ។ វិវរណៈ ១៣:១១-១៦។ សហរដ្ឋអាមេរិកគឺជាអំណាចដែលតំណាងដោយសត្វដែលមានស្នែងដូចកូនចៀម។ ទំនាយនេះនឹងបានសម្រេចនៅពេលសហរដ្ឋអាមេរិកនឹងចេញបញ្ញត្តិឱ្យគោរពថ្ងៃអាទិត្យ ដែលរ៉ូមចាត់ថាជាការទទួលស្គាល់នូវឧត្តមភាព របស់គេ។

«ខ្ញុំឃើញក្បាលវាមួយ ដូចជាបានកាប់សម្លាប់ហើយ តែរបួសដល់ស្លាប់នោះបានសះជាឡើងវិញ ហើយផែនដីក៏អស្ចារ្យនឹងសត្វនោះ»។ វិវរណៈ ១៣:៣។ របួសដល់ស្លាប់ ចង្អុលទៅការរលំធ្លាក់នៃប្រព័ន្ធកាតូលិករ៉ូមក្នុងឆ្នាំ១៧៩៨។ *បន្ទាប់*ពីការនេះមក ហោរាមានប្រសាសន៍ថា៖ «របួសដល់ស្លាប់នោះបានសះជាឡើងវិញ ហើយផែនដីក៏អស្ចារ្យនឹងសត្វនោះ»។ សាវ័កប៉ុលថ្លែងថា «មនុស្សដែលជាតូបាប» នឹងធ្វើកិច្ចបញ្ឆោតរបស់វា រហូតដល់គ្រាចុងក្រោយបង្អស់។ ថែស្សាឡូនីចទី២ ២:៣-៨។ ហើយ «អស់ទាំង

មនុស្សទាំងប៉ុន្មាននៅផែនដី ដែលគ្មានឈ្មោះកត់ទុកក្នុងបញ្ជីជីវិត...នឹង ក្រាបថ្វាយបង្គំចំពោះសត្វនោះ»។ វិវរណៈ ១៣:៨។ នៅក្នុងពិភពលោក ចាស់ និងពិភពលោកថ្មី គេនឹងគោរពប្រព័ន្ធកាតូលិករ៉ូម ក្នុងការគោរពដល់ថ្ងៃអាទិត្យ។

តាំងតែពីពាក់កណ្តាលសតវត្សទី១៩មក សិស្សនៃបទទំនាយបានសម្តែងទីបន្ទាល់នេះទៅដល់ពិភពលោក។ ឥឡូវនេះ មានឃើញវឌ្ឍនភាពយ៉ាងរហ័សមួយ ឆ្ពោះទៅរកការសម្រេចនៃទំនាយនេះ។ រីឯពួកគ្រូប្រូតេស្តង់វិញ ក៏មានការអះអាងដដែលនូវអំណាចពីស្ថានសួគ៌ សម្រាប់ការគោរពនៅថ្ងៃអាទិត្យ ហើយនិងមានការខ្វះខាតបទគម្ពីរជាភ័ស្តុតាង ដូចគ្នានឹងពួកអ្នកដឹកនាំនៃវិហារកាតូលិករ៉ូមដែរ។ ការពោលអះអាងថា សេចក្តីជំនុំជម្រះរបស់ព្រះបានធ្លាក់មកលើមនុស្ស ដោយសារការប្រព្រឹត្តល្មើសថ្ងៃអាទិត្យជាថ្ងៃឈប់សម្រាក នឹងត្រូវបានកើតឡើងម្តងទៀត ហើយគេកំពុងតែចាប់ផ្តើមពោលឡើងរួចស្រេចទៅហើយ។

ភាពប៉ិនប្រសប់នៃវិហារ៉ូមគឺអស្ចារ្យណាស់។ គេអាចឃើញអ្វីដែលនៅអនាគត ពោលគឺថា វិហារប្រូតេស្តង់កំពុងតែឱនគោរពដល់គេ ដោយទទួលស្គាល់ថ្ងៃឈប់សម្រាកក្លែងក្លាយ ហើយពួកគេកំពុងរៀបចំបង្ខំឱ្យចេញប្រតិបត្តជាទូទៅ ដោយមធ្យោបាយដែលវិហារបានប្រើ ក្នុងពេលកន្លងមកហើយនោះ។ គឺជាការមិនពិបាកស្មានទេថា វិហារកាតូលិករ៉ូមត្រៀមខ្លួនចាំតែនឹងជួយពួកប្រូតេស្តង់នៅក្នុងការនេះ។

វិហារកាតូលិករ៉ូមបង្កើតអង្គការដ៏ធំមហិមាមួយ ក្រោមការគ្រប់គ្រងនៃមជ្ឈមណ្ឌលអាជ្ញាធរ៉ូម ដោយមានអ្នកឆ្លងឆ្លើយរាប់លាននាក់នៅគ្រប់ប្រទេស បានចងជាប់ក្នុងសច្ចាប្រណិធានដល់សម្តេចសង្ឃ មិនថាជាតិណា ឬរដ្ឋាភិបាលណាឡើយ។ ទោះបើគេបានស្បថថាស្មោះចំពោះរដ្ឋក៏ដោយ តែនៅពីក្រោយពាក្យទាំងនេះ គឺជាសេចក្តីសច្ចានៃការស្តាប់ឱវាទដល់រ៉ូមវិញ។

ប្រវត្តិសាស្ត្រ ធ្វើបន្ទាល់ប្រាប់ពីការខិតខំតស៊ូដែលប្រកបដោយកលល្បិចរបស់គេ ដើម្បីដាក់ខ្លួនគេចូលទៅក្នុងរឿងរ៉ាវនៃប្រទេសជាតិ លុះដល់មានជំហរមាំមួនហើយ ទើបសម្រេចគោលបំណងរបស់ខ្លួន ទោះជាមានការហិនវិនាសដល់ពួកព្រះអម្ចាស់ និងប្រជាជនយ៉ាងដូចម្តេចក៏ដោយ។[៦]

អំនួតរបស់រ៉ូមគឺថា រ៉ូមមិនដែនផ្លាស់ប្តូរឡើយ។ ជនប្រូតេស្តង់មិនដឹងថាខ្លួនកំពុងធ្វើអ្វីទេនៅពេលដែលគេស្មើជំនួយពីរ៉ូម ក្នុងកិច្ចការនៃការលើកតម្កើងថ្ងៃអាទិត្យនោះ។ នៅពេលគេកំពុងតែតាំងគោលបំណងរបស់គេ រ៉ូមកំពុងតែបម្រុងនឹងស្តាបនាអំណាចរបស់ខ្លួនឡើងវិញ ដើម្បីយកឧត្តមភាពដែលបានបាត់បង់មកវិញ។ ឱ្យតែគោលការនោះបានតាំងឡើងចុះ គឺថាឱ្យតែវិហារគ្រប់គ្រងអំណាចរដ្ឋ ឱ្យតែច្បាប់លោកីយ៍ចេញបញ្ញត្តិឱ្យមានការគោរពសាសនាចុះនិយាយឱ្យខ្លី ឱ្យតែអាជ្ញាធរនៃវិហារ និងរដ្ឋ មានអំណាចលើសតិសម្បជញ្ញៈចុះ នោះរ៉ូមនឹងមានជ័យជម្នះជាពិតប្រាកដមិនខាន។

ពិភពប្រូតេស្តង់នឹងដឹងនូវគោលបំណងរបស់ក្រុងរ៉ូមថាជាអ្វីហើយនៅពេលខ្លួនជាប់អន្ទាក់ ហើយរកវើបម្រះចេញមិនបាន ព្រោះវាហួសពេលទៅហើយ។ រ៉ូមកំពុងតែចម្រើនអំណាចឡើងយ៉ាងស្ងាត់ស្ងៀម។ គោលលទ្ធិទាំងឡាយកំពុងតែបញ្ចេញឥទ្ធិពលក្នុងមន្ទីរនីតិបញ្ញត្តិ ក្នុងវិហារ ព្រមទាំងក្នុងចិត្តរបស់មនុស្សទៀតផង។ គេកំពុងតែចម្រើនកម្លាំងរបស់គេ ដើម្បីសម្រេចគោលបំណងរបស់ខ្លួន រង់ចាំពេលវេលាល្អមកដល់ ដើម្បីនឹងប្រហារ។ អស់ទាំងអ្វីដែលគេចង់បាន គឺទីកន្លែងយកឈ្នះ។ អ្នកណាដែលនឹងជឿហើយស្តាប់តាមព្រះបន្ទូលរបស់ព្រះ នោះនឹងបានទទួលនូវសេចក្តីបន្ទោសហើយនិងការធ្វើទុក្ខទោសជាមិនខាន។

References:

1. John L. von Mosheim, *Institutes of Ecclesiastical History*, bk. 3, century 11, ch. 2, sec. 9, note 17.

2. Robert Cox, *Sabbath Laws and Sabbath Duties*, p. 538.

3. Helyn, *History of the Sabbath*, pt. 2, ch. 5, sec. 7.

4. See Thomas Morer, *Discourse in Six Dialogues on the Name, Notion, and Observation of the Lord's Day*, pp. 281, 282.

5. Michael Geddes, *Church History of Ethiopia*, pp. 311, 312.

6. See John Dowling, *The History of Romanism*, bk. 5, ch. 6, sec. 55; and Mosheim, bk. 3, cent. 11, pt. 2, sec. 9, note 17.

ការប៉ះទង្គិចដែលជិតនឹងកើតឡើង

<u>សុក្រ-១ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៣៦

ខព្រះគម្ពីរប្រចាំថ្ងៃ: *គ្រប់ទាំងរបស់ដ៏ល្អ ដែលព្រះប្រទានមក និងអស់ទាំងអំណោយទានដ៏គ្រប់លក្ខណ៍ នោះសុទ្ធតែមកពីស្ថានលើ គឺមកពីព្រះវរបិតានៃពន្លឺ ដែលទ្រង់មិនចេះប្រែប្រួល សូម្បីតែស្រមោលនៃសេចក្តីផ្លាស់ប្រែក៏គ្មានដែរ។ យ៉ាកុប ១:១៧*

តាំងតែពីដើមដំបូងនៃមហាវិវាទនៅស្ថានសួគ៌មក គោលបំណងរបស់សាតាំងគឺដើម្បីបំបាត់ក្រឹត្យវិន័យរបស់ព្រះ។ ទោះជាការនេះនឹងបានសម្រេចដោយបំបាត់ក្រឹត្យវិន័យទាំងអស់ចោល ឬដោយបដិសេធតែសិក្ខាបទណាមួយ លទ្ធផលគឺដូចគ្នាទេ។ អ្នកដែលប្រព្រឹត្តល្មើស «ក្នុងបទណាមួយ» គឺបង្ហាញសេចក្តីសម្អប់ដល់ក្រឹត្យវិន័យទាំងមូលហើយ ឥទ្ធិពល និងគំរូរបស់គេ គឺស្ថិតនៅខាងសេចក្តីប្រព្រឹត្តរំលង ហើយគេ «ត្រឡប់ជាមានទោសចំពោះក្រឹត្យវិន័យទាំងមូលនោះ» វិញ។ យ៉ាកុប ២:១០។

សាតាំងបានបង្វែរគោលលទ្ធិនៃព្រះគម្ពីរ ម្ល៉ោះហើយសេចក្តីខុសឆ្គងក៏បានជ្រាបចូលក្នុងជំនឿរបស់មនុស្សរាប់ពាន់នាក់។ ការប៉ះទង្គិចចុងក្រោយបង្អស់ដ៏ខ្លាំងបំផុត រវាងសេចក្តីពិត និងសេចក្តីខុសឆ្គង គឺអំពីក្រឹត្យវិន័យរបស់ព្រះ រវាងព្រះគម្ពីរ និងសាសនាប្រឌិត និងទំនៀមទម្លាប់។ មនុស្សគ្រប់រូបអាចមានព្រះគម្ពីរ ប៉ុន្តែមានតិចណាស់ដែលទទួលយកមកធ្វើជាផ្លូវជីវិត។ ក្នុងវិហារវិញ ភាគច្រើនបដិសេធគោលនៃគ្រីស្ទជំនឿ។ ការបង្កបង្កើត មនុស្សក្លាយជាមានបាប សេចក្តីលោះបាប និងក្រឹត្យវិន័យរបស់

ព្រះ ត្រូវបានគេបដិសេធចោលទាំងស្រុង ឬក្នុងផ្នែកណាមួយ។ មនុស្សរាប់ពាន់នាក់ចាត់ទុកថា ការទុកចិត្តយ៉ាងមាំលើព្រះគម្ពីរជាការបង្ហាញនូវភាពកម្សោយ។

ការយកទ្រឹស្តីមិនពិតមកធ្វើជារូបបដិមា ដូចជាឆ្នៃឈើ ឬថ្មធ្វើជារូបចម្លាក់ ជាការងាយស្រួលណាស់។ សាតាំងនាំមនុស្សឱ្យយល់ខុសពីចរិតលក្ខណៈរបស់ព្រះ ដោយមូលបង្កាច់ទ្រង់។ ការលើកតាំងចំណេះវិជ្ជាជារូបបដិមា បានតាំងរាជ្យជួសព្រះដ៏មានព្រះជន្មរស់នៅ ដែលមានសម្តែងក្នុងព្រះបន្ទូលទ្រង់ ក្នុងព្រះគ្រីស្ទ ហើយនិងក្នុងកិច្ចបង្កបង្កើត។ ព្រះរបស់ទស្សនវិទូ អ្នកកវី អ្នកនយោបាយ និងអ្នកសារពត៌មានជាច្រើន ដែលនៅក្នុងសកលវិទ្យាល័យនានា សូម្បីតែក្នុងវិទ្យាស្ថានព្រះគម្ពីរខ្លះផង គឺគ្មានអ្វីគ្រាន់បើប៉ុន្មានជាងព្រះបាល ដែលជាព្រះអាទិត្យនៃភីនីស៊ីយ៉ា នៅជំនាន់ហោរាអេលីយ៉ាទេ។

គ្មានសេចក្តីខុសឆ្គងណាដែលជំទាស់នឹងអំណាចស្ថានសួគ៌ដោយចេញមុខ ហើយគ្មានអ្វីដែលមានលទ្ធផលអាក្រក់ ជាងគោលលទ្ធិនៃក្រឹត្យវិន័យរបស់ព្រះត្រូវលែងមានឥទ្ធិពលទៀតនោះឡើយ។ បើគ្រូគង្វាលល្បីៗបង្រៀនជាសាធារណៈថា ពុំបាច់ត្រូវការគោរពប្រតិបត្តតាមលក្ខន្តិកៈដែលគ្រប់គ្រងទឹកដីរបស់ខ្លួន ព្រោះវាទើសទែងដល់សេរីភាពរបស់ប្រជារាស្ត្រនោះ តើគេទុកឱ្យមនុស្សដូចនេះនៅអធិប្បាយបានយូរប៉ុន្មាន?

ប្រទេសជាតិលុបលក្ខន្តិកៈរបស់ខ្លួនចោល នោះវាសមជាងព្រះដ៏ជាអ្នកកាន់ក្តាប់ពិភពសកលលុបក្រឹត្យវិន័យរបស់ទ្រង់វិញ។ ការធ្វើឱ្យក្រឹត្យវិន័យរបស់ព្រះទៅជាឥតប្រយោជន៍ជាការពិសោធនោះ ត្រូវបានសាកល្បងក្នុងប្រទេសបារាំងរួចទៅហើយ នៅពេលលទ្ធិទមិឡនិយមបានឡើងអំណាចគ្រប់គ្រង។ លទ្ធផលបានបង្ហាញឱ្យឃើញថា ការដកបញ្ញត្តិដែលព្រះបានដាក់មក គឺជាការទទួលច្បាប់របស់ស្តេចនៃសេចក្តីអាក្រក់វិញ។

ការបំភ្លេចចោលក្រឹត្យវិន័យរបស់ព្រះ

អ្នកដែលបង្រៀនប្រជាជនមិនឱ្យយកចិត្តទុកដាក់នឹងបញ្ញត្តិរបស់ព្រះ គឺសាបព្រោះសេចក្តីរឹងចចេស ដើម្បីច្រូតយកសេចក្តីរឹងទទឹងហើយ។ ឱ្យតែបញ្ញត្តិដែលក្រឹត្យវិន័យពីស្ថានសួគ៌ដាក់មកត្រូវបានបំភ្លេចចោលចុះ នោះមិនយូរមិនឆាប់ ច្បាប់របស់មនុស្សក៏នឹងលែងមានគេគោរពដែរ។ លទ្ធផលនៃការបំបែរបង់សិក្ខាបទរបស់ព្រះ គឺជាអ្វីដែលគេមិនបានគិតជាមុន។ ទ្រព្យសម្បត្តិនឹងលែងគង់វង្ស។ មនុស្សនឹងយកកម្មសិទ្ធរបស់អ្នកជិតខាងខ្លួនដោយអំពើហិង្សា ហើយអ្នកដែលខ្លាំងជាងគេបង្អស់ នឹងក្លាយជាអ្នកមានជាងគេ។ គ្មាននរណាគោរពតម្លៃជីវិតឡើយ។ សម្បថក្នុងអាពាហ៍ពិពាហ៍នឹងលែងបានតាំងឈរជាកំពែង ដើម្បីការពារក្រុមគ្រួសារទៀតហើយ។ អ្នកមានអំណាចនឹងយកប្រពន្ធអ្នកជិតខាងខ្លួនដោយហិង្សា។ បញ្ញត្តិទីប្រាំនឹងត្រូវបានទុកចោលដោយឡែក ជាមួយនឹងបញ្ញត្តិទីបួន។ កូននឹងមិនញញើតនឹងប្រល័យជីវិតឪពុកម្តាយរបស់គេទេ ប្រសិនជាធ្វើទៅនឹងបំប៉នសេចក្តីប្រាថ្នានៃចិត្តពុករលួយរបស់ពួកគេ។ ពិភពមានអារ្យធម៌ខ្ពង់ខ្ពស់នឹងក្លាយទៅជាហ្វូងចោរប្លន់ និងហ្វូងឃាតករ ហើយសន្តិសុខ និងសុភមង្គល នឹងត្រូវបានបំបែរបង់ពីផែនដីទៅ។

<u>សៅរ៍-២ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៣៧

ខព្រះគម្ពីរប្រចាំសប្តាហ៍: *ដូច្នេះ បងប្អូនស្ងួនភ្ងាអើយ ចូរឲ្យគ្រប់គ្នាបានឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹងដែរ។ យ៉ាកុប ១:១៩*

គោលលទ្ធិនេះបានបើកទំនប់នៃសេចក្តីទុច្ចរិតមកលើពិភពលោករួចទៅហើយ។ ភាពឥតច្បាប់ និងអំពើពុករលួយ ជះចូលដូចរលកវាយសន្ធប់មកដូច្នោះ។ សូម្បីតែក្នុងក្រុមគ្រួសារនៃអ្នកដែលថាខ្លួនជាអ្នកគ្រីស្ទាន ក៏មានសេចក្តីពុតត្បុត សេចក្តីមិនអើពើនឹងគ្នា សេចក្តីក្បត់សច្ចា និងសេចក្តីបណ្តោយខ្លួនឱ្យត្រេកត្រអាលដែរ។ គោលការសាសនាដែលជាគ្រឹះនៃ

សង្គមជីវិត គឺហាក់បីដូចជាដុំដែលយោលហៀបនឹងរលំធ្លាក់ដូច្នោះ។ ជនឧក្រិដ្ឋដ៏ទុច្ចរិតបំផុត ជាញយៗត្រូវបានធ្វើឱ្យទៅជាតួឯក ធ្វើឱ្យគេផ្តោតអារម្មណ៍មកលើ ហាក់បីដូចជាពួកគេបានទទួលកិត្តិយសខ្ពង់ខ្ពស់ដ៏គួរឱ្យច្រណែន។ មានការផ្សាយជាសាធារណៈយ៉ាងសម្បើមអំពីអំពើឧក្រិដ្ឋរបស់គេ។ សារពត៌មានបោះពុម្ពផ្សាយអំពីអំពើអបាយមុខដ៏គួរឱ្យខ្ពើមរអើម រ៉ាយរ៉ាប់ពីរបៀបដែលអំពើអសីលធម៌បានប្រព្រឹត្តឡើង គឺជាការនាំអាថិអ្នកដទៃឱ្យធ្លាក់ចូលទៅក្នុងអំពើក្លែងបន្លំ អំពើលួចប្លន់ និងអំពើកាប់សម្លាប់ទៀតផង។ សេចក្តីឈ្លក់ចិត្តនឹងអំពើអសីលធម៌ សេចក្តីឥតប្រមាណដ៏អាក្រក់ សេចក្តីទុច្ចរិតគ្រប់ជំពូក គួរតែធ្វើឱ្យមនុស្សទាំងអស់ភ្ញាក់រលឹកស្មារតីឡើង។ តើអាចធ្វើអ្វីខ្លះដើម្បីបញ្ឈប់រលកនៃសេចក្តីអាក្រក់នេះបាន?

សេចក្តីឥតប្រមាណបានពង្វក់ជនជាច្រើន

តុលាការក៏ពុករលួយទៅ អ្នកកាន់ក្តាប់ទាំងឡាយគិតរកតែចំណេញ ហើយគាប់ចិត្តនឹងអ្វីដែលស្រើបស្រាល។ សេចក្តីឥតប្រមាណបានពង្វក់ជនជាច្រើន ធ្វើឱ្យសាតាំងគ្រប់គ្រងគេស្ទើរតែទាំងស្រុងទៅហើយ។ អ្នកបង្កើតច្បាប់បញ្ញត្តិទាំងឡាយ បានឡប់សតិ ស៊ីសំណូកសូកប៉ាន់ រិនិច្ឆ័យមិនត្រឹមត្រូវ។ សេចក្តីប្រមឹក សេចក្តីសប្បាយហោកញ្ជ្រៀវ និងសេចក្តីមិនស្មោះត្រង់គ្រប់ជំពូក គឺបានកើតឡើងក្នុងចំណោមអ្នកចាត់ចែងច្បាប់។ ឥឡូវនេះ ហេតុដែលសាតាំងមិនអាចគ្រប់គ្រងពិភពលោក ដោយព្រោះវាមិនអាចបំបិទបទគម្ពីរបានទៀតនោះ ធ្វើឱ្យវារកមធ្យោបាយផ្សេងទៀត ដើម្បីសម្រេចកម្មវត្ថុដដែល។ ការបំផ្លាញជំនឿដល់ព្រះគម្ពីរ ក៏ដូចជាការបំផ្លាញព្រះគម្ពីរដែរ។

ដូចជានៅជំនាន់ដើមដែរ វាបានធ្វើការតាមរយៈព្រះវិហារ ដើម្បីសម្រេចគម្រោងការណ៍របស់វា។ ក្នុងការប្រយុទ្ធនឹងសេចក្តីពិតទាំងឡាយនៅក្នុងបទគម្ពីរដែលគេមិននិយមជឿ គេយកសេចក្តីពន្យល់ផ្សេងៗដែល

សាបព្រោះគ្រាប់ពូជនៃសេចក្តីសង្ឃឹយវិញ។ ដោយគោងជាប់ទៅនឹង សេចក្តីខុសឆ្គងកាតូលិករ៉ូម ស្តីអំពីអមត:ជាធម្មជាតិ និងភាពមានស្មារតីដឹងខ្លួនរបស់មនុស្សស្លាប់ គេបដិសេធសេចក្តីការពារតែមួយគត់ពីសេចក្តីបញ្ឆោតនៃវិញ្ញាណខន្ធនិយម។ គោលលទ្ធិនៃការរងទុក្ខវេទនាអស់កល្បជានិច្ច បាននាំឱ្យមនុស្សជាច្រើនលែងជឿព្រះគម្ពីរ។ នៅពេលខ្លឹមសារនៃបញ្ញត្តិទីបួននឹងត្រូវបានលើកមក គេនឹងយល់ថា ការគោរពថ្ងៃឈប់សម្រាកនៅថ្ងៃទីប្រាំពីរ គឺជាការបញ្ជាឱ្យធ្វើ ហើយដើម្បីដោះខ្លួនគេពីភារកិច្ចដែលគេមិនចង់ធ្វើនោះ ពួកគ្រូល្បីៗក៏បដិសេធចោលក្រឹត្យវិន័យរបស់ព្រះ និងថ្ងៃឈប់សម្រាកតែម្តងទៅ។ នៅពេលការកែទម្រង់ដល់ថ្ងៃឈប់សម្រាកកាន់តែបន្តទៅមុខ ការបដិសេធក្រឹត្យវិន័យពីស្ថានសួគ៌ដើម្បីជៀសវាងបញ្ញត្តិទីបួន នឹងស្ទើរតែក្លាយទៅជារឿងរ៉ាវដែលរាលដាលទូទាំងសកលលោកដែរ។ អ្នកដឹកនាំសាសនានាំឱ្យមានការខ្វះជំនឿវិញ្ញាណខន្ធនិយម និងសម្លប់ដល់ក្រឹត្យវិន័យដ៏បរិសុទ្ធរបស់ព្រះ។ នេះជាទំនួលខុសត្រូវដ៏គួរឱ្យខ្លាចមួយចំពោះអំពើទុច្ចរិតដែលមានក្នុងពិភពគ្រីស្ទាន។

តែក្រុមនេះអះអាងថា ការបញ្ចេញច្បាប់ឱ្យគោរពថ្ងៃអាទិត្យ នឹងចម្រើនសីលធម៌នៃសង្គមវិញ។ ឧបាយកលរបស់សាតាំង គឺដើម្បីបង្រួមភាពខុសឆ្គងជាមួយសេចក្តីពិតខ្លះៗ ឱ្យល្មមតែគេជឿ។ អ្នកដឹកនាំចលនានៃថ្ងៃអាទិត្យ អាចគាំទ្រកំណែទម្រង់ដែលប្រជាជនត្រូវការ គឺគោលការណ៍ដែលសមស្របនឹងព្រះគម្ពីរ តែក្នុងពេលដែលគោលការណ៍ទាំងនេះ មានសេចក្តីតម្រូវមួយដែលផ្ទុយនឹងក្រឹត្យវិន័យរបស់ព្រះ ទៅយកសិក្ខាបទរបស់មនុស្សឡើយ។

តាមសេចក្តីខុសឆ្គងដ៏ធំពីរដែលជាអមតភាពនៃព្រលឹង និងភាពបរិសុទ្ធនៃថ្ងៃអាទិត្យនោះសាតាំងនឹងនាំមនុស្សមកស្ថិតនៅក្រោមសេចក្តីបញ្ឆោតរបស់វា។ ក្នុងពេលដែលសេចក្តីខុសឆ្គងនៃអមតភាពរបស់ព្រលឹង ក្រាលគ្រឹះនៃវិញ្ញាណខន្ធនិយម សេចក្តីខុសឆ្គងនៃភាពបរិសុទ្ធនៃថ្ងៃអាទិត្យបង្កើត

ចំណងមេត្រីភាពជាមួយរ៉ូម។ ពួកប្រូតេស្តង់នៃសហរដ្ឋអាមេរិក នឹងឈោងដៃមុនគេកាត់ឈូងសមុទ្រទៅចាប់ដៃវិញ្ញាណខន្ធនិយម។ គេនឹងឈោងកាត់ជង្ហុកដ៏ធំ ដើម្បីចាប់ដៃជាមួយអំណាចរ៉ូម ហើយក្រោមឥទ្ធិពលនៃសហភាពបីជាន់នេះ ប្រទេសនេះនឹងដើរតាមជំហានរបស់រ៉ូម ជាន់ឈ្លីសិទ្ធិនៃសតិសម្បជញ្ញៈ។

នៅពេលវិញ្ញាណខន្ធនិយម ចម្លងតាមគ្រីស្ទសាសនាក្នុងសម័យនោះ វានឹងមានអំណាចបញ្ឆោតខ្លាំងណាស់។ សាតាំងផ្ទាល់ត្រូវបាន «ផ្លាស់ប្រែ»។ វានឹងលេចមកជាទេវតានៃពន្លឺ។ ដោយសារវិញ្ញាណខន្ធនិយម ការអស្ចារ្យនឹងមានកើតឡើង អ្នកជំងឺនឹងបានជា ហើយសេចក្តីអស្ចារ្យដែលប្រកែកពុំបានជាច្រើនទៀត នឹងត្រូវបានកើតឡើងផងដែរ។

អ្នកកាន់តាមសម្តេចសង្ឃ ដែលអួតពីការអស្ចារ្យទាំងឡាយថាជាសញ្ញានៃព្រះវិហារពិតនឹងត្រូវបានភាន់ច្រឡំយ៉ាងងាយដោយអំណាចអស្ចារ្យនេះ រីឯបណ្តាប្រូតេស្តង់វិញ ដោយបានទម្លាក់ចោលខែលនៃសេចក្តីពិតហើយ ក៏នឹងត្រូវបានភាន់ច្រឡំផងដែរ។ អ្នកកាន់តាមសម្តេចសង្ឃបណ្តាប្រូតេស្តង់ ហើយនិងអ្នកដើរតាមលោកីយ៍ នឹងឃើញចលនាដ៏មហិមាមួយសម្រាប់ការបំផ្លាស់បំប្រែនៃពិភពលោកក្នុងសហភាពនេះ។

តាមរយៈវិញ្ញាណខន្ធនិយម សាតាំងលេចមកជាអ្នកគ្រងមត៌កនៃពូជសាសន៍ ដោយព្យាបាលជំងឺ និងសម្តែងប្រព័ន្ធនៃជំនឿសាសនាថ្មីមួយ ប៉ុន្តែក្នុងពេលជាមួយគ្នានេះ វានាំពួកបណ្តាជនឱ្យវិនាសទេ។ សេចក្តីឥតប្រមាណ បំបិទមិនឱ្យមានការរកមូលហេតុ ហើយការបំប៉នសេចក្តីត្រេកត្រអាល ជម្លោះ និងការកម្ចាយឈាម នឹងកើតមានតាមក្រោយ។ សង្គ្រាម រំជួលសេចក្តីវេទនាដ៏ចុកចាប់បំផុតនៃព្រលឹង ហើយក៏បោះទម្លាក់ទៅអនន្តភាព នូវជនរងគ្រោះដែលជ្រលក់ក្នុងអំពើអសីលធម៌ និងក្នុងឈាមផង។ កម្មវត្ថុរបស់សាតាំង គឺដើម្បីបង្កប្រទេសជាតិទាំងឡាយឱ្យធ្វើសង្គ្រាម ព្រោះធ្វើដូចនេះ វាអាចបង្វែរមនុស្សមិនឱ្យរៀបចំខ្លួនចាំថ្ងៃរបស់ព្រះ។

<u>អាទិត្យ-៣ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៣៨

ខព្រះគម្ពីរប្រចាំថ្ងៃ: *ចូរឲ្យអ្នករាល់គ្នាប្រព្រឹត្តតាមព្រះបន្ទូលទៅ កុំឲ្យគ្រាន់តែស្តាប់ប៉ុណ្ណោះ ហើយបញ្ឆោតខ្លួនវិញនោះឡើយ។ យ៉ាកុប ១:២២*

សាតាំងបានសិក្សាអាថិកំបាំងធម្មជាតិ ហើយវាប្រើអស់ទាំងអំណាចដែលព្រះទ្រង់អនុញ្ញាតឱ្យវាមាន ដើម្បីក្រឡែកឆ្មែធាតុទាំងឡាយ។ គឺជាព្រះទេដែលបាំងសត្វមានជីវិតរបស់ទ្រង់ពីមេបំផ្លាញ។ ប៉ុន្តែ ពិភពគ្រីស្ទានបានបង្ហាញសេចក្តីសម្អប់ដល់ក្រឹត្យវិន័យរបស់ទ្រង់ ហើយព្រះអង្គទ្រង់នឹងធ្វើនូវអ្វីដែលទ្រង់មានបន្ទូលថានឹងធ្វើ គឺដកសេចក្តីការពាររបស់ទ្រង់ ចេញពីអ្នកដែលប្រឆាំងនឹងក្រឹត្យវិន័យរបស់ទ្រង់ ហើយបង្ខំអ្នកដទៃឱ្យធ្វើដូចខ្លួនដែរ។ សាតាំងគ្រប់គ្រងលើអស់អ្នកដែលព្រះមិនការពារ។ វានឹងផ្គាប់ចិត្តហើយនិងធ្វើឱ្យអ្នកខ្លះចម្រើន ដើម្បីសម្រេចគម្រោងការរបស់វា ហើយវានឹងធ្វើឱ្យអ្នកខ្លះទៀតរងទុក្ខ ហើយនាំមនុស្សឱ្យជឿថា អ្នកដែលកំពុងធ្វើទុក្ខទោសដល់គេគឺព្រះនោះឯង។

ក្នុងពេលដែលសាតាំងលេចចេញមកក្នុងនាមជាគ្រូពេទ្យដ៏ចំណានដែលអាចព្យាបានអស់ទាំងរោគារបស់គេនោះ វានឹងនាំមកនូវជំងឺ និងសេចក្តីអន្តរាយ លុះដល់ទីក្រុងដែលមានប្រជាជនច្រើនបានវិនាសអស់។ ការគ្រោះថ្នាក់នៅតាមសមុទ្រ និងដីគោក ភ្លើងឆាបឆេះដ៏សន្ធោសន្ធៅ ខ្យល់កួច និងការធ្លាក់ព្រឹលដ៏សាហាវ ព្យុះសង្ឃរា ទឹកជំនន់ ព្យុះសុីក្លូន រលកទឹកសមុទ្រកម្ពស់រ៉ាប់ម៉ែត្រដែលវាយលុបហួសឆ្នេរ ហើយនិងការរញ្ជួយផែនដីក្នុងទម្រង់រាប់ពាន់ទៀត សុទ្ធតែជាហេតុដែលសាតាំងសាកល្បងអំណាចរបស់វា។ វាបំផ្លាញចោលនូវចម្រូតដែលទុំ ហើយអំណត់និងទុក្ខវេទនាកើតមានមកតាមក្រោយ។ វាធ្វើឱ្យខ្យល់មានក្លិនអាក្រក់ដល់ស្លាប់ ហើយមនុស្សរាប់ពាន់បាត់បង់ជីវិត។

បន្ទាប់មក អាមេបញ្ឆោតនឹងជំរុញមនុស្សឱ្យចោទអស់ទាំងបញ្ហា

របស់ខ្លួន ទៅលើអ្នកដែលស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះ ព្រោះអ្នកទាំងនេះជាសេចក្តីបន្ទោសឥតឈប់ឈរដល់អ្នកបំពាន។ នឹងមានគេអះអាងថា មនុស្សធ្វើឱ្យព្រះទាស់ព្រះហឫទ័យ ដោយការបំពានថ្ងៃអាទិត្យ ហើយថាអំពើបាបនេះនឹងបាននាំមកនូវសេចក្តីវេទនាដែលនឹងមិនស្បើយឡើយ លុះដល់មានការបង្ខំយ៉ាងតឹងរ៉ឹងឱ្យគោរពថ្ងៃអាទិត្យ។ «អ្នកដែលបំផ្លាញសេចក្តីគោរពថ្ងៃអាទិត្យ គឺកំពុងតែបង្ការមិនឱ្យមានសាជាថ្មីឡើងវិញនូវសំណព្វព្រះហឫទ័យពីព្រះ និងសេចក្តីចម្រើនល្អតលាស់ហើយ»។ ដូច្នេះពាក្យដែលបានលើកចោទមកកាលពីជំនាន់ដើមទាស់នឹងអ្នកបម្រើរបស់ព្រះ នឹងត្រូវមានម្តងទៀត។ «កាលអ‌ហាប់ឃើញអេលីយ៉ាហើយ នោះទ្រង់មានបន្ទូលសួរទៅថា ឱអ្នកដែលធ្វើឱ្យមានសេចក្តីវេទនាដល់ពួកអ៊ីស្រាអែលអើយ តើឯងឬអី?» ពង្សាវតារក្សត្រទី១ ១៨:១៧,១៨។

អំណាចដែលធ្វើបាដិហារ្យ នឹងបញ្ចេញឥទ្ធិពលរបស់វាទាស់នឹងអ្នកដែលស្តាប់តាមព្រះជាជាងមនុស្ស។ «ពួកវិញ្ញាណ» នឹងថ្លែងថាព្រះបន្ទូលបញ្ជូនគេមក ដើម្បីប្រាប់ពីកំហុសនៃអ្នកបដិសេធថ្ងៃអាទិត្យ។ គេនឹងសោកសង្រេងចំពោះភាពទុច្ចរិតដ៏ធំធេងនៃពិភពលោក ហើយនិងគាំទ្រទីបន្ទាល់របស់ពួកគ្រូសាសនា ថាស្ថានភាពនៃសីលធម៌ដែលបានអាប់ឱននោះ គឺបានបណ្តាលមកពីការប្រមាថដល់ថ្ងៃអាទិត្យ។

ក្រោមក្បួនតម្រារបស់រ៉ូម អ្នកណាដែលរងទុក្ខដោយសារដំណឹងល្អ ត្រូវបានគេចាត់ទុកថាជាអ្នកប្រព្រឹត្តអំពើអាក្រក់ ហើយជាគូកនជាមួយនិងសាតាំង។ នៅអនាគតកាលក៏ដូចគ្នាដែរ។ សាតាំងនឹងបណ្តាលឱ្យអ្នកដែលគោរពក្រឹត្យវិន័យរបស់ព្រះ ត្រូវជាប់ចោទថាជាអ្នកនាំសេចក្តីជំនុំជម្រះមកផែនដី។ វាព្យាយាមក្តោបក្តាប់សតិសម្បជញ្ញៈដោយការបំភិតបំភ័យ ដោយនាំអាជ្ញាធរសាសនា និងអាជ្ញាធរលោកីយ៍ ឱ្យចេញប្រតិបត្តិច្បាប់របស់មនុស្ស ក្នុងការប្រឆាំងនឹងក្រឹត្យវិន័យរបស់ព្រះ។

អ្នកដែលគោរពថ្ងៃឈប់សម្រាកតាមព្រះគម្ពីរ នឹងត្រូវបានគេចាត់ទុក

ថាជាសត្រូវនៃច្បាប់ដោយបំបាក់បំបែកគន្លងសីលធម៌នៃសង្គម ទាំងបង្កឱ្យ
កើតសង្គមឥតច្បាប់ និងអំពើពុករលួយ ហើយនិងធ្វើឱ្យព្រះជំនុំជម្រះផែនដី
ទៀតផង។ គេនឹងចោទពួកគេថាមិនស្មោះត្រង់នឹងរដ្ឋាភិបាល។ ពួកគ្រូគង្វាល
ដែលបដិសេធកាតព្វកិច្ចនៃក្រឹត្យវិន័យពីព្រះ នឹងអធិប្បាយនូវភារកិច្ចនៃការ
ស្តាប់បង្គាប់តាមអាជ្ញាធរស៊ីវិល។ ក្នុងសាលានីតិបញ្ញត្តិ និងសាលាកាត់ក្តី
អ្នករក្សាក្រឹត្យបញ្ញត្តិ នឹងត្រូវបានជាប់ទោស។ ពាក្យសម្តី និងគោលបំណង
របស់គេនឹងត្រូវបានគេមូលបង្កាច់។

អ្នកមានតំណែងខ្ពស់ក្នុងព្រះវិហារ និងក្នុងរដ្ឋ នឹងរួបរួមដើម្បីបញ្ចុះ
បញ្ចូល ឬបង្ខំជនគ្រប់រូបឱ្យគោរពថ្ងៃអាទិត្យ។ សូម្បីតែនៅប្រទេសអាមេរិក
សេរីក៏ដោយ អ្នកកាន់ក្តាប់ និងអ្នកបង្កើតច្បាប់ នឹងចុះចូលទៅតាមសំណូម
នៃមនុស្សភាគច្រើន ដោយព្រោះពួកគេទាមទារយកច្បាប់មួយដែលបង្ខំឱ្យ
មានការគោរពថ្ងៃអាទិត្យ។ ការដែលគេបានលះបង់ដ៏ធំធេងសម្រាប់សេរីភាព
ខាងសម្បជញ្ញៈនោះ នឹងទៅជាអសារឥតការទៅវិញ។ នៅក្នុងការប៉ះ
ទង្គិចដែលនឹងមកដល់នោះ យើងនឹងបានយល់យ៉ាងច្បាស់នូវទំនាយរបស់
ហោរាដែលចែងថា៖ «នាគក៏ខឹងនឹងស្ត្រីនោះ ហើយចេញទៅច្បាំងនឹង
សំណល់ពូជនាងទាំងប៉ុន្មាន ជាពួកដែលកាន់តាមបញ្ញត្តិព្រះ ហើយមាន
សេចក្តីបន្ទាល់ពីព្រះយេស៊ូវ»។ វិវរណៈ ១២:១៧។

ប្រដាប់ការពារតែមួយគត់របស់យើង

<u>ចន្ទ-៤ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៣៩

ខព្រះគម្ពីរប្រចាំថ្ងៃ: *បើអ្នកណាស្មានថា ខ្លួនជាអ្នកកាន់សាសនា តែមិនចេះទប់អណ្តាតសោះ អ្នកនោះឈ្មោះថាបញ្ឆោតចិត្តខ្លួនហើយ ឯសាសនារបស់អ្នកនោះជាឥតប្រយោជន៍ទទេ ។ យ៉ាកុប ១:២៦*

ព្រះបានបង្គាប់រាស្ត្ររបស់ទ្រង់ ឱ្យយកបទគម្ពីរទុកជាសេចក្តីការពារនឹងឥទ្ធិពលរបស់ពួកគ្រូក្លែងក្លាយ និងពួកវិញ្ញាណនៃសេចក្តីងងឹត។ សាតាំងប្រើគ្រប់ទាំងឧបាយកលដែលវាអាចប្រើបាន ដើម្បីបង្ការមនុស្សមិនឱ្យទទួលតម្រិះវិជ្ជាអំពីព្រះគម្ពីរ ព្រោះសំណេរដ៏ជាក់ស្តែង បើកសម្តែងសេចក្តីបោកបញ្ឆោតរបស់វា។ ការបញ្ឆោតដ៏ខ្លាំងក្លាចុងក្រោយបង្អស់ នឹងកើតឡើងដល់យើងក្នុងពេលបន្តិចទៀត។ អ្នកទទឹងព្រះគ្រីស្ទនឹងធ្វើការអស្ចារ្យរបស់គេនៅនឹងមុខយើង។ ការក្លែងបន្លំនោះ គឺស្រដៀងគ្នានឹងការពិតណាស់ រហូតដល់មិនអាចបែងចែកថាខុស ឬត្រូវបាន លើកលែងតែដោយសារបទគម្ពីរប៉ុណ្ណោះ។

អ្នកដែលរក្សាអស់ទាំងបញ្ញត្តិរបស់ព្រះ នឹងត្រូវបានគេជំទាស់ហើយនិងចំអកឱ្យផង។ ដើម្បីទ្រាំទ្រនឹងគ្រាទុក្ខលំបាកនេះ ពួកគេត្រូវយល់អំពីព្រះហឫទ័យរបស់ព្រះ ដូចដែលបានចែងនៅក្នុងព្រះបន្ទូលទ្រង់។ មានតែអ្នកដែលបានប្រដាប់ចិត្តគំនិតឱ្យបានមាំមួនដោយសេចក្តីពិតនៃព្រះគម្ពីរទេទើបនឹងអាចឈរតទល់នឹងមហាវិបត្តិចុងក្រោយបាន។

មុននឹងគេឆ្កាងព្រះអង្គសង្គ្រោះ ទ្រង់បានពន្យល់ដល់ពួកសាវ័កទ្រង់

ថា គេនឹងធ្វើគត់ទ្រង់ ហើយទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ។ ប៉ុន្តែ ព្រះបន្ទូលទាំងប៉ុន្មានបានរសាត់រសាយពីគំនិតរបស់ពួកសាវ័កអស់ទៅ។ នៅពេលគ្រាទុក្ខព្រួយមកដល់ សេចក្តីសុគតរបស់ព្រះយេស៊ូវបានបំផ្លាញក្តីសង្ឃឹមរបស់គេអស់សូន្យឈឹងតែម្តង ហាក់បីដូចជាព្រះអង្គពុំបានព្រមានប្រាប់គេពីមុនដូច្នោះ។ ដូច្នេះ នៅក្នុងបទទំនាយទាំងប៉ុន្មាន អនាគតកាលគឺត្រូវបានបើកយ៉ាងច្បាស់នៅចំពោះយើង ដូចដែលព្រះគ្រីស្ទបានបើកដល់ពួកសាវ័កដូច្នោះដែរ។ ព្រឹត្តិការណ៍ទាំងឡាយដែលទាក់ទងនឹងពេលវេលាទុកឱ្យប្រែចិត្ត និងកិច្ចរៀបចំខ្លួនសម្រាប់គ្រាវេទនា គឺត្រូវបានសម្តែងយ៉ាងច្បាស់។ ប៉ុន្តែ ពួកមនុស្សម្នាឥតមានការយល់ដឹងអំពីការពិតទាំងនេះទេ ហើយគេនឹងមិនបានត្រៀមខ្លួនសម្រាប់គ្រាវេទនានោះឡើយ។

នៅពេលព្រះទ្រង់បញ្ជូនសេចក្តីព្រមាន ព្រះអង្គត្រូវបានជនរាល់រូបដែលចេះគិតគូរ ឱ្យយកចិត្តទុកដាក់នឹងព្រះរាជសារនោះ។ សេចក្តីជំនុំជម្រះដ៏គួរឱ្យខ្លាច ដែលជំទាស់នឹងការថ្វាយបង្គំសត្វ និងរូបវា (វិវរណៈ ១៤:៩-១១) គួរតែនាំមនុស្សគ្រប់រូប ឱ្យសិក្សាអំពីទីសម្គាល់នៃសត្វ និងអំពីរបៀបជៀសវាងពីការទទួលទីសម្គាល់នោះ។ ប៉ុន្តែ ពួកបណ្តាជនមិនចង់បានការពិតពីព្រះគម្ពីរទេ ពីព្រោះវាទើសទាស់នឹងសេចក្តីប៉ងប្រាថ្នានៃចិត្តដែលមានបាប។ ម្ល៉ោះហើយសាតាំងក៏ផ្តល់សេចក្តីបញ្ឆោតទាំងឡាយដែលគេស្រឡាញ់វិញ។

តែព្រះនឹងនៅតែមានមនុស្សដែលរក្សាព្រះគម្ពីរ ហើយព្រះគម្ពីរតែមួយគត់ ទុកជាខ្នាតនៃអស់ទាំងគោលលទ្ធិ និងជាមូលដ្ឋាននៃអស់ទាំងកំណែទម្រង់។ យោបល់នៃជនដែលមានតម្រិះវិជ្ជាខ្ពង់ខ្ពស់ អ្វីដែលវិទ្យាសាស្ត្ររកឃើញ ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាសាសនា សំឡេងនៃមនុស្សភាគច្រើន គឺជាកត្តាដែលមិនត្រូវយកមកធ្វើជាភ័ស្តុតាងសម្រាប់គាំទ្រគោលលទ្ធិ ឬជំទាស់គោលលទ្ធិណាមួយឡើយ។ យើងត្រូវទាមទារយកប្រយោគដ៏ងាយដែលថា «ព្រះយេហូវ៉ាមានបន្ទូលដូច្នេះថា» វិញ។ សាតាំងបាននាំ

មនុស្សឱ្យមើលទៅឯគ្រូគង្វាល និងសាស្ត្រាចារ្យនៃសាសនវិទ្យា ថាជាអ្នកនាំផ្លូវ ជាជាងស្វែងរកបទគម្ពីរដោយខ្លួនឯង។ សាតាំងមានឥទ្ធិពលលើហ្វូងមនុស្ស ដោយគ្រប់គ្រងលើអ្នកដឹកនាំទាំងនេះ។

នៅពេលព្រះគ្រីស្ទយាងមក បណ្តាជនសាមញ្ញបានឮអំពីទ្រង់ទាំងមានចិត្តអរសប្បាយ។ ប៉ុន្តែ គ្រូសង្គ្រាជ និងពួកអ្នកធំ បានក្រសោបខ្លួនគេក្នុងសេចក្តីប្រកាន់ ពួកគេបានបដិសេធភ័ស្តុតាងនៃភាពជាព្រះមេស្ស៊ីរបស់ទ្រង់។ បណ្តាជនសួរថា៖ «ហេតុដូចម្តេចបានជាអ្នកដឹកនាំ និងអាចារ្យរបស់យើងមិនជឿដល់ព្រះយេស៊ូវដូច្នេះ?» ពួកគ្រូដូចនេះ បាននាំប្រទេសជូស៊ឱ្យបដិសេធព្រះអង្គប្រោសលោះរបស់ខ្លួន។

<u>អង្គារ-៥ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៤០

ខព្រះគម្ពីរប្រចាំថ្ងៃ: *ឯសាសនាដែលបរិសុទ្ធ ហើយឥតសៅហ្មង នៅចំពោះព្រះដ៏ជាព្រះវរបិតា នោះគឺឲ្យទៅសួរពួកកំព្រា និងពួកមេម៉ាយ ក្នុងកាលដែលគេមានសេចក្តីវេទនា ហើយឲ្យរក្សាខ្លួន មិនឲ្យប្រឡាក់ដោយលោកីយ៍នេះឡើយ។ យ៉ាកុប ១:២៧*

ការលើកតម្កើងអាជ្ញាច្បាប់របស់មនុស្ស

ព្រះគ្រីស្ទបានឃើញជាមុនចំពោះកិច្ចការលើកតម្កើងអាជ្ញាច្បាប់របស់មនុស្ស ឱ្យគ្រប់គ្រងផ្លូវចិត្ត ដែលជាបណ្តាសាដ៏អាក្រក់ក្រៃលែងមួយក្នុងគ្រប់សម័យ។ ការព្រមានរបស់ទ្រង់ដែលមិនឱ្យដើរតាមអ្នកដឹកនាំដ៏កង្វាក់ ត្រូវបានកត់ទុកលើកំណត់ហេតុ ទុកជាសេចក្តីដាស់តឿនដល់តំណទាំងឡាយនៅអនាគតកាល។

វិហារ៉ូមបានផ្តល់សិទ្ធិដល់ក្រុមគ្រូគង្វាល ឱ្យបកស្រាយគម្ពីរ។ ថ្វីដ្បិតតែកំណែទម្រង់បានប្រគល់គម្ពីរដល់ជនគ្រប់រូបក៏ដោយ ក៏គោលការណ៍ដដែល ដែលរ៉ូមប្រកាន់យកនោះ នៅតែបង្ការបណ្តាមនុស្សទាំងឡាយក្នុង

វិហារប្រូតេស្តង់ មិនឱ្យសិក្សាព្រះគម្ពីរសម្រាប់ខ្លួនឯងដែរ។ គេបានបង្រៀនពួកគេឱ្យទទួលសេចក្តីបង្រៀនរបស់វិហារ*តាមតែវិហារបកស្រាយឱ្យ*។ មនុស្សរាប់ពាន់នាក់ពុំហ៊ានទទួលជឿអ្វីដែលផ្ទុយនឹងគោលជំនឿរបស់ខ្លួនឡើយ ទោះជាបទគម្ពីរនោះងាយយល់យ៉ាងណាក៏ដោយ។

មនុស្សជាច្រើនត្រៀមខ្លួនជាស្រេច ដើម្បីនឹងប្រគល់ព្រលឹងរបស់ខ្លួនឱ្យក្រុមគ្រូគង្វាល។ ពួកគេបានមើលរំលងសេចក្តីបង្រៀនរបស់ព្រះអង្គសង្គ្រោះ ស្ទើរតែដោយមិនដឹងខ្លួនសោះ។ ប៉ុន្តែ តើគ្រូគង្វាលទាំងឡាយអាចខុសឬទេ? តើឱ្យយើងទុកចិត្តលើការដឹកនាំរបស់គេដូចម្តេចបាន បើយើងមិនដឹងថាគេជាអ្នកទ្រទ្រង់ពន្លឺដោយសារព្រះបន្ទូលរបស់ព្រះនោះ? ការខ្វះខាតទឹកចិត្តខាងសីលធម៌ បាននាំឱ្យមនុស្សជាច្រើនដើរតាមអ្នករៀនសូត្រចេះដឹង ហើយគេក៏ក្លាយទៅជាអ្នកជាប់ស្និតនឹងសេចក្តីខុសឆ្គង រកទីសង្ឃឹមគ្មាន។ ពួកគេបានឃើញសេចក្តីពិតក្នុងព្រះគម្ពីរសម្រាប់គ្រានេះ ហើយមានអារម្មណ៍ដឹងពីអំណាចនៃព្រះវិញ្ញាណបរិសុទ្ធដែលហៀបជាមួយនឹងការប្រកាសសេចក្តីពិតនោះផង តែពួកគេអនុញ្ញាតឱ្យពួកគ្រូគង្វាលបង្វែរខ្លួនចេញពីពន្លឺវិញ។

សាតាំងចង់ភ្ជាប់បណ្តាមនុស្ស ដោយខ្សែសូត្រនៃសេចក្តីថ្នាក់ថ្នមទៅនឹងអ្នកដែលជាសត្រូវនៃឈើឆ្កាងរបស់ព្រះគ្រីស្ទ។ សេចក្តីជិតស្និទ្ធយ៉ាងស្និតនេះ អាចមានដូចជាឪពុកម្តាយ បងប្អូន ប្តីប្រពន្ធ ឬសង្គមជាដើម។ ព្រលឹងដែលស្ថិតនៅក្រោមឥទ្ធិពលរបស់គេ ពុំមានទឹកចិត្តនឹងស្តាប់តាមសតិសម្បជញ្ញៈរបស់ខ្លួនឡើយ។

ជនជាច្រើន លើកឡើងថា អ្វីដែលជនណាម្នាក់ជឿនោះ គឺគ្មានបញ្ហាទេ ឱ្យតែជីវិតរបស់គេត្រឹមត្រូវចុះ។ ប៉ុន្តែ ជីវិតគឺសូនឡើងដោយជំនឿ។ ប្រសិនបើល្មមឈោងចាប់សេចក្តីពិតបាន តែយើងបែរជាមិនអើពើវិញ គឺយើងហាក់ដូចជាបដិសេធសេចក្តីពិត ទៅយកភាពងងឹត ជាជាងពន្លឺហើយ។

សេចក្តីលួងខ្លៅ គឺពុំមែនជាដំណោះសារសម្រាប់អំពើខុសឆ្គង ឬ

អំពើបាបឡើយ នៅពេលដែលមានឱកាសគ្រប់យ៉ាងដើម្បីជ្រាបដឹងអំពីព្រះហឫទ័យរបស់ព្រះនោះ។ មានបុរសម្នាក់បានធ្វើដំណើរមកដល់កន្លែងដែលមានផ្លូវបែកចេញជាច្រើន ហើយមានសញ្ញាមួយប្រាប់ថាផ្លូវទាំងនោះនឹងនាំទៅទីណា ប្រសិនបើគាត់មិនមើលសញ្ញា ហើយធ្វើដំណើរទៅតាមផ្លូវដែលគាត់គិតថាជាផ្លូវត្រូវនោះ គាត់អាចធ្វើទៅដោយស្មោះពីចិត្តមែន តែប្រហែលជានឹងទៅខាងផ្លូវខុសជាមិនខាន។

ភារកិច្ចទីមួយ ហើយដ៏ខ្ពស់បំផុត

ការដែលមានបំណងល្អ ការដែលធ្វើអ្វីដែលជនមួយរូបគិតថាត្រូវ ឬការធ្វើតាមតែគ្រូគង្វាលប្រាប់ថាត្រូវនោះ គឺមិនគ្រប់គ្រាន់ទេ។ ជននោះត្រូវសិក្សាបទគម្ពីរដោយខ្លួនឯង។ គេមានផែនទីដែលចង្អុលប្រាប់គ្រប់ទាំងផ្លូវទៅស្ថានសួគ៌ ហើយមិនត្រូវស្មានអំពីអ្វីឡើយ។

ភារកិច្ចទីមួយ ហើយដ៏ខ្ពស់បំផុតចំពោះមនុស្សដែលចេះគិតគូរ គឺដើម្បីសិក្សាពីបទគម្ពីរឱ្យដឹងថាអ្វីទៅជាសេចក្តីពិត បន្ទាប់មកទើបធ្វើដំណើរក្នុងពន្លឺ ហើយលើកទឹកចិត្តអ្នកដទៃឱ្យដើរតាមគំរូរបស់ខ្លួន។ យើងត្រូវមានយោបល់ដោយខ្លួន ព្រោះយើងជាអ្នកត្រូវឆ្លើយដល់ព្រះ។

អ្នករៀនសូត្រចេះដឹង ដែលនឹកស្មានថាខ្លួនមានប្រាជ្ញាខ្ពង់ខ្ពស់ បង្រៀនថាបទគម្ពីរមានអាថិកំបាំង មានន័យខាងព្រលឹងវិញ្ញាណដែលមិនមានចែងក្នុងភាសាដែលប្រើនោះ។ ជនទាំងនេះជាគ្រូក្លែងក្លាយទេ។ ភាសារបស់ព្រះគម្ពីរអាចពន្យល់បាន យោងទៅតាមន័យដ៏ងាយយល់ លើកលែងតែមានប្រើនិមិត្តរូប ឬរូបប្រៀបធៀប។ ប្រសិនបើមនុស្សអានព្រះគម្ពីរតាមតែការសរសេរ មនុស្សទាំងពាន់ៗដែលកំពុងរអាក្នុងសេចក្តីខុសឆ្គង នឹងចូលមកក្នុងជំនុំរបស់ព្រះគ្រីស្ទទៅហើយ។

ខព្រះគម្ពីរប្រចាំថ្ងៃ:*ចូរស្តាប់ចុះ បងប្អូនស្ងួនភ្ងាអើយ តើព្រះមិនបានរើសពួកអ្នកក្រនៅលោកីយ៍នេះ ដែលជាអ្នកមានខាងសេចក្តីជំនឿ ហើយជាអ្នកគ្រងមរដកក្នុងនគរ ដែលទ្រង់បានសន្យាទុក ឲ្យពួកអ្នកដែលស្រឡាញ់ទ្រង់ទេឬអី ។ យ៉ាកុប ២:៥*

បទគម្ពីរជាច្រើនដែលអ្នករៀនសូត្រចេះដឹងថ្លែងថាមិនមានសារៈសំខាន់នោះ គឺពោរពេញទៅដោយសេចក្តីកំសាន្តចិត្តដល់អ្នកសិស្សរបស់ព្រះគ្រីស្ទទៅវិញ។ ការយល់ដឹងអំពីសេចក្តីពិតនៃព្រះគម្ពីរ ពុំមែនពឹងផ្អែកទាំងស្រុងទៅលើអំណាចនៃបញ្ញាដែលនាំឱ្យសិស្សានោះទេ គឺទៅលើគោលបំណងតែមួយនោះដែរ ពោលគឺការត្រេកចង់បានសេចក្តីសុចរិតយ៉ាងអស់ពីចិត្ត។

លទ្ធផលនៃការភ្ជួចអធិស្ឋាន និងការសិក្សាព្រះគម្ពីរ

មិនត្រូវសិក្សាព្រះគម្ពីរដោយឥតមានការអធិស្ឋានឡើយ។ មានតែព្រះវិញ្ញាណបរិសុទ្ធមួយព្រះអង្គទេ ដែលបណ្តាលឱ្យយើងមានអារម្មណ៍ដឹងអំពីសារៈសំខាន់នៃអ្វីដែលងាយយល់ ឬបង្ការយើងមិនឱ្យពុះពារជាមួយនឹងសេចក្តីពិតដែលពិបាកយល់។ ពពួកទេវតានៃស្ថានសួគ៌រៀបចំចិត្តមនុស្សប្រយោជន៍ឱ្យគេយល់ព្រះបន្ទូលរបស់ព្រះ។ យើងនឹងបានពោរពេញដោយស្នេហ៍ រលឹកស្មារតីដោយសេចក្តីព្រមាន ហើយនឹងបានរឹងប៉ឹងឡើងដោយសេចក្តីសន្យានៃព្រះបន្ទូលរបស់ទ្រង់។ ការល្បួងល្បងទាំងឡាយ មើលទៅហាក់បីដូចជាពិបាកនឹងទប់ទល់ ពីព្រោះអ្នកដែលត្រូវសេចក្តីល្បួង ពុំបានចងចាំសេចក្តីសន្យាទាំងប៉ុន្មានរបស់ព្រះ និងពុំអាចតទល់ជាមួយសាតាំងដោយអាវុធនៃបទគម្ពីរ។ ប៉ុន្តែ ពពួកទេវតាស្ថិតនៅជុំវិញអ្នកដែលមានចិត្តចង់រៀន ហើយពួកលោកនឹងធ្វើឱ្យគេនឹកចាំនូវសេចក្តីពិតទាំងឡាយដែលគេត្រូវការ។

«ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្តីទាំងអស់ ក៏នឹងរំលឹកពីគ្រប់ទាំងសេចក្តីដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នា»។ យ៉ូហាន ១៤:២៦។ ប៉ុន្តែសេចក្តីបង្រៀនរបស់ព្រះគ្រីស្ទ ប្រាកដជាមាននៅក្នុងគំនិតពីមុនរួចទៅហើយ ទើបព្រះវិញ្ញាណរបស់ព្រះអាចរំលឹកឱ្យយើងចងចាំនៅក្នុងគ្រាមានទុក្ខធំបាន។

វាសនានៃបណ្តាមនុស្សដ៏សន្ធឹកសន្ធាប់នៅផែនដីនេះ គឺហៀបតែនឹងបានសម្រេចសេចក្តីឱ្យដាច់ស្រេចហើយ។ អ្នកដើរតាមព្រះគ្រីស្ទគ្រប់រូប គួរតែស៊ើបសួរយ៉ាងអស់ពីចិត្តថា៖ «ព្រះអម្ចាស់អើយ តើទ្រង់សព្វព្រះទ័យឱ្យទូលបង្គំធ្វើដូចម្តេច?» កិច្ចការ ៩:៦។ ឥឡូវនេះ យើងគួរតែស្វែងរកសេចក្តីពិសោធដែលជ្រាលជ្រៅ ហើយរស់រវើកក្នុងអ្វីៗដែលទាក់ទងដល់ព្រះ។ យើងគ្មានពេលវេលាដែលនឹងត្រូវខាតបង់នោះទេ។ យើងកំពុងស្ថិតនៅលើវាលស្មៅហ៍របស់សាតាំង។ ចូរកុំឱ្យលង់លក់ឡើយ ឆ្មាំរបស់ព្រះអើយ!

ជនជាច្រើននាក់បានសរសើរខ្លួនគេ ចំពោះការដែលខ្លួនពុំបានប្រព្រឹត្តអំពើខុសឆ្គង។ ការដែលគ្រាន់តែជាដើមឈើនៅក្នុងសួនច្បាររបស់ព្រះនោះ គឺមិនគ្រប់គ្រាន់ទេ។ គេត្រូវតែបង្កើតផលផ្លែ។ នៅក្នុងសៀវភៅនៃស្តានសូគិ គេត្រូវបានកត់ទុកថាជាអ្នកបង្ខាតដី។ តែអ្នកដែលមិនយកចិត្តទុកដាក់ចំពោះសេចក្តីមេត្តាករុណារបស់ព្រះ ហើយបង្ខូចព្រះគុណរបស់ទ្រង់ព្រះ ហឫទ័យនៃសេចក្តីស្រឡាញ់ដ៏អត់ធ្មត់នៅតែអង្វរករជានិច្ច។

នៅរដូវក្តៅ មិនឃើញមានភាពខុសគ្នារវាងរុក្ខជាតិដែលរមែងបញ្ចេញពណ៌បៃតង និងរុក្ខជាតិដទៃទៀតឡើយ ប៉ុន្តែនៅពេលរដូវរងាធ្លាក់មក រុក្ខជាតិដែលបញ្ចេញពណ៌បៃតងជានិច្ច នៅមានស្លឹកដដែល តែរុក្ខជាតិដទៃទៀតរុះស្លឹកអស់។ ឱ្យតែមានការប្រឆាំងចុះ ឱ្យតែមានការមិនទ្រាំទ្រយោលយោគមកម្តងទៀតចុះ ឱ្យតែមានការបៀតបៀនឆាបឆេះចុះ នោះអ្នកនឹងមានចិត្តជឿសើៗ និងអ្នកកំពុតនឹងបំបរបង់ជំនឿរបស់គេជាមិនខាន ប៉ុន្តែគ្រីស្ទានពិតប្រាកដ នឹងនៅឈរមាំមួន ជំនឿរបស់គេនឹងបានកាន់តែ

ខ្លាំង សេចក្តីសង្ឃឹមរបស់គេនឹងបានកាន់តែភ្លឺថ្លា ជាងគ្រាចម្រើនបរិបូរទៅទៀត។

«អ្នកនោះនឹងបានដូចជាដើមឈើដាំនៅមាត់ទឹក ដែលចាក់ឫសទៅក្បែរទន្លេ ឥតដឹងរដូវក្តៅទេ គឺស្លឹកនៅតែខៀវខ្ចីវិញ ហើយមិនរឹតត្បិតនៅឆ្នាំដែលរាំងរឹះឡើយ ក៏មិនដែលខាននឹងកើតផងដែរ»។ យេរេមា ១៧:៨។

ព្រះរាជសារចុងក្រោយបង្អស់

<u>ព្រហស្បតិ៍-៧ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៤២

ខព្រះគម្ពីរប្រចាំថ្ងៃ: *ឯអណ្តាតក៏ជាអវយវៈ១យ៉ាងតូចដូច្នោះដែរ ប៉ុន្តែ ចេះអួតអាងយ៉ាងសំបើមណាស់ មើលចុះ ភ្លើងតែបន្តិចទេ អាចនឹងឆេះព្រៃធំៗទៅបាន។ យ៉ាកុប ៣:៥*

«ខ្ញុំឃើញទេវតាមួយទៀតចុះពីស្ថានសួគ៌មក មានអំណាចយ៉ាងធំ ហើយសិរីល្អរបស់ទេវតានោះក៏បំភ្លឺផែនដី ទេវតានោះបន្លឺឡើងដោយសំឡេងយ៉ាងខ្លាំងថា ក្រុងបាប៊ីឡូនដ៏ជាធំបានរលំហើយ បានរលំហើយ ក៏ត្រឡប់ជាលំនៅនៃពួកអារក្ស ជាកន្លែងរបស់អស់ទាំងវិញ្ញាណអសោច និងអស់ទាំងសត្វស្លាបអសោចគួរខ្ពើម...។ ខ្ញុំក៏ឮសំឡេងមួយទៀតពីលើមេឃពោលថា រាស្ត្រអញអើយ ចូរចេញពីទីក្រុងនោះមក ដើម្បីកុំឱ្យត្រូវមានចំណែកក្នុងអំពើបាបវាឡើយ ក្រែងត្រូវវេទនាដូចជាវាដែរ»។ វិវរណៈ ១៨:១,២,៤។

ការប្រកាសដែលបានធ្វើឡើងដោយទេវតាទីពីរនៅវិវរណៈ ១៤:៨ នឹងត្រូវបានផ្ទួនឡើងម្តងទៀត ប្រាប់បន្ថែមអំពីអំពើពុករលួយដែលបានចូលទៅកាន់ក្រុងបាប៊ីឡូន តាំងពីព្រះរាជសារនោះបានផ្សាយនៅលើកទីមួយ។

លក្ខណៈដ៏រន្ធត់មួយ ត្រូវបានរៀបរាប់នៅត្រង់នេះ។ នៅវាល់ការបដិសេធសេចក្តីពិត គំនិតរបស់មនុស្សនឹងចេះតែងងឹតទៅៗ ចិត្តគេក៏ចេះតែរឹងចចេសថែមទៀត។ គេនឹងនៅតែជាន់ឈ្លីទៅលើសិក្ខាបទមួយនៃក្រឹត្យវិន័យដប់ប្រការ រហូតទាល់តែគេបានធ្វើទុក្ខបៀតបៀនដល់អស់អ្នកដែល

រក្សាទុកជាបរិសុទ្ធ។ ព្រះគ្រីស្ទត្រូវបានគេចាត់ទុកថាជាឥតប្រយោជន៍ ក្នុងការដែលគេស្អប់ខ្ពើមព្រះបន្ទូល និងរាស្ត្ររបស់ព្រះ។

អ្នកតាំងខ្លួនថាជាអ្នកកាន់សាសនា នឹងបានក្លាយទៅជាអារដាយធំគ្របបាំងភាពទុច្ចរិតដ៏ថោកទាប។ ការនិយមជឿខាងវិញ្ញាណខន្ធ បើកទ្វារទៅរកគោលលទ្ធិរបស់អារក្ស ម្ល៉ោះហើយឥទ្ធិពលរបស់ទេវតាអារក្ស ក៏មាននៅក្នុងក្រុមជំនុំ។ បាប៊ីឡូនបានពេញដោយសេចក្តីខុសឆ្គង ហើយសេចក្តីហិនវិនាស រៀបនឹងធ្លាក់មកដល់ហើយ។

ប៉ុន្តែ ព្រះនៅមានរាស្ត្ររបស់ទ្រង់នៅក្នុងបាប៊ីឡូនដែរ ហើយបណ្តាអ្នកស្មោះត្រង់ទាំងនេះនឹងត្រូវហៅឱ្យចេញមក ដើម្បីកុំឱ្យមានចំណែកជាមួយអំពើបាបរបស់ក្រុងនោះ ព្រមទាំងកុំឱ្យគេទទួលសេចក្តីវេទនារបស់ក្រុងនោះដែរ។ ទេវតាយាងចុះមកពីស្ថានសួគ៌ បំភ្លឺផែនដីដោយសិរីល្អរបស់លោក ហើយនិងប្រកាសប្រាប់ពីអំពើបាបរបស់ក្រុងបាប៊ីឡូន។ ពាក្យហៅនេះត្រូវបានឮថា៖ «រាស្ត្រអញអើយ ចូរចេញពីទីក្រុងនោះមក»។ ការប្រកាសប្រាប់នេះគឺជាការព្រមានចុងក្រោយបង្អស់ ដល់មនុស្សនៅផែនដី។

អំណាចទាំងឡាយនៅផែនដី ដែលរួបរួមគ្នាធ្វើសង្គ្រាមប្រឆាំងនឹងក្រឹត្យវិន័យរបស់ព្រះនឹងចេញបញ្ជាថា «មនុស្សទាំងអស់ ទាំងធំ ទាំងតូច ទាំងមាន ទាំងក្រ ហើយទាំងអ្នកជា និងបាវគេ» (វិវរណៈ ១៣:១៦) ត្រូវសម្របទៅតាមទំនៀមទម្លាប់របស់វិហារ ដោយរក្សាថ្ងៃសាបាថក្លែងក្លាយ។ អស់អ្នកដែលបដិសេធ នឹងទទួលសេចក្តីស្លាប់នៅទីបំផុត។ ផ្ទុយទៅវិញ ច្បាប់របស់ព្រះដែលបង្គាប់ឱ្យគោរពថ្ងៃឈប់សម្រាករបស់ព្រះអាទិករ គំរាមសេចក្តីក្រោធទាស់នឹងអស់អ្នកដែលរំលងសិក្ខាបទរបស់បញ្ញត្តិ។

ដោយរឿងរ៉ាវនេះត្រូវបាននាំមកយ៉ាងច្បាស់ក្រឡែតនៅចំពោះខ្លួនអស់អ្នកណាដែលជាន់ឈ្លីបញ្ញត្តិរបស់ព្រះ ហើយបែរទៅស្តាប់បង្គាប់ច្បាប់របស់មនុស្ស នឹងទទួលទីសម្គាល់របស់សត្វគឺជាសញ្ញានៃសេចក្តីស្មោះត្រង់ចំពោះច្បាប់ដែលខ្លួនជ្រើសរើសស្តាប់បង្គាប់ ជាជាងស្មោះត្រង់ដល់ព្រះ។

«បើអ្នកណាក្រាបថ្វាយបង្គំដល់សត្វនោះនិងរូបវា ហើយទទួលទីសម្គាល់វា នៅលើថ្ងាស ឬនៅដៃអ្នកនោះនឹងត្រូវផឹកស្រាផងសេចក្ដីឃោរឃៅរបស់ព្រះ ជាស្រាឥតលាយដែលចាក់ទៅក្នុងពែងនៃសេចក្ដីក្រោធរបស់ទ្រង់»។ វិវរណៈ ១៤:៩,១០។

<u>សុក្រ-៨ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៤៣

ខព្រះគម្ពីរប្រចាំថ្ងៃ: *បងប្អូនអើយ តើដើមល្វាអាចនឹងបង្កើតផ្លែជាអូលីវ ឬដើមទំពាំងបាយជូរបង្កើតផ្លែជាល្វាបានឬទេ ដូច្នេះ គ្មានរន្ធទឹកណាចេញទឹកជាប្រៃផងសាបផងបានឡើយ។ យ៉ាកុប ៣:១២*

គ្មាននរណាម្នាក់ទទួលរងនូវសេចក្ដីក្រោធរបស់ព្រះឡើយ រហូតទាល់តែសេចក្ដីពិតបាននាំមកដល់គំនិត និងដល់សម្បជញ្ញៈរបស់ខ្លួនហើយៗ បានបដិសេធចោល។ មានមនុស្សជាច្រើនដែលពុំដែលមានឱកាសស្តាប់សេចក្ដីពិតដ៏វិសេសវិសាលសម្រាប់ពេលនេះឡើយ។ ព្រះអង្គដែលស្គាល់អស់ទាំងជម្រៅចិត្ត នឹងមិនទុកចោលនរណាម្នាក់ដែលប្រាថ្នាសេចក្ដីពិត ឱ្យត្រូវទទួលលសេចក្ដីបញ្ឆោតក្នុងរឿងរ៉ាវនៃសេចក្ដីវិវាទនោះឡើយ។ គ្រប់គ្នានឹងមានពន្លឺគ្រប់គ្រាន់ ដើម្បីសម្រេចចិត្តឱ្យបានត្រឹមត្រូវ។

ការសោកល្បួងដ៏ធំអំពីភក្តីភាព

ថ្ងៃសាបាថ ដែលជាការសោកល្បួងដ៏ធំនៃចិត្តភក្តី គឺជាសេចក្ដីពិតដែលគេយកមកជំទាស់គ្នា។ ក្នុងពេលដែលការរក្សាថ្ងៃសាបាថក្លែងក្លាយជាការបញ្ជាក់ថាស្មោះត្រង់ចំពោះអំណាចប្រឆាំងនឹងព្រះ ការរក្សាថ្ងៃសាបាថពិត គឺជាភ័ស្តុតាងនៃចិត្តភក្តីចំពោះព្រះអាទិករ។ នៅពេលដែលក្រុមមួយទទួលទីសម្គាល់របស់សត្វ ក្រុមមួយទៀតទទួលត្រារបស់ព្រះ។

ការដែលទស្សន៍ទាយថា សេចក្ដីមិនអត់ឱនដល់សាសនានឹងមានអំណាចគ្រប់គ្រង ថាវិហារ ហើយនិងរដ្ឋនឹងធ្វើទុក្ខបៀតបៀនដល់អស់អ្នក

ដែលរក្សាក្រឹត្យវិន័យរបស់ព្រះ ត្រូវបានគេប្រកាសឡើងថា ជាទំនាយដែលគ្មានមូលដ្ឋាន ហើយមិនសមហេតុផលទៀតផង។ ប៉ុន្តែ នៅពេលដែលការរក្សាថ្ងៃអាទិត្យ មានការរំជើបរំជួលជាទូទៅ ព្រឹត្តិការណ៍ដែលគេសង្ឃឹមជាយូរលង់មកហើយនោះ នឹងឃើញថាចេះតែរំកិលចូលមកជិតឡើង។ ហើយព្រះរាជសារនេះនឹងបង្កើតឱ្យមានប្រតិកម្មដែលពុំដែលមានពីមុនមក។

នៅរាល់ទាំងតំណមនុស្ស ព្រះតែងតែបញ្ជូនអ្នកបម្រើព្រះអង្គ មកស្តីបន្ទោសដល់អំពើបាបនៅក្នុងលោកីយ៍ និងនៅក្នុងក្រុមជំនុំ។ អ្នកកែទម្រង់ជាច្រើន នៅពេលចាប់ផ្តើមប្រកបការងាររបស់ខ្លួន បានប្តេជ្ញាអនុវត្តដោយប្រុងប្រយ័ត្នបំផុត ក្នុងការតតាំងជាមួយអំពើបាបរបស់វិហារ និងរបស់ប្រទេសជាតិ។ ពួកគេមានសង្ឃឹមថានឹងអាចណែនាំបណ្តាជនឱ្យត្រឡប់មកឯព្រះគម្ពីរវិញ ដោយសារគំរូដ៏ល្អនៃអ្នកគ្រីស្ទានស្អាតស្អំ។ ប៉ុន្តែ ព្រះវិញ្ញាណនៃព្រះបានមកដល់ពួកគេ ពួកគេក៏ចាប់ផ្តើមអធិប្បាយផ្សាយគោលលទ្ធិដ៏ងាយយល់នៃព្រះគម្ពីរ ដោយឥតខ្លាចក្រែងចំពោះផលវិបាកអ្វីកើតឡើងឡើយ។

ព្រះរាជសារនោះ នឹងត្រូវបានប្រកាសផ្សាយក្នុងរបៀបនេះ។ ព្រះអម្ចាស់នឹងធ្វើការតាមរយៈឧបករណ៍ដ៏ស្រគត់ស្រគំ ដែលថ្វាយខ្លួនគេចំពោះការងារព្រះអង្គ។ អ្នកធ្វើការនឹងមានសមត្ថភាព ដោយសារការចាក់ប្រេងតាំងដោយព្រះវិញ្ញាណរបស់ព្រះ ជាជាងដោយការហ្វឹកហ្វឺនពីវិទ្យាស្ថានអក្សរសាស្ត្រ។ មនុស្សនឹងត្រូវបានបង្ខំទៅមុខទាំងប្រដាប់ដោយសេចក្តីខ្ជាប់ខ្ជួនដ៏បរិសុទ្ធ ប្រកាសផ្សាយព្រះបន្ទូលដែលព្រះប្រទានឱ្យ។ អំពើបាបរបស់បាប៊ីឡូននឹងត្រូវលាតត្រដាងឡើង។ បណ្តាជននឹងត្រូវបានផុសផុលឡើង។ មនុស្សរាប់ពាន់នាក់ពុំដែលបានឮព្រះបន្ទូលបែបនេះទេ។ បាប៊ីឡូនគឺជាវិហារដែលបានរលំដួលដោយព្រោះអំពើបាបរបស់ខ្លួន ដោយព្រោះការបដិសេធសេចក្តីពិត។ នៅពេលដែលបណ្តាមនុស្សទៅរកពួកគ្រូរបស់ខ្លួនទាំងសួរថា «តើដូច្នេះមែនឬ?» ពួកគ្រូគង្វាលក៏និយាយប្រាប់រឿងប្រឌិត ដើម្បីរំងាប់

សម្បជញ្ញៈដៃភ្ញាក់រលឹក។ ប៉ុន្តែ ក្នុងកាលដែលមនុស្សជាច្រើននៅតែទាមទារឃ្លាដ៏ងាយយល់ដែលថា «ព្រះអម្ចាស់មានបន្ទូលដូច្នេះថា» ជំនឿដែលគេនិយមជឿខ្លាំងនោះនឹងបំផុតពូកជនស្រឡាញ់អំពើបាប ឱ្យដេរប្រមាថព្រមទាំងធ្វើទុក្ខបៀតបៀនដល់ពួកអ្នកប្រកាសផ្សាយដំណឹងនោះ។

គណៈគ្រូគង្វាល នឹងខំប្រឹងបញ្ចេញអស់ពីសមត្ថភាពដើម្បីបិទពន្លឺ និងដើម្បីគាបសង្កត់ការពិភាក្សាសំណួរដ៏មានសារៈសំខាន់ទាំងនេះ។ វិហារនឹងអំពាវនាវរកកម្លាំងពីអំណាចប្រជាជន ហើយនៅក្នុងកិច្ចការនេះ កាតូលិក និងប្រូតេស្តង់នឹងរួបរួមគ្នា។ នៅពេលដែលចលនាសម្រាប់ពង្រឹងថ្ងៃអាទិត្យកាន់តែងើបមុខឡើង អ្នករក្សាក្រឹត្យវិន័យនឹងទទួលការគំរាមកំហែងដោយការពិន័យប្រាក់ និងការចាប់ដាក់គុក។ មានអ្នកខ្លះត្រូវគេប្រគល់តំណែងខ្ពង់ខ្ពស់ ហើយនិងរង្វាន់ផ្សេងទៀត ដើម្បីឱ្យលះបង់ជំនឿរបស់ខ្លួន។ ប៉ុន្តែ ចម្លើយរបស់គេគឺ «ចូរបង្ហាញកំហុសយើងពីព្រះបន្ទូលមក»។ អស់អ្នកជាប់ចោទនៅមុខតុលាការ ជាអ្នកគាំទ្រយ៉ាងខ្លាំងចំពោះសេចក្តីពិត ហើយអ្នកខ្លះដែលបានឮ ក៏នឹងសម្រេចចិត្តរក្សាក្រឹត្យវិន័យទាំងអស់របស់ព្រះដែរ បើមិនដូច្នោះទេ មនុស្សរាប់ពាន់នាក់នឹងពុំដឹងអ្វីសោះអំពីសេចក្តីពិតទាំងនេះឡើយ។

ការស្តាប់បង្គាប់ព្រះ នឹងត្រូវគេចាត់ទុកជាការបះបោរ។ មាតាបិតានឹងអនុវត្តនូវភាពតឹងរ៉ឹងចំពោះកូនដែលជឿ។ កូនទាំងឡាយនឹងត្រូវគេដកយកមតិកពីខ្លួន ហើយបណ្តេញចេញពីផ្ទះ។ «ឯអស់អ្នកដែលចង់រស់ដោយគោរពប្រតិបត្តដល់ព្រះគ្រីស្ទយេស៊ូវ នោះនឹងត្រូវមានសេចក្តីបៀតបៀន»។ ធីម៉ូថេទី២ ៣:១២។ នៅពេលដែលអ្នកការពារសេចក្តីពិតបដិសេធ មិនគោរពថ្ងៃអាទិត្យ អ្នកខ្លះនឹងត្រូវគេចាប់បោះទៅក្នុងគុក អ្នកខ្លះនឹងត្រូវបណ្តេញចេញពីស្រុក ខ្លះទៀតនឹងត្រូវគេប្រើដូចទាសករដាច់ថ្លៃ។ នៅពេលដែលព្រះវិញ្ញាណនៃព្រះ ត្រូវបានដកចេញពីមនុស្ស នោះនឹងមានការចម្លែកកើតឡើង។ នៅពេលដែលសេចក្តីកោតខ្លាច និងសេចក្តីស្រឡាញ់របស់ព្រះ

ត្រូវបានដកចេញទៅ មនុស្សអាចមានចិត្តយោរយៅណាស់។

<u>សៅរ៍-៩ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥៥
ខព្រះគម្ពីរប្រចាំសប្តាហ៍: *ក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាមានប្រាជ្ញា និងយោបល់ ត្រូវឲ្យអ្នកនោះសំដែងចេញជាកិរិយាល្អ ដោយសារការដែលខ្លួនប្រព្រឹត្ត ដោយសេចក្តីសុភាពនៃប្រាជ្ញាចុះ។ យ៉ាកុប ៣:១៣*

ព្យុះសង្ឃរាកំពុងចូលមក

នៅពេលព្យុះសង្ឃរាខិតចូលមក ក្រុមមួយធំដែលចាត់ខ្លួនថាមានជំនឿចំពោះព្រះរាជសារនៃទេវតាទីបី ប៉ុន្តែពុំបានញែកជាបរិសុទ្ធដោយការស្តាប់បង្គាប់ដោយសេចក្តីពិត នឹងបោះបង់តំណែងរបស់ខ្លួន បែរទៅចូលរួមជាមួយបក្សប្រឆាំង។ ដោយការរួបរួមជាមួយលោកីយ៍ ពួកគេបានថ្លឹងថ្លែងរឿងរ៉ាវដោយការយល់ដឹងដូចគ្នា តែគេជ្រើសរើសយកខាងដែលមានប្រជាប្រិយភាពជាងវិញ។ មនុស្សដែលធ្លាប់មានអំណរចំពោះសេចក្តីពិត ក៏ប្រើអំណោយទាន និងភោហារបស់ខ្លួនដើម្បីធ្វើឱ្យព្រលឹងមនុស្សវង្វេង។ ពួកគេបានក្លាយជាសត្រូវដ៏ជូរចត់ចំពោះបងប្អូនខ្លួនពីអតីតកាល។ ពួកក្បត់សាសនាទាំងនេះ ជាភ្នាក់ងារដ៏មានប្រសិទ្ធិភាពរបស់សាតាំង ក្នុងការមូលបង្កាច់ និងចោទប្រកាន់អ្នករក្សាថ្ងៃសប្ប៉ាតហ៍ ព្រមទាំងបំផុសបំផុលពួកកាន់អំណាចឱ្យប្រឆាំងថែមទៀត។

អ្នកបម្រើរបស់ព្រះអម្ចាស់ បានផ្តល់នូវការព្រមានដាស់តឿនរួចហើយ។ ព្រះវិញ្ញាណនៃព្រះបានការពារពួកគេ។ ពួកគេពុំបានដេញតាមសេចក្តីប្រាថ្នានៃលោកីយ៍ ឬក៏ចង់រក្សាកេរ្តិ៍ឈ្មោះ ឬជីវិតខ្លួនឡើយ។ កិច្ចការហាក់ដូចជាហួសពីសមត្ថភាព ដើម្បីនឹងធ្វើឱ្យបានសម្រេចណាស់។ តែពួកគេពុំអាចត្រឡប់ក្រោយបានឡើយ។ កាលកំពុងមានអារម្មណ៍តែលតោលដូច្នេះ គេក៏រត់ទៅរកព្រះដ៏មានព្រះចេស្តា ដើម្បីទូលសូមកម្លាំង។

សម័យកាលផ្សេងៗនៅក្នុងប្រវត្តិសាស្ត្រ ត្រូវបានកត់សម្គាល់ដោយការរីកចម្រើនដល់សេចក្តីពិតពិសេសខ្លះ ដែលអាស្រ័យទៅតាមការចាំបាច់នៃបណ្តាជនរបស់ព្រះនាពេលនោះ។ រាល់ទាំងសេចក្តីពិតថ្មីៗ តែងតែចេញមកប្រឆាំងនឹងបក្សជំទាស់។ រាជទូតទាំងឡាយរបស់ព្រះគ្រីស្ទ ត្រូវប្រកបភារកិច្ចរបស់ខ្លួន ហើយទុកលទ្ធផលនៅលើព្រះវិញ។

បក្សប្រឆាំងឡើងដល់កម្ពស់ថ្មី

នៅពេលបក្សប្រឆាំងឡើងដល់កម្ពស់ដ៏សាហាវ អ្នកបម្រើរបស់ព្រះមានការស្មុគស្មាញម្តងទៀត ព្រោះហាក់ដូចជាខ្លួនបាននាំមកនូវឧបសគ្គ។ ប៉ុន្តែ សម្បជញ្ញៈ និងព្រះបន្ទូលនៃព្រះ បានបញ្ជាក់ដល់ពួកគេថា ដំណើរការរបស់ពួកគេគឺត្រឹមត្រូវទេ។ ជំនឿ និងទឹកចិត្តរបស់ពួកគេបានចម្រើនឡើងយ៉ាងរួសរាន់។ ទីបន្ទាល់របស់គេគឺ «ព្រះគ្រីស្ទបានចាប់យកអំណាចលោកីយ៍ហើយ តើគួរឱ្យយើងខ្លាចដល់លោកីយ៍ដែលយកបានរួចហើយនេះឬ?»

គ្មាននរណាម្នាក់អាចបម្រើព្រះ ដោយគ្មានការប្រឆាំងពីពួកពលបរិវារនៃសេចក្តីងងឹតបានឡើយ។ ពួកទេវតាអាក្រក់នឹងវាយសម្រុកអ្នកនោះដោយព្រោះខ្លាចបាត់រំពាដែលនៅក្នុងកណ្តាប់ដៃរបស់ពួកវា។ ពួកមនុស្សអាក្រក់នឹងស្វែងរកវិធីបំបែកអ្នកនោះចេញពីព្រះ ដោយសេចក្តីល្បួងល្បាង។ កាលបើប្រើការទាំងនេះនៅតែមិនបានជោគជ័យ គេនឹងប្រើអំណាចបង្ខំសម្បជញ្ញៈម្តងវិញ។

ប៉ុន្តែ ដរាបណាព្រះយេស៊ូវនៅតែជាអ្នកអង្វរករជួសមនុស្សនៅក្នុងរោងឧបោសថខាងលើ ពួកអ្នកច្បាប់ និងពួកបណ្តាជន នឹងស្ថិតនៅក្រោមឥទ្ធិពលការពាររបស់ព្រះវិញ្ញាណបរិសុទ្ធជានិច្ច។ បើទោះជាមានពួកអ្នកច្បាប់ជាច្រើនរបស់យើង ជាភ្នាក់ងារដ៏សកម្មរបស់សាតាំងក៏ដោយ ក៏ព្រះមានភ្នាក់ងាររបស់ព្រះអង្គនៅក្នុងចំណោមមេដឹកនាំនៃប្រទេសជាតិដែរ។ មានមនុស្សមួយចំនួនតូចនឹងទប់ទល់ចរន្តដ៏ខ្លាំងក្លានៃសេចក្តីអាក្រក់។ បក្ស

ប្រឆាំងនៃសត្រូវរបស់សេចក្តីពិត នឹងត្រូវបានឃាត់ទប់ ដើម្បីទុកឱ្យព្រះរាជសាររបស់ទេវតាទីបីធ្វើការ។ សេចក្តីព្រមានចុងក្រោយនឹងធ្វើឱ្យពួកមេដឹកនាំទាំងនេះចាប់អារម្មណ៍យ៉ាងខ្លាំង ហើយមានអ្នកខ្លះទទួលជឿ ហើយព្រមចូលខាងរាស្ត្ររបស់ព្រះនៅក្នុងគ្រាវេទនា។

ភ្លៀងចុងរដូវ និងសម្រែកដ៏ខ្លាំង

ទេវតាដែលរួមជាមួយទេវតាទីបី នឹងត្រូវបំភ្លឺផែនដីទាំងមូលដោយសិរីល្អរបស់លោក។ ព្រះរាជសាររបស់ទេវតាទីមួយ ត្រូវបាននាំចេញទៅកាន់គ្រប់ទាំងស្តានីយ៍បេសកកម្មក្នុងលោកីយ៍ ហើយប្រទេសខ្លះបានចាប់អារម្មណ៍យ៉ាងខ្លាំងក្លាចំពោះសាសនា ដូចមិនដែលមានពីមុនឡើយ តាំងតែពីគ្រាលទ្ធិកែទម្រង់មក។ ប៉ុន្តែ សេចក្តីព្រមានចុងក្រោយនៃទេវតាទីបីនេះ នឹងបានប្រសើរជាងនោះទៅទៀត។

ការងារនោះនឹងមានសភាពស្រដៀងគ្នាទៅនឹងថ្ងៃបុណ្យទី៥០ដែរ។ «ភ្លៀងដើមរដូវ» ត្រូវបានប្រទានមកនៅពេលចាប់ផ្តើមដំណឹងល្អ ដើម្បីធ្វើឱ្យគ្រាប់ពូជដ៏វិសេសដុះពន្លកឡើង ដូច្នេះ «ភ្លៀងចុងរដូវ» នឹងត្រូវប្រទានមកនៅពេលបញ្ចប់ ដើម្បីបន្ទុំគ្រាប់ពូជសម្រាប់ពេលចម្រូត។ ហូសេ ៦:៣; យ៉ូអែល ២:២៣។ កិច្ចការដ៏ឧត្តមនៃដំណឹងល្អ មិនត្រូវបញ្ចប់ទៅដោយមានការសម្តែងអំណាចព្រះចេស្តារបស់ព្រះ តិចជាងដែលបានកត់សម្គាល់នៅពេលបើកចាប់ផ្តើមនោះឡើយ។ បទទំនាយដែលត្រូវបានសម្រេច នៅក្នុងការបង្អុរភ្លៀងដើមរដូវ នាពេលបើកចាប់ផ្តើមដំណឹងល្អ នឹងត្រូវបានសម្រេចម្តងទៀតក្នុងភ្លៀវចុងរដូវនាពេលបិទបញ្ចប់។ នេះជា «ពេលលំហើយ» ដែលសាវ័កពេត្រុសបានទន្ទឹងរង់ចាំ នៅពេលលោកមានប្រសាសន៍ថា៖ «ដូច្នេះ ចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឱ្យបាបអ្នករាល់គ្នាបានលុបចេញ ប្រយោជន៍ឱ្យមានពេលលំហើយមកពីចំពោះព្រះអម្ចាស់ហើយឱ្យទ្រង់បានចាត់ព្រះអង្គ»។ កិច្ចការ ៣:១៩,២០។

អ្នកបម្រើរបស់ព្រះ ដែលបានថ្វាយខ្លួនជាបរិសុទ្ធ មានទឹកមុខភ្លឺចាំង

នឹងប្រញាប់ប្រញាល់ពីកន្លែងមួយទៅកន្លែងមួយ ប្រកាសផ្សាយព្រះរាជសារពីស្ថានសួគ៌។ ការអស្ចារ្យនឹងសម្តែងឡើង អ្នកជំងឺនឹងត្រូវព្យាបាលឱ្យជា។ សាតាំងក៏ធ្វើការអស្ចារ្យដ៏កំភូត ថែមទាំងនាំឱ្យធ្លាក់ភ្លើងពីលើមេឃមកផង។ វិវរណៈ ១៣:១៣។ ម្ល៉ោះហើយមនុស្សម្នានៅលើផែនដី នឹងត្រូវធ្វើការសម្រេចចិត្ត។

ព្រះរាជសារនឹងត្រូវបានផ្សព្វផ្សាយ ដោយមិនមានការជជែកដេញដោលច្រើនទេ គឺដោយការងារនៃព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះដែលបណ្តាលឱ្យមានចិត្តជឿវិញ។ សេចក្តីវែកញែកត្រូវបានដាក់នៅចំពោះបណ្តាមនុស្សរួចហើយ ការបោះពុម្ពផ្សាយក៏បានបញ្ចេញឥទ្ធិពលដែរ ប៉ុន្តែនៅតែមានមនុស្សជាច្រើនដែលត្រូវបានបង្ខាំងមិនឱ្យយល់សេចក្តីពិតបានពេញលេញឡើយ។ ឥឡូវនេះគេបានឃើញសេចក្តីពិតយ៉ាងច្បាស់ក្រឡែត។ ទំនាក់ទំនងគ្រួសារ និងទំនាក់ទំនងវិហារ ក៏គ្មានអំណាចឃាត់ឃាំងកូនដ៏ស្មោះត្រង់របស់ព្រះបានដែរនៅពេលនេះ។ ថ្វីបើមានភ្នាក់ងារទាំងឡាយរួមគ្នាប្រឆាំងសេចក្តីពិតក៏ដោយ ក៏មានមួយចំនួនធំនាំគ្នាកាន់ខាងព្រះអម្ចាស់ដែរ។

គ្រោះវេទនា

<u>អាទិត្យ-១០ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៤៥

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែប្រាជ្ញាដែលមកពីស្ថានលើ នោះមុនដំបូងហៅថា បរិសុទ្ធ រួចមកមានមេត្រីចិត្ត សេចក្ដីសំឡុត ចិត្តទន់ ក៏ពេញដោយសេចក្ដីមេត្តាករុណា និងផលល្អ ឥតរើសមុខ ហើយឥតពុតមាយាផង។*
យ៉ាកុប ៣:១៧

«នៅគ្រានោះ មីកែល ជាមហាទេវតាដែលតំណាងពួកកូនចៅរបស់សាសន៍អ្នក លោកនឹងឈរឡើង ក៏នឹងមានគ្រាវេទនាជាខ្លាំង ដល់ម្ល៉េះបានជាចាប់តាំងពីមាននគរដរាបដល់វេលានោះឯងនោះមិនដែលកើតមានយ៉ាងដូច្នោះឡើយ ហើយនៅគ្រានោះ សាសន៍អ្នកនឹងបានប្រោសឱ្យរួច គឺអស់អ្នកណាដែលមានកត់ទុកក្នុងបញ្ជី»។ ដានីយ៉ែល ១២:១។

នៅពេលដែលព្រះរាជសាររបស់ទេវតាទី៣បានបញ្ចប់ទៅបណ្តាជនរបស់ព្រះក៏បានបង្ហើយកិច្ចការរបស់ខ្លួនដែរ។ គេបានទទួល «ភ្លៀងចុងរដូវ» ហើយបានត្រៀមខ្លួនសម្រាប់គ្រាទុក្ខលំបាកនៅពេលខាងមុខ។ ការសាកល្បងចុងក្រោយបង្អស់ បាននាំមកចំពោះលោកីយ៍រួចហើយ ហើយទាំងអស់គ្នាដែលបានបង្ហាញថាមានភក្តីភាពដល់សិក្ខាបទរបស់ព្រះ បានទទួល «គ្រារបស់ព្រះដ៏មានព្រះជន្មរស់»។ នៅពេលនោះព្រះយេស៊ូវនឹងបញ្ចប់ការងារជាសង្ឃរបស់ព្រះអង្គ នៅក្នុងរោងឧបោសថខាងលើ ទាំងបញ្ចេញព្រះសូរសៀងដ៏ខ្លាំងថា «ការស្រេចហើយ»។ «អ្នកណាដែលទុច្ចរិតឱ្យអ្នកនោះ

នៅតែទុច្ចរិតចុះ អ្នកណាដែលស្មោកគ្រោក ឱ្យអ្នកនោះនៅតែស្មោកគ្រោកចុះ តែអ្នកណាដែលសុចរិតវិញ ត្រូវឱ្យអ្នកនោះចេះតែប្រព្រឹត្តផ្លូវសុចរិតទៅ ហើយអ្នកណាដែលបរិសុទ្ធ ឱ្យអ្នកនោះនៅតែបរិសុទ្ធដដែល»។ វិវរណៈ ២២:១១។ ព្រះគ្រីស្ទបានធ្វើតង្វាយលោះបាបសម្រាប់រាស្ត្ររបស់ផងព្រះអង្គ ហើយនិងលុបអំពើបាបរបស់គេចេញផង។ «រាជ្យ និងអំណាចគ្រប់គ្រង ព្រមទាំងភាពរុងរឿងឧត្តមនៃអស់ទាំងនគរនៅក្រោមមេឃទាំងមូល» (ដានីយ៉ែល ៧:២៧) គឺហៀបនឹងត្រូវបានប្រគល់ដល់អ្នកទទួលមត៌កនៃសេចក្តីសង្គ្រោះ ហើយព្រះយេស៊ូវទ្រង់នឹងសោយរាជ្យជាស្តេចលើអស់ទាំងស្តេច និងជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់។

នៅពេលព្រះអង្គយាងចេញអំពីរោងឧបោសថ ភាពងងឹតនឹងគ្របដណ្តប់ទៅលើសត្វលោកនៃផែនដី។ ពួកសុចរិតត្រូវតែរស់នៅចំពោះព្រះភ័ក្ត្រនៃព្រះដ៏បរិសុទ្ធដោយគ្មានអ្នកអង្វរករជំនួស។ សេចក្តីការពារដល់ពួកអាក្រក់ត្រូវបានដកចេញ ហើយសាតាំងបានគ្រប់គ្រងទាំងស្រុងទៅលើពួកមិនប្រែចិត្ត។ ព្រះវិញ្ញាណរបស់ព្រះត្រូវបានដកចេញជាទីបំផុតហើយ។ ពេលនោះសាតាំងនឹងបោះសត្វលោកនៃផែនដីទៅក្នុងសេចក្តីវេទនាដ៏ធំនៅចុងក្រោយបង្អស់។ ទេវតារបស់ព្រះនឹងលែងទប់នូវខ្យល់កាចសាហាវនៃតណ្ហារបស់មនុស្សជាតិ។ លោកីយ៍ទាំងមូលនឹងមានការហិនវិនាសដែលលើសជាងក្រុងយេរូសាឡិមពីសម័យដើមទៅទៀត។ មានកម្លាំងទ័ពត្រៀមខ្លួនជាស្រេច នៅរង់ចាំតែការអនុញ្ញាតពីព្រះប៉ុណ្ណោះ ដើម្បីធ្វើឱ្យគ្រប់ទីកន្លែងបានសាបសូន្យអស់ទៅ។

អស់អ្នកដែលគោរពក្រឹត្យវិន័យរបស់ព្រះ នឹងត្រូវគេចាត់ទុកថាជាដើមហេតុនៃសេចក្តីវឹកវរ និងការបង្ហូរឈាមដ៏រន្ធត់ ដែលបានបំពេញផែនដីដោយសេចក្តីវេទនា។ អំណាចដែលមកជាមួយការព្រមានចុងក្រោយបានធ្វើឱ្យពួកអាក្រក់ឆេះឆួលយ៉ាងខ្លាំង រួចសាតាំងក៏ធ្វើឱ្យវិញ្ញាណសម្អប់

និងវិញ្ញាណធ្វើទុក្ខទោស រំជួលឡើងទាស់នឹងអស់អ្នកដែលបានទទួលព្រះ រាជសារ។

នៅពេលដែលវត្តមានរបស់ព្រះបានដកចេញអំពីប្រទេសជ្ងវទៅ ពួក សង្ឃ និងបណ្តាជននៅតែចាត់ខ្លួនគេថាជាអ្នករើសតាំងរបស់ព្រះដដែល។ ការងារក្នុងវិហារនៅតែបន្តទៅមុខ ព្រះពរដ៏ពិសិដ្ឋត្រូវបានអំពាវនាវរាល់ថ្ងៃ ឱ្យមនុស្សដែលមានកំហុសចំពោះព្រះលោហិតរបស់ព្រះរាជបុត្រាព្រះ។ ដូច្នេះ នៅពេលដែលសេចក្តីសម្រេចដ៏មិនអាចតវ៉ាបាននៃរោងឧបោសថ ត្រូវបាន ប្រកាសឡើង ហើយវាសនារបស់លោកីយ៍នឹងស្ថិតនៅក្នុងសភាពដដែលជា រៀងរហូតនោះ បណ្តាមនុស្សដែលរស់នៅលើផែនដីនឹងពុំបានដឹងឡើយ។ មនុស្សដែលព្រះវិញ្ញាណនៃព្រះបានដកចេញពីខ្លួន នៅតែរក្សាទម្រង់ សាសនាដដែល ការខិតខំយ៉ាងស្វាហាប់ដ៏អសោចដើម្បីសម្រេចគម្រោង ការព្យាបាទ នឹងមើលទៅដូចជាការខិតខំយ៉ាងស្វាហាប់សម្រាប់ព្រះ។

<u>ចន្ទ-១១ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៤៦

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែទ្រង់ផ្តល់ព្រះគុណមកកាន់តែខ្លាំងឡើង ហេតុនោះ បានជាទ្រង់មានព្រះបន្ទូលថា «ព្រះទ្រង់ទាស់ទទឹងនឹងពួកមានឫកធំ តែ ទ្រង់ផ្តល់ព្រះគុណមកពួករាបសាវិញ»។ យ៉ាកុប ៤:៦*

នៅពេលដែលថ្ងៃសប្ប៉ាតហ៍បានក្លាយទៅជាចំណុចសំខាន់នៃការវិវាទ ដល់ទូទាំងគ្រីស្ទានពិភពលោក គេនឹងលើកឡើងថា មិនត្រូវអត់ទ្រាំនឹងក្រុម តូចដែលឈរជំទាស់នឹងវិហារ និងរដ្ឋឡើយ ហើយថាវាប្រសើរជាង ដើម្បី ឱ្យពួកគេរងទុក្ខឈឺចាប់ ជាជាងឱ្យជាតិសាសន៍ទាំងមូល ត្រូវបោះចូលទៅ ក្នុងភាពច្របូកច្របល់ និងភាពគ្មានច្បាប់គ្មានវិន័យ។ សម្តីដដែលនេះធ្លាប់ បានពោលទាស់នឹងព្រះគ្រីស្ទរួចមកហើយ។ «បើមានមនុស្សម្នាក់ស្លាប់

ជំនួសបណ្តាជន» លោកកៃផាមានប្រសាសន៍ «នោះមានប្រយោជន៍ដល់អ្នករាល់គ្នាជាជាង ដើម្បីកុំឱ្យជាតិយើងនេះត្រូវវិនាសទាំងអស់ឡើយ»។ យ៉ូហាន ១១:៥០។ ការពោលដូច្នេះនឹងមើលទៅដូចជាត្រឹមត្រូវណាស់ ទីបំផុតនឹងមានចេញបទបញ្ជាមួយ ជំទាស់នឹងអស់អ្នកដែលរក្សាថ្ងៃសប្ប៉ាតហ៍ នៃក្រឹត្យវិន័យទី៤ជាបរិសុទ្ធ ដោយប្រកាសប្រឆាំងនឹងពួកគេ ព្រមទាំងផ្តល់សិទ្ធិដល់បណ្តាជនឱ្យសម្លាប់ពួកគេផង បន្ទាប់ពីមួយរយៈក្រោយមក។ លទ្ធិរ៉ូមនិយមក្នុងសម័យដើម និងលទ្ធិប្រូតេស្តង់និយមដែលងាកចេញពីជំនឿក្នុងសម័យថ្មី នឹងប្រព្រឹត្តអំពើស្រដៀងគ្នាដែរ។ នៅពេលនោះរាស្ត្ររបស់ព្រះនឹងត្រូវបានធ្លាក់ទៅក្នុងទិដ្ឋភាពនៃការខ្លោចផ្សាចិត្ត ដូចបានពណ៌នាថាជា «គ្រាវេទនារបស់យ៉ាកុប»។ យេរេមា ៣០:៥-៧។

គ្រាវេទនារបស់យ៉ាកុប

រាត្រីសោកសៅរបស់យ៉ាកុប ក្នុងពេលដែលគាត់ខំអធិស្ឋានឱ្យរួចខ្លួនពីអេសាវ (លោកុប្បត្តិ ៣២:២៤-៣០) ជាតំណាងពិសោធន៍នៃរាស្ត្ររបស់ព្រះក្នុងគ្រាវេទនា។ ដោយព្រោះការបោកបញ្ឆោតយកពរពីឪពុកដែលបម្រុងទុកឱ្យអេសាវ យ៉ាកុបបានភៀសខ្លួនដោយខ្លាចបងរបស់ខ្លួនសម្លាប់។ បន្ទាប់ពីបាននិរទេសខ្លួនជាច្រើនឆ្នាំមក គាត់ក៏បានសម្រេចចិត្តត្រឡប់ចូលស្រុកកំណើតខ្លួនវិញ។ នៅពេលចូលជិតដល់ព្រំដែន គាត់មានការភិតភ័យជាខ្លាំងដោយឮដំណឹងថាអេសាវកំពុងនាំគ្នាចូលមក ហើយប្រាកដជានឹងមកសងសឹកជាមិនខាន។ យ៉ាកុបមានតែសង្ឃឹមទៅលើសេចក្តីមេត្តាករុណារបស់ព្រះតែប៉ុណ្ណោះ អ្វីដែលការពាររបស់គាត់ គឺមានតែសេចក្តីអធិស្ឋានទេ។

គាត់បានលន់តួបាបដោយការបន្ទាបខ្លួនយ៉ាងខ្លាំងតែម្នាក់ឯងជាមួយព្រះ។ ឧបសគ្គក្នុងជីវិតគាត់បានមកដល់ហើយ។ គាត់បានបន្តអធិស្ឋាននៅក្នុងយប់ងងឹត។ ស្រាប់តែមានដៃមួយដាក់មកលើស្មាគាត់។ គាត់

គិតថាប្រហែលជាសត្រូវមករកសម្លាប់គាត់ហើយ គាត់ក៏ប្រើអស់ទាំង
ថាមពលដែលសេសសល់ទាំងប៉ុន្មាន ចាប់បោកចំបាប់ជាមួយអ្នកយាយី។
នៅពេលថ្ងៃជិតរះ ជនចម្លែកបានប្រើកម្លាំងឥទ្ធិឫទ្ធិរបស់ខ្លួន។ យ៉ាកុបហាក់
ដូចជាទន់ដៃទន់ជើង ធ្វើអ្វីលែងកើត ហើយក៏ទម្លាក់ខ្លួន យំខ្សឹកខ្សួលនៅ
លើស្មាគូបដិបក្សដ៏អាថិកំបាំងរបស់ខ្លួនតែម្តងទៅ។ គ្រានោះគាត់ក៏បានដឹង
ថា គឺជាទេវតានៃសេចក្តីសញ្ញាទេតើ ដែលគាត់បានប្រយុទ្ធជាមួយនោះ។
គាត់មានការសោកស្តាយចំពោះអំពើបាបរបស់គាត់អស់រយៈពេលយូរមក
ហើយ ឥឡូវនេះគាត់ដឹងយ៉ាងច្បាស់ថា គាត់ត្រូវបានអត់ទោសឱ្យជាប្រាកដ។
ភ្លៀវពីស្ថានសួគ៌រៀបតែនឹងចាកចេញទៅវិញ ប៉ុន្តែ យ៉ាកុបបានឱបលោក
ជាប់។ ទេវតាមានបន្ទូលថា «ចូរលែងឱ្យយើងទៅ ដ្បិតភ្លឺហើយ» ប៉ុន្តែ បុព្វ
បុរសបានឧទានថា «ខ្ញុំមិនឱ្យលោកទៅទេ ទាល់តែបានឱ្យពរដល់ខ្ញុំសិន»។
យ៉ាកុបបានលន់តួនូវភាពកម្សោយ និងភាពមិនគួររបស់ខ្លួន ហើយនៅតែទុក
ចិត្តចំពោះសេចក្តីមេត្តាករុណានៃព្រះដ៏រក្សានូវសេចក្តីសញ្ញា។ ដោយការ
ប្រែចិត្តហើយចុះចូល បាបជននេះក៏បានឈ្នះព្រះមហាក្សត្រនៃស្ថានសួគ៌។

សាតាំងបានចោទប្រកាន់យ៉ាកុបនៅចំពោះព្រះ ដោយព្រោះអំពើ
បាបរបស់គាត់ វាបានបណ្តាលឱ្យអេសាវលើកគ្នាមកទាស់នឹងគាត់។ នៅ
ក្នុងរាត្រីកាច់ចំបាប់គ្នា សាតាំងបានខ្ទះខ្ទែងទម្លាក់ទឹកចិត្តគាត់ ឱ្យប្រឡេះដៃ
ចេញពីព្រះ។ គាត់ស្ទើរតែអស់សង្ឃឹមទៅហើយ ប៉ុន្តែ គាត់បានសោកស្តាយ
ដោយស្មោះ ចំពោះអំពើបាបដែលគាត់បានប្រព្រឹត្ត ហើយបានចាប់ទេវតា
ជាប់ ឥតព្រមលែង ព្រមទាំងយំអង្វរ រហូតទាល់តែបានឈ្នះ។

សាតាំងចោទប្រកាន់យ៉ាកុបជាយ៉ាងណា វាក៏នឹងចោទប្រកាន់រាស្ត្រ
របស់ព្រះជាយ៉ាងនោះដែរ។ វាបានដឹងជាក់ច្បាស់នូវអំពើបាបដែលវាបាន
ល្បួងពួកគេឱ្យប្រព្រឹត្ត ក៏ពោលថាព្រះអម្ចាស់មិនអាចយុត្តិធម៌បានទេ ក្នុង
ការដែលអត់ទោសបាបឱ្យពួកគេ រួចបំផ្លាញវា និងពួកទេវតារបស់វាចោល

នោះ។ វាបានទាមទារឱ្យប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃវា ដើម្បីឱ្យវាបំផ្លាញពួកគេចោល។

ព្រះអម្ចាស់នឹងអនុញ្ញាតឱ្យវាសាកល្បងពួកគេដល់កំពូល។ ទំនុកទុកចិត្តរបស់ពួកគេចំពោះព្រះ និងជំនឿរបស់ពួកគេនឹងត្រូវបានសាកលយ៉ាងតឹងរ៉ឹងបំផុត។ សាតាំងខិតខំបំភ័យពួកគេ ដោយសង្ឃឹមថានឹងអាចបំផ្លាញជំនឿរបស់គេប្រយោជន៍ឱ្យធ្លាក់ទៅក្នុងសេចក្តីល្បួង ហើយបំបែរភក្តីភាពរបស់គេចេញអំពីព្រះវិញ។

<u>អង្គារ-១២ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៤៧

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដូច្នេះ ត្រូវចុះចូលចំពោះព្រះ ហើយតស៊ូនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ ។ យ៉ាកុប ៤:៧*

ការឈឺចាប់ដែលនឹងធ្វើឱ្យគេបន្ទោសដល់ព្រះ

ការឈឺចាប់ដែលរាស្ត្ររបស់ព្រះទទួលនេះ ពុំមែនជាការខ្លាចអំពើបៀតបៀននោះទេ។ ពួកគេភ័យខ្លាចក្រែងមានកំហុសក្នុងខ្លួន ដែលនឹងធ្វើឱ្យគេពុំបានដឹងនូវការសម្រេចនៃសេចក្តីសន្យារបស់ព្រះអង្គសង្គ្រោះដែលថា៖ «អញនឹងរក្សាឯងឱ្យរួចពីវេលាល្បងដែលត្រូវមកលើលោកីយ៍ទាំងមូល»។ វិវរណៈ ៣:១០។ បើពួកគេបង្ហាញខ្លួនឱ្យឃើញថាមិនសមគួរដោយព្រោះចរិតលក្ខណៈរៀចវេរនោះ នោះព្រះនាមបរិសុទ្ធនៃព្រះនឹងទទួលការបន្ទោសជាពុំខាន។

ពួកគេចង្អុលទៅកាន់ពេលដែលគេលន់តួបាបដ៏ច្រើនរបស់ខ្លួននៅគ្រាអតីតកាល ហើយទូលអង្វរសូមសេចក្តីសន្យារបស់ព្រះអង្គសង្គ្រោះដែលថា៖ «ឱ្យគេមកពឹងពាក់កម្លាំងអញវិញ ដើម្បីឱ្យបានជាមេត្រីរបស់អញ ចូរឱ្យគេជាមេត្រីនឹងអញចុះ»។ អេសាយ ២៧:៥។ ទោះបីមានការថប់បារម្ភ

និងទុក្ខព្រួយយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែមិនឈប់អង្វរករដែរ។ គេនៅតែតោងជាប់នឹងព្រះ ដូចយ៉ាកុបតោងជាប់នឹងទេវតាយ៉ាងនោះដែរ ហើយភាសានៃវិញ្ញាណរបស់គេគឺ «ទូលបង្គំមិនឱ្យព្រះអម្ចាស់ទៅទេ លើកលែងតែព្រះអម្ចាស់ឱ្យពរទូលបង្គំសិន»។

អំពើបាបត្រូវបានលុបចេញ

នៅក្នុងគ្រាវេទនា ប្រសិនបើវាស្ត្ររបស់ព្រះមានអំពើបាបដែលពុំបានលន់តួ ត្រូវលេចឡើងនៅចំពោះខ្លួន នាពេលដែលសេចក្តីភិតភ័យនិងសេចក្តីឈឺចាប់កំពុងតែធ្វើទុក្ខយ៉ាងខ្លាំដល់ពួកគេនោះ គេនឹងទប់ស្មារតីមិនជាប់ឡើយ។ ការអស់សង្ឃឹមនឹងផ្តាច់ជំនឿរបស់គេចេញ ហើយក៏ពុំអាចទូលអង្វរព្រះឲ្យជួយដោះលែងបានដែរ។ ប៉ុន្តែ គេក៏ពុំមានកំហុសលាក់កំបាំងឯណា យកមកបញ្ចេញសោះ។ អំពើបាបរបស់គេបានចូលទៅចំពោះទីជំនុំជំរះ ព្រមទាំងបានលុបចេញរួចទៅហើយ ហើយគេក៏មិននឹកចាំពីអំពើបាបទាំងនោះទៀតឡើយ។

ព្រះអង្គបានបង្ហាញដល់យ៉ាកុប ថាទ្រង់នឹងមិនអត់ទ្រាំនឹងអំពើអាក្រក់ឡើយ។ អស់អ្នកដែលដោះសា ឬលាក់កំបាំងអំពើបាបរបស់ខ្លួន ហើយទុកឱ្យរក្សានៅក្នុងសៀវភៅនៃស្ថានសួគ៌ ដោយពុំបានលន់តួ និងអត់ទោសឱ្យនោះ នឹងត្រូវស្ថិតនៅក្រោមអំណាចរបស់សាតាំងហើយ។ គេមានតំណែងខ្ពង់ខ្ពស់កាលណា នោះជ័យជម្នះនៃបច្ចាមិត្តរបស់ខ្លួន ច្បាស់ជាបានខ្ពង់ខ្ពស់កាលនោះដែរ។ អស់អ្នកពន្យារការរៀបចំខ្លួន ពុំអាចរៀបចំខ្លួនក្នុងគ្រាវេទនា ឬនៅពេលណាទៀតបានឡើយ។ ករណីរបស់អ្នកបែបនេះពុំមានសង្ឃឹមឡើយ។

ប្រវត្តិយ៉ាកុបក៏ជាការបញ្ជាក់មួយថា ព្រះនឹងមិនបោះបង់ចោលអស់អ្នកដែលបានក្បត់ទៅក្នុងអំពើបាប ហើយបែរមកឯព្រះអង្គវិញ ដោយការ

ប្រែចិត្តពិតប្រាកដនោះឡើយ។ ព្រះនឹងបញ្ជូនទេវតាទៅកំសាន្តចិត្តពួកគេ
នៅក្នុងគ្រាអាសន្ន។ ព្រះនេត្រព្រះតែងតែទតមកលើរាស្ត្រព្រះអង្គ។
អណ្តាតភ្លើងនៃគុកភ្លើង ហាក់ដូចជាហៀបនឹងបញ្ឆេះពួកគេទៅ ប៉ុន្តែ ព្រះ
អង្គដ៏ជាអ្នកចម្រាញ់នឹងយកគេមកដូចជាមាសសុទ្ធដែលបានដេញដោយ
ភ្លើងរួចហើយ។

ជំនឿដែលស៊ូទ្រាំ

គ្រាទុក្ខព្រួយ និងគ្រាឈឺចាប់នៅចំពោះមុខយើង នឹងត្រូវការជំនឿ
ដែលស៊ូទ្រាំនូវភាពខ្សោះល្វើយ ភាពអត់ឃ្លាន និងការបង្អង់ពេលវេលា និង
ជំនឿដែលមិនចេះរសាយ ទោះបីជួបប្រទះសេចក្តីល្បងដ៏ធ្ងន់ធ្ងរយ៉ាងណាក៏
ដោយ។ ជ័យជម្នះរបស់យ៉ាកុប គឺជាភ័ស្តុតាងមួយរបស់អំណាចនៃសេចក្តី
អធិស្ឋានឥតឈប់ឈរ។ អស់អ្នកណាដែលកាន់ខ្ជាប់នូវសេចក្តីសន្យារបស់
ព្រះដូចជាលោកនោះនឹងបានឈ្នះដូចជាលោកដែរ។ កាច់ចំបាប់ជាមួយព្រះ
មានប៉ុន្មាននាក់ដែលដឹងថាជាអ្វីនោះ! នៅពេលដែលរលកនៃភាពអស់
សង្ឃឹមបោកទៅលើអ្នកទូលអង្វរករ តើមានប៉ុន្មាននាក់គោងជាប់ដោយ
ជំនឿចំពោះសេចក្តីសន្យានៃព្រះ។

អស់អ្នកណាដែលមានជំនឿតិច ឥឡូវនេះកំពុងស្ថិតនៅក្នុងគ្រោះ
ថ្នាក់ដ៏ធំ ដោយធ្លាក់ទៅក្រោយអំណាចបោកបញ្ឆោតរបស់សាតាំង។ ទោះបី
គេបានទ្រាំទ្រចំពោះការសាកល្បងក៏ដោយ ក៏គេនឹងត្រូវធ្លាក់ទៅក្នុងក្តីទុក្ខ
ព្រួយយ៉ាងជ្រៅ ពីព្រោះគេពុំទម្លាប់ទុកចិត្តលើព្រះ។ ឥឡូវនេះយើងគួរតែ
ល្បងសេចក្តីសន្យារបស់ព្រះអង្គ។

<u>ពុធ-១៣ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៤៨

ខព្រះគម្ពីរប្រចាំថ្ងៃ: *ខ្ញុំទុកសេចក្តីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្តីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកីយ៍ឲ្យទេ កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ។ យ៉ូហាន ១៤:២៧*

បញ្ហាដែលបានគិតទុកជាមុន តែងតែឃើញធំជាងការពិត ប៉ុន្តែ ឧបសគ្គនៅមុខយើង មិនដូច្នោះទេ។ ការសម្តែងជាក់ស្តែងបំផុត មិនអាចលុកដល់ទំហំនៃការឈឺចាប់នោះបានឡើយ។ នៅក្នុងគ្រាទុក្ខលំបាក ព្រលឹងរាល់រូបត្រូវឈរឡើងសម្រាប់ខ្លួនឯងនៅចំពោះព្រះភ័ក្ត្រព្រះ។

ឥឡូវនេះនៅពេលដែលសម្តេចសង្ឃជាន់ខ្ពស់របស់យើង កំពុងថ្វាយតង្វាយលោះបាបសម្រាប់យើង យើងគួរតែស្វះស្វែងដើម្បីឱ្យបានគ្រប់លក្ខណ៍ក្នុងព្រះគ្រីស្ទ។ ព្រះអង្គសង្គ្រោះរបស់យើង ពុំបានធ្លាយធ្លាក់ទៅក្នុងអំណាចនៃសេចក្តីល្បួងក្នុងគំនិតឡើយ។ សាតាំងតែងតែរកចំណុចដែលវាអាចដាក់ជើងជាន់បាននៅក្នុងចិត្តមនុស្ស ឱ្យតែនឹកប៉ងពីអ្វីដែលមាននិស្ស័យជាបាបចុះ នោះសេចក្តីល្បួងរបស់វានឹងមានអំណាចលើគេហើយ។ ប៉ុន្តែ ព្រះគ្រីស្ទមានបន្ទូលអំពីអង្គទ្រង់ថា៖ «ចៅហ្វាយរបស់លោកីយ៍នេះជិតមកដល់ហើយ តែគ្មានអ្វីនៅក្នុងខ្ញុំទេ»។ យ៉ូហាន ១៤:៣០។ សាតាំងរកពុំឃើញអ្វីនៅក្នុងព្រះរាជបុត្រានៃព្រះ ដែលអាចឱ្យវាមានជ័យជម្នះឡើយ។ គ្មានបាបណានៅក្នុងទ្រង់ដែលសាតាំងអាចកេងប្រយោជន៍បានទេ។ អស់អ្នកដែលនឹងឈរឡើងនៅក្នុងគ្រាវេទនា ត្រូវមានលក្ខណៈដូច្នេះ។

គឺនៅក្នុងជីវិតនេះឯងដែលយើងញែកបាបចេញអំពីខ្លួនយើង ដោយជឿដល់ព្រះលោហិតលោះបាបរបស់ព្រះគ្រីស្ទ។ ព្រះអង្គសង្គ្រោះដ៏វិសេសវិសាលរបស់យើង ទ្រង់អញ្ជើញឱ្យរួមខ្លួនយើងជាមួយព្រះអង្គ ឱ្យរួបរួមភាពខ្សោះខ្សាយរបស់យើងជាមួយកម្លាំងដ៏ខ្លាំងក្លាជាមួយព្រះអង្គ និងភាពមិន

សមគួររបស់យើងជាមួយសេចក្តីថ្លៃថ្នូររបស់ទ្រង់។ គឺសម្រេចលើយើងទេ ចំពោះកិច្ចសហប្រតិបត្តិការជាមួយស្ថានសួគ៌ ដើម្បីជួយឱ្យចរិតលក្ខណៈរបស់យើងបានដូចជាគំរូដ៏ពិសិដ្ឋ។

កិច្ចការបោកបញ្ឆោត និងកិច្ចការបំផ្លិចបំផ្លាញរបស់អារក្ស នឹងលូតដល់កំពូលនៅក្នុងគ្រាវេទនា។ ទិដ្ឋភាពដ៏គួរភ័យខ្លាចដែលមានលក្ខណៈខុសពីធម្មជាតិ នឹងត្រូវលាតត្រដាងនៅលើផ្ទៃមេឃ ជាទីសម្គាល់នៃអំណាចរបស់អារក្សដែលធ្វើការអស្ចារ្យ។ វិញ្ញាណអារក្សនឹងចេញទៅឯ «ពួកស្តេចនៅលើផែនដី» ហើយនិងលោកីយ៍ទាំងមូល ដើម្បីជំរុញឱ្យរួបរួមជាមួយសាតាំង នៅក្នុងការតស៊ូចុងក្រោយដើម្បីប្រឆាំងនឹងការគ្រប់គ្រងនៃស្ថានសួគ៌។ មនុស្សខ្លះនឹងធ្វើពុត លើកខ្លួនឡើងថាជាព្រះគ្រីស្ទ។ គេនឹងសម្តែងការអស្ចារ្យ ព្យាបាលជំងឺ ហើយតាំងខ្លួនថាបានទទួលការបើកសម្តែងមកអំពីស្ថានសួគ៌ដែលផ្ទុយអំពីបទគម្ពីរទៀតផង។

សាតាំងប្រែក្រឡាធ្វើជាព្រះគ្រីស្ទ

ក្នុងការសម្តែងតួកំពូលនៅក្នុងរឿងល្ខោននៃសេចក្តីឆបោកដ៏ធំ សាតាំងផ្ទាល់នឹងដើរតួជាព្រះគ្រីស្ទតែម្តង។ ក្រុមជំនុំបានទន្ទឹងរង់ចាំដំណើរព្រះអង្គសង្គ្រោះយាងមក ថាជាទីសង្ឃឹមចុងក្រោយបង្អស់របស់ខ្លួន។ ឥឡូវនេះមេឆបោកនឹងធ្វើឱ្យមើលដូចជាព្រះគ្រីស្ទយាងមក។ សាតាំងនឹងសម្តែងខ្លួន វាដូចជាព្រះអម្ចាស់ដ៏មានពន្លឺភ្លឺត្រចះត្រចង់ ដូចសេចក្តីពិពណ៌នាអំពីព្រះរាជបុត្រានៃព្រះ នៅក្នុងគម្ពីរវិវរណៈដូច្នោះដែរ។ វិវរណៈ ១:១៣-១៥។

សិរីល្អដែលព័ទ្ធជុំវិញវា គឺអស្ចារ្យជាងអ្វីដែលភ្នែកធម្មតាធ្លាប់ឃើញទៅទៀត។ សម្រែកជ័យឃោសក៏បន្លឺឡើង «ព្រះគ្រីស្ទយាងមកហើយ!» បណ្តាមនុស្សក៏ឱនក្រាបនៅចំពោះវា។ វាលើកដៃឡើងឱ្យពរដល់គេ។ សំឡេងវាទន់ភ្លន់ ហើយពីរោះស្តាប់ក្រៃលែង។ វាបញ្ចេញពាក្យសម្តីដែល

ប្រកបដោយសេចក្តីអាណិតអាសូរ ត្រង់កន្លែងខ្លះមានសភាពដូចគ្នានឹងសេចក្តីនៃស្ថានសួគ៌ដែលព្រះអង្គសង្គ្រោះធ្លាប់មានបន្ទូល។ វានឹងព្យាបាលជំងឺរោគារួចហើយក្នុងការប្រែក្រឡាធ្វើជាតួព្រះគ្រីស្ទនោះ វាក៏អះអាងប្តូរថ្ងៃសប្ប៉ាតហ៍ទៅជាថ្ងៃអាទិត្យទៀតផង។ វាថ្លែងថាអស់អ្នកណាដែលរក្សាថ្ងៃទីប្រាំពីរជាបរិសុទ្ធ គឺប្រមាថដល់ឈ្មោះវាហើយ។ នេះគឺខ្លាំងមែន គឺស្ទើរតែបំភាន់មនុស្សគ្រប់គ្នា។ ហ្វូងមនុស្សនាំគ្នាបែរទៅរកអាបធ្មប់ទាំងនេះ ទាំងនិយាយថា «នេះពិតជាតួព្រះចេស្តានៃព្រះដ៏ធំហើយ»។ កិច្ចការ ៨:១០។

<u>ព្រហស្បតិ៍-១៤ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៤៩

ខព្រះគម្ពីរប្រចាំថ្ងៃ:*ចូរបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់ នោះទ្រង់នឹងដំកើងអ្នករាល់គ្នាឡើង។ យ៉ាកុប ៤:១០*

បណ្តាជនរបស់ព្រះមិនត្រូវបាននាំឱ្យវង្វេងទេ

ប៉ុន្តែ រាស្ត្ររបស់ព្រះនឹងមិនត្រូវបាននាំឱ្យវង្វេងឡើយ។ សេចក្តីបង្រៀនរបស់ព្រះគ្រីស្ទក្លែងក្លាយនេះ ពុំស្របតាមបទគម្ពីរទេ។ ពររបស់វា ឱ្យដល់តែពួកអ្នកថ្វាយបង្គំសត្វ និងរូបវាតែប៉ុណ្ណោះគឺជាពួកដែលព្រះគម្ពីរបានចែងថា សេចក្តីក្រោធឥតឈប់ឈររបស់ព្រះនឹងត្រូវបានចាក់ទៅលើ។

យ៉ាងណាមិញ សាតាំងមិនត្រូវបានអនុញ្ញាតឱ្យក្លែងបន្លំពីរបៀបដែលព្រះគ្រីស្ទយាងមកវិញឡើយ។ ព្រះអង្គសង្គ្រោះបានរំឭកដាស់តឿនរាស្ត្ររបស់ព្រះអង្គ ឱ្យប្រយ័ត្នចំពោះការបោកបញ្ឆោតនៅលើចំណុចនេះ។ «ដ្បិតនឹងមានព្រះគ្រីស្ទក្លែង ហើយហោរាក្លែងកើតឡើង គេនឹងធ្វើទីសម្គាល់យ៉ាងធំ ហើយនិងការអស្ចារ្យ ដើម្បីនឹងនាំទាំងពួកអ្នករើសតាំងឱ្យវង្វេងផង បើសិនជាបាន...។ ដូច្នេះ បើគេប្រាប់អ្នករាល់គ្នាថា មើលទ្រង់គង់នៅទីរហោស្ថាន នោះកុំឱ្យចេញទៅឡើយ ឬថាមើលទ្រង់សុគតនៅក្នុងបន្ទប់

នោះ ក៏កុំឱ្យជឿឱ្យសោះ ព្រោះដំណើរដែលកូនមនុស្សមក នោះនឹងបាន ដូចជាផ្លេកបន្ទោរដែលភ្លឺផ្លេកៗ ពីទិសខាងកើតដល់ទិសខាងលិចដែរ»។ ម៉ាថាយ ២៤:២៤។ សូមអានបន្ថែមទៀតនៅម៉ាថាយ ២៥:៣១; វិវរណៈ ១:៧; ថែស្សាឡូនីចទី១ ៤:១៦,១៧។ ដំណើរយ៉ាងមកនេះ ពុំមានវិធីណា នឹងក្លែងបន្លំបានឡើយ។ លោកីយ៍ទាំងមូលនឹងបានឃើញ។

មានតែអ្នករៀនបទគម្ពីរដោយយកចិត្តទុកដាក់ ហើយបានទទួលនូវសេចក្តីស្រឡាញ់នៃសេចក្តីពិតប៉ុណ្ណោះទេ ដែលនឹងត្រូវបានបាំងការពារអំពីសេចក្តីបំភាន់ដ៏ខ្លាំងក្លា ដែលនាំលោកីយ៍ទៅជាឈ្លើយ។ ដោយទីបន្ទាល់នៃបទគម្ពីរ អ្នកទាំងនេះនឹងអាចតាមដានមេឆបោកឱ្យឃើញនូវការបន្លំខ្លួនរបស់វា។ តើរាស្ត្ររបស់ព្រះឥឡូវនេះបានស្ថាបនាមាំមួនលើព្រះបន្ទូលរបស់ផងទ្រង់ហើយឬនៅ ដើម្បីកុំឱ្យគ្រាន់តែឃើញ និងឮ ហើយជឿនោះ? ហើយនៅក្នុងគ្រាអាសន្នដូច្នេះ តើគេនឹងតោងជាប់ព្រះគម្ពីរ ហើយនិងព្រះគម្ពីរតែមួយគត់ឬទេ?

រាស្ត្ររបស់ព្រះនឹងត្រូវភៀសខ្លួន

នៅពេលដែលពួកអ្នកមានអំណាចនៃគ្រីស្ទានសាកលលោក ចេញច្បាប់ប្រឆាំងនឹងពួកអ្នកកាន់ក្រឹត្យវិន័យ ឱ្យរដ្ឋាភិបាលឈប់ការពារ ហើយបោះបង់ពួកគេទៅក្នុងកណ្តាប់ដៃនៃអស់អ្នកចង់ប្រល័យជីវិតគេ នោះរាស្ត្ររបស់ព្រះនឹងនាំគ្នារត់ចេញពីទីក្រុង និងពីភូមិករ ហើយទៅរួមគ្នាជាក្រុមៗ រស់នៅក្នុងទីស្ងាត់ដាច់ស្រយាល។ មានមនុស្សជាច្រើននឹងរកកន្លែងជ្រកកោនក្នុងទីមាំមួននៃរអាងភ្នំដូចពួកគ្រីស្ទាននៅជ្រលងជាយម៉ន់។ (សូមអានជំពូក ៥)។ ប៉ុន្តែ មានមនុស្សជាច្រើនពីគ្រប់ជាតិសាសន៍ គ្រប់វណ្ណៈខ្ពស់ទាបមានក្រ ខ្មៅ និងស នឹងត្រូវបោះចូលទៅក្នុងទាសកម្មដ៏អយុត្តិធម៌ និងឃោរឃៅបំផុត។ អ្នកដ៏ជាទីស្ងួនភ្ងារបស់ព្រះ ឆ្លងកាត់គ្រាដ៏ខ្សោះល្វើយ ត្រូវគេ

ចាប់ដាក់គុក គេកាត់ទោសប្រហារជីវិត ទាំងទុកឱ្យស្លាប់នៅក្នុងគុកងងឹតដ៏សែនខ្ពើមរអើម។

តើព្រះទ្រង់នឹងភ្លេចរាស្ត្ររបស់ព្រះអង្គនៅក្នុងគ្រាលំបាកវេទនានេះឬ? តើព្រះអង្គមានភ្លេចអ្នកស្មោះត្រង់ណាអេ ឡុត យ៉ូសែប អេលីយ៉ា យេរេមា និងដានីយ៉ែលឬទេ? ទោះបីពួកបច្ចាមិត្តអាចបោះពួកគេចូលទៅក្នុងគុកក៏ដោយ ក៏ជញ្ជាំងនៃគុកងងឹតនោះ ពុំអាចកាត់ផ្តាច់ការទាក់ទងរវាងគេ និងព្រះគ្រីស្ទបានឡើយ។ ពួកទេវតានឹងមកឯពួកគេនៅក្នុងរបាំងគុកដ៏ងងឹត។ គុកនឹងបានដូចជារាំងស្តេច ជញ្ជាំងដ៏អាប់អួ នឹងបានបំភ្លឺឡើងដូចកាលគ្រាសាវ័កប៉ុល និងស៊ីឡាស់ បានច្រៀងចម្រៀងនាកណ្តាលអធ្រាត្រនៅក្នុងគុកងងឹតនៃក្រុងភីលីព។

<u>សុក្រ-១៥ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥០

ខព្រះគម្ពីរប្រចាំថ្ងៃ: *អ្នករាល់គ្នាមិនដឹងជានឹងកើតមានយ៉ាងណាដល់ថ្ងៃស្អែកទេ ដ្បិតជីវិតអ្នករាល់គ្នាជាអ្វី គឺជាចំហាយទឹកទេតើ ដែលឃើញតែ១ភ្លែតរួចបាត់ទៅ។ យ៉ាកុប ៤:១៤*

សេចក្តីជំនុំជម្រះនៃព្រះ នឹងធ្លាក់មកលើអស់អ្នកដែលស្វែងរកបំផ្លាញរាស្ត្ររបស់ព្រះអង្គ។ ចំពោះព្រះ ការដាក់ទារុណកម្មគឺជា «ការយ៉ាងប្លែក»។ អេសាយ ២៨:២១; សូមអានអេសេគាល ៣៣:១១។ ព្រះអម្ចាស់ទ្រង់ជាព្រះ «មានព្រះហឫទ័យមេត្តាករុណា ហើយទន់សន្តោស ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្តីសប្បុរស និងសេចក្តីទៀងត្រង់បរិបូរ...ក៏អត់ទោសសេចក្តីទុច្ចរិត សេចក្តីរំលង និងអំពើបាប»។ ប៉ុន្តែ ទ្រង់នឹងមិន «ទុកជាឥតទោសឡើយ»។ និក្ខមនំ ៣៤:៦,៧; ណាហ៊ុម ១:៣។ ចំពោះជាតិសាសន៍ដែលទ្រង់បានទ្រាំទ្រជាយូរមកហើយ ហើយដែលមានសេចក្តីទុច្ចរិតដ៏ពោរ

ពេញនោះ ទីបំផុតនឹងផឹកពែងនៃសេចក្តីក្រោធ ដោយឥតមានលាយជាមួយព្រះគុណ។

នៅពេលដែលព្រះគ្រីស្ទបញ្ឈប់ការងារជាសង្ឃរបស់ព្រះអង្គនៅក្នុងរោងឧបោសថ សេចក្តីក្រោធឥតលាយ សម្រាប់ពួកអ្នកថ្វាយបង្គំសត្វនោះនឹងត្រូវបានចាកចេញមក។ អាសន្នរោគនៅប្រទេសអេស៊ីព្ទ គឺស្រដៀងគ្នានឹងគ្រោះកាចនៃសេចក្តីជំនុំជម្រះដ៏មានទំហំធំធេង ដែលនឹងធ្លាក់មកលើលោកីយ៍ មុនការរំដោះរាស្ត្ររបស់ព្រះជាចុងក្រោយ។ អ្នកបើកសម្តែងថ្លែងថា៖ «មនុស្សដែលមានទីសម្គាល់របស់សត្វ និងអស់ពួកអ្នកដែលក្រាបថ្វាយបង្គំរូបវា គេក៏កើតដំបៅកាចអាក្រក់ណាស់»។ សមុទ្រ «ត្រឡប់ទៅជាឈាមដូចជាឈាមខ្មោច»។ ហើយ «ទន្លេ និងរន្ធទឹកទាំងប៉ុន្មាន ក៏ប្រែទៅជាឈាមទាំងអស់ដែរ»។ វិវរណៈ ១៦:២-៦,៨,៩។ ហើយទេវតាមានបន្ទូលថា៖ «ឱ ព្រះដ៏គង់នៅ...ដែលទ្រង់បានជំនុំជម្រះកាត់ទោសដូច្នេះ នោះសុចរិតហើយ ដ្បិតគេបានកម្ចាយឈាមនៃពួកបរិសុទ្ធ និងពួកហោរា ហើយទ្រង់បានប្រទានឈាមឱ្យគេផឹក គេគួរមានទោសដូច្នេះហើយ»។ ដោយកាត់ទោសរាស្ត្ររបស់ព្រះឱ្យស្លាប់ ពួកគេក៏បានជំពាក់បំណុលឈាម ដូចជាពួកគេបានបង្ហូរឈាមដោយផ្ទាល់ដៃដូច្នោះដែរ។ ព្រះគ្រីស្ទមានបន្ទូលអំពីពួកជូវនៅក្នុងសម័យព្រះអង្គថា គេមានកំហុសចំពោះការបង្ហូរឈាមពួកសុចរិតទាំងអស់ តាំងពីជំនាន់អេបិលរហូតមក (ម៉ាថាយ ២៣:៣៥-៣៦) ដ្បិតពួកគេមានវិញ្ញាណដូចគ្នានឹងពួកឃាតករនៃពួកហោរាទាំងនេះដែរ។

ក្នុងគ្រោះកាចទី២បន្ទាប់នោះ នឹងមានផ្តល់អំណាចដល់ព្រះអាទិត្យ «ឱ្យមនុស្សត្រូវខ្លាចដោយសារភ្លើង»។ វិវរណៈ ១៦:៨,៩។ ពួកហោរាបានថ្លែងអំពីគ្រាដ៏ភិតភ័យនេះថា៖ «ចម្រូតនៅស្រែចម្ការខូចអស់ហើយ...។ អស់ទាំងដើមឈើនៅចម្ការបានស្វិតក្រៀមទៅ៖ អើសេចក្តីអំណរក៏បានរៀវបាត់ពីមនុស្សលោកដែរ»។ «អើហ្ន៎ សត្វទាំងប៉ុន្មានស្រែកយំសិន ហ្វូងគោត្រូវ

ស្រឡាំងកាំង ដ្បិតគ្មានទីគង្វាលរកស៊ីសោះ...។ អស់ទាំងទឹកជ្រោះបានរីងស្ងួតទៅ ភ្លើងក៏បានឆេះវាលស្មៅនៅទីរហោស្ថានអស់ហើយ»។ យ៉ូអែល ១:១១,១២,១៨-២០។

គ្រោះកាចទាំងនេះ មិនកើតឡើងទូទាំងសាកលលោកទេ ប៉ុន្តែ វានឹងជាដំបៅដ៏ឈឺចាប់បំផុតដែលមនុស្សមិនធ្លាប់ប្រទះ។ សេចក្តីជំនុំជម្រះទាំងអស់នៅមុនកំណត់ពេលវេលាទុកឱ្យប្រែចិត្តមានលាយជាមួយសេចក្តីមេត្តាករុណា។ លោហិតរបស់ព្រះគ្រីស្ទបានគ្របបាំងបាបជន អំពីសេចក្តីខុសដ៏ពោរពេញរបស់ខ្លួន ប៉ុន្តែនៅគ្រាជំនុំជម្រះចុងក្រោយបង្អស់ សេចក្តីក្រោធពុំមានលាយជាមួយសេចក្តីមេត្តាករុណាឡើយ។ ហ្វូងមនុស្សនឹងប្រាថ្នាចង់បាននូវជម្រកនៃសេចក្តីមេត្តាករុណារបស់ព្រះដែលគេធ្លាប់បានស្អប់ខ្ពើម។

<u>សៅរ៍-១៦ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥១

ខព្រះគម្ពីរប្រចាំសប្តាហ៍: *បងប្អូនអើយ ចូរមានចិត្តអត់ធ្មត់ ដរាបដល់ព្រះអម្ចាស់ទ្រង់យាងមក មើល អ្នកធ្វើស្រែគេរង់ចាំផងវិសេស ដែលកើតពីដីមក ដោយសេចក្តីអត់ធ្មត់ ទាល់តែបានភ្លៀងធ្លាក់មកខាងដើមរដូវ និងចុងរដូវផង។ យ៉ាកុប ៥:៧*

នៅពេលគេកំពុងធ្វើទុក្ខទោស ហើយមានទុក្ខព្រួយជាទម្ងន់ នៅពេលគេស្រេកឃ្លានព្រោះខ្វះអាហារ ព្រះពុំបានទុកចោលឱ្យបណ្តាជនព្រះអង្គត្រូវវិនាសឡើយ។ ពួកទេវតានឹងផ្គត់ផ្គង់នូវសេចក្តីត្រូវការ។ «អាហារនឹងបានប្រទានមកអ្នកនោះ ហើយទឹករបស់អ្នកនោះនឹងចេះតែមាននៅ»។ «អញនឹងតបឆ្លើយដល់គេ អញនេះ គឺជាព្រះនៃសាសន៍អ៊ីស្រាអែល អញនឹងមិនបោះបង់ចោលគេឡើយ»។ អេសាយ ៣៣:១៦; ៤១:១៧។

ក៏ប៉ុន្តែ នៅចំពោះភ្នែកមនុស្សនឹងឃើញថាក្នុងពេលបន្តិចទៀតរាស្ត្រ

របស់ព្រះត្រូវតែបោះត្រាទីបន្ទាល់ដោយឈាមរបស់ខ្លួន ដូចជាពួកប្តូរផ្តាច់បានធ្វើកាលពីដើមដូច្នោះដែរ។ ជាគ្រាឈឺចាប់ដ៏ភ័យខ្លាច។ ពួកអាក្រក់សម្តែងការអរសប្បាយ «ឯណាជំនឿរបស់ឯងឥឡូវនេះ? ហេតុអ្វីបានជាព្រះមិនរំដោះឯងចេញពីកណ្តាប់ដៃយើងទៅ បើឯងជាបណ្តាជនរបស់ទ្រង់មែននោះ?» ប៉ុន្តែ ពួកអ្នករង់ចាំបាននឹកឃើញអំពីព្រះយេស៊ូវនៅលើឈើឆ្កាងនាកាល់វ៉ារី។ ដូចជាយ៉ាកុបយ៉ាងនោះដែរ គេទាំងអស់គ្នាកំពុងតែកាច់ចំបាប់ជាមួយព្រះ។

ពួកទេវតាចាំយាម

ពួកទេវតាសំកាំងនៅពីលើអស់អ្នកដែលបានរក្សាព្រះបន្ទូលរបស់ព្រះគ្រីស្ទដែលថាឱ្យស៊ូទ្រាំដោយអត់ធ្មត់។ ពួកលោកបានឃើញផ្ទាល់នូវសេចក្តីទុក្ខព្រួយរបស់ពួកគេ ហើយក៏បានឮពាក្យអធិស្ឋានរបស់គេដែរ។ លោករង់ចាំទទួលបញ្ជាឱ្យឆក់ពួកគេចេញអំពីគ្រោះវេទនាប៉ុណ្ណោះ។ ប៉ុន្តែ ត្រូវរង់ចាំយូរបន្តិចសិន។ រាស្ត្ររបស់ព្រះត្រូវធឹកអំពីពែង ហើយនិងត្រូវឆ្លងកាត់សេចក្តីពិសោធនេះ។ ម៉ាថាយ ២០:២០-២៣។ ដោយព្រោះឈ្មោះអ្នកវីរសតាំង គ្រាវេទនានឹងត្រូវបានបំព្រួញវិញ។ ទីបំផុតនឹងមកដល់ ឆាប់ជាងមនុស្សបានគិតទៅទៀត។

ទោះបីបទបញ្ជាជាទូទៅ បានកំណត់ពេលវេលាឱ្យសម្លាប់ពួកអ្នករក្សាក្រឹត្យវិន័យក៏ដោយក៏មានពួកបច្ចាមិត្តខ្លះ បានឆ្លៀតឱ្នះខ្នែងយកជីវិតពួកគេ មុនពេលចេញបទបញ្ជាទៅទៀត។ ប៉ុន្តែ ពុំមាននរណាម្នាក់អាចឆ្លងកាត់អ្នកយាមដែលសំកាំងនៅជុំវិញរាល់ព្រលឹងស្មោះត្រង់បានឡើយ។ ខ្លះបានខំប្រឹងរត់គេចចេញពីទីក្រុង ប៉ុន្តែ ដាវដែលបានលើកកាប់ពួកគេ បានបាក់ដូចជាចំបើងដូច្នោះ។ អ្នកខ្លះទៀតត្រូវបានការពារដោយពួកទេវតានៅក្នុងទម្រង់ជាអ្នកធ្វើសង្គ្រាម។

ជារៀងរាល់យុគសម័យ ពួកទេវបុត្រនៃស្ថានសួគ៌តែងតែរួមចំណែកយ៉ាងសកម្មនៅក្នុងកិច្ចការរបស់មនុស្ស។ ពួកលោកបានទទួលសេចក្តីរាក់ទាក់នៃគេហដ្ឋានរបស់មនុស្សជាតិ ទាំងបានធ្វើជាអ្នកនាំផ្លូវដល់អ្នកដំណើរ បើកទ្វារគុក និងដោះលែងអ្នកដំណើររបស់ព្រះ។ ពួកលោកបានមកប្រមៀលថ្មចេញអំពីផ្នូររបស់ព្រះអង្គសង្គ្រោះផងដែរ។

ពួកទេវតាបានមកមើលក្រុមមនុស្សអាក្រក់នៅឯក្រុងសូដុំម ដើម្បីសម្រេចឱ្យដឹងថា តើពួកគេបានឆ្លងហួសព្រំដែននៃសេចក្តីទ្រាំទ្ររបស់ព្រះទៅហើយឬយ៉ាងណា។ ដោយព្រោះតែមានអ្នកបម្រើស្មោះត្រង់របស់ព្រះអង្គមួយក្រុមតូច ព្រះជាម្ចាស់បានទប់មហន្តរាយ ហើយនិងពន្យារឱ្យហ្វូងមនុស្សរស់នៅដោយសុខដុមរមនា។ តែពួកបាបជនមិនដឹងខ្លួនសោះថា ខ្លួនបានជំពាក់បំណុលជីវិតដល់ក្រុមតូចដ៏ស្មោះត្រង់ ដែលខ្លួនសប្បាយនឹងជិះជាន់។

<u>អាទិត្យ-១៧ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥២

ខព្រះគម្ពីរប្រចាំថ្ងៃ:*ចូរឲ្យអ្នករាល់គ្នាអត់ធ្មត់ដូច្នោះដែរ ទាំងតាំងចិត្តឲ្យខ្ជាប់ខ្ជួនឡើង ដ្បិតព្រះអម្ចាស់ជិតយាងមកហើយ។ យ៉ាកុប ៥:៨*

ជារឿយៗនៅក្នុងក្រុមប្រឹក្សានៃលោកីយ៍នេះ ពួកទេវតាតែងតែបានមកធ្វើជាអ្នកនាំមុខនិយាយជំនួស (វាគ្មិន)។ ត្រចៀកមនុស្សជាតិបានស្តាប់ពាក្យអង្វរករបស់លោក បបូរមាត់មនុស្សជាតិបានចំអកមើលងាយដល់ ឱវាទរបស់លោក។ អ្នកនាំសារនៃស្ថានសួគ៌ទាំងនេះបានបញ្ជាក់ឱ្យឃើញ ថា ពួកលោកមានសមត្ថភាពអាចតវ៉ាឱ្យពួកអ្នកដែលត្រូវគេគាបសង្កត់ បានប្រសើរជាងស្មាក្តីដ៏ពូកែសម្តីបំផុតទៀតផង។ លោកបានផ្ចាញ់ផ្ចាល ហើយនិងចាប់ចងពួកមេកំណាចដែលអាចបណ្តាល

ឱ្យមានការឈឺចាប់ដ៏ខ្លាំងដល់រាស្ត្ររបស់ព្រះ។

រាស្ត្ររបស់ព្រះបានរង់ចាំទាំងចិត្តអន្ទះសា ដល់សញ្ញានៃស្តេចរបស់ខ្លួនដែលនឹងយាងមក។ នៅពេលអ្នកកាច់ចំបាប់ដាក់សំណូមពររបស់ខ្លួននៅចំពោះព្រះ ផ្ទៃមេឃក៏ភ្លឺព្រោងព្រាតដោយរស្មីភ្លឺព្រាងៗនៃអនន្តភាព ពាក្យពេចន៍ក៏ធ្លាក់មកដល់ត្រចៀកឮស្ងរពីរោះដូចបទចម្រៀងទេវតាថា៖ «ជំនួយមកដល់ហើយ»។ ព្រះសូរសៀងព្រះគ្រីស្ទក៏បន្លឺចេញមកអំពីមាត់ទ្វារថា៖ «មើល ខ្ញុំបានមកនៅជាមួយអ្នករាល់គ្នាហើយ កុំខ្លាចអ្វីឡើយ។ ខ្ញុំបានច្បាំងសង្គ្រាមជំនួសអ្នករាល់គ្នា ហើយដោយនូវឈ្មោះខ្ញុំ អ្នករាល់គ្នាបានលើសជាងអ្នកឈ្នះទៅទៀត»។

ព្រះអង្គសង្គ្រោះដ៏វិសេសវិសាល នឹងបញ្ជូនជំនួយមកចំពេលដែលយើងត្រូវការ។ គ្រាវេទនាជាការដកពិសោធដ៏គួរភ័យរន្ធត់មួយសម្រាប់រាស្ត្ររបស់ព្រះ ប៉ុន្តែ គ្រប់ទាំងអ្នកជឿពិតប្រាកដនឹងអាចឃើញដោយជំនឿនូវឥន្ធនូនៃសេចក្តីសន្យាដែលព័ទ្ធជុំវិញខ្លួន។ «ឯពួកអ្នកប្រោសលោះរបស់ព្រះយេហូវ៉ា គេនឹងវិលមកវិញ ហើយមកដល់ក្រុងស៊ីយ៉ូនដោយច្រៀងចម្រៀង គេនឹងមានសេចក្តីអំណរដ៏នៅអស់កល្បជានិច្ចពាក់លើក្បាល គេនឹងទទួល បានសេចក្តីរីករាយ និងសេចក្តីអំណរ ឯសេចក្តីទុក្ខព្រួយ និងដំងូរនោះនឹង ខ្ចាត់បាត់ទៅ»។ អេសាយ ៥១:១១។

ប្រសិនបើឈាមរបស់ស្មរបន្ទាល់ព្រះគ្រីស្ទត្រូវខ្ចាយនៅពេលនេះ នោះភក្តីភាពរបស់គេនឹងមិនបានជាទីបន្ទាល់ធ្វើឱ្យអ្នកឯទៀតបានជឿដល់សេចក្តីពិតឡើយ ដ្បិតអ្នកមានចិត្តរឹងរូសបានវាយជម្នះរលកនៃសេចក្តីមេត្តាករុណា ទាល់តែលែងត្រឡប់មកវិញ។ ប្រសិនបើពួកសុចរិតបានធ្លាក់ទៅជាចំណីរបស់ពួកសត្រូវរបស់ខ្លួននៅពេលនេះ នោះនឹងបានជាជ័យជម្នះដល់ស្តេចនៃសេចក្តីងងឹតហើយ។ ព្រះគ្រីស្ទមានបន្ទូលថា៖ «ចូរមក ជនជាតិខ្ញុំអើយ ចូរឱ្យចូលទៅក្នុងបន្ទប់ខ្លួនហើយបិទទ្វារចុះ៖ ត្រូវឱ្យពួនខ្លួន

បន្តិចសិន ទាល់តែសេចក្តីក្រោធបានកន្លងហួសទៅ។ ដ្បិតមើលព្រះយេហូវ៉ា
ទ្រង់យាងចេញពីស្ថានរបស់ទ្រង់មក ដើម្បីនឹងសម្រេចទោសដល់មនុស្ស
នៅលើផែនដីដោយព្រោះអំពើទុច្ចរិតរបស់គេ»។ អេសាយ ២៦:២០,២១។

ការរំដោះអស់អ្នកដែលបានរង់ចាំនូវដំណើរយាងមករបស់ព្រះអង្គ
ដោយអត់ធ្មត់ ហើយដែលមានឈ្មោះកត់ទុកនៅក្នុងបញ្ជីជីវិត នឹងប្រកប
ដោយសេចក្តីរុងរឿងពេកក្រៃ។

ដែនដីស្ថិតនៅក្នុងភាពអន្តរាយ

<u>ចន្ទ-១៨ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥៣
ខព្រះគម្ពីរប្រចាំថ្ងៃ:*ដូច្នេះ ចូរឲ្យអ្នករាល់គ្នាលន់តួទោសនឹងគ្នា ហើយអធិស្ឋានឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យបានជាចុះ ដ្បិតសេចក្ដីទូលអង្វរដ៏អស់ពីចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់។ យ៉ាកុប ៥:១៦*

នៅពេលច្បាប់របស់មនុស្ស លែងការពារដល់អ្នកដែលគោរពក្រឹត្យវិន័យរបស់ព្រះហើយនោះនឹងមានចលនាកើតឡើងព្រមៗគ្នាក្នុងទឹកដីផ្សេងៗទៀត ដើម្បីកម្ទេចពួកគេ។ នៅគ្រាដែលពេលកំណត់នៃថ្ងៃអាទិត្យខិតជិតឡើង ពួកបណ្តាជននឹងជំនុំគ្នាដើម្បីវាយកម្ទេចក្នុងមួយយប់ដែលនឹងបំបាត់សេចក្តីមានជំនឿខុសគ្នា និងសេចក្តីបន្ទោស។

រាស្ត្ររបស់ព្រះ ខ្លះនៅក្នុងគុក ខ្លះក្នុងព្រៃភ្នំ អង្វរករសូមឱ្យទ្រង់ការពារ។ ពួកមនុស្សប្រដាប់ដោយអាវុធ ដែលត្រូវបានបន្តុំដោយពួកទេវតាអាក្រក់ កំពុងតែរៀបចំខ្លួនធ្វើមរណកិច្ច។ ក្នុងពេលវេលាដ៏ស្លាប់រស់នេះ ព្រះនឹងចូលមកការពារ៖ «នោះឯងរាល់គ្នានឹងច្រៀងចម្រៀង ដូចនៅពេលណាដែលធ្វើបុណ្យរំលង ហើយនិងមានសេចក្ដីរីករាយក្នុងចិត្ត ដូចជាវេលាដែល ...ទៅឯព្រះដែលជាថ្មដានៃសាសន៍អ៊ីស្រាអែល។ ឯព្រះយេហូវ៉ា នឹងបន្លឺព្រះសូរសៀងដ៏រុងរឿងឧត្តមរបស់ទ្រង់ឱ្យឮ ហើយនិងបង្ហាញព្រះពាហុដែលធ្វើទោស ដោយសេចក្ដីគ្នាន់ក្នាញ់របស់សេចក្ដីក្រោធទ្រង់ និងអណ្តាតភ្លើងដ៏ឆេះបន្សុស ព្រមទាំងសន្ទុះខ្យល់ព្យុះសង្ឃរា និងដុំព្រឹលផង»។ អេសាយ ៣០:២៩,៣០។

ពួកមនុស្សអាក្រក់ ហៀបតែនឹងសម្រុកមករកចំណីរបស់ខ្លួន ស្រាប់តែមានភាពងងឹតយ៉ាងខ្លាំង ដែលខ្មៅជាងភាពងងឹតនៃរាត្រីកាលទៅទៀត ធ្លាក់មកគ្របដណ្តប់លើផែនដី។ បន្ទាប់មកឥន្ធនូលាតត្រដាងកាត់មេឃ ហើយហាក់បីដូចជាព័ទ្ធជុំវិញក្រុមជំនុំនីមួយៗដែលកំពុងអធិស្ឋាន។ ពួកមនុស្សឆេះឆួលក៏ស្រឡាំងកាំង។ គេក៏បានភ្លេចពីកំហឹងរបស់ខ្លួន ហើយសម្លឹងមើលទៅហើយឃើញសិរីល្អរបស់ព្រះ និងកូនមនុស្សនៅលើព្រះរាជបល្ល័ង្ក។ សូមអាន កិច្ចការ ៧:៥៥,៥៦។ គេបានយល់ពីទីសម្គាល់នៃសេចក្តីអាម៉ាស់មុខរបស់ទ្រង់ ហើយឮពាក្យទូលសូមផងៈ «ទូលបង្គំចង់ឱ្យគេនៅជាមួយនឹងទូលបង្គំ ក្នុងកន្លែងដែលទូលបង្គំនៅដែរ»។ យ៉ូហាន ១៧:២៤។ មានឮសំឡេងបន្លឺឡើងថាៈ «ពួកគេមកទាំងបរិសុទ្ធ មិនកាចសាហាវ ហើយមិនប្រឡាក់ផង ពួកគេបានរក្សាបន្ទូលនៃសេចក្តីអត់ធ្មត់របស់អញ!»

ក្នុងកណ្តាលអន្ទាត្រ ព្រះសម្តែងព្រះមហិទ្ធិឫទ្ធិរបស់ទ្រង់ ដើម្បីរំដោះរាស្ត្រទ្រង់។ ព្រះអាទិត្យលេចមកទាំងបញ្ចេញរស្មីដ៏ពេញទំហឹង។ សញ្ញា និងការអស្ចារ្យទាំងឡាយទៀតក៏កើតឡើងតាមលំដាប់។ មនុស្សទុច្ចរិត មើលទៅទស្សនីយភាពនេះដោយភ័យរន្ធត់ ឯពួកអ្នកសុចរិតគេមើលទៅឯសក្ខីភាពនៃការរំដោះរបស់គេវិញ។ ក្នុងកណ្តាលអាកាសវេហាដ៏ក្រៃក្រោធមានឮព្រះសូរសៀងរបស់ព្រះបន្លឺចេញពីទីលំហាមួយដែលមានសេចក្តីរុងរឿងរកពិពណ៌នាពុំបាន ឮសូរដូចជាទឹកធ្លាក់យ៉ាងខ្លាំងថាៈ រួចរាល់ហើយ។ វិវរណៈ ១៦:១៧។

ព្រះសូរសៀងនោះ រំជួយផ្ទៃមេឃ និងផែនដី។ មានការរញ្ជួយផែនដីដ៏ខ្លាំងមួយ «ដល់ម្ល៉េះបានជាតាំងពីមានមនុស្សនៅផែនដីរៀងមក នោះមិនដែលមានកក្រើកដីយ៉ាងខ្លាំង ហើយសម្បើមដូច្នោះឡើយ»។ វិវរណៈ ១៦:១៨។ កម្ទេចថ្ម បែកខ្ចាត់ខ្ចាយគ្រប់ជ្រុង។ សមុទ្រក៏បោកយ៉ាងខ្លាំង។ មានឮសន្ធឹកព្យុះសង្ឃរា ដូចជាសំឡេងព្រាយបិសាច។ ស្រទាប់ផែនដីកក្រើកញែកចេញពីគ្នា។ គ្រឹះរបស់វាទ្រាំទ្រទៀតលែងបាន។ ទឹក

កំណាច បានលេបកំពង់ផែដែលបានក្លាយដូចជាក្រុងសូដុំម ដោយព្រោះតែអំពើទុច្ចរិត។ ព្រះបាននឹកចាំពី «បាប៊ីឡូនដ៏ជាធំ ដើម្បីនឹងឱ្យពែងស្រារបស់សេចក្ដីឃោរឃៅផងសេចក្ដីខ្ញាល់ទ្រង់ដល់គេ»។ វិវរណៈ ១៦:១៩។ ដុំព្រឹលដ៏ធំមហិមាធ្វើការបំផ្លិចបំផ្លាញ។ ទីក្រុងខ្ពស់ៗទាំងឡាយរលំរាបធេង។ វិមានស្តុកស្តម្ភទាំងឡាយដែលពួកមនុស្សបានចំណាយទ្រព្យសម្បត្តិរបស់ខ្លួនទៅលើនោះ រលំធ្លាក់នៅនឹងមុខគេ។ ជញ្ជាំងគុកបែកបាក់ខ្ចាត់ខ្ចាយទៅជាបំណែក ហើយរាស្ត្ររបស់ព្រះបានរួចពីគុក។

<u>អង្គារ-១៩ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥៤

ខព្រះគម្ពីរប្រចាំថ្ងៃ:*នោះត្រូវដឹងថា អ្នកណាដែលនាំមនុស្សបាប ឲ្យត្រឡប់ពីផ្លូវវង្វេងមកវិញ នោះឈ្មោះថា បានជួយសង្គ្រោះព្រលឹង១ ឲ្យរួចពីសេចក្ដីស្លាប់ ហើយក៏គ្របបាំងអំពើបាបជាអនេកអនន្តផង។ យ៉ាកុប ៥:២០*

ផ្នូរទាំងឡាយបើកឡើង «ហើយពួកអ្នកដែលដេកលក់នៅក្នុងធូលីដី ...ភ្ញាក់ឡើងវិញ...ខ្លះឱ្យបានជីវិតរស់នៅអស់កល្បជានិច្ច និងខ្លះឱ្យបានសេចក្ដីអាម៉ាស់ខ្មាស ហើយឱ្យបានជាទីខ្ពើមឆ្អើមនៅអស់កល្បជានិច្ចវិញ»។ ពួកអ្នកដែលបានចាក់ព្រះគ្រីស្ទ អ្នកដែលបានចំអកដល់ការឈឺចុកចាប់ដល់ទីមរណារបស់ទ្រង់ និងអ្នកដែលប្រឆាំងដ៏ហិង្សាដល់សេចក្ដីពិតរបស់ទ្រង់ បានរស់ឡើងវិញ ឱ្យបានឃើញកិត្តិយសដែលបានប្រទានដល់អ្នកស្មោះត្រង់ និងអ្នកស្តាប់ឱវាទ។ ដានីយ៉ែល ១២:២; វិវរណៈ ១:៧។

រន្ធះដ៏សាហាវ គ្របដណ្តប់ផែនដីក្នុងស្រទាប់នៃអណ្តាតភ្លើង។ មានសំឡេងឮខ្លាំងជាងផ្គរលាន់ ហើយអស្ចារ្យជាទីបំផុត ថ្លែងប្រាប់ពីសេចក្ដីវិនាសសាបសូន្យនៃមនុស្សទុច្ចរិត។ អ្នកដែលមានអំនួត និងរឹងចចេស ថែមទាំងឃោរឃៅដល់រាស្ត្រដែលរក្សាក្រឹត្យវិន័យរបស់ព្រះនោះ ឥឡូវនេះញាប់ញ័រដោយសេចក្ដីភ័យខ្លាច។ អារក្សបិសាចទាំងឡាយញ័ររន្ធត់ជាខ្លាំង ក្នុង

ពេលដែលមនុស្សកំពុងទូលអង្វរសូមសេចក្តីមេត្តាករុណា។

ថ្ងៃនៃព្រះយេហូវ៉ា

ហោរាអេសាយបានមានប្រសាសន៍ថា៖ «នៅគ្រានោះ មនុស្សនឹងបោះចោលរូបព្រះរបស់ខ្លួន ដែលធ្វើពីមាសហើយពីប្រាក់ ជារបស់ដែលគេបានធ្វើសម្រាប់នឹងថ្វាយបង្គំ ទៅឱ្យកណ្តុរ ហើយនិងប្រចៀវ ដើម្បីនឹងចូលទៅក្នុងរអាងថ្ម ហើយក្នុងក្រហែងថ្មរខិញរខុញ ឱ្យបានរួចពីសេចក្តីស្ញែងខ្លាចនៃព្រះយេហូវ៉ា និងសិរីល្អនៃឫទ្ធានុភាពរបស់ទ្រង់ ក្នុងកាលដែលទ្រង់ក្រោកឡើងនឹងអង្រួនផែនដី ដោយឫទ្ធិយ៉ាងអស្ចារ្យ»។ អេសាយ ២:២០,២១។

អ្នកដែលបានលះបង់ទាំងអស់សម្រាប់ព្រះគ្រីស្ទ ឥឡូវនេះបានផុតពីគ្រោះភិតភ័យហើយ។ គេបានបង្ហាញយ៉ាងច្បាស់នូវភក្តីភាព ដល់ព្រះទ្រង់ដែលបានសុគតជួសគេ ដល់ពិភពលោក ហើយនិងក្នុងកាលប្រឈមមុខនឹងសេចក្តីស្លាប់។ ទឹកមុខដ៏សស្លាំងហើយស្រពោននោះ ឥឡូវត្រូវបានរីកស្រស់បំព្រង ទាំងមានអំណរយ៉ាងអស្ចារ្យ។ សំឡេងរបស់គេបានស្រែកឡើងក្នុងចម្រៀងជ័យឃោសថា៖ «ព្រះទ្រង់ជាទីពឹងជ្រក ក៏ជាកម្លាំងនៃយើងខ្ញុំជាជំនួយដែលនៅជាប់ជាមួយក្នុងគ្រាអាសន្ន ហេតុនោះយើងខ្ញុំនឹងមិនខ្លាចឡើយ ទោះបើផែនដីប្រែប្រួលទៅ ហើយភ្នំទាំងប៉ុន្មានត្រូវរើធ្លាក់ចុះនៅកណ្តាលសមុទ្រក៏ដោយ។ ទោះបើទឹកសមុទ្របញ្ចេញសូរគឹកកង ហើយរំជួលឡើង ឬភ្នំទាំងឡាយត្រូវកក្រើកញ័រ ដោយរលកលោតចុះឡើងក្តី»។ ទំនុកតំកើង ៤៦:១-៣។

ក្នុងពេលដែលសូរសៀងនៃទំនុកបរិសុទ្ធនេះបានឮឡើងទៅដល់ព្រះ សិរីល្អនៃនគរស្ថានសួគ៌ ក៏ជះចេញពីទ្វារដែលបានបើករួចមកហើយនោះ។ បន្ទាប់មក នៅលើមេឃ មានដៃមួយកាន់បន្ទះថ្មពីរផ្ទាំង។ ក្រឹត្យវិន័យបរិសុទ្ធ ដែលបានប្រកាសនៅភ្នំស៊ីណាយ ឥឡូវបានបើកសម្តែង ជាខ្លាតនៃការជំនុំជម្រះ។ ពាក្យទាំងឡាយងាយស្រួលអាន ហើយពួកគេទាំងអស់គ្នាអាចអានបាន។ ការចងចាំក៏បានភ្ញាក់រលឹកឡើង។ ភាពងងឹតនៃជំនឿអកុសល

និងជំនឿខុសឆ្គងបានរសាត់ពីគំនិតគេគ្រប់ៗគ្នា។

សេចក្តីរន្ធត់ និងសេចក្តីអស់សង្ឃឹមនៃអ្នកដែលបានជាន់ឈ្លីក្រឹត្យវិន័យរបស់ព្រះ គឺរកពិពណ៌នាពុំបានសោះឡើយ។ ដើម្បីផ្គាប់ចិត្តលោកីយ៍ ពួកគេបានបំភ្លេចសិក្ខាបទនៃក្រឹត្យវិន័យ ហើយបង្រៀនអ្នកដទៃឱ្យប្រព្រឹត្តរំលងដែរ។ ឥឡូវនេះ ក្រឹត្យវិន័យដែលគេបានស្អប់ខ្ពើម ត្រូវកាត់ទោសគេវិញ។ គេបានដឹងហើយថា គេមិនអាចដោះសាបានឡើយ។ ពួកសត្រូវនៃក្រឹត្យវិន័យរបស់ព្រះ មានការយល់ដឹងថ្មីអំពីសេចក្តីពិត និងអ្វីដែលត្រូវធ្វើ។ គឺយឺតពេលហើយ នៅពេលគេដឹងថាថ្ងៃឈប់សម្រាកជាគ្រារបស់ព្រះដ៏រស់នៅនោះ។ យឺតពេលហើយ នៅពេលគេឃើញគ្រឹះដែលបានសង់ពីលើនោះជាខ្សាច់។ គេបានជម្នះទទឹងនឹងព្រះ។ គ្រូសាសនាទាំងឡាយបាននាំមនុស្សឱ្យធ្លាក់នរក ក្នុងពេលដែលគេអះអាងថា គេកំពុងដឹកនាំកូនចៀមរបស់ខ្លួនចូលទៅស្ថានបរមសុខ។ ឱ ទំនួលខុសត្រូវនៃមនុស្សក្នុងតំណែងដ៏បរិសុទ្ធនោះធំណាស់ន៎! លទ្ធផលនៃភាពមិនស្មោះត្រង់របស់គេគឺអាក្រក់អ្វីម្ល៉េះ!

<u>ពុធ-២០ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥៥

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដូច្នេះ ចូរក្រវាត់គំនិតអ្នករាល់គ្នាឲ្យមាំមួនចុះ ទាំងដឹងខ្លួន ហើយឲ្យមានសេចក្តីសង្ឃឹមគ្រប់ជំពូក ដល់ព្រះគុណដែលត្រូវផ្តល់មកដល់អ្នករាល់គ្នា ក្នុងកាលដែលព្រះយេស៊ូវគ្រីស្ទទ្រង់លេចមកផង។ ពេត្រុសទី១ ១:១៣*

ស្តេចលើអស់ទាំងស្តេចលេចមក

ព្រះសូរសៀងរបស់ព្រះ ថ្លែងពីពេលវេលានៃការយាងមករបស់ព្រះគ្រីស្ទ ក៏បានឮឡើង។ សាសន៍អ៊ីស្រាអែលរបស់ព្រះកំពុងឈរស្តាប់ ទឹកមុខរបស់គេមានរស្មីភ្លឺថ្លាដោយសិរីល្អរបស់ទ្រង់។ ក្រោយមក ដុំពពកខ្មៅតូច

មួយលេចឡើងនៅឯទិសខាងកើត។ ជាពពកដែលហ៊ឹមព័ទ្ធព្រះអង្គសង្គ្រោះ។ ពេលពពករសាត់កាន់តែជិតមកដល់ហើយ រាស្ត្ររបស់ព្រះក៏សម្លឹងមើលក្នុងភាពស្ងប់ស្ងាត់ជាទីបំផុត រហូតដល់ពពកនោះធំហើយសស្គុស មានបាតជាសេចក្តីរុងរឿងដូចជាភ្លើងដ៏សន្ធោសន្ធៅ ហើយនៅពីលើមានឥន្ទធនូនៃសេចក្តីសញ្ញាផង។ ឥឡូវទ្រង់ពុំមែនជា «មនុស្សទូទុក្ខ» ទៀតទេ ព្រះយេស៊ូវយាងមកដូចជាមេទ័ពដ៏ខ្លាំងពូកែ។ ពួកទេវតាបរិសុទ្ធដែលមានចំនួនដ៏ច្រើនរាប់មិនអស់ ហៃហាមទ្រង់ «មានទាំងពាន់ៗ...ហើយទាំងម៉ឺនទាំងសែន» ផង។ គ្រប់ទាំងភ្នែកសម្លឹងមើលស្តេចនៃជីវិត។ មានមកុដនៃសិរីល្អនៅលើព្រះកេសទ្រង់។ ព្រះភ័ក្ត្ររបស់ទ្រង់ភ្លឺជាងរស្មីនៃព្រះអាទិត្យនាកណ្តាលថ្ងៃត្រង់ទៅទៀត។ ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ និងព្រះឩរូទ្រង់ថា ស្តេចលើអស់ទាំងស្តេច **ព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់**។ វិវរណៈ ១៩:១៦។

ស្តេចលើអស់ទាំងស្តេច ចុះមកពីពពក ហ៊ឹមព័ទ្ធដោយអណ្តាតភ្លើង។ ផែនដីញាប់ញ័រនៅចំពោះទ្រង់៖ «ព្រះនៃយើងទ្រង់យាងមក ហើយមិននៅស្ងៀមទេ មានភ្លើងឆេះនៅចំពោះទ្រង់ ហើយនៅព័ទ្ធជុំវិញទ្រង់មានព្យុះសង្ឃរា។ ទ្រង់បង្គាប់ដល់ស្ថានសួគ៌នៅខាងលើ និងដល់ផែនដី ដើម្បីជំនុំជម្រះរាស្ត្ររបស់ទ្រង់»។ ទំនុកតំកើង ៥០:៣,៤។

«អស់ទាំងស្តេចនៅផែនដី និងពួកអ្នកធំ ពួកអ្នកមាន ពួកមេទ័ព ពួកខ្លាំងពូកែ ហើយគ្រប់ទាំងបាវបម្រើ និងអ្នកជាទាំងប៉ុន្មាន គេពួននៅក្នុងរអាង ហើយក្នុងក្រហែងភ្នំទាំងអស់គ្នា។ គេអង្វរទៅភ្នំ ហើយទៅថ្មថា សូមធ្លាក់មកលើយើង ដើម្បីបំបាំងយើងពីព្រះភ័ក្ត្រព្រះអង្គ ដែលគង់នៅលើបល្ល័ង្ក និងពីសេចក្តីក្រោធរបស់កូនចៀមចេញ។ ដ្បិតថ្ងៃនៃសេចក្តីក្រោធរបស់ទ្រង់បានមកដល់ហើយ តើអ្នកណាអាចនឹងឈរនៅបាន?» វិវរណៈ ៦:១៥-១៧។

ពាក្យចំអកឡកឡឺយលែងមានតទៅទៀត ហើយអណ្តាតនិយាយកុហកក៏បានស្ងាត់ស្ងៀម។ ក្រៅពីសំឡេងអធិស្ឋាន និងសំឡេងទ្រហោយំគ្មានឮសំឡេងអ្វីទៀតសោះ។ មនុស្សទុច្ចរិតបន់ឱ្យគេបង្កប់ខ្លួនក្រោមថ្ម ជា

ជាងជួបព្រះភ័ក្ត្ររបស់ព្រះដែលគេបានស្អប់។ គេស្គាល់សំឡេងដែលដាស់មនុស្សស្លាប់។ តើសំឡេងដ៏ស្រទន់នោះ បានហៅគេប៉ុន្មានដងហើយឱ្យប្រែចិត្ត?។ តើបានឮការអង្វរករបស់មិត្តភក្តិ បងប្អូន និងព្រះដ៏ប្រោសលោះប៉ុន្មានដងហើយ?។ សំឡេងនោះធ្វើឱ្យគេនឹកចាំពីកាលដែលគេបានស្អប់ខ្ពើមដល់សេចក្តីព្រមាន និងពីកាលដែលគេបានបដិសេធសេចក្តីអញ្ជើញ។

មានអ្នកដែលចំអកឱ្យព្រះគ្រីស្ទ ក្នុងសេចក្តីអាម៉ាស់របស់ទ្រង់។ ទ្រង់បានមានបន្ទូលថា៖ «អំណឹះតទៅមុខ អ្នករាល់គ្នានឹងឃើញកូនមនុស្សអង្គុយនៅខាងស្តាំនៃព្រះដ៏មានព្រះចេស្តា ហើយទាំងមកនៅលើពពកនៅលើមេឃផង»។ ម៉ាថាយ ២៦:៦៤។ ឥឡូវនេះ គេមើលទ្រង់ក្នុងសេចក្តីរុងរឿងរបស់ទ្រង់ គេមិនទាន់ឃើញទ្រង់ប្រថាប់នៅខាងស្តាំដៃនៃព្រះដ៏មានព្រះចេស្តានៅឡើយទេ។ មានស្តេចហេរ៉ូឌដ៏ក្រអឺតក្រអាង ដែលចំអកឱ្យព្រះនាមរបស់ទ្រង់។ មានមនុស្សដែលដាក់មកុដបន្លានៅលើព្រះកេសទ្រង់ និងទឹកខ្មេះនៅលើព្រះហស្តទ្រង់ ទាំងស្តោះលើស្តេចនៃជីវិតផង ជាអ្នកដែលឱនគោរពទ្រង់ក្នុងការចំអកប្រមាថមើលងាយ។ ពួកគេរករត់គេចពីវត្តមានរបស់ទ្រង់។ អ្នកដែលបោះដែកគោលទម្លុះព្រះហស្ត និងព្រះបាទារបស់ទ្រង់មើលស្លាកស្នាមទាំងនេះដោយសេចក្តីរន្ធត់ និងស្តាយក្រោយជាទីបំផុត។

ពួកសង្ឃ និងពួកអ្នកដឹកនាំ នឹកទៅដល់ព្រឹត្តិការណ៍នៃកាល៉ារីយ៉ាងច្បាស់អស្ចារ្យ នៅពេលដែលគេបានងក់ក្បាលអរសប្បាយដោយខ្លួនបានទទួលជ័យជម្នះ ហើយឧទានឡើងថា «វាជួយសង្គ្រោះមនុស្សឯទៀតបានតែមិនអាចនឹងជួយសង្គ្រោះដល់ខ្លួនវាបាន»។ ម៉ាថាយ ២៧:៤២។ សំឡេងថ្ងូរអស់សង្ឃឹមដែលបន្លឺឡើងថា «ទ្រង់ជាព្រះរាជបុត្រារបស់ព្រះ!» បានឮខ្លាំងជាងសម្រែក «ឆ្កាងវាទៅ!» ដែលឮខ្ជរពេញក្រុងយេរូសាឡិមទៅទៀត។ គេរករត់គេចខ្លួនពីវត្តមាននៃស្តេចលើអស់ទាំងស្តេច។

<u>ព្រហស្បតិ៍-២១ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥៦

ខព្រះគម្ពីរប្រចាំថ្ងៃ: *តែចូរឲ្យអ្នករាល់គ្នាបានបរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ ដូចជាព្រះដែលហៅអ្នករាល់គ្នាទ្រង់បរិសុទ្ធដែរ។ ពេត្រុសទី១ ១:១៥*

ក្នុងជីវិតនៃអស់អ្នកដែលបដិសេធសេចក្តីពិត មានគ្រាដែលសម្បជញ្ញៈភ្ញាក់រលឹកឡើងម្តងៗនៅពេលដែលសេចក្តីស្តាយក្រោយដ៏ឥតប្រយោជន៍ធ្វើទុក្ខដុកដាន់ដល់ព្រលឹង ប៉ុន្តែ ការទាំងនេះប្រៀបផ្ទឹមនឹងសេចក្តីស្តាយក្រោយនៃថ្ងៃនោះមិនចេះកើត។ ក្នុងក្តីរន្ធត់របស់គេ គេឮសំឡេងនៃពួកបរិសុទ្ធឧទានឡើងថា៖ «មើល នេះគឺជាព្រះនៃយើងរាល់គ្នា យើងបានរង់ចាំទ្រង់ ហើយទ្រង់នឹងជួយសង្គ្រោះយើង»។ អេសាយ ២៥:៩។

ទាំងអស់គ្នាចេញមកពីផ្នូរ ក្នុងសណ្ឋានដូចពេលដែលគេបានចូលទៅក្នុងផ្នូរដូច្នោះដែរ។ ប៉ុន្តែ ទាំងអស់គ្នារស់ឡើងវិញ ដោយមានភាពស្រស់បស់ និងកម្លាំងមាំមួន ជាយុវភាពអស់កល្បជានិច្ច។ ព្រះគ្រីស្ទបានយាងមកដើម្បីកែលម្អឡើងវិញនូវអ្វីដែលបានបាត់បង់ទៅ។ ទ្រង់នឹងបំផ្លាស់បំប្រែរាងកាយទុច្ចរិតរបស់យើង ហើយធ្វើឱ្យដូចជាព្រះកាយដ៏ពោរពេញទៅដោយសិរីល្អរបស់ទ្រង់។ ទម្រង់ដែលរមែងស្លាប់ និងរមែងពុករលួយ ដែលធ្លាប់បានប្រឡាក់កខ្វក់ដោយបាបកម្មនោះក្លាយទៅជាគ្រប់លក្ខណ៍ ល្អឆើតឆាយ និងអមតៈ។ ស្មាមប្រឡាក់ ទម្រង់ខូចរៀចវេរ គឺបានទុកចោលនៅក្នុងផ្នូរវិញ។ អ្នកដែលបានប្រោសលោះ នឹងចម្រើនឡើងទៅជាសាសន៍ដែលមានមាឌ និងកម្ពស់ក្នុងសិរីល្អដូចកាលពីដើមដំបូង។ ស្លាកស្នាមចុងក្រោយបង្អស់នៃបណ្តាសានៃអំពើបាប នឹងត្រូវបានលុបចោល។ ពួកអ្នកស្មោះត្រង់ចំពោះព្រះគ្រីស្ទ នឹងមានភាពដ៏គ្រប់លក្ខណ៍នៅក្នុងគំនិត ព្រលឹង និងសព៌ាង្គកាយរបស់គេ ដូចព្រះអម្ចាស់របស់គេដែរ។

អ្នកសុចរិតដែលរស់នៅ ត្រូវបានផ្លាស់ប្តូរ «ក្នុងមួយរំពេច គឺក្នុងមួយប៉ប្រិចភ្នែកប៉ុណ្ណោះ»។ គ្រាន់តែឮព្រះសូរសៀងរបស់ព្រះ នោះពួកគេបាន

ក្លាយទៅជាអមត:ភ្លាម ហើយក៏ហោះឡើងជាមួយនឹងពួកបរិសុទ្ធ ទៅជួប
ព្រះអម្ចាស់របស់គេនាឰដ៏អាកាស។ ពួកទេវតាប្រមូលពួករើសតាំងរបស់
ព្រះអង្គពីទិសទាំងបួន ចាប់តាំងពីជើងមេឃម្ខាងរហូតដល់ជើងមេឃម្ខាង។
ម៉ាថាយ ២៤:៣១។ កូនតូចតាចត្រូវបានប្រគល់ឱ្យម្តាយរបស់វាបីត្រកងវិញ។
មិត្រសម្លាញ់ដែលបែកគ្នាជាយូរកន្លងមកហើយនោះ ត្រូវបានជួបគ្នាវិញ
ហើយនិងមិនដែលឃ្លាតពីគ្នាទៀតឡើយ ហើយក៏ហោះឡើងជាមួយគ្នា ទៅ
លើទាំងច្រៀងចម្រៀងនៃអំណរ ឆ្ពោះទៅកាន់នគររបស់ព្រះ។

ការចូលទៅក្នុងទីក្រុងបរិសុទ្ធ

អស់ទាំងពួកដែលបានប្រោសលោះ ដែលមានចំនួនឥតគណនា
សម្លឹងមកឯព្រះយេស៊ូវ។ គ្រប់ទាំងភ្នែកសម្លឹងមើលសិរីល្អរបស់ទ្រង់ «ដ្បិតព្រះ
ភ័ក្ត្រទ្រង់ត្រូវខូចទៅខុសជាងមនុស្សធម្មតា ហើយរាងកាយទ្រង់ក៏ខុសនឹង
រាងកាយរបស់មនុស្សជាតិទាំងពួងផង»។ អេសាយ ៥២:១៤។ ព្រះយេស៊ូវ
ទ្រង់បំពាក់មកុដនៃសិរីល្អ នៅលើក្បាលអ្នកដែលមានជ័យជម្នះ។ ម្នាក់ៗ
មានមកុដមួយ មាន «ឈ្មោះថ្មី» របស់គេ (វិវរណៈ ២:១៧) ព្រមទាំងមាន
ចារឹកដែលចែងថា «បរិសុទ្ធដល់ព្រះយេហូវ៉ា» នៅលើមកុដនោះផង។ ក្នុង
ដៃគេម្នាក់ៗ មានរង្វាន់កិត្តិយស និងពិណដ៏ភ្លឺស្រឡាង។ បន្ទាប់មក នៅ
ពេលមេទេវតាចាប់ផ្តើមទំនុកភ្លេង ដៃទាំងប៉ុន្មានក៏ផ្ទាត់ខ្សែពិណ ដោយការ
ប៉ិនប្រសប់ បញ្ចេញសូរសព្វយ៉ាងពីរោះក្រៃលែង។ សំឡេងនីមួយៗ ស្រែក
ឡើងក្នុងការសរសើរតម្កើងដ៏ប្រពៃថា៖ «រីឯព្រះអង្គដែលស្រឡាញ់យើង
រាល់គ្នា ហើយបានលាងយើងដោយព្រះលោហិតទ្រង់ឱ្យបានរួចពីបាប ព្រម
ទាំងតាំងយើងរាល់គ្នាឡើងជានគរ ហើយជាពួកសង្ឃថ្វាយព្រះដ៏ជាព្រះ
វរបិតា នោះសូមឱ្យទ្រង់បានសិរីល្អ និងព្រះចេស្តានៅអស់កល្បជានិច្ច
រៀងរាបតទៅ»។ វិវរណៈ ១:៥,៦។

នៅចំពោះពួកដែលត្រូវបានបង់ថ្លៃលោះ គឺជាទីក្រុងបរិសុទ្ធ។ ព្រះ
យេស៊ូវក៏បើកទ្វារ ហើយប្រជាជាតិដែលបានកាន់សេចក្តីពិតក៏អញ្ជើញចូល

ទៅក្នុង។ បន្ទាប់មកទើបឮព្រះសូរសៀងរបស់ទ្រង់ថា «ឱពួកអ្នកដែលព្រះវរបិតាយើងប្រទានពរអើយ ចូរមកទទួលមរតកចុះ គឺជានគរដែលបានរៀបចំទុកសម្រាប់អ្នករាល់គ្នា តាំងតែពីកំណើតលោកីយ៍មក»។ ម៉ាថាយ ២៥:៣៤។ ព្រះគ្រីស្ទបង្ហាញដល់ព្រះវរបិតានូវទំនិញនៃព្រះលោហិតរបស់ទ្រង់ ដោយមានព្រះបន្ទូលថា៖ «មើល ទូលបង្គំនេះ និងពួកកូនចៅ ដែលទ្រង់បានប្រទានមកទូលបង្គំ»។ «ទូលបង្គំបានរក្សាទុកដល់អស់អ្នកដែលទ្រង់ប្រទានមកទូលបង្គំ»។ ហេព្រើរ ២:១៣; យ៉ូហាន ១៧:១២។ ឱ សេចក្តីសប្បាយរីករាយដ៏ហួសនិស្ស័យស្មាននាពេលនោះ ពេលដែលព្រះវរបិតាដ៏មានព្រះជន្មគ្មានទីបំផុត ទតមើលពួកអ្នកដែលត្រូវបានបង់ថ្លៃលោះ ព្រមទាំងឃើញរូបរបស់ព្រះគ្រីស្ទ ទាំងមានរោគានៃអំពើបាបត្រូវបានដកចេញអស់ទៅ ហើយមនុស្សជាតិបានសមប្រកបនឹងព្រះម្តងទៀត គឺអស្ចារ្យណាស់ហ្ន៎!

<u>សុក្រ-២២ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥៧

ខព្រះគម្ពីរប្រចាំថ្ងៃ: *ហើយបើសិនជាអ្នករាល់គ្នាអំពាវនាវដល់ទ្រង់ ទុកដូចជាព្រះវរបិតាដែលទ្រង់ជំនុំជំរះ តាមការដែលគេប្រព្រឹត្តរៀងខ្លួន ឥតរើសមុខអ្នកណា នោះត្រូវតែប្រព្រឹត្តដោយកោតខ្លាច ក្នុងកាលដែលនៅសំណាក់ក្នុងជីវិតនេះនៅឡើយចុះ។ ពេត្រុសទី១ ១:១៧*

ក្នុងព្រះរាជនគរនៃសេចក្តីរុងរឿង ព្រះអង្គសង្គ្រោះមានសោមនស្សរីករាយ ក្នុងកាលដែលទ្រង់ទតឃើញព្រលឹងទាំងឡាយដែលបានសង្គ្រោះដោយសេចក្តីឈឺចាប់ និងសេចក្តីអាម៉ាស់របស់ទ្រង់។ ពួកដែលត្រូវបានប្រោសលោះក៏ជួយអបអរទ្រង់ដែរ។ គេបានមើលអ្នកមានជ័យជម្នះដោយការអធិស្ឋាន ពលកម្ម និងដោយស្រឡាញ់ការលះបង់។ សេចក្តីរីករាយនឹងបានពេញក្នុងចិត្តគេ នៅពេលគេឃើញមនុស្សម្នាក់បានជួយសង្គ្រោះអ្នកដទៃ ហើយអ្នកនោះសង្គ្រោះអ្នកឯទៀតតៗគ្នាជាលំដាប់ទៅ។

អ័ដាមជាំងពីរដួងគ្នា

នៅពេលអ្នកដែលបានបង់ថ្លៃលោះ បានស្វាគមន៍ចូលទៅក្នុងទីក្រុងរបស់ព្រះហើយ ក៏មានឮសំឡេងសរសើរតម្កើងបន្លឺឡើង។ អ័ដាមទាំងពីរហៀបតែនឹងជួបគ្នា។ ព្រះរាជបុត្រារបស់ព្រះនឹងទទួលឪពុកនៃពូជរបស់យើង ដែលទ្រង់បានបង្កើតមក ក៏បានមានបាប ហើយដោយសារតែអំពើបាបនោះ បានជាមានស្លាកស្នាមនៃការឆ្កាងជាប់នៅលើទម្រង់របស់ព្រះអង្គសង្គ្រោះ។ នៅពេលអ័ដាមឃើញស្នាមដែកគោល លោកក៏ទម្លាក់ខ្លួនចុះនៅនឹងព្រះបាទានៃព្រះគ្រីស្ទក្នុងសេចក្តីអាម៉ាស់។ ព្រះអង្គសង្គ្រោះក៏លើកលោកឡើង ហើយឱ្យមើលម្តងទៀតទៅឯសួនអេដែនដ៏ជាមាតុភូមិដែលលោកបានឃ្លាតចាកចេញជាយូរលង់មកហើយនោះ។

ជីវិតរបស់អ័ដាមបានពោរពេញដោយសេចក្តីសោកសង្រេង។ គ្រប់ទាំងស្លឹកឈើដែលជ្រុះស្វិតស្រពោន គ្រប់ទាំងភាពរងគ្រោះនៃយញ្ញបូជា គ្រប់ទាំងស្នាមប្រឡាក់នៅលើភាពបរិសុទ្ធរបស់មនុស្ស សុទ្ធតែជាការរំលឹកនៃអំពើបាបរបស់លោក។ សេចក្តីចុកចាប់នៃការសោកស្តាយក្រោយនោះខ្លាំងក្លាពន់ពេកណាស់ នៅពេលអ្វីៗដែលលោកឃើញ ចង្អុលមកគាត់ថាជាដើមចមនៃអំពើបាប។ លោកបានលន់តួបាបដោយស្មោះត្រង់ ហើយបានស្លាប់ដោយសង្ឃឹមថានឹងរស់ឡើងវិញ។ ឥឡូវនេះ អ័ដាមត្រូវបានដូចដើមវិញដោយសារការប្រោសលោះ។

ដោយមានចិត្តរំភើបជាក្រៃលែង លោកបានគយគន់មើលព្រៃព្រឹក្សាទាំងឡាយ ដែលធ្លាប់ជាទីគាប់ចិត្តដល់លោក ហើយធ្លាប់បានបេះផ្លែ ក្នុងកាលដែលលោកឥតមានទោស។ លោកឃើញដើមទំពាំងបាយជូរ ដែលដៃរបស់លោកបានបំពាត់ និងផ្កាទាំងឡាយដែលលោកធ្លាប់បីបាច់ថែរក្សា។ ប្រាកដមែន! នេះជាសួនអេដែនដែលត្រូវបានកែលម្អឡើងវិញ។

ព្រះអង្គសង្គ្រោះ នាំលោកទៅឯដើមជីវិត ហើយឱ្យលោកបរិភោគ។ លោកឃើញក្រុមគ្រួសាររបស់លោកដ៏សន្ធឹកដែលត្រូវបានប្រោសលោះ។

បន្ទាប់មក លោកដោះមកុដរបស់លោកដាក់ចុះទាបព្រះបាទាព្រះយេស៊ូវ ហើយក៏ឱបព្រះអង្គប្រោសលោះ។ លោកក៏ប៉ះពិណ ហើយចម្រៀងជ័យ យោសក៏បញ្ចេញសូរស័ព្ទខ្លាំងពេញប្រាសាទនៃស្ថានសួគ៌៖ «កូនចៀមដែលបានសម្លាប់នោះនឹងបានព្រះចេស្តា»។ វិវរណៈ ៥:១២។ ក្រុមគ្រួសារអ័ដាមដោះមកុដរបស់គេដាក់នៅនឹងព្រះបាទានៃព្រះអង្គសង្គ្រោះ ហើយគេឱនក្បាលគោរពក្នុងសេចក្តីកោតសរសើរ។ ពួកទេវតាយំនៅពេលអ័ដាមបានមានបាប ហើយអរសប្បាយនៅពេលព្រះយេស៊ូវ បានប្រោសដល់អស់អ្នកដែលជឿដល់ព្រះនាមទ្រង់ឱ្យរស់ឡើងវិញ។ ឥឡូវនេះ ពួកគេមើលកិច្ចការនៃការប្រោសលោះបានសម្រេចជាស្តាពរ ហើយបន្លឺសំឡេងរបស់ពួកគេក្នុងសេចក្តីកោតសរសើរ។

នៅលើ «សមុទ្រកែវលាយនឹងភ្លើង» គឺជាក្រុមដែល «បានឈ្នះនឹងសត្វនោះ និងរូបវារហើយជាលេខរបស់វាផង»។ ពួកមួយសែនបួនម៉ឺនបួនពាន់ ត្រូវបានប្រោសលោះពីចំណោមមនុស្ស ហើយគេច្រៀង «បទមួយថ្មី» ជាចម្រៀងរបស់លោកម៉ូសេ និងកូនចៀម។ វិវរណៈ ១៥:២,៣។ គ្មាននរណាអាចច្រៀងចម្រៀងនោះបានទេ មានតែពួកមួយសែនបួនម៉ឺនបួនពាន់ប៉ុណ្ណោះ ព្រោះជាចម្រៀងនៃសេចក្តីពិសោធ ដែលគ្មានក្រុមមនុស្សណាធ្លាប់មានសោះឡើយ។ ពួកគេទាំងនេះ «តាមកូនចៀមទៅគ្រប់កន្លែងដែលទ្រង់យាងទៅ»។ ពួកគេទាំងនេះ ដែលបានលើកឡើងពីចំណោមអ្នករស់នៅគឺ «ជាផ្លែដំបូងថ្វាយដល់ព្រះ ហើយនិងកូនចៀម»។ វិវរណៈ ១៤:៤,៥។ គេបានឆ្លងផុតគ្រាវេទនាដូចពុំដែលមានពីមុន តាំងពីមានជាតិសាសន៍មក។ គេបានស៊ូទ្រាំនឹងការឈឺចាប់នៃគ្រាលំបាកនៃជំនាន់លោកយ៉ាកុប គេបានទ្រាំទ្រដោយគ្មានអ្នកអង្វរជំនួស ក្នុងការជំនុំជម្រះចុងក្រោយបង្អស់របស់ព្រះ។ «គេបានបោកអាវ ហើយធ្វើឱ្យឡើងសក្នុងឈាមរបស់កូនចៀម» ក៏ «មិនឃើញមានសេចក្តីភូតភរ នៅក្នុងមាត់គេឡើយ ដ្បិតគេឥតសៅហ្មង» នៅចំពោះព្រះ។ «គេនឹងមិនឃ្លាន ឬស្រេកទៀត ក៏មិនត្រូវថ្ងៃចាំងមកលើគេ ឬ

ចំហាយណាទៀតឡើយ ពីព្រោះកូនចៀមដែលនៅចំពោះបល្ល័ង្ក ទ្រង់នឹងឃ្វាល ហើយនាំគេទៅដល់រន្ធទឹកនៃជីវិត ហើយព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែកពីភ្នែកគេចេញ»។ វិវរណៈ ៧:១៤; ១៤:៥; ៧:១៦,១៧។

<u>សៅរ៍-២៣ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥៨

ខព្រះគម្ពីរប្រចាំសប្តាហ៍: *អ្នករាល់គ្នាបានជំរះសំអាតចិត្ត ដោយស្តាប់តាមសេចក្តីពិត សំរាប់ឲ្យបានសេចក្តីស្រឡាញ់ជាបងប្អូនឥតពុតមាយា ដូច្នេះ ចូរស្រឡាញ់គ្នាទៅវិញទៅមកជាយ៉ាងខ្លាំង ដោយចិត្តដ៏ស្អាតចុះ។ ពេត្រុសទី១ ១:២២*

អ្នកដែលត្រូវបានប្រោសលោះ ប្រកបដោយសេចក្តីរុងរឿង

ក្នុងគ្រប់ទាំងសម័យ អ្នករើសតាំងនៃព្រះអង្គសង្គ្រោះ បានដើរក្នុងផ្លូវចង្អៀត។ គេត្រូវបានចម្រាញ់ក្នុងឡនៃភាពទុក្ខលំបាក។ គេបានស៊ូទ្រាំនឹងក្តីសម្អប់ ពាក្យមួលបង្កាច់ សេចក្តីលះបង់ខ្លួន ហើយនិងការខកចិត្តដ៏ជូរចត់។ គេបានរៀនពីភាពអាក្រក់នៃអំពើបាប ពីអំណាចរបស់វា កំហុសរបស់វា និងសេចក្តីវិវររបស់វា ហើយគេមើលទៅអំពើបាបនោះ ដោយសេចក្តីស្អប់ខ្ពើមជាក្រៃលែង។ ការយល់ដល់សេចក្តីលះបង់ដ៏គ្មានទីបំផុត ដែលត្រូវបានធ្វើសម្រាប់ព្យាបាលបាប បានធ្វើឱ្យគេបន្ទាបខ្លួនគេ និងបំពេញចិត្តគេដោយសេចក្តីដឹងគុណ។ គេមានសេចក្តីស្រឡាញ់ដ៏លើសលប់ ព្រោះគេបានទទួលការអត់ទោសដល់ខ្លួនវិញដ៏លើសលប់ដែរ។ សូមអានលូកា ៧:៤៧។ អ្នកមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ គឺសមជាអ្នកដែលមានចំណែកក្នុងសិរីល្អរបស់ទ្រង់។

អ្នកគ្រងរាជ្យរបស់ព្រះ មានមកពីយោធភូមិ ខ្ទម រន្ធា គុកក្រោមដី ព្រៃភ្នំ វាលរហោស្ថាន និងរូងភ្នំ។ គេបាន «កម្សត់ទុគ៌ត ត្រូវគេសង្កត់សង្កិន ហើយ [គេ] ធ្វើបាប»។ មនុស្សរាប់លាននាក់បានលាចាកលោកីយ៍ទាំងអាប់

យស ពីព្រោះគេមិនព្រមចុះចូលនឹងសាតាំង។ ប៉ុន្តែ ឥឡូវគេលែងមានទុក្ខព្រួយ ការបែកបាក់ខ្ចាត់ខ្ចាយ និងលែងមានគេជិះជាន់ទៀតឡើយ។ អំណឹះតទៅ គេឈរនៅ ទាំងពាក់អាវដែលមានតម្លៃថ្លៃជាងអាវរបស់មនុស្សដែលមានកិត្តិយសបំផុតនៃផែនដី ហើយពាក់មកុដដែលភ្លឺចិញ្ចែងចិញ្ចាច ល្អថ្លៃថ្លាជាងអ្វីដែលបានបំពាក់លើព្រះកេសនៃមហាក្សត្រនៃផែនដីទៅទៀត។ ព្រះមហាក្សត្រនៃសិរីល្អ ជូតអស់ទាំងទឹកភ្នែកចេញពីថ្ពាល់របស់គេ។ ពួកគេច្រៀងចម្រៀងសរសើរមួយបទ ដែលឮច្បាស់ផ្អែមពីរោះ ហើយត្រូវចង្វាក់គ្នាសូររងំ។ ទំនុកសរសើរព្រះឮខ្ទរខ្ទារពេញប្រាសាទនៃស្ថានសួគ៌៖ «សេចក្តីសង្គ្រោះ ស្រេចនឹងព្រះនៃយើងរាល់គ្នាដែលគង់នៅលើបល្ល័ង្ក ហើយស្រេចនឹងកូនចៀមផង»។ ហើយទាំងអស់គ្នាក៏បន្ទរតបទៅវិញថា «អាម៉ែន សូមថ្វាយព្រះពរសិរីល្អ ប្រាជ្ញា ពាក្យអរព្រះគុណ កិត្តិនាម ព្រះចេស្តា និងឥទ្ធិឫទ្ធិដល់ព្រះនៃយើងរាល់គ្នា នៅអស់កល្បជានិច្ចរៀងរាបតទៅ»។ វិវរណៈ ៧:១០,១២។

ក្នុងជីវិតនេះ យើងទើបតែយល់ពីឆាកនៃការប្រោសលោះប៉ុណ្ណោះទេ។ ដោយការឈ្វេងយល់ដឹងដ៏មានកំណត់របស់យើង យើងអាចពិចារណាបានជ្រាលជ្រៅ បានត្រឹមតែពីសេចក្តីអាម៉ាស់ និងសិរីល្អ ជីវិតនិងសេចក្តីស្លាប់ យុត្តិធម៌ និងមេត្តាធម៌ដែលប្រសព្វគ្នានៅឯឈើឆ្កាងប៉ុណ្ណោះ តែទោះជាខំប្រឹងប្រើអំណាចខាងគំនិតប្រាជ្ញាប៉ុណ្ណឹងហើយក៏ដោយ យើងនៅតែគោងយល់នូវអត្ថន័យទាំងមូលមិនអស់ដែរ។ គឺបានយល់តិចតួចណាស់អំពីបណ្តោយ និងទទឹង ជម្រៅ និងកម្ពស់នៃសេចក្តីស្រឡាញ់ប្រោសលោះ។ គម្រោងការប្រោសលោះ នឹងមិនត្រូវបានយល់ពេញលេញឡើយ ទោះបីជាអ្នកដែលត្រូវបានបង់ថ្លៃលោះ បានយល់ហើយបានដឹងប៉ុណ្ណឹងក៏ដោយ ប៉ុន្តែចំណេរតទៅអនន្តភាព សេចក្តីពិតថ្មីនឹងចេះតែបើកសម្តែងឡើង ដល់គំនិតងឿងឆ្ងល់ និងគំនិតដែលត្រេកអរ។ ទោះជាការសោកសង្រេង ការឈឺចាប់ និងការល្បួងល្បងទាំងឡាយនៃផែនដី លែងមានតទៅទៀត ហើយដើម

ហេតុត្រូវបានដកចេញហើយក៏ដោយ រាស្ត្ររបស់ព្រះនឹងមានតម្រិះប្រាជ្ញា
ឈ្លាសវៃ យល់ច្បាស់អំពីតម្លៃនៃសេចក្តីសង្គ្រោះរបស់ខ្លួន។

ឈើឆ្កាងនឹងបានជាទំនុកចម្រៀងនៃអ្នកដែលត្រូវបានប្រោសលោះ
លុះដល់អស់កល្ប ពីព្រោះនៅពេលគេលើកតម្កើងព្រះគ្រីស្ទ គេក៏ឃើញព្រះ
គ្រីស្ទដែលបានជាប់ឆ្កាងដែរ។ នឹងគ្មាននរណាម្នាក់ភ្លេចពីដំណើរដែលព្រះ
មហាក្សត្រនៃស្ថានសួគ៌បានបន្ទាបព្រះអង្គទ្រង់ មកលើកស្ទួយមនុស្សមាន
បាប និងពីដំណើរដែលទ្រង់បានទ្រាំទ្រទោស និងទ្រាំទ្រសេចក្តីអាម៉ាស់នៃ
អំពើបាប ហើយបិទព្រះភ័ក្ត្រព្រះវរបិតា រហូតដល់សេចក្តីវិវរនៃពិភពដែល
បានបាត់បង់ បំបែកព្រះឱរាទ្រង់ ហើយប្រល័យព្រះជន្មទ្រង់ឡើយ។ ព្រះ
ដែលជាអ្នកបង្កបង្កើតពិភពទាំងអស់ ដែលជាសេចក្តីស្រឡាញ់ទ្រង់បានទុក
សិរីល្អរបស់ទ្រង់ដោយឡែក ហើយត្រឡប់ទៅជាមនុស្សលោក ការនេះធ្វើ
ឱ្យពិភពលោកអស្ចារ្យពេកក្រៃ។ នៅពេលប្រជាជាតិទាំងឡាយដែលត្រូវ
បានសង្គ្រោះ សម្លឹងមើលព្រះអង្គប្រោសលោះរបស់ខ្លួន ហើយដឹងថាព្រះ
រាជនគររបស់ទ្រង់ គឺនឹងមិនមានទីបំផុតនោះ គេក៏ស្រែកច្រៀងឡើងថា៖
«កូនចៀមដែលគេបានសម្លាប់ ហើយបានប្រោសលោះយើងទៅឯព្រះ
ដោយព្រះលោហិតដ៏ថ្លៃ វិសេសរបស់ទ្រង់ នោះគួរនឹងបានព្រះចេស្តា!»

អាថិកំបាំងនៃឈើឆ្កាង ពន្យល់អស់ទាំងអាថិកំបាំងទាំងឡាយ។ គេ
នឹងយល់ដឹងថា ព្រះទ្រង់ដែលមានព្រះតម្រិះដ៏គ្មានទីបំផុត ពុំអាចគ្រោងគម្រោង
ការសម្រាប់សេចក្តីសង្គ្រោះរបស់យើងបាន ក្រៅពីការធ្វើយញ្ញបូជាព្រះរាជ
បុត្ររបស់ទ្រង់ឡើយ។ ការសងមកវិញសម្រាប់យញ្ញបូជានេះ គឺជាអំណាចនៃ
ការដាក់ប្រជារាស្ត្រលើផែនដី ឱ្យបានពោរពេញទៅដោយមនុស្សដែលត្រូវ
បានសងថ្លៃលោះ បរិសុទ្ធ សប្បាយ និងអមត:។ នេះហើយជាតម្លៃនៃ
ព្រលឹងដែលព្រះវរបិតា ទ្រង់សព្វព្រះទ័យនឹងបង់។ ហើយព្រះគ្រីស្ទផ្ទាល់ក៏
សព្វព្រះហឫទ័យដែរ ដោយទតមើលទៅផលផ្លែនៃការលះបង់ដ៏ធំរបស់
ទ្រង់។

ការរំដោះរាស្ត្ររបស់ព្រះ

<u>អាទិត្យ-២៤ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៥៩

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដ្បិតព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី មិនមែនពីពូជដែលតែងតែពុករលួយនោះទេ គឺពីពូជដែលមិនចេះពុករលួយវិញ គឺជាព្រះបន្ទូលដ៏រស់ ហើយនៅជាប់លាប់។ ពេត្រុសទី១ ១:២៣*

នៅពេលព្រះសូរសៀងរបស់ព្រះ រំដោះរាស្ត្រទ្រង់ឱ្យរួចពីភាពជាឈ្លើយហើយនោះ អ្នកដែលបាត់បង់អ្វីៗទាំងអស់ក្នុងវិបត្តិដ៏ធំនៃជីវិត មានការភ្ញាក់រលឹកយ៉ាងខ្លាំង។ បន្ទាប់ពីបានងងឹតងងុលដោយសេចក្តីបញ្ឆោតរបស់សាតាំងហើយ ពួកអ្នកមាន បានគិតថាខ្លួនគេថ្កុំថ្កើងជាងអ្នកដែលពុំសូវមានភ័ព្វវាសនាដូចខ្លួន។ ប៉ុន្តែ គេពុំបានបញ្ចុកអ្នកស្រែកឃ្លាន បំពាក់អ្នកនៅខ្លួនទទេប្រព្រឹត្តដោយយុត្តិធម៌ ហើយនិងស្រឡាញ់ធម៌មេត្តាទេ។ ឥឡូវនេះ អ្វីដែលធ្វើឱ្យគេថ្កុំថ្កើងនោះត្រូវបានដកចេញអស់ ហើយគេនៅឯកោតែឯង។ គេមើលទៅសេចក្តីវិនាសហិនហោចនៃរូបសំណាករបស់ខ្លួនដោយក្តីរន្ធត់។ គេបានលក់ព្រលឹងរបស់ខ្លួន សម្រាប់ការសប្បាយហឹហានៅនាលោកីយ៍ ប៉ុន្តែ មិនបានខំរកឱ្យមានខាងឯព្រះទេ។ ជីវិតរបស់គេជាជីវិតអសារបង់ ហើយការសប្បាយរបស់គេ បានត្រឡប់ទៅជាល្វីងជូរចត់ទៅវិញ។ ភោគផលដែលកេងមកក្នុងមួយជីវិត ត្រូវបានរសាត់បាត់បង់ក្នុងមួយរំពេច។ ពួកអ្នកមាន គេសោកស្តាយដល់វិនាសកម្មនៃវិមានរបស់ខ្លួន ដល់ការខ្ចាត់ខ្ចាយនៃមាសប្រាក់ ហើយនិងភ័យខ្លាចខ្លួនត្រូវរលាយសាបសូន្យជាមួយនឹងទ្រព្យសម្បត្តិរបស់ខ្លួនដែរ។ អ្នកទុច្ចរិត គេសោកសង្រេងដោយ

ដឹងថាខ្លួននឹងទទួលលទ្ធផលជាប្រាកដ ប៉ុន្តែ គេពុំបានសោកស្តាយចំពោះអំពើទុច្ចរិតរបស់ខ្លួនទេ។

គ្រូគង្វាលដែលលះបង់សេចក្តីពិត ដើម្បីឱ្យមនុស្សចូលចិត្តនោះ ឥឡូវយល់ដឹងពីឥទ្ធិពលនៃសេចក្តីបង្រៀនរបស់ខ្លួនហើយ។ គ្រប់ទាំងឃ្លា ដែលបានសរសេរ គ្រប់ទាំងពាក្យពេចន៍ដែលបន្លឺឡើង ដែលនាំមនុស្សឱ្យជ្រកកោនក្នុងទីជម្រកនៃសេចក្តីមិនពិត គឺសុទ្ធតែជាគ្រាប់ពូជដែលសាបព្រោះ ហើយឥឡូវនេះ គេមើលចម្រូតវិញម្តង។ ព្រះយេហូវ៉ាមានបន្ទូលថា៖ «វេទនាដល់ពួកគង្វាលដែលបំផ្លាញ ហើយកម្ចាត់កម្ចាយហ្វូងចៀមនៃទីឃ្វាលរបស់អញ!...ដូច្នេះអញនឹងទម្លាក់អំពើអាក្រក់របស់ឯងរាល់គ្នាទៅលើឯងវិញ»។ «ហើយដោយព្រោះឯងរាល់គ្នាបានបញ្ឈឺចិត្តពួកសុចរិតដោយសេចក្តីកំភូត ជាពួកដែលអញមិនបានឱ្យព្រួយចិត្តសោះ ហើយឯងបានចម្រើនកម្លាំងដៃនៃមនុស្សអាក្រក់ ដើម្បីមិនឱ្យគេលះបង់ចោលផ្លូវអាក្រក់របស់ខ្លួន ឱ្យបានសង្គ្រោះរួចជីវិតវិញឡើយ»។ យេរេមា ២៣:១,២; អេសេគាល ១៣:២២។

ពួកគ្រូគង្វាល និងពួកបណ្តាជន ដឹងខ្លួនថាគេបានប្រឆាំងទាស់នឹងព្រះដែលជាអ្នកសរសេរអស់ទាំងក្រឹត្យវិន័យដ៏សុចរិត។ ការបំផាត់ចោលសិក្ខាបទពីស្ថានសួគ៌ បណ្តាលឱ្យកើតមានប្រភពនៃភាពទុច្ចរិតកាន់តែច្រើនឡើង ដល់រាប់ពាន់ រហូតទាល់តែផែនដីបានពោរពេញទៅដោយភាពពុករលួយ។ គ្មានភាសាណាអាចពិពណ៌នាអំពីសេចក្តីខកចិត្តរបស់អ្នកមានចិត្តមិនស្មោះត្រង់បានឡើយ ចំពោះអ្វីដែលគេបានបាត់បង់អស់រៀងដរាបទៅនោះ ពោលគឺជីវិតអស់កល្ប។

ពួកបណ្តាជនចោទគ្នាទៅវិញទៅមកថា គេបាននាំខ្លួនឱ្យវិនាស ប៉ុន្តែទាំងអស់គ្នារួមគ្នាបន្លឺពាក្យចោទប្រកាន់ដ៏ជូរចត់ ទៅលើគ្រូគង្វាលដែលមិនស្មោះត្រង់ទាំងឡាយ ដែលអធិប្បាយតែ «សេចក្តីស្រួលបួល» (អេសាយ ៣០:១០) ហើយនិងនាំអ្នកស្តាប់ឱ្យបំភ្លេចក្រឹត្យវិន័យរបស់ព្រះ ព្រមទាំងឱ្យ

ធ្វើទុក្ខទោសដល់អ្នកដែលរក្សាជាបរិសុទ្ធទៀតផង។ «យើងបានបាត់បង់ហើយ!» គេបន្លឺឡើង «ហើយអ្នកឯងជាដើមហេតុ»។ ដៃដែលធ្លាប់បំពាក់កម្រងផ្កាដល់គ្រូទាំងនោះ នឹងលើកឡើងធ្វើវិនាសកម្មដល់គេ។ ទំនាស់នឹងការកម្ចាយឈាមមានគ្រប់ទីកន្លែង។

ព្រះរាជបុត្រារបស់ព្រះ និងអ្នកនាំសារនៃស្ថានសួគ៌ បានមានទំនាស់ជាមួយនឹងអារក្ស ដើម្បីព្រមាន បំភ្លឺ ព្រមទាំងជួយសង្គ្រោះកូនចៅរបស់មនុស្ស។ ឥឡូវនេះ គេទាំងអស់គ្នាបានសម្រេចចិត្តរបស់ខ្លួន ហើយពួកទុច្ចរិតរួបរួមគ្នាជាមួយនឹងសាតាំង ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងព្រះ។ វិវាទគឺមិនមែនកើតឡើងជាមួយសាតាំងតែម្នាក់ប៉ុណ្ណោះទេ តែជាមួយមនុស្សដែរ។ «ដ្បិតព្រះយេហូវ៉ាទ្រង់មានការទាស់នឹងសាសន៍ទាំងប៉ុន្មាន»។ យេរេមា ២៥:៣១។

<u>ចន្ទ-២៥ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៦០

ខព្រះគម្ពីរប្រចាំថ្ងៃ: *អ្នកនោះគ្រាន់តែមើលខ្លួន រួចចេញបាត់ទៅ ហើយក៏ភ្លេចពីបែបភាពខ្លួនជាយ៉ាងណាភ្លាម តែអ្នកណាដែលពិនិត្យមើលក្នុងក្រឹត្យវិន័យដ៏គ្រប់លក្ខណ៍ គឺជាក្រឹត្យវិន័យខាងឯសេរីភាព ហើយក៏ជាប់ចិត្តចំពោះ ឥតមានភ្លេចសេចក្ដីដែលស្តាប់នោះឡើយ គឺបានប្រព្រឹត្តតាមវិញ អ្នកនោះនឹងមានពរក្នុងគ្រប់ទាំងការដែលខ្លួនធ្វើទាំងប៉ុន្មាន។ យ៉ាកុប ១:២៤-២៥*

ទេវតានៃសេចក្តីស្លាប់

ឥឡូវនេះទេវតានៃសេចក្តីស្លាប់ដែលតំណាងដោយជនដែលមានអាវុធសម្លាប់ ក្នុងសុបិននិមិត្តរបស់ហោរាអេសេគាល ក៏ចេញទៅឯអ្នកដែលព្រះបញ្ជាឱ្យសម្លាប់៖ «ត្រូវឱ្យសម្លាប់ទាំងពួកចាស់ ពួកកំឡោះ ពួកក្រមុំ ពួកក្មេង និងពួកស្រីៗឱ្យអស់រលីងទៅ ប៉ុន្តែកុំឱ្យចូលទៅជិតមនុស្សណា ដែលមានទីសម្គាល់នៅខ្លួនឡើយ ហើយត្រូវឱ្យចាប់ផ្តើមការតាំងពីទីបរិសុទ្ធរបស់អញផង»។ «អ្នកទាំងនោះក៏ផ្តើមការ ចាប់តាំងពីពួកចាស់ទុំដែលនៅមុខព្រះវិហារ»ជាអ្នកដែលអះអាងខ្លួនថាជាអ្នកដឹកនាំប្រជារាស្ត្រខាងព្រលឹងវិញ្ញាណ។

អេសេគាល ៩:៦។

អ្នកចាំយាមក្លែងក្លាយ ត្រូវរលំស្លាប់មុនគេ។ «ព្រះយេហូវ៉ាទ្រង់យាងចេញពីស្ថានសួគ៌របស់ទ្រង់មក ដើម្បីនឹងសម្រេចទោសនៅផែនដី ដោយព្រោះអំពើទុច្ចរិតរបស់គេ។ ឯដីនឹងបើកបង្ហាញឈាមគេឱ្យឃើញ ឥតគ្របបាំងមនុស្សដែលគេសម្លាប់ទៀតឡើយ»។ «នៅថ្ងៃនោះ នឹងមានការចលាចលជាធំ ដែលមានមកពីព្រះយេហូវ៉ា កើតឡើងនៅកណ្តាលគេ គ្រប់គ្នានឹងចាប់យកអ្នកជិតខាងខ្លួន ហើយនិងលើកដៃឡើងទាស់នឹងអ្នកជិតខាងរៀងខ្លួន»។ អេសាយ ២៦:២១; សាការី ១៤:១៣។

ក្នុងទំនាស់ខ្វែងគំនិតដ៏អាក្រក់នៃការត្រេកត្រអាលដ៏សាហាវរបស់ខ្លួនគេ និងដោយការបង្អុរសេចក្តីក្រោធដែលឥតរលាយនោះ ពួកសង្ឃ អ្នកដឹកនាំ និងប្រជារាស្ត្រទុច្ចរិត ត្រូវរលំស្លាប់។ «នៅថ្ងៃនោះសាកសពនៃមនុស្សដែលព្រះយេហូវ៉ាបានប្រហារ នឹងនៅរោយពេញពីចុងផែនដីម្ខាងទៅដល់ចុងផែនដីម្ខាង»។ យេរេមា ២៥:៣៣។

នៅពេលព្រះគ្រីស្ទយាងមក មនុស្សទុច្ចរិតត្រូវវិនាសសាបសូន្យ ដោយពន្លឺភ្លឺត្រចះត្រចង់នៃសិរីល្អរបស់ទ្រង់។ ព្រះគ្រីស្ទក៏យករាស្ត្រទ្រង់ទៅឯទីក្រុងរបស់ព្រះ ហើយផែនដីក៏នៅទទេឥតមានអ្នកណារស់នៅលើនោះឡើយ។ «មើល ព្រះយេហូវ៉ាទ្រង់ធ្វើឱ្យផែនដីនៅទទេសោះ ហើយឱ្យស្ងាត់សូន្យ ក៏ធ្វើឱ្យត្រឡប់ត្រឡិន ព្រមទាំងកម្ចាត់កម្ចាយអស់ពួកអ្នកដែលនៅផែនដីផង...។ ផែនដីនឹងត្រូវផ្ទឹងឱ្យនៅទទេឆេង ហើយស្ងាត់សូន្យឈឹង ពីព្រោះព្រះយេហូវ៉ាទ្រង់បានមានបន្ទូលដូច្នេះហើយ...ពីព្រោះគេបានរំលងអស់ទាំងក្រឹត្យក្រម គេបានធ្វើខុសនឹងច្បាប់ទាំងប៉ុន្មាន ហើយផ្តាច់សេចក្តីសញ្ញាដ៏នៅអស់កល្បជានិច្ចចេញ។ ហេតុដូច្នោះ បានជាសេចក្តីបណ្តាសាបានលេបស៊ីផែនដី ហើយពួកអ្នកអាស្រ័យនៅ ក៏មានទោសទាំងអស់គ្នា បានជាពួកអ្នកអាស្រ័យនៅនោះ គេត្រូវឆេះអស់រលីងទៅ»។ អេសាយ ២៤:១,៣,៥,៦។

ផែនដីមើលទៅហាក់បីដូចជាវាលទីរហោស្ថានដ៏ឆ្ងាយដាច់ស្រយាល។ ការរញ្ជួយផែនដីបានបំផ្លាញទីក្រុងទាំងឡាយ ដើមឈើត្រូវរលំកម្ទេចថ្មដែលខ្ចាតចេញពីដី រសាត់ខ្ចាត់ខ្ចាយពាសពេញផែនដី។ ទីណាដែលភ្នំទាំងឡាយញែកចេញពីគ្រឹះរបស់វានោះ ឃើញមានរូងដ៏ធំក្រៃលែង។

ការបំបរបង់សាតាំង

ឥឡូវនេះ ព្រឹត្តិការណ៍ដែលតំណាងយញ្ញកិច្ចចុងក្រោយនៃថ្ងៃនៃការប្រោសលោះ ក៏ចាប់ផ្តើមឡើង។ នៅពេលអំពើបាបនៃសាសន៍អ៊ីស្រាអែលត្រូវបានលុបចេញពីរោងឧបោសថ ដោយអាស្រ័យនូវឈាមនៃតង្វាយបាបកម្មនោះ គេបានថ្វាយពពែរស់ដែលទទួលទោសជំនួសនៅចំពោះព្រះយេហូវ៉ា។ សង្ឃជាន់ខ្ពស់ក៏លន់តួបាប «ពីអស់ទាំងសេចក្តីទុច្ចរិត...របស់ពួកកូនចៅអ៊ីស្រាអែល...ដាក់ទាំងអស់លើក្បាលពពែនោះ»។ លេវីវិន័យ ១៦:២១។ ក៏ដូចគ្នាដែរ នៅពេលកិច្ចការនៃការប្រោសលោះបាបក្នុងរោងឧបោសថនៃស្ថានសួគ៌បានសម្រេចសព្វគ្រប់ហើយ នោះអំពើបាបទាំងឡាយនៃរាស្ត្ររបស់ទ្រង់ នឹងត្រូវដាក់ទៅលើសាតាំង នៅចំពោះព្រះ ពពួកទេវតានៃស្ថានសួគ៌ ហើយនិងពួកពលដែលត្រូវបានប្រោសលោះផងដែរ។ គេនឹងប្រកាសថា វាមានកំហុសចំពោះទាំងសេចក្តីអាក្រក់ ដែលវាបានបណ្តាលឱ្យគេប្រព្រឹត្ត។ ដូចជាពពែដែលទទួលទោសត្រូវបានបណ្តេញចេញឱ្យទៅដីដែលឥតមនុស្សអាស្រ័យនៅយ៉ាងណានោះ សាតាំងក៏នឹងត្រូវបំបរបង់ឱ្យទៅកាន់ឯផែនដីដែលស្ងាត់សូន្យឈឹងដែរ។

បន្ទាប់ពីបានសម្តែងទស្សនីយភាពនៃការយាងមកវិញរបស់ព្រះអម្ចាស់រួចហើយ អ្នកបើកសម្តែងក៏បន្តទៅទៀតថា៖ «ខ្ញុំក៏ឃើញទេវតាមួយ ចុះពីស្ថានសួគ៌មក ទាំងកាន់កូនសោជង្ហុកធំ និងច្រវាក់មួយយ៉ាងធំនៅដៃ។ ទេវតានោះក៏ចាប់នាគចងទុកមួយពាន់ឆ្នាំ គឺជាពស់ពីចាស់បុរាណដែលជាអារក្សឈ្មោះថាសាតាំង ក៏បោះវាចោលទៅក្នុងជង្ហុកធំ ទាំងខ្ទប់ហើយបិទត្រាពីលើ ដើម្បីកុំឱ្យវានាំអស់ទាំងសាសន៍ឱ្យវង្វេងទៀត ទាល់តែផុតមួយពាន់ឆ្នាំនោះ

ទៅ ក្រោយនោះត្រូវតែស្រាយវាលែងបន្តិច»។ វិវរណៈ ២០:១-៣។

<u>អង្គារ-២៦ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៦១

ខព្រះគម្ពីរប្រចាំថ្ងៃ:*ដ្បិត «អ្នកណាដែលចូលចិត្តចង់ស្រឡាញ់ជីវិត ហើយចង់ឃើញគ្រាដ៏ល្អ នោះត្រូវបញ្ឈៀសអណ្តាតពីសេចក្តីអាក្រក់ចេញ ហើយបបូរមាត់ក៏ដែរ កុំឲ្យពោលពាក្យប្រកបដោយឧបាយកលឡើយ។*
ពេត្រុសទី១ ៣:១០

«ជង្ហុកធំ» តំណាងផែនដីដែលស្ថិតក្នុងភាពច្របូកច្របល់និងភាពងងឹត។ ដោយមើលឆ្ពោះទៅថ្ងៃដ៏ធំរបស់ព្រះ ហោរាយេរេមាថ្លែងថា៖ «ខ្ញុំបានពិចារណាមើលផែនដី ឃើញថាខូចហើយទៅទទេ រួចមើលទៅលើមេឃ នោះក៏ឥតមានពន្លឺដែរ។ ខ្ញុំក្រឡេកមើលទៅភ្នំធំ ឃើញថាញ័រទាំងអស់ ហើយភ្នំតូចទាំងប៉ុន្មានកក្រើករញ្ជួយ។ ខ្ញុំក៏ពិចារណាមើលឃើញថា គ្មានមនុស្សណាទៀតសោះ អស់ទាំងសត្វហើរលើអាកាសបានហើរទៅបាត់ហើយ។ រួចខ្ញុំក៏មើលទៅឃើញដីដុះដាលបានត្រឡប់ជាវាលស្ងាត់ ហើយអស់ទាំងទីក្រុងក៏ត្រូវរលំចុះ»។ យេរេមា ៤:២៣-២៦។

ទីនេះនឹងបានជាផ្ទះរបស់សាតាំង និងពួកទេវតាអាក្រក់របស់វាអស់ ១០០០ឆ្នាំ។ វានឹងមិនត្រូវមានផ្លូវចេញចូលទៅពិភពផ្សេងៗទៀត ដើម្បីទៅល្បួង និងរំខានអ្នកដែលមិនដែលមានបាបឡើយ ព្រោះវាត្រូវបានកំណត់ឱ្យនៅផែនដី។ ក្នុងន័យនេះហើយដែលវាត្រូវ «ចងទុក» នោះ។ គ្មាននរណាម្នាក់នៅសល់ ដែលវាអាចប្រើអំណាចរបស់វាមកលើបានទៀតឡើយ។ វាត្រូវបានកាត់ចេញពីកិច្ចបោកបញ្ឆោត និងបំផ្លិចបំផ្លាញ ដែលជាការសប្បាយតែមួយគត់របស់វា។

ដោយមើលទៅការរលំធ្លាក់របស់សាតាំង ហោរាអេសាយឧទានឡើងថា៖ «ឱ តារាប្រចាំថ្ងៃជាផ្កាយព្រឹកអើយ នំ ឯងបានធ្លាក់ចុះមកពីលើមេឃហើយ ឯងដែលបានផ្តេកអស់ទាំងនគរឱ្យរាប...ឯងបានគិតក្នុងចិត្តថា អញ

នឹងឡើងទៅស្ថានសួគ៌ អញនឹងតម្កើងបល្ល័ង្កអញឱ្យខ្ពស់ជាងអស់ទាំងផ្កាយ
របស់ព្រះ...អញនឹងលើកតម្កើងខ្លួនឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត។ តែឯងត្រូវ
បានទម្លាក់ចុះដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់វិញ គឺដល់ទីជម្រៅនៃជង្ហុក
ធំ។ ពួកអ្នកដែលឃើញឯង គេនឹងសម្លឹងមើលចំឯង ហើយពិចារណាឯង
ដោយពាក្យថា តើមនុស្សនេះឬអីដែលធ្លាប់ធ្វើឱ្យផែនដីញាប់ញ័រ ហើយឱ្យ
នគរទាំងប៉ុន្មាន កក្រើករំពើកនោះ ជាអ្នកដែលធ្វើឱ្យលោកីយ៍រលីងដូចជា
សមុទ្រខ្សាច់ ព្រមទាំងបំផ្លាញទីក្រុងទាំងប៉ុន្មាន ឥតដែលលែងពួកឈ្លើយ
ឱ្យត្រឡប់ទៅឯផ្ទះគេវិញឡើយ»។ អេសាយ ១៤:១២-១៧។

អស់រយៈ៦០០០ឆ្នាំហើយ ដែលសាតាំងបានឃុំរាស្ត្ររបស់ព្រះទុក
ក្នុងគុករបស់វា ប៉ុន្តែ ព្រះគ្រីស្ទបានបណ្តាច់ចំណងរបស់វា ហើយលែងអ្នក
គុកចេញ។ ដោយនៅឯកោជាមួយនឹងពពួកទេវតារបស់វា វាបានយល់ដឹងពី
លទ្ធផលនៃអំពើបាប៖ «ឯសពនៃអស់ទាំងស្តេចរបស់សាសន៍ទាំងប៉ុន្មាន
សុទ្ធតែដេកនៅក្នុងទីរុងរឿងនាម៉ឺង [ផ្ទរ] របស់គេ។ តែឯងបានត្រូវបោះ
ចោលចេញឆ្ងាយពីម៉ឺងឯងទៅ ដូចជាមែក [ឈើ] ដែលគួរខ្ពើមវិញ...។ ឯង
នឹងមិនបានចូលទៅជាមួយនឹងគេនៅក្នុងផ្ទរទេ ពីព្រោះឯងបានបំផ្លាញស្រុក
របស់ឯង ហើយបានសម្លាប់ប្រជាជនរបស់ឯងផង»។ អេសាយ ១៤:១៨-២០។

សាតាំងនឹងមើលលទ្ធផលនៃការប្រឆាំងទាស់នឹងក្រឹត្យវិន័យរបស់
ព្រះ អស់១០០០ឆ្នាំ។ សេចក្តីរងទុក្ខវេទនារបស់វានោះខ្លាំងពេកក្រៃ។ ឥឡូវ
នេះ គេទុកវាឱ្យនៅតែឯង ឱ្យគិតពិចារណាពីការដែលវាបានប្រព្រឹត្ត តាំងតែ
ពីពេលវាបានប្រឆាំងមក ហើយឱ្យទន្ទឹងចាំងទាំងរន្ធត់ដល់អនាគតដ៏គួរឱ្យ
ខ្លាច នៅពេលវានឹងត្រូវទទួលទណ្ឌកម្មរបស់វា។

ការជំនុំជម្រះពួកមនុស្សទុច្ចរិត គឺប្រព្រឹត្តឡើងក្នុងអំឡុងពេល
១០០០ឆ្នាំ រវាងការរស់ឡើងវិញលើកទីមួយ និងលើកទីពីរ។ សាវ័កប៉ុល
ចង្អុលទៅការនេះ ថាជាព្រឹត្តិការណ៍ដែលនឹងកើតឡើង បន្ទាប់ពីការយាង
មកជាលើកទីពីរ។ កូរិនថូសទី១ ៥:៥។ ពួកសុចរិតត្រូវគ្រងរាជ្យជាស្តេច និង

ជាសង្ឃ។ យ៉ូហានមានប្រសាសន៍ថា៖ «ខ្ញុំក៏ឃើញបល្ល័ង្កជាច្រើន និងពួក
អ្នកដែលអង្គុយលើ ហើយមានអំណាចបានប្រគល់ដល់អ្នកទាំងនោះ ឱ្យ
ជំនុំជម្រះ...។ ពួកអ្នកទាំងនោះនឹងធ្វើដូចជាសង្ឃនៃព្រះ និងព្រះគ្រីស្ទ ហើយ
និងសោយរាជ្យជាមួយនឹងទ្រង់អស់មួយពាន់ឆ្នាំ»។ វិវរណៈ ២០:៤-៦។

នៅពេលនេះ «ពួកបរិសុទ្ធនឹងជំនុំជម្រះលោកីយ៍»។ កូរិនថូសទី១
៦:២។ គេជំនុំជម្រះពួកទុច្ចរិតរួមជាមួយនឹងព្រះគ្រីស្ទ ដោយសម្រេចគ្រប់ទាំង
ករណីតាមតែអំពើដែលរូបកាយបានប្រព្រឹត្ត។ បន្ទាប់មក ចំណែកដែលអ្នក
ទុច្ចរិតត្រូវទទួលរងទុក្ខនោះ បានចែកចេញជាផ្នែកតាមតែការដែលគេបាន
ធ្វើ ហើយត្រូវកត់ទុកក្នុងបញ្ជីមរណៈតាមឈ្មោះរបស់គេ។

ព្រះគ្រីស្ទ និងរាស្ត្រទ្រង់ វិនិច្ឆ័យសាតាំង និងពួកទេវតាអាក្រក់។
សាវ័កប៉ុលមានប្រសាសន៍ថា៖ «តើមិនដឹងថា យើងរាល់គ្នានឹងជំនុំជម្រះ
ដល់ទាំងពួកទេវតាផងទេឬអី?» កូរិនថូសទី១ ៦:៣។ សាវ័កយូដាសថ្លែងថា៖
«ទោះទាំងពួកទេវតាដែលមិនបានរក្សាសណ្ឋានដើមរបស់ខ្លួន គឺជាទេវតា
ដែលបោះបង់ទីលំនៅចេញ នោះទ្រង់បានឃុំក្នុងសេចក្តីងងឹត ទាំងជាប់
ចំណងអស់កល្បជានិច្ច ទុកសម្រាប់នឹងជំនុំជម្រះនៅថ្ងៃដ៏ធំនោះ»។
យូដាស ៦។

នៅចុងអំឡុងពេល១០០០ឆ្នាំ ការរស់ឡើងជាលើកទីពីរនឹងកើត
មានឡើង។ ពេលនោះពួកអ្នកទុច្ចរិតនឹងរស់ឡើងវិញ ហើយក៏លេចនៅ
ចំពោះព្រះ សម្រាប់ទទួលការប្រតិបត្តិនៃសេចក្តីជំនុំជម្រះដែលបានកត់ទុក។
ទំនុកតំកើង ១៤៩:៩។ ព្រះដែលជាអ្នកបើកសម្តែងមានបន្ទូលដូច្នេះថា៖
«តែមនុស្សស្លាប់ឯទៀត មិនបានរស់វិញទេ ទាល់តែផុតពីមួយពាន់ឆ្នាំនោះ
ទៅ»។ វិវរណៈ ២០:៥។ ស្តីពីពួកអ្នកទុច្ចរិតវិញ ហោរាអេសាយថ្លែងថា៖ «គេ
នឹងត្រូវប្រមូលគ្នាដូចជាឈ្លើយដែលប្រមូលទុកក្នុងរំលុង ហើយនឹងត្រូវឃុំ
នៅក្នុងគុក *ក្រោយមកជាយូរថ្ងៃ គេត្រូវរងទោស*»។ អេសាយ ២៤:២២។

សន្តិភាពអស់កល្បជានិច្ច មហាវិវាទត្រូវបានបញ្ចប់

<u>ពុធ-២៧ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៦២

ខព្រះគម្ពីរប្រចាំថ្ងៃ: *ចូរឲ្យតាំងព្រះគ្រីស្ទឡើង ជាបរិសុទ្ធ នៅក្នុងចិត្តអ្នករាល់គ្នា ទុកជាព្រះអម្ចាស់ចុះ ហើយឲ្យប្រុងប្រៀបជានិច្ច ដោយសុភាព ហើយកោតខ្លាច ដើម្បីនឹងតបឆ្លើយដល់អ្នកណាដែលសួរពីហេតុនៃសេចក្ដីសង្ឃឹមរបស់អ្នករាល់គ្នា ។ ពេត្រុសទី១ ៣:១៥*

នៅទីបំផុតនៃ១០០០ឆ្នាំ ព្រះគ្រីស្ទយាងមកកាន់ផែនដី ដោយមានការហែហមអំពីពួកអ្នកប្រោសលោះ និងពួកទេវតាទាំងសល់សែន។ ទ្រង់បានដាស់ពួកអាក្រក់ឱ្យរស់ឡើង ដើម្បីទទួលវាសនាអាក្រក់របស់ខ្លួន។ គេចេញមកមានចំនួនរាប់មិនអស់ ប្រៀបដូចជាខ្សាច់សមុទ្រ មានទាំងស្លាកស្នាមជំងឺរោគា និងសេចក្ដីស្លាប់។ មានភាពផ្ទុយស្រឡះអំពីអស់អ្នកដែលបានរស់ឡើងនៅលើកទីមួយ។

គ្រប់ទាំងភ្នែកបានបែរទៅមើលសេរីរុងរឿងនៃព្រះរាជបុត្រារបស់ព្រះ។ ពួកអាក្រក់ឧទានឡើងមួយសំឡេងដូចគ្នាថា៖ «ព្រះអង្គដែលយាងមកដោយនូវព្រះនាមព្រះអម្ចាស់ ទ្រង់ប្រកបដោយព្រះពរ»។ ម៉ាថាយ ២៣:៣៩។ ពាក្យទាំងនេះពុំបានបណ្តាលមកដោយសេចក្ដីស្រឡាញ់ទេ គឺជាកម្លាំងនៃសេចក្ដីពិតដែលជំរុញពាក្យទាំងនេះឱ្យចេញអំពីបបូរមាត់ដ៏គ្មានបំណង។ ក៏ដូចគ្នាដែរនៅពេលដែលពួកអាក្រក់បានចូលទៅក្នុងផ្នូរជាយ៉ាងណា គេក៏ចេញមកជាយ៉ាងនោះដែរ គឺមានភាពជាខ្មាំងសត្រូវចំពោះព្រះគ្រីស្ទ និងប្រកបដោយវិញ្ញាណប្រឆាំងបះបោរដដែល។ គ្មានរយៈពេលទុក

ឱ្យប្រែចិត្តណាទៀត សម្រាប់ឱ្យពួកគេព្យាបាលជីវិតចាស់បានឡើយ។

ហោរាថ្លែងថា៖ «នៅថ្ងៃនោះ ព្រះបាទទ្រង់នឹងជាន់លើភ្នំដើមអូលីវ... ហើយភ្នំដើមអូលីវនឹងត្រូវពុះញែកជាពីរ»។ សាការី ១៤:៤។ នៅពេលទីក្រុងយេរូសាឡិមថ្មីចុះមកអំពីស្ថានសួគ៌មកតាំងនៅលើទីកន្លែងដែលបានរៀបចំហើយជាស្រេចនោះ ព្រះគ្រីស្ទរួមជាមួយព្រះអង្គហើយនិងពួកទេវតា នាំគ្នាចូលទីក្រុងបរិសុទ្ធនោះ។

កាលបើត្រូវបានកាត់ចេញអំពីការងារឆបោកហើយ មេកំណាចមានការស្រពន់ចិត្ត ហើយអស់សង្ឃឹមជាខ្លាំង ប៉ុន្តែនៅពេលដែលពួកអាក្រក់ដែលបានស្លាប់ត្រូវបានរស់ឡើងវិញហើយនោះ វាក៏ឃើញមានមនុស្សដ៏សន្ធឹកសន្ធាប់នៅខាងវា វាក៏មានសង្ឃឹមឡើងវិញ ហើយប្តេជ្ញាមិនព្រមបញ្ចប់មហាវិវាទ។ វានឹងបញ្ជាពួកបាត់បង់នៅក្រោមទង់របស់វា។ ក្នុងការបដិសេធព្រះគ្រីស្ទ ពួកគេបានទទួលយកបទបញ្ជារបស់មេបះបោរ ហើយត្រៀមខ្លួនចាំធ្វើតាមបង្គាប់របស់វា។ ដូចឧបាយកលដ៏ប៉ិនប្រសប់តាំងពីដំបូងដែរ វាមិនទទួលស្គាល់ថាខ្លួនវាជាសាតាំងទេ។ វាអះអាងថាវាជាម្ចាស់ដ៏ត្រឹមត្រូវនៃលោកីយ៍ ព្រោះគេដណ្តើមមតិកអំពីវាដោយខុសច្បាប់។ វាតាំងខ្លួនវាជាអ្នកប្រោសលោះ ដោយបញ្ជាក់ប្រាប់ពួករណបរបស់វាទាំងប៉ុន្មានដែលវាបានឆបោកថា មហិទ្ធិឫទ្ធិរបស់វាបាននាំពួកគេឱ្យចេញអំពីផ្នូរ។ សាតាំងធ្វើឱ្យអ្នកទន់ខ្សោយមានកម្លាំងឡើង ហើយបណ្តាលចិត្តទាំងអស់គ្នា ដោយថាមពលរបស់វាផ្ទាល់ ដើម្បីដឹកនាំពួកគេទៅចាប់យកទីក្រុងរបស់ព្រះ។ វាចង្អុលទៅឯមនុស្សដ៏រាប់មិនអស់ ដែលបានរស់ពីស្លាប់ឡើងវិញ រួចប្រកាសថា ក្នុងនាមជាអ្នកដឹកនាំ វាមានសមត្ថភាពយកបល្ល័ង្ក និងនគរមកវិញបាន។

នៅក្នុងបណ្តាមនុស្សកុះករដ៏ល្វឹងល្វើយនោះ មានជាតិសាសន៍ដែលរស់នៅតាំងពីមុនទឹកជំនន់ជាមនុស្សដែលមានកម្ពស់ដ៏ខ្ពស់ ហើយមានបញ្ញាឈ្លាសវៃដ៏សម្បើម ជាមនុស្សដែលចេះធ្វើកិច្ចការដ៏អស្ចារ្យដែលនាំលោកីយ៍ឱ្យសរសើរតម្កើងការប៉ិនប្រសប់របស់ខ្លួន ប៉ុន្តែ ការដែលគេបង្កើត

នូវអ្វីដែលយោរយៅ និងអាក្រក់អាក្រី បានបណ្តាលឱ្យព្រះបំបាត់គេចេញ អំពីការបង្កបង្កើតរបស់ព្រះអង្គ។ មានពួកស្តេច និងពួកមេទ័ពធំៗដែលមិន ធ្លាប់ចាញ់សង្គ្រាមសោះ។ ពេលស្លាប់ទៅ ពួកនេះមិនបានផ្លាស់ប្តូរទេ។ នៅ ពេលចេញពីផ្នូរមក ពួកគេនៅតែមានសេចក្តីប៉ងប្រាថ្នាចង់ដណ្តើមយក ដូច ដែលបានគ្រប់គ្រងពួកគេ កាលគេក្បាយជីវិតនោះដែរ។

ការខាយសម្រុកចុងក្រោយទាស់នឹងព្រះ

សាតាំងបានពិគ្រោះជាមួយពួកខ្លាំងពូកែទាំងនេះ។ ពួកគេពោលថា កងទ័ពនៅក្នុងទីក្រុងប្រៀបធៀបទៅតូចជាងកងទ័ពរបស់ពួកគេទេ ហើយ ពួកគេអាចយកឈ្នះបាន។ ពួកសិប្បករដ៏មានជំនាញការ នាំគ្នាផលិត ឧបករណ៍សង្គ្រាម។ ពួកមេទ័ព បញ្ជាពួកអ្នកធ្វើសង្គ្រាមឱ្យទៅតាមក្រុម និង តាមផ្នែក។

នៅទីបំផុតក៏មានបទបញ្ជាឱ្យឈានទៅមុខ ហើយចំនួនដ៏រាប់មិន អស់ក៏ចេញទៅ ជាកងទ័ពមួយដែលកងទ័ពរួមគ្នាគ្រប់ទាំងជំនាន់នៅតែពុំ អាចស្មើបាន។ សាតាំងដឹកនាំពួកស្តេច និងពួកប្រដាប់អាវុធនៅក្នុងជួរទ័ព របស់វា។ ដោយដឹងទីដៅប្រយុទ្ធប្រាកដហើយ ពួកកងទ័ពតាមលំដាប់ ស័ក្តិយស ចេញទៅពេញលើផ្ទៃផែនដីដែលបាក់បែក សំដៅទៅរកទីក្រុង របស់ព្រះ។ ដោយព្រះបន្ទូលបង្គាប់របស់ព្រះយេស៊ូវ ខ្លោងទ្វារនៃទីក្រុង យេរូសាឡិមថ្មីក៏បានបិទជិត ហើយកងទ័ពទាំងប៉ុន្មានរបស់សាតាំងបាន ហ៊ុមព័ទ្ធទីក្រុង ត្រៀមខ្លួនជាស្រេចដើម្បីចាប់ផ្តើមប្រយុទ្ធ។

ឥឡូវនេះព្រះយេស៊ូវទ្រង់លេចមកឱ្យពួកសត្រូវរបស់ព្រះអង្គបាន ឃើញ។ នៅលើគ្រឹះមាសដ៏រលោងខាងលើទីក្រុងដ៏ខ្ពស់នោះ មានបល្ល័ង្ក មួយ។ ព្រះរាជបុត្រានៃព្រះ គង់លើបល្ល័ង្កនេះ ហើយប្រជារាស្ត្រនៃនគរ របស់ព្រះអង្គនៅព័ទ្ធជុំវិញ។ សិរីរុងរឿងនៃព្រះវរបិតាដ៏អស់កល្ប ស្រោប ជុំវិញព្រះរាជបុត្រា។ ពន្លឺភ្លឺចិញ្ចែងនៃវត្តមានរបស់ព្រះអង្គ ចាំងជះចេញពី ខ្លោងទ្វារ ជោរជន់ផែនដីដោយកាំរស្មីភ្លឺចិញ្ចែងចិញ្ចាច។

នៅជិតបល្ល័ង្កជាងគេ គឺជាពួកអ្នកដែលធ្លាប់បានខ្ជាប់ខ្ជួនក្នុងដំណើរការបស់សាតាំង ប៉ុន្តែត្រូវបានដកចេញ ដូចដកកន្ទុយឧសចេញពីភ្លើងកំពុងឆេះ ហើយបានដើរតាមព្រះអង្គសង្គ្រោះ ដោយចិត្តលះបង់យ៉ាងខ្លាំង។ បន្ទាប់ពីនោះ ជាពួកអ្នកមានចរិតលក្ខណៈគ្រប់លក្ខណ៍ នៅក្នុងកណ្តាលចំណោមពួកខុសឆ្គង និងពួកកំជិត ជាពួកអ្នកដែលបានលើកតម្កើងក្រឹត្យវិន័យរបស់ព្រះក្នុងពេលដែលលោកីយ៍យកក្រឹត្យវិន័យនោះធ្វើជាអសារបង់ ហើយនិងមនុស្សរាប់លាននាក់នៅគ្រប់ជំនាន់ ដែលបានប្តូរផ្តាច់ចំពោះសេចក្តីជំនឿរបស់ខ្លួន។ ហួសពីនោះទៀតគឺជា «មនុស្សមួយហ្វូងយ៉ាងធំដែលគ្មានអ្នកណាអាចនឹងរាប់អស់ឡើយ គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា...ទាំងពាក់អាវសវែង ហើយកាន់ធាងចាកនៅដៃ»។ វិវរណៈ ៧:៩។ ចម្បាំងរបស់គេបានបញ្ចប់ទៅ គេក៏មានជ័យជម្នះ។ ធាងចាកជានិមិត្តរូបអំពីជ័យជម្នះ អាវសវែងជារូបសញ្ញាអំពីភាពសុចរិតនៃព្រះគ្រីស្ទដែលជារបស់ផងគេនៅពេលនេះ។

<u>ព្រហស្បតិ៍-២៨ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៦៣

ខព្រះគម្ពីរប្រចាំថ្ងៃ: *រីឯចុងបំផុតនៃរបស់ទាំងអស់ នោះជិតដល់ហើយ ដូច្នេះ ចូរឲ្យមានគំនិតនឹងធឹង ហើយចាំយាមក្នុងសេចក្តីអធិស្ឋានចុះ ។*
ពេត្រុសទី១ ៤:៧

នៅក្នុងបណ្តាមនុស្សទាំងអស់នោះ គ្មាននរណាម្នាក់ហ៊ានអះអាងថាខ្លួនបានទទួលសេចក្តីសង្គ្រោះ ដោយសារអំពើល្អរបស់ខ្លួនឡើយ។ ក៏ពុំមាននិយាយអំពីអ្វីដែលខ្លួនបានទទួលរងឈឺចាប់ដែរ ទំនុកដ៏សំខាន់នៃរាល់ទាំងបទនគររាជ គឺសេចក្តីសង្គ្រោះជារបស់ព្រះនៃយើងនិងកូនចៀម។

ការកាត់ទោសត្រូវបានប្រកាសចំពោះពួកបះបោរ

ពិធីបំពាក់មកុដដល់ព្រះរាជបុត្រានៃព្រះ ត្រូវប្រព្រឹត្តឡើងនៅចំពោះ

វត្តមាននៃការប្រមូលផ្តុំដ៏កុះករបស់សត្វលោកនៃផែនដី និងស្ថានសួគ៌។ ឥឡូវនេះស្តេចនៃអស់ទាំងស្តេច ដែលប្រកបដោយមហិទ្ធិឫទ្ធិនិងព្រះចេស្តាដ៏ឧត្តម ទ្រង់ប្រកាសកាត់ទោសដល់ពួកបះបោរ ដែលបានបំបាក្រឹត្យវិន័យព្រះអង្គ ព្រមទាំងជិះជាន់ដល់បណ្តាជនរបស់ទ្រង់។ «ខ្ញុំក៏ឃើញបល្ល័ង្កសមួយយ៉ាងធំ និងព្រះអង្គដែលគង់លើផែនដីនិងផ្ទៃមេឃក៏រត់ពីចំពោះទ្រង់ចេញ ឥតឃើញមានកន្លែងណាឱ្យនៅទៀតឡើយ នោះខ្ញុំក៏ឃើញមនុស្សស្លាប់ ទាំងអ្នកធំ ទាំងអ្នកតូច គេឈរនៅចំពោះព្រះ។ បញ្ជីក៏បានបើកឡើង ហើយបញ្ជី១ទៀត គឺជាបញ្ជីជីវិតបានបើកឡើងដែរ រួចមនុស្សស្លាប់ទាំងអស់ត្រូវជំនុំជម្រះ ពីសេចក្តីកត់ទុកក្នុងបញ្ជីទាំងនោះ តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន»។ វិវរណៈ ២០:១១,១២។

នៅពេលដែលព្រះនេត្រព្រះយេស៊ូវទតទៅលើពួកអាក្រក់ ពួកគេបានភ្ញាក់ដឹងខ្លួននូវរាល់អំពើបាបដែលខ្លួនធ្លាប់បានប្រព្រឹត្ត។ គេបានឃើញពីការដែលជើងរបស់គេបានទាសចេញអំពីផ្លូវនៃភាពសុចរិត។ សេចក្តីល្បួងលួងលោមដែលពួកគេពេញចិត្តដោយការបណ្តោយខ្លួនក្នុងអំពើបាប សេចក្តីស្អប់ខ្ពើមដល់អ្នកនាំសាររបស់ព្រះ សេចក្តីបដិសេធនូវការព្រមានដាស់តឿន និងរលកនៃសេចក្តីមេត្តាករុណាដែលបានច្រានទៅវិញដោយចិត្តមិនព្រមផ្លាស់ប្រែ និងចិត្តរឹងចចេសទាំងអស់នេះ លេចធ្លោឡើងហាក់បីដូចជាបានចារនៅក្នុងអក្សរនៃអណ្តាតភ្លើង។

នៅពីខាងលើបល្ល័ង្ក មានបើកសម្តែងឱ្យឃើញឈើឆ្កាង។ ផ្ទាំងទិដ្ឋភាពមួយក៏លេចឡើង បញ្ជាំងទស្សនីយភាពនៃការធ្លាក់មានបាបរបស់លោកអ័ដាម ហើយនិងដំណាក់ការបន្តបន្ទាប់នៅក្នុងផែនការនៃសេចក្តីប្រោសលោះ។ កំណើតដ៏រាបទាបរបស់ព្រះអង្គសង្គ្រោះ ព្រះជន្មរស់នៅដ៏សាមញ្ញ ពិធីជ្រមុជទឹកក្នុងទន្លេយ័រដាន់ ការតមអត់ និងសេចក្តីល្បួងល្បងនៅក្នុងទីរហោស្ថាន ការងាររបស់ទ្រង់ដែលបើកព្រះពរស្ថានសួគ៌ឱ្យដល់មនុស្ស ទិវាដ៏ពោរពេញទៅដោយសេចក្តីមេត្តាករុណា រាត្រីនៃសេចក្តីអធិស្ឋាន

នៅលើភ្នំ ការលបធ្វើឃាតដោយសេចក្តីច្រណែនឈ្នានីសដែលបានសង
ន្លូវបំណាច់របស់ទ្រង់ ការចុកចាប់ដ៏អាថិកំបាំងនៅក្នុងសួនច្បារកេតសេម៉ានី
នៅក្រោមទម្ងន់នៃអំពើបាបរបស់លោកីយ៍ ការក្បត់ដោយបានប្រគល់ទៅឱ្យ
ពួកឃាតករ ព្រឹត្តិការណ៍ដ៏សែនរន្ធត់នារាត្រីនោះ អ្នកទោសដែលត្រូវបោះ
បង់ចោលដោយពួកសិស្ស ការជាប់ចោទនៅក្នុងដំណាក់សង្ឃជាន់ខ្ពស់ នៅ
ក្នុងសាលាជំនុំជម្រះរបស់ពីឡាត់ នៅចំពោះមុខស្តេចហេរ៉ូឌដ៏កំសាកត្រូវ
ទទួលការចំអកមើលងាយ ការនិយាយបញ្ឆិ ការដាក់ទារុណកម្ម ហើយ
កាត់ទោស ប្រហារជីវិតទៀតផងទាំងអស់នេះសុទ្ធតែបានបង្ហាញ
យ៉ាងច្បាស់។

ឥឡូវនេះ នៅចំពោះមុខពួកមនុស្សដែលមានចិត្តអរោ មានការបើក
សម្តែងឱ្យឃើញនូវទិដ្ឋភាពចុងក្រោយ៖ ព្រះអង្គដែលរងឈឺចាប់ទាំងអត់ធ្មត់
កំពុងយាងដំណើរទ្រេតទ្រោតនៅតាមផ្លូវទៅកាន់កាល់វ៉ារី ព្រះអម្ចាស់នៃ
ស្ថានសួគ៌ក្បួរជាប់នៅលើឈើឆ្កាង ពួកសង្ឃ និងពួកគ្រូពោលពាក្យមើល
ងាយដល់ការឈឺចាប់ដ៏ហួសល្បត់របស់ព្រះអង្គ ភាពងងឹតដ៏ហួសប្រមាណ
ដែលកត់ចំណាំនូវគ្រាដែលព្រះអង្គសង្គ្រោះនៃលោកីយ៍បានប្រគល់ព្រះជន្ម
ទ្រង់។

ទស្សនីយភាពដ៏គួរស្ញប់ស្ញែងបានលេចឱ្យឃើញតាមតែការដែល
បានកើតឡើង។ សាតាំង និងពួករណបរបស់វា គ្មានអំណាចបែរចេញអំពី
រូបភាពនោះបានឡើយ។ គួសម្តែងម្នាក់ៗ នឹងនឹកដល់ផ្នែកដែលខ្លួនបាន
សម្តែង។ ស្តេចហេរ៉ូឌដែលបានប្រល័យទារកដ៏ឥតមានទោសពៃរ៍នៅ
បេថ្លេហិម ស្តេចហេរ៉ូដាសដែលបានកម្ចាយឈាមយ៉ូហានបាទីស្ទ
ពីឡាត់ដ៏កម្សោយដែល ពន្យារពេលវេលា ពួកទាហានដែលចំអកឡកឡឺយ
ពួកមនុស្សលីលាដែលបាននាំគ្នាស្រែកឡើងថា «ចូរឱ្យឈាមវាធ្លាក់មកលើ
យើងរាល់គ្នា និងកូនចៅរបស់យើងចុះ» ទាំងអស់គ្នាខំគេចខ្លួនពីព្រះភ័ក្ត្រ
នៃព្រះករុណាទាំងឥត ប្រយោជន៍ ក្នុងពេលជាមួយគ្នានេះ ពួកដែល

ត្រូវបានប្រោសលោះដាក់មកុដ របស់ខ្លួនទៅទៀបព្រះបាទនៃព្រះអង្គ សង្គ្រោះ រួចឧទានថា «ទ្រង់បានសុគត សម្រាប់យើងខ្ញុំ»

មានមេទ័ពនេរ៉ូ ជាសត្វតិរច្ឆានខាងអំពើឃោរឃៅ និងបាបធម៌ កំពុង សម្លឹងមើលសេចក្តីថ្កុំថ្កើងនៃពួកអ្នកដែលគាត់ធ្លាប់បានអរសប្បាយចំពោះ ចិត្តខ្លោចផ្សារបស់គេ។ ម្តាយរបស់គាត់ ក៏ឃើញកិច្ចការរបស់ខ្លួនផ្ទាល់ដែរ ពោលគឺឃើញអំពីរបៀបដែលកិលេសទាំងឡាយ (ដែលបានចម្រើនមកអំពី ឥទ្ធិពល និងគំរូរបស់ខ្លួន) ហុចផលផ្លែជាឧក្រិដ្ឋកម្មដែលបណ្តាលឱ្យពិភព លោកញាប់ញ័រ។

<u>សុក្រ-២៩ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៦៥
ខព្រះគម្ពីរប្រចាំថ្ងៃ:*តែមុនដំបូងបង្អស់ ត្រូវឲ្យអ្នករាល់គ្នាមានសេចក្តី ស្រឡាញ់គ្នា ឲ្យអស់ពីចិត្ត ដ្បិតសេចក្តីស្រឡាញ់នឹងគ្របបាំងអំពើបាបជា អនេកអនន្ត។ ពេត្រុសទី១ ៤:៨*

មានពួកសង្ឃរបស់ប៉ាប និងពួកសង្គ្រាជដែលអះអាងខ្លួនថាជាទូត របស់ព្រះគ្រីស្ទ តែបានប្រើគ្រឿងយន្តដាក់ទណ្ឌកម្មទាញដៃជើង គុកងងឹត និងបង្គោលពិឃាត ដើម្បីគ្រប់គ្រងបណ្តាជនរបស់ព្រះអង្គ។ មានពួកស្តេច សង្ឃដ៏ក្រអឺត ដែលបានលើកតម្កើងខ្លួនឯងខ្ពស់ជាងព្រះ ហើយហ៊ានផ្លាស់ ប្តូរក្រឹត្យវិន័យរបស់ព្រះដ៏ខ្ពស់បំផុតផង។ ពួកអ្នកធំដ៏កំពុតទាំងនោះ ត្រូវឆ្លើយ ដល់ព្រះអំពីការដែលខ្លួនបានប្រព្រឹត្ត។ ហួសពេលហើយ នៅពេលព្រះដ៏ជ្រាប សព្វសារពើបង្ហាញឱ្យគេឃើញថាទ្រង់មានព្រះហឫទ័យប្រច័ណ្ឌ ចំពោះ ក្រឹត្យវិន័យរបស់ព្រះអង្គណាស់។ គេបានយល់ដឹងនៅពេលនេះ ថាព្រះគ្រីស្ទ យកព្រះទ័យទុកដាក់ ជាមួយរាស្ត្ររបស់ព្រះអង្គដែលរងឈឺចាប់។

លោកីយ៍ដ៏អាក្រក់ទាំងមូល ត្រូវជាប់ចោទដោយព្រោះអំពើក្បត់ដ៏កំពូល ទាស់នឹងការគ្រប់គ្រងនៃស្ថានសួគ៌។ គេពុំមានអ្វីនឹងអង្វរករចំពោះបុព្វហេតុ

របស់ខ្លួនឡើយ គេពុំមានអ្វីដោះសាទេ ហើយការកាត់ទោសឱ្យស្លាប់អស់កល្បជានិច្ច ត្រូវបានប្រកាសចំពោះពួកគេ។

ពួកអាក្រក់បានឃើញថាខ្លួនបានខាតបង់ដោយអំពើបះបោររបស់ខ្លួន។ «ទាំងអស់នេះហើយ» ព្រលឹងបាត់បង់ស្រែកឡើង «ដែលខ្ញុំត្រូវបាន។ ឱ សេចក្តីចម្អូតដ៏ចម្លែកអើយ! ខ្ញុំបានផ្លូវសុខសន្តិភាព សុភមង្គល និងកិត្តិយស មកយកសេចក្តីអន្តរាយ សេចក្តីអាប់ឱន និងសេចក្តីអស់សង្ឃឹមទៅវិញ»។ ពួកគេទាំងអស់គ្នាបានឃើញថា ការមិនបានបញ្ចូលទៅក្នុងស្ថានសួគ៌នោះ គឺយុត្តិធម៌ណាស់។ ពួកគេបានបញ្ជាក់ដោយជីវិតខ្លួនថា៖ «យើងនឹងពុំមានបុគ្គលនេះ ព្រះយេស៊ូវ គ្រងរាជ្យលើយើងឡើយ»។

សាតាំងឧទ្ធូលបរាជ័យ

ពួកអាក្រក់មើលទៅលើពិធីបំពាក់មកុដដល់ព្រះរាជបុត្រានៃព្រះទាំងស្រឡាំងកាំង។ ពួកគេឃើញនៅក្នុងព្រះហស្តព្រះអង្គ មានថ្មនៃក្រឹត្យវិន័យដ៏ពិសិដ្ឋពីរផ្ទាំងដែលពួកគេបានស្អប់ខ្ពើម។ ពួកនេះបានឃើញការផ្ទុះសំឡេងសរសើរតម្កើងអំពីពួកអ្នកបានសង្គ្រោះ នៅពេលដែលរលកតន្ត្រីដ៏ពីរោះស្រទន់បបោសមកលើហ្វូងបណ្តាជននៅខាងក្រៅទីក្រុង ទាំងអស់គ្នាឧទានឡើងថា «ឱ ស្តេចនៃអស់ទាំងសាសន៍អើយ ផ្លូវទ្រង់សុទ្ធតែសុចរិតហើយពិតត្រង់»។ ពួកគេក៏ទម្លាក់ខ្លួនផ្កាប់មុខថ្វាយបង្គំព្រះរាជបុត្រានៃជីវិត។ វិវរណៈ ១៥:៣។

សាតាំងហាក់ដូចជាស្ងិតដៃស្ងិតជើង។ វានឹកចាំនៅពេលវាបានធ្លាក់ចុះ ព្រោះកាលពីដើមជាទេវតាចេរូប៊ីនមួយរូប។ ក្រុមប្រឹក្សាដែលវាធ្លាប់មានកិត្តិយស ឥឡូវនេះវាមិនត្រូវរាប់បញ្ចូលនៅទីនោះទៀតជារៀងរហូត។ វាឃើញម្នាក់ទៀតកំពុងឈរនៅជិតព្រះវរបិតា ជាទេវតាមួយរូបដែលប្រកបដោយរស្មីដ៏អស្ចារ្យ។ វាដឹងថាតំណែងដ៏ខ្ពង់ខ្ពស់នៃទេវតា ត្រូវបានជារបស់វា តែបែរជាឥតបានទៅវិញ។

វាបាននឹកទៅដល់លំនៅដ៏គ្មានទោសសោះ ដល់សេចក្តីសុខ និង

ការស្អប់ចិត្តដែលជារបស់ផងវាដរាបដល់គ្រាបះបោររបស់វា។ វានឹកឃើញ ឡើងវិញនូវកិច្ចការ និងលទ្ធផលដែលវាបានធ្វើនៅក្នុងចំណោមមនុស្ស ភាព ជាខ្មាំងរបស់មនុស្សចំពោះមនុស្សផងគ្នា វិនាសកម្មដ៏ស្លុតរន្ធត់នៃជីវិត ការ រលំនៃរាជ្យបល្ល័ង្កទាំងឡាយ ភាពចលាចល ទំនាស់ និងបដិវត្តន៍ទាំងឡាយ។ វានឹកឃើញពីការដែលវាបានខិតខំប្រឆាំងនឹងកិច្ចការរបស់ព្រះគ្រីស្ទ។ នៅ ពេលវាពិនិត្យមើលផលផ្លែនៃការប្រឹងប្រែងដ៏ត្រដរខ្សល់របស់វា វាឃើញ បានត្រឹមតែបរាជ័យប៉ុណ្ណោះ។ ម្តងហើយ ម្តងទៀត នៅក្នុងវឌ្ឍនភាពនៃ មហាវិវាទ វាបានទទួលបរាជ័យហើយត្រូវបានបង្ខំឱ្យចុះចាញ់។

គោលបំណងនៃការបះបោរដ៏ធំ គឺដើម្បីបង្ហាញអំពីការគ្រប់គ្រងរបស់ ព្រះដែលទទួលខុសត្រូវចំពោះអំពើបះបោរ។ វាបានដឹកនាំមនុស្សម្នាដ៏សន្ធឹក សន្ធាប់ឱ្យទទួលនូវការបកស្រាយរបស់វា។ មេធ្យុំគំនិតនេះ បានយកការ ខុសឆ្គងមកបន្លំសេចក្តីពិត អស់រាប់ពាន់ឆ្នាំមកហើយ។ ប៉ុន្តែ ពេលវេលា បានមកដល់ហើយ ប្រវត្តិសាស្ត្រ និងចរិតលក្ខណៈរបស់សាតាំងនឹងត្រូវ បានលាតត្រដាងឱ្យគេឃើញ។ នៅក្នុងការខិតខំក្រោយបង្អស់ដើម្បីរំលង បល្ល័ង្កព្រះគ្រីស្ទ ដើម្បីបំផ្លាញបណ្តាជនព្រះអង្គ ហើយនិងដើម្បីចាប់យក ទីក្រុងរបស់ព្រះនោះ មេឆបោកក៏ត្រូវបានបើកមុខឱ្យឃើញយ៉ាងច្បាស់។ អស់អ្នកដែលបានរួបរួមជាមួយវា ក៏ឃើញសេចក្តីបរាជ័យទាំងស្រុងរបស់ វា។

សាតាំងបានឃើញថាអំពើបះបោរដ៏ស្ម័គ្រពីចិត្តរបស់ខ្លួន ពុំអាចឱ្យ ខ្លួនចូលនគរស្ថានសួគ៌បានទេ។ វាបានហ្វឹកហ្វឺនអំណាចរបស់វា ដើម្បីធ្វើ សង្គ្រាមតតាំងជាមួយព្រះ ភាពឥតខ្ចោះ និងសាមគ្គីភាពនៃនគរស្ថានសួគ៌ នឹងបានជាទារុណកម្មចំពោះវា។ វាឱនចុះសារភាពថាការកាត់ទោសដល់ខ្លួន នោះយុត្តិធម៌ណាស់។

<u>សៅរ៍-៣០ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៦៥

ខព្រះគម្ពីរប្រចាំសប្តាហ៍: *ចូរប្រព្រឹត្តនឹងគ្នាដោយសេចក្តីចៅរៅ ឥតមានត្អូញត្អែរឡើយ គឺដោយខំបំរើគ្នាទៅវិញទៅមក តាមអំណោយទានដែលគ្រប់គ្នាបានទទួលមក ទុកដូចជាអ្នកចែកចាយយ៉ាងល្អ នៃព្រះគុណដ៏បែកជាច្រើនផ្លូវវិញ។ ពេត្រុសទី១ ៤:៩-១០*

រាល់ទាំងសំណូរនៃសេចក្តីពិត និងការខុសឆ្គងនៅក្នុងវិវាទដ៏វែងឆ្ងាយ ក៏ត្រូវបានធ្វើឱ្យឃើញច្បាស់នៅពេលនេះ។ លទ្ធផលនៃការដាក់ចោលលក្ខន្តិក:របស់ព្រះទៅម្ខាង ក៏ត្រូវបានបើកត្រដាងឱ្យពិភពសាកលទាំងមូលបានឃើញដែរ។ ប្រវត្តិសាស្ត្រនៃអំពើបាបនឹងស្ថិតស្ថេររហូតដល់អស់ទាំងកល្បទុកជាទីបន្ទាល់ថា អស់ទាំងសត្វលោកដែលទ្រង់បានបង្កើតមកនោះ អាចទទួលបានសុភមង្គលដោយសារមានក្រឹត្យវិន័យរបស់ព្រះ។ ពិភពសាកលទាំងមូល ទាំងពួកស្មោះត្រង់ និងពួកបះបោរបានបន្លឺសំឡេងតែមួយថា «ផ្លូវទ្រង់សុទ្ធតែសុចរិត ហើយពិតត្រង់ ទ្រង់ជាស្តេចនៃអស់ទាំងសាសន៍»។

ពេលវេលាបានមកដល់ នៅពេលព្រះគ្រីស្ទត្រូវបានលើកសរសើរឱ្យខ្ពស់លើអស់ទាំងឈ្មោះ។ ដ្បិតមានអំណរនៅចំពោះទ្រង់ ដែលទ្រង់អាចនាំយកកូនជាច្រើនមកកាន់សិរីល្អ ទ្រង់បានទ្រាំទ្រឈើឆ្កាង។ ទ្រង់ទតទៅពួកដែលត្រូវបានប្រោសលោះ ដែលបានជាថ្មីឡើងវិញក្នុងរូបភាពរបស់ព្រះអង្គ។ ទ្រង់ឃើញនៅក្នុងគេនូវលទ្ធផលនៃការងារដ៏លំបាករបស់ព្រះវិញ្ញាណទ្រង់ ហើយទ្រង់ក៏បានស្កប់ព្រះទ័យ។ អេសាយ ៥៣:១១។ នៅក្នុងព្រះសូរសៀងដែលឲ្យដល់បណ្តាមនុស្ស ទាំងពួកសុចរិត និងពួកអាក្រក់ ទ្រង់មានបន្ទូលថា៖ «មើល នេះជាទំនិញនៃឈាមខ្ញុំ ដ្បិតគឺចំពោះអ្នកទាំងនេះហើយដែលខ្ញុំបានទទួលរងទោស ព្រមទាំងបានស្លាប់ទៀតផង»។

ការបញ្ចប់ដោយហិង្សានៃពួកអាក្រក់

ចរិតលក្ខណៈរបស់សាតាំងនៅតែឥតផ្លាស់ប្តូរ។ ការបះបោរដូចជាទឹកជ្រោះធំ ក៏ផុសឡើងម្តងទៀត។ វាប្តេជ្ញាមិនចុះចាញ់នូវការតស៊ូចុងក្រោយទាស់នឹងព្រះមហាក្សត្រនៃស្ថានសួគ៌។ វាស្ទុះទៅក្នុងចំណោមពួករណបវា ហើយខិតខំបំផុសបំផុលពួកគេដោយកំហឹង ឱ្យចាប់ផ្តើមប្រយុទ្ធជាបន្ទាន់។ ប៉ុន្តែ ចំពោះមនុស្សទាំងសល់សែនដ៏រាប់មិនអស់ដែលវាបានល្បួងឱ្យចូលក្នុងអំពើបះបោរ ឥឡូវនេះពុំមាននរណាម្នាក់ទទួលស្គាល់ឧត្តមភាពរបស់វាទេ។ វាអស់អំណាចហើយ។ ពួកអាក្រក់មានចិត្តពោរពេញទៅដោយសេចក្តីសម្អប់របស់សាតាំង ស្មើគ្នានឹងសាតាំងដែលមានសេចក្តីសម្អប់ដល់ព្រះដែរ គេបានឃើញថាករណីរបស់ខ្លួនពុំមានសង្ឃឹមសោះឡើយ។ គម្រោងរបស់គេក៏ឆេះឆួលឡើងទាស់នឹងសាតាំង និងអស់អ្នកដែលបានធ្វើជាភ្នាក់ងារក្នុងការបោកបញ្ឆោតរបស់វា ហើយគេបែរមកពួកទាំងនោះដោយកំហឹងកំបុតត្បូងនៃបិសាច។ «ដោយព្រោះឯងបានតាំងចិត្តឱ្យបានដូចជាព្រះហឫទ័យនៃព្រះ នោះមើល អញនឹងនាំសាសន៍ដទៃ គឺជាពួកអ្នកគួរស្ញែងខ្លាច នៅកណ្តាលគ្រប់ទាំងសាសន៍មកលើឯង៖ គេនឹងហូតដាវទៅទាស់នឹងលម្អនៃប្រាជ្ញារបស់ឯង ព្រមទាំងបង្អាប់រស្មីរបស់ឯងផង។ គេនឹងទម្លាក់ឯងទៅក្នុងជង្ហុកធំ...។ ឱ ចេរូប៊ីនដែលគ្របបាំងអើយ អញបានបំផ្លាញឯងចេញពីកណ្តាលថ្មភ្លឺចាំងនោះទៅ...។ អញបានបោះឯងចុះដល់ដី ព្រមទាំងដាក់ឯងនៅមុខពួកស្តេចឱ្យគេបានពិចារណាឯង...។ អញបានឱ្យឯងទៅជាផេះនៅលើផែនដីនៅចំពោះភ្នែកនៃអស់អ្នកដែលបានឃើញឯង...។ ឯងបានត្រឡប់ជាទីស្ញែងខ្លាច ហើយលែងមាននៅជាដរាបទៅ»។ អេសេគាល ២៨:៦-៨; ១៦-១៩។

«ព្រះយេហូវ៉ាទ្រង់មានសេចក្តីគ្នាន់ក្នាញ់នឹងគ្រប់ទាំងសាសន៍»។ «ទ្រង់នឹងបង្អុរឱ្យភ្លៀងជាអន្ទាក់មកលើមនុស្សអាក្រក់ គឺជាភ្លើងឆេះនឹងស្ពាន់ធ័រ ហើយខ្យល់ក្តៅក្រហាយនោះ នឹងបានជាចំណែកក្នុងពែងរបស់គេ»។

អេសាយ ៣៤:២; ទំនុកតំកើង ១១:៦។ ភ្លើងក៏ចុះមកអំពីព្រះចេញពីស្ថានសួគ៌។ ផែនដីត្រូវបែកបាក់។ អណ្តាតភ្លើងដ៏សន្ធោសន្ធៅផុសចេញមកពីគ្រប់ទាំងក្រហែងដីដែលរបើកបាក់នោះ។ ថ្មទាំងឡាយក៏ឆេះឡើង។ ធាតុទាំងឡាយរលាយដោយកម្តៅដ៏ក្តៅក្រៃលែង ហើយផែនដី និងរបស់សព្វសារពើក៏បានឆេះឡើង។ ធាតុទាំងឡាយរលាយដោយកម្តៅដ៏ក្តៅក្រៃលែង ហើយផែនដី និងរបស់សព្វសារពើ ក៏បានឆេះអស់រលីងទៅ។ ពេត្រុសទី២ ៣:១០។ សំបកផែនដីហាក់ដូចជាដុំភ្លើងដែលរលាយមួយ ជាបឹងភ្លើងពុះកញ្ជ្រោលដ៏ល្វឹងល្វើយមួយ។ គឺ «ទ្រង់មានថ្ងៃសម្រាប់សងសឹក មានឆ្នាំសម្រាប់ស្នងដល់គេ ជំនួសក្រុងស៊ីយ៉ូន»។ អេសាយ ៣៤:៨។

ពួកអាក្រក់ត្រូវទទួលទណ្ឌកម្មទៅ «តាមអំពើដែលគេបានប្រព្រឹត្ត»។ សាតាំងត្រូវរងទុក្ខវេទនាមិនគ្រាន់តែសម្រាប់អំពើបះបោររបស់ខ្លួនតែប៉ុណ្ណោះទេ គឺសម្រាប់អស់ទាំងអំពើបាបដែលវាបណ្តាលឱ្យបណ្តាជននៃព្រះបានប្រព្រឹត្តផង។ ពួកអាក្រក់ត្រូវបានបំផ្លាញឱ្យវិនាសបង់ជាទីបញ្ចប់នៅក្នុងភ្លើង ទាំងឫស និងមែក សាតាំងជាឫស អ្នកដើរតាមវាជាមែក។ ពិន័យដ៏ពេញលេញនៃក្រឹត្យវិន័យត្រូវបានអនុវត្ត ការទាមទារឱ្យមានយុត្តិធម៌ត្រូវបានសម្រេច។ ការងារបំផ្លិចបំផ្លាញរបស់សាតាំងត្រូវបានបញ្ចប់ទៅជារៀងរហូត។ ហើយសត្វលោករបស់ព្រះត្រូវបានរំដោះចេញអំពីសេចក្តីល្បួងល្បងរបស់សាតាំងជារៀងរហូតទៅដែរ។

នៅពេលដែលផែនដីត្រូវស្រោបទៅដោយភ្លើង ពួកសុចរិតរស់នៅដោយផុតទុក្ខភ័យនៅក្នុងទីក្រុងបរិសុទ្ធ។ ក្នុងពេលដែលព្រះទ្រង់ជាភ្លើងឆាបឆេះដល់ពួកអាក្រក់ ទ្រង់ក៏ជាកំផែងការពារដល់រាស្ត្ររបស់ផងទ្រង់ដែរ។ សូមអានវិវរណៈ ២០:៦; ទំនុកតំកើង ៨៥:១១។

«រួចខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី៖ ដ្បិតផ្ទៃមេឃមុន និងផែនដីមុនបានកន្លងបាត់ទៅហើយ»។ វិវរណៈ ២១:១។ ភ្លើងដែលបញ្ឆេះពួកអាក្រក់បានសម្អាតផែនដី។ រាល់ទាំងស្នាមនៃបណ្តាសាត្រូវបានបោសចេញ។ ពុំ

មានភ្លើងនរកដ៏ឆេះអស់កល្បជានិច្ច នឹងឆេះនៅមុខពួកអ្នកដែលត្រូវបានប្រោសលោះ ដើម្បីឱ្យគេខ្លាចកម្មនៃអំពើបាបនោះឡើយ។

សេចក្តីរំលឹកអំពីការជាប់ឆ្កាង

មានតែរបស់មួយទេដែលត្រូវរំលឹក៖ ព្រះអង្គប្រោសលោះរបស់យើងនឹងនៅតែមានស្លាកស្នាមនៃការជាប់ឆ្កាងរបស់ព្រះអង្គ គឺជាស្នាមនៃកិច្ចការដ៏ឃោរឃៅដែលអំពើបាបបានធ្វើ។ រហូសនៃកាល់វ៉ារីនឹងបង្ហាញការសរសើរព្រមទាំងបញ្ជាក់នូវអំណាចព្រះចេស្តារបស់ព្រះអង្គ នៅទូទាំងយុគដ៏អស់កល្បជានិច្ច។

ព្រះគ្រីស្ទបានបញ្ជាក់ដល់ពួកសិស្សព្រះអង្គថា ទ្រង់បានយាងទៅរៀបចំកន្លែងសម្រាប់ពួកគេនៅក្នុងដំណាក់ព្រះវរបិតា។ ភាសាមនុស្សជាតិពុំអាចពិពណ៌នាអំពីរង្វាន់នៃពួកសុចរិតបានឡើយ។ គឺបានស្គាល់តែអ្នកណាដែលឃើញប៉ុណ្ណោះ។ គ្មានសតិដែលមានកំណត់ណា អាចយល់នូវសិរីរុងរឿងនៃស្ថានសួគ៌របស់ព្រះបានទេ។

នៅក្នុងព្រះគម្ពីរ មរតករបស់អ្នកបានសង្គ្រោះបានហៅថា «ស្រុក»។ ហេព្រើរ ១១:១៤-១៦។ នៅទីនោះ ព្រះអង្គដ៏ជាអ្នកគង្វាលនៃស្ថានសួគ៌ នឹងនាំហ្វូងចៀមរបស់ទ្រង់ទៅកាន់ប្រភពទឹកមានជីវិត។ មានផ្លូវទឹកហូរថ្លាដូចកែវចរណៃ ហើយនៅក្បែរនោះ មានដើមឈើបក់រំភើយចោលស្រមោលមកលើផ្លូវដើរ ដែលបានរៀបចំសម្រាប់ពួកអ្នកដែលត្រូវបានបង់ថ្លៃលោះរបស់ព្រះអម្ចាស់។ ទីវាលធំល្វឹងល្វើយលាតសន្ធឹងឡើងទៅទួលភ្នំនៃសោភណភាព ហើយភ្នំទាំងឡាយរបស់ព្រះ ងើបកំពូលឡើងខ្ពស់ត្រដែត។ នៅលើវាលដ៏ក្សេមក្សាន្តទាំងនោះ ក្បែរទឹកជ្រោះរស់រាស្ត្ររបស់ព្រះ ដែលជាអ្នកធ្វើធម្មយាត្រា និងដំណើរតត្រុកដ៏វែងឆ្ងាយ ក៏រកបានទីលំនៅ។

«គេនឹងសង់ផ្ទះ ហើយអាស្រ័យនៅផង ក៏នឹងដាំចម្ការទំពាំងបាយជូរ ហើយនិងបរិភោគផលដែរ។ គេនឹងមិនសង់ រួចមានម្នាក់ទៀតអាស្រ័យ ឬដាំ រួចមានម្នាក់ទៀតបរិភោគផលនោះឡើយ...។ ហើយពួករើសតាំងរបស់

អញ នឹងប្រើប្រាស់ការដែលដៃគេធ្វើ»។ «ទីរហោស្ថាន ហើយទីហួតហែង មានសេចក្តីអំណរ ឯសមុទ្រខ្សាច់នឹងរីករាយ ហើយផ្កាឡើងដូចជាកុលាប»។ «ឆ្កែព្រៃនឹងនៅជាមួយកូនចៀម ឯខ្លារខិននឹងដេកនៅជាមួយនិងកូនពពែ... ហើយក្មេងតូចៗ ជាអ្នកគង្វាលវា...។ វារាល់គ្នានឹងមិនធ្វើទុក្ខ ឬបំផ្លាញគ្នា នៅគ្រប់លើភ្នំបរិសុទ្ធរបស់អញ» ឡើយ។ អេសាយ ៦៥:២១,២២; ៣៥:១; ១១:៦,៩។

<u>អាទិត្យ-៣១ តុលា</u> អំណាន ព្រះគម្ពីរប្រចាំថ្ងៃ៖ អេសាយ ជំពូក ៦៦

ខព្រះគម្ពីរប្រចាំថ្ងៃ: *ដ្បិតពេលវេលាដែលសេចក្តីជំនុំជំរះត្រូវចាប់ផ្តើមពីដំណាក់នៃព្រះទៅ នោះបានមកដល់ហើយ បើសិនជាចាប់តាំងពីយើងរាល់គ្នាជាមុនដូច្នេះ នោះតើចុងបំផុតរបស់ពួកអ្នក ដែលមិនជឿតាមដំណឹងល្អនៃព្រះ នឹងបានយ៉ាងដូចម្តេចទៅ។ ពេត្រុសទី១ ៤:១៧*

ការឈឺចាប់អាចកើតមាននៅស្ថានសួគ៌បានទេ។ នឹងពុំមានទឹកភ្នែក ឬការហៅខ្មោចទៀតឡើយ។ «នឹងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោក សង្រេង ឬសេចក្តីយំទួញ៖...ដ្បិតសេចក្តីមុនទាំងប៉ុន្មានបានកន្លងបាត់ទៅហើយ»។ «ឯពួកអ្នកដែលនៅក្នុងក្រុង គេនឹងមិនដែលថាឈឺទៀតឡើយ ព្រះទ្រង់នឹងអត់ទោសចំពោះអំពើទុច្ចរិតរបស់ប្រជាជនផង»។ វិវរណៈ ២១:៤; អេសាយ ៣៣:២៤។

មានទីក្រុងយេរូសាឡិមថ្មី ជាទីក្រុងធំនៃផែនដីថ្មីដ៏មានសិរីរុងរឿង។ «ពន្លឺរស្មីរបស់ទីក្រុងនោះក៏ដូចជាត្បូងមានតម្លៃថ្លៃវិសេស គឺដូចជាត្បូងមណីជោតិ ហើយដូចជាកែវចរណៃ»។ «អស់ទាំងសាសន៍ដែលត្រូវបានសង្គ្រោះនឹងដើរក្នុងពន្លឺក្រុងនោះ អស់ទាំងស្តេចនៅផែនដី ក៏យកសិរីល្អនៃកិត្តិយសខ្លួនមកទុកក្នុងក្រុងនោះដែរ»។ «រោងឧបោសថរបស់ព្រះបាននៅជាមួយមនុស្ស ហើយទ្រង់នឹងគង់នៅជាមួយគេ គេនឹងធ្វើជារាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ក៏នឹងធ្វើជាព្រះដល់គេ»។ វិវរណៈ ២១:១១,២៤,៣។

នៅក្នុងទីក្រុងនៃព្រះ «នឹងឥតមានយប់ទៀតឡើយ»។ វិវរណៈ ២២:៥។ នឹងគ្មានការហាត់នឿយទេ។ យើងនឹងចេះតែមានអារម្មណ៍ស្វាងស្រឡះនៃវេលាព្រឹក ហើយក៏មិនចេះងុយងោកឡើយ។ ពន្លឺព្រះអាទិត្យនឹងត្រូវបានជំនួសដោយពន្លឺស្រទន់ដែលមិនធ្វើឱ្យស្រវាំងភ្នែក ប៉ុន្តែ ភ្លឺលើសជាងពន្លឺនាពេលកណ្តាលថ្ងៃត្រង់របស់យើងដ៏រកវាស់ស្ទង់មិនស្មើទៀតផង។ អ្នកដែលត្រូវបានប្រោសលោះ ដើរនៅក្នុងសិរីរុងរឿងនៃទិវាដ៏និរន្តរ៍។

«ខ្ញុំមិនឃើញមានវិហារណានៅក្នុងក្រុងនោះទេ ដ្បិតព្រះអម្ចាស់ជាព្រះដ៏មានព្រះចេស្តាបំផុត ព្រមទាំងកូនចៀមដែរ ទ្រង់ជាព្រះវិហារនៃទីក្រុងនោះ»។ វិវរណៈ ២១:២២។ រាស្ត្ររបស់ព្រះមានបុព្វសិទ្ធិនឹងសាសងដោយសេរីជាមួយព្រះវរបិតា និងព្រះរាជបុត្រា។ ឥឡូវនេះ យើងឃើញរូបភាពនៃព្រះដូចជានៅក្នុងកញ្ចក់ស្រអាប់ ប៉ុន្តែ នៅពេលនោះ យើងនឹងបានឃើញទ្រង់មុខទល់នឹងមុខវិញ ដោយគ្មានស្បៃស្រអាប់បាំងរវាងយើងទៀតឡើយ។

ជ័យជម្នះនៃសេចក្តីស្រឡាញ់របស់ព្រះ

នៅទីនោះសេចក្តីស្រឡាញ់ និងសេចក្តីអាណិតអាសូរដែលព្រះអង្គទ្រង់ផ្ទាល់បានបណ្តុះនៅក្នុងព្រលឹង នឹងត្រូវបានប្រើចំពោះគ្នាទៅវិញទៅមកដោយល្អកល្អឺន ហើយនិងផ្អែមល្ហែមបំផុត។ ការប្រកបគ្នាដោយឥតខ្ចោះជាមួយសត្វលោកបរិសុទ្ធ និងពួកស្មោះត្រង់នៅគ្រប់ទាំងយុគសម័យ ចំណងដ៏ពិសិដ្ឋដែលបានចងភ្ជាប់ជាមួយគ្នានូវ «គ្រប់ទាំងគ្រួនៅស្ថានសួគ៌ ហើយនៅផែនដី» (អេភេសូរ ៣:១៥) ទាំងនេះ បានជួយផ្សំផ្គុំដល់សេចក្តីសប្បាយរីករាយរបស់អ្នកដែលត្រូវបានប្រោសលោះ។

នៅទីនោះ គំនិតដែលមិនចេះស្លាប់ នឹងសញ្ជឹងគិតដោយក្តីអំណរីករាយជានិច្ច ចំពោះអំណាចព្រះចេស្តានៃការបង្កបង្កើតដ៏អស្ចារ្យ និងអាថកំបាំងទាំងឡាយនៃសេចក្តីស្រឡាញ់ដ៏ប្រកបដោយការប្រោសលោះ។ រាល់ទាំងបញ្ញាបារមីនឹងត្រូវបានលូតលាស់ឡើង រាល់ទាំងបញ្ញានុរូបនឹងត្រូវបាន

ចម្រើនឡើង។ ការបានមកនូវចំណេះដឹង នឹងមិនធ្វើឱ្យថាមពលទាំងប៉ុន្មាន អស់ឥទ្ធិពលឡើយ។ គ្រោងការដ៏ឆ្នើមបំផុតប្រហែលជានៅតែបន្តទៅមុខ សេចក្តីប្រាថ្នាដ៏ខ្ពស់ត្រដែតត្រូវបានឈោងដល់ មហិច្ឆតាដ៏ខ្ពង់ខ្ពស់ក៏ត្រូវបានមកជាពិត។ ហើយនៅតែមានកំពូលខ្ពស់ៗថ្មីៗដើម្បីឡើង របស់អស្ចារ្យថ្មីៗដើម្បីស្ងើចសរសើរ សេចក្តីពិតថ្មីៗដើម្បីនឹងយល់ដឹង និងរបស់ស្រស់ថ្មីដើម្បីឱ្យអំណាចនៃគំនិត ព្រលឹង និងរូបកាយប្រឡែងលេង។

សម្បត្តិទាំងអស់នៃពិភពសាកល នឹងបើកចំពោះពួកប្រោសលោះរបស់ព្រះ។ ដោយលែងជាប់ចំណងនឹងភាពដែលរមែងស្លាប់ទៀតហើយនោះ គេហោះហើរដោយឥតចេះហត់នឿយទៅពិភពឆ្ងាយៗ។ កូនមនុស្សនៃផែនដីនឹងពិសោធអំណាននិងប្រាជ្ញារបស់ពពួកទេវបុត្រដែលមិនបានភ្លាត់ដួល ហើយចែករំលែកសម្បត្តិនៃតម្រិះដែលបានមកពីយុគមួយដល់យុគមួយ។ គេសម្លឹងមើលសិរីល្អនៃការបង្កបង្កើតដោយទស្សន:ដែលមិនស្រអាប់ ដូងសុរិយា និងតារា ព្រមទាំងប្រព័ន្ធទាំងឡាយក្នុងលំដាប់ដែលបានចាត់មក ទាំងអស់វិលជុំវិញបល្ល័ង្កនៃព្រះ។

ឯពេលវេលានៃភាពអស់កល្បជានិច្ច នៅពេលដែលវាចេះតែកន្លងទៅមុខ នឹងនៅតែនាំមកនូវការបើកសម្តែងដ៏រុងរឿងថែមទៀត អំពីព្រះ និងព្រះគ្រីស្ទ។ មនុស្សរៀនដឹងអំពីព្រះច្រើនកាលណា គេនឹងសរសើរតម្កើងដល់ចរិតលក្ខណ:របស់ទ្រង់ច្រើនកាលនោះ។ ពេលដែលព្រះយេស៊ូវបើកចំពោះពួកគេនូវភាពបរិបូរនៃសេចក្តីប្រោសលោះ និងការសម្រេចលទ្ធផលដ៏អស្ចារ្យនៅក្នុងមហាវិវាទជាមួយសាតាំង នោះចិត្តពួកដែលត្រូវបានបង់ថ្លៃលោះបានរំភើបឡើងដោយភក្តីភាព ហើយសំឡេងទាំងម៉ឺនទាំងសែនរួមគ្នាបំពងឡើងនូវបទបន្ទរសរសើរតម្កើងដ៏ប្រកបដោយអំណាចព្រះចេស្តា។

«នោះខ្ញុំក៏ឮគ្រប់ទាំងអស់ដែលមានជីវិតនៅស្ថានសួគ៌ នៅផែនដី នៅក្រោមដី ហើយនៅក្នុងសមុទ្រ និងគ្រប់ទាំងអស់ដែលនៅស្ថានទាំងនោះ និយាយថា សូមថ្វាយព្រះពរ កិត្តិនាម សិរីល្អ និងព្រះចេស្តាដល់ព្រះអង្គ

ដែលគង់លើបល្ល័ង្ក ហើយដល់កូនចៀមនៅអស់កល្បជានិច្ចរៀងរាបតទៅ»។
វិវរណៈ ៥:១៣។

មហាវិវាទត្រូវបានចប់។ ពុំមានអំពើបាប និងបាបជនតទៅទៀត
ឡើយ។ ពិភពសាកលទាំងមូលបានស្អាតបាត។ ជីពចរនៃសាមគ្គីភាព និង
ក្តីអរសប្បាយមួយ បានលោតទៅតាមរយៈឧប្បត្តិកម្មដ៏ល្វឹងល្វើយ។ មានហូរ
ចេញមកអំពីទ្រង់ដ៏ជាអ្នកបង្កបង្កើតអ្វីៗទាំងអស់ នូវជីវិត និងពន្លឺ ហើយនិង
ក្តីអំណរ ទូទាំងវិស័យនៃលំហអាកាសដ៏គ្មានព្រំដែន។ ចាប់ពីអាតូមដ៏តូច
បំផុតទៅដល់ពិភពដ៏ធំបំផុត អស់ទាំងរបស់សព្វសារពើ មានចលនា និង
ឥតចលនា ដែលប្រកបដោយសោភណភាពឥតលាក់ស្រមោល និងដោយ
អំណរដ៏គ្រប់លក្ខណ៍ នាំគ្នាបញ្ចេញវាចាថាព្រះទ្រង់ជាសេចក្តីស្រឡាញ់៕

តើព្រះនៅឯណា នៅពេលដែលមនុស្សល្អទទួលរងទុក្ខ? ជំពូក២៩។
តើមនុស្សលោកនឹងត្រូវសាបសូន្យក្នុងសង្គ្រាមបរមាណូឬ? ជំពូក៥០។
បន្ទាប់ពីស្លាប់ទៅ តើនៅមានព្រលឹងឬទេ? ជំពូក៣៣ និង៣៤។
តើមានអារក្សឬទេ? ចុះបើមាន? ជំពូក២៩, ៣០ និង៣១។
តើប្រទេសអាមេរិកនឹងលែងទទួលស្គាល់សេរីភាពខាងសាសនាឬ? ជំពូក
២៥ និង៣៦។
តើអ្នកទទឹងព្រះគ្រីស្ទលេចមកនៅពេលនេះហើយឬនៅ? ជំពូក៣ និង៣៥។

សំណួរទាំងនេះ និងសំណួរដទៃទៀត ដុកដាន់មនុស្សជាច្រើន

មហាវិទាន

នឹងប្រឡូកជាមួយសំណួរទាំងនេះ ហើយឆ្លើយតមដោយសមសួនបំផុត និង
ដោយអំណាចទៀតផង។ អ្នកអានជាច្រើនបានទទួលផលប្រយោជន៍ពី
ការបើកសំដែងខាងក្រោយឆាកអំពីឥទ្ធិពល
ដែលសួនជីវិតប្រចាំថ្ងៃរបស់គេ។ តើតួនាទីរបស់លោកអ្នកជាអ្វី ក្នុង
មហាវិទាន រវាងសេចក្តីល្អ និងសេចក្តីអាក្រក់នេះ?

អែល្លីន ជី ង៉ែត *(១៨២៧-១៩១៥) ជាស្ត្រីទីមួយក្នុងប្រវត្តិសាស្ត្រពិភពលោក
ដែលបានសរសេរនិងនិពន្ធសៀវភៅច្រើនជាងគេបង្អស់។ សៀវភៅរបស់
គាត់ត្រូវបានបកប្រែរាប់រយភាសា។ មនុស្សរាប់លាននាក់បានជឿថា
គាត់ជាហោរា។ ក្នុងជីវិតគាត់ អ្នកស្រីបានទទួលទស្សននិមិត្តប្រមាណ
២០០០ដង មកពីព្រះ ស្តីអំពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។
សៀវភៅ មហាវិទាន នេះ ត្រូវនិពន្ធឡើង បន្ទាប់ពីព្រះ បានបង្ហាញគាត់នូវ
ទស្សននិមិត្តដូចជាភាពយន្ត អំពីសង្គ្រាមរវាងព្រះគ្រីស្ទនិងសាតាំង តាំងពី*

ដើមកំណើតពិភពលោករហូតដល់ទីបញ្ចប់។ អ្នកស្រីក៏បានទទួលការបង្គាប់
មកពីព្រះផងដែរ អំពីរឿងរ៉ាវដែលទាក់ទងនឹងសុខភាព កណ្តាលឲ្យ
អ្នកដែលអនុវត្តតាម បង្កើនអាយុបានឧឆ្នាំជាមធ្យម លើមនុស្សធម្មតា។